# ព្រះ
# ត្រៃបិដក

## ប្រែរួមនឹង
## ព្រះអដ្ឋកថា

## ភាគ៧៣

ពុទ្ធសករាជ ២៥៥៣
ច្បាប់ពិនិត្យ លើកទី១

# ព្រះ

# អភិធម្មបិដក

## និង

## បរមត្ថទីបនី  អដ្ឋកថា

### សេចក្តីប្រែជាភាសាខ្មែរ

## យមកៈ

## បឋមភាគ ~ ទុតិយភាគ

## ៧៣

## បាលីប្រែ  ៨៧ ~ ៨៨



*បោះពុម្ពលើកទី  ១  ពុទ្ធសករាជ  ២៥៥៣*

# ក្បាលទី ៧៣

# អភិធម្មបិដក ចាលីប្រែ -៨៧

## យមក បឋមភាគ

*សូមនមស្ការ ចំពោះព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ*

## មូលយមកៈ

## ឧទ្ទេសវារៈ

[ ១ ] *ពួកធម៌ណាមួយ ជាកុសល ពួកធម៌ទាំងអស់នោះ មានកុសលជាមូល មួយយ៉ាងទៀត ពួកធម៌ណា មានកុសលជាមូល ពួកធម៌ទាំងអស់នោះ ជាកុសល ។ ពួកធម៌ណាមួយ ជាកុសល ពួកធម៌ទាំងអស់នោះ មានមូលតែមួយ ដោយកុសលមូល មួយយ៉ាងទៀត ពួកធម៌ណា មានមូលតែមួយ ដោយកុសលមូល ពួកធម៌ទាំងអស់នោះ ជាកុសល ។ ពួកធម៌ណាមួយ មានមូលតែមួយ ដោយកុសលមូល ពួកធម៌ទាំងអស់នោះ មានគ្នានិងគ្នាជាមូល ដោយកុសលមូល មួយយ៉ាងទៀត ពួកធម៌ណា មានគ្នានិងគ្នាជាមូល ដោយកុសលមូល ពួកធម៌ទាំងអស់នោះ ជាកុសល ។ ពួកធម៌ណាមួយ ជាកុសល ពួកធម៌ទាំងអស់នោះ មានកុសលជាមូល មួយយ៉ាងទៀត ពួកធម៌ណា មានកុសលមូលជាមូល ពួកធម៌ទាំងអស់នោះ ជាកុសល ។ ពួកធម៌ណាមួយ ជាកុសល ពួកធម៌ទាំងអស់នោះ មានមូលតែមួយជាមូល ដោយកុសលមូល មួយយ៉ាងទៀត ពួកធម៌ណា មានមូលតែមួយជាមូល ដោយ*

កុសលមូល ពួកធម៌ទាំងអស់នោះ ជាកុសល ។ ពួកធម៌ណាមួយ មានមូលតែមួយជាមូល ដោយកុសលមូល ពួកធម៌ទាំងអស់នោះ មានមូលនៃគ្នានិងគ្នាជាមូល ដោយកុសលមូល មួយយ៉ាងទៀត ពួកធម៌ណា មានមូលនៃគ្នានិងគ្នាជាមូល ដោយកុសលមូល ពួកធម៌ទាំងអស់នោះ ជាកុសល ។ ពួកធម៌ណាមួយ ជាកុសល ពួកធម៌ទាំងអស់នោះ មានកុសលជាមូល មួយយ៉ាងទៀត ពួកធម៌ណា មានកុសលជាមូល ពួកធម៌ទាំងអស់នោះ ជាកុសល ។ ពួកធម៌ណាមួយ ជាកុសល ពួកធម៌ទាំងអស់នោះ មានមូលតែមួយ ដោយកុសលមូល មួយយ៉ាងទៀត ពួកធម៌ណា មានមូលតែមួយ ដោយកុសលមូល ពួកធម៌ទាំងអស់នោះ ជាកុសល ។ ពួកធម៌ណាមួយ មានមូលតែមួយ ដោយកុសលមូល ពួកធម៌ទាំងអស់នោះ មានគ្នានិងគ្នាជាមូល ដោយកុសលមូល មួយយ៉ាងទៀត ពួកធម៌ណា មានគ្នានិងគ្នាជាមូល ដោយកុសលមូល ពួកធម៌ទាំងអស់នោះ ជាកុសល ។ ពួកធម៌ណាមួយ ជាកុសល ពួកធម៌ទាំងអស់នោះ មានកុសលមូលជាមូល មួយយ៉ាងទៀត ពួកធម៌ណា មានកុសលមូលជាមូល ពួកធម៌ទាំងអស់នោះ ជាកុសល ។ ពួកធម៌ណាមួយ ជាកុសល ពួកធម៌ទាំងអស់នោះ មានមូលតែមួយជាមូល ដោយកុសលមូល មួយយ៉ាងទៀត ពួកធម៌ណា មានមូលតែមួយជាមូល ដោយកុសលមូល ពួកធម៌ទាំងអស់នោះ ជាកុសល ។ ពួកធម៌ណាមួយ មានមូលតែមួយជាមូល ដោយកុសលមូល ពួកធម៌ទាំងអស់នោះ មានមូលនៃគ្នានិងគ្នាជាមូល ដោយកុសលមូល មួយយ៉ាងទៀត ពួកធម៌ណា មានមូលនៃគ្នានិងគ្នាជាមូល ដោយ

កុសលមូល ពួកធម៌ទាំងអស់នោះ ជាកុសល ។

[ ២ ] ពួកធម៌ណាមួយ ជាអកុសល ពួកធម៌ទាំងអស់នោះ មានអកុសលជាមូល មួយយ៉ាងទៀត ពួកធម៌ណា មានអកុសលជាមូល ពួកធម៌ទាំងអស់នោះ ជាអកុសល ។ ពួកធម៌ណាមួយ ជាអកុសល ពួកធម៌ទាំងអស់នោះ មានមូលតែមួយ ដោយអកុសលមូល មួយយ៉ាងទៀត ពួកធម៌ណា មានមូលតែមួយ ដោយអកុសលមូល ពួកធម៌ទាំងអស់នោះ ជាអកុសល ។ ពួកធម៌ណាមួយ មានមូលតែមួយ ដោយអកុសលមូល ពួកធម៌ទាំងអស់នោះ មានគ្នានិងគ្នាជាមូល ដោយអកុសលមូល មួយយ៉ាងទៀត ពួកធម៌ណា មានគ្នានិងគ្នាជាមូល ដោយអកុសលមូល ពួកធម៌ទាំងអស់នោះ ជាអកុសល ។ ពួកធម៌ណាមួយ ជាអកុសល ពួកធម៌ទាំងអស់នោះ មានអកុសលមូលជាមូល មួយយ៉ាងទៀត ពួកធម៌ណា មានអកុសលមូលជាមូល ពួកធម៌ទាំងអស់នោះ ជាអកុសល ។ ពួកធម៌ណាមួយ ជាអកុសល ពួកធម៌ទាំងអស់នោះ មានមូលតែមួយជាមូល ដោយអកុសលមូល មួយយ៉ាងទៀត ពួកធម៌ណា មានមូលតែមួយជាមូល ដោយអកុសលមូល ពួកធម៌ទាំងអស់នោះ ជាអកុសល ។ ពួកធម៌ណាមួយ មានមូលតែមួយជាមូល ដោយអកុសលមូល ពួកធម៌ទាំងអស់នោះ មានមូលនៃគ្នានិងគ្នាជាមូល ដោយអកុសលមូល មួយយ៉ាងទៀត ពួកធម៌ណា មានមូលនៃគ្នានិងគ្នាជាមូល ដោយអកុសលមូល ពួកធម៌ទាំងអស់នោះ ជាអកុសល ។ ពួកធម៌ណាមួយ ជាអកុសល ពួកធម៌ទាំងអស់នោះ មានអកុ-

សលជាមូល មួយយ៉ាងទៀត ពួកធម៌ណា មានអកុសលជាមូល ពួកធម៌ទាំងអស់នោះ ជាអកុសល ។ ពួកធម៌ណាមួយ ជាអកុសល ពួកធម៌ទាំងអស់នោះ មានមូលតែមួយ ដោយអកុសលមូល មួយយ៉ាងទៀត ពួកធម៌ណា មានមូលតែមួយ ដោយអកុសលមូល ពួកធម៌ទាំងអស់នោះ ជាអកុសល ។ ពួកធម៌ណាមួយ មានមូលតែមួយ ដោយអកុសលមូល ពួកធម៌ទាំងអស់នោះ មានគ្នានិងគ្នាជាមូល ដោយអកុសលមូល មួយយ៉ាងទៀត ពួកធម៌ណា មានគ្នានិងគ្នាជាមូល ដោយអកុសលមូល ពួកធម៌ទាំងអស់នោះ ជាអកុសល ។ ពួកធម៌ណាមួយ ជាអកុសល ពួកធម៌ទាំងអស់នោះ មានអកុសលមូលជាមូល មួយយ៉ាងទៀត ពួកធម៌ណា មានអកុសលមូលជាមូល ពួកធម៌ទាំងអស់នោះ ជាអកុសល ។ ពួកធម៌ណាមួយ ជាអកុសល ពួកធម៌ទាំងអស់នោះ មានមូលតែមួយជាមូល ដោយអកុសលមូល មួយយ៉ាងទៀត ពួកធម៌ណា មានមូលតែមួយជាមូល ដោយអកុសលមូល ពួកធម៌ទាំងអស់នោះ ជាអកុសល ។ ពួកធម៌ណាមួយ មានមូលតែមួយជាមូល ដោយអកុសលមូល ពួកធម៌ទាំងអស់នោះ មានមូលនៃគ្នានិងគ្នាជាមូល ដោយអកុសលមូល មួយយ៉ាងទៀត ពួកធម៌ណា មានមូលនៃគ្នានិងគ្នាជាមូល ដោយអកុសលមូល ពួកធម៌ទាំងអស់នោះ ជាអកុសល ។

[ ៣ ] ពួកធម៌ណាមួយ ជាអព្យាក្រឹត ពួកធម៌ទាំងអស់នោះ ជាមូលនៃអព្យាក្រឹត មួយយ៉ាងទៀត ពួកធម៌ណា ជាមូលនៃអព្យាក្រឹត ពួកធម៌ទាំងអស់នោះ ជាអព្យាក្រឹត ។ ពួកធម៌ណាមួយ ជាអព្យាក្រឹត ពួកធម៌ទាំងអស់

នោះ មានមូលតែមួយ ដោយអព្យាកតមូល មួយយ៉ាងទៀត ពួកធម៌ណា មានមូលតែមួយ ដោយអព្យាកតមូល ពួកធម៌ទាំងអស់នោះ ជាអព្យាក្រឹត ។ ពួកធម៌ណាមួយ មានមូលតែមួយ ដោយអព្យាកតមូល ពួកធម៌ទាំងអស់នោះ មានគ្នានិងគ្នាជាមូល ដោយអព្យាកតមូល មួយយ៉ាងទៀត ពួកធម៌ណា មានគ្នានិងគ្នាជាមូល ដោយអព្យាកតមូល ពួកធម៌ទាំងអស់នោះ ជាអព្យា-ក្រឹត ។ ពួកធម៌ណាមួយ ជាអព្យាក្រឹត ពួកធម៌ទាំងអស់នោះ មានមូលនៃអព្យាក្រឹតជាមូល មួយយ៉ាងទៀត ពួកធម៌ណា មានមូលនៃអព្យាក្រឹតជាមូល ពួកធម៌ទាំងអស់នោះ ជាអព្យាក្រឹត ។ ពួកធម៌ណាមួយ ជាអព្យាក្រឹត ពួកធម៌ទាំងអស់នោះ មានមូលតែមួយជាមូល ដោយអព្យាកតមូល មួយយ៉ាងទៀត ពួកធម៌ណា មានមូលតែមួយជាមូល ដោយអព្យាកតមូល ពួកធម៌ទាំងអស់នោះ ជាអព្យាក្រឹត ។ ពួកធម៌ណាមួយ មានមូលតែមួយជាមូល ដោយអព្យាកតមូល ពួកធម៌ទាំងអស់នោះ មានមូលនៃគ្នានិងគ្នាជាមូល ដោយអព្យាកតមូល មួយយ៉ាងទៀត ពួកធម៌ណា មានមូលនៃគ្នានិងគ្នាជាមូល ដោយអព្យាកតមូល ពួកធម៌ទាំងអស់នោះ ជាអព្យាក្រឹត ។ ពួកធម៌ណាមួយ ជាអព្យាក្រឹត ពួកធម៌ទាំងអស់នោះ មានអព្យាក្រឹតជាមូល មួយយ៉ាងទៀត ពួកធម៌ណា មានអព្យាក្រឹតជាមូល ពួកធម៌ទាំងអស់នោះ ជាអព្យាក្រឹត ។ ពួកធម៌ណាមួយ ជាអព្យាក្រឹត ពួកធម៌ទាំងអស់នោះ មានមូលតែមួយ ដោយអព្យាកតមូល មួយយ៉ាងទៀត ពួកធម៌ណា មានមូលតែមួយ ដោយអព្យាកតមូល ពួកធម៌ទាំងអស់នោះ ជាអព្យាក្រឹត ។ ពួកធម៌ណា

មួយ មានមូលតែមួយ ដោយអព្យាកតមូល ពួកធម៌ទាំងអស់នោះ មានគ្នា និងគ្នាជាមូល ដោយអព្យាកតមូល មួយយ៉ាងទៀត ពួកធម៌ណា មានគ្នានិងគ្នាជាមូល ដោយអព្យាកតមូល ពួកធម៌ទាំងអស់នោះ ជាអព្យាក្រឹត ។ ពួកធម៌ណាមួយ ជាអព្យាក្រឹត ពួកធម៌ទាំងអស់នោះ មានអព្យាកតមូលជាមូល មួយយ៉ាងទៀត ពួកធម៌ណា មានអព្យាកតមូលជាមូល ពួកធម៌ទាំងអស់នោះ ជាអព្យាក្រឹត ។ ពួកធម៌ណាមួយ ជាអព្យាក្រឹត ពួកធម៌ទាំងអស់នោះ មានមូលតែមួយជាមូល ដោយអព្យាកតមូល មួយយ៉ាងទៀត ពួកធម៌ណា មានមូលតែមួយជាមូល ដោយអព្យាកតមូល ពួកធម៌ទាំងអស់នោះ ជាអព្យាក្រឹត ។ ពួកធម៌ណាមួយ មានមូលតែមួយជាមូល ដោយអព្យាកតមូល ពួកធម៌ទាំងអស់នោះ មានមូលនៃគ្នានិងគ្នាជាមូល ដោយអព្យាកតមូល មួយយ៉ាងទៀត ពួកធម៌ណា មានមូលនៃគ្នានិងគ្នាជាមូល ដោយអព្យាកតមូល ពួកធម៌ទាំងអស់នោះ ជាអព្យាក្រឹត ។

[ ៤ ] ពួកធម៌ណាមួយ ជានាម ពួកធម៌ទាំងអស់នោះ ជាមូលនៃនាម មួយយ៉ាងទៀត ពួកធម៌ណា ជាមូលនៃនាម ពួកធម៌ទាំងអស់នោះ ជានាម ។ ពួកធម៌ណាមួយ ជានាម ពួកធម៌ទាំងអស់នោះ មានមូលតែមួយ ដោយនាមមូល មួយយ៉ាងទៀត ពួកធម៌ណា មានមូលតែមួយ ដោយនាមមូល ពួកធម៌ទាំងអស់នោះ ជានាម ។ ពួកធម៌ណាមួយ មានមូលតែមួយ ដោយនាមមូល ពួកធម៌ទាំងអស់នោះ មានគ្នានិងគ្នាជាមូល ដោយនាមមូល មួយយ៉ាងទៀត ពួកធម៌ណា មានគ្នានិងគ្នាជាមូល ដោយនាមមូល ពួកធម៌ទាំងអស់នោះ ជានាម ។

*ពួកធម៌ណាមួយ ជានាម ពួកធម៌ទាំងអស់នោះ មាននាមមូលជាមូល មួយយ៉ាងទៀត ពួកធម៌ណា មាននាមមូលជាមូល ពួកធម៌ទាំងអស់នោះ ជានាម ។ ពួកធម៌ណាមួយ ជានាម ពួកធម៌ទាំងអស់នោះ មានមូលតែមួយជាមូល ដោយនាមមូល មួយយ៉ាងទៀត ពួកធម៌ណា មានមូលតែមួយ ជាមូល ដោយនាមមូល ពួកធម៌ទាំងអស់នោះ ជានាម ។ ពួកធម៌ណាមួយ មានមូលតែមួយ ជាមូល ដោយនាមមូល ពួកធម៌ទាំងអស់នោះ មានមូលនៃគ្នានិងគ្នាជាមូល ដោយនាមមូល មួយយ៉ាងទៀត ពួកធម៌ណា មានមូលនៃគ្នានិងគ្នាជាមូល ដោយនាមមូល ពួកធម៌ទាំងអស់នោះ ជានាម ។ ពួកធម៌ណាមួយ ជានាម ពួកធម៌ទាំងអស់នោះ មាននាមជាមូល មួយយ៉ាងទៀត ពួកធម៌ណា មាននាមជាមូល ពួកធម៌ទាំងអស់នោះ ជានាម ។ ពួកធម៌ណាមួយ ជានាម ពួកធម៌ទាំងអស់នោះ មានមូលតែមួយ ដោយនាមមូល មួយយ៉ាងទៀត ពួកធម៌ណា មានមូលតែមួយ ដោយនាមមូល ពួកធម៌ទាំងអស់នោះ ជានាម ។ ពួកធម៌ណាមួយ មានមូលតែមួយ ដោយនាមមូល ពួកធម៌ទាំងអស់នោះ មានគ្នានិងគ្នាជាមូល ដោយនាមមូល មួយយ៉ាងទៀត ពួកធម៌ណា មានគ្នានិងគ្នាជាមូល ដោយនាមមូល ពួកធម៌ទាំងអស់នោះ ជានាម ។ ពួកធម៌ណាមួយជានាម ពួកធម៌ទាំងអស់នោះ មាននាមមូលជាមូល មួយយ៉ាងទៀត ពួកធម៌ណា មាននាមមូលជាមូល ពួកធម៌ទាំងអស់នោះ ជានាម ។ ពួកធម៌ណាមួយ ជានាម ពួកធម៌ទាំងអស់នោះ មានមូលតែមួយជាមូល ដោយនាមមូល មួយយ៉ាងទៀត ពួកធម៌ណា មានមូលតែមួយជាមូល ដោយនាមមូល ពួក*

ធម៌ទាំងអស់នោះ ជានាម ។ ពួកធម៌ណាមួយ មានមូលតែមួយជាមូល ដោយនាមមូល ពួកធម៌ទាំងអស់នោះ មានមូលនៃគ្នានិងគ្នាជាមូល ដោយនាមមូល មួយយ៉ាងទៀត ពួកធម៌ណា មានមូលនៃគ្នានិងគ្នាជាមូល ដោយនាមមូល ពួកធម៌ទាំងអស់នោះ ជានាម ។

[ ៥ ] ពួកធម៌ណាមួយ ជាកុសល ពួកធម៌ទាំងអស់នោះ ជាហេតុនៃកុសល ។បេ។ ជានិទាននៃកុសល ។បេ។ ជាទីកើតនៃកុសល ។បេ។ ជាដែនកើតនៃកុសល ។បេ។ ជាសមុដ្ឋាននៃកុសល ។បេ។ ជាអាហារនៃកុសល ។បេ។ ជាអារម្មណ៍នៃកុសល ។បេ។ ជាបច្ច័យនៃកុសល ។បេ។ ជាសមុទ័យនៃកុសល ។បេ។

មូល ១ ហេតុ ១ និទាន ១ សម្ភវៈ ១ បភវៈ ១ សមុដ្ឋាន ១
អាហារ ១ អារម្មណ៍ ១ បច្ច័យ ១ សមុទ័យ ១ ។

ឧទ្ទេសវារៈ ចប់

# អដ្ឋកថា
# បរមត្ថទីបនី

## មូលយមកៈ
### អារម្ភបទ

ព្រះសម្មាសម្ពុទ្ធ ទ្រង់ជាទេវតាក្រៃលែងជាងទេវតា ទ្រង់ប្រហារកិលេស ដែលជាហេតុញ៉ាំងសត្វឲ្យទ្រហោយំ ក្នុងភពតូច និងភពធំ កាលទ្រង់សម្ដែងកថាវត្ថុប្បករណ៍ដោយសង្ខេប ដល់ពួកទេវតាទាំងឡាយ ក្នុងសុរាល័យទេវលោកហើយ ទ្រង់ជាអ្នកឈានកន្លងផុតវិស័យរបស់ស្ដេចយម ជាអ្នកមិនមានមន្ទិលកើតក្នុងព្រះអង្គ ដែលបែរមុខមកកាន់វដ្ដៈទៀត ទ្រង់សម្ដែងធម៌ជាគ្រឿងប្រហារកិលេស ទ្រង់សម្ដែងអភិធម្មប្បករណ៍ ឈ្មោះថា យមកៈ ដែលជាបករណ៍ទី ៦ ប្រដាប់ដោយយមកៈផ្សេងៗ ហើយ ឥឡូវនេះ លំដាប់នៃកិច្ចពណ៌នាបករណ៍នោះ ដល់ព្រមហើយ ព្រោះហេតុនោះ កិច្ចពណ៌នាមានដូចតទៅ ។

# អដ្ឋកថា ឧទ្ទេសវារៈ

[ ១-៥ ] បករណ៍នេះ ព្រះមានព្រះភាគ ទ្រង់ចែកហើយ ១០ យ៉ាង ដោយអំណាចយមកៈ ១០ គឺមូលយមកៈ ១ ខន្ធយមកៈ ១ អាយតនយមកៈ ១ ធាតុយមកៈ ១ សច្ចយមកៈ ១ សង្ខារយមកៈ ១ អនុសយយមកៈ ១ ចិត្តយមកៈ ១ ធម្មយមកៈ ១ ឥន្ទ្រិយយមកៈ ១ គប្បីជ្រាប អត្ថនៃយមកៈទាំង ១០ យ៉ាងនេះ របស់បករណ៍នេះយ៉ាងនេះ ។

សួរថា ឈ្មោះថា **យមក** ព្រោះអត្ថដូចម្តេច ឆ្លើយថា ព្រោះអត្ថថា ធម៌ជាគូគ្នា ។ ពិតហើយ ធម៌ជាគូគ្នា លោកហៅថា **យមក** ដូចលោកពោលថា **យមកបាដិហារ** គឺបាដិហារិយ៍ជាគូៗ **យមកសាល** គឺដើមរាំងទាំងគូជាដើម ។

ក្នុងយមកៈ ១០ យ៉ាងនេះ យមកៈនីមួយៗ ឈ្មោះថា ធម៌ជាគូ ព្រោះសម្តែងដោយអំណាចនៃយមកៈទាំងឡាយ គឺធម៌ជាគូដោយប្រការដូច្នេះ ។ បករណ៍ទាំងអស់នេះ គប្បីជ្រាបថា ឈ្មោះថា យមកៈ ព្រោះរួបរួមធម៌ជាគូទាំងឡាយនេះ ។

យមកៈទី ១ នៃយមកៈ ១០ យ៉ាង ហៅថា **មូលយមក** ព្រោះក្នុងមូលយមកៈនោះ ព្រះពុទ្ធអង្គទ្រង់ធ្វើការសួរ និងការឆ្លើយដោយអំណាចនៃមូលសម្តែង ។

មូលយមកៈនោះ មាន ២ វារៈ គឺឧទ្ទេសវារៈ ១ និទ្ទេសវារៈ ១ ។ ក្នុង ២ វារៈនោះ ឧទ្ទេសវារៈ ជាវារៈដំបូង ព្រោះទ្រង់លើកឡើងនាំចេញសម្តែងទៅតាមលំដាប់ ។

យមកៈនេះថា ពួកធម៌ណាមួយ ជាកុសល ពួកធម៌ទាំងអស់នោះ មានកុសលជាមូល មួយយ៉ាងទៀត ពួកធម៌ណា មានកុសលជាមូល ពួកធម៌ទាំងអស់នោះ ជាកុសល ដូច្នេះ ជាយមកៈដំបូងរបស់មូលយមកៈនោះ ។

គប្បីជ្រាបភាពជាយមកៈនៃឧទ្ទេសវារៈនោះ ដោយវិធី ៣ យ៉ាង គឺ **អត្ថយមក** លោកសម្តែងដោយអំណាចន័យអត្ថ ២ យ៉ាង គឺកុសល និងអកុសល ១ **ធម្មយមក** លោកសម្តែងដោយអំណាចនៃធម៌ដែលជាបែបផែនប្រព្រឹត្តទៅដោយអនុលោម និងបដិលោម ដោយអំណាចន័យទាំងនោះ ១ លោកសម្តែង **បុច្ឆាយមក** ដោយអំណាចពាក្យសួរដែលប្រព្រឹត្តទៅដោយអនុលោម និងបដិលោម ១ ។ យមកៈទាំងឡាយដ៏សេស ក៏មានន័យនេះដូចគ្នា ។ ឥឡូវនេះ គប្បីជ្រាបការកំណត់ព្រះបាលីដោយអំណាចនៃប្រភេទរបស់វារៈ មានន័យ យមកៈ បុច្ឆា និងអត្ថ របស់ឧទ្ទេសវារៈ ក្នុងមូលយមកៈនេះ ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយ ដោយយមកៈទាំងឡាយនេះយ៉ាងនេះ ។

ក្នុងកុសលត្តិកមាតិកា មានន័យ ៤ យ៉ាង គឺមូលន័យ ១ មូលមូលន័យ ១ មូលកន័យ ១ មូលមូលកន័យ ១ ព្រោះអាស្រ័យបទដែលជាខាងដើមនេះថា **កុសលា ធម្មា** ដូច្នេះ ។

ក្នុងន័យទាំង ៤ យ៉ាងនេះ ន័យនីមួយៗ មានយមកៈ ៣ យ៉ាង គឺ មូលយមកៈ ១ ឯកមូលយមកៈ ១ អញ្ញមញ្ញមូលយមកៈ ១ ទើបជាយមកៈ ១២ យ៉ាង ។ ក្នុងយមកៈនីមួយៗ មានបុច្ឆា ២ យ៉ាង ដោយ

*អំណាចអនុលោម និងបដិលោម ទើបជាបុច្ឆា ២៤ ដូច្នេះ ។*

*ក្នុងបុច្ឆានីមួយៗ មានអត្ថ ២ យ៉ាង ដោយអំណាចសន្និដ្ឋាន និងសំសយៈ ទើបជាអត្ថ ៤៨ ។ ក្នុងអត្ថទាំងនោះ គប្បីជ្រាបអត្ថនៃសន្និដ្ឋានក្នុងបទនេះថា* **យេកេចិ កុសលា ធម្មា** *ព្រោះការមិនមានសេចក្តីសង្ស័យក្នុងកុសលទាំងឡាយថា ជាកុសល ឬមិនមែនជាកុសល ។*

*គប្បីជ្រាបអត្ថនៃសំសយៈ ក្នុងបទនេះថា* **សព្វេ តេ កុសលមូលា** *ព្រោះការសួរដោយអំណាចសេចក្តីសង្ស័យយ៉ាងនេះថា ពួកធម៌ទាំងអស់នោះមានកុសលជាមូលឬ[១] ។ សេចក្តីនោះ ព្រះមានព្រះភាគត្រាស់ហើយ ដើម្បីសម្តែងសេចក្តីសង្ស័យ ក្នុងទីជាទីសង្ស័យរបស់វេនេយ្យសត្វទាំងឡាយ តែឈ្មោះថា សេចក្តីសង្ស័យមិនមានដល់ព្រះតថាគត ។ ក្នុងបុច្ឆាដទៃអំពីបទនេះ ក៏ន័យនេះដូចគ្នា ។*

*បណ្ឌិតគប្បីជ្រាបថា ក្នុងបទទាំងឡាយ ៤ ដែលលោកពោលហើយដោយន័យ ១៦ យមកៈ ៤៨ បុច្ឆា ៩៦ អត្ថ ១៩២ ដោយអំណាចនៃឧទ្ទេសក្នុងកុសលត្តិកមាតិកាថា ន័យទាំង ៤ នេះ រមែងមានព្រោះអាស្រ័យកុសលបទ យមកៈ ១២ រមែងមានដោយអំណាចនៃយមកៈនីមួយៗ ៣ ក្នុងន័យនីមួយៗ បុច្ឆា ២៤ រមែងមានដោយអំណាចបុច្ឆានីមួយៗ ២ ក្នុងយមកៈនីមួយៗ អត្ថ ៤៨ រមែងមានដោយអំណាចនៃអត្ថនីមួយៗ ២ ក្នុងបុច្ឆានីមួយៗ*

---

*១- បិដកខ្មែរ មិនមានពាក្យថា ឬ តែក្នុងទីនេះ យើងបន្ថែមពាក្យថា ឬ ព្រោះជាសំសយបទ ។*

ដូច្នេះ យ៉ាងណា ន័យទាំង ៤ នេះ រមែងមានព្រោះអាស្រ័យអកុសលបទខ្លះ ព្រោះអាស្រ័យអព្យាកតបទខ្លះ ព្រោះអាស្រ័យនូវបទ ទើបឈ្មោះថា នាំចេញសម្តែងហើយ ព្រោះធ្វើបទទាំង ៣ ឲ្យជាបទតែមួយខ្លះ ក៏យ៉ាងនោះដូចគ្នា ។

ខាងមុខអំពីនោះ វារៈ ៩ មានវារៈថា **យេកេចិ កុសលា ធម្មា សព្វេ តេ កុសលហេតុ** ដូច្នេះជាដើម ព្រះមានព្រះភាគ ទ្រង់លើកឡើងសម្តែងហើយដោយអំណាចវេវចនៈនៃមូលវារៈនោះ វារៈទាំងអស់ ១០ គឺមូលវារៈ ១ ហេតុវារៈ ១ និទានវារៈ ១ សម្ភវវារៈ ១ បភវវារៈ ១ សមុដ្ឋានវារៈ ១ អាហារវារៈ ១ អាលម្ពណវារៈ ១ បច្ចយវារៈ ១ សមុទយវារៈ ១ រមែងមានដោយប្រការដូច្នេះ ។

ន័យ ១៦០ យមកៈ ៤៨០ បុច្ឆា ៩៦០ អត្ថ ១៩២០ គប្បីជ្រាបថា លោកលើកឡើងសម្តែងហើយ ក្នុងវារៈទាំង ១០ ថា គប្បីជ្រាបវារៈទាំងឡាយ មានន័យជាដើម ក្នុងបទដ៏សេស ដោយការកំណត់បទដែលមកហើយក្នុងមូលវារៈនោះ ។ បណ្ឌិតគប្បីជ្រាបការកំណត់ព្រះបាលី ដោយអំណាចប្រភេទនៃវារៈ មានន័យ យមកៈ បុច្ឆា និងអត្ថក្នុងឧទ្ទេសវារៈយ៉ាងនេះ ។

ព្រះគាថាថា **មូលំ ហេតុ និទានំ ច** ដូច្នេះជាដើម ឈ្មោះថាឧទានគាថារបស់វារៈទាំងឡាយ ១០ ។ ពាក្យទាំងឡាយ មានពាក្យថា **មូល** ជាដើម ក្នុងគាថានោះ ជាវេវចនៈរបស់ហេតុនោះឯង ។

ហេតុ ឈ្មោះថា **មូល** ព្រោះអត្ថថា តាំងចំពោះ ។

ធម្មជាតណា រមែងទៅ គឺរមែងប្រព្រឹត្តទៅ ដើម្បីញុំាងផលរបស់ខ្លួនឲ្យសម្រេច ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **ហេតុ** ។

ធម្មជាតណា រមែងឲ្យនូវផលរបស់ខ្លួន ហាក់ដូចជាប្រាប់ថា សូមលោកកាន់យកផលនោះ ព្រោះហេតុនោះ ធម្មជាតនោះ ឈ្មោះថា **និទាន**។

ផល រមែងកើតព្រមអំពីធម៌ណា ព្រោះហេតុនោះ ធម៌នោះ ឈ្មោះថា **សម្ភវ** ។

ផល រមែងកើតទូទៅអំពីធម៌ណា ព្រោះហេតុនោះ ធម៌នោះ ឈ្មោះថា **បភវ** ។

ផល រមែងតាំងឡើងក្នុងធម៌នេះ ឬតាំងឡើងដោយធម៌នេះ ព្រោះហេតុនោះ ធម៌នេះ ឈ្មោះថា **សមុដ្ឋាន** ។

ធម៌ណា រមែងនាំមកនូវផលរបស់ខ្លួន ព្រោះហេតុនោះ ធម៌នោះ ឈ្មោះថា **អាហារ** ។

ធម៌ណា ដែលផលរបស់ខ្លួនទាញទុក ព្រោះអត្ថថា មិនគួរបដិសេធ ព្រោះហេតុនោះ ធម៌នោះ ឈ្មោះថា **អាលម្ពណា** ។

ផល អាស្រ័យធម៌នោះ គឺមិនបដិសេធ រមែងកើត គឺរមែងប្រព្រឹត្តទៅ ព្រោះហេតុនោះ ធម៌នោះ ឈ្មោះថា **បច្ចយ** ។

ផល រមែងកើតអំពីធម៌នេះ ព្រោះហេតុនោះ ធម៌នោះ ឈ្មោះថា **សមុទយ** ។

បណ្ឌិតគប្បីជ្រាបអត្ថរបស់ពាក្យនៃបទទាំងឡាយនោះយ៉ាងនេះ ដោយប្រការដូច្នេះ ។៚

# អភិធម្មបិដក

## និទ្ទេសវារៈ

[ ៦ ] ពួកធម៌ណាមួយ ជាកុសល ពួកធម៌ទាំងអស់នោះ ជាកុសលមូល ឬ ។ កុសលមូល មានត្រឹមតែ ៣ ឯពួកធម៌ជាកុសលដ៏សេស មិនមែនជាកុសលមូលឡើយ ។ មួយយ៉ាងទៀត ពួកធម៌ណា ជាកុសលមូល ពួកធម៌ទាំងអស់នោះ ជាកុសលឬ ។ អើ ។ ពួកធម៌ណាមួយ ជាកុសល ពួកធម៌ទាំងអស់នោះ មានមូលតែមួយ ដោយកុសលមូលឬ ។ អើ ។ មួយយ៉ាងទៀត ពួកធម៌ណា មានមូលតែមួយ ដោយកុសលមូល ពួកធម៌ទាំងអស់នោះ ជាកុសលឬ ។ រូប មានកុសលជាសមុដ្ឋាន មានមូលតែមួយ ដោយកុសលមូល តែមិនមែនជាកុសលឡើយ ឯកុសល មានមូលតែមួយ ដោយកុសលមូលផង ជាកុសលផង ។ ពួកធម៌ណាមួយ មានមូលតែមួយ ដោយកុសលមូល ពួកធម៌ទាំងអស់នោះ មានគ្នានិងគ្នាជាមូល ដោយកុសលមូលឬ ។ មូលទាំងឡាយណា ជាកុសលមូល កើតក្នុងទីជាមួយគ្នា មានមូលតែមួយផង មានគ្នានិងគ្នាជាមូលផង ឯពួកធម៌ដ៏សេស ដែលកើតជាមួយនឹងកុសលមូល ឈ្មោះថា មានមូលតែមួយ ដោយកុសលមូល តែមិនមែនឈ្មោះថា មានគ្នានិងគ្នាជាមូលឡើយ ។ មួយយ៉ាងទៀត ពួកធម៌ណា មានគ្នានិងគ្នាជាមូល ដោយកុសលមូល ពួកធម៌ទាំងអស់នោះ ជាកុសលឬ ។ អើ ។

[ ៧ ] ពួកធម៌ណាមួយ ជាកុសល ពួកធម៌ទាំងអស់នោះ មានកុសលមូលជាមូលឬ ។ ពួកកុសលមូលជាមូល មានត្រឹមតែ ៣ ពួកធម៌ជាកុសលដ៏សេស មិនមែនឈ្មោះថា មានកុសលមូលជាមូលឡើយ ។ មួយយ៉ាងទៀត ពួកធម៌

ណា មានកុសលមូលជាមូល ពួកធម៌ទាំងអស់នោះ ជាកុសលឬ ។ អើ ។ ពួកធម៌ណាមួយ ជាកុសល ពួកធម៌ទាំងអស់នោះ មានមូលតែមួយជាមូល ដោយកុសលមូលឬ ។ អើ ។ មួយយ៉ាងទៀត ពួកធម៌ណា មានមូលតែមួយ ជាមូល ដោយកុសលមូល ពួកធម៌ទាំងអស់នោះ ជាកុសលឬ ។ រូប មាន កុសលជាសមុដ្ឋាន មានមូលតែមួយជាមូល ដោយកុសលមូល តែមិនមែន ជាកុសល ឯកុសល មានមូលតែមួយជាមូល ដោយកុសលមូលផង ជាកុសល ផង ។ ពួកធម៌ណាមួយ មានមូលតែមួយជាមូល ដោយកុសលមូល ពួកធម៌ ទាំងអស់នោះ មានមូលនៃគ្នានិងគ្នាជាមូល ដោយកុសលមូលឬ ។ មូលទាំង ឡាយណា ជាកុសលមូល កើតក្នុងទីជាមួយគ្នា ( មូលទាំងឡាយនោះ ) ឈ្មោះ ថា មានមូលតែមួយជាមូលផង ឈ្មោះថា មានមូលនៃគ្នានិងគ្នាជាមូលផង ឯពួកធម៌ដ៏សេស ដែលកើតជាមួយនឹងកុសលមូល ឈ្មោះថា មានមូលតែ មួយជាមូល ដោយកុសលមូល តែមិនមែនឈ្មោះថា មានមូលនៃគ្នានិងគ្នាជា មូលឡើយ ។ មួយយ៉ាងទៀត ពួកធម៌ណា មានមូលនៃគ្នានិងគ្នាជាមូល ដោយកុសលមូល ពួកធម៌ទាំងអស់នោះ ជាកុសលឬ ។ អើ ។

[ ៨ ] ពួកធម៌ណាមួយ ជាកុសល ពួកធម៌ទាំងអស់នោះ មានកុសល ជាមូលឬ ។ អើ ។ មួយយ៉ាងទៀត ពួកធម៌ណា មានកុសលជាមូល ពួក ធម៌ទាំងអស់នោះ ជាកុសលឬ ។ រូប មានកុសលជាសមុដ្ឋាន មានកុសល ជាមូល តែមិនមែនជាកុសលឡើយ ឯកុសល មានកុសលជាមូលផង ជាកុសល ផង ។ ពួកធម៌ណាមួយ ជាកុសល ពួកធម៌ទាំងអស់នោះ មានមូលតែមួយ

ដោយកុសលមូលឬ ។ អើ ។ មួយយ៉ាងទៀត ពួកធម៌ណា មានមូលតែមួយ ដោយកុសលមូល ពួកធម៌ទាំងអស់នោះ ជាកុសលឬ ។ រូប មានកុសលជាសមុដ្ឋាន មានមូលតែមួយ ដោយកុសលមូល តែមិនមែនជាកុសលឡើយ ឯកុសល មានមូលតែមួយ ដោយកុសលមូលផង ជាកុសលផង ។ ពួកធម៌ណាមួយ មានមូលតែមួយ ដោយកុសលមូល ពួកធម៌ទាំងអស់នោះ មានគ្នានិងគ្នាជាមូល ដោយកុសលមូលឬ ។ មូលទាំងឡាយណា ជាកុសលមូល កើតក្នុងទីជាមួយគ្នា ( មូលទាំងឡាយនោះ ) មានមូលតែមួយផង មានគ្នានិងគ្នាជាមូលផង ឯពួកធម៌ដ៏សេស ដែលកើតជាមួយនឹងកុសលមូល គ្រាន់តែមានមូលតែមួយ ដោយកុសលមូល តែមិនមែនមានគ្នានិងគ្នាជាមូលឡើយ ។ មួយយ៉ាងទៀត ពួកធម៌ណា មានគ្នានិងគ្នាជាមូល ដោយកុសលមូល ពួកធម៌ទាំងអស់នោះ ជាកុសលឬ ។ អើ ។

[ ៩ ] ពួកធម៌ណាមួយ ជាកុសល ពួកធម៌ទាំងអស់នោះ មានកុសល-មូលជាមូលឬ ។ អើ ។ មួយយ៉ាងទៀត ពួកធម៌ណា មានកុសលមូលជាមូល ពួកធម៌ទាំងអស់នោះ ជាកុសលឬ ។ រូប មានកុសលជាសមុដ្ឋាន មានកុសលមូលជាមូល តែមិនមែនជាកុសលឡើយ ឯកុសល មានកុសលមូលជាមូលផង ជាកុសលផង ។ ពួកធម៌ណាមួយ ជាកុសល ពួកធម៌ទាំងអស់នោះ មានមូលតែមួយជាមូល ដោយកុសលមូលឬ ។ អើ ។ មួយយ៉ាងទៀត ពួកធម៌ណា មានមូលតែមួយជាមូល ដោយកុសលមូល ពួកធម៌ទាំងអស់នោះ ជាកុសលឬ ។ រូប មានកុសលជាសមុដ្ឋាន មានមូលតែមួយជាមូល ដោយ

កុសលមូល តែមិនមែនជាកុសលឡើយ ឯកុសល ឈ្មោះថា មានមូលតែមួយជាមូល ដោយកុសលមូលផង ជាកុសលផង ។ ពួកធម៌ណាមួយ មានមូលតែមួយជាមូល ដោយកុសលមូល ពួកធម៌ទាំងអស់នោះ មានមូលនៃគ្នានិងគ្នាជាមូល ដោយកុសលមូលឬ ។ មូលទាំងឡាយណា ជាកុសលមូលកើតក្នុងទីជាមួយគ្នា ( មូលទាំងឡាយនោះ ) មានមូលតែមួយជាមូលផង មានមូលនៃគ្នានិងគ្នាជាមូលផង ពួកធម៌ដ៏សេស ដែលកើតជាមួយនឹងកុសលមូលគ្រាន់តែមានមូលតែមួយជាមូល ដោយកុសលមូល តែមិនមែនមានមូលនៃគ្នានិងគ្នាជាមូលឡើយ ។ មួយយ៉ាងទៀត ពួកធម៌ណា មានមូលនៃគ្នានិងគ្នាជាមូល ដោយកុសលមូល ពួកធម៌ទាំងអស់នោះ ជាកុសលមូលឬ ។ អើ ។

[ ១០ ] ពួកធម៌ណាមួយ ជាអកុសល ពួកធម៌ទាំងអស់នោះ ជាអកុសលមូលឬ ។ ពួកអកុសលមូល មានត្រឹមតែ ៣ ឯពួកធម៌ជាអកុសលដ៏សេស មិនមែនឈ្មោះថា អកុសលមូលឡើយ ។ មួយយ៉ាងទៀត ពួកធម៌ណាជាអកុសលមូល ពួកធម៌ទាំងអស់នោះ ជាអកុសលឬ ។ អើ ។ ពួកធម៌ណាមួយ ជាអកុសល ពួកធម៌ទាំងអស់នោះ មានមូលតែមួយ ដោយអកុសលមូលឬ ។ អកុសលជាអហេតុកៈ មិនមែនមានមូលតែមួយ ដោយអកុសលមូលឡើយ ឯអកុសល ជាសហេតុកៈ ទើបមានមូលតែមួយ ដោយអកុសលមូល ។ មួយយ៉ាងទៀត ពួកធម៌ណា មានមូលតែមួយ ដោយអកុសលមូល ពួកធម៌ទាំងអស់នោះ ជាអកុសលឬ ។ រូប មានអកុសលជាសមុដ្ឋាន មានមូលតែមួយ ដោយអកុសលមូល តែមិនមែនជាអកុសល

ឡើយ ឯអកុសល មានមូលតែមួយ ដោយអកុសលមូលផង ជាអកុសលផង ។ ពួកធម៌ណាមួយ មានមូលតែមួយ ដោយអកុសលមូល ពួកធម៌ទាំងអស់នោះ មានគ្នានិងគ្នាជាមូល ដោយអកុសលមូលឬ ។ មូលទាំងឡាយណា ជាអកុសលមូល កើតក្នុងទីជាមួយគ្នា ( មូលទាំងឡាយនោះ ) មានមូលតែមួយផង មានគ្នានិងគ្នាជាមូលផង ឯពួកធម៌ដ៏សេស ដែលកើតជាមួយនឹងអកុសលមូល មានមូលតែមួយ ដោយអកុសលមូល តែមិនមែនមានគ្នានិងគ្នាជាមូលឡើយ ។ មួយយ៉ាងទៀត ពួកធម៌ណា មានគ្នានិងគ្នាជាមូល ដោយអកុសលមូល ពួកធម៌ទាំងអស់នោះ ជាអកុសលឬ ។ អើ ។

[ ១១ ] ពួកធម៌ណាមួយ ជាអកុសល ពួកធម៌ទាំងអស់នោះ មានអកុសលមូលជាមូលឬ ។ ពួកអកុសលមូលជាមូល មានត្រឹមតែ ៣ ឯពួកធម៌ជាអកុសលដ៏សេស មិនមែនឈ្មោះថា មានអកុសលមូលជាមូលឡើយ ។ មួយយ៉ាងទៀត ពួកធម៌ណា មានអកុសលមូលជាមូល ពួកធម៌ទាំងអស់នោះ ជាអកុសលឬ ។ អើ ។ ពួកធម៌ណាមួយ ជាអកុសល ពួកធម៌ទាំងអស់នោះ មានមូលតែមួយជាមូល ដោយអកុសលមូលឬ ។ អកុសល ជាអហេតុកៈ មិនមែនមានមូលតែមួយជាមូល ដោយអកុសលមូលឡើយ ឯអកុសល ជាសហេតុកៈ ទើបមានមូលតែមួយជាមូល ដោយអកុសលមូល ។ មួយយ៉ាងទៀត ពួកធម៌ណា មានមូលតែមួយជាមូល ដោយអកុសលមូល ពួកធម៌ទាំងអស់នោះ ជាអកុសលឬ ។ រូប មានអកុសលជាសមុដ្ឋាន មានមូលតែមួយជាមូល ដោយអកុសលមូល តែមិនមែនជាអកុសលឡើយ ឯអកុសល មាន

មូលតែមួយជាមូល ដោយអកុសលមូលផង ជាអកុសលផង ។ ពួកធម៌ណា មួយ មានមូលតែមួយជាមូល ដោយអកុសលមូល ពួកធម៌ទាំងអស់នោះ មាន មូលនៃគ្នានិងគ្នាជាមូល ដោយអកុសលមូលឬ ។ មូលទាំងឡាយណា ជា អកុសលមូល កើតក្នុងទីជាមួយគ្នា ( មូលទាំងឡាយនោះ ) មានមូលតែមួយ ជាមូលផង មានមូលនៃគ្នានិងគ្នាជាមូលផង ឯពួកធម៌ដ៏សេស ដែលកើតព្រម គ្នានឹងអកុសលមូល គ្រាន់តែមានមូលតែមួយជាមូល ដោយអកុសលមូល តែ មិនមែនមានមូលនៃគ្នានិងគ្នាជាមូលឡើយ ។ មួយយ៉ាងទៀត ពួកធម៌ណា មានមូលនៃគ្នានិងគ្នាជាមូល ដោយអកុសលមូល ពួកធម៌ទាំងអស់នោះ ជា អកុសលឬ ។ អើ ។

[ ១២ ] ពួកធម៌ណាមួយ ជាអកុសល ពួកធម៌ទាំងអស់នោះ មាន អកុសលជាមូលឬ ។ អកុសល ជាអហេតុកៈ មិនមែនមានអកុសលជាមូល ឡើយ ឯអកុសល ជាសហេតុកៈ ទើបមានអកុសលជាមូល ។ មួយយ៉ាងទៀត ពួកធម៌ណា មានអកុសលជាមូល ពួកធម៌ទាំងអស់នោះ ជាអកុសលឬ ។ រូប មានអកុសលជាសមុដ្ឋាន មានអកុសលជាមូល តែមិនមែនជាអកុសល ឡើយ ឯអកុសល ទើបមានអកុសលជាមូលផង ជាអកុសលផង ។ ពួកធម៌ ណាមួយ ជាអកុសល ពួកធម៌ទាំងអស់នោះ មានមូលតែមួយ ដោយអកុ-សលមូលឬ ។ អកុសល ជាអហេតុកៈ មិនមែនមានមូលតែមួយ ដោយ អកុសលមូលឡើយ ឯអកុសល ជាសហេតុកៈ ទើបមានមូលតែមួយ ដោយ អកុសលមូល ។ មួយយ៉ាងទៀត ពួកធម៌ណា មានមូលតែមួយ ដោយអកុ-

សលមូល ពួកធម៌ទាំងអស់នោះ ជាអកុសលឬ ។ រូប មានអកុសលជាសមុដ្ឋាន មានមូលតែមួយ ដោយអកុសលមូល តែមិនមែនជាអកុសលឡើយ ឯអកុសល មានមូលតែមួយ ដោយអកុសលមូលផង ជាអកុសលផង ។ ពួកធម៌ណាមួយ មានមូលតែមួយ ដោយអកុសលមូល ពួកធម៌ទាំងអស់នោះ មានគ្នានិងគ្នាជាមូល ដោយអកុសលមូលឬ ។ មូលទាំងឡាយណា ជាអកុសលមូល កើតក្នុងទីជាមួយគ្នា ( មូលទាំងឡាយនោះ ) មានមូលតែមួយផង ជាមូលនៃគ្នានិងគ្នាផង ឯពួកធម៌ដ៏សេស ដែលកើតព្រមគ្នានឹងអកុសលមូល គ្រាន់តែមានមូលតែមួយ ដោយអកុសលមូល តែមិនមែនមានគ្នានិងគ្នាជាមូលឡើយ ។ មួយយ៉ាងទៀត ពួកធម៌ណា មានគ្នានិងគ្នាជាមូល ដោយអកុសលមូល ពួកធម៌ទាំងអស់នោះ ជាអកុសលឬ ។ អើ ។

[ ១៣ ] ពួកធម៌ណាមួយ ជាអកុសល ពួកធម៌ទាំងអស់នោះ មានអកុសលមូលជាមូលឬ ។ អកុសល ជាអហេតុកៈ មិនមែនមានអកុសលមូលជាមូលឡើយ ឯអកុសល ជាសហេតុកៈ ទើបមានអកុសលមូលជាមូល ។ មួយយ៉ាងទៀត ពួកធម៌ណា មានអកុសលមូលជាមូល ពួកធម៌ទាំងអស់នោះ ជាអកុសលឬ ។ រូប មានអកុសលជាសមុដ្ឋាន មានអកុសលមូលជាមូល តែមិនមែនជាអកុសលឡើយ ឯអកុសល មានអកុសលមូលជាមូលផង ជាអកុសលផង ។ ពួកធម៌ណាមួយ ជាអកុសល ពួកធម៌ទាំងអស់នោះ មានមូលតែមួយជាមូល ដោយអកុសលមូលឬ ។ អកុសល ជាអហេតុកៈ មិនមែនមានមូលតែមួយជាមូល ដោយអកុសលមូលឡើយ ឯ

អកុសល ជាសហេតុកៈ ទើបមានមូលតែមួយជាមូល ដោយអកុសលមូល ។ មួយយ៉ាងទៀត ពួកធម៌ណា មានមូលតែមួយជាមូល ដោយអកុសលមូល ពួកធម៌ទាំងអស់នោះ ជាអកុសលឬ ។ រូប មានអកុសលជាសមុដ្ឋាន មានមូលតែមួយជាមូល ដោយអកុសលមូល តែមិនមែនជាអកុសលឡើយ ឯអកុសល មានមូលតែមួយជាមូល ដោយអកុសលមូលផង ជាអកុសលផង ។ ពួកធម៌ណាមួយ មានមូលតែមួយជាមូល ដោយអកុសលមូល ពួកធម៌ទាំងអស់នោះ មានគ្នានិងគ្នាជាមូល ដោយអកុសលមូលឬ ។ មូលទាំងឡាយណា ជាអកុសលមូល កើតក្នុងទីជាមួយគ្នា ( មូលទាំងឡាយនោះ ) មានមូលតែមួយជាមូលផង មានមូលនៃគ្នានិងគ្នាជាមូលផង ឯពួកធម៌ដ៏សេសដែលកើតព្រមគ្នានឹងអកុសលមូល គ្រាន់តែមានមូលតែមួយជាមូល ដោយអកុសលមូល តែមិនមែនមានមូលនៃគ្នានិងគ្នាជាមូលឡើយ ។ មួយយ៉ាងទៀត ពួកធម៌ណា មានមូលនៃគ្នានិងគ្នាជាមូល ដោយអកុសលមូល ពួកធម៌ទាំងអស់នោះ ជាអកុសលឬ ។ អើ ។

[ ១៤ ] ពួកធម៌ណាមួយ ជាអព្យាក្រឹត ពួកធម៌ទាំងអស់នោះ ជាមូលនៃអព្យាក្រឹតឬ ។ អព្យាកតមូលទាំងឡាយ មានត្រឹមតែ ៣ ឯពួកធម៌ជាអព្យាក្រឹតដ៏សេស មិនមែនឈ្មោះថាអព្យាកតមូលឡើយ ។ មួយយ៉ាងទៀត ពួកធម៌ណាមួយ ជាមូលនៃអព្យាក្រឹត ពួកធម៌ទាំងអស់នោះ ជាអព្យាក្រឹតឬ ។ អើ ។ ពួកធម៌ណាមួយ ជាអព្យាក្រឹត ពួកធម៌ទាំងអស់នោះ មានមូលតែមួយ ដោយអព្យាកតមូលឬ ។ អព្យាក្រឹត ជាអហេតុកៈ មិនមែនមានមូលតែមួយ

ដោយអព្យាកតមូលឡើយ ឯអព្យាក្រឹត ជាសហេតុកៈ ទើបមានមូលតែមួយ ដោយអព្យាកតមូល ។ មួយយ៉ាងទៀត ពួកធម៌ណា មានមូលតែមួយ ដោយអព្យាកតមូល ពួកធម៌ទាំងអស់នោះ ជាអព្យាក្រឹតឬ ។ អើ ។ ពួកធម៌ណាមួយ មានមូលតែមួយ ដោយអព្យាកតមូល ពួកធម៌ទាំងអស់នោះ មានគ្នានិងគ្នាជាមូល ដោយអព្យាកតមូលឬ ។ មូលទាំងឡាយណា ជាអព្យាកតមូល កើតក្នុងទីជាមួយគ្នា ( មូលទាំងឡាយនោះ ) មានមូលតែមួយផង មានគ្នានិងគ្នាជាមូលផង ឯពួកធម៌ដ៏សេស ដែលកើតព្រមគ្នានឹងអព្យាកតមូល គ្រាន់តែមានមូលតែមួយ ដោយអព្យាកតមូល តែមិនមែនមានគ្នានិងគ្នាជាមូលឡើយ ។ មួយយ៉ាងទៀត ពួកធម៌ណា មានគ្នានិងគ្នាជាមូល ដោយអព្យាកតមូល ពួកធម៌ទាំងអស់នោះ ជាអព្យាក្រឹតឬ ។ អើ ។

[ ១៥ ] ពួកធម៌ណាមួយ ជាអព្យាក្រឹត ពួកធម៌ទាំងអស់នោះ ជាមូលនៃអព្យាកតមូលឬ ។ មូលនៃអព្យាកតមូល មានត្រឹមតែ ៣ ឯពួកធម៌ជាអព្យាក្រឹតដ៏សេស មិនមែនជាមូលនៃអព្យាកតមូលឡើយ ។ មួយយ៉ាងទៀត ពួកធម៌ណា ជាមូលនៃអព្យាកតមូល ពួកធម៌ទាំងអស់នោះ ជាអព្យាក្រឹតឬ ។ អើ ។ ពួកធម៌ណាមួយ ជាអព្យាក្រឹត ពួកធម៌ទាំងអស់នោះ មានមូលតែមួយជាមូល ដោយអព្យាកតមូលឬ ។ អព្យាក្រឹត ជាអហេតុកៈ មិនមែនមានមូលតែមួយជាមូល ដោយអព្យាកតមូលឡើយ ឯអព្យាក្រឹត ជាសហេតុកៈ ទើបមានមូលតែមួយជាមូល ដោយអព្យាកតមូល ។ មួយយ៉ាងទៀត ពួកធម៌ណា មានមូលតែមួយជាមូល ដោយអព្យាកតមូល ពួកធម៌ទាំងអស់នោះ ជាអព្យាក្រឹត

ឬ ។ អើ ។ ពួកធម៌ណាមួយ មានមូលតែមួយជាមូល ដោយអព្យាកតមូល ពួកធម៌ទាំងអស់នោះ មានមូលនៃគ្នានិងគ្នាជាមូល ដោយអព្យាកតមូលឬ ។ មូលទាំងឡាយណា ជាអព្យាកតមូល កើតក្នុងទីជាមួយគ្នា ( មូលទាំងឡាយនោះ ) មានមូលតែមួយជាមូលផង មានមូលនៃគ្នានិងគ្នាជាមូលផង ឯពួកធម៌ដ៏សេស ដែលកើតព្រមគ្នានឹងអព្យាកតមូល គ្រាន់តែមានមូលតែមួយជាមូល ដោយអព្យាកតមូល តែមិនមែនមានមូលនៃគ្នានិងគ្នាជាមូលឡើយ ។ មួយយ៉ាងទៀត ពួកធម៌ណា មានមូលនៃគ្នានិងគ្នាជាមូល ដោយអព្យាកតមូល ពួកធម៌ទាំងអស់នោះ ជាអព្យាក្រឹតឬ ។ អើ ។

[ ១៦ ] ពួកធម៌ណាមួយ ជាអព្យាក្រឹត ពួកធម៌ទាំងអស់នោះ មានអព្យាក្រឹតជាមូលឬ ។ អព្យាក្រឹត ជាអហេតុកៈ មិនមែនមានអព្យាក្រឹតជាមូលឡើយ ឯអព្យាក្រឹត ជាសហេតុកៈ ទើបមានអព្យាក្រឹតជាមូល ។ មួយយ៉ាងទៀត ពួកធម៌ណា មានអព្យាក្រឹតជាមូល ពួកធម៌ទាំងអស់នោះ ជាអព្យាក្រឹតឬ ។ អើ ។ ពួកធម៌ណាមួយ ជាអព្យាក្រឹត ពួកធម៌ទាំងអស់នោះ មានមូលតែមួយ ដោយអព្យាកតមូលឬ ។ អព្យាក្រឹត ជាអហេតុកៈ មិនមែនមានមូលតែមួយ ដោយអព្យាកតមូលឡើយ ឯអព្យាក្រឹត ជាសហេតុកៈ ទើបមានមូលតែមួយ ដោយអព្យាកតមូល ។ មួយយ៉ាងទៀត ពួកធម៌ណា មានមូលតែមួយ ដោយអព្យាកតមូល ពួកធម៌ទាំងអស់នោះ ជាអព្យាក្រឹតឬ ។ អើ ។ ពួកធម៌ណាមួយ មានមូលតែមួយ ដោយអព្យាកតមូល ពួកធម៌ទាំងអស់នោះ មានគ្នានិងគ្នាជាមូល ដោយអព្យាកតមូលឬ ។ មូលទាំងឡាយណា ជាអព្យាកត-

មូល កើតក្នុងទីជាមួយគ្នា ( មូលទាំងឡាយនោះ ) មានមូលតែមួយផង មានគ្នានិងគ្នាជាមូលផង ឯពួកធម៌ដ៏សេស ដែលកើតព្រមគ្នានឹងអព្យាកតមូល គ្រាន់តែមានមូលតែមួយ ដោយអព្យាកតមូល តែមិនមែនមានគ្នានិងគ្នាជាមូលឡើយ ។ មួយយ៉ាងទៀត ពួកធម៌ណា មានគ្នានិងគ្នាជាមូល ដោយអព្យាកតមូល ពួកធម៌ទាំងអស់នោះ ជាអព្យាក្រឹតឬ ។ អើ ។

[ ១៧ ] ពួកធម៌ណាមួយ ជាអព្យាក្រឹត ពួកធម៌ទាំងអស់នោះ មានអព្យាកតមូលជាមូលឬ ។ អព្យាក្រឹត ជាអហេតុកៈ មិនមែនមានអព្យាកត-មូលជាមូលឡើយ ឯអព្យាក្រឹត ជាសហេតុកៈ ទើបមានអព្យាកតមូលជាមូល ។ មួយយ៉ាងទៀត ពួកធម៌ណា មានអព្យាកតមូលជាមូល ពួកធម៌ទាំងអស់នោះ ជាអព្យាក្រឹតឬ ។ អើ ។ ពួកធម៌ណាមួយ ជាអព្យាក្រឹត ពួកធម៌ទាំងអស់នោះ មានមូលតែមួយជាមូល ដោយអព្យាកតមូលឬ ។ អព្យាក្រឹត ជាអហេតុកៈ មិនមែនមានមូលតែមួយជាមូល ដោយអព្យាកតមូលឡើយ ឯអព្យាក្រឹត ជាសហេតុកៈ ទើបមានមូលតែមួយជាមូល ដោយអព្យាកតមូល ។ មួយយ៉ាងទៀត ពួកធម៌ណា មានមូលតែមួយជាមូល ដោយអព្យាកតមូល ពួកធម៌ទាំងអស់នោះ ជាអព្យាក្រឹតឬ ។ អើ ។ ពួកធម៌ណាមួយ មានមូលតែមួយជាមូល ដោយអព្យាកតមូល ពួកធម៌ទាំងអស់នោះ មានមូលនៃគ្នានិងគ្នាជាមូល ដោយអព្យាកតមូលឬ ។ មូលទាំងឡាយណា ជាអព្យាកតមូល កើតក្នុងទីជាមួយគ្នា ( មូលទាំងឡាយនោះ ) មានមូលតែមួយជាមូលផង មានមូលនៃគ្នានិងគ្នាជាមូលផង ឯពួកធម៌ដ៏សេស ដែលកើតព្រមគ្នានឹងអព្យាកតមូល គ្រាន់តែ

មានមូលតែមួយជាមូល ដោយអព្យាកតមូល តែមិនមែនមានមូលនៃគ្នានិងគ្នាជាមូលឡើយ ។ មួយយ៉ាងទៀត ពួកធម៌ណា មានមូលនៃគ្នានិងគ្នាជាមូល ដោយអព្យាកតមូល ពួកធម៌ទាំងអស់នោះ ជាអព្យាក្រឹតឬ ។ អើ ។

[ ១៨ ] ពួកធម៌ណាមួយ ជានាម ពួកធម៌ទាំងអស់នោះ ជាមូលនៃនាមឬ ។ មូលនៃនាមទាំងឡាយ មានត្រឹមតែ ៩ ប៉ុណ្ណោះ ឯពួកធម៌ជានាមដ៏សេសមិនមែនជាមូលនៃនាមឡើយ ។ មួយយ៉ាងទៀត ពួកធម៌ណា ជាមូលនៃនាម ពួកធម៌ទាំងអស់នោះ ជានាមឬ ។ អើ ។ ពួកធម៌ណាមួយ ជានាម ពួកធម៌ទាំងអស់នោះ មានមូលតែមួយ ដោយនាមមូលឬ ។ នាម ជាអហេតុកៈ មិនមែនមានមូលតែមួយ ដោយនាមមូលឡើយ ឯនាម ជាសហេតុកៈ ទើបមានមូលតែមួយ ដោយនាមមូល ។ មួយយ៉ាងទៀត ពួកធម៌ណា មានមូលតែមួយ ដោយនាមមូល ពួកធម៌ទាំងអស់នោះ ជានាមឬ ។ រូប មាននាមជាសមុដ្ឋាន មានមូលតែមួយ ដោយនាមមូល តែមិនមែនជានាមឡើយ ឯនាម មានមូលតែមួយ ដោយនាមមូលផង ជានាមផង ។ ពួកធម៌ណាមួយ មានមូលតែមួយ ដោយនាមមូល ពួកធម៌ទាំងអស់នោះ មានគ្នានិងគ្នាជាមូល ដោយនាមមូលឬ ។ មូលទាំងឡាយណា ជានាមមូល កើតក្នុងទីជាមួយគ្នា ( មូលទាំងឡាយនោះ ) មានមូលតែមួយផង មានគ្នានិងគ្នាជាមូលផង ឯពួកធម៌ដ៏សេស ដែលកើតព្រមគ្នានឹងនាមមូល គ្រាន់តែមានមូលតែមួយ ដោយនាមមូល តែមិនមែនមានគ្នានិងគ្នាជាមូលឡើយ ។ មួយយ៉ាងទៀត ពួកធម៌ណា មានគ្នានិងគ្នាជាមូល ដោយនាមមូល ពួកធម៌ទាំងអស់នោះ ជានាមឬ ។ អើ ។

[ ១៩ ] ពួកធម៌ណាមួយ ជានាម ពួកធម៌ទាំងអស់នោះ មានមូលនៃនាមជាមូលឬ ។ មូលនៃនាមជាមូលទាំងឡាយ មានត្រឹមតែ ៩ ប៉ុណ្ណោះ ឯពួកធម៌ជានាមដ៏សេស មិនមែនមានមូលនៃនាមជាមូលឡើយ ។ មួយយ៉ាងទៀត ពួកធម៌ណា មានមូលនៃនាមជាមូល ពួកធម៌ទាំងអស់នោះ ជានាមឬ ។ អើ ។ ពួកធម៌ណាមួយ ជានាម ពួកធម៌ទាំងអស់នោះ មានមូលតែមួយជាមូលដោយនាមមូលឬ ។ នាមជាអហេតុកៈ មិនមែនមានមូលតែមួយជាមូល ដោយនាមមូលឡើយ ឯនាម ជាសហេតុកៈ ទើបមានមូលតែមួយជាមូល ដោយនាមមូល ។ មួយយ៉ាងទៀត ពួកធម៌ណា មានមូលតែមួយជាមូល ដោយនាមមូល ពួកធម៌ទាំងអស់នោះ ជានាមឬ ។ រូប មាននាមជាសមុដ្ឋាន មានមូលតែមួយជាមូល ដោយនាមមូល តែមិនមែនជានាមឡើយ ឯនាម មានមូលតែមួយជាមូល ដោយនាមមូលផង ជានាមផង ។ ពួកធម៌ណាមួយ មានមូលតែមួយជាមូល ដោយនាមមូល ពួកធម៌ទាំងអស់នោះ មានមូលនៃគ្នានិងគ្នាជាមូល ដោយនាមមូលឬ ។ មូលទាំងឡាយណា ជានាមមូល កើតក្នុងទីជាមួយគ្នា ( មូលទាំងឡាយនោះ ) មានមូលតែមួយជាមូលផង មានមូលនៃគ្នានិងគ្នាជាមូលផង ឯពួកធម៌ដ៏សេស ដែលកើតព្រមគ្នានឹងនាមមូលគ្រាន់តែមានមូលតែមួយជាមូល ដោយនាមមូល តែមិនមែនមានមូលនៃគ្នានិងគ្នាជាមូលឡើយ ។ មួយយ៉ាងទៀត ពួកធម៌ណា មានមូលនៃគ្នានិងគ្នាជាមូល ដោយនាមមូល ពួកធម៌ទាំងអស់នោះ ជានាមឬ ។ អើ ។

[ ២០ ] ពួកធម៌ណាមួយ ជានាម ពួកធម៌ទាំងអស់នោះ មាននាមជា

មូលឬ ។ នាម ជាអហេតុកៈ មិនមែនមាននាមជាមូលឡើយ ឯនាម ជាសហេតុកៈ ទើបមាននាមជាមូល ។ មួយយ៉ាងទៀត ពួកធម៌ណា មាននាមជាមូល ពួកធម៌ទាំងអស់នោះ ជានាមឬ ។ រូប មាននាមជាសមុដ្ឋាន មាននាមជាមូល តែមិនមែនជានាមឡើយ ឯនាម មាននាមជាមូលផង ជានាមផង ។ ពួកធម៌ណាមួយ ជានាម ពួកធម៌ទាំងអស់នោះ មានមូលតែមួយ ដោយនាមមូលឬ ។ នាម ជាអហេតុកៈ មិនមែនមានមូលតែមួយ ដោយនាមមូលឡើយ ឯនាម ជាសហេតុកៈ ទើបមានមូលតែមួយ ដោយនាមមូល ។ មួយយ៉ាងទៀត ពួកធម៌ណា មានមូលតែមួយ ដោយនាមមូល ពួកធម៌ទាំងអស់នោះ ជានាមឬ ។ រូប មាននាមជាសមុដ្ឋាន មានមូលតែមួយ ដោយនាមមូល តែមិនមែនជានាមឡើយ ឯនាម មានមូលតែមួយ ដោយនាមមូលផង ជានាមផង ។ ពួកធម៌ណាមួយ មានមូលតែមួយ ដោយនាមមូល ពួកធម៌ទាំងអស់នោះ មានគ្នានិងគ្នាជាមូល ដោយនាមមូលឬ ។ មូលទាំងឡាយណា ជានាមមូល កើតក្នុងទីជាមួយគ្នា ( មូលទាំងឡាយនោះ ) មានមូលតែមួយផង មានគ្នានិងគ្នាជាមូលផង ឯពួកធម៌ដ៏សេស ដែលកើតព្រមគ្នានឹងនាមមូល គ្រាន់តែមានមូលតែមួយ ដោយនាមមូល តែមិនមែនមានគ្នានិងគ្នាជាមូលឡើយ ។ មួយយ៉ាងទៀត ពួកធម៌ណា មានគ្នានិងគ្នាជាមូល ដោយនាមមូល ពួកធម៌ទាំងអស់នោះ ជានាមឬ ។ អើ ។

[ ២១ ] ពួកធម៌ណាមួយ ជានាម ពួកធម៌ទាំងអស់នោះ មានមូលនៃនាមជាមូលឬ ។ នាម ជាអហេតុកៈ មិនមែនមាននាមមូលជាមូលឡើយ ឯ

នាម ជាសហេតុកៈ ទើបមាននាមមូលជាមូល ។ មួយយ៉ាងទៀត ពួកធម៌ណា មាននាមមូលជាមូល ពួកធម៌ទាំងអស់នោះ ជានាមឬ ។ រូប មាននាមជាសមុដ្ឋាន មាននាមមូលជាមូល តែមិនមែនជានាមឡើយ ឯនាម មាននាមមូលជាមូលផង ជានាមផង ។ ពួកធម៌ណាមួយ ជានាម ពួកធម៌ទាំងអស់នោះ មានមូលតែមួយជាមូល ដោយនាមមូលឬ ។ នាម ជាអហេតុកៈ មិនមែនមានមូលតែមួយជាមូល ដោយនាមមូលឡើយ ឯនាម ជាសហេតុកៈ ទើបមានមូលតែមួយជាមូល ដោយនាមមូល ។ មួយយ៉ាងទៀត ពួកធម៌ណា មានមូលតែមួយជាមូល ដោយនាមមូល ពួកធម៌ទាំងអស់នោះ ជានាមឬ ។ រូប មាននាមជាសមុដ្ឋាន មានមូលតែមួយជាមូល ដោយនាមមូល តែមិនមែនជានាមឡើយ ឯនាម មានមូលតែមួយជាមូល ដោយនាមមូលផង ជានាមផង ។ ពួកធម៌ណាមួយ មានមូលតែមួយជាមូល ដោយនាមមូល ពួកធម៌ទាំងអស់នោះ មានមូលនៃគ្នានិងគ្នាជាមូល ដោយនាមមូលឬ ។ មូលទាំងឡាយណា ជានាមមូល កើតក្នុងទីជាមួយគ្នា ( មូលទាំងឡាយនោះ ) មានមូលតែមួយជាមូលផង មានមូលនៃគ្នានិងគ្នាជាមូលផង ឯពួកធម៌ដ៏សេស ដែលកើតព្រមគ្នានឹងនាមមូល គ្រាន់តែមានមូលតែមួយជាមូល ដោយនាមមូល តែមិនមែនមានមូលនៃគ្នានិងគ្នាជាមូលឡើយ ។ មួយយ៉ាងទៀត ពួកធម៌ណា មានមូលនៃគ្នានិងគ្នាជាមូល ដោយនាមមូល ពួកធម៌ទាំងអស់នោះ ជានាមឬ ។ អើ ។

[ ២២ ] ពួកធម៌ណាមួយ ជាកុសល ពួកធម៌ទាំងអស់នោះ ជាហេតុនៃកុសល ... ជានិទាននៃកុសល ជាទីកើតនៃកុសល ជាដែនកើតនៃកុសល ជាសមុដ្ឋាននៃកុសល ជាអាហារនៃកុសល ជាអារម្មណ៍នៃកុសល ជាបច្ច័យនៃកុសល ជាសមុទ័យនៃកុសល ... ។ ពួកធម៌ណាមួយ ជាអកុសល ... ពួកធម៌ណាមួយ ជាអព្យាក្រឹត ... ពួកធម៌ណាមួយ ជានាម ពួកធម៌ទាំងអស់នោះ ជាហេតុនៃនាម ... ជានិទាននៃនាម ជាទីកើតនៃនាម ជាដែនកើតនៃនាម ជាសមុដ្ឋាននៃនាម ជាអាហារនៃនាម ជាអារម្មណ៍នៃនាម ជាបច្ច័យនៃនាម ជាសមុទ័យនៃនាម ... ។

មូល ១ ហេតុ ១ និទាន ១ សម្ភព ១ ប្រភព ១ សមុដ្ឋាន ១
អាហារ ១ អារម្មណ៍ ១ បច្ច័យ ១ សមុទ័យ ១ ។

## មូលយមកៈ ចប់

# អដ្ឋកថា

## និទ្ទេសវារៈ

[ ៦ ] ឥឡូវនេះ ព្រះមានព្រះភាគទ្រង់ផ្ដើមនិទ្ទេសវារៈ ដោយន័យជាដើមថា **យេកេចិ កុសលា ធម្មា** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **យេកេចិ** ជាបទសម្ដែងដល់កុសលទាំងអស់ដោយមិនមានចំណែកសេសសល់ ។

បទថា **កុសលា ធម្មា** បានដល់ សភាវធម៌ដែលជាកុសល មិនមានទោស មានផលជាសេចក្ដីសុខ ដែលជាលក្ខណៈ ដែលព្រះមានព្រះភាគត្រាស់ហើយក្នុងបទភាជនៈនៃកុសលត្តិកៈ ។

បទថា **សព្វេ តេ កុសលមូលា** បានដល់ រមែងសួរថា ធម៌ទាំងពួងនោះឯង ជាកុសលមូល ពិត ឬមិនពិត ។

បទថា **តីណេវ កុសលមូលានិ** បានដល់ ធម៌ទាំងអស់នោះ មិនឈ្មោះថា កុសលមូល អធិប្បាយថា មូល ៣ មានអលោភៈជាដើមប៉ុណ្ណោះ ឈ្មោះថា កុសលមូល ។

បទថា **អវសេសា កុសលា ធម្មា ន កុសលមូលា** បានដល់ កុសលធម៌ទាំងឡាយដ៏សេស មានផស្សៈជាដើម មិនឈ្មោះថាកុសលមូលម្យ៉ាងទៀត អធិប្បាយថា កុសលទាំងឡាយដ៏សេស មានផស្សៈជាដើមឈ្មោះថា កុសលធម៌ប៉ុណ្ណោះ មិនឈ្មោះថា កុសលមូល ។

បទថា **យេ វា បន កុសលមូលា** បានដល់ មូល ៣ មានអលោភៈជាដើម លោកកាន់យកហើយថា ធម៌ពួកណាជាកុសលមូល ដោយបទទី ២

នៃបុច្ឆាដំបូង ។

បទថា **សព្វេ តេ ធម្មា កុសលា** បានដល់ រមែងសួរថា ធម៌ទាំង ៣ នោះ ជាកុសលឬ ។ បទថា **អាមន្តា** បានដល់ ព្រះមានព្រះភាគ កាលទ្រង់ទទួលភាពនៃកុសលមូលទាំងឡាយ ជាកុសល ទើបត្រាស់ ។ នេះជាអត្ថរបស់មូលយមកៈ ក្នុងមូលន័យ ។ គប្បីជ្រាបន័យរបស់ការវិសជ្ជនាក្នុងបុច្ឆាទាំងពួងដោយឧបាយនេះ ។

ការប្លែកគ្នាឯណា មានក្នុងទីណា ខ្ញុំ ( ពុទ្ធឃោសាចារ្យ ) នឹងពណ៌នាការប្លែកគ្នានោះ ក្នុងទីនោះតទៅ កុសលទាំងឡាយ បណ្ឌិតមិនគួរកាន់យកកុសលដែលមានមូល ១ ដោយអត្ថនៃការរាប់ តែគួរកាន់យកដោយអត្ថដែលស្មើគ្នា អធិប្បាយថា ក្នុងឯកមូលយមកៈនេះ កុសលទាំងអស់នោះ មានមូលស្មើគ្នាជាមួយកុសលមូល មូលណាជាមូលរបស់ផស្សៈ មូលនោះ ក៏ជាមូលរបស់ធម៌ទាំងឡាយ មានវេទនាជាដើមនោះឯង ។ កាលបើភាពយ៉ាងនោះមាន ព្រះមានព្រះភាគ កាលទ្រង់ទទួលភាពដែលកុសលទាំងនោះជាយ៉ាងនោះ ទើបត្រាស់ពាក្យថា **អាមន្តា** ។

បទថា **កុសលសមុដ្ឋានំ** លោកសម្តែងរូប ដែលមានកុសលចិត្តជាសមុដ្ឋាន ។ បទថា **ឯកមូលំ** បានដល់ មានមូលស្មើគ្នាជាមួយកុសលមូល មានអលោភៈជាដើម មូលទាំងឡាយ មានអលោភៈជាដើម ឈ្មោះថា មូល ព្រោះជាហេតុ ជាបច្ច័យដល់ធម៌ទាំងឡាយ មានផស្សៈជាដើម យ៉ាងណា មូលនោះ ក៏ជាមូលដល់សមុដ្ឋានរូប ក៏យ៉ាងនោះ តែសមុដ្ឋានរូបនោះ មិន

*មែនកុសល ព្រោះការមិនមានលក្ខណៈនៃកុសល ។*

*ព្រះមានព្រះភាគមិនត្រាស់សួរក្នុងយមកៈដទៃៗ ថា* **យេកេចិ កុសលា** *តែត្រាស់សួរថា* **យេកេចិ កុសលមូលេន ឯកមូលា** ។

*សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះសេចក្តីនោះឯង មានព្រមដោយព្យញ្ជនៈនោះ ។ បទថា* **កុសលមូលានិ** *នេះជាវិសេសនៈនៃពាក្យមុន ពិតហើយ ទ្រង់ត្រាស់ថា មូលទាំងឡាយណា រមែងកើតឡើងដោយភាពតែមួយ មូលទាំងឡាយនោះ ជាកុសលមូលខ្លះ ជាអកុសលមូលខ្លះ ជាអព្យាកតមូលខ្លះ ពាក្យនេះ លោកពោលដើម្បីសម្តែងភាពវិសេសនៃបទថា* **កុសល-មូលានិ** ។

*បទថា* **អញ្ញមញ្ញមូលានិ ច** *អធិប្បាយថា មូលទាំងឡាយ រមែងជាហេតុជាបច្ច័យដល់គ្នានិងគ្នា ដោយជាហេតុជាបច្ច័យ ។ ក្នុងបដិលោមបុច្ឆាទ្រង់មិនត្រាស់ថា* **សព្វេ តេ ធម្មា កុសលមូលេន ឯកមូលា** *តែត្រាស់ថា* **សព្វេ តេ ធម្មា កុសលា** *ដូច្នេះ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះមិនមានអត្ថប្លែកគ្នា ។ កាលធ្វើបុច្ឆាថា* **កុសលមូលេន ឯកមូលា** *ដូច្នេះ គប្បីធ្វើការវិសជ្ជនាតាមន័យដែលពោលហើយខាងដើមថា* **មូលានិ យានិ ឯកតោ ឧប្បជ្ជន្តិ** *កាលសេចក្តីប្លែកគ្នានៃអត្ថមិនមាន ព្រោះហេតុនោះ ទើបទ្រង់មិនធ្វើការសួរយ៉ាងនោះ តែទ្រង់ធ្វើការសួរយ៉ាងនេះ ។ ក្នុងមូលន័យជាដើម ក្នុងអញ្ញមញ្ញមូលយមកៈ ក៏គប្បីជ្រាបពាក្យសួរដែលប្លែកគ្នាដោយឧបាយនេះ ។*

*[ ៧ ] ក្នុងមូលមូលន័យ បទថា* **សព្វេ តេ កុសលមូលមូលា** *បាន*

ដល់ រមែងសួរថា ធម៌ទាំងឡាយនោះ ឈ្មោះថា មូល ពោល គឺកុសល-មូលឬ ។ បទថា **ឯកមូលមូលា** ដូច្នេះ អធិប្បាយថា មូលដែលជាមូលតែមួយជាមួយនឹងកុសលមាន ព្រោះហេតុនោះ ទើបមូលនោះ ឈ្មោះថាជាមូលដែលមានមូលតែមួយ ព្រោះអត្ថថា ស្មើគ្នា ។

បទថា **អញ្ញមញ្ញមូលមូលា** បានដល់ មូលដល់គ្នានិងគ្នា ឈ្មោះថាអញ្ញមញ្ញមូល គឺអញ្ញមញ្ញមូល ឈ្មោះថា មូលរបស់ធម៌ទាំងនោះ ព្រោះអត្ថថា ជាហេតុ ជាបច្ច័យ ព្រោះហេតុនោះ ទើបមូលនោះ ឈ្មោះថា **អញ្ញមញ្ញមូលមូល** ។

[ ៨ ] ក្នុងមូលកន័យ បទថា **កុសលមូលកា** ដូច្នេះ អធិប្បាយថា មូលដែលជាកុសលរបស់ធម៌ទាំងនោះមាន ព្រោះអត្ថថា ជាហេតុ ជាបច្ច័យ ព្រោះហេតុនោះ ទើបធម៌ទាំងនោះ ឈ្មោះថា មានមូលដែលជាកុសល ។

[ ៩ ] ក្នុងមូលមូលកន័យ បទថា **កុសលមូលមូលកា** ដូច្នេះ អធិប្បាយថា មូលរបស់កុសលទាំងនោះ ជាកុសលមូល គឺមូលដែលជាកុសលមូលរបស់កុសលទាំងនោះមាន ព្រោះអត្ថថា ជាហេតុ ជាបច្ច័យ ព្រោះហេតុនោះ ទើបកុសលទាំងនោះ ឈ្មោះថា មានមូលដែលជាកុសលមូល ។ នេះជាអត្ថវិសេសក្នុងនយយមកបុច្ឆាជាដើម ព្រោះអាស្រ័យកុសលបទត្រឹមប៉ុណ្ណោះ ។ សូម្បីក្នុងបទទាំងឡាយ មានអកុសលបទជាដើម ក៏ន័យនេះចំណែកសេចក្តីពិសេស មានដូចតទៅនេះ

[ ១០ ] បទថា **អហេតុកំ អកុសលំ** ត្រាស់សំដៅយកមោហៈដែល

សម្បយុត្តដោយវិចិកិច្ឆា និងឧទ្ធច្ចៈ ។ បទថា **អហេតុកំ អព្យាកតំ** បាន ដល់ ធម៌ដ៏សេស វៀរសហេតុកៈ និងអព្យាកតសមុដ្ឋានរូប រមែងបានក្នុងទីនេះថា ចិត្តុប្បាទ ១៨ រូប និងនិព្វាន ឈ្មោះថា មិនមានមូលដូចគ្នានឹងអព្យាកតមូល ។ សហេតុកៈ និងអព្យាកតសមុដ្ឋានរូប មានមូលតែមួយដូចគ្នានឹងអព្យាកតមូល ។ លោកធ្វើអព្យាកតនោះ ឲ្យជាអព្វោហារិកៈ គឺវត្ថុដែលពោលអាងមិនបានហើយ ទើបធ្វើការវិសជ្ជនា ដោយអំណាចរបស់អព្យាកតមូល ដែលបានដោយភាពតែមួយ ។

[ ១៨ ] ធម៌ទាំងឡាយ ពោល គឺនាម ឈ្មោះថា **នាមា ធម្មា** នាមទាំងនោះ ពោលដោយអត្ថ បានដល់ អរូបក្ខន្ធ ៤ និងនិព្វាន ។ បទថា **នវ នាមមូលានិ** បានដល់ មូល ៩ យ៉ាង ដោយអំណាចរបស់កុសល អកុសល និងអព្យាកតមូល នាមដែលជាអហេតុកៈ មិនមានមូលជាមួយគ្នានឹងនាមមូល ព្រោះហេតុនោះ ទើបនាមនោះ ឈ្មោះថា មិនមានហេតុ ។ នាមទាំងអស់ គឺចិត្តុប្បាទ ១៨ មោហៈដែលសម្បយុត្តដោយវិចិកិច្ឆា និងឧទ្ធច្ចៈ និងនិព្វាន មិនមានមូលតែមួយជាមួយនឹងនាមមូល ឯអហេតុកនាមនោះ រមែងមិនកើតព្រមជាមួយនាមមូល អធិប្បាយថា សហេតុកនាម រមែងកើតឡើងព្រមនឹងនាមមូល សូម្បីក្នុងបទទាំងឡាយថា **សហេតុកំ នាមំ នាមមូលេន** អធិប្បាយថា នាមដែលជាសហេតុកៈ មានមូលតែមួយជាមួយ

*នាមមូល ។ ពាក្យដ៏សេស ក្នុងទីទាំងពួង មានអត្ថងាយយល់ហើយ ដោយប្រការដូច្នេះ ។*

## អធិប្បាយ មូលវារៈ ចប់

*ក្នុងវារៈទាំងឡាយ មានហេតុវារៈជាដើម គប្បីជ្រាបអត្ថដោយឧបាយនេះ ។ គាថាថា* **មូលំ ហេតុ និទានំ ច** *ដូច្នេះជាដើម ព្រះមានព្រះភាគត្រាស់ហើយ ដោយអំណាចឧទាននៃវារៈទាំង ១០ តាមដែលខ្ញុំពោលចង្អុលបង្ហាញមកហើយ ដូច្នេះឯង ។ល។*

## អធិប្បាយហេតុវារៈ ចប់
## អដ្ឋកថាមូលយមកៈ ចប់

# អភិធម្មបិដក

## ខន្ធយមកៈ

[ ២៣ ] ពួកខន្ធ ៥ គឺរូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ វិញ្ញាណក្ខន្ធ ។

## ឧទ្ទេសវារៈ

[ ២៤ ] រូប ហៅថា រូបក្ខន្ធ រូបក្ខន្ធ ហៅថា រូប ។ វេទនា ហៅថា វេទនាខន្ធ វេទនាខន្ធ ហៅថា វេទនា ។ សញ្ញា ហៅថា សញ្ញាខន្ធ សញ្ញាខន្ធ ហៅថា សញ្ញា ។ ពួកសង្ខារ ហៅថា សង្ខារក្ខន្ធ សង្ខារក្ខន្ធ ហៅថា ពួកសង្ខារ ។ វិញ្ញាណ ហៅថា វិញ្ញាណក្ខន្ធ វិញ្ញាណក្ខន្ធ ហៅថា វិញ្ញាណ ។

[ ២៥ ] មិនមែនរូប មិនហៅថា រូបក្ខន្ធ មិនមែនរូបក្ខន្ធ មិនហៅថា រូប ។ មិនមែនវេទនា មិនហៅថា វេទនាខន្ធ មិនមែនវេទនាខន្ធ មិនហៅថា វេទនា ។ មិនមែនសញ្ញា មិនហៅថា សញ្ញាខន្ធ មិនមែនសញ្ញាខន្ធ មិនហៅថា សញ្ញា ។ មិនមែនពួកសង្ខារ មិនហៅថា សង្ខារក្ខន្ធ មិនមែនសង្ខារក្ខន្ធ មិនហៅថា សង្ខារ ។ មិនមែនវិញ្ញាណ មិនហៅថា វិញ្ញាណក្ខន្ធ មិនមែនវិញ្ញាណក្ខន្ធ មិនហៅថា វិញ្ញាណ ។

[ ២៦ ] រូប ហៅថា រូបក្ខន្ធ ខន្ធទាំងឡាយ ហៅថា វេទនាខន្ធ ។ រូប ហៅថា រូបក្ខន្ធ ខន្ធទាំងឡាយ ហៅថា សញ្ញាខន្ធ ។ រូប ហៅថា រូបក្ខន្ធ ខន្ធទាំងឡាយ ហៅថា សង្ខារក្ខន្ធ ។ រូប ហៅថា រូបក្ខន្ធ ខន្ធទាំងឡាយ ហៅថា វិញ្ញាណក្ខន្ធ ។ វេទនា ហៅថា វេទនាខន្ធ ខន្ធទាំងឡាយ ហៅថា

រូបក្ខន្ធ ។ វេទនា ហៅថា វេទនាខន្ធ ខន្ធទាំងឡាយ ហៅថា សញ្ញាខន្ធ ។ វេទនា ហៅថា វេទនាខន្ធ ខន្ធទាំងឡាយ ហៅថា សង្ខារក្ខន្ធ ។ វេទនា ហៅថា វេទនាខន្ធ ខន្ធទាំងឡាយ ហៅថា វិញ្ញាណក្ខន្ធ ។ សញ្ញា ហៅថា សញ្ញាខន្ធ ខន្ធទាំងឡាយ ហៅថា រូបក្ខន្ធ ។ សញ្ញា ហៅថា សញ្ញាខន្ធ ខន្ធទាំងឡាយ ហៅថា វេទនាខន្ធ ។ សញ្ញា ហៅថា សញ្ញាខន្ធ ខន្ធទាំងឡាយ ហៅថា សង្ខារក្ខន្ធ ។ សញ្ញា ហៅថា សញ្ញាខន្ធ ខន្ធទាំងឡាយ ហៅថា វិញ្ញាណក្ខន្ធ ។ ពួកសង្ខារ ហៅថា សង្ខារក្ខន្ធ ខន្ធទាំងឡាយ ហៅថា រូបក្ខន្ធ ។ ពួកសង្ខារ ហៅថា សង្ខារក្ខន្ធ ខន្ធទាំងឡាយ ហៅថា វេទនាខន្ធ ។ ពួកសង្ខារ ហៅថា សង្ខារក្ខន្ធ ខន្ធទាំងឡាយ ហៅថា សញ្ញាខន្ធ ។ ពួកសង្ខារ ហៅថា សង្ខារក្ខន្ធ ខន្ធទាំងឡាយ ហៅថា វិញ្ញាណក្ខន្ធ ។ វិញ្ញាណ ហៅថា វិញ្ញាណក្ខន្ធ ខន្ធទាំងឡាយ ហៅថា រូបក្ខន្ធ ។ វិញ្ញាណ ហៅថា វិញ្ញាណក្ខន្ធ ខន្ធទាំងឡាយ ហៅថា វេទនាខន្ធ ។ វិញ្ញាណ ហៅថា វិញ្ញាណក្ខន្ធ ខន្ធទាំងឡាយ ហៅថា សញ្ញាខន្ធ ។ វិញ្ញាណ ហៅថា វិញ្ញាណក្ខន្ធ ខន្ធទាំងឡាយ ហៅថា សង្ខារក្ខន្ធ ។

[ ២៧ ] មិនមែនរូប មិនហៅថា រូបក្ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា វេទនាខន្ធ ។ មិនមែនរូប មិនហៅថា រូបក្ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា សញ្ញាខន្ធ ។ មិនមែនរូប មិនហៅថា រូបក្ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា សង្ខារក្ខន្ធ ។ មិនមែនរូប មិនហៅថា រូបក្ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា វិញ្ញាណក្ខន្ធ ។ មិនមែនវេទនា មិនហៅថា វេទនាខន្ធ

មិនមែនខន្ធទាំងឡាយ មិនហៅថា រូបក្ខន្ធ ។ មិនមែនវេទនា មិនហៅថា វេទនាខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា សញ្ញាខន្ធ ។ មិនមែនវេទនា មិនហៅថា វេទនាខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា សង្ខារក្ខន្ធ ។ មិនមែនវេទនា មិនហៅថា វេទនាខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា វិញ្ញាណក្ខន្ធ ។ មិនមែនសញ្ញា មិនហៅថា សញ្ញាខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា រូបក្ខន្ធ ។ មិនមែនសញ្ញា មិនហៅថា សញ្ញាខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា វេទនាខន្ធ ។ មិនមែនសញ្ញា មិនហៅថា សញ្ញាខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា សង្ខារក្ខន្ធ ។ មិនមែនសញ្ញា មិនហៅថា សញ្ញាខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា វិញ្ញាណក្ខន្ធ ។ មិនមែនពួកសង្ខារ មិនហៅថា សង្ខារក្ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា រូបក្ខន្ធ ។ មិនមែនពួកសង្ខារ មិនហៅថា សង្ខារក្ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា វេទនាខន្ធ ។ មិនមែនពួកសង្ខារ មិនហៅថា សង្ខារក្ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា សញ្ញាខន្ធ ។ មិនមែនពួកសង្ខារ មិនហៅថា សង្ខារក្ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា វិញ្ញាណក្ខន្ធ ។ មិនមែនវិញ្ញាណ មិនហៅថា វិញ្ញាណក្ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា រូបក្ខន្ធ ។ មិនមែនវិញ្ញាណ មិនហៅថា វិញ្ញាណក្ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា វេទនាខន្ធ ។ មិនមែនវិញ្ញាណ មិនហៅថា វិញ្ញាណក្ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា សញ្ញាខន្ធ ។ មិនមែនវិញ្ញាណ មិនហៅថា វិញ្ញាណក្ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា សង្ខារក្ខន្ធ ។

[ ២៨ ] រូប ហៅថា ខន្ធ ខន្ធទាំងឡាយ ហៅថា រូប ។ វេទនា ហៅថា ខន្ធ ខន្ធទាំងឡាយ ហៅថា វេទនា ។ សញ្ញា ហៅថា ខន្ធ ខន្ធទាំងឡាយ ហៅថា សញ្ញា ។ ពួកសង្ខារ ហៅថា ខន្ធ ខន្ធទាំងឡាយ ហៅថា សង្ខារ ។ វិញ្ញាណ ហៅថា ខន្ធ ខន្ធទាំងឡាយ ហៅថា វិញ្ញាណ ។

[ ២៩ ] មិនមែនរូប មិនហៅថា ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា រូប ។ មិនមែនវេទនា មិនហៅថា ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា វេទនា ។ មិនមែនសញ្ញា មិនហៅថា ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា សញ្ញា ។ មិនមែនពួកសង្ខារ មិនហៅថា ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា ពួកសង្ខារ ។ មិនមែនវិញ្ញាណ មិនហៅថា ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា វិញ្ញាណ ។

[ ៣០ ] រូប ហៅថា ខន្ធ ខន្ធទាំងឡាយ ហៅថា វេទនា ។ រូប ហៅថា ខន្ធ ខន្ធទាំងឡាយ ហៅថា សញ្ញា ។ រូប ហៅថា ខន្ធ ខន្ធទាំងឡាយ ហៅថា ពួកសង្ខារ ។ រូប ហៅថា ខន្ធ ខន្ធទាំងឡាយ ហៅថា វិញ្ញាណ ។ វេទនា ហៅថា ខន្ធ ខន្ធទាំងឡាយ ហៅថា រូប ។ វេទនា ហៅថា ខន្ធ ខន្ធទាំងឡាយ ហៅថា សញ្ញា ។ វេទនា ហៅថា ខន្ធ ខន្ធទាំងឡាយ ហៅថា ពួកសង្ខារ ។ វេទនា ហៅថា ខន្ធ ខន្ធទាំងឡាយ ហៅថា វិញ្ញាណ ។ សញ្ញា ហៅថា ខន្ធ ខន្ធទាំងឡាយ ហៅថា រូប ។ សញ្ញា ហៅថា ខន្ធ ខន្ធទាំងឡាយ ហៅថា វេទនា ។ សញ្ញា ហៅថា ខន្ធ ខន្ធទាំងឡាយ ហៅថា ពួកសង្ខារ ។ សញ្ញា ហៅថា ខន្ធ ខន្ធទាំងឡាយ ហៅថា វិញ្ញាណ ។ ពួកសង្ខារ

ហៅថា ខន្ធ ខន្ធទាំងឡាយ ហៅថា រូប ។ ពួកសង្ខារ ហៅថា ខន្ធ ខន្ធទាំងឡាយ ហៅថា វេទនា ។ ពួកសង្ខារ ហៅថា ខន្ធ ខន្ធទាំងឡាយ ហៅថា សញ្ញា ។ ពួកសង្ខារ ហៅថា ខន្ធ ខន្ធទាំងឡាយ ហៅថា វិញ្ញាណ ។ វិញ្ញាណ ហៅថា ខន្ធ ខន្ធទាំងឡាយ ហៅថា រូប ។ វិញ្ញាណ ហៅថា ខន្ធ ខន្ធទាំងឡាយ ហៅថា វេទនា ។ វិញ្ញាណ ហៅថា ខន្ធ ខន្ធទាំងឡាយ ហៅថា សញ្ញា ។ វិញ្ញាណ ហៅថា ខន្ធ ខន្ធទាំងឡាយ ហៅថា ពួកសង្ខារ ។

[ ៣១ ] មិនមែនរូប មិនហៅថា ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា វេទនា ។ មិនមែនរូប មិនហៅថា ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា សញ្ញា ។ មិនមែនរូប មិនហៅថា ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា ពួកសង្ខារ ។ មិនមែនរូប មិនហៅថា ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា វិញ្ញាណ ។ មិនមែនវេទនា មិនហៅថា ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា រូប ។ មិនមែនវេទនា មិនហៅថា ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា សញ្ញា ។ មិនមែនវេទនា មិនហៅថា ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា ពួកសង្ខារ ។ មិនមែនវេទនា មិនហៅថា ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា វិញ្ញាណ ។ មិនមែនសញ្ញា មិនហៅថា ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា រូប ។ មិនមែនសញ្ញា មិនហៅថា ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា វេទនា ។ មិនមែនសញ្ញា មិនហៅថា ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា ពួកសង្ខារ ។ មិនមែនសញ្ញា មិនហៅថា ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា វិញ្ញាណ ។ មិនមែនពួកសង្ខារ មិនហៅថា

ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា រូប ។ មិនមែនពួកសង្ខារ មិនហៅថា ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា វេទនា ។ មិនមែនពួកសង្ខារ មិនហៅថា ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា សញ្ញា ។ មិនមែនពួកសង្ខារ មិនហៅថា ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា វិញ្ញាណ ។ មិនមែនវិញ្ញាណ មិនហៅថា ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា រូប ។ មិនមែនវិញ្ញាណ មិនហៅថា ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា វេទនា ។ មិនមែនវិញ្ញាណ មិនហៅថា ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា សញ្ញា ។ មិនមែនវិញ្ញាណ មិនហៅថា ខន្ធ មិនមែនខន្ធទាំងឡាយ មិនហៅថា ពួកសង្ខារ ។

# អដ្ឋកថា

# ខន្ធយមកៈ

## បណ្ណត្តិឧទ្ទេសវារៈ

[ ២៤-៣១ ] ឥឡូវនេះ ជាកិច្ចពណ៌នាខន្ធយមកៈ ដែលព្រះមានព្រះភាគ ទ្រង់សម្ដែងក្នុងលំដាប់បន្ទាប់អំពីមូលយមកៈ ព្រោះទ្រង់សង្គ្រោះនូវធម៌ទាំងឡាយ មានកុសលជាដើម ដែលទ្រង់សម្ដែងហើយ ក្នុងមូលយមកៈ ដោយអំណាចនៃខន្ធ គប្បីជ្រាបការកំណត់ព្រះបាលី ក្នុងខន្ធយមកៈយ៉ាងនេះ ។

ក្នុងខន្ធយមកៈនេះ មានមហាវារៈ ៣ គឺ **បណ្ណត្តិវារ** **បវត្តិវារ** និង **បរិញ្ញាវារ** ។

ក្នុងមហាវារៈទាំង ៣ នោះ **បណ្ណត្តិវារ** ទ្រង់ត្រាស់ហៅថា **បណ្ណត្តិវារ** ព្រោះទ្រង់ធ្វើដោយអំណាចការជម្រះឈ្មោះរបស់ខន្ធទាំងឡាយ ។

**បវត្តិវារ** ទ្រង់ត្រាស់ហៅថា **បវត្តិវារ** ព្រោះទ្រង់ជម្រះការប្រព្រឹត្តទៅដោយអំណាចការកើតឡើង និងការរលត់ទៅនៃខន្ធទាំងឡាយ ដែលទ្រង់ជម្រះឈ្មោះហើយ ។

**បរិញ្ញាវារ** ទ្រង់ត្រាស់ហៅថា **បរិញ្ញាវារ** ព្រោះទ្រង់សម្ដែងបរិញ្ញា ៣ នៃខន្ធទាំងឡាយ ដែលប្រព្រឹត្តទៅហើយតាមលំដាប់នេះដោយសង្ខេប ។

*ក្នុងមហាវារៈទាំងនោះ* **បណ្ណត្តិវារ** *ទ្រង់កំណត់ដោយអាការ ២ យ៉ាង គឺ* **ឧទ្ទេស** *និង* **និទ្ទេស** *ក្នុងឧទ្ទេស និងនិទ្ទេសទាំងនេះ ឧទ្ទេសវារៈ មិនមានដោយផ្នែកមួយ ។ ចាប់តាំងអំពីដើម ទ្រង់កំណត់និទ្ទេសដោយចំណែកមួយដោយអំណាចបុច្ឆា និងវិសជ្ជនា ។ ក្នុងវារៈទាំងនោះ បណ្ឌិតគប្បីជ្រាបឧទ្ទេសវារៈ នៃបណ្ណត្តិវារៈ តាំងអំពីបទថា* **បញ្ចក្ខន្ធា** *ជាដើម រហូតដល់បទថា* **ន ខន្ធា ន សង្ខារា** ។ *ពាក្យថា* **បុច្ឆាវារ** *នេះ ក៏ជាឈ្មោះរបស់ឧទ្ទេសក្នុងបណ្ណត្តិវារៈនោះ ។ បណ្ដាវារៈទាំងនោះ បទថា* **បញ្ចក្ខន្ធា** *ដូច្នេះ ជាឧទ្ទេសរបស់ខន្ធទាំងឡាយ ដែលគប្បីសួរដោយអំណាចយមកៈ ។*

*គប្បីជ្រាបការកំណត់ឈ្មោះរបស់ខន្ធទាំងឡាយនោះ ដោយប្រភេទថា រូបក្ខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ និងវិញ្ញាណក្ខន្ធ ។*

*ឥឡូវនេះ នយវារៈ ៤ គឺ* **បទសោធនវារ ១ បទសោធនមូលចក្កវារ ១ សុទ្ធក្ខន្ធវារ ១ សុទ្ធក្ខន្ធមូលចក្កវារ ១** *រមែងមានដោយអំណាចនៃខន្ធទាំងឡាយនោះ ។*

*ក្នុងនយវារៈទាំងនោះ វារៈដែលធ្វើនូវការជម្រះបទដោយន័យជាដើមថា* **រូបំ រូបក្ខន្ធោ រូបក្ខន្ធោ រូបំ** *ដូច្នេះនោះឯង ឈ្មោះថា* **បទសោធនវារ** ។ *ក្នុងបទសោធនវារៈនោះមានពីរយ៉ាង ដោយអំណាចអនុលោម និងបដិលោម ។ ក្នុងបទសោធនវារៈនោះ ក្នុងអនុលោមវារៈ មានយមកៈ ៥ គឺ* **រូបំ រូប–ក្ខន្ធោ រូបក្ខន្ធោ រូបំ** *ដូច្នេះជាដើម ។ ក្នុងបដិលោមក៏មាន ៥ យ៉ាង គឺ* **ន រូបំ ន រូបក្ខន្ធោ ន រូបក្ខន្ធោ ន រូបំ** *ដូច្នេះជាដើម ។*

ខាងមុខអំពីនេះ ជាវារៈដែលទ្រង់ចងមូលនៃខន្ធនីមួយៗ នៃខន្ធទាំងឡាយ ដែលទ្រង់ជម្រះហើយ ក្នុងបទសោធនវារៈទាំងនោះឯង ឲ្យជាចក្កនីមួយៗ ៤ ដោយន័យជាដើមថា **រូបំ រូបក្ខន្ធោ ខន្ធា វេទនាក្ខន្ធោ** ដូច្នេះ ឈ្មោះថា **បទសោធនមូលចក្កវារ** ព្រោះភាពនៃចក្កទាំងឡាយ ជាមូលនៃការជម្រះបទមាន ។ សូម្បីក្នុងបទសោធនមូលចក្កវារៈនោះ ក៏មាន ២ យ៉ាង ដោយអំណាចអនុលោម និងបដិលោម ។ ក្នុងអនុលោម និងបដិលោមទាំងនោះ ក្នុងអនុលោមវារៈ មានយមកៈ ២០ ព្រោះធ្វើនូវមូលនៃខន្ធនីមួយៗ ឲ្យជា ៤ មានពាក្យថា **រូបំ រូបក្ខន្ធោ ខន្ធា វេទនាក្ខន្ធោ** ដូច្នេះជាដើម សូម្បីក្នុងបដិលោមក៏មាន ២០ ដូចគ្នា ព្រោះធ្វើមូលនៃខន្ធនីមួយៗ ឲ្យជា ៤ មានពាក្យថា **ន រូបំ ន រូបក្ខន្ធោ ន ខន្ធា ន វេទនាក្ខន្ធោ** ដូច្នេះជាដើម ។

ខាងមុខអំពីនេះ វារៈដែលប្រព្រឹត្តទៅហើយ ដោយអំណាចខន្ធសុទ្ធៗ ដោយន័យជាដើមថា **រូបំ ខន្ធោ ខន្ធា រូបំ** ដូច្នេះ ឈ្មោះថា **សុទ្ធក្ខន្ធវារ** ។ ក្នុងសុទ្ធក្ខន្ធវារៈនោះ ។ ក្នុងបុច្ឆាថា **ខន្ធា រូបំ** ជាដើម គប្បីកាន់យកអត្ថថា ខន្ធ ហៅថា រូបក្ខន្ធ ខន្ធទាំងឡាយ ហៅថា វេទនាខន្ធ ។ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះលោកបានចែកក្នុងនិទ្ទេសវារៈយ៉ាងនេះ ។

ក្នុងនិទ្ទេសវារៈនោះ សួរថា រូប ហៅថា ខន្ធឬ ឆ្លើយថា អើ សួរថា ខន្ធទាំងឡាយ ហៅថា រូបក្ខន្ធឬ ឆ្លើយថា រូបក្ខន្ធ ហៅថា រូបផង ហៅថា រូបក្ខន្ធផង ខន្ធទាំងឡាយដ៏សេស មិនហៅថា រូបក្ខន្ធ ដូច្នេះ លោកលើកបទឡើងចែកអត្ថ ដោយន័យជាដើមថា ខន្ធទាំងឡាយ ហៅថា រូបក្ខន្ធឬ នៃ

បទទាំងឡាយថា ខន្ធទាំងឡាយ ហៅថា រូបឬ ដូច្នេះ ដោយប្រការដូច្នេះ ដោយហេតុនោះ ទើបវារៈនោះ លោកហៅថា **សុទ្ធក្ខន្ធវារ** ។ ក្នុងសុទ្ធក្ខន្ធ-វារៈនេះ ។ បទថា **ន ខន្ធា** ជាពាក្យមានប្រមាណ ដូចក្នុងការជម្រះពាក្យ ។ ឯសុទ្ធក្ខន្ធវារៈ រមែងបានដោយប្រការណាមួយ អត្ថនោះឯងជាប្រមាណ រមែងបានដោយប្រការនោះៗ សូម្បីក្នុងអាយតនយមកៈជាដើមខាងមុខ ក៏មានន័យដូចគ្នា ។ ឯសុទ្ធក្ខន្ធវារៈនេះ មាន ២ យ៉ាង ដោយអំណាចអនុលោម និងបដិលោម ។ ក្នុងអនុលោម និងបដិលោមទាំងនោះ អនុលោមវារៈ មានយមកៈ ៥ គឺ **រូបំ រូបក្ខន្ធោ ខន្ធា រូបំ** ជាដើម ។ សូម្បីក្នុងបដិលោមវារៈក៏មានយមកៈ ៥ គឺ **ន រូបំ ន ខន្ធោ ន ខន្ធា ន រូបំ** ដូច្នេះជាដើម ។

ខាងមុខអំពីនោះ លោកធ្វើការចងមូលនៃខន្ធនីមួយៗ នៃសុទ្ធក្ខន្ធទាំងឡាយនោះ ដោយន័យជាដើមថា **រូបំ ខន្ធោ ខន្ធា វេទនា** ឲ្យជាចក្កនីមួយៗ ៤ ឈ្មោះថា **សុទ្ធក្ខន្ធមូលចក្កវារ** ព្រោះភាពដែលចក្ក មានសុទ្ធក្ខន្ធជាមូលមាន ។ ក្នុងសុទ្ធក្ខន្ធមូលចក្កវារៈនោះ គប្បីជ្រាបអត្ថដោយន័យជាដើមថា ខន្ធទាំងឡាយ ហៅថា វេទនាខន្ធឬ នៃពាក្យសួរថា **ខន្ធា វេទនា** ជាដើម ។

ដោយប្រការក្រៅអំពីនេះ ទើបមានការខុសគ្នានឹងនិទ្ទេសវារៈ ។ សូម្បីសុទ្ធក្ខន្ធមូលចក្កវារៈនោះ ក៏មាន ២ យ៉ាង ដោយអំណាចអនុលោម និងបដិលោម ។ ក្នុងអនុលោម និងបដិលោមទាំងនោះ ក្នុងអនុលោមវារៈ មាន

*យមកៈ ២០ ព្រោះធ្វើមូលនៃខន្ធនីមួយៗ ឲ្យជាចក្កនីមួយៗ ៤ មានបទថា* **រូបំ ខន្ធោ ខន្ធា វេទនា** *ដូច្នេះជាដើម ។ សូម្បីក្នុងបដិលោមវារៈ ក៏មាន ២០ ដូចគ្នា ព្រោះធ្វើមូលនៃខន្ធនីមួយៗ ឲ្យជាចក្កនីមួយៗ ៤ មានបទថា* **ន រូបំ ន ខន្ធោ ន ខន្ធា ន វេទនា** *ដូច្នេះជាដើម គប្បីជ្រាបឧទ្ទេសវារៈនៃបណ្ណត្តិវារៈ ដែលប្រដាប់ហើយដោយយមកៈ ១០០ ដោយពាក្យសួរ ២០០ និងដោយអត្ថ ៤០០ ព្រោះធ្វើអត្ថទាំងឡាយនីមួយៗ ឲ្យជា ២ ដោយអំណាច* **សន្និដ្ឋាន** *និង* **សំសយ** *ដើម្បីការសួរក្នុងន័យនីមួយៗ យ៉ាងនេះ ដោយប្រការដូច្នេះ ៗ។*

**អដ្ឋកថាឧទ្ទេសវារៈ ចប់**

# អភិធម្មបិដក

## និទ្ទេសវារៈ

[ ៣២ ] រូប ហៅថា រូបក្ខន្ធឬ ។ រូបជាទីស្រឡាញ់ រូបដ៏ធ្លាញ់ពិសា ហៅថា រូប តែមិនមែនហៅថា រូបក្ខន្ធទេ ឯរូបក្ខន្ធ ហៅថា រូបផង ហៅថា រូបក្ខន្ធផង ។ រូបក្ខន្ធ ហៅថា រូបឬ ។ អើ ។

[ ៣៣ ] វេទនា ហៅថា វេទនាខន្ធឬ ។ អើ ។ វេទនាខន្ធ ហៅថា វេទនាឬ ។ អើ ។

[ ៣៤ ] សញ្ញា ហៅថា សញ្ញាខន្ធឬ ។ ទិដ្ឋិសញ្ញា ហៅថា សញ្ញា តែមិនមែនហៅថា សញ្ញាខន្ធទេ ឯសញ្ញាខន្ធ ហៅថា សញ្ញាផង ហៅថា សញ្ញាខន្ធផង ។ សញ្ញាខន្ធ ហៅថា សញ្ញាឬ ។ អើ ។

[ ៣៥ ] ពួកសង្ខារ ហៅថា សង្ខារក្ខន្ធឬ ។ ពួកសង្ខារដ៏សេស លើកលែងតែសង្ខារក្ខន្ធចេញ ហៅថា ពួកសង្ខារ តែមិនមែនហៅថា សង្ខារក្ខន្ធទេ ឯសង្ខារក្ខន្ធ ហៅថា ពួកសង្ខារផង ហៅថា សង្ខារក្ខន្ធផង ។ សង្ខារក្ខន្ធ ហៅថា ពួកសង្ខារឬ ។ អើ ។

[ ៣៦ ] វិញ្ញាណ ហៅថា វិញ្ញាណក្ខន្ធឬ ។ អើ ។ វិញ្ញាណក្ខន្ធ ហៅថា វិញ្ញាណឬ ។ អើ ។

[ ៣៧ ] មិនមែនរូប មិនហៅថា រូបក្ខន្ធឬ ។ អើ ។ មិនមែនរូបក្ខន្ធ មិនហៅថា រូបឬ ។ រូបជាទីស្រឡាញ់ រូបដ៏ធ្លាញ់ពិសា មិនមែនហៅថា រូបក្ខន្ធទេ គ្រាន់តែជារូប ឯធម៌ទាំងឡាយដ៏សេស វៀរលែងតែរូប និងរូបក្ខន្ធចេញ មិនមែនហៅថា រូបផង មិនមែនហៅថា រូបក្ខន្ធផង ។

[ ៣៨ ] មិនមែនវេទនា មិនហៅថា វេទនាខន្ធឬ ។ អើ ។ មិនមែនវេទនាខន្ធ មិនហៅថា វេទនាឬ ។ អើ ។

[ ៣៩ ] មិនមែនសញ្ញា មិនហៅថា សញ្ញាខន្ធឬ ។ អើ ។ មិនមែនសញ្ញាខន្ធ មិនហៅថា សញ្ញាឬ ។ ទិដ្ឋិសញ្ញា មិនមែនហៅថា សញ្ញាខន្ធទេ គ្រាន់តែជាសញ្ញាប៉ុណ្ណោះ ឯពួកធម៌ដ៏សេស វៀរលែងតែសញ្ញា និងសញ្ញាខន្ធចេញ មិនមែនហៅថា សញ្ញាផង មិនមែនហៅថា សញ្ញាខន្ធផង ។

[ ៤០ ] មិនមែនពួកសង្ខារ មិនហៅថា សង្ខារក្ខន្ធឬ ។ អើ ។ មិនមែនសង្ខារក្ខន្ធ មិនហៅថា ពួកសង្ខារឬ ។ ពួកសង្ខារដ៏សេស វៀរលែងតែសង្ខារក្ខន្ធចេញ មិនមែនហៅថា សង្ខារក្ខន្ធទេ គ្រាន់តែជាពួកសង្ខារប៉ុណ្ណោះ ឯពួកធម៌ដ៏សេស វៀរលែងតែពួកសង្ខារ និងសង្ខារក្ខន្ធចេញ មិនមែនហៅថា ពួកសង្ខារផង មិនមែនហៅថា សង្ខារក្ខន្ធផង ។

[ ៤១ ] មិនមែនវិញ្ញាណ មិនហៅថា វិញ្ញាណក្ខន្ធឬ ។ អើ ។ មិនមែនវិញ្ញាណក្ខន្ធ មិនហៅថា វិញ្ញាណឬ ។ អើ ។

# អដ្ឋកថា

# បណ្ណត្តិនិទ្ទេសវារៈ

## បទសោធនវារៈ

[ ៣២-៤១ ] ឥឡូវនេះ ព្រះមានព្រះភាគ ទ្រង់ផ្ដើមនិទ្ទេសវារៈ ដោយន័យជាដើមថា **រូបំ រូបក្ខន្ធោ** ក្នុងបញ្ហាថា **រូបំ រូបក្ខន្ធោ** ដូច្នេះ រូបណាមួយព្រះមានព្រះភាគត្រាស់ហៅថា រូប រូបទាំងអស់នោះ ទ្រង់ត្រាស់ដើម្បីជម្រះពាក្យថា **រូបក្ខន្ធ** ។

ពាក្យវិសជ្ជនាថា **បិយរូបំ សាតរូបំ រូបំ ន រូបក្ខន្ធោ** អធិប្បាយថា ពាក្យថា រូបណា ទ្រង់ត្រាស់ថា រូប ក្នុងពាក្យនេះថា **បិយរូបំ សាតរូបំ** រូបនោះ ហៅថា រូបប៉ុណ្ណោះ មិនហៅថា រូបក្ខន្ធឡើយ ។

ពាក្យវិសជ្ជនាថា **រូបក្ខន្ធោ រូបញ្ចេវ រូបក្ខន្ធោ ច** អធិប្បាយថា សភាវធម៌ណាជារូបក្ខន្ធ សភាវធម៌នោះ រមែងគួរដើម្បីនឹងពោលថា ជារូបផង ជារូបក្ខន្ធផង ។

ក្នុងបញ្ហាថា **រូបក្ខន្ធោ រូបំ** ដូច្នេះ ព្រោះរូបក្ខន្ធ គប្បីពោលថា ជារូបដោយពិតប្រាកដប៉ុណ្ណោះ ហេតុនោះ ទើបទ្រង់ត្រាស់ថា **អាមន្តា** គប្បីជ្រាបអត្ថក្នុងវិសជ្ជនាទាំងអស់ដោយឧបាយនេះ ឯការប្លែកគ្នា មានក្នុងទីណា នឹងពណ៌នាការប្លែកគ្នានោះ ក្នុងទីនោះ ។

*ក្នុងសញ្ញាយមកៈ បទថា* **ទិដ្ឋិសញ្ញា** *បានដល់ ទិដ្ឋិសញ្ញា ដែលមកហើយក្នុងពាក្យថា* **បបញ្ចសញ្ញា** *គឺសញ្ញាជាគ្រឿងធ្វើឲ្យយឺតយូរជាដើម ។*

*ក្នុងសង្ខារយមកៈ បទថា* **អវសេសា សង្ខារា** *បានដល់ សង្ខតធម៌ដ៏សេសសល់អំពីសង្ខារក្ខន្ធ ដែលមកហើយក្នុងពាក្យថា* **អនិច្ចា វត សង្ខារា** *សង្ខារទាំងឡាយ មិនទៀងហ្ន៎ ដូច្នេះជាដើម ។ ក្នុងបដិលោមវារៈ ក៏ន័យនេះឯង ។៚*

## អធិប្បាយបទសោធនវារៈ ចប់

# អភិធម្មបិដក

[ ៤២ ] រូប ហៅថា រូបក្ខន្ធឬ ។ រូបជាទីស្រឡាញ់ រូបដ៏ធ្លាញ់ពិសា ហៅថា រូប តែមិនមែនហៅថា រូបក្ខន្ធទេ ឯរូបក្ខន្ធ ហៅថា រូបផង ហៅថា រូបក្ខន្ធផង ។ ខន្ធទាំងឡាយ ហៅថា វេទនាខន្ធឬ ។ វេទនាខន្ធ ហៅថា ខន្ធផង ហៅថា វេទនាខន្ធផង ឯខន្ធទាំងឡាយដ៏សេស ហៅថា ពួកខន្ធ តែមិនមែនហៅថា វេទនាខន្ធទេ ។

[ ៤៣ ] រូប ហៅថា រូបក្ខន្ធឬ ។ រូបជាទីស្រឡាញ់ រូបដ៏ធ្លាញ់ពិសា ហៅថា រូប តែមិនមែនហៅថា រូបក្ខន្ធទេ ឯរូបក្ខន្ធ ហៅថា រូបផង ហៅថា រូបក្ខន្ធផង ។ ខន្ធទាំងឡាយ ហៅថា សញ្ញាខន្ធឬ ។ សញ្ញាខន្ធ ហៅថា ខន្ធផង ហៅថា សញ្ញាខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា សញ្ញាខន្ធទេ ។

[ ៤៤ ] រូប ហៅថា រូបក្ខន្ធឬ ។ រូបជាទីស្រឡាញ់ រូបដ៏ធ្លាញ់ពិសា ហៅថា រូប តែមិនមែនហៅថា រូបក្ខន្ធទេ ឯរូបក្ខន្ធ ហៅថា រូបផង ហៅថា រូបក្ខន្ធផង ។ ខន្ធទាំងឡាយ ហៅថា សង្ខារក្ខន្ធឬ ។ សង្ខារក្ខន្ធ ហៅថា ខន្ធផង ហៅថា សង្ខារក្ខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា សង្ខារក្ខន្ធទេ ។

[ ៤៥ ] រូប ហៅថា រូបក្ខន្ធឬ ។ រូបជាទីស្រឡាញ់ រូបដ៏ធ្លាញ់ពិសា ហៅថា រូប តែមិនមែនហៅថា រូបក្ខន្ធទេ ឯរូបក្ខន្ធ ហៅថា រូបផង ហៅថា រូបក្ខន្ធផង ។ ខន្ធទាំងឡាយ ហៅថា វិញ្ញាណក្ខន្ធឬ ។ វិញ្ញាណក្ខន្ធ ហៅថា ខន្ធផង ហៅថា វិញ្ញាណក្ខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ

មិនមែនហៅថា វិញ្ញាណក្ខន្ធទេ ។

[ ៤៦ ] វេទនា ហៅថា វេទនាខន្ធឬ ។ អើ ។ ខន្ធទាំងឡាយ ហៅថា រូបក្ខន្ធឬ ។ រូបក្ខន្ធ ហៅថា ខន្ធផង ហៅថា រូបក្ខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា រូបក្ខន្ធទេ ។

[ ៤៧ ] វេទនា ហៅថា វេទនាខន្ធឬ ។ អើ ។ ខន្ធទាំងឡាយ ហៅថា សញ្ញាខន្ធឬ ។ សញ្ញាខន្ធ ហៅថា ខន្ធផង ហៅថា សញ្ញាខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា សញ្ញាខន្ធទេ ។

[ ៤៨ ] វេទនា ហៅថា វេទនាខន្ធឬ ។ អើ ។ ខន្ធទាំងឡាយ ហៅថា សង្ខារក្ខន្ធឬ ។ សង្ខារក្ខន្ធ ហៅថា ខន្ធផង ហៅថា សង្ខារក្ខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា សង្ខារក្ខន្ធទេ ។

[ ៤៩ ] វេទនា ហៅថា វេទនាខន្ធឬ ។ អើ ។ ខន្ធទាំងឡាយ ហៅថា វិញ្ញាណក្ខន្ធឬ ។ វិញ្ញាណក្ខន្ធ ហៅថា ខន្ធផង ហៅថា វិញ្ញាណក្ខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា វិញ្ញាណក្ខន្ធទេ ។

[ ៥០ ] សញ្ញា ហៅថា សញ្ញាខន្ធឬ ។ ទិដ្ឋិសញ្ញា ហៅថា សញ្ញា តែមិនមែនហៅថា សញ្ញាខន្ធទេ ឯសញ្ញាខន្ធ ហៅថា សញ្ញាផង ហៅថា សញ្ញាខន្ធផង ។ ខន្ធទាំងឡាយ ហៅថា រូបក្ខន្ធឬ ។ រូបក្ខន្ធ ហៅថា ខន្ធផង ហៅថា រូបក្ខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា រូបក្ខន្ធទេ ។

[ ៥១ ] សញ្ញា ហៅថា សញ្ញាខន្ធឬ ។ ទិដ្ឋិសញ្ញា ហៅថា សញ្ញា

តែមិនមែនហៅថា សញ្ញាខន្ធទេ ឯសញ្ញាខន្ធ ហៅថា សញ្ញាផង ហៅថា សញ្ញាខន្ធផង ។ ខន្ធទាំងឡាយ ហៅថា វេទនាខន្ធឬ ។ វេទនាខន្ធ ហៅថា ខន្ធផង ហៅថា វេទនាខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា វេទនាខន្ធទេ ។

[ ៥២ ] សញ្ញា ហៅថា សញ្ញាខន្ធឬ ។ ទិដ្ឋិសញ្ញា ហៅថា សញ្ញា តែមិនមែនហៅថា សញ្ញាខន្ធទេ ឯសញ្ញាខន្ធ ហៅថា សញ្ញាផង ហៅថា សញ្ញាខន្ធផង ។ ខន្ធទាំងឡាយ ហៅថា សង្ខារក្ខន្ធឬ ។ សង្ខារក្ខន្ធ ហៅថា ខន្ធផង ហៅថា សង្ខារក្ខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា សង្ខារក្ខន្ធទេ ។

[ ៥៣ ] សញ្ញា ហៅថា សញ្ញាខន្ធឬ ។ ទិដ្ឋិសញ្ញា ហៅថា សញ្ញា តែមិនមែនហៅថា សញ្ញាខន្ធទេ ឯសញ្ញាខន្ធ ហៅថា សញ្ញាផង ហៅថា សញ្ញាខន្ធផង ។ ខន្ធទាំងឡាយ ហៅថា វិញ្ញាណក្ខន្ធឬ ។ វិញ្ញាណក្ខន្ធ ហៅថា ខន្ធផង ហៅថា វិញ្ញាណក្ខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា វិញ្ញាណក្ខន្ធទេ ។

[ ៥៤ ] ពួកសង្ខារ ហៅថា សង្ខារក្ខន្ធឬ ។ ពួកសង្ខារដ៏សេស វៀរលែងតែសង្ខារក្ខន្ធចេញ ហៅថា ពួកសង្ខារ តែមិនមែនហៅថា សង្ខារក្ខន្ធទេ ឯសង្ខារក្ខន្ធ ហៅថា ពួកសង្ខារផង ហៅថា សង្ខារក្ខន្ធផង ។ ខន្ធទាំងឡាយ ហៅថា រូបក្ខន្ធឬ ។ រូបក្ខន្ធ ហៅថា ខន្ធផង ហៅថា រូបក្ខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា រូបក្ខន្ធទេ ។

[ ៥៥ ] ពួកសង្ខារ ហៅថា សង្ខារក្ខន្ធឬ ។ ពួកសង្ខារដ៏សេស វៀរលែងតែសង្ខារក្ខន្ធចេញ ហៅថា ពួកសង្ខារ តែមិនមែនហៅថា សង្ខារក្ខន្ធទេ ឯសង្ខារក្ខន្ធ ហៅថា ពួកសង្ខារផង ហៅថា សង្ខារក្ខន្ធផង ។ ខន្ធទាំងឡាយហៅថា វេទនាខន្ធឬ ។ វេទនាខន្ធ ហៅថា ខន្ធផង ហៅថា វេទនាខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា វេទនាខន្ធទេ ។

[ ៥៦ ] ពួកសង្ខារ ហៅថា សង្ខារក្ខន្ធឬ ។ ពួកសង្ខារដ៏សេស វៀរលែងតែសង្ខារក្ខន្ធចេញ ហៅថា ពួកសង្ខារ តែមិនមែនហៅថា សង្ខារក្ខន្ធទេ ឯសង្ខារក្ខន្ធ ហៅថា ពួកសង្ខារផង ហៅថា សង្ខារក្ខន្ធផង ។ ខន្ធទាំងឡាយហៅថា សញ្ញាខន្ធឬ ។ សញ្ញាខន្ធ ហៅថា ខន្ធផង ហៅថា សញ្ញាខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា សញ្ញាខន្ធទេ ។

[ ៥៧ ] ពួកសង្ខារ ហៅថា សង្ខារក្ខន្ធឬ ។ ពួកសង្ខារដ៏សេស វៀរលែងតែសង្ខារក្ខន្ធចេញ ហៅថា ពួកសង្ខារ តែមិនមែនហៅថា សង្ខារក្ខន្ធទេ ឯសង្ខារក្ខន្ធ ហៅថា ពួកសង្ខារផង ហៅថា សង្ខារក្ខន្ធផង ។ ខន្ធទាំងឡាយហៅថា វិញ្ញាណក្ខន្ធឬ ។ វិញ្ញាណក្ខន្ធ ហៅថា ខន្ធផង ហៅថា វិញ្ញាណក្ខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា វិញ្ញាណក្ខន្ធទេ ។

[ ៥៨ ] វិញ្ញាណ ហៅថា វិញ្ញាណក្ខន្ធឬ ។ អើ ។ ខន្ធទាំងឡាយហៅថា រូបក្ខន្ធឬ ។ រូបក្ខន្ធ ហៅថា ខន្ធផង ហៅថា រូបក្ខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា រូបក្ខន្ធទេ ។

[ ៥៩ ] វិញ្ញាណ ហៅថា វិញ្ញាណក្ខន្ធឬ ។ អើ ។ ខន្ធទាំងឡាយ ហៅថា វេទនាខន្ធឬ ។ វេទនាខន្ធ ហៅថា ខន្ធផង ហៅថា វេទនាខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា វេទនាខន្ធទេ ។

[ ៦០ ] វិញ្ញាណ ហៅថា វិញ្ញាណក្ខន្ធឬ ។ អើ ។ ខន្ធទាំងឡាយ ហៅថា សញ្ញាខន្ធឬ ។ សញ្ញាខន្ធ ហៅថា ខន្ធផង ហៅថា សញ្ញាខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា សញ្ញាខន្ធទេ ។

[ ៦១ ] វិញ្ញាណ ហៅថា វិញ្ញាណក្ខន្ធឬ ។ អើ ។ ខន្ធទាំងឡាយ ហៅថា សង្ខារក្ខន្ធឬ ។ សង្ខារក្ខន្ធ ហៅថា ខន្ធផង ហៅថា សង្ខារក្ខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា សង្ខារក្ខន្ធទេ ។

[ ៦២ ] មិនមែនរូប មិនហៅថា រូបក្ខន្ធឬ ។ អើ ។ មិនមែនខន្ធទាំងឡាយ មិនហៅថា វេទនាខន្ធឬ ។ អើ ។ មិនមែនរូប មិនហៅថា រូបក្ខន្ធឬ ។ អើ ។ មិនមែនខន្ធទាំងឡាយ មិនហៅថា សញ្ញាខន្ធឬ ។ អើ ។ មិនមែនរូប មិនហៅថា រូបក្ខន្ធឬ ។ អើ ។ មិនមែនខន្ធទាំងឡាយ មិនហៅថា សង្ខារក្ខន្ធឬ ។ អើ ។ មិនមែនរូប មិនហៅថា រូបក្ខន្ធឬ ។ អើ ។ មិនមែនខន្ធទាំងឡាយ មិនហៅថា វិញ្ញាណក្ខន្ធឬ ។ អើ ។

[ ៦៣ ] មិនមែនវេទនា មិនហៅថា វេទនាខន្ធឬ ។ អើ ។ មិនមែនខន្ធទាំងឡាយ មិនហៅថា រូបក្ខន្ធឬ ។ អើ ។ មិនមែនវេទនា មិនហៅថា វេទនាខន្ធឬ ។ អើ ។ មិនមែនខន្ធទាំងឡាយ មិនហៅថា សញ្ញាខន្ធឬ ។ អើ ។ មិនមែនវេទនា មិនហៅថា វេទនាខន្ធឬ ។ អើ ។ មិនមែនខន្ធទាំង

ឡាយ មិនហៅថា សង្ខារក្ខន្ធឬ ។ អើ ។ មិនមែនវេទនា មិនហៅថា វេទនាខន្ធឬ ។ អើ ។ មិនមែនខន្ធទាំងឡាយ មិនហៅថា វិញ្ញាណក្ខន្ធឬ ។ អើ ។

[ ៦៤ ] មិនមែនសញ្ញា មិនហៅថា សញ្ញាខន្ធឬ ។ អើ ។ មិនមែនខន្ធទាំងឡាយ មិនហៅថា រូបក្ខន្ធឬ ។ អើ ។ មិនមែនសញ្ញា មិនហៅថា សញ្ញាខន្ធឬ ។ អើ ។ មិនមែនខន្ធទាំងឡាយ មិនហៅថា វេទនាខន្ធឬ ។ អើ ។ មិនមែនសញ្ញា មិនហៅថា សញ្ញាខន្ធឬ ។ អើ ។ មិនមែនខន្ធទាំងឡាយ មិនហៅថា សង្ខារក្ខន្ធឬ ។ អើ ។ មិនមែនសញ្ញា មិនហៅថា សញ្ញាខន្ធឬ ។ អើ ។ មិនមែនខន្ធទាំងឡាយ មិនហៅថា វិញ្ញាណក្ខន្ធឬ ។ អើ ។

[ ៦៥ ] មិនមែនពួកសង្ខារ មិនហៅថា សង្ខារក្ខន្ធឬ ។ អើ ។ មិនមែនខន្ធទាំងឡាយ មិនហៅថា រូបក្ខន្ធឬ ។ អើ ។ មិនមែនពួកសង្ខារ មិនហៅថា សង្ខារក្ខន្ធឬ ។ អើ ។ មិនមែនខន្ធទាំងឡាយ មិនហៅថា វេទនាខន្ធឬ ។ អើ ។ មិនមែនពួកសង្ខារ មិនហៅថា សង្ខារក្ខន្ធឬ ។ អើ ។ មិនមែនខន្ធទាំងឡាយ មិនហៅថា សញ្ញាខន្ធឬ ។ អើ ។ មិនមែនពួកសង្ខារ មិនហៅថា សង្ខារក្ខន្ធឬ ។ អើ ។ មិនមែនខន្ធទាំងឡាយ មិនហៅថា វិញ្ញាណក្ខន្ធឬ ។ អើ ។

[ ៦៦ ] មិនមែនវិញ្ញាណ មិនហៅថា វិញ្ញាណក្ខន្ធឬ ។ អើ ។ មិនមែនខន្ធទាំងឡាយ មិនហៅថា រូបក្ខន្ធឬ ។ អើ ។ មិនមែនវិញ្ញាណ មិនហៅថា វិញ្ញាណក្ខន្ធឬ ។ អើ ។ មិនមែនខន្ធទាំងឡាយ មិនហៅថា វេទនាខន្ធឬ ។ អើ ។ មិនមែនវិញ្ញាណ មិនហៅថា វិញ្ញាណក្ខន្ធឬ ។ អើ ។ មិនមែនខន្ធទាំងឡាយ មិនហៅថា សញ្ញាខន្ធឬ ។ អើ ។ មិនមែនវិញ្ញាណ មិនហៅថា វិញ្ញាណក្ខន្ធឬ ។ អើ ។ មិនមែនខន្ធទាំងឡាយ មិនហៅថា សង្ខារក្ខន្ធឬ ។ អើ ។

# អដ្ឋកថា

## បធសោធនមូលចក្កវារៈ

[ ៤២-៦៦ ] ក្នុងបទសោធនមូលចក្កវារៈ ពាក្យបុច្ឆាថា **ខន្ធា វេទនា-ខន្ធោ** ដូច្នេះ រមែងត្រាស់សួរថា ខន្ធទាំងឡាយពួកណា មានខន្ធទាំងឡាយនោះ ហៅថា វេទនាខន្ធឬ ត្រាស់ឆ្លើយថា វេទនាខន្ធ ហៅថា ខន្ធផង ហៅថា វេទនាខន្ធផង តែខន្ធទាំងឡាយដ៏សេស ហៅថា ខន្ធប៉ុណ្ណោះ មិនហៅថា វេទនាខន្ធ ដូច្នេះ ។ នៃពាក្យសួរនោះ ។ ពាក្យដ៏សេសក៏ន័យនេះ ។

ក្នុងបដិលោម ពាក្យសួរនេះថា **ន ខន្ធា ន វេទនាខន្ធោ** បានដល់ព្រោះធម៌ទាំងឡាយណា ពោល គឺបញ្ញត្តិ និងនិព្វាន មិនហៅថា ខន្ធ ធម៌ទាំងឡាយនោះ មិនហៅថា វេទនាខន្ធ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា **អាមន្តា** ។ សូម្បីក្នុងពាក្យវិសជ្ជនាដ៏សេស ក៏មានន័យនេះ ដោយប្រការដូច្នេះ ។

**អដ្ឋកថាបធសោធនមូលចក្កវារៈ ចប់**

# អភិធម្មបិដក

[ ៦៧ ] រូប ហៅថា ខន្ធឬ ។ អើ ។ ខន្ធទាំងឡាយ ហៅថា រូបក្ខន្ធ ឬ ។ រូបក្ខន្ធ ហៅថា ខន្ធផង ហៅថា រូបក្ខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា រូបក្ខន្ធទេ ។

[ ៦៨ ] វេទនា ហៅថា ខន្ធឬ ។ អើ ។ ខន្ធទាំងឡាយ ហៅថា វេទនាខន្ធឬ ។ វេទនាខន្ធ ហៅថា ខន្ធផង ហៅថា វេទនាខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា វេទនាខន្ធទេ ។

[ ៦៩ ] សញ្ញា ហៅថា ខន្ធឬ ។ អើ ។ ខន្ធទាំងឡាយ ហៅថា សញ្ញាខន្ធឬ ។ សញ្ញាខន្ធ ហៅថា ខន្ធផង ហៅថា សញ្ញាខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា សញ្ញាខន្ធទេ ។

[ ៧០ ] ពួកសង្ខារ ហៅថា ខន្ធឬ ។ អើ ។ ខន្ធទាំងឡាយ ហៅថា សង្ខារក្ខន្ធឬ ។ សង្ខារក្ខន្ធ ហៅថា ខន្ធផង ហៅថា សង្ខារក្ខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា សង្ខារក្ខន្ធទេ ។

[ ៧១ ] វិញ្ញាណ ហៅថា ខន្ធឬ ។ អើ ។ ខន្ធទាំងឡាយ ហៅថា វិញ្ញាណក្ខន្ធឬ ។ វិញ្ញាណក្ខន្ធ ហៅថា ខន្ធផង ហៅថា វិញ្ញាណក្ខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា វិញ្ញាណក្ខន្ធទេ ។

[ ៧២ ] មិនមែនរូប មិនហៅថា ខន្ធឬ ។ ខន្ធទាំងឡាយដ៏សេស វៀរលែងតែរូបចេញ មិនហៅថា រូបទេ ហៅថា ពួកខន្ធ ខន្ធទាំងឡាយដ៏សេស វៀរលែងតែរូប និងពួកខន្ធចេញ មិនហៅថា រូបផង មិនហៅថា ពួកខន្ធផង ទេ ។ មិនមែនពួកខន្ធ មិនហៅថា រូបក្ខន្ធឬ ។ អើ ។

[ ៧៣ ] មិនមែនវេទនា មិនហៅថា ខន្ធឬ ។ ខន្ធទាំងឡាយដ៏សេស វៀរលែងតែវេទនាចេញ មិនហៅថា វេទនាទេ ហៅថា ពួកខន្ធ ខន្ធទាំងឡាយដ៏សេស វៀរលែងតែវេទនា និងពួកខន្ធចេញ មិនហៅថា វេទនាផង មិនហៅថា ពួកខន្ធផងទេ ។ មិនមែនពួកខន្ធ មិនហៅថា វេទនាខន្ធឬ ។ អើ ។

[ ៧៤ ] មិនមែនសញ្ញា មិនហៅថា ខន្ធឬ ។ ខន្ធទាំងឡាយដ៏សេស វៀរលែងតែសញ្ញាចេញ មិនហៅថា សញ្ញាទេ ហៅថា ពួកខន្ធ ខន្ធទាំងឡាយដ៏សេស វៀរលែងតែសញ្ញា និងពួកខន្ធចេញ មិនហៅថា សញ្ញាផង មិនហៅថា ពួកខន្ធផងទេ ។ មិនមែនពួកខន្ធ មិនហៅថា សញ្ញាខន្ធឬ ។ អើ ។

[ ៧៥ ] មិនមែនពួកសង្ខារ មិនហៅថា ខន្ធឬ ។ ខន្ធទាំងឡាយដ៏សេស វៀរលែងតែពួកសង្ខារចេញ មិនហៅថា ពួកសង្ខារទេ ហៅថា ពួកខន្ធ ខន្ធទាំងឡាយដ៏សេស វៀរលែងតែពួកសង្ខារ និងពួកខន្ធចេញ មិនហៅថា ពួកសង្ខារផង មិនហៅថា ពួកខន្ធផងទេ ។ មិនមែនពួកខន្ធ មិនហៅថា សង្ខារក្ខន្ធឬ ។ អើ ។

[ ៧៦ ] មិនមែនវិញ្ញាណ មិនហៅថា ខន្ធឬ ។ ខន្ធទាំងឡាយដ៏សេស វៀរលែងតែវិញ្ញាណចេញ មិនហៅថា វិញ្ញាណទេ ហៅថា ពួកខន្ធ ខន្ធទាំងឡាយដ៏សេស វៀរលែងតែវិញ្ញាណ និងពួកខន្ធចេញ មិនហៅថា វិញ្ញាណផង មិនហៅថា ពួកខន្ធផងទេ ។ មិនមែនពួកខន្ធ មិនហៅថា វិញ្ញាណក្ខន្ធឬ ។ អើ ។

# អដ្ឋកថា

## សុទ្ធក្ខន្ធវារៈ

[ ៦៧-៧៦ ] *សុទ្ធក្ខន្ធវារៈ ពាក្យសួរថា* **រូបំ ខន្ធោ** *រមែងត្រាស់សួរថា រូបណាមួយ ដែលពោលថា រូប រូបទាំងអស់នោះ ជាខន្ធឬ ។ ក្នុងពាក្យសួរនោះ ព្រោះរូប ពោល គឺបិយរូប សាតរូបក្តី ភូតរូប និងឧបាទារូបទាំងអស់ក្តី ដល់នូវការសង្គ្រោះក្នុងខន្ធ ៥ ។ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ទូលថា* **អាមន្តា** ។

*ក្នុងទុតិយបទ គួរសួរថា ខន្ធទាំងឡាយ ហៅថា រូបឬ ព្រោះទ្រង់អធិប្បាយរូបក្ខន្ធហើយ ដោយពាក្យថា រូប ព្រោះហេតុនោះ ទើបទ្រង់មិនពិចារណាដល់ពាក្យ កាលត្រាស់សួរដោយអំណាចនៃអត្ថ ទើបត្រាស់ថា* **ខន្ធា រូបក្ខន្ធោ** *ដូច្នេះ ។ គប្បីជ្រាបអត្ថក្នុងបទទាំងពួង ដោយឧបាយនេះ ។ សូម្បីក្នុងនិទ្ទេសវារៈ នៃអាយតនយមកៈជាដើមខាងមុខ ក៏ន័យនេះ ។*

*ក្នុងពាក្យសួរថា* **សញ្ញា ខន្ធោ** *នេះ ទិដ្ឋិសញ្ញាក្តី សញ្ញាក្តី ចូរមានទ្រង់ត្រាស់ថា* **អាមន្តា** *ព្រោះភាពនៃទិដ្ឋិសញ្ញា និងសញ្ញាទាំងអស់ក៏ជាខន្ធ ។*

*ក្នុងបទថា* **សង្ខារា ខន្ធោ** *ក៏មានន័យនេះ ។ ពិតហើយ ឈ្មោះថាសង្ខារដែលផុតចាកភាពជាខន្ធ រមែងមិនមាន ។*

*ក្នុងបដិលោម ពាក្យសួរថា* ***ន រូបំ ន ខន្ធោ*** *ដូច្នេះ ព្រះមានព្រះភាគត្រាស់សួរថា ធម្មជាតណាមិនមែនរូប ធម្មជាតនោះ ក៏មិនមែនខន្ធឬ ក្នុងវិសជ្ជនាបញ្ហានោះ ដូច្នេះថា* ***រូបំ ឋបេត្វា អវសេសា ខន្ធា ន រូបំ ខន្ធា*** *អធិប្បាយថា ខន្ធទាំងឡាយ មានវេទនាជាដើម ដទៃអំពីរូប មិនហៅថា រូប តែហៅថា ខន្ធ ។*

*បទថា* ***រូបញ្ច ខន្ធេ ច ឋបេត្វា អវសេសា*** *ដូច្នេះ បានដល់ បញ្ញត្តិ និងនិព្វាន ដែលផុតចាកខន្ធ ៥ ។ ក្នុងបទថា* ***អវសេសា*** *ដទៃអំពីបទនេះ ក៏មានន័យនេះ ដោយប្រការដូច្នេះ ៚*

**អដ្ឋកថាសុទ្ធក្ខន្ធវារៈ ចប់**

# អភិធម្មបិដក

[ ៧៧ ] រូប ហៅថា ខន្ធឬ ។ អើ ។ ខន្ធទាំងឡាយ ហៅថា វេទនាខន្ធ ឬ ។ វេទនាខន្ធ ហៅថា ខន្ធផង ហៅថា វេទនាខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា វេទនាខន្ធទេ ។

[ ៧៨ ] រូប ហៅថា ខន្ធឬ ។ អើ ។ ខន្ធទាំងឡាយ ហៅថា សញ្ញាខន្ធ ឬ ។ សញ្ញាខន្ធ ហៅថា ខន្ធផង ហៅថា សញ្ញាខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា សញ្ញាខន្ធទេ ។

[ ៧៩ ] រូប ហៅថា ខន្ធឬ ។ អើ ។ ខន្ធទាំងឡាយ ហៅថា សង្ខារក្ខន្ធ ឬ ។ សង្ខារក្ខន្ធ ហៅថា ខន្ធផង ហៅថា សង្ខារក្ខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា សង្ខារក្ខន្ធទេ ។

[ ៨០ ] រូប ហៅថា ខន្ធឬ ។ អើ ។ ខន្ធទាំងឡាយ ហៅថា វិញ្ញាណក្ខន្ធ ឬ ។ វិញ្ញាណក្ខន្ធ ហៅថា ខន្ធផង ហៅថា វិញ្ញាណក្ខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា វិញ្ញាណក្ខន្ធទេ ។

[ ៨១ ] វេទនា ហៅថា ខន្ធឬ ។ អើ ។ ខន្ធ ហៅថា រូបក្ខន្ធឬ ។ រូបក្ខន្ធ ហៅថា ខន្ធផង ហៅថា រូបក្ខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា រូបក្ខន្ធទេ ។

[ ៨២ ] វេទនា ហៅថា ខន្ធឬ ។ អើ ។ ខន្ធទាំងឡាយ ហៅថា សញ្ញាខន្ធឬ ។ សញ្ញាខន្ធ ហៅថា ខន្ធផង ហៅថា សញ្ញាខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា សញ្ញាខន្ធទេ ។

[ ៨៣ ] វេទនា ហៅថា ខន្ធឬ ។ អើ ។ ខន្ធទាំងឡាយ ហៅថា

សង្ខារក្ខន្ធឬ ។ សង្ខារក្ខន្ធ ហៅថា ខន្ធផង ហៅថា សង្ខារក្ខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា សង្ខារក្ខន្ធទេ ។

[ ៨៤ ] វេទនា ហៅថា ខន្ធឬ ។ អើ ។ ខន្ធទាំងឡាយ ហៅថា វិញ្ញាណក្ខន្ធឬ ។ វិញ្ញាណក្ខន្ធ ហៅថា ខន្ធផង ហៅថា វិញ្ញាណក្ខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា វិញ្ញាណក្ខន្ធទេ ។

[ ៨៥ ] សញ្ញា ហៅថា ខន្ធឬ ។ អើ ។ ខន្ធទាំងឡាយ ហៅថា រូបក្ខន្ធឬ ។ រូបក្ខន្ធ ហៅថា ខន្ធផង ហៅថា រូបក្ខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា រូបក្ខន្ធទេ ។

[ ៨៦ ] សញ្ញា ហៅថា ខន្ធឬ ។ អើ ។ ខន្ធទាំងឡាយ ហៅថា វេទនាខន្ធឬ ។ វេទនាខន្ធ ហៅថា ខន្ធផង ហៅថា វេទនាខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា វេទនាខន្ធទេ ។

[ ៨៧ ] សញ្ញា ហៅថា ខន្ធឬ ។ អើ ។ ខន្ធទាំងឡាយ ហៅថា សង្ខារក្ខន្ធឬ ។ សង្ខារក្ខន្ធ ហៅថា ខន្ធផង ហៅថា សង្ខារក្ខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា សង្ខារក្ខន្ធទេ ។

[ ៨៨ ] សញ្ញា ហៅថា ខន្ធឬ ។ អើ ។ ខន្ធទាំងឡាយ ហៅថា វិញ្ញាណក្ខន្ធឬ ។ វិញ្ញាណក្ខន្ធ ហៅថា ខន្ធផង ហៅថា វិញ្ញាណក្ខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា វិញ្ញាណក្ខន្ធទេ ។

[ ៨៩ ] ពួកសង្ខារ ហៅថា ខន្ធឬ ។ អើ ។ ខន្ធទាំងឡាយ ហៅថា រូបក្ខន្ធឬ ។ រូបក្ខន្ធ ហៅថា ខន្ធផង ហៅថា រូបក្ខន្ធផង ឯខន្ធទាំងឡាយ

ដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា រូបក្ខន្ធទេ ។

[ ៩០ ] ពួកសង្ខារ ហៅថា ខន្ធឬ ។ អើ ។ ខន្ធទាំងឡាយ ហៅថា វេទនាខន្ធឬ ។ វេទនាខន្ធ ហៅថា ខន្ធផង ហៅថា វេទនាខន្ធផង ឯខន្ធទាំងឡាយដ៏សេស គ្រាន់តែជាពួកខន្ធ មិនមែនហៅថា វេទនាខន្ធទេ ។

[ ៩១ ] សង្ខារទាំងឡាយ ហៅថា ខន្ធឬ ។ អើ ។ ខន្ធទាំងឡាយ ហៅថា សញ្ញាខន្ធឬ ។ សញ្ញាខន្ធ ហៅថា ខន្ធផង ហៅថា វេទនាខន្ធផង[១] ឯខន្ធទាំងឡាយដ៏សេស ហៅថា ខន្ធ មិនមែនហៅថា សញ្ញាខន្ធទេ ។

[ ៩២ ] សង្ខារទាំងឡាយ ហៅថា ខន្ធឬ ។ អើ ។ ខន្ធទាំងឡាយ ហៅថា វិញ្ញាណក្ខន្ធឬ ។ វិញ្ញាណក្ខន្ធ ហៅថា ខន្ធផង ហៅថា វិញ្ញាណក្ខន្ធផង ឯខន្ធទាំងឡាយដ៏សេស ហៅថា ខន្ធ មិនមែនហៅថា វិញ្ញាណក្ខន្ធទេ ។

[ ៩៣ ] វិញ្ញាណ ហៅថា ខន្ធឬ ។ អើ ។ ខន្ធទាំងឡាយ ហៅថា រូបក្ខន្ធឬ ។ រូបក្ខន្ធ ហៅថា ខន្ធផង ហៅថា រូបក្ខន្ធផង ឯខន្ធទាំងឡាយដ៏សេស ហៅថា ខន្ធ មិនមែនហៅថា រូបក្ខន្ធទេ ។

[ ៩៤ ] វិញ្ញាណ ហៅថា ខន្ធឬ ។ អើ ។ ខន្ធទាំងឡាយ ហៅថា វេទនាខន្ធឬ ។ វេទនាខន្ធ ហៅថា ខន្ធផង ហៅថា វេទនាខន្ធផង ឯខន្ធទាំងឡាយដ៏សេស ហៅថា ខន្ធ មិនមែនហៅថា វេទនាខន្ធទេ ។

[ ៩៥ ] វិញ្ញាណ ហៅថា ខន្ធឬ ។ អើ ។ ខន្ធទាំងឡាយ ហៅថា សញ្ញាខន្ធឬ ។ សញ្ញាខន្ធ ហៅថា ខន្ធផង ហៅថា សញ្ញាខន្ធផង ឯខន្ធ

---

១- ច្បាប់របស់ស្យាម ជាសញ្ញាខន្ធផង ។

ទាំងឡាយដ៏សេស ហៅថា ខន្ធ មិនមែនហៅថា សញ្ញាខន្ធទេ ។

[ ៩៦ ] វិញ្ញាណ ហៅថា ខន្ធឬ ។ អើ ។ ខន្ធទាំងឡាយ ហៅថា សង្ខារក្ខន្ធឬ ។ សង្ខារក្ខន្ធ ហៅថា ខន្ធផង ហៅថា សង្ខារក្ខន្ធផង ឯខន្ធទាំងឡាយដ៏សេស ហៅថា ខន្ធ មិនមែនហៅថា សង្ខារក្ខន្ធទេ ។

[ ៩៧ ] មិនមែនរូប មិនហៅថា ខន្ធឬ ។ ខន្ធទាំងឡាយដ៏សេស វៀរលែងតែរូបចេញ មិនហៅថា រូបទេ ហៅថា ខន្ធ ខន្ធទាំងឡាយដ៏សេស វៀរលែងតែរូប និងខន្ធចេញ មិនហៅថា រូបផង មិនហៅថា ខន្ធផងទេ ។ មិនមែនខន្ធទាំងឡាយ មិនហៅថា វេទនាខន្ធឬ ។ អើ ។

[ ៩៨ ] មិនមែនរូប មិនហៅថា ខន្ធឬ ។ ខន្ធទាំងឡាយដ៏សេស វៀរលែងតែរូបចេញ មិនមែនហៅថា រូបទេ ហៅថា ខន្ធ ខន្ធទាំងឡាយដ៏សេស វៀរលែងតែរូប និងខន្ធចេញ មិនហៅថា រូបផង មិនហៅថា ខន្ធផងទេ ។ មិនមែនខន្ធ មិនហៅថា សញ្ញាខន្ធឬ ។ អើ ។

[ ៩៩ ] មិនមែនរូប មិនហៅថា ខន្ធឬ ។ ខន្ធទាំងឡាយដ៏សេស វៀរលែងតែរូបចេញ មិនហៅថា រូបទេ ហៅថា ខន្ធ ខន្ធទាំងឡាយដ៏សេស វៀរលែងតែរូប និងខន្ធចេញ មិនហៅថា រូបផង មិនហៅថា ខន្ធផងទេ ។ មិនមែនខន្ធ មិនហៅថា សង្ខារក្ខន្ធឬ ។ អើ ។

[ ១០០ ] មិនមែនរូប មិនហៅថា ខន្ធឬ ។ ខន្ធទាំងឡាយដ៏សេស វៀរលែងតែរូបចេញ មិនហៅថា រូបទេ ហៅថា ខន្ធ ខន្ធទាំងឡាយដ៏សេស វៀរលែងតែរូប និងខន្ធចេញ មិនហៅថា រូបផង មិនហៅថា ខន្ធផងទេ ។

មិនមែនខន្ធ មិនហៅថា វិញ្ញាណក្ខន្ធឬ ។ អើ ។

[ ១០១ ] មិនមែនវេទនា មិនហៅថា ខន្ធឬ ។ ខន្ធទាំងឡាយដ៏សេស វៀរលែងតែវេទនាចេញ មិនហៅថា វេទនាទេ ហៅថា ខន្ធ ខន្ធទាំងឡាយដ៏សេស វៀរលែងតែវេទនា និងខន្ធចេញ មិនហៅថា វេទនាផង មិនហៅថា ខន្ធផងទេ ។ មិនមែនខន្ធ មិនហៅថា រូបក្ខន្ធឬ ។ អើ ។

[ ១០២ ] មិនមែនវេទនា មិនហៅថា ខន្ធឬ ។ ខន្ធទាំងឡាយដ៏សេស វៀរលែងតែវេទនាចេញ មិនហៅថា វេទនាទេ ហៅថា ខន្ធ ខន្ធទាំងឡាយដ៏សេស វៀរលែងតែវេទនា និងខន្ធចេញ មិនហៅថា វេទនាផង មិនហៅថា ខន្ធផងទេ ។ មិនមែនខន្ធ មិនហៅថា សញ្ញាខន្ធឬ ។ អើ ។

[ ១០៣ ] មិនមែនវេទនា មិនហៅថា ខន្ធឬ ។ ខន្ធទាំងឡាយដ៏សេស វៀរលែងតែវេទនាចេញ មិនហៅថា វេទនាទេ ហៅថា ខន្ធ ខន្ធទាំងឡាយដ៏សេស វៀរលែងតែវេទនា និងខន្ធចេញ មិនហៅថា វេទនាផង មិនហៅថា ខន្ធផងទេ ។ មិនមែនខន្ធ មិនហៅថា សង្ខារក្ខន្ធឬ ។ អើ ។

[ ១០៤ ] មិនមែនវេទនា មិនហៅថា ខន្ធឬ ។ ខន្ធទាំងឡាយដ៏សេស វៀរលែងតែវេទនាចេញ មិនហៅថា វេទនាទេ ហៅថា ខន្ធ ខន្ធទាំងឡាយដ៏សេស វៀរលែងតែវេទនា និងខន្ធចេញ មិនហៅថា វេទនាផង មិនហៅថា ខន្ធផងទេ ។ មិនមែនខន្ធ មិនហៅថា វិញ្ញាណក្ខន្ធឬ ។ អើ ។

[ ១០៥ ] មិនមែនសញ្ញា មិនហៅថា ខន្ធឬ ។ ខន្ធទាំងឡាយដ៏សេស វៀរលែងតែសញ្ញាចេញ មិនហៅថា សញ្ញាទេ ហៅថា ខន្ធ ខន្ធទាំងឡាយ

ដ៏សេស វៀរលែងតែសញ្ញា និងខន្ធចេញ មិនហៅថា សញ្ញាផង មិនហៅថា ខន្ធផងទេ ។ មិនមែនខន្ធ មិនហៅថា រូបក្ខន្ធឬ ។ អើ ។

[ ១០៦ ] មិនមែនសញ្ញា មិនហៅថា ខន្ធឬ ។ ខន្ធទាំងឡាយដ៏សេស វៀរលែងតែសញ្ញាចេញ មិនហៅថា សញ្ញាទេ ហៅថា ខន្ធ ខន្ធទាំងឡាយដ៏សេស វៀរលែងតែសញ្ញា និងខន្ធចេញ មិនហៅថា សញ្ញាផង មិនហៅថា ខន្ធផងទេ ។ មិនមែនខន្ធ មិនហៅថា វេទនាខន្ធឬ ។ អើ ។

[ ១០៧ ] មិនមែនសញ្ញា មិនហៅថា ខន្ធឬ ។ ខន្ធទាំងឡាយដ៏សេស វៀរលែងតែសញ្ញាចេញ មិនហៅថា សញ្ញាទេ ហៅថា ខន្ធ ខន្ធទាំងឡាយដ៏សេស វៀរលែងតែសញ្ញា និងខន្ធចេញ មិនហៅថា សញ្ញាផង មិនហៅថា ខន្ធផងទេ ។ មិនមែនខន្ធ មិនហៅថា សង្ខារក្ខន្ធឬ ។ អើ ។

[ ១០៨ ] មិនមែនសញ្ញា មិនហៅថា ខន្ធឬ ។ ខន្ធទាំងឡាយដ៏សេស វៀរលែងតែសញ្ញាចេញ មិនហៅថា សញ្ញាទេ ហៅថា ខន្ធ ខន្ធទាំងឡាយដ៏សេស វៀរលែងតែសញ្ញា និងខន្ធចេញ មិនហៅថា សញ្ញាផង មិនហៅថា ខន្ធផងទេ ។ មិនមែនខន្ធ មិនហៅថា វិញ្ញាណក្ខន្ធឬ ។ អើ ។

[ ១០៩ ] មិនមែនសង្ខារ មិនហៅថា ខន្ធឬ ។ អើ ។ មិនមែនខន្ធ មិន

ហៅថា រូបក្ខន្ធឬ ។ អើ ។

[ ១១០ ] មិនមែនសង្ខារ មិនហៅថា ខន្ធឬ ។ អើ ។ មិនមែនខន្ធ មិនហៅថា វេទនាខន្ធឬ ។ អើ ។

[ ១១១ ] មិនមែនសង្ខារ មិនហៅថា ខន្ធឬ ។ អើ ។ មិនមែនខន្ធ មិនហៅថា សញ្ញាខន្ធឬ ។ អើ ។

[ ១១២ ] មិនមែនសង្ខារ មិនហៅថា ខន្ធឬ ។ អើ ។ មិនមែនខន្ធ មិនហៅថា វិញ្ញាណក្ខន្ធឬ ។ អើ ។

[ ១១៣ ] មិនមែនវិញ្ញាណ មិនហៅថា ខន្ធឬ ។ ខន្ធទាំងឡាយដ៏សេស វៀរលែងតែវិញ្ញាណចេញ មិនហៅថា វិញ្ញាណទេ ហៅថា ខន្ធ ខន្ធទាំងឡាយដ៏សេស វៀរលែងតែវិញ្ញាណ និងខន្ធចេញ មិនហៅថា វិញ្ញាណផង មិនហៅថា ខន្ធផងទេ ។ មិនមែនខន្ធ មិនហៅថា រូបក្ខន្ធឬ ។ អើ ។

[ ១១៤ ] មិនមែនវិញ្ញាណ មិនហៅថា ខន្ធឬ ។ ខន្ធទាំងឡាយដ៏សេស វៀរលែងតែវិញ្ញាណចេញ មិនហៅថា វិញ្ញាណទេ ហៅថា ខន្ធ ខន្ធទាំងឡាយដ៏សេស វៀរលែងតែវិញ្ញាណ និងខន្ធចេញ មិនហៅថា វិញ្ញាណផង មិនហៅថា ខន្ធផងទេ ។ មិនមែនខន្ធ មិនហៅថា វេទនាខន្ធឬ ។ អើ ។

[ ១១៥ ] មិនមែនវិញ្ញាណ មិនហៅថា វិញ្ញាណក្ខន្ធឬ ។ ខន្ធទាំងឡាយដ៏សេស វៀរលែងតែវិញ្ញាណចេញ មិនហៅថា វិញ្ញាណទេ ហៅថា ខន្ធ ខន្ធទាំងឡាយដ៏សេស វៀរលែងតែវិញ្ញាណ និងខន្ធចេញ មិនហៅថា វិញ្ញាណផង មិនហៅថា ខន្ធផងទេ ។ មិនមែនខន្ធ មិនហៅថា សញ្ញាខន្ធឬ ។ អើ ។

[ ១១៦ ] មិនមែនវិញ្ញាណ មិនហៅថា ខន្ធឬ ។ ខន្ធទាំងឡាយដ៏សេស វៀរលែងតែវិញ្ញាណចេញ មិនហៅថា វិញ្ញាណទេ ហៅថា ខន្ធ ខន្ធទាំងឡាយដ៏សេស វៀរលែងតែវិញ្ញាណ និងខន្ធចេញ មិនហៅថា វិញ្ញាណផង មិនហៅថា ខន្ធផងទេ ។ មិនមែនខន្ធ មិនហៅថា សង្ខារក្ខន្ធឬ ។ អើ ។

បណ្ណត្តិវារៈ ចប់

# អដ្ឋកថា

## សុទ្ធក្ខន្ធមូលចក្កវារៈ

[ ៧៧-១១៦ ] *ក្នុងសុទ្ធក្ខន្ធមូលចក្កវារៈ ពាក្យសួរទាំងឡាយ មានពាក្យសួរថា* **រូបំ ១ល្ខ** *ដូច្នេះ គប្បីជ្រាបអត្ថដោយន័យ ដែលពោលខាងដើមនោះឯង ។ល។*

## សុទ្ធក្ខន្ធមូលចក្កវារៈ ចប់

## អដ្ឋកថាបណ្ណត្តិវារៈ ចប់

# អភិធម្មបិដក

## បវត្តិវារៈ

[ ១១៧ ] រូបក្ខន្ធ របស់សត្វណា កើតឡើង វេទនាខន្ធ របស់សត្វនោះ ក៏កើតឡើងដែរឬ ។ ពួកសត្វចូលទៅកាន់អសញ្ញសត្វ រូបក្ខន្ធរបស់សត្វទាំងនោះ កើតឡើង ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វចូលទៅកាន់បញ្ចវោការភព រូបក្ខន្ធកើតឡើងផង របស់សត្វទាំងនោះ វេទនាខន្ធកើតឡើងផង ។ មួយយ៉ាងទៀត វេទនាខន្ធរបស់សត្វណាកើតឡើង រូបក្ខន្ធរបស់សត្វនោះ ក៏កើតឡើងដែរឬ ។ ពួកសត្វ ចូលទៅកាន់អរូបភព វេទនាខន្ធរបស់សត្វទាំងនោះ កើតឡើង ឯរូបក្ខន្ធ របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វចូលទៅកាន់បញ្ចវោការភព វេទនាខន្ធរបស់សត្វទាំងនោះ កើតឡើងផង រូបក្ខន្ធកើតឡើងផង ។

[ ១១៨ ] រូបក្ខន្ធ កើតឡើងក្នុងទីណា វេទនាខន្ធ ក៏កើតឡើងក្នុងទីនោះដែរឬ ។ រូបក្ខន្ធ កើតឡើងក្នុងអសញ្ញសត្វនោះ ឯវេទនាខន្ធ មិនកើតឡើងក្នុងអសញ្ញសត្វនោះទេ រូបក្ខន្ធ រមែងកើតឡើងផង វេទនាខន្ធ រមែងកើតឡើងផងក្នុងបញ្ចវោការភពនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ កើតឡើងក្នុងទីណា រូបក្ខន្ធ ក៏កើតឡើងក្នុងទីនោះដែរឬ ។ វេទនាខន្ធកើតឡើង ក្នុងអរូបភពនោះ ឯរូបក្ខន្ធ មិនកើតឡើងក្នុងទីនោះទេ វេទនាខន្ធ រមែងកើតឡើងផង រូបក្ខន្ធរមែងកើតឡើងផង ក្នុងបញ្ចវោការភពនោះ ។

[ ១១៩ ] រូបក្ខន្ធ របស់សត្វណា កើតឡើង ក្នុងទីណា វេទនាខន្ធរបស់សត្វនោះ ក៏កើតឡើងក្នុងទីនោះដែរឬ ។ ពួកសត្វ ចូលទៅកាន់

អសញ្ញសត្វ រូបក្ខន្ធរបស់សត្វទាំងនោះ កើតឡើង ក្នុងទីនោះ ឯវេទនាខន្ធរបស់សត្វទាំងនោះ មិនកើតឡើងក្នុងទីនោះទេ ពួកសត្វ ចូលទៅកាន់បញ្ចវោការភព រូបក្ខន្ធរបស់សត្វទាំងនោះ ក៏កើតឡើងផង វេទនាខន្ធក៏កើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា កើតឡើងក្នុងទីណា រូបក្ខន្ធ របស់សត្វនោះ កើតឡើងក្នុងទីនោះដែរឬ ។ ពួកសត្វចូលទៅកាន់អរូបភព វេទនាខន្ធរបស់សត្វទាំងនោះ កើតឡើង ក្នុងទីនោះ ឯរូបក្ខន្ធ របស់សត្វទាំងនោះ មិនកើតឡើងក្នុងទីនោះទេ ។ ពួកសត្វ ចូលទៅកាន់បញ្ចវោការភព វេទនាខន្ធ របស់សត្វទាំងនោះ ក៏កើតឡើងផង រូបក្ខន្ធក៏កើតឡើងផង ក្នុងទីនោះ ។

[ ១២០ ] រូបក្ខន្ធ របស់សត្វណា មិនកើតឡើង វេទនាខន្ធ របស់សត្វនោះ ក៏មិនកើតឡើងដែរឬ ។ ពួកសត្វ ចូលទៅកាន់អរូបភព រូបក្ខន្ធ របស់សត្វទាំងនោះ មិនកើតឡើង ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ កាលពួកសត្វទាំងពួងច្យុត រូបក្ខន្ធរបស់សត្វទាំងនោះ ក៏មិនកើតឡើងផង វេទនាខន្ធ ក៏មិនកើតឡើងផង ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា មិនកើតឡើង រូបក្ខន្ធរបស់សត្វនោះ ក៏មិនកើតឡើងដែរឬ ។ ពួកសត្វ ចូលទៅកាន់អសញ្ញសត្វ វេទនាខន្ធ របស់សត្វទាំងនោះ មិនកើតឡើង ឯរូបក្ខន្ធរបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ កាលពួកសត្វទាំងពួងច្យុត វេទនាខន្ធ របស់សត្វទាំងនោះ ក៏មិនកើតឡើងផង រូបក្ខន្ធក៏មិនកើតឡើងផង ។

[ ១២១ ] រូបក្ខន្ធ មិនកើតឡើង ក្នុងទីណា វេទនាខន្ធ មិនកើតឡើង ក្នុងទីនោះដែរឬ ។ កើតឡើង ។ មួយយ៉ាងទៀត វេទនាខន្ធ មិនកើតឡើង ក្នុងទីណា រូបក្ខន្ធ មិនកើតឡើង ក្នុងទីនោះដែរឬ ។ កើតឡើង ។

[ ១២២ ] រូបក្ខន្ធ របស់សត្វណា មិនកើតឡើង ក្នុងទីណា វេទនាខន្ធ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះដែរឬ ។ កាលពួកសត្វ ចូលទៅកាន់អរូបភព រូបក្ខន្ធរបស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ ឯវេទនាខន្ធរបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងក្នុងទីនោះទេ ពួកសត្វទាំងពួង កាលច្យុត រូបក្ខន្ធរបស់សត្វទាំងនោះ មិនកើតឡើងផង វេទនាខន្ធ ក៏មិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា មិនកើតឡើងក្នុងទីណា រូបក្ខន្ធរបស់សត្វនោះ មិនកើតឡើងក្នុងទីនោះដែរឬ ។ ពួកសត្វ កាលចូលទៅកាន់អសញ្ញសត្វ វេទនាខន្ធរបស់សត្វទាំងនោះ មិនកើតឡើងក្នុងទីនោះ ឯរូបក្ខន្ធរបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងក្នុងទីនោះទេ ពួកសត្វទាំងពួង កាលច្យុត វេទនាខន្ធ របស់សត្វទាំងនោះ ក៏មិនកើតឡើងផង រូបក្ខន្ធក៏មិនកើតឡើងផង ក្នុងទីនោះ ។

[ ១២៣ ] រូបក្ខន្ធ របស់សត្វណា កើតឡើងហើយ វេទនាខន្ធ របស់សត្វនោះ កើតឡើងហើយដែរឬ ។ អើ ។ មួយយ៉ាងទៀត វេទនាខន្ធរបស់សត្វណា កើតឡើងហើយ រូបក្ខន្ធរបស់សត្វនោះ កើតឡើងហើយដែរឬ ។ អើ ។

[ ១២៤ ] រូបក្ខន្ធ កើតឡើងហើយ ក្នុងទីណា វេទនាខន្ធ កើតឡើង

ហើយ ក្នុងទីនោះដែរឬ ។ រូបក្ខន្ធ កើតឡើងហើយ ក្នុងអសញ្ញសត្វនោះ ឯវេទនាខន្ធ មិនកើតឡើងហើយ ក្នុងទីនោះទេ រូបក្ខន្ធក៏កើតឡើងហើយផង វេទនាខន្ធ ក៏កើតឡើងហើយផង ក្នុងបញ្ចវោការភពនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ កើតឡើងហើយ ក្នុងទីណា រូបក្ខន្ធកើតឡើងហើយ ក្នុងទីនោះដែរឬ ។ វេទនាខន្ធ កើតឡើងហើយ ក្នុងអរូបភពនោះ ឯរូបក្ខន្ធ មិនកើតឡើងហើយ ក្នុងទីនោះទេ វេទនាខន្ធ ក៏កើតឡើងហើយផង រូបក្ខន្ធក៏កើតឡើងហើយផង ក្នុងបញ្ចវោការភពនោះ ។

[ ១២៥ ] រូបក្ខន្ធ របស់សត្វណា កើតឡើងហើយ ក្នុងទីណា វេទនាខន្ធរបស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ រូបក្ខន្ធ របស់ពួកអសញ្ញសត្វនោះ កើតឡើងហើយ ក្នុងទីនោះ ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ រូបក្ខន្ធរបស់ពួកបញ្ចវោការសត្វនោះ ក៏កើតឡើងហើយផង វេទនាខន្ធ ក៏កើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា កើតឡើងហើយ ក្នុងទីណា រូបក្ខន្ធ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ វេទនាខន្ធ របស់ពួកអរូបព្រហ្មនោះ កើតឡើងហើយក្នុងទីនោះ ឯរូបក្ខន្ធរបស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ វេទនាខន្ធ របស់ពួកបញ្ចវោការសត្វនោះ ក៏កើតឡើងហើយផង រូបក្ខន្ធក៏កើតឡើងហើយផង ក្នុងទីនោះ ។

[ ១២៦ ] រូបក្ខន្ធរបស់សត្វណា មិនកើតឡើងហើយ វេទនាខន្ធរបស់សត្វនោះ មិនកើតឡើងហើយដែរឬ ។ មិនមានទេ ។ មួយយ៉ាងទៀត វេទនាខន្ធ

របស់សត្វណា មិនកើតឡើងហើយ រូបក្ខន្ធ របស់សត្វនោះ មិនកើតឡើងហើយដែរឬ ។ មិនមានទេ ។

[ ១២៧ ] រូបក្ខន្ធកើតឡើងហើយ ក្នុងទីណា វេទនាខន្ធ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ កើតឡើងហើយ ។ មួយយ៉ាងទៀត វេទនាខន្ធមិនកើតឡើងហើយ ក្នុងទីណា រូបក្ខន្ធ មិនកើតឡើងហើយ ក្នុងទីនោះដែរឬ ។ កើតឡើងហើយ ។

[ ១២៨ ] រូបក្ខន្ធ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា វេទនាខន្ធ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះដែរឬ ។ រូបក្ខន្ធរបស់ពួកអរូបព្រហ្មនោះ មិនកើតឡើងហើយ ក្នុងទីនោះ ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ រូបក្ខន្ធរបស់ពួកសុទ្ធាវាសសត្វនោះ ក៏មិនកើតឡើងហើយផង វេទនាខន្ធ ក៏មិនកើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា រូបក្ខន្ធរបស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះដែរឬ ។ វេទនាខន្ធ របស់ពួកអសញ្ញសត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះ ឯរូបក្ខន្ធរបស់ពួកសត្វនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ វេទនាខន្ធ របស់ពួកសុទ្ធាវាសសត្វនោះ ក៏មិនកើតឡើងហើយផង រូបក្ខន្ធក៏មិនកើតឡើងហើយផង ក្នុងទីនោះ ។

[ ១២៩ ] រូបក្ខន្ធរបស់សត្វណា នឹងកើតឡើង វេទនាខន្ធរបស់សត្វនោះ នឹងកើតឡើងដែរឬ ។ អើ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា

នឹងកើតឡើង រូបក្ខន្ធ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ សត្វទាំងឡាយណា ចូលទៅកាន់អរូបព្រហ្មហើយ នឹងបរិនិព្វាន វេទនាខន្ធ របស់សត្វទាំងនោះ នឹងកើតឡើង ឯរូបក្ខន្ធរបស់សត្វទាំងនោះ នឹងមិនកើតឡើងទេ វេទនា-ខន្ធរបស់សត្វទាំងនោះក្រៅនេះ នឹងកើតឡើងផង រូបក្ខន្ធនឹងកើតឡើងផង ។

[ ១៣០ ] រូបក្ខន្ធ នឹងកើតឡើង ក្នុងទីណា វេទនាខន្ធ នឹងកើតឡើងក្នុងទីនោះដែរឬ ។ រូបក្ខន្ធ នឹងកើតឡើង ក្នុងអសញ្ញសត្វនោះ ឯវេទនាខន្ធ នឹងមិនកើតឡើង ក្នុងទីនោះទេ រូបក្ខន្ធនឹងកើតឡើងផង វេទនាខន្ធនឹងកើតឡើងផង ក្នុងបញ្ចវោការភពនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ នឹងកើតឡើងក្នុងទីណា រូបក្ខន្ធ នឹងកើតឡើងក្នុងទីនោះដែរឬ ។ វេទនាខន្ធ នឹងកើតឡើងក្នុងអរូបភពនោះ ឯរូបក្ខន្ធ នឹងមិនកើតឡើងក្នុងទីនោះទេ វេទនាខន្ធ នឹងកើតឡើងផង រូបក្ខន្ធ នឹងកើតឡើងផង ក្នុងបញ្ចវោការភពនោះ ។

[ ១៣១ ] រូបក្ខន្ធ របស់សត្វណា នឹងកើតឡើងក្នុងទីណា វេទនាខន្ធរបស់សត្វនោះ នឹងកើតឡើងក្នុងទីនោះដែរឬ ។ រូបក្ខន្ធរបស់ពួកអសញ្ញសត្វនោះ នឹងកើតឡើង ក្នុងទីនោះ ឯវេទនាខន្ធរបស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ រូបក្ខន្ធរបស់ពួកបញ្ចវោការសត្វនោះ នឹងកើតឡើងផង វេទនាខន្ធ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា នឹងកើតឡើង ក្នុងទីណា រូបក្ខន្ធរបស់សត្វនោះ នឹងកើតឡើងក្នុងទីនោះដែរឬ ។ វេទនាខន្ធ របស់ពួកអរូបព្រហ្មនោះ នឹងកើតឡើងក្នុងទីនោះ ឯរូបក្ខន្ធរបស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ វេទនាខន្ធ របស់

ពួកបញ្ចវោការសត្វនោះ នឹងកើតឡើងផង រូបក្ខន្ធនឹងកើតឡើងផង ក្នុងទីនោះ ។

[ ១៣២ ] រូបក្ខន្ធរបស់សត្វណា នឹងមិនកើតឡើង វេទនាខន្ធរបស់សត្វនោះ នឹងមិនកើតឡើងដែរឬ ។ សត្វទាំងឡាយណា ចូលទៅកាន់អរូបព្រហ្ម ហើយ នឹងបរិនិព្វាន រូបក្ខន្ធរបស់សត្វទាំងនោះ នឹងមិនកើតឡើង ឯវេទនាខន្ធរបស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ រូបក្ខន្ធរបស់ពួកសត្វជាបច្ឆិមភពនោះ នឹងមិនកើតឡើងផង វេទនាខន្ធ នឹងមិនកើតឡើងផង ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា នឹងមិនកើតឡើង រូបក្ខន្ធរបស់សត្វនោះ នឹងមិនកើតឡើងដែរឬ ។ អើ ។

[ ១៣៣ ] រូបក្ខន្ធ នឹងមិនកើតឡើង ក្នុងទីណា វេទនាខន្ធ នឹងមិនកើតឡើង ក្នុងទីនោះដែរឬ ។ នឹងកើតឡើង ។ មួយយ៉ាងទៀត វេទនាខន្ធ នឹងមិនកើតឡើង ក្នុងទីណា រូបក្ខន្ធ នឹងមិនកើតឡើង ក្នុងទីនោះដែរឬ ។ នឹងកើតឡើង ។

[ ១៣៤ ] រូបក្ខន្ធរបស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា វេទនាខន្ធរបស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះដែរឬ ។ រូបក្ខន្ធ របស់ពួកអរូបព្រហ្មនោះ នឹងមិនកើតឡើង ក្នុងទីនោះ ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ រូបក្ខន្ធរបស់ពួកសត្វជាបច្ឆិមភពនោះ នឹងមិនកើតឡើងផង វេទនាខន្ធ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា រូបក្ខន្ធ របស់

សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះដែរឬ ។ វេទនាខន្ធ របស់ពួកអសញ្ញ-សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះ ឯរូបក្ខន្ធ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ វេទនាខន្ធ របស់ពួកសត្វជាបច្ឆិមកពនោះ នឹងមិនកើតឡើងផង រូបក្ខន្ធ នឹងមិនកើតឡើងផង ក្នុងទីនោះ ។

[ ១៣៥ ] រូបក្ខន្ធ របស់សត្វណា កើតឡើង វេទនាខន្ធ របស់សត្វនោះ កើតឡើងហើយដែរឬ ។ អើ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា កើតឡើងហើយ រូបក្ខន្ធ របស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វទាំងពួង កាលច្យុត ចូលទៅកាន់អរូបកព វេទនាខន្ធ របស់សត្វទាំងនោះ កើតឡើងហើយ ឯរូបក្ខន្ធ របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វ កាលចូលទៅកាន់បញ្ចវោការកព ចូលទៅកាន់អសញ្ញសត្វ វេទនាខន្ធ របស់សត្វទាំងនោះ កើតឡើងហើយផង រូបក្ខន្ធកើតឡើងផង ។

[ ១៣៦ ] វេទនាខន្ធ របស់សត្វណា កើតឡើង សញ្ញាខន្ធរបស់សត្វនោះ កើតឡើងហើយដែរឬ ។ អើ ។ មួយយ៉ាងទៀត សញ្ញាខន្ធរបស់សត្វណា កើតឡើងហើយ វេទនាខន្ធរបស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វទាំងពួង កាលច្យុត ចូលទៅកាន់អសញ្ញសត្វ សញ្ញាខន្ធរបស់សត្វទាំងនោះ កើតឡើងហើយ ឯវេទនាខន្ធរបស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វ កាលចូលទៅកាន់ចតុវោការកព និងបញ្ចវោការកព សញ្ញាខន្ធរបស់សត្វទាំងនោះ កើតឡើងហើយផង វេទនាខន្ធ កើតឡើងផង ។

[ ១៣៧ ] រូបក្ខន្ធកើតឡើង ក្នុងទីណា វេទនាខន្ធ កើតឡើងហើយ ក្នុង

ទីនោះដែរឬ ។ រូបក្ខន្ធ កើតឡើង ក្នុងអសញ្ញសត្តនោះ ឯវេទនាខន្ធ មិនកើតឡើងហើយ ក្នុងទីនោះទេ រូបក្ខន្ធ កើតឡើងផង វេទនាខន្ធ កើតឡើងហើយផង ក្នុងបញ្ចវោការភពនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ កើតឡើងហើយ ក្នុងទីណា រូបក្ខន្ធ កើតឡើងក្នុងទីនោះដែរឬ ។ វេទនាខន្ធ កើតឡើងហើយ ក្នុងអរូបភពនោះ ឯរូបក្ខន្ធមិនកើតឡើង ក្នុងទីនោះទេ វេទនាខន្ធ កើតឡើងហើយផង រូបក្ខន្ធ កើតឡើងផង ក្នុងបញ្ចវោការភពនោះ ។

[ ១៣៨ ] វេទនាខន្ធ កើតឡើង ក្នុងទីណា សញ្ញាខន្ធ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត សញ្ញាខន្ធ កើតឡើងហើយ ក្នុងទីណា វេទនាខន្ធ កើតឡើង ក្នុងទីនោះដែរឬ ។ អើ ។

[ ១៣៩ ] រូបក្ខន្ធ របស់សត្វណា កើតឡើង ក្នុងទីណា វេទនាខន្ធ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស ចូលទៅកាន់អសញ្ញសត្វ រូបក្ខន្ធ របស់សត្វទាំងនោះ កើតឡើងក្នុងទីនោះ ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសត្វក្រៅនេះ កាលចូលទៅកាន់បញ្ចវោការភព រូបក្ខន្ធ របស់សត្វទាំងនោះ កើតឡើងផង វេទនាខន្ធ កើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា កើតឡើងហើយ ក្នុងទីណា រូបក្ខន្ធ របស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកអរូបព្រហ្ម កាលច្យុតចាកបញ្ចវោការភព វេទនាខន្ធ របស់សត្វទាំងនោះ កើតឡើងហើយ ក្នុងទីនោះ ឯរូបក្ខន្ធរបស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលចូល

ទៅកាន់បញ្ចវោការភព វេទនាខន្ធរបស់សត្វទាំងនោះ កើតឡើងហើយផង រូបក្ខន្ធ កើតឡើងផង ក្នុងទីនោះ ។

[ ១៤០ ] វេទនាខន្ធ របស់សត្វណា កើតឡើង ក្នុងទីណា សញ្ញាខន្ធ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស វេទនាខន្ធរបស់សត្វទាំងនោះកើតឡើងក្នុងទីនោះ ឯសញ្ញាខន្ធ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសត្វក្រៅនេះ កាលចូលទៅកាន់ចតុវោការភព និងបញ្ចវោការភព វេទនាខន្ធ កើតឡើងផង សញ្ញាខន្ធរបស់សត្វទាំងនោះ កើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សញ្ញាខន្ធរបស់សត្វណា កើតឡើងហើយ ក្នុងទីណា វេទនាខន្ធរបស់សត្វនោះ កើតឡើងក្នុងទីនោះដែរឬ ។ ពួកសត្វ កាលច្យុតចាកចតុវោការភព និងបញ្ចវោការភព សញ្ញាខន្ធរបស់សត្វទាំងនោះ កើតឡើងហើយ ក្នុងទីនោះ ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនកើតឡើងក្នុងទីនោះទេ ពួកសត្វ កាលចូលទៅកាន់ចតុវោការភព និងបញ្ចវោការភព សញ្ញាខន្ធរបស់សត្វទាំងនោះ កើតឡើងហើយផង វេទនាខន្ធ កើតឡើងផង ក្នុងទីនោះ ។

[ ១៤១ ] រូបក្ខន្ធ របស់សត្វណា មិនកើតឡើង វេទនាខន្ធ របស់សត្វនោះ មិនកើតឡើងហើយដែរឬ ។ កើតឡើងហើយ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា មិនកើតឡើងហើយ រូបក្ខន្ធ របស់សត្វនោះ មិនកើតឡើងដែរឬ ។ មិនមានទេ ។

[ ១៤២ ] វេទនាខន្ធរបស់សត្វណា មិនកើតឡើង សញ្ញាខន្ធរបស់

សត្វនោះ មិនកើតឡើងហើយដែរឬ ។ កើតឡើងហើយ ។ មួយយ៉ាងទៀត សញ្ញាខន្ធរបស់សត្វណា មិនកើតឡើងហើយ វេទនាខន្ធរបស់សត្វនោះ មិនកើតឡើងដែរឬ ។ មិនមានទេ ។

[ ១៨៣ ] រូបក្ខន្ធ មិនកើតឡើង ក្នុងទីណា វេទនាខន្ធ មិនកើតឡើងហើយ ក្នុងទីនោះដែរឬ ។ កើតឡើងហើយ ។ មួយយ៉ាងទៀត វេទនាខន្ធ មិនកើតឡើងហើយ ក្នុងទីណា រូបក្ខន្ធ មិនកើតឡើង ក្នុងទីនោះដែរឬ ។ កើតឡើង ។

[ ១៨៤ ] វេទនាខន្ធ មិនកើតឡើង ក្នុងទីណា សញ្ញាខន្ធ មិនកើតឡើងហើយ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត សញ្ញាខន្ធ មិនកើតឡើងហើយ ក្នុងទីណា វេទនាខន្ធ មិនកើតឡើង ក្នុងទីនោះដែរឬ ។ អើ ។

[ ១៨៥ ] រូបក្ខន្ធ របស់សត្វណា មិនកើតឡើងក្នុងទីណា វេទនាខន្ធរបស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះដែរឬ ។ ពួកអរូបព្រហ្ម កាលច្យុតចាកបញ្ចវោការភព រូបក្ខន្ធរបស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះឯវេទនាខន្ធ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសត្វដែលបរិនិព្វាន ក្នុងសុទ្ធាវាស និងពួកសត្វដែលច្យុតចាកអសញ្ញសត្វ រូបក្ខន្ធ របស់សត្វទាំងនោះ មិនកើតឡើងផង វេទនាខន្ធ មិនកើតឡើងហើយផង ក្នុងទីនោះទេ ។ មួយយ៉ាងទៀត វេទនាខន្ធរបស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា រូបក្ខន្ធរបស់សត្វនោះ មិនកើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស និងពួកសត្វកាលចូលទៅកាន់អសញ្ញ-

សត្វ វេទនាខន្ធរបស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះ ឯរូបក្ខន្ធរបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលបរិនិព្វានក្នុងសុទ្ធាវាស និងពួកសត្វដែលច្យុតចាកអសញ្ញសត្វ វេទនាខន្ធរបស់សត្វទាំងនោះ មិនកើតឡើងហើយផង រូបក្ខន្ធ មិនកើតឡើងផង ក្នុងទីនោះទេ ។

[ ១៤៦ ] វេទនាខន្ធរបស់សត្វណា មិនកើតឡើង ក្នុងទីណា សញ្ញាខន្ធរបស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលច្យុតចាកចតុវោការភព និងបញ្ចវោការភព វេទនាខន្ធរបស់សត្វទាំងនោះ មិនកើតឡើងក្នុងទីនោះ ឯសញ្ញាខន្ធរបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយក្នុងទីនោះទេ ពួកសត្វដែលបរិនិព្វាន ក្នុងសុទ្ធាវាស និងពួកអសញ្ញសត្វ វេទនាខន្ធរបស់សត្វទាំងនោះ មិនកើតឡើងផង សញ្ញាខន្ធ មិនកើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សញ្ញាខន្ធរបស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា វេទនាខន្ធ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស សញ្ញាខន្ធ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះ ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលបរិនិព្វានក្នុងសុទ្ធាវាស និងពួកអសញ្ញសត្វ សញ្ញាខន្ធ របស់សត្វទាំងនោះ មិនកើតឡើងហើយផង វេទនាខន្ធ មិនកើតឡើងផង ក្នុងទីនោះ ។

[ ១៤៧ ] រូបក្ខន្ធ របស់សត្វណា កើតឡើង វេទនាខន្ធ របស់សត្វនោះ

នឹងកើតឡើងដែរឬ ។ ពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព រូបក្ខន្ធរបស់សត្វទាំងនោះ កើតឡើង ឯវេទនាខន្ធ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ ពួកសត្វក្រៅនេះ កាលចូលទៅកាន់បញ្ច-វោការភព និងចូលទៅកាន់អសញ្ញសត្វ រូបក្ខន្ធរបស់សត្វទាំងនោះ កើតឡើងផង វេទនាខន្ធ នឹងកើតឡើងផង ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា នឹងកើតឡើង រូបក្ខន្ធរបស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វទាំងពួង កាលច្យុត ចូលទៅកាន់អរូបព្រហ្ម វេទនាខន្ធរបស់សត្វទាំងនោះ នឹងកើតឡើង ឯរូបក្ខន្ធរបស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វ កាលចូលទៅកាន់បញ្ចវោការភព និងចូលទៅកាន់អសញ្ញសត្វ វេទនាខន្ធ របស់សត្វទាំងនោះ នឹងកើតឡើងផង រូបក្ខន្ធកើតឡើងផង ។

[ ១៤៨ ] វេទនាខន្ធ របស់សត្វណា កើតឡើង សញ្ញាខន្ធ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ វេទនាខន្ធ របស់សត្វទាំងនោះ កើតឡើង ឯសញ្ញាខន្ធ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ ពួកសត្វក្រៅនេះ កាលចូលទៅកាន់ចតុវោការភព និងបញ្ច-វោការភព វេទនាខន្ធ របស់សត្វទាំងនោះ កើតឡើងផង សញ្ញាខន្ធ នឹងកើតឡើងផង ។ មួយយ៉ាងទៀត សញ្ញាខន្ធរបស់សត្វណា នឹងកើតឡើង វេទនាខន្ធរបស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វទាំងពួង កាលច្យុត និងពួកសត្វកាលចូលទៅកាន់អសញ្ញសត្វ សញ្ញាខន្ធរបស់សត្វទាំងនោះ នឹងកើតឡើង ឯវេទនាខន្ធរបស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វ កាលចូលទៅកាន់

ចតុវោការភព និងបញ្ចវោការភព សញ្ញាខន្ធរបស់សត្វទាំងនោះ នឹងកើតឡើងផង វេទនាខន្ធ កើតឡើងផង ។

[ ១៤៩ ] រូបក្ខន្ធ កើតឡើងក្នុងទីណា វេទនាខន្ធ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ រូបក្ខន្ធ កើតឡើងក្នុងអសញ្ញសត្វនោះ ឯវេទនាខន្ធ នឹងមិនកើតឡើងក្នុងទីនោះទេ រូបក្ខន្ធ កើតឡើងផង វេទនាខន្ធ នឹងកើតឡើងផង ក្នុងបញ្ចវោការភពនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ នឹងកើតឡើង ក្នុងទីណា រូបក្ខន្ធ កើតឡើងក្នុងទីនោះដែរឬ ។ វេទនាខន្ធនឹងកើតឡើង ក្នុងអរូបភពនោះ ឯរូបក្ខន្ធ មិនកើតឡើងក្នុងទីនោះទេ វេទនាខន្ធ នឹងកើតឡើងផង រូបក្ខន្ធ កើតឡើងផង ក្នុងបញ្ចវោការភពនោះ ។

[ ១៥០ ] វេទនាខន្ធ កើតឡើងក្នុងទីណា សញ្ញាខន្ធ នឹងកើតឡើងក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត សញ្ញាខន្ធ នឹងកើតឡើង ក្នុងទីណា វេទនាខន្ធ កើតឡើងក្នុងទីនោះដែរឬ ។ អើ ។

[ ១៥១ ] រូបក្ខន្ធ របស់សត្វណា កើតឡើងក្នុងទីណា វេទនាខន្ធរបស់សត្វនោះ នឹងកើតឡើងក្នុងទីនោះដែរឬ ។ ពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព និងចូលទៅកាន់អសញ្ញសត្វ រូបក្ខន្ធរបស់សត្វទាំងនោះ កើតឡើងក្នុងទីនោះ ឯវេទនាខន្ធរបស់សត្វទាំងនោះ នឹងមិនកើតឡើងក្នុងទីនោះទេ ពួកសត្វក្រៅនេះ កាលចូលទៅកាន់បញ្ចវោការភព រូបក្ខន្ធរបស់សត្វទាំងនោះ កើតឡើងផង វេទនាខន្ធ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា នឹងកើតឡើង

ក្នុងទីណា រូបក្ខន្ធរបស់សត្វនោះ កើតឡើងក្នុងទីនោះដែរឬ ។ ពួកអរូបព្រហ្ម កាលច្យុតចាកបញ្ចវោការភព វេទនាខន្ធ របស់សត្វទាំងនោះ នឹងកើតឡើង ក្នុងទីនោះ ឯរូបក្ខន្ធ របស់សត្វទាំងនោះ មិនកើតឡើងក្នុងទីនោះទេ ពួកសត្វ កាលចូលទៅកាន់បញ្ចវោការភព វេទនាខន្ធរបស់សត្វទាំងនោះ នឹងកើត ឡើងផង រូបក្ខន្ធកើតឡើងផង ក្នុងទីនោះ ។

[ ១៥២ ] វេទនាខន្ធ របស់សត្វណា កើតឡើង ក្នុងទីណា សញ្ញាខន្ធ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វដែលកើតក្នុង បច្ឆិមភព កាលចាប់បដិសន្ធិ វេទនាខន្ធរបស់សត្វទាំងនោះ កើតឡើងក្នុង ទីនោះ ឯសញ្ញាខន្ធរបស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ពួក សត្វក្រៅនេះ កាលចូលទៅកាន់ចតុវោការភព និងបញ្ចវោការភព វេទនាខន្ធ របស់សត្វទាំងនោះ កើតឡើងផង សញ្ញាខន្ធ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សញ្ញាខន្ធរបស់សត្វណា នឹងកើតឡើង ក្នុងទីណា វេទនា-ខន្ធរបស់សត្វនោះ កើតឡើងក្នុងទីនោះដែរឬ ។ ពួកសត្វ កាលច្យុតចាកចតុ-វោការភព និងបញ្ចវោការភព សញ្ញាខន្ធរបស់សត្វទាំងនោះ នឹងកើតឡើង ក្នុងទីនោះ ឯវេទនាខន្ធរបស់សត្វទាំងនោះ មិនកើតឡើងក្នុងទីនោះទេ ពួក សត្វ កាលចូលទៅកាន់ចតុវោការភព និងបញ្ចវោការភព សញ្ញាខន្ធរបស់ សត្វទាំងនោះ នឹងកើតឡើងផង វេទនាខន្ធ កើតឡើងផង ក្នុងទីនោះ ។

[ ១៥៣ ] រូបក្ខន្ធ របស់សត្វណា មិនកើតឡើង វេទនាខន្ធ របស់សត្វ នោះ នឹងមិនកើតឡើងដែរឬ ។ ពួកសត្វទាំងពួង កាលច្យុត ចូលទៅកាន់

អរូបភព រូបក្ខន្ធរបស់សត្វទាំងនោះ មិនកើតឡើង ឯវេទនាខន្ធរបស់សត្វទាំងនោះ នឹងមិនមែនជាមិនកើតឡើងទេ ពួកសត្វដែលបរិនិព្វាន ក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបព្រហ្ម រូបក្ខន្ធរបស់សត្វទាំងនោះ មិនកើតឡើងផង វេទនាខន្ធ នឹងមិនកើតឡើងផង ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា នឹងមិនកើតឡើង រូបក្ខន្ធ របស់សត្វនោះ មិនកើតឡើងដែរឬ ។ ពួកសត្វដែលកើតឡើងក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព វេទនាខន្ធរបស់សត្វទាំងនោះ នឹងមិនកើតឡើង ឯរូបក្ខន្ធរបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ពួកសត្វដែលបរិនិព្វានក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបព្រហ្ម វេទនាខន្ធរបស់សត្វទាំងនោះ នឹងមិនកើតឡើងផង រូបក្ខន្ធ មិនកើតឡើងផង ។

[ ១៥៤ ] វេទនាខន្ធ របស់សត្វណា មិនកើតឡើង សញ្ញាខន្ធ របស់សត្វនោះ នឹងមិនកើតឡើងដែរឬ ។ ពួកសត្វទាំងពួង កាលច្យុត ចូលទៅកាន់អសញ្ញសត្វ វេទនាខន្ធរបស់សត្វទាំងនោះ មិនកើតឡើង ឯសញ្ញាខន្ធរបស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ វេទនាខន្ធ របស់សត្វទាំងនោះ ដែលបរិនិព្វាន មិនកើតឡើងផង សញ្ញាខន្ធ នឹងមិនកើតឡើងផង ។ មួយយ៉ាងទៀត សញ្ញាខន្ធរបស់សត្វណា នឹងមិនកើតឡើង វេទនាខន្ធ របស់សត្វនោះ មិនកើតឡើងដែរឬ ។ ពួកសត្វ ដែលកើតឡើងក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព សញ្ញាខន្ធរបស់សត្វទាំងនោះ នឹងមិនកើតឡើង ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ សញ្ញាខន្ធ របស់

សត្វទាំងនោះ ដែលបរិនិព្វាន នឹងមិនកើតឡើងផង វេទនាខន្ធ មិនកើតឡើងផង ៗ

[ ១៥៥ ] រូបក្ខន្ធ មិនកើតឡើងក្នុងទីណា វេទនាខន្ធ នឹងមិនកើតឡើងក្នុងទីនោះដែរឬ ។ នឹងកើតឡើង ។ មួយយ៉ាងទៀត វេទនាខន្ធ នឹងមិនកើតឡើង ក្នុងទីណា រូបក្ខន្ធ មិនកើតឡើងក្នុងទីនោះដែរឬ ។ កើតឡើង ។

[ ១៥៦ ] វេទនាខន្ធ មិនកើតឡើង ក្នុងទីណា សញ្ញាខន្ធ នឹងមិនកើតឡើង ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត សញ្ញាខន្ធ នឹងមិនកើតឡើងក្នុងទីណា វេទនាខន្ធ មិនកើតឡើងក្នុងទីនោះដែរឬ ។ អើ ។

[ ១៥៧ ] រូបក្ខន្ធ របស់សត្វណា មិនកើតឡើងក្នុងទីណា វេទនាខន្ធរបស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះដែរឬ ។ ពួកអរូបព្រហ្ម កាលច្យុតចាកបញ្ចវោការភព រូបក្ខន្ធរបស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ ឯវេទនាខន្ធរបស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងក្នុងទីនោះទេ ពួកសត្វដែលបរិនិព្វានក្នុងបញ្ចវោការភព ពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបព្រហ្ម និងពួកសត្វដែលច្យុតចាកអសញ្ញសត្វ រូបក្ខន្ធ របស់សត្វទាំងនោះ មិនកើតឡើងផង វេទនាខន្ធ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា រូបក្ខន្ធរបស់សត្វនោះ មិនកើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព និងចូលទៅកាន់អសញ្ញសត្វ វេទនាខន្ធរបស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ ឯរូបក្ខន្ធរបស់សត្វ

ទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលបរិនិព្វានក្នុងបញ្ចវោការភព ពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបព្រហ្ម និងពួកសត្វដែលច្យុតចាកអសញ្ញសត្វ វេទនាខន្ធរបស់សត្វទាំងនោះ នឹងមិនកើតឡើងផង រូបក្ខន្ធ មិនកើតឡើងផង ក្នុងទីនោះ ។

[ ១៥៨ ] វេទនាខន្ធ របស់សត្វណា មិនកើតឡើង ក្នុងទីណា សញ្ញាខន្ធរបស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលច្យុតចាកចតុវោការភព និងបញ្ចវោការភព វេទនាខន្ធ របស់សត្វទាំងនោះ មិនកើតឡើងក្នុងទីនោះទេ ឯសញ្ញាខន្ធ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលបរិនិព្វាន និងពួកអសញ្ញសត្វ វេទនាខន្ធរបស់សត្វទាំងនោះ មិនកើតឡើងផង សញ្ញាខន្ធ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សញ្ញាខន្ធរបស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា វេទនាខន្ធរបស់សត្វនោះ មិនកើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ សញ្ញាខន្ធរបស់សត្វទាំងនោះ នឹងមិនកើតឡើងក្នុងទីនោះ ឯវេទនាខន្ធរបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ សញ្ញាខន្ធរបស់ពួកសត្វដែលបរិនិព្វាន និងពួកអសញ្ញសត្វនោះ នឹងមិនកើតឡើងផង វេទនាខន្ធ មិនកើតឡើងផង ក្នុងទីនោះ ។

[ ១៥៩ ] រូបក្ខន្ធរបស់សត្វណា កើតឡើងហើយ វេទនាខន្ធ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ ពួកសត្វ ដែលកើតក្នុងបច្ឆិមភព រូបក្ខន្ធរបស់សត្វទាំងនោះ កើតឡើងហើយ ឯវេទនាខន្ធ របស់សត្វទាំងនោះ នឹងមិនកើត

ឡើងទេ រូបក្ខន្ធរបស់សត្វទាំងនោះក្រៅនេះ កើតឡើងហើយផង វេទនាខន្ធនឹងកើតឡើងផង ។ មួយយ៉ាងទៀត វេទនាខន្ធរបស់សត្វណា នឹងកើតឡើង រូបក្ខន្ធរបស់សត្វនោះ កើតឡើងហើយដែរឬ ។ អើ ។

[ ១៦០ ] វេទនាខន្ធ របស់សត្វណា កើតឡើងហើយ សញ្ញាខន្ធរបស់សត្វនោះ នឹងកើតឡើងដែរឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព វេទនាខន្ធរបស់សត្វទាំងនោះ កើតឡើងហើយ ឯសញ្ញាខន្ធរបស់សត្វទាំងនោះ នឹងមិនកើតឡើងទេ វេទនាខន្ធរបស់សត្វទាំងនោះ ក្រៅនេះ កើតឡើងហើយផង សញ្ញាខន្ធនឹងកើតឡើងផង ។ មួយយ៉ាងទៀត សញ្ញាខន្ធរបស់សត្វណា នឹងកើតឡើង វេទនាខន្ធរបស់សត្វនោះ កើតឡើងហើយដែរឬ ។ អើ ។

[ ១៦១ ] រូបក្ខន្ធ កើតឡើងហើយ ក្នុងទីណា វេទនាខន្ធ នឹងកើតឡើងក្នុងទីនោះដែរឬ ។ រូបក្ខន្ធកើតឡើងហើយ ក្នុងអសញ្ញសត្វនោះ ឯវេទនាខន្ធនឹងមិនកើតឡើង ក្នុងទីនោះទេ រូបក្ខន្ធកើតឡើងហើយផង វេទនាខន្ធ នឹងកើតឡើងផង ក្នុងបញ្ចវោការភពនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ នឹងកើតឡើង ក្នុងទីណា រូបក្ខន្ធកើតឡើងហើយ ក្នុងទីនោះដែរឬ ។ វេទនាខន្ធ នឹងកើតឡើង ក្នុងអរូបភពនោះ ឯរូបក្ខន្ធមិនកើតឡើងហើយ ក្នុងទីនោះទេ វេទនាខន្ធនឹងកើតឡើងផង រូបក្ខន្ធកើតឡើងហើយផង ក្នុងបញ្ចវោការភពនោះ ។

[ ១៦២ ] វេទនាខន្ធ កើតឡើងហើយ ក្នុងទីណា សញ្ញាខន្ធ នឹងកើតឡើងក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត សញ្ញាខន្ធ នឹងកើតឡើងក្នុងទីណា វេទនាខន្ធ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ អើ ។

[ ១៦៣ ] រូបក្ខន្ធ របស់សត្វណា កើតឡើងហើយ ក្នុងទីណា វេទនាខន្ធ របស់សត្វនោះ នឹងកើតឡើងក្នុងទីនោះដែរឬ ។ ពួកសត្វ ដែលកើតក្នុងបច្ឆិមភព ក្នុងបញ្ចវោការភព និងពួកអសញ្ញសត្វ រូបក្ខន្ធរបស់សត្វទាំងនោះ កើតឡើងហើយ ក្នុងទីនោះ ឯវេទនាខន្ធ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វក្រៅនេះ ដែលកើតក្នុងបញ្ចវោការភព រូបក្ខន្ធរបស់សត្វទាំងនោះ កើតឡើងហើយផង វេទនាខន្ធ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វេទនាខន្ធរបស់សត្វណា នឹងកើតឡើងក្នុងទីណា រូបក្ខន្ធ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ វេទនាខន្ធ របស់ពួកអរូបព្រហ្មទាំងនោះ នឹងកើតឡើងក្នុងទីនោះ ឯរូបក្ខន្ធ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ វេទនាខន្ធរបស់សត្វទាំងនោះ ដែលកើតក្នុងបញ្ចវោការភព នឹងកើតឡើងផង រូបក្ខន្ធ កើតឡើងហើយផង ក្នុងទីនោះ ។

[ ១៦៤ ] វេទនាខន្ធ របស់សត្វណា កើតឡើងហើយក្នុងទីណា សញ្ញាខន្ធ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ វេទនាខន្ធ របស់ពួកសត្វ កើតឡើងហើយ ក្នុងទីនោះ ដែលកើតក្នុងបច្ឆិមភពនោះ ឯសញ្ញាខន្ធរបស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វក្រៅនេះ ( ដែលកើត ) ក្នុងចតុវោការភព និងបញ្ចវោការភព វេទនាខន្ធរបស់សត្វទាំងនោះ កើតឡើងហើយផង សញ្ញាខន្ធ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សញ្ញាខន្ធ របស់សត្វណា នឹងកើតឡើង ក្នុងទីណា វេទនាខន្ធ របស់សត្វនោះ នឹងកើតឡើងហើយ ក្នុងទីនោះដែរឬ ។ អើ ។

[ ១៦៥ ] រូបក្ខន្ធ របស់សត្វណា មិនកើតឡើងហើយ វេទនាខន្ធរបស់សត្វនោះ នឹងមិនកើតឡើងដែរឬ ។ មិនមានទេ ។ មួយយ៉ាងទៀត វេទនាខន្ធរបស់សត្វណា នឹងមិនកើតឡើង រូបក្ខន្ធរបស់សត្វនោះ មិនកើតឡើងហើយដែរឬ ។ កើតឡើងហើយ ។

[ ១៦៦ ] វេទនាខន្ធ របស់សត្វណា មិនកើតឡើងហើយ សញ្ញាខន្ធរបស់សត្វនោះ នឹងមិនកើតឡើងដែរឬ ។ មិនមានទេ ។ មួយយ៉ាងទៀត សញ្ញាខន្ធ របស់សត្វណា នឹងមិនកើតឡើង វេទនាខន្ធ របស់សត្វនោះ មិនកើតឡើងហើយដែរឬ ។ កើតឡើងហើយ ។

[ ១៦៧ ] រូបក្ខន្ធ មិនកើតឡើងហើយ ក្នុងទីណា វេទនាខន្ធ នឹងមិនកើតឡើង ក្នុងទីនោះដែរឬ ។ នឹងកើតឡើង ។ មួយយ៉ាងទៀត វេទនាខន្ធនឹងមិនកើតឡើងក្នុងទីណា រូបក្ខន្ធ មិនកើតឡើងហើយ ក្នុងទីនោះដែរឬ ។ កើតឡើងហើយ ។

[ ១៦៨ ] វេទនាខន្ធ មិនកើតឡើងហើយក្នុងទីណា សញ្ញាខន្ធ នឹងមិនកើតឡើងក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត សញ្ញាខន្ធ នឹងមិនកើតឡើងក្នុងទីណា វេទនាខន្ធ មិនកើតឡើងហើយ ក្នុងទីនោះដែរឬ ។ អើ ។

[ ១៦៩ ] រូបក្ខន្ធ របស់សត្វណា មិនកើតឡើងហើយក្នុងទីណា វេទនាខន្ធរបស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះដែរឬ ។ ពួកអរូបព្រហ្ម រូបក្ខន្ធរបស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះ ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសុទ្ធាវាសសត្វ និង

ពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព រូបក្ខន្ធរបស់សត្វទាំងនោះ មិនកើតឡើងផង វេទនាខន្ធ នឹងមិនកើតឡើងផងក្នុងទីនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា រូបក្ខន្ធ របស់សត្វនោះ មិនកើតឡើងហើយក្នុងទីនោះដែរឬ ។ ពួកសត្វ ដែលកើតក្នុងបច្ឆិមភព ក្នុងបញ្ចវោការភព និងពួកអសញ្ញសត្វ វេទនាខន្ធ របស់សត្វទាំងនោះ នឹងមិនកើតឡើងក្នុងទីនោះ ឯរូបក្ខន្ធរបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសុទ្ធាវាសសត្វ និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព វេទនាខន្ធរបស់សត្វទាំងនោះ នឹងមិនកើតឡើងផង រូបក្ខន្ធមិនកើតឡើងហើយផង ក្នុងទីនោះ ។

[ ១៧០ ] វេទនាខន្ធ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា សញ្ញាខន្ធ របស់សត្វនោះ នឹងមិនកើតឡើងក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត សញ្ញាខន្ធរបស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា វេទនាខន្ធរបស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះដែរឬ ។ ពួកសត្វ ដែលកើតក្នុងបច្ឆិមភព សញ្ញាខន្ធរបស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ ពួកអសញ្ញសត្វ ដែលកើតក្នុងសុទ្ធាវាស សញ្ញាខន្ធរបស់សត្វទាំងនោះ នឹងមិនកើតឡើងផង វេទនាខន្ធ មិនកើតឡើងហើយផង ក្នុងទីនោះ ។

**ឧប្បាទវារៈ ចប់**

[ ១៧១ ] រូបក្ខន្ធ របស់សត្វណារលត់ទៅ វេទនាខន្ធ របស់សត្វនោះ

រលត់ទៅដែរឬ ។ ពួកសត្វដែលច្យុតចាកអសញ្ញសត្វ រូបក្ខន្ធរបស់សត្វទាំងនោះ រមែងរលត់ទៅ ឯវេទនាខន្ធរបស់សត្វទាំងនោះ មិនមែនរលត់ទៅទេ ពួកសត្វដែលច្យុតចាកបញ្ចវោការភព រូបក្ខន្ធរបស់សត្វទាំងនោះ រលត់ទៅផង វេទនាខន្ធរលត់ទៅផង ។ មួយយ៉ាងទៀត វេទនាខន្ធរបស់សត្វណា រលត់ទៅ រូបក្ខន្ធរបស់សត្វនោះ រលត់ទៅដែរឬ ។ ពួកសត្វដែលច្យុតចាកអរូបភព វេទនាខន្ធរបស់សត្វទាំងនោះរលត់ទៅ ឯរូបក្ខន្ធ របស់សត្វទាំងនោះ មិនមែនរលត់ទៅទេ ពួកសត្វដែលច្យុតចាកបញ្ចវោការភព វេទនាខន្ធរបស់សត្វទាំងនោះ រលត់ទៅផង រូបក្ខន្ធរលត់ទៅផង ។

[ ១៧២ ] រូបក្ខន្ធ រលត់ទៅក្នុងទីណា វេទនាខន្ធ រលត់ទៅ ក្នុងទីនោះដែរឬ ។ រូបក្ខន្ធ រលត់ទៅ ក្នុងអសញ្ញសត្វនោះ ឯវេទនាខន្ធ មិនរលត់ទៅក្នុងទីនោះទេ រូបក្ខន្ធ រលត់ទៅផង វេទនាខន្ធ រលត់ទៅផង ក្នុងបញ្ចវោ-ការភពនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ រលត់ទៅក្នុងទីណា រូបក្ខន្ធ រលត់ទៅ ក្នុងទីនោះដែរឬ ។ វេទនាខន្ធ រលត់ទៅ ក្នុងអរូបភពនោះ ឯរូបក្ខន្ធ មិនរលត់ទៅក្នុងទីនោះទេ វេទនាខន្ធ រលត់ទៅផង រូបក្ខន្ធ រលត់ទៅផង ក្នុងបញ្ចវោការភពនោះ ។

[ ១៧៣ ] រូបក្ខន្ធ របស់សត្វណា រលត់ទៅក្នុងទីណា វេទនាខន្ធរបស់សត្វនោះ រលត់ទៅក្នុងទីនោះដែរឬ ។ ពួកសត្វ ដែលច្យុតចាកអសញ្ញសត្វ រូបក្ខន្ធរបស់សត្វទាំងនោះ រលត់ទៅក្នុងទីនោះ ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនរលត់ទៅក្នុងទីនោះទេ ពួកសត្វដែលច្យុតចាកបញ្ចវោការភព រូបក្ខន្ធ

របស់សត្វទាំងនោះ រលត់ទៅផង វេទនាខន្ធរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា រលត់ទៅក្នុងទីណា រូបក្ខន្ធ របស់សត្វនោះ រលត់ទៅក្នុងទីនោះដែរឬ ។ ពួកសត្វដែលច្យុតចាកអរូបភព វេទនាខន្ធ របស់សត្វទាំងនោះ រលត់ទៅក្នុងទីនោះ ឯរូបក្ខន្ធ របស់សត្វទាំងនោះ មិនមែនរលត់ទៅក្នុងទីនោះទេ ពួកសត្វ ដែលច្យុតចាកបញ្ចវោការភព វេទនាខន្ធរបស់សត្វទាំងនោះ រលត់ទៅផង រូបក្ខន្ធរលត់ទៅផង ក្នុងទីនោះ ។

[ ១៧៤ ] រូបក្ខន្ធ របស់សត្វណា មិនរលត់ទៅ វេទនាខន្ធ របស់សត្វនោះ មិនរលត់ទៅដែរឬ ។ ពួកសត្វដែលច្យុតចាកអរូបភព រូបក្ខន្ធ របស់សត្វទាំងនោះ មិនរលត់ទៅ ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វទាំងអស់ កាលចាប់បដិសន្ធិ រូបក្ខន្ធ របស់សត្វទាំងនោះ មិនរលត់ទៅផង វេទនាខន្ធមិនរលត់ទៅផង ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា មិនរលត់ទៅ រូបក្ខន្ធរបស់សត្វនោះ មិនរលត់ទៅដែរឬ ។ ពួកសត្វ ដែលច្យុតចាកអសញ្ញសត្វ វេទនាខន្ធរបស់សត្វទាំងនោះ មិនរលត់ទៅ ឯរូបក្ខន្ធរបស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វទាំងអស់ កាលចាប់បដិសន្ធិ វេទនាខន្ធ របស់សត្វទាំងនោះ មិនរលត់ទៅផង រូបក្ខន្ធ មិនរលត់ទៅផង ។

[ ១៧៥ ] រូបក្ខន្ធមិនរលត់ទៅ ក្នុងទីណា វេទនាខន្ធ មិនរលត់ទៅ ក្នុងទីនោះដែរឬ ។ រលត់ទៅ ។ មួយយ៉ាងទៀត វេទនាខន្ធ មិនរលត់ទៅ ក្នុងទីណា រូបក្ខន្ធ មិនរលត់ទៅ ក្នុងទីនោះដែរឬ ។ រលត់ទៅ ។

[ ១៧៦ ] រូបក្ខន្ធ របស់សត្វណា មិនរលត់ទៅ ក្នុងទីណា វេទនាខន្ធ របស់សត្វនោះ មិនរលត់ទៅក្នុងទីនោះដែរឬ ។ ពួកសត្វដែលច្យុតចាកអរូបភព រូបក្ខន្ធ របស់សត្វទាំងនោះ មិនរលត់ទៅក្នុងទីនោះ ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅក្នុងទីនោះទេ ពួកសត្វទាំងអស់ កាលចាប់បដិសន្ធិ រូបក្ខន្ធរបស់សត្វទាំងនោះ មិនរលត់ទៅផង វេទនាខន្ធ មិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា មិនរលត់ទៅក្នុងទីណា រូបក្ខន្ធ របស់សត្វនោះ មិនរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលច្យុតចាកអសញ្ញសត្វ វេទនាខន្ធរបស់សត្វទាំងនោះ មិនរលត់ទៅក្នុងទីនោះ ឯរូបក្ខន្ធរបស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វទាំងអស់ កាលចាប់បដិសន្ធិ វេទនាខន្ធរបស់សត្វទាំងនោះ មិនរលត់ទៅផង រូបក្ខន្ធមិនរលត់ទៅផង ក្នុងទីនោះ ។

[ ១៧៧ ] រូបក្ខន្ធ របស់សត្វណា រលត់ហើយ វេទនាខន្ធ របស់សត្វនោះ រលត់ហើយដែរឬ ។ អើ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា រលត់ហើយ រូបក្ខន្ធ របស់សត្វនោះ រលត់ដែរឬ ។ អើ ។

[ ១៧៨ ] រូបក្ខន្ធរលត់ហើយ ក្នុងទីណា វេទនាខន្ធរលត់ហើយ ក្នុងទីនោះដែរឬ ។ រូបក្ខន្ធរលត់ហើយ ក្នុងអសញ្ញសត្វនោះ ឯវេទនាខន្ធ មិនរលត់ហើយ ក្នុងទីនោះទេ រូបក្ខន្ធរលត់ហើយផង វេទនាខន្ធរលត់ហើយផង ក្នុងបញ្ចវោការភពនោះ ។ មួយយ៉ាងទៀត វេទនាខន្ធរលត់ហើយ ក្នុងទីណា រូបក្ខន្ធរលត់ហើយ ក្នុងទីនោះដែរឬ ។ វេទនាខន្ធរលត់ហើយ ក្នុងអរូបភព

នោះ ឯរូបក្ខន្ធមិនរលត់ហើយ ក្នុងទីនោះទេ វេទនាខន្ធ រលត់ហើយផង រូបក្ខន្ធរលត់ហើយផង ក្នុងបញ្ចវោការភពនោះ ។

[ ១៧៩ ] រូបក្ខន្ធរបស់សត្វណា រលត់ហើយ ក្នុងទីណា វេទនាខន្ធរបស់សត្វនោះ រលត់ហើយ ក្នុងទីនោះដែរឬ ។ រូបក្ខន្ធរបស់អសញ្ញសត្វទាំងនោះ រលត់ហើយក្នុងទីនោះ ឯវេទនាខន្ធរបស់សត្វទាំងនោះ មិនរលត់ហើយក្នុងទីនោះទេ រូបក្ខន្ធរបស់ពួកសត្វ ក្នុងបញ្ចវោការភពនោះ រលត់ហើយផង វេទនាខន្ធរលត់ហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា រលត់ហើយ ក្នុងទីណា រូបក្ខន្ធរបស់សត្វនោះ រលត់ហើយ ក្នុងទីនោះដែរឬ ។ វេទនាខន្ធរបស់អរូបព្រហ្មទាំងនោះ រលត់ហើយ ក្នុងទីនោះ ឯរូបក្ខន្ធ របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះទេ វេទនាខន្ធរបស់ពួកសត្វ ក្នុងបញ្ចវោការភពនោះ រលត់ហើយផង រូបក្ខន្ធរលត់ហើយផង ក្នុងទីនោះ ។

[ ១៨០ ] រូបក្ខន្ធរបស់សត្វណា មិនរលត់ហើយ វេទនាខន្ធរបស់សត្វនោះ មិនរលត់ហើយដែរឬ ។ មិនមានទេ ។ មួយយ៉ាងទៀត វេទនាខន្ធរបស់សត្វណា មិនរលត់ហើយ រូបក្ខន្ធរបស់សត្វនោះ មិនរលត់ហើយដែរឬ ។ មិនមានទេ ។

[ ១៨១ ] រូបក្ខន្ធមិនរលត់ហើយ ក្នុងទីណា វេទនាខន្ធមិនរលត់ហើយ ក្នុងទីនោះដែរឬ ។ រលត់ហើយ ។ មួយយ៉ាងទៀត វេទនាខន្ធមិនរលត់ហើយ ក្នុងទីណា រូបក្ខន្ធមិនរលត់ហើយ ក្នុងទីនោះដែរឬ ។ រលត់ហើយ ។

[ ១៨២ ] រូបក្ខន្ធរបស់សត្វណា មិនរលត់ហើយ ក្នុងទីណា វេទនាខន្ធរបស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះដែរឬ ។ រូបក្ខន្ធ របស់អរូបព្រហ្មទាំងនោះ មិនរលត់ហើយក្នុងទីនោះ ឯវេទនាខន្ធរបស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយ ក្នុងទីនោះទេ រូបក្ខន្ធ របស់ពួកសុទ្ធាវាសសត្វនោះ មិនរលត់ហើយផង វេទនាខន្ធមិនរលត់ហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វេទនាខន្ធរបស់សត្វណា មិនរលត់ហើយ ក្នុងទីណា រូបក្ខន្ធ របស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះដែរឬ ។ វេទនាខន្ធរបស់អសញ្ញសត្វទាំងនោះ មិនរលត់ហើយក្នុងទីនោះ ឯរូបក្ខន្ធ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយក្នុងទីនោះទេ វេទនាខន្ធរបស់ពួកសុទ្ធាវាសសត្វនោះ មិនរលត់ហើយផង រូបក្ខន្ធមិនរលត់ហើយផង ក្នុងទីនោះ ។

[ ១៨៣ ] រូបក្ខន្ធ របស់សត្វណា នឹងរលត់ទៅ វេទនាខន្ធ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ អើ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា នឹងរលត់ទៅ រូបក្ខន្ធរបស់សត្វនោះ នឹងរលត់ទៅដែរឬ ។ បណ្តាពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលកាន់អរូបភព សត្វទាំងឡាយណា ចូលកាន់អរូបភពហើយ នឹងបរិនិព្វាន កាលសត្វទាំងនោះ កំពុងច្យុត វេទនាខន្ធរបស់ពួកសត្វនោះ នឹងរលត់ទៅ ឯរូបក្ខន្ធ របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ វេទនាខន្ធរបស់សត្វទាំងនោះ ក្រៅនេះ នឹងរលត់ទៅផង រូបក្ខន្ធ នឹងរលត់ទៅផង ។

[ ១៨៤ ] រូបក្ខន្ធ នឹងរលត់ទៅ ក្នុងទីណា វេទនាខន្ធ នឹងរលត់ទៅ

ក្នុងទីនោះដែរឬ ។ រូបក្ខន្ធ នឹងរលត់ទៅក្នុងអសញ្ញសត្វនោះ ឯវេទនាខន្ធ នឹងមិនរលត់ទៅក្នុងទីនោះទេ រូបក្ខន្ធ នឹងរលត់ទៅផង វេទនាខន្ធ នឹងរលត់ទៅផង ក្នុងបញ្ចវោការភពនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ នឹងរលត់ទៅក្នុងទីណា រូបក្ខន្ធ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ វេទនាខន្ធ នឹងរលត់ទៅក្នុងអរូបភពនោះ ឯរូបក្ខន្ធ នឹងមិនរលត់ទៅក្នុងទីនោះទេ វេទនាខន្ធ នឹងរលត់ទៅផង រូបក្ខន្ធ នឹងរលត់ទៅផង ក្នុងបញ្ចវោការភពនោះ ។

[ ១៨៥ ] រូបក្ខន្ធ របស់សត្វណា នឹងរលត់ទៅក្នុងទីណា វេទនាខន្ធ របស់សត្វនោះ នឹងរលត់ទៅក្នុងទីនោះដែរឬ ។ រូបក្ខន្ធ របស់អសញ្ញសត្វទាំងនោះ នឹងរលត់ទៅក្នុងទីនោះ ឯវេទនាខន្ធ របស់សត្វទាំងនោះ នឹងមិនរលត់ទៅក្នុងទីនោះទេ រូបក្ខន្ធ របស់ពួកសត្វ ក្នុងបញ្ចវោការភពនោះ នឹងរលត់ទៅផង វេទនាខន្ធ នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា រូបក្ខន្ធ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ វេទនាខន្ធ របស់អរូបព្រហ្មទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ ឯរូបក្ខន្ធ របស់សត្វទាំងនោះ នឹងមិនរលត់ទៅក្នុងទីនោះទេ វេទនាខន្ធ របស់ពួកសត្វ ក្នុងបញ្ចវោការភពនោះ នឹងរលត់ទៅផង រូបក្ខន្ធ នឹងរលត់ទៅផង ក្នុងទីនោះ ។

[ ១៨៦ ] រូបក្ខន្ធ របស់សត្វណា នឹងមិនរលត់ទៅ វេទនាខន្ធ របស់សត្វនោះ នឹងមិនរលត់ដែរឬ ។ បណ្ដាពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់អរូបភព សត្វទាំងឡាយណា ចូលទៅកាន់អរូបភពហើយ នឹង

បរិនិព្វាន កាលសត្វទាំងនោះ កំពុងច្យុត រូបក្ខន្ធរបស់ពួកសត្វទាំងនោះ នឹងមិនរលត់ទៅ ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ ពួកសត្វ កាលបរិនិព្វាន រូបក្ខន្ធរបស់ពួកសត្វទាំងនោះ នឹងមិនរលត់ទៅផង វេទនាខន្ធនឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា នឹងមិនរលត់ទៅ រូបក្ខន្ធរបស់សត្វនោះ នឹងមិនរលត់ទៅដែរឬ ។ អើ ។

[ ១៨៧ ] រូបក្ខន្ធ នឹងមិនរលត់ទៅក្នុងទីណា វេទនាខន្ធ នឹងមិនរលត់ទៅក្នុងទីនោះដែរឬ ។ នឹងរលត់ទៅ ។ មួយយ៉ាងទៀត វេទនាខន្ធ នឹងមិនរលត់ទៅក្នុងទីណា រូបក្ខន្ធ នឹងមិនរលត់ទៅក្នុងទីនោះដែរឬ ។ នឹងរលត់ទៅ ។

[ ១៨៨ ] រូបក្ខន្ធរបស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា វេទនាខន្ធរបស់សត្វនោះ នឹងមិនរលត់ទៅក្នុងទីនោះដែរឬ ។ រូបក្ខន្ធរបស់អរូបព្រហ្មទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន រូបក្ខន្ធ របស់ពួកសត្វទាំងនោះ នឹងមិនរលត់ទៅផង វេទនាខន្ធ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វេទនាខន្ធរបស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា រូបក្ខន្ធរបស់សត្វនោះ នឹងមិនរលត់ទៅក្នុងទីនោះទេឬ ។ វេទនាខន្ធ របស់អសញ្ញសត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ ឯរូបក្ខន្ធ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន វេទនាខន្ធរបស់សត្វទាំងនោះ នឹងមិនរលត់ទៅផង រូបក្ខន្ធ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។

[ ១៨៩ ] រូបក្ខន្ធរបស់សត្វណា រលត់ទៅ វេទនាខន្ធរបស់សត្វនោះ រលត់ហើយដែរឬ ។ អើ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណារលត់ហើយ រូបក្ខន្ធរបស់សត្វនោះ រលត់ទៅដែរឬ ។ ពួកសត្វទាំងអស់ កាលចាប់បដិសន្ធិ វេទនាខន្ធ របស់សត្វទាំងនោះ រលត់ហើយ ឯរូបក្ខន្ធ របស់សត្វទាំងនោះ មិនរលត់ទៅទេ ពួកសត្វ កាលច្យុតចាកបញ្ចវោការភព កាលច្យុតចាកអសញ្ញសត្វ វេទនាខន្ធ របស់សត្វទាំងនោះ រលត់ហើយផង រូបក្ខន្ធ រលត់ទៅផង ។

[ ១៩០ ] វេទនាខន្ធ របស់សត្វណា រលត់ទៅ សញ្ញាខន្ធ របស់សត្វនោះ រលត់ទៅហើយដែរឬ ។ អើ ។ មួយយ៉ាងទៀត សញ្ញាខន្ធ របស់សត្វណា រលត់ហើយ វេទនាខន្ធ របស់សត្វនោះ រលត់ទៅដែរឬ ។ ពួកសត្វទាំងអស់ កាលចាប់បដិសន្ធិ កាលច្យុតចាកអសញ្ញសត្វ សញ្ញាខន្ធរបស់សត្វទាំងនោះ រលត់ហើយ ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនរលត់ទៅទេ ពួកសត្វ កាលច្យុតចាកចតុវោការភព និងបញ្ចវោការភព សញ្ញាខន្ធរបស់សត្វទាំងនោះ រលត់ហើយផង វេទនាខន្ធរលត់ទៅផង ។

[ ១៩១ ] រូបក្ខន្ធ រលត់ទៅ ក្នុងទីណា វេទនាខន្ធ រលត់ហើយ ក្នុងទីនោះដែរឬ ។ រូបក្ខន្ធ រលត់ទៅ ក្នុងអសញ្ញសត្វនោះ ឯវេទនាខន្ធ មិនរលត់ហើយ ក្នុងទីនោះទេ រូបក្ខន្ធ រលត់ទៅផង វេទនាខន្ធ រលត់ហើយផង ក្នុងបញ្ចវោការភពនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ រលត់ហើយ ក្នុងទីណា រូបក្ខន្ធ រលត់ទៅ ក្នុងទីនោះដែរឬ ។ វេទនាខន្ធ រលត់ហើយ ក្នុងអរូបភពនោះ

ឯរូបក្ខន្ធ មិនរលត់ទៅ ក្នុងទីនោះទេ វេទនាខន្ធ រលត់ហើយផង រូបក្ខន្ធរលត់ទៅផង ក្នុងបញ្ចវោការភពនោះ ។

[ ១៩២ ] វេទនាខន្ធ រលត់ទៅ ក្នុងទីណា សញ្ញាខន្ធ រលត់ហើយក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត សញ្ញាខន្ធ រលត់ហើយ ក្នុងទីណា វេទនាខន្ធ រលត់ទៅ ក្នុងទីនោះដែរឬ ។ អើ ។

[ ១៩៣ ] រូបក្ខន្ធរបស់សត្វណា រលត់ទៅ ក្នុងទីណា វេទនាខន្ធរបស់សត្វនោះ រលត់ហើយក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងសុទ្ធាវាស កាលច្យុតចាកអសញ្ញសត្វ រូបក្ខន្ធរបស់សត្វទាំងនោះ រលត់ទៅ ក្នុងទីនោះ ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនរលត់ហើយក្នុងទីនោះទេ ពួកសត្វក្រៅនេះ កាលច្យុតចាកបញ្ចវោការភព រូបក្ខន្ធ របស់សត្វទាំងនោះ រលត់ទៅផង វេទនាខន្ធរលត់ហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វេទនាខន្ធរបស់សត្វណា រលត់ហើយ ក្នុងទីណា រូបក្ខន្ធ របស់សត្វនោះ រលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលចូលទៅកាន់បញ្ចវោការភព និងពួកអរូបព្រហ្ម វេទនាខន្ធរបស់សត្វទាំងនោះ រលត់ហើយ ក្នុងទីនោះ ឯរូបក្ខន្ធ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វកាលច្យុតចាកបញ្ចវោការភព វេទនាខន្ធ របស់សត្វទាំងនោះ រលត់ហើយផង រូបក្ខន្ធ រលត់ទៅផង ក្នុងទីនោះ ។

[ ១៩៤ ] វេទនាខន្ធ របស់សត្វណា រលត់ទៅ ក្នុងទីណា សញ្ញាខន្ធរបស់សត្វនោះ រលត់ហើយ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វានក្នុង

សុទ្ធាវាស វេទនាខន្ធ របស់សត្វទាំងនោះ រលត់ទៅ ក្នុងទីនោះ ឯសញ្ញាខន្ធ របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះទេ ពួកសត្វក្រៅនេះ កាលច្យុតចាកចតុវោការភព និងបញ្ចវោការភព វេទនាខន្ធ របស់សត្វទាំងនោះ រលត់ទៅផង សញ្ញាខន្ធ រលត់ហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សញ្ញាខន្ធ របស់សត្វណា រលត់ហើយ ក្នុងទីណា វេទនាខន្ធ របស់សត្វនោះ រលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វកាលចូលទៅកាន់ចតុវោការភព និងបញ្ចវោការភព សញ្ញាខន្ធ របស់សត្វទាំងនោះ រលត់ហើយ ក្នុងទីនោះ ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលច្យុតចាកចតុវោការភព និងបញ្ចវោការភព សញ្ញាខន្ធរបស់សត្វទាំងនោះ រលត់ហើយផង វេទនាខន្ធ រលត់ទៅផង ក្នុងទីនោះ ។

[ ១៩៥ ] រូបក្ខន្ធ របស់សត្វណា មិនរលត់ទៅ វេទនាខន្ធ របស់សត្វនោះ មិនរលត់ហើយដែរឬ ។ រលត់ហើយ ។ មួយយ៉ាងទៀត វេទនាខន្ធរបស់សត្វណា មិនរលត់ហើយ រូបក្ខន្ធរបស់សត្វនោះ មិនរលត់ទៅដែរឬ ។ មិនមានទេ ។

[ ១៩៦ ] វេទនាខន្ធ របស់សត្វណា មិនរលត់ទៅ សញ្ញាខន្ធ របស់សត្វនោះ មិនរលត់ហើយដែរឬ ។ រលត់ហើយ ។ មួយយ៉ាងទៀត សញ្ញាខន្ធ របស់សត្វណា មិនរលត់ហើយ វេទនាខន្ធ របស់សត្វនោះ មិនរលត់ទៅដែរឬ ។ មិនមានទេ ។

[ ១៩៧ ] រូបក្ខន្ធក្នុងទីណា ( ពាក្យទាំងប៉ុន្មាន បណ្ឌិតគប្បីធ្វើឲ្យ

បរិបូណ៌ ) ។

[ ១៩៨ ] រូបក្ខន្ធរបស់សត្វណា មិនរលត់ទៅក្នុងទីណា វេទនាខន្ធរបស់សត្វនោះ មិនរលត់ហើយក្នុងទីនោះដែរឬ ។ ពួកសត្វ កាលចូលទៅកាន់បញ្ចវោការភព និងពួកអរូបព្រហ្ម រូបក្ខន្ធរបស់សត្វទាំងនោះ មិនរលត់ទៅក្នុងទីនោះ ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយ ក្នុងទីនោះទេ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស ចូលទៅកាន់អសញ្ញសត្វ រូបក្ខន្ធរបស់សត្វទាំងនោះ មិនរលត់ទៅផង វេទនាខន្ធ មិនរលត់ហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា មិនរលត់ហើយ ក្នុងទីណា រូបក្ខន្ធរបស់សត្វនោះ មិនរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងសុទ្ធាវាស កាលច្យុតចាកអសញ្ញសត្វ វេទនាខន្ធ របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះ ឯរូបក្ខន្ធ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅក្នុងទីនោះទេ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស ចូលទៅកាន់អសញ្ញសត្វ វេទនាខន្ធ របស់សត្វទាំងនោះ មិនរលត់ហើយផង រូបក្ខន្ធមិនរលត់ទៅផង ក្នុងទីនោះ ។

[ ១៩៩ ] វេទនាខន្ធ របស់សត្វណា មិនរលត់ទៅ ក្នុងទីណា សញ្ញាខន្ធរបស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលចូលទៅកាន់ចតុវោការភព និងបញ្ចវោការភព វេទនាខន្ធរបស់សត្វទាំងនោះ មិនរលត់ទៅក្នុងទីនោះ ឯសញ្ញាខន្ធ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយក្នុងទីនោះទេ ពួកសត្វកាលចូលទៅកាន់សុទ្ធាវាស និងពួកអសញ្ញសត្វ វេទនាខន្ធ

របស់សត្វទាំងនោះ មិនរលត់ទៅផង សញ្ញាខន្ធ មិនរលត់ហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សញ្ញាខន្ធ របស់សត្វណា មិនរលត់ហើយ ក្នុងទីណា វេទនាខន្ធរបស់សត្វនោះ មិនរលត់ទៅក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងសុទ្ធាវាស សញ្ញាខន្ធរបស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះ ឯវេទនាខន្ធរបស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស និងពួកអសញ្ញសត្វ សញ្ញាខន្ធរបស់សត្វទាំងនោះ មិនរលត់ហើយផង វេទនាខន្ធ មិនរលត់ទៅផង ក្នុងទីនោះ ។

[ ២០០ ] រូបក្ខន្ធរបស់សត្វណា រលត់ទៅ វេទនាខន្ធ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ ពួកសត្វ កាលបរិនិព្វាន ក្នុងបញ្ចវោការភព រូបក្ខន្ធ របស់សត្វទាំងនោះ រលត់ទៅ ឯវេទនាខន្ធ របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ពួកសត្វក្រៅនេះ កាលច្យុតចាកបញ្ចវោការភព កាលច្យុតចាកអសញ្ញសត្វ រូបក្ខន្ធ របស់សត្វទាំងនោះ រលត់ទៅផង វេទនាខន្ធ នឹងរលត់ទៅផង ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា នឹងរលត់ទៅ រូបក្ខន្ធរបស់សត្វនោះ រលត់ទៅដែរឬ ។ ពួកសត្វទាំងអស់ កំពុងកើត កំពុងច្យុតចាកអរូបភព វេទនាខន្ធ របស់សត្វទាំងនោះ នឹងរលត់ទៅ ឯរូបក្ខន្ធ របស់សត្វទាំងនោះ មិនរលត់ទៅទេ ពួកសត្វ កាលច្យុតចាកបញ្ចវោការភព កាលច្យុតចាកអសញ្ញសត្វ វេទនាខន្ធរបស់សត្វទាំងនោះ នឹងរលត់ទៅផង រូបក្ខន្ធរលត់ទៅផង ។

[ ២០១ ] វេទនាខន្ធ របស់សត្វណា រលត់ទៅ សញ្ញាខន្ធ របស់សត្វ

នោះ នឹងរលត់ទៅដែរឬ ។ ពួកសត្វ កាលបរិនិព្វាន វេទនាខន្ធ របស់សត្វទាំងនោះ រលត់ទៅ ឯសញ្ញាខន្ធ របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ពួកសត្វក្រៅនេះ កាលច្យុតចាកចតុវោការភព និងបញ្ចវោការភព វេទនាខន្ធ របស់សត្វទាំងនោះ រលត់ទៅផង សញ្ញាខន្ធ នឹងរលត់ទៅផង ។ មួយយ៉ាងទៀត សញ្ញាខន្ធ របស់សត្វណា នឹងរលត់ទៅ វេទនាខន្ធ របស់សត្វនោះ រលត់ទៅដែរឬ ។ ពួកសត្វទាំងអស់ កំពុងកើត កំពុងច្យុតចាកអសញ្ញសត្វ សញ្ញាខន្ធ របស់សត្វទាំងនោះ នឹងរលត់ទៅ ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនរលត់ទៅទេ ពួកសត្វ កាលច្យុតចាកចតុវោការភព និងបញ្ចវោការភព សញ្ញាខន្ធ របស់សត្វទាំងនោះ នឹងរលត់ទៅផង វេទនាខន្ធរលត់ទៅផង ។

[ ២០២ ] រូបក្ខន្ធ រលត់ទៅ ក្នុងទីណា ។បេ។

[ ២០៣ ] រូបក្ខន្ធរបស់សត្វណា រលត់ទៅ ក្នុងទីណា វេទនាខន្ធរបស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វាន ក្នុងបញ្ចវោការភព កាលច្យុតចាកអសញ្ញសត្វ រូបក្ខន្ធ របស់សត្វទាំងនោះ រលត់ទៅ ក្នុងទីនោះ ឯវេទនាខន្ធ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វក្រៅនេះ កាលច្យុតចាកបញ្ចវោការភព រូបក្ខន្ធរបស់សត្វទាំងនោះ រលត់ទៅផង វេទនាខន្ធ នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា រូបក្ខន្ធ របស់សត្វនោះ រលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលចូលទៅកាន់បញ្ចវោការភព និងពួកអរូបព្រហ្ម វេទនាខន្ធ របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ ឯ

រូបក្ខន្ធ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលច្យុត ចាកបញ្ចវោការភព វេទនាខន្ធ របស់សត្វទាំងនោះ នឹងរលត់ទៅផង រូបក្ខន្ធ រលត់ទៅផង ក្នុងទីនោះ ។

[ ២០៤ ] វេទនាខន្ធ របស់សត្វណា រលត់ទៅ ក្នុងទីណា សញ្ញាខន្ធ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះ ដែរឬ ។ ពួកសត្វ កាលបរិនិព្វាន វេទនាខន្ធ របស់សត្វទាំងនោះ រលត់ទៅ ក្នុងទីនោះ ឯសញ្ញាខន្ធ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វក្រៅនេះ កាលច្យុតចាក ចតុវោការភព និងបញ្ចវោការភព វេទនាខន្ធ របស់សត្វទាំងនោះ រលត់ទៅផង សញ្ញាខន្ធ នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សញ្ញាខន្ធ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា វេទនាខន្ធ របស់សត្វនោះ រលត់ទៅក្នុងទីនោះដែរឬ ។ ពួកសត្វ កាលចូលទៅកាន់ចតុវោការភព និងបញ្ច-វោការភព សញ្ញាខន្ធរបស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលច្យុតចាក ចតុវោការភព និងបញ្ចវោការភព សញ្ញាខន្ធ របស់សត្វទាំងនោះ នឹងរលត់ទៅផង វេទនាខន្ធរលត់ទៅផង ក្នុងទីនោះ ។

[ ២០៥ ] រូបក្ខន្ធ របស់សត្វណា មិនរលត់ទៅ វេទនាខន្ធ របស់សត្វនោះ នឹងមិនរលត់ទៅដែរឬ ។ ពួកសត្វទាំងអស់ កាលកើត កាលច្យុតចាក អរូបភព រូបក្ខន្ធរបស់សត្វទាំងនោះ មិនរលត់ទៅ ឯវេទនាខន្ធ របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ពួកសត្វ កាលបរិនិព្វាន ក្នុងអរូបភព រូបក្ខន្ធ

របស់សត្វទាំងនោះ មិនរលត់ទៅផង វេទនាខន្ធ នឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា នឹងមិនរលត់ទៅ រូបក្ខន្ធ របស់សត្វនោះ មិនរលត់ទៅដែរឬ ។ ពួកសត្វ កាលបរិនិព្វាន ក្នុងបញ្ចវោការភព វេទនាខន្ធ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ឯរូបក្ខន្ធរបស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ។ ពួកសត្វ កាលបរិនិព្វានក្នុងអរូបភព វេទនាខន្ធ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង រូបក្ខន្ធ មិនរលត់ទៅផង ។

[ ២០៦ ] វេទនាខន្ធ របស់សត្វណា មិនរលត់ទៅ សញ្ញាខន្ធ របស់សត្វនោះ នឹងមិនរលត់ទៅដែរឬ ។ នឹងរលត់ទៅ ។ មួយយ៉ាងទៀត សញ្ញាខន្ធ របស់សត្វណា នឹងមិនរលត់ទៅ វេទនាខន្ធ របស់សត្វនោះ នឹងមិនរលត់ទៅដែរឬ ។ រលត់ទៅ ។

[ ២០៧ ] រូបក្ខន្ធ មិនរលត់ទៅ ក្នុងទីណា ។បេ។

[ ២០៨ ] រូបក្ខន្ធ របស់សត្វណា មិនរលត់ទៅ ក្នុងទីណា វេទនាខន្ធ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលចូលទៅកាន់បញ្ចវោការភព និងពួកអរូបព្រហ្ម រូបក្ខន្ធរបស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះ ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន ក្នុងអរូបភព កាលចូលទៅកាន់អសញ្ញសត្វ រូបក្ខន្ធ របស់សត្វទាំងនោះ មិនរលត់ទៅផង វេទនាខន្ធ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា រូបក្ខន្ធ របស់សត្វនោះ មិនរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួក

សត្វ កាលបរិនិព្វាន ក្នុងបញ្ចវោការភព កាលច្យុតចាកអសញ្ញសត្វ វេទនាខន្ធ របស់សត្វទាំងនោះ នឹងមិនរលត់ទៅក្នុងទីនោះ ឯរូបក្ខន្ធ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន ក្នុងអរូបភព កាលចូលទៅកាន់អសញ្ញសត្វនោះ វេទនាខន្ធ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង រូបក្ខន្ធ មិនរលត់ទៅផង ក្នុងទីនោះ ។

[ ២០៩ ] វេទនាខន្ធ របស់សត្វណា មិនរលត់ទៅ ក្នុងទីណា សញ្ញាខន្ធ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលចូលទៅកាន់ចតុវោការភព និងបញ្ចវោការភព វេទនាខន្ធ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះ ឯសញ្ញាខន្ធ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅក្នុងទីនោះទេ វេទនាខន្ធ របស់អសញ្ញសត្វទាំងនោះ មិនរលត់ទៅផង សញ្ញាខន្ធ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សញ្ញាខន្ធ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា វេទនាខន្ធ របស់សត្វនោះ មិនរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វាន សញ្ញាខន្ធ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅក្នុងទីនោះទេ សញ្ញាខន្ធ របស់អសញ្ញសត្វទាំងនោះ នឹងមិនរលត់ទៅផង វេទនាខន្ធ មិនរលត់ទៅផង ក្នុងទីនោះ ។

[ ២១០ ] រូបក្ខន្ធរបស់សត្វណា រលត់ហើយ វេទនាខន្ធរបស់សត្វនោះ នឹងរលត់ទៅដែរឬ ។ ពួកសត្វ កាលបរិនិព្វាន រូបក្ខន្ធ របស់សត្វទាំងនោះ រលត់ហើយ ឯវេទនាខន្ធ របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ រូបក្ខន្ធរបស់

ពួកសត្វទាំងនោះ ក្រៅនេះ រលត់ហើយផង វេទនាខន្ធ នឹងរលត់ទៅផង ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា នឹងរលត់ទៅ រូបក្ខន្ធ របស់សត្វនោះ រលត់ហើយដែរឬ ។ អើ ។

[ ២១១ ] វេទនាខន្ធ របស់សត្វណា រលត់ហើយ សញ្ញាខន្ធ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ ពួកសត្វ កាលបរិនិព្វាន វេទនាខន្ធ របស់សត្វទាំងនោះ រលត់ហើយ ឯសញ្ញាខន្ធ របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ វេទនាខន្ធរបស់ពួកសត្វទាំងនោះ ក្រៅនេះ រលត់ហើយផង សញ្ញាខន្ធ នឹងរលត់ទៅផង ។ មួយយ៉ាងទៀត សញ្ញាខន្ធ របស់សត្វណា នឹងរលត់ទៅ វេទនាខន្ធរបស់សត្វនោះ រលត់ហើយដែរឬ ។ អើ ។

[ ២១២ ] រូបក្ខន្ធ រលត់ហើយ ក្នុងទីណា ។បេ។

[ ២១៣ ] រូបក្ខន្ធ របស់សត្វណា រលត់ហើយ ក្នុងទីណា វេទនាខន្ធ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព និងពួកអសញ្ញសត្វ រូបក្ខន្ធ របស់សត្វទាំងនោះ រលត់ហើយ ក្នុងទីនោះ ឯវេទនាខន្ធ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ រូបក្ខន្ធរបស់សត្វទាំងនោះ ក្រៅនេះ ជាបញ្ចវោការ រលត់ហើយផង វេទនាខន្ធ នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា រូបក្ខន្ធរបស់សត្វនោះ រលត់ហើយ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស និងពួកអរូបព្រហ្ម វេទនាខន្ធ របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ ឯរូបក្ខន្ធ របស់សត្វទាំងនោះ មិនរលត់

ហើយ ក្នុងទីនោះទេ វេទនាខន្ធ របស់សត្វទាំងនោះ ក្រៅនេះ ជាបញ្ចវោការ នឹងរលត់ទៅផង រូបក្ខន្ធរលត់ហើយផង ក្នុងទីនោះ ។

[ ២១៤ ] វេទនាខន្ធ របស់សត្វណា រលត់ហើយ ក្នុងទីណា សញ្ញាខន្ធ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វាន វេទនាខន្ធ របស់សត្វទាំងនោះ រលត់ហើយ ក្នុងទីនោះ ឯសញ្ញាខន្ធ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ វេទនាខន្ធ របស់សត្វទាំងនោះ ក្រៅនេះ ជាចតុវោការ និងបញ្ចវោការ រលត់ហើយផង សញ្ញាខន្ធ នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សញ្ញាខន្ធ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា វេទនាខន្ធ របស់សត្វនោះ រលត់ហើយ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស សញ្ញាខន្ធ របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះទេ សញ្ញាខន្ធ របស់សត្វទាំងនោះ ក្រៅនេះ ជាចតុវោការ និងបញ្ច-វោការ នឹងរលត់ទៅផង វេទនាខន្ធ រលត់ហើយផង ក្នុងទីនោះ ។

[ ២១៥ ] រូបក្ខន្ធរបស់សត្វណា មិនរលត់ហើយ វេទនាខន្ធរបស់សត្វនោះ នឹងមិនរលត់ទៅដែរឬ ។ មិនមានទេ ។ មួយយ៉ាងទៀត វេទនាខន្ធរបស់សត្វណា នឹងមិនរលត់ទៅ រូបក្ខន្ធរបស់សត្វនោះ មិនរលត់ទៅហើយដែរឬ ។ រលត់ហើយ ។

[ ២១៦ ] វេទនាខន្ធរបស់សត្វណា មិនរលត់ហើយ សញ្ញាខន្ធរបស់សត្វនោះ នឹងមិនរលត់ទៅដែរឬ ។ មិនមានទេ ។ មួយយ៉ាងទៀត សញ្ញាខន្ធ

របស់សត្វណា នឹងមិនរលត់ទៅ វេទនាខន្ធ របស់សត្វនោះ មិនរលត់ហើយដែរឬ ។ រលត់ហើយ ។

[ ២១៧ ] រូបក្ខន្ធ មិនរលត់ហើយ ក្នុងទីណា ។បេ។

[ ២១៨ ] រូបក្ខន្ធ របស់សត្វណា មិនរលត់ហើយ ក្នុងទីណា វេទនាខន្ធ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស និងពួកអរូបព្រហ្ម រូបក្ខន្ធ របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះ ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន ក្នុងសុទ្ធាវាស បរិនិព្វានក្នុងអរូបភព រូបក្ខន្ធ របស់សត្វទាំងនោះ មិនរលត់ហើយផង វេទនាខន្ធ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា រូបក្ខន្ធ របស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វាន ក្នុងបញ្ចវោការភព និងពួកអសញ្ញសត្វ វេទនាខន្ធ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ ឯរូបក្ខន្ធ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងសុទ្ធាវាស បរិនិព្វានក្នុងអរូបភព វេទនាខន្ធ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង រូបក្ខន្ធ មិនរលត់ហើយផង ក្នុងទីនោះ ។

[ ២១៩ ] វេទនាខន្ធរបស់សត្វណា មិនរលត់ហើយ ក្នុងទីណា សញ្ញាខន្ធ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស វេទនាខន្ធរបស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះ ឯ

សញ្ញាខន្ធ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងសុទ្ធាវាស និងពួកអសញ្ញសត្វ វេទនាខន្ធ របស់សត្វទាំងនោះ មិនរលត់ហើយផង សញ្ញាខន្ធ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សញ្ញាខន្ធរបស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា វេទនាខន្ធរបស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព សញ្ញាខន្ធរបស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ ឯវេទនាខន្ធរបស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងសុទ្ធាវាស និងពួកអសញ្ញសត្វ សញ្ញាខន្ធរបស់សត្វទាំងនោះ នឹងមិនរលត់ទៅផង វេទនាខន្ធ មិនរលត់ហើយផង ក្នុងទីនោះ ។

## និរោធវារៈ ចប់

[ ២២០ ] រូបក្ខន្ធ របស់សត្វណាកើតឡើង វេទនាខន្ធរបស់សត្វនោះ រលត់ទៅដែរឬ ។ មិនរលត់ទេ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា រលត់ទៅ រូបក្ខន្ធរបស់សត្វនោះ កើតឡើងដែរឬ ។ មិនកើតឡើងទេ ។

[ ២២១ ] វេទនាខន្ធ របស់សត្វណា កើតឡើង សញ្ញាខន្ធ របស់សត្វនោះ រលត់ទៅដែរឬ ។ មិនរលត់ទេ ។ មួយយ៉ាងទៀត សញ្ញាខន្ធរបស់សត្វណា រលត់ទៅ វេទនាខន្ធ របស់សត្វនោះ កើតឡើងដែរឬ ។ មិនកើតឡើងទេ ។

[ ២២២ ] រូបក្ខន្ធ កើតឡើង ក្នុងទីណា វេទនាខន្ធ រលត់ទៅ ក្នុងទីនោះដែរឬ ។ រូបក្ខន្ធ កើតឡើង ក្នុងអសញ្ញសត្វនោះ ឯវេទនាខន្ធ មិនរលត់ទៅ

ក្នុងទីនោះទេ រូបក្ខន្ធកើតឡើងផង វេទនាខន្ធរលត់ទៅផង ក្នុងបញ្ចវោការ-ភពនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ រលត់ទៅ ក្នុងទីណា រូបក្ខន្ធ កើតឡើង ក្នុងទីនោះដែរឬ ។ វេទនាខន្ធ រលត់ទៅ ក្នុងអរូបភពនោះ ឯរូបក្ខន្ធ មិនកើតឡើងក្នុងទីនោះទេ វេទនាខន្ធ រលត់ទៅផង រូបក្ខន្ធ ក៏កើតឡើងផង ក្នុងបញ្ចវោការភពនោះ ។

[ ២២៣ ] វេទនាខន្ធកើតឡើង ក្នុងទីណា សញ្ញាខន្ធ រលត់ទៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត សញ្ញាខន្ធ រលត់ទៅ ក្នុងទីណា វេទនាខន្ធកើតឡើងក្នុងទីនោះដែរឬ ។ អើ ។

[ ២២៤ ] រូបក្ខន្ធ របស់សត្វណា កើតឡើង ក្នុងទីណា វេទនាខន្ធរបស់សត្វនោះ រលត់ទៅក្នុងទីនោះដែរឬ ។ មិនរលត់ទេ ។ មួយយ៉ាងទៀត វេទនាខន្ធរបស់សត្វណា រលត់ទៅក្នុងទីណា រូបក្ខន្ធ របស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ មិនកើតឡើងទេ ។

[ ២២៥ ] វេទនាខន្ធ របស់សត្វណា កើតឡើង ក្នុងទីណា សញ្ញាខន្ធរបស់សត្វនោះ រលត់ទៅក្នុងទីនោះដែរឬ ។ មិនរលត់ទេ ។ មួយយ៉ាងទៀត សញ្ញាខន្ធរបស់សត្វណា រលត់ទៅ ក្នុងទីណា វេទនាខន្ធ របស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ មិនកើតឡើងទេ ។

[ ២២៦ ] រូបក្ខន្ធ របស់សត្វណា មិនកើតឡើង វេទនាខន្ធ របស់សត្វនោះ មិនរលត់ទៅដែរឬ ។ ពួកសត្វ កាលច្យុតចាកចតុវោការភព និងបញ្ច-វោការភព រូបក្ខន្ធរបស់សត្វទាំងនោះ មិនកើតឡើង ឯវេទនាខន្ធ របស់សត្វ

ទាំងនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វ កាលចូលទៅកាន់អរូបភព ច្យុត ចាកអសញ្ញសត្វ រូបក្ខន្ធរបស់សត្វទាំងនោះ មិនកើតឡើងផង វេទនាខន្ធ មិនរលត់ទៅផង ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា មិនរលត់ទៅ រូបក្ខន្ធ របស់សត្វនោះ មិនកើតឡើងដែរឬ ។ ពួកសត្វ កាលចូលទៅកាន់ បញ្ចវោការភព ចូលទៅកាន់អសញ្ញសត្វ វេទនាខន្ធ របស់សត្វទាំងនោះ មិន រលត់ទៅ ឯរូបក្ខន្ធ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ពួកសត្វ កាលចូលទៅកាន់អរូបភព កាលច្យុតចាកអសញ្ញសត្វ វេទនាខន្ធ របស់សត្វ ទាំងនោះ មិនរលត់ទៅផង រូបក្ខន្ធ មិនកើតឡើងផង ។

[ ២២៧ ] វេទនាខន្ធ របស់សត្វណា មិនកើតឡើង សញ្ញាខន្ធ របស់ សត្វនោះ មិនរលត់ទៅដែរឬ ។ ពួកសត្វ កាលច្យុតចាកចតុវោការភព និង បញ្ចវោការភព វេទនាខន្ធ របស់សត្វទាំងនោះ មិនកើតឡើង ឯសញ្ញាខន្ធ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ វេទនាខន្ធ របស់អសញ្ញសត្វ ទាំងនោះ មិនកើតឡើងផង សញ្ញាខន្ធ មិនរលត់ទៅផង ។ មួយយ៉ាងទៀត សញ្ញាខន្ធ របស់សត្វណា មិនរលត់ទៅ វេទនាខន្ធ របស់សត្វនោះ មិនកើត ឡើងដែរឬ ។ ពួកសត្វ កាលចូលទៅកាន់ចតុវោការភព និងបញ្ចវោការភព សញ្ញាខន្ធរបស់សត្វទាំងនោះ មិនរលត់ទៅ ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ សញ្ញាខន្ធរបស់អសញ្ញសត្វទាំងនោះ មិនរលត់ ទៅផង វេទនាខន្ធ មិនកើតឡើងផង ។

[ ២២៨ ] រូបក្ខន្ធ មិនកើតឡើងក្នុងទីណា វេទនាខន្ធ មិនរលត់ទៅក្នុង

ទីនោះដែរឬ ។ រលត់ទៅ ។ មួយយ៉ាងទៀត វេទនាខន្ធ មិនរលត់ទៅ ក្នុងទីណា រូបក្ខន្ធ មិនកើតឡើង ក្នុងទីនោះដែរឬ ។ កើតឡើង ។

[ ២២៩ ] វេទនាខន្ធ មិនកើតឡើង ក្នុងទីណា សញ្ញាខន្ធ មិនរលត់ទៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត សញ្ញាខន្ធ មិនរលត់ទៅ ក្នុងទីណា វេទនាខន្ធ មិនកើតឡើង ក្នុងទីនោះដែរឬ ។ អើ ។

[ ២៣០ ] រូបក្ខន្ធ របស់សត្វណា មិនកើតឡើង ក្នុងទីណា វេទនាខន្ធ របស់សត្វនោះ មិនរលត់ទៅក្នុងទីនោះដែរឬ ។ ពួកសត្វ កាលច្យុតចាកចតុវោការភព និងបញ្ចវោការភព រូបក្ខន្ធ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលចូលទៅកាន់អរូបភព ច្យុតចាកអសញ្ញសត្វ រូបក្ខន្ធ របស់សត្វទាំងនោះ មិនកើតឡើងផង វេទនាខន្ធ មិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា មិនរលត់ទៅ ក្នុងទីណា រូបក្ខន្ធ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលចូលទៅកាន់បញ្ចវោការភព ចូលទៅកាន់អសញ្ញសត្វ វេទនាខន្ធ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះ ឯរូបក្ខន្ធ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលចូលទៅកាន់អរូបភព កាលច្យុតចាកអសញ្ញ-សត្វ វេទនាខន្ធ របស់សត្វទាំងនោះ មិនរលត់ទៅផង រូបក្ខន្ធ មិនកើតឡើងផង ក្នុងទីនោះ ។

[ ២៣១ ] វេទនាខន្ធរបស់សត្វណា មិនកើតឡើង ក្នុងទីណា សញ្ញាខន្ធ

របស់សត្វនោះ មិនរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលច្យុតចាក ចតុវោការភព និងបញ្ចវោការភព វេទនាខន្ធ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ ឯសញ្ញាខន្ធ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅក្នុងទីនោះទេ វេទនាខន្ធរបស់អសញ្ញសត្វទាំងនោះ មិនកើតឡើងផង សញ្ញាខន្ធមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សញ្ញាខន្ធ របស់សត្វណា មិនរលត់ទៅក្នុងទីណា វេទនាខន្ធ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលចូលទៅកាន់ចតុវោការភព និងបញ្ចវោការភព សញ្ញាខន្ធរបស់សត្វទាំងនោះ មិនរលត់ទៅក្នុងទីនោះ ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងក្នុងទីនោះទេ សញ្ញាខន្ធ របស់អសញ្ញសត្វទាំងនោះ មិនរលត់ទៅផង វេទនាខន្ធ មិនកើតឡើងផង ក្នុងទីនោះ ។

[ ២៣២ ] រូបក្ខន្ធ របស់សត្វណា កើតហើយ វេទនាខន្ធ របស់សត្វនោះ រលត់ហើយដែរឬ ។ អើ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា រលត់ហើយ រូបក្ខន្ធ របស់សត្វនោះ កើតហើយដែរឬ ។ អើ ។

[ ២៣៣ ] វេទនាខន្ធរបស់សត្វណា កើតហើយ សញ្ញាខន្ធរបស់សត្វនោះ រលត់ហើយដែរឬ ។ អើ ។ មួយយ៉ាងទៀត សញ្ញាខន្ធរបស់សត្វណា រលត់ហើយ វេទនាខន្ធរបស់សត្វនោះ កើតហើយដែរឬ ។ អើ ។

[ ២៣៤ ] រូបក្ខន្ធ កើតហើយ ក្នុងទីណា ។បេ។

[ ២៣៥ ] រូបក្ខន្ធ របស់សត្វណា កើតហើយ ក្នុងទីណា វេទនាខន្ធរបស់សត្វនោះ រលត់ហើយ ក្នុងទីនោះដែរឬ ។ រូបក្ខន្ធ របស់អសញ្ញសត្វទាំងនោះ

កើតហើយ ក្នុងទីនោះ ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះទេ រូបក្ខន្ធ របស់សត្វទាំងនោះ ជាបញ្ចវោការ កើតហើយផង វេទនាខន្ធ រលត់ហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា រលត់ហើយ ក្នុងទីណា រូបក្ខន្ធ របស់សត្វនោះ កើតហើយ ក្នុងទីនោះដែរឬ ។ វេទនាខន្ធ របស់អរូបព្រហ្មទាំងនោះ រលត់ហើយ ក្នុងទីនោះ ឯរូបក្ខន្ធ របស់សត្វទាំងនោះ មិនកើតហើយ ក្នុងទីនោះទេ វេទនាខន្ធ របស់សត្វទាំងនោះ ជាបញ្ចវោការ រលត់ហើយផង រូបក្ខន្ធ កើតហើយផង ក្នុងទីនោះ ។

[ ២៣៦ ] វេទនាខន្ធរបស់សត្វណា កើតហើយ ក្នុងទីណា សញ្ញាខន្ធ របស់សត្វនោះ រលត់ហើយ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត សញ្ញាខន្ធ របស់សត្វណា រលត់ហើយ ក្នុងទីណា វេទនាខន្ធ របស់សត្វនោះ កើតហើយ ក្នុងទីនោះដែរឬ ។ អើ ។

[ ២៣៧ ] រូបក្ខន្ធរបស់សត្វណា មិនកើតហើយ វេទនាខន្ធរបស់សត្វនោះ មិនរលត់ហើយដែរឬ ។ មិនមានទេ ។ មួយយ៉ាងទៀត វេទនាខន្ធរបស់សត្វណា មិនរលត់ហើយ រូបក្ខន្ធរបស់សត្វនោះ មិនកើតហើយដែរឬ ។ មិនមានទេ ។

[ ២៣៨ ] វេទនាខន្ធរបស់សត្វណា មិនកើតឡើងហើយ សញ្ញាខន្ធ របស់សត្វនោះ មិនរលត់ហើយដែរឬ ។ មិនមានទេ ។ មួយយ៉ាងទៀត សញ្ញាខន្ធ របស់សត្វណា មិនរលត់ហើយ វេទនាខន្ធ របស់សត្វនោះ មិនកើតហើយដែរឬ ។ មិនមានទេ ។

[ ២៣៩ ] រូបក្ខន្ធ មិនកើតហើយ ក្នុងទីណា ។បេ។

[ ២៤០ ] រូបក្ខន្ធរបស់សត្វណា មិនកើតហើយ ក្នុងទីណា វេទនាខន្ធរបស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះដែរឬ ។ រូបក្ខន្ធរបស់អរូបព្រហ្ម ទាំងនោះ មិនកើតហើយ ក្នុងទីនោះ ឯវេទនាខន្ធរបស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយ ក្នុងទីនោះទេ រូបក្ខន្ធ របស់សុទ្ធាវាសសត្វទាំងនោះ មិនកើតហើយផង វេទនាខន្ធ មិនរលត់ហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា មិនរលត់ហើយ ក្នុងទីណា រូបក្ខន្ធ របស់សត្វនោះ មិនកើតហើយ ក្នុងទីនោះដែរឬ ។ វេទនាខន្ធ របស់អសញ្ញសត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះ ឯរូបក្ខន្ធ របស់សត្វទាំងនោះ មិនមែនជាមិនកើតហើយ ក្នុងទីនោះទេ វេទនាខន្ធ របស់សុទ្ធាវាសសត្វទាំងនោះ មិនរលត់ហើយផង រូបក្ខន្ធ មិនកើតហើយផង ក្នុងទីនោះ ។

[ ២៤១ ] វេទនាខន្ធ របស់សត្វណា មិនកើតហើយ ក្នុងទីណា សញ្ញាខន្ធ របស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត សញ្ញាខន្ធ របស់សត្វណា មិនរលត់ហើយ ក្នុងទីណា វេទនាខន្ធ របស់សត្វនោះ មិនកើតហើយ ក្នុងទីនោះដែរឬ ។ អើ ។

[ ២៤២ ] រូបក្ខន្ធរបស់សត្វណា នឹងកើតឡើង វេទនាខន្ធរបស់សត្វនោះ នឹងរលត់ទៅដែរឬ ។ អើ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា នឹងរលត់ទៅ រូបក្ខន្ធ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ ពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ និងពួកសត្វណា ចូលទៅកាន់អរូបភព

ហើយ នឹងបរិនិព្វាន វេទនាខន្ធ របស់សត្វទាំងនោះ នឹងរលត់ទៅ ឯរូបក្ខន្ធ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ វេទនាខន្ធ របស់សត្វទាំងនោះ ក្រៅនេះ នឹងរលត់ទៅផង រូបក្ខន្ធ នឹងកើតឡើងផង ។

[ ២៤៣ ] វេទនាខន្ធ របស់សត្វណា នឹងកើតឡើង សញ្ញាខន្ធ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ អើ ។ មួយយ៉ាងទៀត សញ្ញាខន្ធ របស់សត្វណា នឹងរលត់ទៅ វេទនាខន្ធ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ សញ្ញាខន្ធ របស់សត្វទាំងនោះ នឹងរលត់ទៅ ឯវេទនាខន្ធ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ សញ្ញាខន្ធ របស់សត្វទាំងនោះ ក្រៅនេះ នឹងរលត់ទៅផង វេទនាខន្ធនឹងកើតឡើងផង ។

[ ២៤៤ ] រូបក្ខន្ធ នឹងកើតឡើង ក្នុងទីណា ។បេ។

[ ២៤៥ ] រូបក្ខន្ធ របស់សត្វណា នឹងកើតឡើង ក្នុងទីណា វេទនាខន្ធ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ រូបក្ខន្ធ របស់អសញ្ញសត្វទាំងនោះ នឹងកើតឡើងក្នុងទីនោះ ឯវេទនាខន្ធ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ រូបក្ខន្ធ របស់ពួកសត្វជាបញ្ចវោការនោះ នឹងកើតឡើងផង វេទនាខន្ធ នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា រូបក្ខន្ធ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព និងពួកអរូបព្រហ្ម វេទនាខន្ធ របស់សត្វទាំងនោះ នឹងរលត់ទៅក្នុងទីនោះ ឯរូបក្ខន្ធរបស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ

វេទនាខន្ធ របស់ពួកសត្វ ជាបញ្ចវោការនោះ ក្រៅនេះ នឹងរលត់ទៅផង រូបក្ខន្ធ នឹងកើតឡើងផង ក្នុងទីនោះ ។

[ ២៤៦ ] វេទនាខន្ធ របស់សត្វណា នឹងកើតឡើង ក្នុងទីណា សញ្ញាខន្ធ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត សញ្ញាខន្ធ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា វេទនាខន្ធ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ សញ្ញាខន្ធរបស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ ឯវេទនាខន្ធ របស់សត្វទាំងនោះ នឹងមិនកើតឡើងក្នុងទីនោះទេ សញ្ញាខន្ធ របស់ពួកសត្វ ជាចតុវោការ និងបញ្ចវោការ ក្រៅនេះ នឹងរលត់ទៅផង វេទនាខន្ធ នឹងកើតឡើងផង ក្នុងទីនោះ ។

[ ២៤៧ ] រូបក្ខន្ធ របស់សត្វណា នឹងមិនកើតឡើង វេទនាខន្ធ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ និងពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន រូបក្ខន្ធ របស់សត្វទាំងនោះ នឹងមិនកើតឡើង ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ ពួកសត្វ កាលបរិនិព្វាន រូបក្ខន្ធ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង វេទនាខន្ធ នឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា នឹងមិនរលត់ទៅ រូបក្ខន្ធ របស់សត្វនោះ នឹងមិនកើតឡើងដែរឬ ។ អើ ។

[ ២៤៨ ] វេទនាខន្ធ របស់សត្វណា នឹងមិនកើតឡើង សញ្ញាខន្ធរបស់

សត្វនោះ នឹងមិនរលត់ទៅដែរឬ ។ ពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ វេទនាខន្ធ របស់សត្វទាំងនោះ នឹងមិនកើតឡើង ឯសញ្ញាខន្ធរបស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ ពួកសត្វ កាលបរិនិព្វាន វេទនាខន្ធរបស់សត្វទាំងនោះ នឹងមិនកើតឡើងផង សញ្ញាខន្ធ នឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត សញ្ញាខន្ធរបស់សត្វណា នឹងមិនរលត់ទៅ វេទនាខន្ធរបស់សត្វនោះ នឹងមិនកើតឡើងដែរឬ ។ អើ ។

[ ២៤៩ ] រូបក្ខន្ធ នឹងមិនកើតឡើង ក្នុងទីណា ។បេ។

[ ២៥០ ] រូបក្ខន្ធរបស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា វេទនាខន្ធរបស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព និងពួកអរូបព្រហ្ម រូបក្ខន្ធរបស់សត្វទាំងនោះ នឹងមិនកើតឡើងក្នុងទីនោះ ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន រូបក្ខន្ធរបស់សត្វទាំងនោះ នឹងមិនកើតឡើងផង វេទនាខន្ធ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា រូបក្ខន្ធ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះដែរឬ ។ វេទនាខន្ធរបស់អសញ្ញសត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ ឯរូបក្ខន្ធរបស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន វេទនាខន្ធរបស់សត្វទាំងនោះ នឹងមិនរលត់ទៅផង រូបក្ខន្ធ នឹងមិនកើតឡើងផង ក្នុងទីនោះ ។

[ ២៥១ ] វេទនាខន្ធរបស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា សញ្ញាខន្ធរបស់សត្វនោះ នឹងមិនរលត់ទៅក្នុងទីនោះដែរឬ ។ ពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ វេទនាខន្ធរបស់សត្វទាំងនោះ នឹងមិនកើតឡើងក្នុងទីនោះ ឯសញ្ញាខន្ធ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន និងពួកអសញ្ញសត្វ វេទនាខន្ធ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង សញ្ញាខន្ធ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សញ្ញាខន្ធរបស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា វេទនាខន្ធរបស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះដែរឬ ។ អើ ។

[ ២៥២ ] រូបក្ខន្ធ របស់សត្វណា មិនកើតឡើង វេទនាខន្ធ របស់សត្វនោះ រលត់ហើយឬ ។ អើ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា រលត់ហើយ រូបក្ខន្ធរបស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វទាំងអស់ កាលច្យុត កាលចូលទៅកាន់អរូបភព វេទនាខន្ធ របស់សត្វទាំងនោះ រលត់ហើយ ឯរូបក្ខន្ធ របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វ កាលចូលទៅកាន់បញ្ចវោការភព ចូលទៅកាន់អសញ្ញសត្វ វេទនាខន្ធ របស់សត្វទាំងនោះ រលត់ហើយផង រូបក្ខន្ធកើតឡើងផង ។បេ។ ( ពាក្យថា បច្ចុប្បន្ន និងអតីត ក្នុងឧប្បាទវារៈ យើងបានចែកមកហើយ យ៉ាងណា បណ្ឌិតគប្បីចែកក្នុងទីនោះ ក៏យ៉ាងនោះដែរ ) ។

[ ២៥៣ ] រូបក្ខន្ធ របស់សត្វណា កើតឡើង វេទនាខន្ធ របស់សត្វនោះ នឹងរលត់ទៅឬ ។ អើ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា នឹងរលត់

ទៅ រូបក្ខន្ធរបស់សត្វនោះ កើតឡើងឬ ។ ពួកសត្វទាំងអស់ កាលច្យុត កាលចូលទៅកាន់អរូបភព វេទនាខន្ធរបស់សត្វទាំងនោះ នឹងរលត់ទៅ ឯរូបក្ខន្ធរបស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វ កាលចូលទៅកាន់បញ្ច-វោការភព កាលចូលទៅកាន់អសញ្ញសត្វ វេទនាខន្ធ របស់សត្វទាំងនោះ នឹងរលត់ទៅផង រូបក្ខន្ធកើតឡើងផង ។

[ ២៥៤ ] វេទនាខន្ធ របស់សត្វណា កើតឡើង សញ្ញាខន្ធ របស់សត្វនោះ នឹងរលត់ទៅឬ ។ អើ ។ មួយយ៉ាងទៀត សញ្ញាខន្ធ របស់សត្វណា នឹងរលត់ទៅ វេទនាខន្ធ របស់សត្វនោះ កើតឡើងឬ ។ ពួកសត្វទាំងអស់ កាលច្យុត កាលចូលទៅកាន់អសញ្ញសត្វ សញ្ញាខន្ធ របស់សត្វទាំងនោះ នឹងរលត់ទៅ ឯវេទនាខន្ធរបស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វ កាលចូលទៅកាន់ចតុវោការភព និងបញ្ចវោការភព សញ្ញាខន្ធ របស់សត្វទាំងនោះ នឹងរលត់ទៅផង វេទនាខន្ធ កើតឡើងផង ។

[ ២៥៥ ] រូបក្ខន្ធ កើតឡើង ក្នុងទីណា ។បេ។

[ ២៥៦ ] រូបក្ខន្ធ របស់សត្វណា កើតឡើងក្នុងទីណា វេទនាខន្ធរបស់សត្វនោះ នឹងរលត់ទៅក្នុងទីនោះដែរឬ ។ ពួកសត្វ កាលចូលទៅកាន់អសញ្ញសត្វ រូបក្ខន្ធ របស់សត្វទាំងនោះ កើតឡើងក្នុងទីនោះ ឯវេទនាខន្ធរបស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វកាលចូលទៅកាន់បញ្ចវោការភព រូបក្ខន្ធ របស់សត្វទាំងនោះ កើតឡើងផង វេទនាខន្ធ នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា នឹង

វេលត់ទៅ ក្នុងទីណា រូបក្ខន្ធ របស់សត្វនោះ កើតឡើងក្នុងទីនោះឬ ។ ពួកសត្វ កាលច្យុតចាកបញ្ចវោការភព កាលចូលទៅកាន់អរូបភព វេទនាខន្ធរបស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ ឯរូបក្ខន្ធ របស់សត្វទាំងនោះមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលចូលទៅកាន់បញ្ចវោការភព វេទនាខន្ធរបស់សត្វទាំងនោះ នឹងរលត់ទៅផង រូបក្ខន្ធ កើតឡើងផង ក្នុងទីនោះ ។

[ ២៥៧ ] វេទនាខន្ធ របស់សត្វណា កើតឡើង ក្នុងទីណា សញ្ញាខន្ធរបស់សត្វនោះ នឹងរលត់ទៅក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត សញ្ញាខន្ធរបស់សត្វណា នឹងរលត់ទៅ ក្នុងទីណា វេទនាខន្ធ របស់សត្វនោះ កើតឡើងក្នុងទីនោះដែរឬ ។ ពួកសត្វ កាលច្យុតចាកចតុវោការភព និងបញ្ចវោការភព សញ្ញាខន្ធរបស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនកើតឡើងក្នុងទីនោះទេ ពួកសត្វ កាលចូលទៅកាន់ចតុ-វោការភព និងបញ្ចវោការភព សញ្ញាខន្ធ របស់សត្វទាំងនោះ នឹងរលត់ទៅផង វេទនាខន្ធ កើតឡើងផង ក្នុងទីនោះ ។

[ ២៥៨ ] រូបក្ខន្ធ របស់សត្វណា មិនកើតឡើង វេទនាខន្ធ របស់សត្វនោះ នឹងមិនរលត់ទៅឬ ។ ពួកសត្វទាំងអស់ កាលច្យុត កាលចូលទៅកាន់អរូបភព រូបក្ខន្ធ របស់សត្វទាំងនោះ មិនកើតឡើង ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ ពួកសត្វកាលបរិនិព្វាន រូបក្ខន្ធរបស់សត្វទាំងនោះ មិនកើតឡើងផង វេទនាខន្ធ នឹងមិនរលត់ទៅផង ។ មួយយ៉ាង

ទៀត វេទនាខន្ធ របស់សត្វណា នឹងមិនរលត់ទៅ រូបក្ខន្ធ របស់សត្វនោះ មិនកើតឡើងឬ ។ អើ ។

[ ២៥៩ ] វេទនាខន្ធ របស់សត្វណា មិនកើតឡើង សញ្ញាខន្ធ របស់សត្វនោះ នឹងមិនរលត់ទៅឬ ។ ពួកសត្វទាំងអស់ កាលច្យុត កាលចូលទៅកាន់អសញ្ញសត្វ វេទនាខន្ធ របស់សត្វទាំងនោះ មិនកើតឡើង ឯសញ្ញាខន្ធរបស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ ពួកសត្វ កាលបរិនិព្វានវេទនាខន្ធ របស់សត្វទាំងនោះ មិនកើតឡើងផង សញ្ញាខន្ធនឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត សញ្ញាខន្ធ របស់សត្វណា នឹងមិនរលត់ទៅ វេទនាខន្ធ របស់សត្វនោះ មិនកើតឡើងឬ ។ អើ ។

[ ២៦០ ] រូបក្ខន្ធ មិនកើតឡើង ក្នុងទីណា ។បេ។

[ ២៦១ ] រូបក្ខន្ធ របស់សត្វណា មិនកើតឡើង ក្នុងទីណា វេទនាខន្ធរបស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះឬ ។ ពួកសត្វ កាលច្យុតចាកបញ្ចវោការភព និងពួកអរូបព្រហ្ម រូបក្ខន្ធរបស់សត្វទាំងនោះ មិនកើតឡើងក្នុងទីនោះ ឯវេទនាខន្ធរបស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន កាលច្យុតចាកអសញ្ញសត្វ រូបក្ខន្ធ របស់សត្វទាំងនោះ មិនកើតឡើងផង វេទនាខន្ធ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា រូបក្ខន្ធ របស់សត្វនោះ មិនកើតឡើងក្នុងទីនោះឬ ។ ពួកសត្វ កាលចូលទៅកាន់អសញ្ញសត្វ វេទនាខន្ធ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ

ឯរូបក្ខន្ធ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន កាលច្យុតចាកអសញ្ញសត្វ វេទនាខន្ធ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង រូបក្ខន្ធមិនកើតឡើងផង ក្នុងទីនោះ ។

[ ២៦២ ] វេទនាខន្ធរបស់សត្វណា មិនកើតឡើង ក្នុងទីណា សញ្ញាខន្ធរបស់សត្វនោះ នឹងមិនរលត់ទៅក្នុងទីនោះឬ ។ ពួកសត្វ កាលច្យុតចាកចតុវោការភព និងបញ្ចវោការភព វេទនាខន្ធ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ ឯសញ្ញាខន្ធ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន និងពួកអសញ្ញសត្វ វេទនាខន្ធរបស់សត្វទាំងនោះ មិនកើតឡើងផង សញ្ញាខន្ធ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សញ្ញាខន្ធ របស់សត្វណា នឹងមិនរលត់ទៅក្នុងទីណា វេទនាខន្ធរបស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ អើ ។

[ ២៦៣ ] រូបក្ខន្ធ របស់សត្វណា មិនកើតហើយ វេទនាខន្ធ របស់សត្វនោះ នឹងរលត់ទៅឬ ។ ពួកសត្វ កាលបរិនិព្វាន រូបក្ខន្ធ របស់សត្វទាំងនោះ មិនកើតហើយ ឯវេទនាខន្ធ របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ រូបក្ខន្ធរបស់ពួកសត្វនោះ ក្រៅនេះ កើតហើយផង វេទនាខន្ធ នឹងរលត់ទៅផង ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា នឹងរលត់ទៅ រូបក្ខន្ធ របស់សត្វនោះ កើតហើយឬ ។ អើ ។

[ ២៦៤ ] វេទនាខន្ធ របស់សត្វណា កើតហើយ សញ្ញាខន្ធ របស់សត្វនោះ នឹងរលត់ទៅឬ ។ ពួកសត្វកាលបរិនិព្វាន វេទនាខន្ធរបស់សត្វទាំងនោះ

កើតហើយ ឯសញ្ញាខន្ធ របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ វេទនាខន្ធ របស់ពួកសត្វនោះ ក្រៅនេះ កើតហើយផង សញ្ញាខន្ធ នឹងរលត់ទៅផង ។ មួយយ៉ាងទៀត សញ្ញាខន្ធ របស់សត្វណា នឹងរលត់ទៅ វេទនាខន្ធ របស់សត្វនោះ កើតហើយឬ ។ អើ ។

[ ២៦៥ ] រូបក្ខន្ធ របស់សត្វណា កើតហើយ ។បេ។

[ ២៦៦ ] រូបក្ខន្ធ របស់សត្វណា កើតហើយ ក្នុងទីណា វេទនាខន្ធរបស់សត្វនោះ នឹងរលត់ទៅក្នុងទីនោះឬ ។ ពួកសត្វ កាលបរិនិព្វាន ក្នុងបញ្ចវោការភព និងពួកអសញ្ញសត្វ រូបក្ខន្ធរបស់សត្វទាំងនោះ កើតហើយ ក្នុងទីនោះ ឯវេទនាខន្ធរបស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ រូបក្ខន្ធរបស់ពួកសត្វ ជាបញ្ចវោការនោះ ក្រៅនេះ កើតហើយផង វេទនាខន្ធ នឹងរលត់ទៅផង ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា រូបក្ខន្ធ របស់សត្វនោះ កើតហើយក្នុងទីនោះឬ ។ ពួកសត្វកាលចូលទៅកាន់សុទ្ធាវាស និងពួកអរូបព្រហ្ម វេទនាខន្ធ របស់សត្វទាំងនោះ នឹងរលត់ទៅក្នុងទីនោះ ឯរូបក្ខន្ធ របស់សត្វទាំងនោះ មិនកើតហើយ ក្នុងទីនោះទេ វេទនាខន្ធរបស់ពួកសត្វជាបញ្ចវោការនោះ ក្រៅនេះ នឹងរលត់ទៅផង រូបក្ខន្ធ កើតហើយផង ក្នុងទីនោះ ។

[ ២៦៧ ] វេទនាខន្ធរបស់សត្វណា កើតហើយ ក្នុងទីណា សញ្ញាខន្ធរបស់សត្វនោះ នឹងរលត់ទៅក្នុងទីនោះឬ ។ ពួកសត្វកាលបរិនិព្វាន វេទនាខន្ធរបស់សត្វទាំងនោះ កើតហើយ ក្នុងទីនោះ ឯសញ្ញាខន្ធ របស់សត្វទាំងនោះ

នឹងមិនរលត់ទៅ ក្នុងទីនោះទេ វេទនាខន្ធ របស់ពួកសត្វ ជាចតុវោការ និង បញ្ចវោការនោះ ក្រៅនេះ កើតហើយផង សញ្ញាខន្ធ នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សញ្ញាខន្ធ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា វេទនាខន្ធ របស់សត្វនោះ កើតហើយក្នុងទីនោះឬ ។ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស សញ្ញាខន្ធ របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនកើតហើយ ក្នុងទីនោះទេ សញ្ញាខន្ធរបស់ពួកសត្វជាចតុវោការ និងបញ្ចវោការនោះ ក្រៅនេះ នឹងរលត់ទៅផង វេទនាខន្ធកើតហើយផង ក្នុងទីនោះ ។

[ ២៦៨ ] រូបក្ខន្ធ របស់សត្វណា មិនកើតហើយ វេទនាខន្ធ របស់សត្វនោះ នឹងមិនរលត់ទៅឬ ។ មិនមានទេ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា នឹងមិនរលត់ទៅ រូបក្ខន្ធ របស់សត្វនោះ មិនកើតហើយឬ ។ កើតហើយ ។

[ ២៦៩ ] វេទនាខន្ធ របស់សត្វណា មិនកើតហើយ សញ្ញាខន្ធ របស់សត្វនោះ នឹងមិនរលត់ទៅឬ ។ មិនមានទេ ។ មួយយ៉ាងទៀត សញ្ញាខន្ធរបស់សត្វណា នឹងមិនរលត់ទៅ វេទនាខន្ធ របស់សត្វនោះ មិនកើតហើយឬ ។ កើតហើយ ។

[ ២៧០ ] រូបក្ខន្ធ មិនកើតហើយ ក្នុងទីណា ។បេ។

[ ២៧១ ] រូបក្ខន្ធរបស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា វេទនាខន្ធរបស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលចូលទៅ

កាន់សុទ្ធាវាស និងពួកអរូបព្រហ្ម រូបក្ខន្ធ របស់សត្វទាំងនោះ មិនកើតឡើង ហើយ ក្នុងទីនោះ ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ ទៅក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងសុទ្ធាវាស កាលបរិនិព្វានក្នុង អរូបភព រូបក្ខន្ធ របស់សត្វទាំងនោះ មិនកើតឡើងហើយផង វេទនាខន្ធនឹង មិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វេទនាខន្ធ របស់សត្វណា នឹង មិនរលត់ទៅក្នុងទីណា រូបក្ខន្ធ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទី នោះដែរឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព និងពួកអសញ្ញសត្វ វេទនាខន្ធ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ ឯរូបក្ខន្ធ របស់សត្វ ទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសត្វ កាលបរិ- និព្វានក្នុងសុទ្ធាវាស កាលបរិនិព្វានក្នុងអរូបភព វេទនាខន្ធ របស់សត្វទាំង នោះ នឹងមិនរលត់ទៅផង រូបក្ខន្ធ មិនកើតឡើងហើយផង ក្នុងទីនោះ ។

[ ២៧២ ] វេទនាខន្ធ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា សញ្ញាខន្ធរបស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាល ចូលទៅកាន់សុទ្ធាវាស វេទនាខន្ធ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះ ឯសញ្ញាខន្ធ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅ ក្នុងទីនោះ

ទេ ពួកសត្វ កាលបរិនិព្វាន ក្នុងសុទ្ធាវាស និងពួកអសញ្ញសត្វ វេទនាខន្ធ របស់សត្វទាំងនោះ មិនកើតឡើងហើយផង សញ្ញាខន្ធ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សញ្ញាខន្ធ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា វេទនាខន្ធ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វាន សញ្ញាខន្ធ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ ឯវេទនាខន្ធ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងសុទ្ធាវាស និងពួកអសញ្ញសត្វ សញ្ញាខន្ធ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង វេទនាខន្ធ មិនកើតឡើងហើយផង ក្នុងទីនោះ ។

ឧប្បាទនិរោធវារៈ ចប់

បវត្តិវារៈ ចប់

# អដ្ឋកថា

## បវត្តិវារៈ

[ ១១៧-២៧២ ] ឥឡូវនេះ ព្រះមានព្រះភាគទ្រង់ផ្ដើមបវត្តិវារៈ ដោយន័យជាដើមថា **យស្ស រូបក្ខន្ធោ** ។ សួរថា ព្រោះហេតុអ្វី ទើបទ្រង់មិនត្រាស់ឧទ្ទេសវារៈក្នុងបវត្តិវារៈនេះ ឆ្លើយថា ព្រោះជាន័យដែលទ្រង់សម្ដែងហើយខាងដើម ។ ឯន័យក្នុងឧទ្ទេសវារៈ ទ្រង់សម្ដែងហើយក្នុងបណ្ណត្តិវារៈ ។ ដោយន័យនោះ ទើបព្រះមានព្រះភាគមិនត្រាស់ឧទ្ទេសវារៈនោះ ទ្រង់ផ្ដើមនិទ្ទេសវារៈតែម្ដង ព្រោះមិនត្រាស់ឧទ្ទេសវារៈក្នុងបណ្ណត្តិវារៈនេះ បុគ្គលណាមួយ ក៏អាចជ្រាបបាន ។

អន្តរវារៈ ៣ គឺ **ឧប្បាទវារ ១ និរោធវារ ១ ឧប្បាទនិរោធវារ ១** រមែងមានក្នុងមហាវារៈ ពោល គឺបវត្តិវារៈនេះ ។ ក្នុងវារៈទាំង ៣ នោះ វារៈទី ១ ហៅថា **ឧប្បាទវារ** ព្រោះសម្ដែងលក្ខណៈនៃការកើតឡើងរបស់ធម៌ទាំងឡាយ ។ វារៈទី ២ ហៅថា **និរោធវារ** ព្រោះសម្ដែងលក្ខណៈនៃការរលត់របស់ធម៌ទាំងឡាយនោះឯង ។ វារៈទី ៣ ហៅថា **ឧប្បាទនិរោធវារ** ព្រោះសម្ដែងលក្ខណៈទាំងពីរ ។

ព្រះមានព្រះភាគ ទ្រង់សម្ដែងអាការ នៃការកើតឡើងរបស់ធម៌ទាំងឡាយ ក្នុងបវត្តិវារៈនេះ ដោយឧប្បាទវារៈ ទ្រង់សម្ដែងការមិនទៀងរបស់ធម៌ទាំងឡាយនោះឯង ដោយនិរោធវារៈថា ឈ្មោះថា ធម្មជាតដែលកើតឡើងហើយ ទៀង រមែងមិនមាន ទ្រង់សម្ដែងការកើតឡើង និងការមិនទៀងទាំងពីរនោះ ដោយឧប្បាទនិរោធវារៈ ។ ក្នុងឧប្បាទវារៈនោះ មានប្រភេទនៃកាល

៦ យ៉ាង ដោយអំណាចអទ្ធា ៣ គឺ **បច្ចុប្បន្ន ១ អតីត ១ អនាគត ១** អតីត និងបច្ចុប្បន្ន ១ អនាគត និងបច្ចុប្បន្ន ១ អនាគត និងអតីត ១ ។

ក្នុងកាលទាំងនោះ បទថា **យស្ស រូបក្ខន្ធោ ឧប្បជ្ជតិ** គប្បីជ្រាបកាលជាបច្ចុប្បន្ន ដោយអំណាចនៃឈ្មោះដែលជាបច្ចុប្បន្ន បច្ចុប្បន្ននោះទ្រង់ត្រាស់មុនថា បច្ចុប្បន្ននោះ ជាធម្មជាតដែលបុគ្គលគប្បីដឹងដោយល្អហួសគណនា ព្រោះភាពដែលធម៌ទាំងឡាយជាបច្ចុប្បន្ន បុគ្គលគប្បីកាន់យកបានដោយប្រចក្ស ។

គប្បីជ្រាបអតីតកាល ដោយអំណាចនៃឈ្មោះដែលជាអតីតថា **យស្ស រូបក្ខន្ធោ ឧប្បជ្ជិត្ថ** ។ ឯអតីតកាលនោះ លោកពោលជាគម្រប់ ២ ព្រោះអតីតធម៌ ដែលធ្លាប់កើតឡើងហើយខាងដើម ជាធម៌ដែលបុគ្គលគប្បីកំណត់ដឹងដោយប្រចក្សល្អជាងអនាគត ដែលបុគ្គលគប្បីកំណត់ដឹងដោយអនុមាន ។

គប្បីជ្រាបអនាគតកាល ដោយអំណាចនៃឈ្មោះ ដែលជាអនាគតថា **យស្ស រូបក្ខន្ធោ ឧប្បជ្ជិស្សតិ** ។ អនាគតកាលនោះ លោកពោលជាគម្រប់ ៣ ព្រោះកាន់យកថា ធម៌ទាំងឡាយបែបនេះ នឹងកើតឡើងក្នុងអនាគត ដោយអំណាចធម៌ដែលធ្លាប់កើតឡើងហើយខាងក្រោយ ដោយប្រចក្ស និងដោយធម៌ ដែលកាន់យកហើយ ដោយអនុមាន ។

ពាក្យសួរថា **យស្ស រូបក្ខន្ធោ ឧប្បជ្ជតិ តស្ស វេទនាក្ខន្ធោ ឧប្បជ្ជិត្ថ** គប្បីជ្រាបកាលដែលជាអតីត និងបច្ចុប្បន្ន ដោយអំណាចឈ្មោះ ដែលជាអតីត ។ អតីត និងបច្ចុប្បន្ន ( បច្ចុប្បន្នាតីតវារៈ ) នោះ លោកពោលជា

*គម្រប់ ៤ ព្រោះអតីត និងបច្ចុប្បន្ននោះ បុគ្គលគប្បីកំណត់ដឹងបានងាយជាងកាលទាំង ៣ ដែលលាយឡំគ្នា ។*

*គប្បីជ្រាបអនាគត និងបច្ចុប្បន្ន ដោយអំណាចឈ្មោះដែលជាអនាគត និងឈ្មោះដែលជាបច្ចុប្បន្នថា* **យស្ស រូបក្ខន្ធោ ឧប្បជ្ជតិ តស្ស វេទនា-ក្ខន្ធោ ឧប្បជ្ជិស្សតិ ។** *អនាគត និងបច្ចុប្បន្ននោះ លោកពោលជាគម្រប់ ៥ ព្រោះកាន់យកថា អនាគត និងបច្ចុប្បន្ននោះ ជាកាលដែលបុគ្គលគប្បីដឹងបានងាយជាងដោយអត្ថ ព្រោះធម៌ទាំងឡាយ ដែលគប្បីកាន់យកដោយប្រចក្សមាន ។*

*គប្បីជ្រាបអនាគត និងអតីត ដោយឈ្មោះដែលជាអនាគត និងអតីតថា* **យស្ស រូបក្ខន្ធោ ឧប្បជ្ជិត្ថ តស្ស វេទនាក្ខន្ធោ ឧប្បជ្ជិស្សតិ** *អនាគត និងអតីតនោះ គប្បីដឹងបានលំបាកជាងកាលទាំងឡាយមុនៗ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ក្នុងលំដាប់ទី ៦ ។*

*ក្នុងប្រភេទនៃកាលទាំង ៦ នោះ បច្ចុប្បន្នកាល ដែលជាកាលទី ១ មាន ៣ វារៈ គឺដោយបុគ្គល ដោយឱកាស ដោយបុគ្គល និងឱកាស ( បុគ្គលវារៈ ឱកាសវារៈ និងបុគ្គលោកាសវារៈ ) ។*

*ក្នុងវារៈទាំង ៣ នោះ ការសម្តែងការកើតឡើងនៃខន្ធទាំងឡាយ ដោយអំណាចបុគ្គល ដោយបទថា* **យស្ស** *ឈ្មោះថា បុគ្គលវារៈ ។*

*ការសម្តែងការកើតឡើងនៃខន្ធទាំងឡាយ ដោយអំណាចឱកាស ដោយបទថា* **យត្ថ** *ឈ្មោះថា ឱកាសវារៈ ។*

*ការសម្តែងការកើតឡើងនៃខន្ធទាំងឡាយ ដោយអំណាចបុគ្គល និង ឱកាស ដោយពាក្យថា* **យស្ស យត្ថ** *ឈ្មោះថា បុគ្គលោកាសវារៈ ។*

*វារៈទាំង ៣ នេះ ទ្រង់សម្តែងអនុលោមន័យមុនហើយ ទើបសម្តែង បដិលោមន័យតាមក្រោយ ។ ក្នុងអនុលោមន័យ និងបដិលោមន័យ ការ សម្តែងការកើតឡើង ដោយបទថា* **ឧប្បជ្ជតិ** *ប្រែថា កំពុងកើត* **ឧប្បជ្ជិត្ថ** *ប្រែថា កើតហើយ* **ឧប្បជ្ជិស្សតិ** *ប្រែថា នឹងកើត ឈ្មោះថា អនុលោមន័យ ការសម្តែងការមិនកើតឡើងដោយបទថា* **នុប្បជ្ជតិ** *ប្រែថា មិនមែនកំពុង កើត* **នុប្បជ្ជិត្ថ** *ប្រែថា មិនមែនកើតហើយ* **នុប្បជ្ជិស្សតិ** *ប្រែថា មិនមែន នឹងកើត ឈ្មោះថា បដិលោមន័យ ។*

*ក្នុងអនុលោមន័យរបស់បុគ្គលវារៈ ក្នុងបច្ចុប្បន្នកាលនោះ មាន យមកៈ ១០ យ៉ាង ព្រោះរាប់ហើយ មិនរាប់ទៀត គឺយមកៈ ៤ យ៉ាង ដែលមានរូបក្ខន្ធជាមូលយ៉ាងនេះថា*

*រូបក្ខន្ធរបស់សត្វណាកើតឡើង វេទនាខន្ធរបស់សត្វនោះ ក៏កើតឡើង ដែរឬ ។ មួយយ៉ាងទៀត វេទនាខន្ធរបស់សត្វណាកើតឡើង រូបក្ខន្ធរបស់ សត្វនោះ ក៏កើតឡើងដែរឬ ។*

*រូបក្ខន្ធរបស់សត្វណាកើតឡើង សញ្ញាខន្ធរបស់សត្វនោះ ក៏កើតឡើង ដែរឬ ។ មួយយ៉ាងទៀត សញ្ញាខន្ធរបស់សត្វណាកើតឡើង រូបក្ខន្ធរបស់ សត្វនោះ ក៏កើតឡើងដែរឬ ។*

*រូបក្ខន្ធរបស់សត្វណាកើតឡើង សង្ខារក្ខន្ធរបស់សត្វនោះ ក៏កើតឡើង*

ដែរឬ ។ មួយយ៉ាងទៀត សង្ខារក្ខន្ធរបស់សត្វណាកើតឡើង រូបក្ខន្ធរបស់សត្វនោះ ក៏កើតឡើងដែរឬ ។

រូបក្ខន្ធ របស់សត្វណាកើតឡើង វិញ្ញាណក្ខន្ធ របស់សត្វនោះ ក៏កើតឡើងដែរឬ ។ មួយយ៉ាងទៀត វិញ្ញាណក្ខន្ធ របស់សត្វណាកើតឡើង រូបក្ខន្ធរបស់សត្វនោះ ក៏កើតឡើងដែរឬ ។

យមកៈ ៣ មានវេទនាខន្ធជាមូល ដោយន័យជាដើមថា វេទនាខន្ធ របស់សត្វណាកើតឡើង សញ្ញាខន្ធ របស់សត្វនោះ ក៏កើតឡើងដែរឬ ។

យមកៈ ២ មានសញ្ញាខន្ធជាមូល យមកៈ ១ មានសង្ខារក្ខន្ធជាមូល ។

ក្នុងយមកៈទាំង ១០ នោះ យមកៈ ៤ មានរូបក្ខន្ធជាមូល ទ្រង់វិសជ្ជនាយមកៈដើមតែម្យ៉ាងប៉ុណ្ណោះ យមកៈដ៏សេស ៣ ទៀត មានការវិសជ្ជនា ដូចគ្នានឹងយមកៈដើមនោះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់សង្ខេបដើម្បីឆាយក្នុងភាសាដែលជាបែបផែន ។ ក្នុងមូលទាំងឡាយ មានវេទនាខន្ធជាមូលជាដើម ការវិសជ្ជនាតែម្យ៉ាងដូចគ្នា ដោយពាក្យថា **អាមន្តា** ព្រោះហេតុនោះ គប្បីជ្រាបថា ព្រះមានព្រះភាគ ទ្រង់វិសជ្ជនាយមកៈ ១០ យ៉ាងហើយ ដោយការវិសជ្ជនាយមកៈនីមួយៗ ក្នុងអនុលោមន័យ ក្នុងបុគ្គលវារៈ ក្នុងបច្ចុប្បន្នកាលទាំងនេះ យ៉ាងនេះថា យមកៈទាំងនោះ ទ្រង់សង្ខេបដើម្បីឆាយយល់ក្នុងភាសាដែលជាបែបផែន ។ ក្នុងអនុលោមន័យក្នុងវារៈទាំង ៣ ក្នុងបច្ចុប្បន្នកាល មានយមកៈ ៣០ គឺក្នុងបុគ្គលវារៈ មាន

១០ យ៉ាងណា ក្នុងឱកាសវារៈក៏មាន ១០ ក្នុងបុគ្គលោកាសវារៈក៏មាន ១០ យ៉ាងនោះ យមកៈក្នុងបច្ចុប្បន្នកាលទាំងអស់ មាន ៦០ គឺក្នុងអនុលោមន័យ មាន ៣០ យ៉ាងណា ក្នុងបដិលោមន័យ ក៏មាន ៣០ យ៉ាងនោះ ។ ក្នុងយមកៈ ៦០ នោះ គប្បីជ្រាបថា មានបុច្ឆា ១២០ មានអត្ថ ២៤០ ។ គប្បីជ្រាបវារៈទាំង ៦ ដោយអំណាចអនុលោម និងបដិលោមដោយការផ្សេងគ្នានៃបុគ្គលជាដើម ក្នុងការផ្សេងគ្នានៃកាល ៥ ដ៏សេស យ៉ាងនេះ ។ យមកៈ ៣០០ គឺមានយមកៈនីមួយៗ ៦០ ព្រោះធ្វើវារៈនីមួយៗ ឲ្យជា ១០ រួមជាមួយយមកៈ ៣០០ ខាងដើម ទើបជាយមកៈ ៣៦០ បុច្ឆា ៧២០ អត្ថ ១៤៤០ នេះ ជាការកំណត់ព្រះបាលី ក្នុងឧប្បាទវារៈមុន ។ ក្នុងឧប្បាទវារៈយ៉ាងណា គប្បីជ្រាបថា ក្នុងនិរោធវារៈ ក្នុងឧប្បាទនិរោធវារៈក៏យ៉ាងនោះ ព្រោះហេតុនោះ ទើបក្នុងបវត្តិមហាវារៈទាំងអស់ មានយមកៈ ១០៨០ បុច្ឆា ២១៦០ អត្ថ ៤៣២០ តែព្រះបាលីក្នុងឧប្បាទវារៈ និងនិរោធវារៈ ព្រះមានព្រះភាគទ្រង់វិសជ្ជនាដោយសង្ខេបហើយ នូវយមកៈនីមួយៗ ប៉ុណ្ណោះក្នុងវារៈនោះៗ ក្នុងប្រភេទនៃកាល ដែលមិនលាយឡំគ្នា ៣ យ៉ាង ក្នុងប្រភេទនៃកាលដែលលាយឡំគ្នា ៣ យ៉ាង ព្រះមានព្រះភាគ ទ្រង់វិសជ្ជនាយមកៈនីមួយៗ ក្នុងមូលដែលមានវេទនាខន្ធជាមូលជាដើម ដោយន័យជាដើមថា វេទនាខន្ធ របស់សត្វណាកើតឡើង សញ្ញាខន្ធ របស់សត្វនោះ កើតឡើងហើយដែរឬ ។ ក្នុងឧប្បាទនិរោធវារៈ ព្រះមានព្រះភាគ ក៏ទ្រង់វិសជ្ជនាយមកៈនោះក្នុងប្រភេទនៃកាលទាំង ៦ ។ គប្បីជ្រាបថា យមកៈដ៏សេស

*ទ្រង់សង្ខេប ព្រោះយមកៈទាំងនោះ ទ្រង់វិសជ្ជនាឲ្យស្មើជាមួយគ្នានឹងយមកៈនោះ នេះជាការកំណត់ព្រះបាលី ក្នុងបវត្តិមហាវារៈទាំងមូល ។*

*ដើម្បីវិនិច្ឆ័យអត្ថរបស់ខន្ធយមកៈនេះ គប្បីជ្រាបលក្ខណៈដូចតទៅ បណ្ឌិតគប្បីជ្រាបការវិនិច្ឆ័យអត្ថនៃបញ្ហា ៤ យ៉ាង ក្នុងបវត្តិមហាវារៈនេះ ដែលលោកដាក់វិសជ្ជនា ៥ យ៉ាង ក្នុងឋានៈ ២៧ ក្នុងអត្ថវិនិច្ឆ័យនោះ ។ ក្នុងអត្ថវិនិច្ឆ័យនោះ ឈ្មោះបញ្ហា ៤ យ៉ាងនេះ គឺ* **បុរេបញ្ហា ១ បច្ឆាបញ្ហា ១ បរិបុណ្ណបញ្ហា ១ មោឃបញ្ហា ១ ។** *ក្នុងយមកៈនីមួយៗ មានបុច្ឆា ២ យ៉ាង ( គឺអនុលោម និងបដិលោម ) បុច្ឆានីមួយៗ ក៏មានបទ ២ យ៉ាង គឺសន្និដ្ឋាន និងសំសយៈ ។*

*ក្នុងបញ្ហា ៤ យ៉ាងនោះ ក្នុងការវិសជ្ជនានូវបញ្ហាណា រមែងបានការកើតឡើង ឬការរលត់ទៅនៃខន្ធ ដែលកាន់យកដោយបទត្រឹមតែបទមួយ បញ្ហានេះ ឈ្មោះថា* **បុរេបញ្ហា ។**

*ក្នុងការវិសជ្ជនានូវបញ្ហាណា រមែងបាននូវការកើតឡើង ឬការរលត់ទៅនៃខន្ធដែលកាន់យកដោយបទទាំងពីរ បញ្ហានេះ ឈ្មោះថា* **បច្ឆាបញ្ហា ។**

*ក្នុងការវិសជ្ជនានូវបញ្ហាណា រមែងបាននូវការកើតឡើង ឬការរលត់ទៅនៃខន្ធដែលកាន់យកហើយ ដោយបទត្រឹមតែមួយខ្លះ ដោយបទទាំងពីរខ្លះ បញ្ហានេះ ឈ្មោះថា* **បរិបុណ្ណបញ្ហា** *តែការហាម ឬការបដិសេធ រមែងបានក្នុងការវិសជ្ជនានូវបញ្ហាណា បញ្ហានេះ ឈ្មោះថា* **មោឃបញ្ហា** *ព្រោះមោឃបញ្ហានេះ បើទ្រង់មិនសម្តែង បុគ្គលណាមួយក៏មិនអាចដឹងបាន ព្រោះ*

*ហេតុនោះ ទើបសម្តែងបញ្ហានោះ ។*

*ការកើតឡើងនៃវេទនាខន្ធ ដែលលោកកាន់យកដោយបទត្រឹមតែបទមួយ រមែងបានក្នុងការវិសជ្ជនានេះថា* **ឧប្បជ្ជតិ** *ប្រែថា កើតឡើង ក្នុងពាក្យសួរថា រូបក្ខន្ធមិនកើតឡើង ក្នុងទីណា វេទនាខន្ធមិនកើតឡើង ក្នុងទីនោះដែរឬ ព្រោះហេតុនោះ បញ្ហានេះផង បញ្ហាដទៃដែលមានសភាពបែបនេះផង គប្បីជ្រាបថាជា* **បុរេបញ្ហា ។**

*ការកើតឡើងនៃរូប និងវេទនាខន្ធ ក្នុងអតីតរបស់សត្វណាមួយ ដែលលោកកាន់យកដោយបទទាំងពីរ រមែងបានក្នុងការវិសជ្ជនានេះថា* **អាមន្តា** *ប្រែថា អើ ក្នុងពាក្យសួរថា រូបក្ខន្ធរបស់សត្វណាកើតឡើងហើយ វេទនា-ខន្ធរបស់សត្វនោះ កើតឡើងហើយដែរឬ ព្រោះហេតុនោះ បញ្ហានេះ និងបញ្ហាដទៃដែលមានសភាពយ៉ាងនេះ ឈ្មោះថា* **បច្ឆាបញ្ហា ។**

*ការកើតឡើងរបស់រូបក្ខន្ធ ដែលលោកកាន់យកហើយដោយបទត្រឹមតែមួយប៉ុណ្ណោះ រមែងបានក្នុងកោដ្ឋាសនេះថា ពួកសត្វចូលទៅកាន់អសញ្ញ-សត្វ រូបក្ខន្ធរបស់សត្វទាំងនោះកើតឡើង ឯវេទនាខន្ធរបស់សត្វទាំងនោះមិនកើតឡើងទេ ក្នុងការឆ្លើយនេះ ពាក្យថា ពួកសត្វចូលទៅកាន់អសញ្ញ-សត្វជាដើម ក្នុងបឋមបុច្ឆានេះថា រូបក្ខន្ធរបស់សត្វណាកើតឡើង វេទនាខន្ធរបស់សត្វនោះ ក៏កើតឡើងដែរឬ ដូច្នេះ ការកើតឡើងរបស់រូប និងវេទនា-ខន្ធដែលលោកកាន់យកហើយដោយបទទាំងពីរ រមែងបានក្នុងកោដ្ឋាសនេះថា ពួកសត្វចូលទៅកាន់បញ្ចវោការភព រូបក្ខន្ធកើតឡើងផង របស់សត្វទាំង*

*នោះ វេទនាខន្ធកើតឡើងផង ព្រោះហេតុនោះ បញ្ហានេះ និងបញ្ហាដទៃដែលមានសភាពបែបនេះ គប្បីជ្រាបថាជា* **បរិបុណ្ណាបញ្ហា** *សូម្បីពាក្យថា* **បុរេបច្ឆាបញ្ហា** *ក៏ជាឈ្មោះរបស់បរិបុណ្ណបញ្ហានោះឯង ។*

*ក្នុងការវិសជ្ជនា បរិបុណ្ណបញ្ហានេះ ព្រះមានព្រះភាគទ្រង់សម្តែងការកើតឡើងនៃរូបក្ខន្ធនោះឯង ដែលសង្គ្រោះដោយបទមួយ ក្នុងបុរិមកោដ្ឋាស ក្នុងទុតិយកោដ្ឋាស ការកើតឡើងនៃរូបក្ខន្ធ និងវេទនាខន្ធ ដែលលោកកាន់យកហើយ រមែងបានដោយបទពីរ ការកើតឡើង ឬការរលត់ទៅរបស់ខន្ធដែលលោកកាន់យកហើយ រមែងបានដោយបទមួយ ក្នុងបញ្ហាណា ដោយន័យ និងលក្ខណៈនេះ បញ្ហានោះ ហៅថា* **បុរេបញ្ហា** ។

*ការកើតឡើង ឬការរលត់ទៅរបស់ខន្ធទាំងឡាយ ដែលលោកកាន់យកដោយបទទាំងពីរ រមែងបានក្នុងបញ្ហាណា បញ្ហានោះ ហៅថា* **បច្ឆាបញ្ហា** ។

*បដិក្ខេបវិសជ្ជនា រមែងបានក្នុងការវិសជ្ជនានេះ ដោយបទថា* **នត្ថិ** *ក្នុងពាក្យសួរនេះថា រូបក្ខន្ធរបស់សត្វណា មិនកើតឡើងហើយ វេទនាខន្ធរបស់សត្វនោះ ក៏មិនកើតឡើងហើយដែរឬ ។*

*បដិសេធវិសជ្ជនា រមែងបានក្នុងការវិសជ្ជនានេះ ដោយពាក្យថា* **នោ** *ក្នុងពាក្យសួរថា រូបក្ខន្ធរបស់សត្វណាកើតឡើង វេទនាខន្ធរបស់សត្វនោះរលត់ទៅដែរឬ ហេតុនោះ បញ្ហានេះ និងបញ្ហាដទៃដែលមានទំនងយ៉ាងនេះរួម ២ យ៉ាង គប្បីជ្រាបថាជា មោឃបញ្ហា ។ មោឃបញ្ហានេះ ហៅថា*

**ជេនគុច្ចបញ្ហា** ក៏បាន គប្បីជ្រាបបញ្ហាទាំង ៤ យ៉ាងនេះសិន ។

វិសជ្ជនាទាំងនេះ គឺបាលិគតិវិសជ្ជនា បដិវចនវិសជ្ជនា សរូបទស្សនវិសជ្ជនា បដិក្ខេបវិសជ្ជនា បដិសេធវិសជ្ជនា ឈ្មោះថា វិសជ្ជនា ៥ យ៉ាង ។ ក្នុងវិសជ្ជនា ៥ យ៉ាងនោះ វិសជ្ជនាណាជាបទបាលីប៉ុណ្ណោះ ដែលលោកវិសជ្ជនាអត្ថ វិសជ្ជនានេះ ឈ្មោះថា **បាលិគតិវិសជ្ជនា** បាលិគតិវិសជ្ជនានោះ រមែងបានក្នុងបុរេបញ្ហា ។ ពាក្យឆ្លើយនេះថា **ឧប្បជ្ជតិ** ប្រែថា កើតឡើង ក្នុងសំណួរថា រូបក្ខន្ធ មិនកើតឡើង ក្នុងទីណា វេទនាខន្ធ មិនកើតឡើងក្នុងទីនោះដែរឬ ត្រឹមតែជាបទបាលីប៉ុណ្ណោះ ដែលទ្រង់វិសជ្ជនាអត្ថរៀបរយហើយ ព្រោះហេតុនោះ គប្បីជ្រាបការវិសជ្ជនា ដោយបាលិគតិវិសជ្ជនា ក្នុងឋានៈបែបនេះយ៉ាងនេះ ។

វិសជ្ជនាណាដែលលោកវិសជ្ជនាអត្ថ ដោយភាពជាពាក្យឆ្លើយ វិសជ្ជនានេះ ឈ្មោះថា **បដិវចនវិសជ្ជនា** បដិវចនវិសជ្ជនានោះ រមែងបានក្នុងបច្ចាបញ្ហា ។ វិសជ្ជនានេះ ដោយពាក្យថា **អាមន្តា** ប្រែថា អើ ក្នុងពាក្យសួរថា រូបក្ខន្ធរបស់សត្វណា កើតឡើងហើយ វេទនាខន្ធរបស់សត្វនោះ កើតឡើងហើយដែរឬ ដែលទ្រង់វិសជ្ជនាអត្ថរៀបរយហើយ ដោយភាពជាពាក្យឆ្លើយនោះឯង ព្រោះហេតុនោះ គប្បីជ្រាបបដិវចនវិសជ្ជនាក្នុងឋានៈបែបនេះ ។

ពាក្យវិសជ្ជនាណា ដែលលោកសម្តែងអត្ថដោយសរុប វិសជ្ជនានេះ ឈ្មោះថា **សរូបទស្សនវិសជ្ជនា** សរូបទស្សនវិសជ្ជនានោះ រមែងបានក្នុងបរិបុណ្ណបញ្ហា ។

វិសជ្ជនានេះថា **អសញ្ញសត្តំ ឧបបជ្ជន្តានំ** ពួកសត្វដែលចូលទៅកាន់អសញ្ញសត្វ ក្នុងពាក្យសួរថា រូបក្ខន្ធ របស់សត្វណាកើតឡើង វេទនាខន្ធរបស់សត្វនោះ កើតឡើងដែរឬ ដែលទ្រង់វិសជ្ជនាអត្ថរៀបរយហើយ ដោយការសំដែងសរុបថា រូបក្ខន្ធ រមែងកើតដល់បុគ្គលទាំងនេះ តែវេទនាខន្ធមិនកើត រូបក្ខន្ធ និងវេទនាខន្ធ ក៏រមែងកើតដល់បុគ្គលទាំងនេះ ព្រោះហេតុនោះគប្បីជ្រាបសរុបទស្សនវិសជ្ជនាក្នុងឋានៈបែបនេះ ។

ពាក្យវិសជ្ជនាណា ដែលលោកវិសជ្ជនាបញ្ហាដោយការហាមអត្ថ ព្រោះការមិនមានអត្ថបែបនោះ ពាក្យវិសជ្ជនានេះ ឈ្មោះថា **បដិក្ខេបវិសជ្ជនា** ។ វិសជ្ជនាណា ដែលលោកវិសជ្ជនាបញ្ហា ដោយបដិសេធអត្ថ ព្រោះមិនបាននូវអត្ថបែបនោះ ក្នុងខណៈនីមួយៗ វិសជ្ជនានេះ ឈ្មោះថា **បដិសេធវិសជ្ជនា** បដិសេធវិសជ្ជនានោះ រមែងបានក្នុងមោឃបញ្ហា ។

ពិតហើយ ពាក្យវិសជ្ជនានេះថា **នត្ថិ** ប្រែថា មិនមាន ក្នុងពាក្យសួរថា រូបក្ខន្ធរបស់សត្វណា មិនកើតឡើងហើយ វេទនាខន្ធរបស់សត្វនោះ មិនកើតឡើងហើយដែរឬ ជាពាក្យវិសជ្ជនា ដែលទ្រង់វិសជ្ជនារៀបរយហើយ ដោយការហាមអត្ថថា ឈ្មោះថា សត្វបែបនេះ រមែងមិនមាន ព្រោះហេតុនោះគប្បីជ្រាបការវិសជ្ជនាក្នុងទីទាំងពួងបែបនេះ ដោយបដិក្ខេបវិសជ្ជនា ។

ពាក្យវិសជ្ជនានេះថា **នោ** ប្រែថា មិនមែន ក្នុងពាក្យសួរថា រូបក្ខន្ធរបស់សត្វណាកើតឡើង វេទនាខន្ធរបស់សត្វនោះរលត់ទៅដែរឬ ដែលទ្រង់វិសជ្ជនារៀបរយហើយ ដោយការបដិសេធអត្ថថា ឈ្មោះថា ការរលត់ទៅ

*ព្រមជាមួយនឹងការកើតឡើង រមែងមិនបានក្នុងបដិសន្ធិក្ខណៈមួយ ព្រោះហេតុនោះ គប្បីជ្រាបវិសជ្ជនាដោយការបដិសេធក្នុងឋានៈបែបនេះ ។*

*ឥឡូវនេះ គប្បីជ្រាបបញ្ហា ៤ យ៉ាង និងការវិសជ្ជនា ៥ យ៉ាងនេះ ដែលគួរបញ្ចូលក្នុងឋានៈ ២៧ ទាំងឡាយណា គប្បីជ្រាបឋានៈទាំងនោះយ៉ាងនេះ គឺ* **អសញ្ញសត្តំ ឧបបជ្ជន្តានំ** *ជាឋានៈ* ១ **អសញ្ញសត្តេ តត្ថ** *ជាឋានៈ* ១ **អសញ្ញសត្តានំ** *ជាឋានៈ* ១ **អសញ្ញសត្តា ចវន្តានំ** *ជាឋានៈ* ១ **អរូបំ ឧបបជ្ជន្តានំ** *ជាឋានៈ* ១ **អរូបេ តត្ថ** *ជាឋានៈ* ១ **អរូបានំ** *ជាឋានៈ* ១ **អរូបា ចវន្តានំ** *ជាឋានៈ* ១ **អរូបេ បច្ឆិមភវិកានំ** *ជាឋានៈ* ១ **អរូបេ បរិនិព្វន្តានំ** *ជាឋានៈ* ១ **យេ ច អរូបំ ឧប្បជ្ជិត្វា បរិនិព្វាយិស្សន្តិ** *ជាឋានៈ* ១ **បញ្ចវោការំ ឧបបជ្ជន្តានំ** *ជាឋានៈ* ១ **បញ្ចវោការេ តត្ថ** *ជាឋានៈ* ១ **បញ្ចវោការានំ** *ជាឋានៈ* ១ **បញ្ចវោការា ចវន្តានំ** *ជាឋានៈ* ១ **បញ្ចវោការេ បច្ឆិមភវិកានំ** *ជាឋានៈ* ១ **សុទ្ធាវាសំ ឧបបជ្ជន្តានំ** *ជាឋានៈ* ១ **សុទ្ធាវាសេ តត្ថ** *ជាឋានៈ* ១ **សុទ្ធាវាសានំ** *ជាឋានៈ* ១ **សុទ្ធាវាសេ បរិនិព្វន្តានំ** *ជាឋានៈ* ១ **សព្វេសំ ឧបបជ្ជន្តានំ** *ជាឋានៈ* ១ **សព្វេសំ ចវន្តានំ** *ជាឋានៈ* ១ **បច្ឆិមភវិកានំ** *ដោយអំណាចដែលសាធារណៈដល់សត្វទាំងពួងទៀត ជាឋានៈ* ១ **បរិនិព្វន្តានំ** *ជាឋានៈ* ១ **ចតុវោការំ បញ្ចវោការំ ឧបបជ្ជន្តានំ** *ជាឋានៈ* ១ **ចតុវោការា បញ្ចវោការា ចវន្តានំ** *ជាឋានៈ* ១ *បណ្ឌិតគប្បីដាក់ពាក្យវិសជ្ជនា ៥ យ៉ាង ក្នុងឋានៈទាំង ២៧ យ៉ាងនេះហើយ គប្បីជ្រាបការវិនិច្ឆ័យអត្ថនៃបញ្ហា ៤ យ៉ាងនេះ ក្នុងបវត្តិមហាវារៈ ដោយ*

*ប្រការដូច្នេះ ។ អត្ថវិនិច្ឆ័យនោះ បណ្ឌិតជ្រាបហើយយ៉ាងនេះ កាលវិសជ្ជនាបញ្ហា រមែងជាការវិសជ្ជនាហើយដោយងាយ និងកាលវិនិច្ឆ័យនូវអត្ថ រមែងជាការវិនិច្ឆ័យហើយដោយងាយ ។*

*ន័យនេះ ក្នុងពាក្យសួរនោះថា* **យស្ស រូបក្ខន្ធោ ឧប្បជ្ជតិ** *រូបក្ខន្ធរបស់សត្វណាកើតឡើង បានដល់ រមែងសួរថា រូបក្ខន្ធកំពុងកើតក្នុងឧប្បាទក្ខណសមង្គីដល់បុគ្គលណា វេទនាក៏កំពុងកើតដល់បុគ្គលនោះឬ ព្រោះហេតុនេះ សូម្បីវេទនាខន្ធ ក៏កំពុងកើតដល់បុគ្គលនោះ ក្នុងខណៈនោះឯង ។ បទថា* **អសញ្ញសត្តំ ឧបបជ្ជន្តានំ** *អសញ្ញសត្វកើតឡើង បានដល់ កាលបុគ្គលទាំងនោះ កើតក្នុងអសញ្ញសត្តភព ដោយអំណាចបដិសន្ធិដែលមិនមែនចិត្ត ។ បទថា* **តេសំ រូបក្ខន្ធោ ឧប្បជ្ជតិ** *បានដល់ រូបក្ខន្ធកំពុងកើតត្រឹមតែម្យ៉ាងដល់អសញ្ញសត្វនោះ ឯរូបក្ខន្ធរបស់អសញ្ញសត្វដែលកើតហើយក្នុងបវត្តិកាល រមែងកើតខ្លះ រមែងរលត់ខ្លះ ព្រោះហេតុនោះ ទើបមិនត្រាស់ថា* **អសញ្ញសត្តានំ** *តែត្រាស់ថា* **អសញ្ញសត្តំ ឧបបជ្ជន្តានំ** *។ បទថា* **នោ ច តេសំ វេទនាក្ខន្ធោ ឧប្បជ្ជតិ** *បានដល់ វេទនាខន្ធរបស់អសញ្ញសត្វទាំងនោះ មិនមែនកំពុងកើត ព្រោះភាពនៃអសញ្ញសត្វនោះ មិនមានចិត្ត ។ នេះជាការវិសជ្ជនាដោយការសម្តែង ដោយសរុបក្នុងបុរិមកោដ្ឋាស នៃបរិបុណ្ណបញ្ហាក្នុងឋានៈទី ១ បណ្តាឋានៈ ២៧ យ៉ាង ។*

*បទថា* **បញ្ចវោការំ ឧបបជ្ជន្តានំ** *បានដល់ ចូលដល់បញ្ចវោការភពដោយអំណាចនៃបដិសន្ធិ ដែលលាយឡំដោយរូប និងអរូប ។ បទថា* **តេសំ**

**រូបក្ខន្ធោ ច ឧប្បជ្ជតិ វេទនាក្ខន្ធោ ច** *បានដល់ ខន្ធទាំងពីរ ពោល គឺរូប និងវេទនា រមែងកើតឡើងនោះឯង ដល់សត្វទាំងឡាយ ដែលចូលដល់បញ្ចវោការភពទាំងនោះដោយពិតប្រាកដ តែក្នុងបវត្តិកាល ខន្ធទាំងពីរនោះរមែងកើតឡើងខ្លះ រមែងរលត់ខ្លះ ដល់សត្វដែលកើតឡើងហើយ ក្នុងបញ្ចវោការភូមិនោះ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគមិនត្រាស់ថា* **បញ្ចវោការានំ** *តែត្រាស់ថា* **បញ្ចវោការំ ឧបបជ្ជន្តានំ ។** *នេះជាការវិសជ្ជនាដោយការសម្តែងដោយសរុប ក្នុងបច្ឆិមកោដ្ឋាសនៃបរិបុណ្ណបញ្ហា ក្នុងឋានៈថា* **បញ្ចវោការំ ឧបបជ្ជន្តានំ ។** *គប្បីជ្រាបការវិសជ្ជនាទាំងអស់ ដោយឧបាយនេះ ។*

*នេះជានិយមលក្ខណៈ ក្នុងការកើត និងការរលត់នេះ ។ ក្នុងខន្ធយមកៈនេះទាំងអស់ ព្រះមានព្រះភាគ ទ្រង់ត្រាស់ឧប្បាទវារៈ ដោយអំណាចនៃការកើតឡើង ក្នុងបដិសន្ធិកាលនោះឯងថា ការមិនបញ្ចេសអង្គែល នូវការកើតនិងការរលត់ក្នុងបវត្តិកាលថា កាលសត្វទាំងឡាយ កើតឡើងហើយ ក្នុងបញ្ចវោការភពនោះៗ កាលការកើតឡើង និងការរលត់ ដែលមិនមានទីបំផុតនៃខន្ធ ៥ មានក្នុងបវត្តិកាល រហូតដល់ស្លាប់ ការធ្វើនូវការចែកធម៌ទាំងឡាយ ដែលប្រព្រឹត្តទៅរហ័ស ដើម្បីសម្តែងការកើត និងការរលត់ មិនមែនធ្វើបានងាយ ដូច្នេះហើយ ទើបទ្រង់សម្តែងការកើតឡើងនៃខន្ធទាំងឡាយក្នុងបដិសន្ធិរបស់សត្វដែលកើតហើយ ដោយកម្មផ្សេងៗ ដែលញុំាងវិបាកវដ្តថ្មីៗ ឲ្យសម្រេច ជាការធ្វើបានងាយ ព្រះមានព្រះភាគ ត្រាស់និរោធវារៈ*

ដោយអំណាចការរលត់ ក្នុងមរណកាលថា ការសម្តែងការរលត់ក្នុងកាលជាទីបំផុតនៃវិបាកវដ្ត ដែលកើតឡើងហើយ ជាការធ្វើបានឆាយ ។

ឯការមិនបញ្ចោសអង្ហែល ការកើត និងការរលត់ក្នុងបវត្តិកាល នេះជាប្រមាណដូចម្តេច គឺព្រះបាលីនោះឯង ។ម្យ៉ាងទៀត ព្រះបាលីថា **បច្ឆិមភវិកានំ តេសំ រូបក្ខន្ធោ ច ឧប្បជ្ជិស្សតិ វេទនាក្ខន្ធោ ច ឧប្បជ្ជិស្សតិ** នេះ ជាប្រមាណក្រៃលែងក្នុងវារៈ នៃអនាគតកាលរបស់ឧប្បាទវារៈ ដោយពិសេសក្នុងព្រះបាលី ។ កាលភាវៈដែលសមគួរដើម្បីការកើតឡើងនៃរូបធម៌ និងអរូបធម៌ទាំងឡាយ ក្នុងបវត្តិកាលរបស់បច្ឆិមភវិកបុគ្គល សូម្បីមានការកើតឡើងក្នុងបវត្តិកាល គប្បីជ្រាបថា ព្រះមានព្រះភាគ ទ្រង់មិនកាន់យកដូច្នេះ ដោយភាវៈដែលពោលហើយ ដោយទ្រង់ធ្វើការសន្និដ្ឋានថា រូបក្ខន្ធនឹងមិនកើតឡើងផង វេទនាខន្ធ នឹងមិនកើតឡើងផង ។ ព្រះបាលីនេះថា **សុទ្ធាវាសេ បរិនិព្វន្តានំ តេសំ តត្ថ សញ្ញាក្ខន្ធោ ន និរុជ្ឈិត្ថ នោ ច តេសំ តត្ថ វេទនាក្ខន្ធោ ន និរុជ្ឈតិ** ដូច្នេះ ជាប្រមាណក្រៃលែងក្នុងការមិនពាល់ត្រូវនូវការរលត់ ក្នុងបវត្តិកាល ឯគន្ធនៃការរាប់នូវសញ្ញាខន្ធ ដែលកើតឡើង ហើយរលត់ទៅ ក្នុងបវត្តិកាល ចាប់តាំងអំពីបដិសន្ធិកាល ដែលតាំងនៅក្នុងភង្គក្ខណៈនៃចុតិចិត្ត របស់បរិនិព្វន្តបុគ្គល ក្នុងសុទ្ធាវាស រមែងមិនមាន កាលបើយ៉ាងនោះ គប្បីជ្រាបថា ព្រះមានព្រះភាគ ទ្រង់មិនកាន់យកការរលត់ក្នុងបវត្តិកាល ដោយភាវៈដែលពោលហើយ ដោយទ្រង់ធ្វើនូវការសន្និដ្ឋានថា ឯសញ្ញាខន្ធរបស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយក្នុង

ទីនោះទេ ។

បណ្ឌិតកាលជ្រាបលក្ខណៈដែលពិតប្រាកដ ក្នុងការកើតឡើង និងការរលត់ទៅនេះហើយ គួរកាន់យកការកើតឡើងដោយបដិសន្ធិកាល និងការរលត់ដោយចុតិកាលប៉ុណ្ណោះ ហើយគប្បីជ្រាបការវិនិច្ឆ័យអត្ថនៃការវិសជ្ជនាទាំងឡាយ ដែលមកហើយក្នុងឋានៈទាំងឡាយនោះៗ ដោយប្រការដូច្នេះ តែការវិនិច្ឆ័យអត្ថនោះ លោកមិនឲ្យពិស្តារហើយដោយលំដាប់នៃការវិសជ្ជនាថា ការវិនិច្ឆ័យអត្ថនោះ បុគ្គលណាមួយ ក៏អាចជ្រាបបានក្នុងឋានៈទាំងពួង ដោយន័យដែលពោលហើយក្នុងការវិសជ្ជនាដំបូង ។ បើបុគ្គលណា មិនអាចជ្រាបការវិនិច្ឆ័យអត្ថទាំងនោះ បុគ្គលនោះ គប្បីចូលទៅអង្គុយជិតអាចារ្យ ស្តាប់ដោយល្អហើយ គប្បីជ្រាបតាមន័យដែលអាចារ្យឲ្យហើយនេះយ៉ាងនេះ ។

យមកៈទាំងឡាយណា ក្នុងខន្ធ ៥ រមែងមានដោយអំណាចនៃឧប្បាទវារៈ និរោធវារៈ និងឧប្បាទៈផង និរោធៈផង ទាំងពីររួមគ្នា ដោយអំណាចនៃអនុលោមន័យ និងបដិលោមន័យ ព្រះជិនស្រីត្រាស់ហើយ នូវយមកៈទាំងឡាយនោះ ក្នុងវារៈទាំងឡាយ ក្នុងបវត្តិកាល ព្រោះទ្រង់សម្តែងហើយ នូវបុគ្គលវារៈ ឱកាសវារៈ និងបុគ្គលោកាសវារៈ ការកំណត់ព្រះបាលីនៃវារៈទាំងនោះ ព្រះមានព្រះភាគ ទ្រង់សម្តែងហើយដោយលំដាប់ សូម្បីការប្រកបអត្ថ ដើម្បីការវិនិច្ឆ័យបញ្ហា និងវិសជ្ជនា ព្រមទាំងឋានៈទាំងឡាយ នៃការវិសជ្ជនាណាមួយ

*ដោយប្រការទាំងពួង ព្រះជិនស្រី ទ្រង់សម្តែងហើយ ទ្រង់ប្រកាសហើយ ក្នុងបញ្ហានីមួយៗ លំដាប់ការវិសជ្ជនាបញ្ហា ក្នុងបវត្តិមហាវារៈនេះ ប្រព្រឹត្តទៅហើយដោយពិស្តារ ខាងមុខអំពីនេះទៅ តើបុគ្គលណាមួយ អាចពណ៌នាអត្ថនេះបាន ដូចម្តេចហ្ន៎ ព្រោះហេតុនោះ បណ្ឌិតទាំងឡាយ ចូរជ្រាបអត្ថ ដោយន័យនេះឯង ។៚*

## អដ្ឋកថាបវត្តិវារៈ ចប់

# អភិធម្មបិដក

## បរិញ្ញាវារៈ

[ ២៧៣ ] បុគ្គលណា កំណត់ដឹងនូវរូបក្ខន្ធ បុគ្គលនោះ ឈ្មោះថា កំណត់ដឹងនូវវេទនាខន្ធដែរឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងនូវវេទនាខន្ធ បុគ្គលនោះ ឈ្មោះថា កំណត់ដឹងនូវរូបក្ខន្ធដែរឬ ។ អើ ។ បុគ្គលណា មិនកំណត់ដឹងនូវរូបក្ខន្ធ បុគ្គលនោះ ឈ្មោះថា មិនកំណត់ដឹងនូវវេទនាខន្ធដែរឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គលណា មិនកំណត់ដឹងនូវវេទនាខន្ធ បុគ្គលនោះ ឈ្មោះថា មិនកំណត់ដឹងនូវរូបក្ខន្ធដែរឬ ។ អើ ។

[ ២៧៤ ] បុគ្គលណា កំណត់ដឹងហើយ នូវរូបក្ខន្ធ បុគ្គលនោះ ឈ្មោះថា កំណត់ដឹងហើយ នូវវេទនាខន្ធដែរឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងហើយ នូវវេទនាខន្ធ បុគ្គលនោះ ឈ្មោះថា កំណត់ដឹងហើយ នូវរូបក្ខន្ធដែរឬ ។ អើ ។ បុគ្គលណា មិនកំណត់ដឹងហើយ នូវរូបក្ខន្ធ បុគ្គលនោះ ឈ្មោះថា មិនកំណត់ដឹងហើយ នូវវេទនាខន្ធដែរឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គលណា មិនកំណត់ដឹងហើយ នូវវេទនាខន្ធ បុគ្គលនោះ ឈ្មោះថា មិនកំណត់ដឹងហើយ នូវរូបក្ខន្ធដែរឬ ។ អើ ។

[ ២៧៥ ] បុគ្គលណា នឹងកំណត់ដឹង នូវរូបក្ខន្ធ បុគ្គលនោះ ឈ្មោះថា នឹងកំណត់ដឹង នូវវេទនាខន្ធដែរឬ ។ អើ ។ មួយយ៉ាងទៀត បុគ្គលណា នឹងកំណត់ដឹង នូវវេទនាខន្ធ បុគ្គលនោះ ឈ្មោះថា នឹងកំណត់ដឹង នូវរូបក្ខន្ធដែរឬ ។ អើ ។ បុគ្គលណា នឹងមិនកំណត់ដឹង នូវរូបក្ខន្ធ បុគ្គលនោះ ឈ្មោះថា នឹងមិនកំណត់ដឹង នូវវេទនាខន្ធដែរឬ ។ អើ ។ មួយយ៉ាងទៀត

បុគ្គលណា នឹងមិនកំណត់ដឹង នូវវេទនាខន្ធ បុគ្គលនោះ ឈ្មោះថា នឹងមិនកំណត់ដឹង នូវរូបក្ខន្ធដែរឬ ។ អើ ។

[ ២៧៦ ] បុគ្គលណា កំណត់ដឹង នូវរូបក្ខន្ធ បុគ្គលនោះ ឈ្មោះថា កំណត់ដឹងហើយ នូវវេទនាខន្ធដែរឬ ។ ទេ ។ មួយយ៉ាងទៀត បុគ្គលណា កំណត់ដឹងហើយ នូវវេទនាខន្ធ បុគ្គលនោះ ឈ្មោះថា កំណត់ដឹងនូវរូបក្ខន្ធដែរឬ ។ ទេ ។ បុគ្គលណា មិនកំណត់ដឹងនូវរូបក្ខន្ធ បុគ្គលនោះ ឈ្មោះថា មិនកំណត់ដឹងហើយនូវវេទនាខន្ធដែរឬ ។ ព្រះអរហន្ត មិនកំណត់ដឹងនូវរូបក្ខន្ធ តែមិនមែនជាមិនកំណត់ដឹងហើយ នូវវេទនាខន្ធទេ បុគ្គលទាំងឡាយ ដ៏សេសសល់ លើកលែងតែអគ្គមគ្គសមង្គិបុគ្គល និងព្រះអរហន្តចេញ សុទ្ធតែមិនកំណត់ដឹងនូវរូបក្ខន្ធផង មិនកំណត់ដឹងហើយនូវវេទនាខន្ធផង ។ មួយយ៉ាងទៀត បុគ្គលណាមិនកំណត់ដឹងហើយ នូវវេទនាខន្ធ បុគ្គលនោះ ឈ្មោះថា មិនកំណត់ដឹង នូវរូបក្ខន្ធដែរឬ ។ អគ្គមគ្គសមង្គិបុគ្គល មិនកំណត់ដឹងហើយ នូវវេទនាខន្ធ តែមិនមែនជាមិនកំណត់ដឹងនូវរូបក្ខន្ធទេ បុគ្គលទាំងឡាយដ៏សេសសល់ វៀរលែងតែអគ្គមគ្គសមង្គិបុគ្គល និងព្រះអរហន្តចេញ សុទ្ធតែមិនកំណត់ដឹងហើយ នូវវេទនាខន្ធផង មិនកំណត់ដឹងនូវរូបក្ខន្ធផង ។

[ ២៧៧ ] បុគ្គលណា កំណត់ដឹងនូវរូបក្ខន្ធ បុគ្គលនោះ ឈ្មោះថា នឹងកំណត់ដឹងនូវវេទនាខន្ធដែរឬ ។ ទេ ។ មួយយ៉ាងទៀត បុគ្គលណា នឹងកំណត់ដឹងនូវវេទនាខន្ធ បុគ្គលនោះ ឈ្មោះថា កំណត់ដឹង នូវរូបក្ខន្ធដែរឬ ។ ទេ ។ បុគ្គលណា មិនកំណត់ដឹងនូវរូបក្ខន្ធ បុគ្គលនោះ ឈ្មោះថា នឹងមិនកំណត់ដឹង

នូវវេទនាខន្ធដែរឬ ។ បុគ្គលទាំងឡាយណា នឹងបាននូវមគ្គ បុគ្គលទាំងឡាយនោះ មិនកំណត់ដឹងនូវរូបក្ខន្ធ តែមិនមែនជានឹងមិនកំណត់ដឹង នូវវេទនាខន្ធទេ បុគ្គលណា ជាព្រះអរហន្តក្តី ជាបុថុជ្ជនក្តី នឹងមិនបាននូវមគ្គ បុគ្គលទាំងឡាយនោះ មិនកំណត់ដឹងនូវរូបក្ខន្ធផង នឹងមិនកំណត់ដឹងនូវវេទនាខន្ធផង ។ មួយយ៉ាងទៀត បុគ្គលណា នឹងមិនកំណត់ដឹងនូវវេទនាខន្ធ បុគ្គលនោះ ឈ្មោះថា មិនកំណត់ដឹងនូវរូបក្ខន្ធដែរឬ ។ អគ្គមគ្គសមង្គិបុគ្គល នឹងមិនកំណត់ដឹងនូវវេទនាខន្ធ តែមិនមែនជាមិនកំណត់ដឹង នូវរូបក្ខន្ធទេ បុគ្គលទាំងឡាយណា ជាព្រះអរហន្តក្តី ជាបុថុជ្ជនក្តី នឹងមិនបាននូវមគ្គ បុគ្គលទាំងឡាយនោះ នឹងមិនកំណត់ដឹងនូវវេទនាខន្ធផង មិនកំណត់ដឹងនូវរូបក្ខន្ធផង ។

[ ២៧៨ ] បុគ្គលណា កំណត់ដឹងហើយនូវរូបក្ខន្ធ បុគ្គលនោះ ឈ្មោះថា នឹងកំណត់ដឹងនូវវេទនាខន្ធដែរឬ ។ ទេ ។ មួយយ៉ាងទៀត បុគ្គលណា នឹងកំណត់ដឹងនូវវេទនាខន្ធ បុគ្គលនោះ ឈ្មោះថា កំណត់ដឹងហើយ នូវរូបក្ខន្ធដែរឬ ។ ទេ ។ បុគ្គលណា មិនកំណត់ដឹងហើយ នូវរូបក្ខន្ធ បុគ្គលនោះ ឈ្មោះថា នឹងមិនកំណត់ដឹងនូវវេទនាខន្ធដែរឬ ។ បុគ្គលទាំងឡាយណា នឹងបាននូវមគ្គ បុគ្គលទាំងឡាយនោះ នឹងមិនកំណត់ដឹងហើយ នូវរូបក្ខន្ធ តែមិន

*មែនជានឹងមិនកំណត់ដឹង នូវវេទនាខន្ធទេ បុគ្គលទាំងឡាយណា ជាអគ្គមគ្គ-សមង្គិបុគ្គលក្តី ជាបុថុជ្ជនក្តី នឹងមិនបាននូវមគ្គ បុគ្គលទាំងឡាយនោះ មិនកំណត់ដឹងហើយ នូវរូបក្ខន្ធផង នឹងមិនកំណត់ដឹងនូវវេទនាខន្ធផង ។ មួយយ៉ាងទៀត បុគ្គលណា នឹងមិនកំណត់ដឹង នូវវេទនាខន្ធ បុគ្គលនោះ ឈ្មោះថា មិនកំណត់ដឹងហើយ នូវរូបក្ខន្ធដែរឬ ។ ព្រះអរហន្ត នឹងមិនកំណត់ដឹងនូវវេទនាខន្ធ តែមិនមែនជាមិនកំណត់ដឹងហើយ នូវរូបក្ខន្ធទេ បុគ្គលទាំងឡាយណា ជាអគ្គមគ្គសមង្គិបុគ្គលក្តី ជាបុថុជ្ជនក្តី នឹងមិនបាននូវមគ្គ បុគ្គលទាំងឡាយនោះ នឹងមិនកំណត់ដឹងនូវវេទនាខន្ធផង មិនកំណត់ដឹងហើយ នូវរូបក្ខន្ធផង ។*

*បរិញ្ញាវារៈ ចប់*

*ខន្ធយមកៈ ចប់*

# អដ្ឋកថា

## បរិញ្ញាវារៈ

[ ២៧៣-២៧៨ ] ក្នុងបរិញ្ញាវារៈ ដែលមានក្នុងលំដាប់បន្ទាប់អំពីបវត្តិមហាវារៈនោះ មានប្រភេទនៃកាល ៦ យ៉ាងប៉ុណ្ណោះ មានន័យ ២ យ៉ាង ដោយអនុលោម និងបដិលោម តែក្នុងវារៈទាំង ៣ គឺបុគ្គលវារៈ ឱកាសវារៈ បុគ្គលោកាសវារៈ រមែងបានបុគ្គលវារៈប៉ុណ្ណោះ មិនបានវារៈក្រៅអំពីនេះឡើយ ។

សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះមានពាក្យវិសជ្ជនាតែមួយដូចគ្នា ។ បើបុគ្គលណានីមួយកំណត់ដឹងរូបក្ខន្ធក្នុងទីណាមួយសោត ក៏រមែងកំណត់ដឹងវេទនាខន្ធនោះឯង បើកំណត់ដឹងវេទនាខន្ធសោត ក៏រមែងកំណត់ដឹងរូបក្ខន្ធនោះឯង បើបុគ្គលណាមិនកំណត់ដឹងរូបក្ខន្ធសោត ក៏មិនកំណត់ដឹងវេទនាខន្ធនោះឯង បើមិនកំណត់ដឹងវេទនាខន្ធ ក៏មិនកំណត់ដឹងនូវរូបក្ខន្ធនោះឯង ព្រោះហេតុនោះ វារៈទាំងនោះ គប្បីជ្រាបថា រមែងមិនបានវារៈទាំង ២ នោះ ក្នុងបរិញ្ញាវារៈនេះ ព្រោះមានពាក្យវិសជ្ជនាដូចគ្នាថា បុគ្គលគប្បីធ្វើការសាកសួរ ដោយអំណាចពាក្យសួរជាដើមថា បុគ្គលរមែងកំណត់ដឹងរូបក្ខន្ធ ក្នុងទីណា ក៏រមែងកំណត់ដឹងវេទនាខន្ធក្នុងទីនោះ ដូច្នេះហើយ គប្បីធ្វើការវិសជ្ជនាថា អើ នោះឯង ។

មួយវិញទៀត បុគ្គលវារៈ ព្រះមានព្រះភាគទ្រង់សម្ដែងហើយ ក្នុងបរិញ្ញាវារៈនេះថា ឈ្មោះថា បរិញ្ញាកិច្ច រមែងមានដល់បុគ្គលប៉ុណ្ណោះ មិនមានដល់ឱកាស បុគ្គលប៉ុណ្ណោះអាចដឹងជុំវិញ មិនមែនឱកាស ព្រោះហេតុនោះ

ទើបទ្រង់មិនកាន់យកឱកាសវារៈ ព្រោះព្រះមានព្រះភាគ ទ្រង់មិនកាន់យកឱកាសវារៈនោះ បុគ្គលោកាសវារៈ ដែលមានក្នុងលំដាប់នៃឱកាសវារៈនោះសូម្បីបាន ក៏ទ្រង់មិនកាន់យក បុគ្គលវារៈនេះទ្រង់កាន់យកហើយក្នុងបច្ចុប្បន្នកាលយមកៈ ១០ ដោយការមិនកាន់យកទៀតក្នុងអនុលោមន័យ ដោយន័យដែលពោលហើយខាងដើមថា យមកៈដែលមានរូបក្ខន្ធជាមូល ៤ វេទនាខន្ធជាមូល ៣ សញ្ញាខន្ធជាមូល ២ សង្ខារក្ខន្ធជាមូល ១ ក្នុងបដិលោមន័យ ១០ ទៀត ទើបរួមជាយមកៈ ២០ ក្នុងកាលដ៏សេសក៏យ៉ាងនោះ ព្រោះហេតុនោះ គប្បីជ្រាបការកំណត់ព្រះបាលី ក្នុងបរិញ្ញាវារៈនេះថា យមកៈ ១២០ បុច្ឆា ២៤០ អត្ថ ៤៨០ រមែងមានក្នុងកាលទាំង ៦ ព្រោះធ្វើកាលនីមួយៗឲ្យជា ២០ ។

ក្នុងការវិនិច្ឆ័យអត្ថ ក្នុងបរិញ្ញាវារៈនេះ អទ្ធា ៣ គឺអតីត អនាគតបច្ចុប្បន្ន រមែងមិនបានដោយអំណាចចុតិ និងបដិសន្ធិដូចក្នុងបវត្តិវារៈ តែរមែងបានដោយអំណាចខណៈនៃចិត្តក្នុងបវត្តិប៉ុណ្ណោះ ព្រោះហេតុនោះ ទើបក្នុងបរិញ្ញាវារៈនេះ លោកធ្វើនូវការវិសជ្ជនាថា **អាមន្តា** ក្នុងពាក្យសួរទាំងឡាយជាដើមថា បុគ្គលណាកំណត់ដឹងនូវរូបក្ខន្ធ បុគ្គលនោះ ឈ្មោះថាកំណត់ដឹងនូវវេទនាខន្ធដែរឬ បុគ្គលដឹងនូវខន្ធណានីមួយក្នុងខន្ធ ៥ ព្រោះញ៉ាំងបរិញ្ញាកិច្ចឲ្យសម្រេច ដោយកិច្ចដែលមាននិព្វានជាអារម្មណ៍ ក្នុងលោកុត្តរមគ្គ រមែងពោលបានថា រមែងកំណត់ដឹងខន្ធក្រៅអំពីនេះ ។

បទថា **បរិជានាតិ** ក្នុងបរិញ្ញាវារៈនេះ គប្បីជ្រាបថា ព្រះមានព្រះភាគ

*ត្រាស់ថា* **អាមន្តា** *ព្រោះទ្រង់សំដៅយកការព្រមព្រៀងនៃមគ្គដ៏ប្រសើរ ដែលដល់នូវទីបំផុតនៃបរិញ្ញាកិច្ច ក្នុងបញ្ហាទាំងឡាយ ក្នុងអនុលោមន័យ យ៉ាងនេះ តែក្នុងបដិលោមន័យ បទថា* **ន បរិជានាតិ** *ក្នុងសំណួរទាំងឡាយ ព្រះមានព្រះភាគត្រាស់ថា* **អាមន្តា** *ព្រោះទ្រង់សំដៅយកបុគ្គលទាំងឡាយ មានបុថុជ្ជនជាដើម ។ ចំណែកក្នុងវារៈនៃអតីតកាលនេះថា* **បរិជានិត្ថ** *បាន ដល់ បុគ្គលសូម្បីតាំងនៅក្នុងផលដ៏ប្រសើរក្នុងលំដាប់នៃមគ្គ ឈ្មោះថា ធ្លាប់ កំណត់ដឹងហើយនោះឯង ព្រោះសម្រេចបរិញ្ញាកិច្ចហើយ ។ ព្រះមានព្រះភាគ រមែងត្រាស់សួរនូវការដល់ព្រមនៃមគ្គដ៏ប្រសើរ ដោយសំណួរថា* **យោ រូបក្ខន្ធំ បរិជានាតិ សោ វេទនាក្ខន្ធំ បរិជានិត្ថ** *ព្រោះបុគ្គលនេះ ឈ្មោះថា កំណត់ដឹងនូវខន្ធ ៥ ប៉ុណ្ណោះ ព្រោះបរិញ្ញាកិច្ច ដែលខន្ធមិនសម្រេចហើយ មុន ព្រោះហេតុនោះ ទើបព្រះមានព្រះភាគធ្វើការបដិសេធថា* **នោ** ។

*ក្នុងបញ្ហាទី ២ ព្រះមានព្រះភាគត្រាស់សួរនូវព្រះអរហន្តថា* **បរិជានិត្ថ** *ព្រោះបរិញ្ញាកិច្ចលោកធ្វើសម្រេចហើយ ព្រោះហេតុនោះ ឈ្មោះថា កិច្ចដែល គួរកំណត់ដឹង ទើបមិនមានដល់ព្រះអរហន្តនោះ ដូច្នោះ ទើបព្រះមានព្រះភាគ ធ្វើការបដិសេធថា* **នោ** ។ *ក្នុងការវិសជ្ជនារបស់បដិលោម ន័យក្នុងទុតិយ-បញ្ហានេះថា* **អរហា រូបក្ខន្ធំ ន បរិជានាតិ** *ព្រះមានព្រះភាគត្រាស់ហើយ ព្រោះការមិនមានការកំណត់ដឹងរបស់ព្រះអរហន្ត ។ បទថា* **អគ្គមគ្គសមង្គី វេទនាក្ខន្ធំ ន បរិជានិត្ថ** *ព្រះមានព្រះភាគត្រាស់ហើយ ព្រោះបុគ្គលតាំងនៅ ក្នុងអរហត្តមគ្គ មិនទាន់សម្រេចបរិញ្ញាកិច្ច អរហត្តមគ្គបុគ្គលនោះ មិនធ្លាប់*

*កំណត់ដឹងធម៌មួយ គឺវេទនាខន្ធតែម្យ៉ាងប៉ុណ្ណោះក៏មិនមែន ។ ព្រះមានព្រះភាគត្រាស់ពាក្យនេះ ដោយអំណាចពាក្យសួរ ។ សូម្បីពាក្យនេះថា* **នោ ច រូបក្ខន្ធំ** *ទ្រង់ក៏ត្រាស់ហើយ ដោយអំណាចពាក្យសួរនោះឯង អរហត្តមគ្គបុគ្គលនោះ មិនមែនកំណត់ដឹងនូវខន្ធដទៃ ។*

*ពាក្យសួរថា* **យោ រូបក្ខន្ធំ បរិជានាតិ សោ វេទនាក្ខន្ធំ បរិជានិស្សតិ** *អធិប្បាយថា ព្រោះបុគ្គលដែលតាំងនៅក្នុងមគ្គ ជាអ្នកមានខណចិត្តមួយ គឺមគ្គចិត្តកើតមួយខណៈ ព្រោះហេតុនោះ បុគ្គលនោះ រមែងមិនដល់នូវការរាប់ថា នឹងកំណត់ដឹង ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ថា* **នោ ។** *បទថា* **តេ រូបក្ខន្ធញ្ច បរិជានិត្ថ** *ព្រះមានព្រះភាគត្រាស់ហើយ ដោយពាក្យសួរដែលស្មើគ្នា អធិប្បាយក្នុងបញ្ហានេះថា បុគ្គលទាំងឡាយ មិនកំណត់ដឹងហើយ ។ បណ្ឌិតគប្បីជ្រាបការវិនិច្ឆ័យអត្ថ ក្នុងទីទាំងពួងដោយឧបាយនេះ ។៚*

**អដ្ឋកថាបរិញ្ញាវារៈ ចប់**

**ខន្ធយមកៈ ចប់**

# អភិធម្មបិដក

# អាយតនយមកៈ

## បណ្ណត្តិវារៈ

[ ២៧៩ ] អាយតនៈ ១២ គឺចក្ខាយតនៈ ១ សោតាយតនៈ ១ ឃានាយតនៈ ១ ជិវ្ហាយតនៈ ១ កាយាយតនៈ ១ រូបាយតនៈ ១ សទ្ទាយតនៈ ១ គន្ធាយតនៈ ១ រសាយតនៈ ១ ផោដ្ឋព្វាយតនៈ ១ មនាយតនៈ ១ ធម្មាយតនៈ ១ ។

## ឧទ្ទេសវារៈ

[ ២៨០ ] ចក្ខុ ហៅថា ចក្ខាយតនៈ ចក្ខាយតនៈ ហៅថា ចក្ខុ ។ សោតៈ ហៅថា សោតាយតនៈ សោតាយតនៈ ហៅថា សោតៈ ។ ឃានៈ ហៅថា ឃានាយតនៈ ឃានាយតនៈ ហៅថា ឃានៈ ។ ជិវ្ហា ហៅថា ជិវ្ហាយតនៈ ជិវ្ហាយតនៈ ហៅថា ជិវ្ហា ។ កាយ ហៅថា កាយាយតនៈ កាយាយតនៈ ហៅថា កាយ ។ រូប ហៅថា រូបាយតនៈ រូបាយតនៈ ហៅថា រូប ។ សទ្ទៈ ហៅថា សទ្ទាយតនៈ សទ្ទាយតនៈ ហៅថា សទ្ទៈ ។ គន្ធៈ ហៅថា គន្ធាយតនៈ គន្ធាយតនៈ ហៅថា គន្ធៈ ។ រសៈ ហៅថា រសាយតនៈ រសាយតនៈ ហៅថា រសៈ ។ ផោដ្ឋព្វៈ ហៅថា ផោដ្ឋព្វាយតនៈ ផោដ្ឋព្វាយតនៈ ហៅថា ផោដ្ឋព្វៈ ។ មនៈ ហៅថា មនាយតនៈ មនាយតនៈ ហៅថា មនៈ ។ ធម្មៈ ហៅថា ធម្មាយតនៈ ធម្មាយតនៈ ហៅថា ធម្មៈ ។

[ ២៨១ ] មិនមែនចក្ខុ មិនហៅថា ចក្ខាយតនៈ មិនមែនចក្ខាយតនៈ មិនហៅថា ចក្ខុ ។ មិនមែនសោតៈ មិនហៅថា សោតាយតនៈ មិនមែនសោតាយតនៈ មិនហៅថា សោតៈ ។ មិនមែនឃានៈ មិនហៅថា ឃានាយតនៈ មិនមែនឃានាយតនៈ មិនហៅថា ឃានៈ ។ មិនមែនជិវ្ហា មិនហៅថា ជិវ្ហាយតនៈ មិនមែនជិវ្ហាយតនៈ មិនហៅថា ជិវ្ហា ។ មិនមែនកាយ មិនហៅថា កាយាយតនៈ មិនមែនកាយាយតនៈ មិនហៅថា កាយ ។ មិនមែនរូប មិនហៅថា រូបាយតនៈ មិនមែនរូបាយតនៈ មិនហៅថា រូប ។ មិនមែនសទ្ទៈ មិនហៅថា សទ្ទាយតនៈ មិនមែនសទ្ទាយតនៈ មិនហៅថា សទ្ទៈ ។ មិនមែនគន្ធៈ មិនហៅថា គន្ធាយតនៈ មិនមែនគន្ធាយតនៈ មិនហៅថា គន្ធៈ ។ មិនមែនរសៈ មិនហៅថា រសាយតនៈ មិនមែនរសាយតនៈ មិនហៅថា រសៈ ។ មិនមែនផោដ្ឋព្វៈ មិនហៅថា ផោដ្ឋព្វាយតនៈ មិនមែនផោដ្ឋព្វាយតនៈ មិនហៅថា ផោដ្ឋព្វៈ ។ មិនមែនមនៈ មិនហៅថា មនាយតនៈ មិនមែនមនាយតនៈ មិនហៅថា មនៈ ។ មិនមែនធម្មៈ មិនហៅថា ធម្មាយតនៈ មិនមែនធម្មាយតនៈ មិនហៅថា ធម្មៈ ។

[ ២៨២ ] ចក្ខុ ហៅថា ចក្ខាយតនៈ អាយតនៈទាំងឡាយ ហៅថា សោតាយតនៈ ។ ចក្ខុ ហៅថា ចក្ខាយតនៈ អាយតនៈទាំងឡាយ ហៅថា ឃានាយតនៈ ។ ចក្ខុ ហៅថា ចក្ខាយតនៈ អាយតនៈទាំងឡាយ ហៅថា ជិវ្ហាយតនៈ ។បេ។ អាយតនៈទាំងឡាយ ហៅថា ធម្មាយតនៈ ។ សោតៈ ហៅថា សោតាយតនៈ អាយតនៈទាំងឡាយ ហៅថា ចក្ខាយតនៈ ។ សោតៈ

ហៅថា សោតាយតនៈ អាយតនៈទាំងឡាយ ហៅថា ឃានាយតនៈ ។បេ។ អាយតនៈទាំងឡាយ ហៅថា ធម្មាយតនៈ ។ ឃានៈ ហៅថា ឃានាយតនៈ ។បេ។ អាយតនៈទាំងឡាយ ហៅថា ធម្មាយតនៈ ។បេ។ ធម្មៈ ហៅថា ធម្មាយតនៈ អាយតនៈទាំងឡាយ ហៅថា ចក្ខាយតនៈ ។ ធម្មៈ ហៅថា ធម្មាយតនៈ អាយតនៈទាំងឡាយ ហៅថា សោតាយតនៈ ។បេ។ អាយតនៈទាំងឡាយ ហៅថា មនាយតនៈ ។ ( ចក្កៈ បណ្ឌិតគប្បីចងទុក ) ។

[ ២៨៣ ] មិនមែន ចក្ខុ មិនហៅថា ចក្ខាយតនៈ មិនមែនអាយតនៈទាំងឡាយ មិនហៅថា សោតាយតនៈ ។ មិនមែន ចក្ខុ មិនហៅថា ចក្ខាយតនៈ មិនមែនអាយតនៈទាំងឡាយ មិនហៅថា ឃានាយតនៈ ។ មិនមែន ចក្ខុ មិនហៅថា ចក្ខាយតនៈ មិនមែនអាយតនៈទាំងឡាយ មិនហៅថា ជិវ្ហាយតនៈ ។បេ។ មិនមែនអាយតនៈទាំងឡាយ មិនហៅថា ធម្មាយតនៈ ។ មិនមែនសោតៈ មិនហៅថា សោតាយតនៈ មិនមែនអាយតនៈទាំងឡាយ មិនហៅថា ចក្ខាយតនៈ ។ មិនមែនសោតៈ មិនហៅថា សោតាយតនៈ មិនមែនអាយតនៈទាំងឡាយ មិនហៅថា ឃានាយតនៈ ។បេ។ មិនមែនអាយតនៈទាំងឡាយ មិនហៅថា ធម្មាយតនៈ ។ មិនមែនឃានៈ មិនហៅថា ឃានាយតនៈ ។បេ។ មិនមែនអាយតនៈទាំងឡាយ មិនហៅថា ធម្មាយតនៈ ។បេ។ មិនមែនធម្មៈ មិនហៅថា ធម្មាយតនៈ មិនមែនអាយតនៈទាំងឡាយ មិនហៅថា ចក្ខាយតនៈ ។ មិនមែនធម្មៈ មិនហៅថា ធម្មាយតនៈ មិនមែនអាយតនៈទាំងឡាយ មិនហៅថា សោតាយតនៈ ។បេ។ មិនមែនអាយតនៈទាំងឡាយ

មិនហៅថា មនាយតនៈ ។ ( ចក្កៈ បណ្ឌិតគប្បីចងទុក ) ។

[ ២៨៤ ] ចក្ខុ ហៅថា អាយតនៈ អាយតនៈទាំងឡាយ ហៅថា ចក្ខុ ។ សោតៈ ហៅថា អាយតនៈ អាយតនៈទាំងឡាយ ហៅថា សោតៈ ។ ឃានៈ ហៅថា អាយតនៈ អាយតនៈទាំងឡាយ ហៅថា ឃានៈ ។ ជិវ្ហា ហៅថា អាយតនៈ អាយតនៈទាំងឡាយ ហៅថា ជិវ្ហា ។ កាយ ហៅថា អាយតនៈ អាយតនៈទាំងឡាយ ហៅថា កាយ ។ រូប ហៅថា អាយតនៈ អាយតនៈទាំងឡាយ ហៅថា រូប ។ សទ្ទៈ ហៅថា អាយតនៈ អាយតនៈទាំងឡាយ ហៅថា សទ្ទៈ ។ គន្ធៈ ហៅថា អាយតនៈ អាយតនៈទាំងឡាយ ហៅថា គន្ធៈ ។ រសៈ ហៅថា អាយតនៈ អាយតនៈទាំងឡាយ ហៅថា រសៈ ។ ផោដ្ឋព្វៈ ហៅថា អាយតនៈ អាយតនៈទាំងឡាយ ហៅថា ផោដ្ឋព្វៈ ។ មនៈ ហៅថា អាយតនៈ អាយតនៈទាំងឡាយ ហៅថា មនៈ ។ ធម្មៈ ហៅថា អាយតនៈ អាយតនៈទាំងឡាយ ហៅថា ធម្មៈ ។

[ ២៨៥ ] មិនមែនចក្ខុ មិនហៅថា អាយតនៈ មិនមែនអាយតនៈទាំងឡាយ មិនហៅថា ចក្ខុ ។ មិនមែនសោតៈ មិនហៅថា អាយតនៈ មិនមែនអាយតនៈទាំងឡាយ មិនហៅថា សោតៈ ។ មិនមែនឃានៈ មិនហៅថា អាយតនៈ មិនមែនអាយតនៈទាំងឡាយ មិនហៅថា ឃានៈ ។ មិនមែនជិវ្ហា មិនហៅថា អាយតនៈ មិនមែនអាយតនៈទាំងឡាយ មិនហៅថា ជិវ្ហា ។ មិនមែនកាយ មិនហៅថា អាយតនៈ មិនមែនអាយតនៈទាំងឡាយ មិនហៅថា កាយ ។ មិនមែនរូប មិនហៅថា អាយតនៈ មិនមែនអាយតនៈទាំង

ឡាយ មិនហៅថា រូប ។ មិនមែនសទ្ទ: មិនហៅថា អាយតនៈ មិនមែន អាយតនៈទាំងឡាយ មិនហៅថា សទ្ទ: ។ មិនមែនគន្ធ: មិនហៅថា អាយតនៈ មិនមែនអាយតនៈទាំងឡាយ មិនហៅថា គន្ធ: ។ មិនមែនរស: មិនហៅថា អាយតនៈ មិនមែនអាយតនៈទាំងឡាយ មិនហៅថា រស: ។ មិនមែនផោដ្ឋព្វ: មិនហៅថា អាយតនៈ មិនមែនអាយតនៈទាំងឡាយ មិនហៅថា ផោដ្ឋព្វ: ។ មិនមែនមនៈ មិនហៅថា អាយតនៈ មិនមែនអាយតនៈទាំងឡាយ មិនហៅថា មនៈ ។ មិនមែនធម្មៈ មិនហៅថា អាយតនៈ មិនមែនអាយតនៈទាំងឡាយ មិនហៅថា មនៈ ។

[ ២៨៦ ] ចក្ខុ ហៅថា អាយតនៈ អាយតនៈទាំងឡាយ ហៅថា សោតៈ ។បេ។ ចក្ខុ ហៅថា អាយតនៈ អាយតនៈទាំងឡាយ ហៅថា ធម្មៈ ។ សោតៈ ហៅថា អាយតនៈ អាយតនៈទាំងឡាយ ហៅថា ចក្ខុ ។បេ។ សោតៈ ហៅថា អាយតនៈ អាយតនៈទាំងឡាយ ហៅថា ធម្មៈ ។ ឃានៈ ហៅថា អាយតនៈ អាយតនៈទាំងឡាយ ហៅថា ចក្ខុ ។បេ។ អាយតនៈទាំងឡាយ ហៅថា ធម្មៈ ។ ធម្មៈ ហៅថា អាយតនៈ អាយតនៈទាំងឡាយ ហៅថា ចក្ខុ ។ ធម្មៈ ហៅថា អាយតនៈ អាយតនៈទាំងឡាយ ហៅថា សោតៈ ។បេ។ អាយតនៈទាំងឡាយ ហៅថា មនៈ ។ ( ចក្កៈ បណ្ឌិតគប្បីចងទុក ) ។

[ ២៨៧ ] មិនមែនចក្ខុ មិនហៅថា អាយតនៈ មិនមែនអាយតនៈទាំងឡាយ មិនហៅថា សោតៈ ។បេ។ មិនមែនចក្ខុ មិនហៅថា អាយតនៈ មិនមែនអាយតនៈទាំងឡាយ មិនហៅថា ធម្មៈ ។ មិនមែនសោតៈ មិនហៅថា

អាយតនៈ មិនមែនអាយតនៈទាំងឡាយ មិនហៅថា ចក្ខុ ។បេ។ មិនមែនអាយតនៈទាំងឡាយ មិនហៅថា ធម្មៈ ។ មិនមែនឃានៈ មិនហៅថាអាយតនៈ មិនមែនអាយតនៈទាំងឡាយ មិនហៅថា ចក្ខុ ។បេ។ មិនមែនអាយតនៈទាំងឡាយ មិនហៅថា ធម្មៈ ។ មិនមែនធម្មៈ មិនហៅថាអាយតនៈ មិនមែនអាយតនៈទាំងឡាយ មិនហៅថា ចក្ខុ ។ មិនមែនធម្មៈ មិនហៅថា អាយតនៈ មិនមែនអាយតនៈទាំងឡាយ មិនហៅថា សោតៈ ។បេ។ មិនមែនអាយតនៈទាំងឡាយ មិនហៅថា មនៈ ។ ( ចក្កៈ បណ្ឌិតគប្បីចងទុក ) ។

ឧទ្ទេសវារៈ ចប់

## និទ្ទេសវារៈ

[ ២៨៨ ] ចក្ខុ ហៅថា ចក្ខាយតនៈឬ ។ ទិព្វចក្ខុ បញ្ញាចក្ខុ ហៅថាចក្ខុ មិនហៅថា ចក្ខាយតនៈទេ ចក្ខាយតនៈ ហៅថា ចក្ខុផង ហៅថា ចក្ខាយតនៈផង ។ ចក្ខាយតនៈ ហៅថា ចក្ខុដែរឬ ។ អើ ។ សោតៈ ហៅថាសោតាយតនៈដែរឬ ។ ទិព្វសោតៈ តណ្ហាសោតៈ ហៅថា សោតៈ មិនហៅថា សោតាយតនៈទេ សោតាយតនៈ ហៅថា សោតៈផង ហៅថា សោតាយតនៈផង ។ សោតាយតនៈ ហៅថា សោតៈដែរឬ ។ អើ ។ ឃានៈ ហៅថា ឃានាយតនៈដែរឬ ។ អើ ។ ឃានាយតនៈ ហៅថា ឃានៈដែរឬ ។ អើ ។ជិវ្ហា ហៅថា ជិវ្ហាយតនៈដែរឬ ។ អើ ។ ជិវ្ហាយតនៈ ហៅថា ជិវ្ហាដែរឬ ។ អើ ។ កាយ ហៅថា កាយាយតនៈដែរឬ ។ កាយដ៏សេស វៀរលែងតែ

កាយាយតនៈចេញ ហៅថា កាយ មិនហៅថា កាយាយតនៈទេ កាយាយតនៈ ហៅថា កាយផង ហៅថា កាយាយតនៈផង ។ កាយាយតនៈ ហៅថា កាយ ដែរឬ ។ អើ ។ រូប ហៅថា រូបាយតនៈដែរឬ ។ រូបដ៏សេស វៀរលែងតែ រូបាយតនៈចេញ ហៅថា រូប មិនហៅថា រូបាយតនៈទេ រូបាយតនៈ ហៅថា រូបផង ហៅថា រូបាយតនៈផង ។ រូបាយតនៈ ហៅថា រូបដែរឬ ។ អើ ។ សទ្ទៈ ហៅថា សទ្ទាយតនៈដែរឬ ។ អើ ។ សទ្ទាយតនៈ ហៅថា សទ្ទៈដែរ ឬ ។ អើ ។ គន្ធៈ ហៅថា គន្ធាយតនៈដែរឬ ។ សីលគន្ធៈ សមាធិគន្ធៈ បញ្ញាគន្ធៈ ហៅថា គន្ធៈ មិនហៅថា គន្ធាយតនៈទេ គន្ធាយតនៈ ហៅថា គន្ធៈផង ហៅ ថា គន្ធាយតនៈផង ។ គន្ធាយតនៈ ហៅថា គន្ធៈដែរឬ ។ អើ ។ រសៈ ហៅ ថា រសាយតនៈដែរឬ ។ អត្ថរស ធម្មរស វិមុត្តិរស ហៅថា រសៈ មិនហៅ ថា រសាយតនៈទេ រសាយតនៈ ហៅថា រសៈផង ហៅថា រសាយតនៈ ផង ។ រសាយតនៈ ហៅថា រសៈដែរឬ ។ អើ ។ ផោដ្ឋព្វៈ ហៅថា ផោដ្ឋព្វាយតនៈដែរឬ ។ អើ ។ ផោដ្ឋព្វាយតនៈ ហៅថា ផោដ្ឋព្វៈដែរឬ ។ អើ ។ មនៈ ហៅថា មនាយតនៈដែរឬ ។ អើ ។ មនាយតនៈ ហៅថា មនៈ ដែរឬ ។ អើ ។ ធម្មៈ ហៅថា ធម្មាយតនៈដែរឬ ។ ធម្មៈដ៏សេស វៀរលែង តែធម្មាយតនៈចេញ ហៅថា ធម្មៈ មិនហៅថា ធម្មាយតនៈទេ ធម្មាយតនៈ ហៅថា ធម្មៈផង ហៅថា ធម្មាយតនៈផង ។ ធម្មាយតនៈ ហៅថា ធម្មៈ ដែរឬ ។ អើ ។

[ ២៨៩ ] មិនមែនចក្ខុ មិនហៅថា ចក្ខាយតនៈទេឬ ។ អើ ។ មិនមែន

*ចក្ខាយតនៈ មិនហៅថា ចក្ខុទេឬ ។ ទិព្វចក្ខុ បញ្ញាចក្ខុ មិនហៅថា ចក្ខាយតនៈទេ ហៅថា ចក្ខុ អាយតនៈទាំងឡាយដ៏សេស វៀរលែងតែចក្ខុ និងចក្ខាយតនៈចេញ មិនហៅថា ចក្ខុផង មិនហៅថា ចក្ខាយតនៈផង ។ មិនមែនសោតៈ មិនហៅថា សោតាយតនៈទេឬ ។ អើ ។ មិនមែនសោតាយតនៈ មិនហៅថា សោតៈទេឬ ។ ទិព្វសោតៈ តណ្ហាសោតៈ មិនហៅថា សោតាយតនៈទេ ហៅថា សោតៈ អាយតនៈទាំងឡាយដ៏សេស វៀរលែងតែសោតៈ និងសោតាយតនៈចេញ មិនហៅថា សោតៈផង មិនហៅថា សោតាយតនៈផង ។ មិនមែនឃានៈ មិនហៅថា ឃានាយតនៈទេឬ ។ អើ ។ មិនមែនឃានាយតនៈ មិនហៅថា ឃានៈទេឬ ។ អើ ។ មិនមែនជិវ្ហា មិនហៅថា ជិវ្ហាយតនៈទេឬ ។ អើ ។ មិនមែនជិវ្ហាយតនៈ មិនហៅថា ជិវ្ហាទេឬ ។ អើ ។ មិនមែនកាយ មិនហៅថា កាយាយតនៈទេឬ ។ អើ ។ មិនមែនកាយាយតនៈ មិនហៅថា កាយទេឬ ។ កាយដ៏សេស វៀរលែងតែកាយាយតនៈចេញ មិនហៅថា កាយាយតនៈទេ ហៅថា កាយ សភាវៈដ៏សេស វៀរលែងតែកាយ និងកាយាយតនៈចេញ មិនហៅថា កាយផង មិនហៅថា កាយាយតនៈផង ។ មិនមែនរូប មិនហៅថា រូបាយតនៈទេឬ ។ អើ ។ មិនមែនរូបាយតនៈ មិនហៅថា រូបទេឬ ។ រូបដ៏សេស វៀរលែងតែរូបាយតនៈចេញ មិនហៅថា រូបាយតនៈទេ ហៅថា រូប ធម្មជាតដ៏សេស វៀរលែងតែរូប និងរូបាយតនៈចេញ មិនហៅថា រូបផង មិនហៅថា រូបាយតនៈផង ។ មិនមែនសទ្ទៈ មិនហៅថា សទ្ទាយតនៈទេឬ ។ អើ ។ មិនមែន*

សទ្ទាយតនៈ មិនហៅថា សទ្ទៈទេឬ ។ អើ ។ មិនមែនគន្ធៈ មិនហៅថា គន្ធាយតនៈទេឬ ។ អើ ។ មិនមែនគន្ធាយតនៈ មិនហៅថា គន្ធៈទេឬ ។ សីលគន្ធៈ សមាធិគន្ធៈ បញ្ញាគន្ធៈ មិនហៅថា គន្ធាយតនៈទេ ហៅថា គន្ធៈ សភាវៈទាំងឡាយដ៏សេស វៀរលែងតែគន្ធៈ និងគន្ធាយតនៈចេញ មិនហៅថា គន្ធៈផង មិនហៅថា គន្ធាយតនៈផង ។ មិនមែនរសៈ មិនហៅថា រសាយតនៈទេឬ ។ អើ ។ មិនមែនរសាយតនៈ មិនហៅថា រសៈទេឬ ។ អត្ថរស ធម្មរស វិមុត្តិរស មិនហៅថា រសាយតនៈទេ ហៅថា រសៈ សភាវៈទាំងឡាយដ៏សេស វៀរលែងតែរសៈ និងរសាយតនៈចេញ មិនហៅថា រសៈផង មិនហៅថា រសាយតនៈផង ។ មិនមែនផោដ្ឋព្វៈ មិនហៅថា ផោដ្ឋព្វាយតនៈទេឬ ។ អើ ។ មិនមែនផោដ្ឋព្វាយតនៈ មិនហៅថា ផោដ្ឋព្វៈទេឬ ។ អើ ។ មិនមែនមនៈ មិនហៅថា មនាយតនៈទេឬ ។ អើ ។ មិនមែនមនាយតនៈ មិនហៅថា មនៈទេឬ ។ អើ ។ មិនមែនធម្មៈ មិនហៅថា ធម្មាយតនៈទេឬ ។ អើ ។ មិនមែនធម្មាយតនៈ មិនហៅថា ធម្មៈទេឬ ។ ធម៌ដ៏សេស វៀរលែងតែធម្មាយតនៈចេញ មិនហៅថា ធម្មាយតនៈទេ ហៅថា ធម្មៈ សភាវៈដ៏សេស វៀរលែងតែធម្មៈ និងធម្មាយតនៈចេញ មិនហៅថា ធម្មៈផង មិនហៅថា ធម្មាយតនៈផង ។

[ ២៩០ ] ចក្ខុ ហៅថា ចក្ខាយតនៈដែរឬ ។ ទិព្វចក្ខុ បញ្ញាចក្ខុ ហៅថា ចក្ខុ មិនហៅថា ចក្ខាយតនៈទេ ចក្ខាយតនៈ ហៅថា ចក្ខុផង ហៅថា ចក្ខាយតនៈផង ។ អាយតនៈទាំងឡាយ ហៅថា សោតាយតនៈដែរឬ ។

សោតាយតនៈ ហៅថា អាយតនៈផង ហៅថា សោតាយតនៈផង អាយតនៈទាំងឡាយដ៏សេស ហៅថា អាយតនៈទាំងឡាយ មិនហៅថា សោតាយតនៈទេ ។ ចក្ខុ ហៅថា ចក្ខាយតនៈដែរឬ ។ ទិព្វចក្ខុ បញ្ញាចក្ខុ ហៅថា ចក្ខុ មិនហៅថា ចក្ខាយតនៈទេ ចក្ខាយតនៈ ហៅថា ចក្ខុផង ហៅថា ចក្ខាយតនៈផង ។ អាយតនៈទាំងឡាយ ហៅថា ឃានាយតនៈដែរឬ ។បេ។ អាយតនៈទាំងឡាយ ហៅថា ធម្មាយតនៈដែរឬ ។ ធម្មាយតនៈ ហៅថា អាយតនៈផង ហៅថា ធម្មាយតនៈផង អាយតនៈទាំងឡាយដ៏សេស ហៅថា អាយតនៈទាំងឡាយ មិនហៅថា ធម្មាយតនៈទេ ។ សោតៈ ។បេ។ ឃានៈ ។បេ។ ធម្មៈ ហៅថា ធម្មាយតនៈដែរឬ ។ ធម្មៈដ៏សេស វៀរលែងតែធម្មាយតនៈចេញ ហៅថា ធម្មៈ មិនហៅថា ធម្មាយតនៈទេ ធម្មាយតនៈ ហៅថា ធម្មៈផង ហៅថា ធម្មាយតនៈផង ។ អាយតនៈទាំងឡាយ ហៅថា ចក្ខាយតនៈដែរឬ ។ ចក្ខាយតនៈ ហៅថា អាយតនៈផង ហៅថា ចក្ខាយតនៈផង អាយតនៈទាំងឡាយដ៏សេស ហៅថា អាយតនៈទាំងឡាយ មិនហៅថា ចក្ខាយតនៈទេ ។ ធម្មៈ ហៅថា ធម្មាយតនៈដែរឬ ។ ធម្មៈដ៏សេស វៀរលែងតែធម្មាយតនៈចេញ មិនហៅថា ធម្មាយតនៈទេ ធម្មាយតនៈ ហៅថា ធម្មៈផង ហៅថា ធម្មាយតនៈផង ។ អាយតនៈទាំងឡាយ ហៅថា សោតាយតនៈដែរឬ ។បេ។ អាយតនៈទាំងឡាយ ហៅថា មនាយតនៈដែរឬ ។ មនាយតនៈ ហៅថា អាយតនៈផង ហៅថា មនាយតនៈផង អាយតនៈទាំងឡាយដ៏សេស ហៅថា អាយតនៈទាំងឡាយ មិនហៅថា មនាយតនៈទេ ។ ( បណ្ឌិត គប្បីចង

នូវចក្ក: ដែលមានមូលនៃបទមួយៗ កុំឲ្យក្រឡូច ) ។

[ ២៩១ ] មិនមែនចក្ខុ មិនហៅថា ចក្ខាយតនៈទេឬ ។ អើ ។ មិនមែនអាយតនៈទាំងឡាយ មិនហៅថា សោតាយតនៈទេឬ ។ អើ ។ មិនមែនចក្ខុ មិនហៅថា ចក្ខាយតនៈទេឬ ។ អើ ។ មិនមែនអាយតនៈទាំងឡាយ មិនហៅថា ឃានាយតនៈទេឬ ។ អើ ។បេ។ មិនមែនអាយតនៈទាំងឡាយ មិនហៅថា ធម្មាយតនៈទេឬ ។ អើ ។ មិនមែនសោតៈ មិនហៅថា សោតាយតនៈទេឬ ។ អើ ។ មិនមែនអាយតនៈទាំងឡាយ មិនហៅថា ចក្ខាយតនៈទេឬ ។បេ។ មិនមែនអាយតនៈទាំងឡាយ មិនហៅថា ធម្មាយតនៈទេឬ ។ អើ ។ មិនមែនឃានៈ មិនហៅថា ឃានាយតនៈទេឬ ។បេ។ មិនមែនធម្មៈ មិនហៅថា ធម្មាយតនៈទេឬ ។ អើ ។ មិនមែនអាយតនៈទាំងឡាយ មិនហៅថា ចក្ខាយតនៈទេឬ ។ អើ ។ មិនមែនធម្មៈ មិនហៅថា ធម្មាយតនៈទេឬ ។ អើ ។ មិនមែនអាយតនៈទាំងឡាយ មិនហៅថា សោតាយតនៈទេឬ ។បេ។ មិនមែនអាយតនៈទាំងឡាយ មិនហៅថា មនាយតនៈទេឬ ។ អើ ។ ( បណ្ឌិត កាលចងនូវចក្កៈ គប្បីធ្វើនូវពាក្យថា អើ គ្រប់បទទាំងអស់ ) ។

[ ២៩២ ] ចក្ខុ ហៅថា អាយតនៈដែរឬ ។ អើ ។ អាយតនៈទាំងឡាយ ហៅថា ចក្ខាយតនៈដែរឬ ។ ចក្ខាយតនៈ ហៅថា អាយតនៈផង ហៅថា ចក្ខាយតនៈផង អាយតនៈទាំងឡាយដ៏សេស ហៅថា អាយតនៈទាំងឡាយ មិនហៅថា ចក្ខាយតនៈទេ ។ សោតៈ ហៅថា អាយតនៈដែរឬ ។ អើ ។បេ។ ឃានៈ ជិវ្ហា កាយៈ រូបៈ សទ្ទៈ គន្ធៈ រសៈ ផោដ្ឋព្វៈ មនៈ ។ ធម្មៈ ហៅថា

អាយតនៈដែរឬ ។ អើ ។ អាយតនៈទាំងឡាយ ហៅថា ធម្មាយតនៈដែរឬ ។ ធម្មាយតនៈ ហៅថា អាយតនៈផង ហៅថា ធម្មាយតនៈផង អាយតនៈទាំងឡាយដ៏សេស ហៅថា អាយតនៈទាំងឡាយ មិនហៅថា ធម្មាយតនៈទេ ។

[ ២៩៣ ] មិនមែនចក្ខុ មិនហៅថា អាយតនៈទេឬ ។ អាយតនៈទាំងឡាយដ៏សេស វៀរលែងតែចក្ខុចេញ មិនហៅថា ចក្ខុទេ ហៅថា អាយតនៈទាំងឡាយ អាយតនៈទាំងឡាយដ៏សេស វៀរលែងតែចក្ខុ និងអាយតនៈចេញ មិនហៅថា ចក្ខុផង មិនហៅថា អាយតនៈទាំងឡាយផង ។ មិនមែនអាយតនៈទាំងឡាយ មិនហៅថា ចក្ខាយតនៈទេឬ ។ អើ ។ មិនមែនសោតៈ មិនហៅថា អាយតនៈទេឬ ។ វៀរលែងតែសោតៈ ។បេ។ វៀរលែងតែឃានៈ វៀរលែងតែជិវ្ហាចេញ ។បេ។ មិនហៅថា អាយតនៈទាំងឡាយទេ ។ មិនមែនកាយ មិនហៅថា អាយតនៈទេឬ ។ អើ ។ មិនមែនអាយតនៈទាំងឡាយ មិនហៅថា កាយាយតនៈទេឬ ។ អើ ។ មិនមែនរូប មិនហៅថា អាយតនៈទេឬ ។ វៀរលែងតែរូប ។បេ។ វៀរលែងតែសទ្ទៈ វៀរលែងតែគន្ធៈ វៀរលែងតែរសៈ វៀរលែងតែផោដ្ឋព្វៈចេញ ។បេ។ មិនហៅថា អាយតនៈទាំងឡាយទេ ។ មិនមែនមនៈ មិនហៅថា អាយតនៈទេឬ ។ អាយតនៈទាំងឡាយដ៏សេស វៀរលែងតែមនៈចេញ មិនហៅថា មនៈទេ ហៅថា អាយតនៈទាំងឡាយ អាយតនៈទាំងឡាយដ៏សេស វៀរលែងតែមនៈ និងអាយតនៈចេញ មិនហៅថា មនៈផង មិនហៅថា អាយតនៈទាំងឡាយផង ។ មិនមែនអាយតនៈទាំងឡាយ មិនហៅថា មនាយតនៈទេឬ ។ អើ ។ មិនមែន

ធម្មៈ មិនហៅថា អាយតនៈទេឬ ។ អើ ។ មិនមែនអាយតនៈទាំងឡាយ មិនហៅថា ធម្មាយតនៈទេឬ ។ អើ ។

[ ២៩៤ ] ចក្ខុ ហៅថា អាយតនៈដែរឬ ។ អើ ។ អាយតនៈទាំងឡាយ ហៅថា សោតាយតនៈដែរឬ ។ សោតាយតនៈ ហៅថា អាយតនៈផង ហៅថា សោតាយតនៈផង អាយតនៈទាំងឡាយដ៏សេស ហៅថា អាយតនៈទាំងឡាយ មិនហៅថា សោតាយតនៈទេ ។ ចក្ខុ ហៅថា អាយតនៈដែរឬ ។ អើ ។ អាយតនៈទាំងឡាយ ហៅថា ឃានាយតនៈ ។បេ។ អាយតនៈទាំងឡាយ ហៅថា ធម្មាយតនៈដែរឬ ។ ធម្មាយតនៈ ហៅថា អាយតនៈផង ហៅថា ធម្មាយតនៈផង អាយតនៈទាំងឡាយដ៏សេស ហៅថា អាយតនៈទាំងឡាយ មិនហៅថា ធម្មាយតនៈទេ ។ សោតៈ ហៅថា អាយតនៈដែរឬ ។ អើ ។ អាយតនៈទាំងឡាយ ហៅថា ចក្ខាយតនៈដែរឬ ។បេ។ មិនហៅថា ចក្ខាយតនៈទេ ។បេ។ អាយតនៈទាំងឡាយ ហៅថា ធម្មាយតនៈដែរឬ ។បេ។ មិនហៅថា ធម្មាយតនៈទេ ។ ឃានៈ ជិវ្ហា ។បេ។ ធម្មៈ ហៅថា អាយតនៈដែរឬ ។ អើ ។ អាយតនៈទាំងឡាយ ហៅថា ចក្ខាយតនៈ ។បេ។ អាយតនៈទាំងឡាយ ហៅថា មនាយតនៈដែរឬ ។ មនាយតនៈ ហៅថា អាយតនៈផង ហៅថា មនាយតនៈផង អាយតនៈទាំងឡាយដ៏សេស ហៅថា អាយតនៈទាំងឡាយ មិនហៅថា មនាយតនៈទេ ។ ( ចក្កៈ បណ្ឌិតគប្បីចងក្រងទុក ) ។

[ ២៩៥ ] មិនមែនចក្ខុ មិនហៅថា អាយតនៈទេឬ ។ អាយតនៈទាំងឡាយដ៏សេស វៀរលែងតែចក្ខុចេញ មិនហៅថា ចក្ខុទេ ហៅថា អាយតនៈ

ទាំងឡាយ អាយតនៈទាំងឡាយដ៏សេស វៀរលែងតែចក្ខុ និងអាយតនៈចេញ មិនហៅថា ចក្ខុផង មិនហៅថា អាយតនៈទាំងឡាយផង ។ មិនមែនអាយតនៈទាំងឡាយ មិនហៅថា សោតាយតនៈទេឬ ។ អើ ។បេ។ មិនមែនចក្ខុ មិនហៅថា អាយតនៈទេឬ ។ អាយតនៈទាំងឡាយដ៏សេស វៀរលែងតែចក្ខុចេញ មិនហៅថា ចក្ខុទេ ហៅថា អាយតនៈទាំងឡាយ អាយតនៈទាំងឡាយដ៏សេស វៀរលែងតែចក្ខុ និងអាយតនៈចេញ មិនហៅថា ចក្ខុផង មិនហៅថា អាយតនៈទាំងឡាយផង ។ មិនមែនអាយតនៈទាំងឡាយ មិនហៅថា ឃានា-យតនៈ ។បេ។ មិនមែនអាយតនៈទាំងឡាយ មិនហៅថា ធម្មាយតនៈទេឬ ។ អើ ។ មិនមែនសោតៈ មិនហៅថា អាយតនៈទេឬ ។ វៀរលែងតែសោតៈ ។បេ។ វៀរលែងតែឃានៈ វៀរលែងតែជិវ្ហាចេញ ។បេ។ មិនហៅថា អាយតនៈទាំងឡាយផង ។ មិនមែនកាយៈ មិនហៅថា អាយតនៈទេឬ ។ អើ ។ មិនមែនអាយតនៈទាំងឡាយ មិនហៅថា ចក្ខ្វាយតនៈទេឬ ។ អើ ។បេ។ មិនមែនអាយតនៈទាំងឡាយ មិនហៅថា ធម្មាយតនៈទេឬ ។ អើ ។បេ។ មិនមែនធម្មៈ មិនហៅថា អាយតនៈទេឬ ។ អើ ។ មិនមែនអាយតនៈទាំងឡាយ មិនហៅថា ចក្ខ្វាយតនៈទេឬ ។ អើ ។ មិនមែនធម្មៈ មិនហៅថា អាយតនៈទេឬ ។ អើ ។ មិនមែនអាយតនៈទាំងឡាយ មិនហៅថា សោតាយតនៈទេឬ ។ អើ ។បេ។ មិនមែនអាយតនៈទាំងឡាយ មិនហៅថា មនាយតនៈទេឬ ។ អើ ។ ( ចក្កៈ បណ្ឌិតគប្បីចងក្រងទុក ) ។

បណ្ណត្តិវារៈ ចប់

# បវត្តិវារៈ

[ ២៩៦ ] ចក្ខាយតនៈរបស់សត្វណា កើតឡើង សោតាយតនៈរបស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វដែលប្រកបដោយចក្ខុ មិនមានសោតៈ កាលចាប់បដិសន្ធិ ចក្ខាយតនៈរបស់សត្វទាំងនោះ កើតឡើង តែសោតាយតនៈរបស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វដែលប្រកបដោយចក្ខុ ប្រកបដោយសោតៈ កាលចាប់បដិសន្ធិ ចក្ខាយតនៈរបស់សត្វទាំងនោះ កើតឡើងផង សោតាយតនៈ កើតឡើងផង ។ មួយយ៉ាងទៀត សោតាយតនៈរបស់សត្វណា កើតឡើង ចក្ខាយតនៈរបស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វដែលប្រកបដោយសោតៈ មិនមានចក្ខុ កាលចាប់បដិសន្ធិ សោតាយតនៈរបស់សត្វទាំងនោះ កើតឡើង តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វដែលប្រកបដោយសោតៈ ប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ សោតាយតនៈ របស់សត្វទាំងនោះ កើតឡើងផង ចក្ខាយតនៈ កើតឡើងផង ។

[ ២៩៧ ] ចក្ខាយតនៈរបស់សត្វណា កើតឡើង ឃានាយតនៈរបស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វដែលប្រកបដោយចក្ខុ មិនមានឃានៈ កាលចាប់បដិសន្ធិ ចក្ខាយតនៈរបស់សត្វទាំងនោះ កើតឡើង តែឃានាយតនៈរបស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វដែលប្រកបដោយចក្ខុ ប្រកបដោយឃានៈ កាលចាប់បដិសន្ធិ ចក្ខាយតនៈរបស់សត្វទាំងនោះ កើតឡើងផង ឃានាយតនៈ កើតឡើងផង ។ មួយយ៉ាងទៀត ឃានាយតនៈរបស់សត្វណាកើតឡើង ចក្ខាយតនៈរបស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វដែលប្រកបដោយឃានៈ មិនមានចក្ខុ កាលចាប់បដិសន្ធិ ឃានាយតនៈរបស់

សត្វទាំងនោះ កើតឡើង តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វដែលប្រកបដោយឃានៈ ប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ ឃានាយតនៈរបស់សត្វទាំងនោះ កើតឡើងផង ចក្ខាយតនៈកើតឡើងផង ។

[ ២៩៨ ] ចក្ខាយតនៈ របស់សត្វណា កើតឡើង រូបាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ អើ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា កើតឡើង ចក្ខាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វដែលប្រកបដោយរូប មិនមានចក្ខុ កាលចាប់បដិសន្ធិ រូបាយតនៈ របស់សត្វទាំងនោះ កើតឡើង តែចក្ខាយតនៈរបស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ រូបាយតនៈ របស់សត្វទាំងនោះ កើតឡើងផង ចក្ខាយតនៈ កើតឡើងផង ។

[ ២៩៩ ] ចក្ខាយតនៈ របស់សត្វណា កើតឡើង មនាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ អើ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា កើតឡើង ចក្ខាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វដែលប្រកបដោយចិត្ត មិនមានចក្ខុ កាលចាប់បដិសន្ធិ មនាយតនៈរបស់សត្វទាំងនោះ កើតឡើង តែចក្ខាយតនៈរបស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ មនាយតនៈ របស់សត្វទាំងនោះ កើតឡើងផង ចក្ខាយតនៈ កើតឡើងផង ។

[ ៣០០ ] ចក្ខាយតនៈ របស់សត្វណា កើតឡើង ធម្មាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វ

ណាកើតឡើង ចក្ខាយតនៈរបស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ កើតឡើងតែចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ កើតឡើងផង ចក្ខាយតនៈ កើតឡើងផង ។

[ ៣០១ ] ឃានាយតនៈ របស់សត្វណា កើតឡើង រូបាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ អើ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា កើតឡើង ឃានាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វដែលប្រកបដោយរូប មិនមានឃានៈ កាលចាប់បដិសន្ធិ រូបាយតនៈ របស់សត្វទាំងនោះ កើតឡើង តែឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វដែលប្រកបដោយឃានៈ កាលចាប់បដិសន្ធិ រូបាយតនៈ របស់សត្វទាំងនោះ កើតឡើងផង ឃានាយតនៈ កើតឡើងផង ។

[ ៣០២ ] ឃានាយតនៈ របស់សត្វណា កើតឡើង មនាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ អើ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា កើតឡើង ឃានាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វដែលប្រកបដោយចិត្ត មិនមានឃានៈ កាលចាប់បដិសន្ធិ មនាយតនៈ របស់សត្វទាំងនោះ កើតឡើង តែឃានាយតនៈរបស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វដែលប្រកបដោយឃានៈ កាលចាប់បដិសន្ធិ មនាយតនៈ របស់សត្វទាំងនោះ កើតឡើងផង ឃានាយតនៈ កើតឡើងផង ។

[ ៣០៣ ] ឃានាយតនៈ របស់សត្វណា កើតឡើង ធម្មាយតនៈរបស់សត្វនោះ កើតឡើងដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា កើតឡើង ឃានាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វដែលមិនមានឃានៈ កាលចាប់បដិសន្ធិ ធម្មាយតនៈរបស់សត្វទាំងនោះ កើតឡើង តែឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វដែលប្រកបដោយឃានៈ កាលចាប់បដិសន្ធិ ធម្មាយតនៈរបស់សត្វទាំងនោះ កើតឡើងផង ឃានាយតនៈ កើតឡើងផង ។

[ ៣០៤ ] រូបាយតនៈ របស់សត្វណា កើតឡើង មនាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វដែលមិនមានចិត្ត កាលចាប់បដិសន្ធិ រូបាយតនៈរបស់សត្វទាំងនោះ កើតឡើង តែមនាយតនៈរបស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វដែលប្រកបដោយរូប ប្រកបដោយចិត្ត កាលចាប់បដិសន្ធិ រូបាយតនៈ របស់សត្វទាំងនោះ កើតឡើងផង មនាយតនៈ កើតឡើងផង ។ មួយយ៉ាងទៀត មនាយតនៈរបស់សត្វណា កើតឡើង រូបាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វដែលមិនមានរូប កាលចាប់បដិសន្ធិ មនាយតនៈរបស់សត្វទាំងនោះ កើតឡើង តែរូបាយតនៈរបស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វដែលប្រកបដោយចិត្ត ប្រកបដោយរូប កាលចាប់បដិសន្ធិ មនាយតនៈ របស់សត្វទាំងនោះ កើតឡើងផង រូបាយតនៈ កើតឡើងផង ។

[ ៣០៥ ] រូបាយតនៈ របស់សត្វណា កើតឡើង ធម្មាយតនៈ របស់

សត្វនោះ កើតឡើងដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា កើតឡើង រូបាយតនៈរបស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វដែលមិនមានរូប កាលចាប់បដិសន្ធិ ធម្មាយតនៈរបស់សត្វទាំងនោះ កើតឡើង តែរូបាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វដែលប្រកបដោយរូប កាលចាប់បដិសន្ធិ ធម្មាយតនៈរបស់សត្វទាំងនោះ កើតឡើងផង រូបា-យតនៈ កើតឡើងផង ។

[ ៣០៦ ] មនាយតនៈ របស់សត្វណា កើតឡើង ធម្មាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា កើតឡើង មនាយតនៈរបស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វដែលមិនមានចិត្ត កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ កើតឡើង តែមនាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វដែលប្រកបដោយចិត្ត កាលចាប់បដិសន្ធិ ធម្មាយតនៈរបស់សត្វទាំងនោះ កើតឡើងផង មនាយតនៈ កើតឡើងផង ។

[ ៣០៧ ] ចក្ខាយតនៈ កើតឡើង ក្នុងទីណា សោតាយតនៈ កើតឡើង ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត សោតាយតនៈ កើតឡើង ក្នុងទីណា ចក្ខាយតនៈ កើតឡើង ក្នុងទីនោះដែរឬ ។ អើ ។

[ ៣០៨ ] ចក្ខាយតនៈ កើតឡើង ក្នុងទីណា ឃានាយតនៈ កើតឡើង ក្នុងទីនោះដែរឬ ។ ចក្ខាយតនៈកើតឡើង ក្នុងរូបាវចរភពនោះ តែឃានាយតនៈ មិនកើតឡើងក្នុងរូបាវចរភពនោះទេ ចក្ខាយតនៈ កើតឡើងផង ឃានាយតនៈ

កើតឡើងផង ក្នុងកាមាវចរភពនោះ ។ មួយយ៉ាងទៀត ឃានាយតនៈ កើតឡើង ក្នុងទីណា ចក្ខាយតនៈ កើតឡើង ក្នុងទីនោះដែរឬ ។ អើ ។

[ ៣០៩ ] ចក្ខាយតនៈ កើតឡើង ក្នុងទីណា រូបាយតនៈ កើតឡើងក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត រូបាយតនៈ កើតឡើង ក្នុងទីណា ចក្ខាយតនៈ កើតឡើង ក្នុងទីនោះដែរឬ ។ រូបាយតនៈ កើតឡើង ក្នុងអសញ្ញសត្តនោះ តែចក្ខាយតនៈ មិនកើតឡើង ក្នុងអសញ្ញសត្តនោះទេ រូបាយតនៈ កើតឡើងផង ចក្ខាយតនៈ កើតឡើងផង ក្នុងបញ្ចវោការភពនោះ ។

[ ៣១០ ] ចក្ខាយតនៈ កើតឡើង ក្នុងទីណា មនាយតនៈ កើតឡើង ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត មនាយតនៈ កើតឡើង ក្នុងទីណា ចក្ខាយតនៈ កើតឡើងក្នុងទីនោះដែរឬ ។ មនាយតនៈ កើតឡើង ក្នុងអរូបភពនោះ តែចក្ខាយតនៈ មិនកើតឡើង ក្នុងអរូបភពនោះទេ មនាយតនៈ កើតឡើងផង ចក្ខាយតនៈ កើតឡើងផង ក្នុងបញ្ចវោការភពនោះ ។

[ ៣១១ ] ចក្ខាយតនៈ កើតឡើង ក្នុងទីណា ធម្មាយតនៈ កើតឡើង ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ កើតឡើង ក្នុងទីណា ចក្ខាយតនៈកើតឡើង ក្នុងទីនោះដែរឬ ។ ធម្មាយតនៈកើតឡើង ក្នុងអសញ្ញសត្តនិងអរូបភពនោះ តែចក្ខាយតនៈ មិនកើតឡើង ក្នុងទីនោះទេ ធម្មាយតនៈ កើតឡើងផង ចក្ខាយតនៈ កើតឡើងផង ក្នុងបញ្ចវោការភពនោះ ។

[ ៣១២ ] ឃានាយតនៈ កើតឡើង ក្នុងទីណា រូបាយតនៈ កើតឡើង ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត រូបាយតនៈ កើតឡើង ក្នុងទីណា

ឃានាយតនៈ កើតឡើង ក្នុងទីនោះដែរឬ ។ រូបាយតនៈ កើតឡើង ក្នុងរូបាវចរភពនោះ តែឃានាយតនៈមិនកើតឡើងក្នុងរូបាវចរភពនោះទេ រូបាយតនៈ កើតឡើងផង ឃានាយតនៈ កើតឡើងផង ក្នុងកាមាវចរភពនោះ ។ ( បណ្ឌិតគប្បីដឹងថា ឃានាយតនៈ កើតឡើង ក្នុងទីណា មនាយតនៈក្តី ធម្មាយតនៈក្តី ដូចគ្នា ឬផ្សេងគ្នា មិនមានក្នុងទីនោះ សេចក្តីសង្ខេប មានក្នុងវារៈខាងលើ ) ។

[ ៣១៣ ] ឃានាយតនៈ កើតឡើង ក្នុងទីណា ធម្មាយតនៈ កើតឡើង ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ កើតឡើង ក្នុងទីណា ឃានាយតនៈកើតឡើង ក្នុងទីនោះដែរឬ ។ ធម្មាយតនៈកើតឡើងក្នុងរូបាវចរភព និងអរូបាវចរភពនោះ តែឃានាយតនៈ មិនកើតឡើងក្នុងទីនោះទេ ធម្មាយតនៈ កើតឡើងផង ឃានាយតនៈ កើតឡើងផង ក្នុងកាមាវចរភពនោះ ។

[ ៣១៤ ] រូបាយតនៈ កើតឡើង ក្នុងទីណា មនាយតនៈ កើតឡើងក្នុងទីនោះដែរឬ ។ រូបាយតនៈ កើតឡើង ក្នុងអសញ្ញសត្វនោះ តែមនាយតនៈ មិនកើតឡើង ក្នុងអសញ្ញសត្វនោះទេ រូបាយតនៈ កើតឡើងផង មនាយតនៈ កើតឡើងផង ក្នុងបញ្ចវោការភពនោះ ។ មួយយ៉ាងទៀត មនាយតនៈ កើតឡើង ក្នុងទីណា រូបាយតនៈ កើតឡើង ក្នុងទីនោះដែរឬ ។ មនាយតនៈ កើតឡើង ក្នុងអរូបភពនោះ តែរូបាយតនៈ មិនកើតឡើង ក្នុងអរូបភពនោះទេ មនាយតនៈ កើតឡើងផង រូបាយតនៈ កើតឡើងផង ក្នុងបញ្ចវោការភពនោះ ។

[ ៣១៥ ] រូបាយតនៈ កើតឡើង ក្នុងទីណា ធម្មាយតនៈ កើតឡើង

ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ កើតឡើង ក្នុងទីណា រូបាយតនៈ កើតឡើង ក្នុងទីនោះដែរឬ ។ ធម្មាយតនៈ កើតឡើង ក្នុងអរូបភពនោះ តែរូបាយតនៈ មិនកើតឡើងក្នុងអរូបភពនោះទេ ធម្មាយតនៈ កើតឡើងផង រូបាយតនៈ កើតឡើងផង ក្នុងបញ្ចវោការភព និងអសញ្ញសត្វនោះ ។

[ ៣១៦ ] មនាយតនៈ កើតឡើង ក្នុងទីណា ធម្មាយតនៈ កើតឡើង ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ កើតឡើង ក្នុងទីណា មនាយតនៈកើតឡើងក្នុងទីនោះដែរឬ ។ ធម្មាយតនៈ កើតឡើង ក្នុងអសញ្ញសត្វនោះ តែមនាយតនៈ មិនកើតឡើង ក្នុងអសញ្ញសត្វនោះទេ ធម្មាយតនៈកើតឡើងផង មនាយតនៈកើតឡើងផង ក្នុងចតុវោការភព និងបញ្ចវោការភពនោះ ។

[ ៣១៧ ] ចក្ខាយតនៈ របស់សត្វណា កើតឡើង ក្នុងទីណា សោតាយតនៈ របស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វដែលប្រកបដោយចក្ខុ មិនមានសោតៈ កាលចាប់បដិសន្ធិ ចក្ខាយតនៈរបស់សត្វទាំងនោះ កើតឡើង ក្នុងទីនោះ តែសោតាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយចក្ខុ ប្រកបដោយសោតៈ កាលចាប់បដិសន្ធិ ចក្ខាយតនៈ របស់សត្វទាំងនោះ កើតឡើងផង សោតាយតនៈកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សោតាយតនៈរបស់សត្វណា កើតឡើង ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វដែលប្រកបដោយសោតៈ មិនមានចក្ខុ កាលចាប់បដិសន្ធិ សោតាយតនៈរបស់សត្វទាំងនោះ កើតឡើងក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វ

ទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយសោតៈ ប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ សោតាយតនៈរបស់សត្វទាំងនោះ កើតឡើងផង ចក្ខាយតនៈ កើតឡើងផង ក្នុងទីនោះ ។ ( សេចក្ដីដែលលោកបង្រួញហើយ សុទ្ធតែដូចគ្នា ) ។

[ ៣១៨ ] មនាយតនៈ របស់សត្វណា កើតឡើង ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ កើតឡើងក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា កើតឡើង ក្នុងទីណា មនាយតនៈ របស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វដែលមិនមានចិត្ត កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ កើតឡើង ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយចិត្ត កាលចាប់បដិសន្ធិ ធម្មាយតនៈរបស់សត្វទាំងនោះ កើតឡើងផង មនាយតនៈ កើតឡើងផង ក្នុងទីនោះ ។

[ ៣១៩ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើង សោតាយតនៈ របស់សត្វនោះ មិនកើតឡើងដែរឬ ។ ពួកសត្វដែលមិនមានចក្ខុ ប្រកបដោយសោតៈ កាលចាប់បដិសន្ធិ ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង តែសោតាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ពួកសត្វទាំងអស់ ដែលមិនមានចក្ខុ មិនមានសោតៈ កាលច្យុត កាលចាប់បដិសន្ធិ ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង សោតាយតនៈ មិនកើតឡើងផង ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា មិនកើតឡើង

ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើងដែរឬ ។ ពួកសត្វដែលមិនមាន សោតៈ ប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ សោតាយតនៈ របស់សត្វទាំង នោះ មិនកើតឡើង តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើត ឡើងទេ ពួកសត្វទាំងអស់ ដែលមិនមានសោតៈ មិនមានចក្ខុ កាលច្យុត កាល ចាប់បដិសន្ធិ សោតាយតនៈ របស់សត្វទាំងនោះ កើតឡើងផង ចក្ខាយតនៈ មិនកើតឡើងផង ។

[ ៣២០ ] ចក្ខាយតនៈរបស់សត្វណា មិនកើតឡើង ឃានាយតនៈរបស់ សត្វនោះ មិនកើតឡើងដែរឬ ។ ពួកសត្វដែលមិនមានចក្ខុ ប្រកបដោយឃានៈ កាលចាប់បដិសន្ធិ ចក្ខាយតនៈរបស់សត្វទាំងនោះ មិនកើតឡើង តែឃានា-យតនៈរបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ពួកសត្វទាំងអស់ ដែល មិនមានចក្ខុ មិនមានឃានៈ កាលច្យុត កាលចាប់បដិសន្ធិ ចក្ខាយតនៈរបស់ សត្វទាំងនោះ មិនកើតឡើងផង ឃានាយតនៈ មិនកើតឡើងផង ។ មួយយ៉ាង ទៀត ឃានាយតនៈ របស់សត្វណា មិនកើតឡើង ចក្ខាយតនៈ របស់សត្វ នោះ មិនកើតឡើងដែរឬ ។ ពួកសត្វដែលមិនមានឃានៈ ប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ ឃានាយតនៈរបស់សត្វទាំងនោះ មិនកើតឡើង តែចក្ខា-យតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ពួកសត្វទាំងអស់ ដែលមិនមានឃានៈ មិនមានចក្ខុ កាលច្យុត កាលចាប់បដិសន្ធិ ឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង ចក្ខាយតនៈ មិនកើតឡើងផង ។

[ ៣២១ ] ចក្ខាយតនៈរបស់សត្វណា មិនកើតឡើង រូបាយតនៈរបស់

សត្វនោះ មិនកើតឡើងដែរឬ ។ ពួកសត្វដែលមិនមានចក្ខុ ប្រកបដោយរូប កាលចាប់បដិសន្ធិ ចក្ខាយតនៈរបស់សត្វទាំងនោះ មិនកើតឡើង តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ពួកសត្វទាំងអស់ ដែលមិនមានរូប កាលច្យុត កាលចាប់បដិសន្ធិ ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង រូបាយតនៈ មិនកើតឡើងផង ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា មិនកើតឡើង ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើងដែរឬ ។ អើ ។

[ ៣២២ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើង មនាយតនៈរបស់សត្វនោះ មិនកើតឡើងដែរឬ ។ ពួកសត្វដែលមិនមានចក្ខុ ប្រកបដោយចិត្ត កាលចាប់បដិសន្ធិ ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង តែមនាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ពួកសត្វទាំងអស់ ដែលមិនមានចិត្ត កាលច្យុត កាលចាប់បដិសន្ធិ ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង មនាយតនៈ មិនកើតឡើងផង ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា មិនកើតឡើង ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើងដែរឬ ។ អើ ។

[ ៣២៣ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើង ធម្មាយតនៈ របស់សត្វនោះ មិនកើតឡើងដែរឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលចាប់បដិសន្ធិ ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ពួកសត្វទាំងអស់ កាលច្យុត

ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង ធម្មាយតនៈ មិនកើតឡើងផង ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា មិនកើតឡើង ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើងដែរឬ ។ អើ ។

[ ៣២៤ ] ឃានាយតនៈរបស់សត្វណា មិនកើតឡើង រូបាយតនៈរបស់សត្វនោះ មិនកើតឡើងដែរឬ ។ ពួកសត្វដែលមិនមានឃានៈ ប្រកបដោយរូប កាលចាប់បដិសន្ធិ ឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង តែរូបាយតនៈរបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ពួកសត្វទាំងអស់ដែលមិនមានរូប កាលច្យុត កាលចាប់បដិសន្ធិ ឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង រូបាយតនៈ មិនកើតឡើងផង ។ មួយយ៉ាងទៀត រូបា-យតនៈរបស់សត្វណា មិនកើតឡើង ឃានាយតនៈ របស់សត្វនោះ មិនកើតឡើងដែរឬ ។ អើ ។

[ ៣២៥ ] ឃានាយតនៈ របស់សត្វណា មិនកើតឡើង មនាយតនៈ របស់សត្វនោះ មិនកើតឡើងដែរឬ ។ ពួកសត្វដែលមិនមានឃានៈ ប្រកបដោយចិត្ត កាលចាប់បដិសន្ធិ ឃានាយតនៈរបស់សត្វទាំងនោះ មិនកើតឡើង តែមនាយតនៈរបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ពួកសត្វទាំងអស់ ដែលមិនមានចិត្ត កាលច្យុត កាលចាប់បដិសន្ធិ ឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង មនាយតនៈ មិនកើតឡើងផង ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា មិនកើតឡើង ឃានាយតនៈ របស់សត្វនោះ មិនកើតឡើងដែរឬ ។ អើ ។

[ ៣២៦ ] ឃានាយតនៈ របស់សត្វណា មិនកើតឡើង ធម្មាយតនៈ របស់សត្វនោះ មិនកើតឡើងដែរឬ ។ ពួកសត្វដែលមិនមានឃានៈ កាលចាប់បដិសន្ធិ ឃានាយតនៈរបស់សត្វទាំងនោះ មិនកើតឡើង តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ពួកសត្វទាំងអស់ កាលច្យុត ឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង ធម្មាយតនៈ មិនកើតឡើងផង ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា មិនកើតឡើង ឃានាយតនៈ របស់សត្វនោះ មិនកើតឡើងដែរឬ ។ អើ ។

[ ៣២៧ ] រូបាយតនៈ របស់សត្វណា មិនកើតឡើង មនាយតនៈ របស់សត្វនោះ មិនកើតឡើងដែរឬ ។ ពួកសត្វដែលមិនមានរូប កាលចាប់បដិសន្ធិ រូបាយតនៈរបស់សត្វទាំងនោះ មិនកើតឡើង តែមនាយតនៈរបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ពួកសត្វទាំងអស់ កាលច្យុត រូបាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង មនាយតនៈ មិនកើតឡើងផង ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា មិនកើតឡើង រូបាយតនៈ របស់សត្វនោះ មិនកើតឡើងដែរឬ ។ ពួកសត្វដែលមិនមានចិត្ត កាលចាប់បដិសន្ធិ មនាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ពួកសត្វទាំងអស់ កាលច្យុត មនាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង រូបាយតនៈ មិនកើតឡើងផង ។

[ ៣២៨ ] រូបាយតនៈ របស់សត្វណា មិនកើតឡើង ធម្មាយតនៈរបស់

សត្វនោះ មិនកើតឡើងដែរឬ ។ ពួកសត្វដែលមិនមានរូប កាលចាប់បដិសន្ធិ រូបាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ពួកសត្វទាំងអស់ កាលច្យុត រូបាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង ធម្មាយតនៈ មិនកើតឡើងផង ។ មួយយ៉ាងទៀត ធម្មាយតនៈរបស់សត្វណា មិនកើតឡើង រូបាយតនៈរបស់សត្វនោះ មិនកើតឡើងដែរឬ ។ អើ ។

[ ៣២៩ ] មនាយតនៈរបស់សត្វណា មិនកើតឡើង ធម្មាយតនៈរបស់សត្វនោះ មិនកើតឡើងដែរឬ ។ ពួកសត្វដែលមិនមានចិត្ត កាលចាប់បដិសន្ធិ មនាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ពួកសត្វទាំងអស់ កាលច្យុត មនាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង ធម្មាយតនៈ មិនកើតឡើងផង ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា មិនកើតឡើង មនាយតនៈ របស់សត្វនោះ មិនកើតឡើងដែរឬ ។ អើ ។

[ ៣៣០ ] ចក្ខាយតនៈ មិនកើតឡើង ក្នុងទីណា សោតាយតនៈ មិនកើតឡើង ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត សោតាយតនៈ មិនកើតឡើង ក្នុងទីណា ចក្ខាយតនៈ មិនកើតឡើង ក្នុងទីនោះដែរឬ ។ អើ ។

[ ៣៣១ ] ចក្ខាយតនៈ មិនកើតឡើង ក្នុងទីណា ឃានាយតនៈ មិនកើតឡើង ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត ឃានាយតនៈ មិនកើតឡើង ក្នុងទីណា ចក្ខាយតនៈ មិនកើតឡើង ក្នុងទីនោះដែរឬ ។ ឃានាយតនៈ មិន

កើតឡើង ក្នុងរូបាវចរភពនោះ តែចក្ខាយតនៈ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ឃានាយតនៈ មិនកើតឡើងផង ចក្ខាយតនៈ មិនកើតឡើងផង ក្នុងអសញ្ញសត្វ និងក្នុងអរូបភពនោះ ។

[ ៣៣២ ] ចក្ខាយតនៈ មិនកើតឡើង ក្នុងទីណា រូបាយតនៈ មិនកើតឡើង ក្នុងទីនោះដែរឬ ។ ចក្ខាយតនៈ មិនកើតឡើង ក្នុងអសញ្ញសត្វនោះ តែរូបាយតនៈ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ចក្ខាយតនៈ មិនកើតឡើងផង រូបាយតនៈ មិនកើតឡើងផង ក្នុងអរូបភពនោះ ។ មួយយ៉ាងទៀត រូបាយតនៈ មិនកើតឡើង ក្នុងទីណា ចក្ខាយតនៈ មិនកើតឡើង ក្នុងទីនោះដែរឬ ។ អើ ។

[ ៣៣៣ ] ចក្ខាយតនៈ មិនកើតឡើង ក្នុងទីណា មនាយតនៈ មិនកើតឡើង ក្នុងទីនោះដែរឬ ។ ចក្ខាយតនៈ មិនកើតឡើង ក្នុងអរូបភពនោះ តែមនាយតនៈ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ចក្ខាយតនៈ មិនកើតឡើងផង មនាយតនៈ មិនកើតឡើងផង ក្នុងអសញ្ញសត្វនោះ ។ មួយយ៉ាងទៀត មនាយតនៈ មិនកើតឡើង ក្នុងទីណា ចក្ខាយតនៈ មិនកើតឡើង ក្នុងទីនោះដែរឬ ។ អើ ។

[ ៣៣៤ ] ចក្ខាយតនៈ មិនកើតឡើង ក្នុងទីណា ធម្មាយតនៈ មិនកើតឡើង ក្នុងទីនោះដែរឬ ។ កើតឡើង ។ មួយយ៉ាងទៀត ធម្មាយតនៈ មិនកើតឡើង ក្នុងទីណា ចក្ខាយតនៈ មិនកើតឡើង ក្នុងទីនោះដែរឬ ។ មិនមានទេ ។

[ ៣៣៥ ] ឃានាយតនៈ មិនកើតឡើង ក្នុងទីណា រូបាយតនៈ មិន

កើតឡើង ក្នុងទីនោះដែរឬ ។ ឃានាយតនៈ មិនកើតឡើង ក្នុងរូបាវចរភព នោះ តែរូបាយតនៈ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ឃានាយតនៈ មិនកើតឡើងផង រូបាយតនៈ មិនកើតឡើងផង ក្នុងអរូបភពនោះ ។ មួយយ៉ាងទៀត រូបាយតនៈ មិនកើតឡើង ក្នុងទីណា ឃានាយតនៈ មិនកើតឡើង ក្នុងទីនោះដែរឬ ។ អើ ។

[ ៣៣៦ ] ឃានាយតនៈ មិនកើតឡើង ក្នុងទីណា មនាយតនៈ មិនកើតឡើង ក្នុងទីនោះដែរឬ ។ ឃានាយតនៈ មិនកើតឡើង ក្នុងរូបាវចរភព និងអរូបាវចរភពនោះ តែមនាយតនៈ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ឃានាយតនៈ មិនកើតឡើងផង មនាយតនៈ មិនកើតឡើងផង ក្នុងអសញ្ញ-សត្វនោះទេ ។ មួយយ៉ាងទៀត មនាយតនៈ មិនកើតឡើង ក្នុងទីណា ឃានា-យតនៈ មិនកើតឡើង ក្នុងទីនោះដែរឬ ។ អើ ។

[ ៣៣៧ ] ឃានាយតនៈ មិនកើតឡើង ក្នុងទីណា ធម្មាយតនៈ មិនកើតឡើង ក្នុងទីនោះដែរឬ ។ កើតឡើង ។ មួយយ៉ាងទៀត ធម្មាយតនៈមិនកើតឡើង ក្នុងទីណា ឃានាយតនៈ មិនកើតឡើង ក្នុងទីនោះដែរឬ ។ មិនមានទេ ។

[ ៣៣៨ ] រូបាយតនៈ មិនកើតឡើង ក្នុងទីណា មនាយតនៈ មិនកើតឡើង ក្នុងទីនោះទេឬ ។ កើតឡើង ។ មួយយ៉ាងទៀត មនាយតនៈ មិនកើតឡើង ក្នុងទីណា រូបាយតនៈ មិនកើតឡើង ក្នុងទីនោះទេឬ ។ កើតឡើង ។

[ ៣៣៩ ] រូបាយតនៈ មិនកើតឡើង ក្នុងទីណា ធម្មាយតនៈ មិនកើត

ឡើង ក្នុងទីនោះទេឬ ។ កើតឡើង ។ មួយយ៉ាងទៀត ធម្មាយតនៈ មិនកើតឡើង ក្នុងទីណា រូបាយតនៈ មិនកើតឡើង ក្នុងទីនោះទេឬ ។ មិនមានទេ ។

[ ៣៤០ ] មនាយតនៈ មិនកើតឡើង ក្នុងទីណា ធម្មាយតនៈ មិនកើតឡើង ក្នុងទីនោះទេឬ ។ កើតឡើង ។ មួយយ៉ាងទៀត ធម្មាយតនៈ មិនកើតឡើង ក្នុងទីណា មនាយតនៈ មិនកើតឡើង ក្នុងទីនោះទេឬ ។ មិនមានទេ ។

[ ៣៤១ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើង ក្នុងទីណា សោតាយតនៈ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះទេឬ ។ ពួកសត្វដែលមិនមានចក្ខុ ប្រកបដោយសោតៈ កាលចាប់បដិសន្ធិ ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ តែសោតាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងក្នុងទីនោះទេ ពួកសត្វទាំងអស់ ដែលមិនមានចក្ខុ មិនមានសោតៈ កាលច្យុត កាលចាប់បដិសន្ធិ ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង សោតាយតនៈ មិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា មិនកើតឡើង ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះទេឬ ។ ពួកសត្វដែលមិនមានសោតៈ ប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ សោតាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វទាំងអស់ ដែលមិនមានសោតៈ មិនមានចក្ខុ កាលច្យុត កាលចាប់បដិសន្ធិ សោតាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង ចក្ខាយតនៈ មិនកើតឡើងផង ក្នុង

ទីនោះ ។បេ។

[ ៣៨២ ] មនាយតនៈ របស់សត្វណា មិនកើតឡើង ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះទេឬ ។ ពួកសត្វដែល មិនមានចិត្ត កាលចាប់បដិសន្ធិ មនាយតនៈ របស់សត្វទាំងនោះ មិនកើត ឡើង ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើត ឡើង ក្នុងទីនោះទេ ពួកសត្វទាំងអស់ កាលច្យុត មនាយតនៈ របស់សត្វ ទាំងនោះ មិនកើតឡើងផង ធម្មាយតនៈ មិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា មិនកើតឡើង ក្នុងទីណា មនាយតនៈ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះទេឬ ។ អើ ។

[ ៣៨៣ ] ចក្ខាយតនៈ របស់សត្វណា កើតឡើងហើយ សោតាយតនៈ របស់សត្វនោះ កើតឡើងហើយដែរឬ ។ អើ ។ មួយយ៉ាងទៀត សោតា- យតនៈ របស់សត្វណា កើតឡើងហើយ ចក្ខាយតនៈ របស់សត្វនោះ កើតឡើងហើយដែរឬ ។ អើ ។

[ ៣៨៤ ] ចក្ខាយតនៈ របស់សត្វណា កើតឡើងហើយ ឃានាយតនៈ របស់សត្វនោះ ។បេ។ រូបាយតនៈ មនាយតនៈ ធម្មាយតនៈ កើតឡើងហើយ ដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈរបស់សត្វណា កើតឡើងហើយ ចក្ខាយតនៈ របស់សត្វនោះ កើតឡើងហើយដែរឬ ។ អើ ។បេ។

[ ៣៨៥ ] ឃានាយតនៈ របស់សត្វណា ។បេ។ រូបាយតនៈ មនាយតនៈ កើតឡើងហើយ ធម្មាយតនៈរបស់សត្វនោះ កើតឡើងហើយដែរឬ ។ អើ ។

មួយយ៉ាងទៀត ឃានាយតនៈ របស់សត្វណា កើតឡើងហើយ មនាយតនៈ របស់សត្វនោះ កើតឡើងហើយដែរឬ ។ អើ ។

[ ៣៤៦ ] ចក្ខាយតនៈ កើតឡើងហើយ ក្នុងទីណា ។បេ។ ( ប្រយោគ ដែលប្រកបដោយពាក្យថា ក្នុងទីណា ជាពាក្យប្រហែលគ្នាទាំងអស់ ក្នុង បច្ចុប្បន្នត្តិ ក្នុងអតីតត្តិ ក្នុងអនាគតត្តិ ក្នុងអតីតជិតបច្ចុប្បន្នត្តិ ក្នុងអនាគតជិត បច្ចុប្បន្នត្តិ ក្នុងអនាគតជិតអតីតត្តិ បណ្ឌិតគប្បីធ្វើឲ្យក្រៃលែង នូវឈ្មោះថា កើតឡើង កើតឡើងហើយ ) ។

[ ៣៤៧ ] ចក្ខាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា សោតាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ អើ ។

[ ៣៤៨ ] ចក្ខាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ ចក្ខា-យតនៈ របស់ពួកសត្វជារូបាវចរនោះ កើតឡើងហើយ ក្នុងទីនោះ តែ ឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ចក្ខា-យតនៈ របស់ពួកសត្វជាកាមាវចរនោះ កើតឡើងហើយផង ឃានាយតនៈ កើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ឃានាយតនៈ របស់សត្វ ណា កើតឡើងហើយ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ កើតឡើង ហើយ ក្នុងទីនោះដែរឬ ។ អើ ។

[ ៣៤៩ ] ចក្ខាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ រូបាយតនៈ របស់អសញ្ញសត្វទាំងនោះ កើតឡើងហើយ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ រូបាយតនៈ របស់សត្វជាបញ្ចវោការទាំងនោះ កើតឡើងហើយផង ចក្ខាយតនៈ កើតឡើងហើយផង ក្នុងទីនោះ ។

[ ៣៥០ ] ចក្ខាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា មនាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ មនាយតនៈ របស់អរូបព្រហ្មទាំងនោះ កើតឡើងហើយ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ មនាយតនៈ របស់សត្វជាបញ្ចវោការទាំងនោះ កើតឡើងហើយផង ចក្ខាយតនៈ កើតឡើងហើយផង ក្នុងទីនោះ ។

[ ៣៥១ ] ចក្ខាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈរបស់សត្វណា កើតឡើងហើយ ក្នុងទីណា ចក្ខា-

យតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ ធម្មាយតនៈ របស់ពួកអសញ្ញសត្វ និងអរូបព្រហ្មទាំងនោះ កើតឡើងហើយ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ធម្មាយតនៈ របស់សត្វជាបញ្ចវោការទាំងនោះ កើតឡើងហើយផង ចក្ខាយតនៈ កើតឡើងហើយផង ក្នុងទីនោះ ។

[ ៣៥២ ] ឃានាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ រូបាយតនៈ របស់សត្វជារូបាវចរទាំងនោះ កើតឡើងហើយ ក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ រូបាយតនៈ របស់សត្វជាកាមាវចរទាំងនោះ កើតឡើងហើយផង ឃានាយតនៈ កើតឡើងហើយផង ក្នុងទីនោះ ។

[ ៣៥៣ ] ឃានាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា មនាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ មនាយតនៈ របស់ពួកសត្វជារូបាវចរ និងអរូបាវចរទាំងនោះ កើតឡើងហើយ ក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ មនា-

យតនៈ របស់សត្វជាកាមាវចរទាំងនោះ កើតឡើងហើយផង ឃានាយតនៈ កើតឡើងហើយផង ក្នុងទីនោះ ។

[ ៣៥៤ ] ឃានាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ ធម្មាយតនៈរបស់ពួកសត្វជារូបាវចរ និងអរូបាវចរទាំងនោះ កើតឡើងហើយ ក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយក្នុងទីនោះទេ ធម្មាយតនៈ របស់សត្វជាកាមាវចរទាំងនោះ កើតឡើងហើយផង ឃានាយតនៈ កើតឡើងហើយផង ក្នុងទីនោះ ។

[ ៣៥៥ ] រូបាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា មនាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ រូបាយតនៈ របស់អសញ្ញសត្វទាំងនោះ កើតឡើងហើយ ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ រូបាយតនៈ របស់សត្វជាបញ្ចវោការទាំងនោះ កើតឡើងហើយផង មនាយតនៈ កើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ មនាយតនៈ របស់អរូបព្រហ្មទាំងនោះ កើតឡើងហើយ ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ មនាយតនៈ របស់សត្វ

ជាបញ្ចវោការទាំងនោះ កើតឡើងហើយផង រូបាយតនៈ កើតឡើងហើយផង ក្នុងទីនោះ ។

[ ៣៥៦ ] រូបាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ ធម្មាយតនៈ របស់អរូបព្រហ្មទាំងនោះ កើតឡើងហើយ ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ធម្មាយតនៈ របស់ពួកសត្វជាបញ្ចវោការ និងអសញ្ញសត្វទាំងនោះ កើតឡើងហើយផង រូបាយតនៈ កើតឡើងហើយផង ក្នុងទីនោះ ។

[ ៣៥៧ ] មនាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈរបស់សត្វណា កើតឡើងហើយ ក្នុងទីណា មនាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ ធម្មាយតនៈ របស់អសញ្ញសត្វទាំងនោះ កើតឡើងហើយ ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ធម្មាយតនៈ របស់ពួកសត្វជាចតុវោការ និងបញ្ចវោការទាំងនោះ កើតឡើងហើយផង មនាយតនៈ កើតឡើងហើយផង ក្នុងទីនោះ ។

[ ៣៥៨ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើងហើយ សោតាយតនៈ

របស់សត្វនោះ មិនកើតឡើងហើយទេឬ ។ មិនមានទេ ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា កើតឡើងហើយ ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើងហើយទេឬ ។ មិនមានទេ ។ ( នេះជាសេចក្តីសង្ខេប ) ។

[ ៣៥៩ ] មនាយតនៈ របស់សត្វណា មិនកើតឡើងហើយ ធម្មាយតនៈ របស់សត្វនោះ មិនកើតឡើងហើយទេឬ ។ មិនមានទេ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា មិនកើតឡើងហើយ មនាយតនៈ របស់សត្វនោះ មិនកើតឡើងហើយទេឬ ។ មិនមានទេ ។

[ ៣៦០ ] ចក្ខាយតនៈ មិនកើតឡើងហើយ ក្នុងទីណា ។បេ។

[ ៣៦១ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា សោតាយតនៈ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ អើ ។ មួយយ៉ាងទៀត សោតាយតនៈរបស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ អើ ។

[ ៣៦២ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ អើ ។ មួយយ៉ាងទៀត ឃានាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ ឃានាយតនៈ របស់សត្វជារូបាវចរទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ ឃានាយតនៈ របស់ពួកសុទ្ធាវាសសត្វ និងពួកអសញ្ញសត្វ និងអរូបព្រហ្ម

ទាំងនោះ មិនកើតឡើងហើយផង ចក្ខាយតនៈ មិនកើតឡើងហើយផង ក្នុងទីនោះ ។

[ ៣៦៣ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ ចក្ខាយតនៈ របស់អសញ្ញសត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ ចក្ខាយតនៈ របស់ពួកសុទ្ធាវាសសត្វ និងអរូបព្រហ្មទាំងនោះ មិនកើតឡើងហើយផង រូបាយតនៈ មិនកើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ អើ ។

[ ៣៦៤ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា មនាយតនៈរបស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ ចក្ខាយតនៈ របស់អរូបព្រហ្មទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ ចក្ខាយតនៈ របស់ពួកសុទ្ធាវាសសត្វ និងអសញ្ញសត្វទាំងនោះ មិនកើតឡើងហើយផង មនាយតនៈ មិនកើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ អើ ។

[ ៣៦៥ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុង

ទីណា ធម្មាយតនៈ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ ចក្ខាយតនៈ របស់ពួកអសញ្ញសត្វ និងអរូបព្រហ្មទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ ចក្ខាយតនៈ របស់សុទ្ធាវាសសត្វទាំងនោះ មិនកើតឡើងហើយផង ធម្មាយតនៈ មិនកើតឡើងហើយផងក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើងហើយក្នុងទីនោះទេឬ ។ អើ ។

[ ៣៦៦ ] ឃានាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា រូបាយតនៈរបស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ ឃានាយតនៈ របស់សត្វជារូបាវចរទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ ឃានាយតនៈ របស់ពួកសុទ្ធាវាសសត្វ និងអរូបព្រហ្មទាំងនោះ មិនកើតឡើងហើយផង រូបាយតនៈ មិនកើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ អើ ។

[ ៣៦៧ ] ឃានាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា មនាយតនៈរបស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ ឃានាយតនៈ របស់ពួកសត្វជារូបាវចរ និងអរូបាវចរទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែមនាយតនៈរបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុង

ទីនោះទេ យានាយតនៈ របស់ពួកសុទ្ធាវាសសត្វ និងអសញ្ញសត្វទាំងនោះ មិនកើតឡើងហើយផង មនាយតនៈ មិនកើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា យានាយតនៈ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ អើ ។

[ ៣៦៨ ] យានាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា ធម្មាយតនៈរបស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ យានាយតនៈ របស់ពួកសត្វជារូបាវចរ និងអរូបាវចរទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ យានាយតនៈ របស់សុទ្ធាវាសសត្វទាំងនោះ មិនកើតឡើងហើយផង ធម្មាយតនៈ មិនកើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា យានាយតនៈ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ អើ ។

[ ៣៦៩ ] រូបាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា មនាយតនៈរបស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ រូបាយតនៈ របស់អរូបព្រហ្មទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែមនាយតនៈរបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ រូបាយតនៈរបស់សុទ្ធាវាសសត្វទាំងនោះ មិនកើតឡើងហើយផង មនាយតនៈ មិនកើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ មិនកើតឡើងហើយ

ក្នុងទីនោះទេឬ ។ មនាយតនៈរបស់អសញ្ញសត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ មនាយតនៈ របស់សុទ្ធាវាសសត្វទាំងនោះ មិនកើតឡើងហើយផង រូបាយតនៈ មិនកើតឡើងហើយផង ក្នុងទីនោះ ។

[ ៣៧០ ] រូបាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា ធម្មាយតនៈរបស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ រូបាយតនៈ របស់អរូបព្រហ្មទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែធម្មាយតនៈរបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ រូបាយតនៈរបស់សុទ្ធាវាសសត្វទាំងនោះ មិនកើតឡើងហើយផង ធម្មាយតនៈ មិនកើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ អើ ។

[ ៣៧១ ] មនាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ មនាយតនៈ របស់អសញ្ញសត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ មនាយតនៈ របស់សុទ្ធាវាសសត្វទាំងនោះ មិនកើតឡើងហើយផង ធម្មាយតនៈ មិនកើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា មិនកើតឡើងហើយក្នុងទីណា មនាយតនៈ របស់

សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ អើ ។

[ ៣៧២ ] ចក្ខាយតនៈ របស់សត្វណា នឹងកើតឡើង សោតាយតនៈ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ អើ ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា នឹងកើតឡើង ចក្ខាយតនៈ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ អើ ។

[ ៣៧៣ ] ចក្ខាយតនៈ របស់សត្វណា នឹងកើតឡើង ឃានាយតនៈ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ ពួកសត្វណា ចូលទៅកាន់រូបាវចរភព ហើយ នឹងបរិនិព្វាន ចក្ខាយតនៈ របស់សត្វទាំងនោះ នឹងកើតឡើង តែ ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ ចក្ខាយតនៈ របស់សត្វទាំងនោះ ក្រៅនេះ នឹងកើតឡើងផង ឃានាយតនៈ នឹងកើតឡើងផង ។ មួយយ៉ាងទៀត ឃានាយតនៈ របស់សត្វណា នឹងកើតឡើង ចក្ខាយតនៈ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ អើ ។

[ ៣៧៤ ] ចក្ខាយតនៈ របស់សត្វណា នឹងកើតឡើង រូបាយតនៈរបស់សត្វនោះ នឹងកើតឡើងដែរឬ ។ អើ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងកើតឡើង ចក្ខាយតនៈ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ អើ ។ ( ចក្ខាយតនៈ របស់សត្វណា នឹងកើតឡើង មនាយតនៈក្តី ធម្មាយតនៈក្តី របស់សត្វនោះ ក៏ដូចគ្នា អាយតនៈទាំងពីរនេះ ដូចគ្នាតែម្យ៉ាង ) ។

[ ៣៧៥ ] ចក្ខាយតនៈរបស់សត្វណា នឹងកើតឡើង ធម្មាយតនៈរបស់សត្វនោះ នឹងកើតឡើងដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់

សត្វណា នឹងកើតឡើង ចក្ខាយតនៈ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន ធម្មាយតនៈ របស់សត្វទាំងនោះ នឹងកើតឡើង តែចក្ខាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ ធម្មាយតនៈ របស់សត្វទាំងនោះ ក្រៅនេះ នឹងកើតឡើងផង ចក្ខាយតនៈ នឹងកើតឡើងផង ។

[ ៣៧៦ ] ឃានាយតនៈរបស់សត្វណា នឹងកើតឡើង រូបាយតនៈរបស់សត្វនោះ នឹងកើតឡើងដែរឬ ។ អើ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងកើតឡើង ឃានាយតនៈ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ ពួកសត្វណា ចូលទៅកាន់រូបាវចរភពហើយ នឹងបរិនិព្វាន រូបាយតនៈរបស់សត្វទាំងនោះ នឹងកើតឡើង តែឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ រូបាយតនៈ របស់សត្វទាំងនោះ ក្រៅនេះ នឹងកើតឡើងផង ឃានាយតនៈ នឹងកើតឡើងផង ។

[ ៣៧៧ ] ឃានាយតនៈរបស់សត្វណា នឹងកើតឡើង មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងកើតឡើង ឃានាយតនៈ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ ពួកសត្វណា ចូលទៅកាន់រូបាវចរភព និងអរូបាវចរភពហើយ នឹងបរិនិព្វាន ធម្មាយតនៈ របស់សត្វទាំងនោះ នឹងកើតឡើង តែឃានាយតនៈរបស់សត្វទាំងនោះ នឹងមិនកើតឡើងទេ ធម្មាយតនៈរបស់សត្វទាំងនោះ ក្រៅនេះ នឹងកើតឡើងផង ឃានាយតនៈ នឹងកើតឡើងផង ។

[ ៣៧៨ ] រូបាយតនៈ របស់សត្វណា នឹងកើតឡើង មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងកើតឡើង រូបាយតនៈ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន ធម្មាយតនៈ របស់សត្វទាំងនោះ នឹងកើតឡើង តែរូបាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ ធម្មាយតនៈ របស់សត្វទាំងនោះ ក្រៅនេះ នឹងកើតឡើងផង រូបាយតនៈ នឹងកើតឡើងផង ។

[ ៣៧៩ ] មនាយតនៈរបស់សត្វណា នឹងកើតឡើង ធម្មាយតនៈរបស់សត្វនោះ នឹងកើតឡើងដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងកើតឡើង មនាយតនៈ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ អើ ។

[ ៣៨០ ] ចក្ខាយតនៈ នឹងកើតឡើង ក្នុងទីណា ។បេ។

[ ៣៨១ ] ចក្ខាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា សោតាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ អើ ។

[ ៣៨២ ] ចក្ខាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ ចក្ខាយតនៈ របស់សត្វជារូបាវចរទាំងនោះ នឹងកើតឡើង ក្នុងទីនោះ តែឃានាយតនៈ

របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ចក្ខាយតនៈ របស់សត្វជាកាមាវចរទាំងនោះ នឹងកើតឡើងផង ឃានាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ឃានាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ អើ ។

[ ៣៨៣ ] ចក្ខាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា រូបាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ រូបាយតនៈ របស់អសញ្ញសត្វទាំងនោះ នឹងកើតឡើងក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ រូបាយតនៈ របស់សត្វជាបញ្ចវោការទាំងនោះ នឹងកើតឡើងផង ចក្ខាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។

[ ៣៨៤ ] ចក្ខាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា មនាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ នឹងកើតឡើងក្នុងទីនោះដែរឬ ។ មនាយតនៈ របស់អរូបព្រហ្មទាំងនោះ នឹងកើតឡើងក្នុងទីនោះ តែចក្ខាយតនៈរបស់សត្វនោះ នឹងមិនកើតឡើងក្នុងទីនោះទេ មនាយតនៈ របស់សត្វជាបញ្ចវោការទាំងនោះ នឹងកើតឡើងផង ចក្ខាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។

[ ៣៨៥ ] ចក្ខាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា

ធម្មាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ ធម្មាយតនៈ របស់ពួកអសញ្ញសត្វ និងអរូបព្រហ្មទាំងនោះ នឹងកើតឡើង ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ធម្មាយតនៈ របស់សត្វជាបញ្ចវោការទាំងនោះ នឹងកើតឡើងផង ចក្ខាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។

[ ៣៨៦ ] ឃានាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា រូបាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ឃានាយតនៈរបស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ រូបាយតនៈរបស់សត្វជារូបាវចរទាំងនោះ នឹងកើតឡើងក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ រូបាយតនៈ របស់សត្វជាកាមាវចរទាំងនោះ នឹងកើតឡើងផង ឃានាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។

[ ៣៨៧ ] ឃានាយតនៈ របស់សត្វណា នឹងកើតឡើងក្នុងទីណា មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈរបស់សត្វណា នឹងកើតឡើង ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។

ធម្មាយតនៈ របស់ពួកសត្វជារូបាវចរ និងអរូបាវចរទាំងនោះ នឹងកើតឡើង ក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ធម្មាយតនៈ របស់សត្វជាកាមាវចរទាំងនោះ នឹងកើតឡើងផង ឃានាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។

[ ៣៨៨ ] រូបាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា មនាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ រូបាយតនៈ របស់អសញ្ញសត្វទាំងនោះ នឹងកើតឡើង ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ រូបាយតនៈ របស់សត្វជាបញ្ចវោការទាំងនោះ នឹងកើតឡើងផង មនាយតនៈ កើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈរបស់សត្វណា នឹងកើតឡើង ក្នុងទីណា រូបាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ មនាយតនៈរបស់អរូបព្រហ្មទាំងនោះ នឹងកើតឡើង ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ មនាយតនៈ របស់ពួកសត្វជាបញ្ចវោការទាំងនោះ នឹងកើតឡើងផង រូបាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។

[ ៣៨៩ ] រូបាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា រូបាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ ធម្មាយតនៈ របស់អរូបព្រហ្មទាំងនោះ នឹងកើតឡើង ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំង

នោះ នឹងមិនកើតឡើងក្នុងទីនោះទេ ធម្មាយតនៈរបស់ពួកសត្វជាបញ្ចវោការ និងអសញ្ញសត្វទាំងនោះ នឹងកើតឡើងផង រូបាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។

[ ៣៩០ ] មនាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា មនាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ ធម្មាយតនៈ របស់អសញ្ញសត្វទាំងនោះ នឹងកើតឡើង ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ធម្មាយតនៈ របស់ពួកសត្វជាចតុវោការ និងបញ្ចវោការទាំងនោះ នឹងកើតឡើងផង មនាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។

[ ៣៩១ ] ចក្ខាយតនៈរបស់សត្វណា នឹងមិនកើតឡើង សោតាយតនៈ របស់សត្វនោះ នឹងមិនកើតឡើងទេឬ ។ អើ ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា នឹងមិនកើតឡើង ចក្ខាយតនៈ របស់សត្វនោះ នឹងមិនកើតឡើងទេឬ ។ អើ ។

[ ៣៩២ ] ចក្ខាយតនៈ របស់សត្វណា នឹងមិនកើតឡើង ឃានាយតនៈ របស់សត្វនោះ នឹងមិនកើតឡើងទេឬ ។ អើ ។ មួយយ៉ាងទៀត ឃានាយតនៈ របស់សត្វណា នឹងមិនកើតឡើង ចក្ខាយតនៈ របស់សត្វនោះ នឹងមិនកើតឡើងទេឬ ។ ពួកសត្វណា ចូលទៅកាន់រូបាវចរភពហើយ នឹងបរិនិព្វាន

ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ បណ្ដាពួកសត្វ ដែលកើតក្នុងបច្ឆិមភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ចក្ខាយតនៈ នឹងមិនកើតឡើងផង ។

[ ៣៩៣ ] ចក្ខាយតនៈ របស់សត្វណា នឹងមិនកើតឡើង រូបាយតនៈ របស់សត្វនោះ នឹងមិនកើតឡើងទេឬ ។ អើ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងមិនកើតឡើង ចក្ខាយតនៈ របស់សត្វនោះ នឹងមិនកើតឡើងទេឬ ។ អើ ។

[ ៣៩៤ ] ចក្ខាយតនៈ របស់សត្វណា នឹងមិនកើតឡើង មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ នឹងមិនកើតឡើងទេឬ ។ ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន ចក្ខាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ ចក្ខាយតនៈ របស់ពួកសត្វដែលកើតក្នុងបច្ឆិមភពទាំងនោះ នឹងមិនកើតឡើងផង ធម្មាយតនៈ នឹងមិនកើតឡើងផង ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនកើតឡើង ចក្ខាយតនៈ របស់សត្វនោះ នឹងមិនកើតឡើងទេឬ ។ អើ ។

[ ៣៩៥ ] ឃានាយតនៈ របស់សត្វណា នឹងមិនកើតឡើង រូបាយតនៈ របស់សត្វនោះ នឹងមិនកើតឡើងទេឬ ។ ពួកសត្វណា ចូលទៅកាន់រូបាវចរភព

*ហើយ នឹងបរិនិព្វាន ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ បណ្ដាពួកសត្វដែលកើតក្នុងបច្ឆិមភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង រូបាយតនៈ នឹងមិនកើតឡើងផង ។ មួយយ៉ាងទៀត រូបាយតនៈរបស់សត្វណា នឹងមិនកើតឡើង ឃានាយតនៈ របស់សត្វនោះ នឹងមិនកើតឡើងទេឬ ។ អើ ។*

*[ ៣៩៦ ] ឃានាយតនៈ របស់សត្វណា នឹងមិនកើតឡើង មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ នឹងមិនកើតឡើងទេឬ ។ ពួកសត្វណា ចូលទៅកាន់រូបាវចរភព និងអរូបាវចរភពហើយ នឹងបរិនិព្វាន ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ ឃានាយតនៈ របស់ពួកសត្វដែលកើតក្នុងបច្ឆិម-ភពទាំងនោះ នឹងមិនកើតឡើងផង ធម្មាយតនៈ នឹងមិនកើតឡើងផង ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនកើតឡើង ឃានាយតនៈ របស់សត្វនោះ នឹងមិនកើតឡើងទេឬ ។ អើ ។*

*[ ៣៩៧ ] រូបាយតនៈ របស់សត្វណា នឹងមិនកើតឡើង មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ នឹងមិនកើតឡើងទេឬ ។ ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន រូបាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង តែធម្មាយតនៈរបស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ រូបាយតនៈ របស់ពួកសត្វ ដែលកើតក្នុងបច្ឆិមភពទាំងនោះ នឹងមិនកើត*

ឡើងផង ធម្មាយតនៈ នឹងមិនកើតឡើងផង ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនកើតឡើង រូបាយតនៈ របស់សត្វនោះ នឹងមិនកើតឡើងទេឬ ។ អើ ។

[ ៣៩៨ ] មនាយតនៈ របស់សត្វណា នឹងមិនកើតឡើង ធម្មាយតនៈ របស់សត្វនោះ នឹងមិនកើតឡើងទេឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនកើតឡើង មនាយតនៈ របស់សត្វនោះ នឹងមិនកើតឡើងទេឬ ។ អើ ។

[ ៣៩៩ ] ចក្ខាយតនៈ នឹងមិនកើតឡើង ក្នុងទីណា ។បេ។

[ ៤០០ ] ចក្ខាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា សោតាយតនៈ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ អើ ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ចក្ខាយតនៈរបស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ អើ ។

[ ៤០១ ] ចក្ខាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ អើ ។ មួយយ៉ាងទៀត ឃានាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ ឃានាយតនៈ របស់សត្វជារូបាវចរទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងបញ្ចវោការភព និងពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម

ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ចក្ខាយតនៈ នឹងមិនកើតឡើងផង ក្នុងទីនោះ ។

[ ៤០២ ] ចក្ខាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា រូបាយតនៈ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ ចក្ខាយតនៈ របស់អសញ្ញសត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែរូបាយតនៈរបស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងបញ្ចវោការភព និងពួកអរូបព្រហ្ម ចក្ខាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង រូបាយតនៈ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ អើ ។

[ ៤០៣ ] ចក្ខាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា មនាយតនៈ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ ចក្ខាយតនៈ របស់អរូបព្រហ្មទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ចក្ខាយតនៈ របស់ពួកសត្វដែលកើតក្នុងបច្ឆិមភព និងរបស់អសញ្ញសត្វទាំងនោះ នឹងមិនកើតឡើងផង មនាយតនៈ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ អើ ។

[ ៤០៤ ] ចក្ខាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា

ធម្មាយតនៈ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ ចក្ខាយតនៈ របស់ពួកអសញ្ញសត្វ និងអរូបព្រហ្មទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ចក្ខាយតនៈ របស់ពួកសត្វ ដែលកើតក្នុងបច្ឆិមភពទាំងនោះ នឹងមិនកើតឡើងផង ធម្មាយតនៈ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ អើ ។

[ ៤០៥ ] ឃានាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា រូបាយតនៈ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ ឃានាយតនៈ របស់សត្វជារូបាវចរទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងបញ្ចវោការភព និងពួកអរូបព្រហ្ម ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង រូបាយតនៈ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ឃានាយតនៈរបស់សត្វនោះ នឹងមិនកើតឡើងក្នុងទីនោះទេឬ ។ អើ ។

[ ៤០៦ ] ឃានាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា មនាយតនៈរបស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ ឃានាយតនៈ របស់ពួកសត្វជារូបាវចរ និងអរូបាវចរទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទី

នោះទេ ឃានាយតនៈ របស់ពួកសត្វដែលកើតក្នុងបច្ចិមភព និងអសញ្ញសត្វទាំងនោះ នឹងមិនកើតឡើងផង មនាយតនៈ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ អើ ។

[ ៤០៧ ] ឃានាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ធម្មាយតនៈរបស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ ឃានាយតនៈ របស់ពួកសត្វជារូបាវចរ និងអរូបាវចរទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ឃានាយតនៈ របស់ពួកសត្វដែលកើតក្នុងបច្ចិមភពទាំងនោះ នឹងមិនកើតឡើងផង ធម្មាយតនៈ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈរបស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ អើ ។

[ ៤០៨ ] រូបាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា មនាយតនៈ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ រូបាយតនៈ របស់អរូបព្រហ្មទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ រូបាយតនៈ របស់ពួកសត្វដែលកើតក្នុងបច្ចិមភពទាំងនោះ នឹងមិនកើតឡើងផង មនាយតនៈ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា រូបាយតនៈ របស់សត្វនោះ នឹងមិនកើត

ឡើងក្នុងទីនោះទេឬ ។ មនាយតនៈ របស់អសញ្ញសត្វទាំងនោះ នឹងមិនកើតឡើងក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងក្នុងទីនោះទេ មនាយតនៈ របស់ពួកសត្វ ដែលកើតក្នុងបច្ឆិមភពទាំងនោះ នឹងមិនកើតឡើងផង រូបាយតនៈ នឹងមិនកើតឡើងផង ក្នុងទីនោះ ។

[ ៤០៩ ] រូបាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ រូបាយតនៈ របស់អរូបព្រហ្មទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ រូបាយតនៈ របស់ពួកសត្វដែលកើតក្នុងបច្ឆិមភពទាំងនោះ នឹងមិនកើតឡើងផង ធម្មាយតនៈ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា រូបាយតនៈ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ អើ ។

[ ៤១០ ] មនាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ មនាយតនៈ របស់អសញ្ញសត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែធម្មាយតនៈរបស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ មនាយតនៈ របស់ពួកសត្វទាំងនោះ ដែលកើតក្នុងបច្ឆិមភព នឹងមិនកើតឡើងផង ធម្មាយតនៈ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា មនាយតនៈ របស់សត្វនោះ នឹងមិនកើត

ឡើង ក្នុងទីនោះទេឬ ។ អើ ។

[ ៤១១ ] ចក្ខាយតនៈ របស់សត្វណា កើតឡើង សោតាយតនៈរបស់សត្វនោះ កើតឡើងហើយដែរឬ ។ អើ ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា កើតឡើងហើយ ចក្ខាយតនៈ របស់សត្វនោះ កើតឡើងដែរ ឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចក្ខុ កាលច្យុត កាលចាប់បដិសន្ធិ សោតាយតនៈ របស់សត្វទាំងនោះ កើតឡើងហើយ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ សោតាយតនៈ របស់សត្វទាំងនោះ កើតឡើងហើយផង ចក្ខាយតនៈ កើតឡើងផង ។

[ ៤១២ ] ចក្ខាយតនៈ របស់សត្វណា កើតឡើង ឃានាយតនៈ ។បេ។ រូបាយតនៈ មនាយតនៈ ធម្មាយតនៈរបស់សត្វនោះ កើតឡើងហើយដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈរបស់សត្វណា កើតឡើងហើយ ចក្ខាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វទាំងអស់ដែលមិនមានចក្ខុ កាល ច្យុត កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ កើតឡើងហើយ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វដែលប្រកប ដោយចក្ខុ កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ កើតឡើង ហើយផង ចក្ខាយតនៈ កើតឡើងផង ។

[ ៤១៣ ] ឃានាយតនៈ របស់សត្វណា កើតឡើង រូបាយតនៈ ។បេ។ មនាយតនៈ ធម្មាយតនៈ របស់សត្វនោះ កើតឡើងហើយដែរឬ ។ អើ ។

មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា កើតឡើងហើយ ឃានាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានឃានៈ កាលច្យុត កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ កើតឡើងហើយ តែឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វដែលប្រកបដោយឃានៈ កាលចាប់បដិសន្ធិ ធម្មាយតនៈរបស់សត្វទាំងនោះ កើតឡើងហើយផង ឃានាយតនៈ កើតឡើងផង ។

[ ៤១៤ ] រូបាយតនៈ របស់សត្វណា កើតឡើង មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ កើតឡើងហើយដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា កើតឡើងហើយ រូបាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានរូប កាលច្យុត កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ កើតឡើងហើយ តែរូបាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វដែលប្រកបដោយរូប កាលចាប់បដិសន្ធិ ធម្មាយតនៈរបស់សត្វទាំងនោះ កើតឡើងហើយផង រូបាយតនៈ កើតឡើងផង ។

[ ៤១៥ ] មនាយតនៈ របស់សត្វណា កើតឡើង ធម្មាយតនៈ របស់សត្វនោះ កើតឡើងហើយដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា កើតឡើងហើយ មនាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វដែលមិនមានចិត្ត កាលច្យុត កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ កើតឡើងហើយ តែមនាយតនៈ របស់សត្វទាំងនោះ មិនកើត

ឡើងទេ ពួកសត្វដែលប្រកបដោយចិត្ត កាលចាប់បដិសន្ធិ ធម្មាយតនៈរបស់សត្វទាំងនោះ កើតឡើងហើយផង មនាយតនៈ កើតឡើងផង ។

[ ៤១៦ ] ចក្ខាយតនៈ កើតឡើង ក្នុងទីណា ។បេ។

[ ៤១៧ ] ចក្ខាយតនៈ របស់សត្វណា កើតឡើង ក្នុងទីណា សោតាយតនៈរបស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ ពួកសុទ្ធាវាសសត្វ កាលចាប់បដិសន្ធិ ចក្ខាយតនៈ របស់សត្វទាំងនោះ កើតឡើង ក្នុងទីនោះ តែសោតាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ ចក្ខាយតនៈរបស់សត្វទាំងនោះ កើតឡើងផង សោតាយតនៈ កើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលច្យុតចាកបញ្ចវោការភព កាលចូលទៅកាន់កាមាវចរភព សោតាយតនៈ របស់សត្វទាំងនោះ កើតឡើងហើយ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ សោតាយតនៈ របស់សត្វទាំងនោះកើតឡើងហើយផង ចក្ខាយតនៈ កើតឡើងផង ក្នុងទីនោះ ។

[ ៤១៨ ] ចក្ខាយតនៈ របស់សត្វណា កើតឡើង ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ ពួកសត្វកាលចូលទៅកាន់រូបាវចរភព ចក្ខាយតនៈ របស់សត្វទាំងនោះ កើតឡើង ក្នុងទី

នោះ តែឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលចូលទៅកាន់កាមាវចរភព ចក្ខាយតនៈ របស់សត្វទាំងនោះ កើតឡើងផង ឃានាយតនៈ កើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ឃានាយតនៈរបស់សត្វណា កើតឡើងហើយ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព ឃានាយតនៈរបស់សត្វទាំងនោះ កើតឡើងហើយ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលចូលទៅកាន់កាមាវចរភព ឃានាយតនៈរបស់សត្វទាំងនោះ កើតឡើងហើយផង ចក្ខាយតនៈ កើតឡើងផង ក្នុងទីនោះ ។

[ ៤១៩ ] ចក្ខាយតនៈ របស់សត្វណា កើតឡើង ក្នុងទីណា រូបាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ ពួកសត្វកាលចូលទៅកាន់សុទ្ធាវាស ចក្ខាយតនៈ របស់សត្វទាំងនោះ កើតឡើង ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ ចក្ខាយតនៈ របស់សត្វទាំងនោះ កើតឡើងផង រូបាយតនៈ កើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត រូបាយតនៈរបស់សត្វណា កើតឡើងហើយ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលច្យុតចាកបញ្ចវោការភព កាលចូលទៅកាន់កាមាវចរភព និងពួកអសញ្ញសត្វ

រូបាយតនៈ របស់សត្វទាំងនោះ កើតឡើងហើយ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ រូបាយតនៈ របស់សត្វទាំងនោះ កើតឡើងហើយផង ចក្ខាយតនៈ កើតឡើងផង ក្នុងទីនោះ ។

[ ៤២០ ] ចក្ខាយតនៈ របស់សត្វណា កើតឡើង ក្នុងទីណា មនាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ ពួកសត្វកាលចូលទៅកាន់សុទ្ធាវាស ចក្ខាយតនៈ របស់សត្វទាំងនោះ កើតឡើង ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ ចក្ខាយតនៈ របស់សត្វទាំងនោះ កើតឡើងផង មនាយតនៈ កើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលច្យុតចាកបញ្ចវោការភព កាលចូលទៅកាន់កាមាវចរភព និងពួកអរូបព្រហ្ម មនាយតនៈ របស់សត្វទាំងនោះ កើតឡើងហើយ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ មនាយតនៈ របស់សត្វទាំងនោះ កើតឡើងហើយផង ចក្ខាយតនៈ កើតឡើងផង ក្នុងទីនោះ ។

[ ៤២១ ] ចក្ខាយតនៈ របស់សត្វណា កើតឡើង ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ ពួកសត្វកាលចូលទៅ

កាន់សុទ្ធាវាស ចក្ខាយតនៈ របស់សត្វទាំងនោះ កើតឡើង ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ ចក្ខាយតនៈ របស់សត្វទាំងនោះ កើតឡើងផង ធម្មាយតនៈ កើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលច្យុត កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ កើតឡើងហើយ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ កើតឡើងហើយផង ចក្ខាយតនៈ កើតឡើងផង ក្នុងទីនោះ ។

[ ៤២២ ] ឃានាយតនៈ របស់សត្វណា កើតឡើង ក្នុងទីណា រូបាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វដែលមិនមានឃានៈ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព និងពួកសត្វជារូបាវចរ រូបាយតនៈ របស់សត្វទាំងនោះ កើតឡើងហើយ ក្នុងទីនោះ តែឃានាយតនៈរបស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយឃានៈ កាលចាប់បដិសន្ធិ កើតឡើងហើយផង

យានាយតនៈ កើតឡើងផង ក្នុងទីនោះ ។

[ ៤២៣ ] យានាយតនៈ របស់សត្វណា កើតឡើង ក្នុងទីណា មនាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា យានាយតនៈរបស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វដែលមិនមានយានៈ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព និងពួកសត្វជារូបាវចរ និងជាអរូបាវចរ មនាយតនៈ របស់សត្វទាំងនោះ កើតឡើងហើយ ក្នុងទីនោះ តែយានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយយានៈ កាលចាប់បដិសន្ធិ មនាយតនៈ របស់សត្វទាំងនោះ កើតឡើងហើយផង យានាយតនៈ កើតឡើងផង ក្នុងទីនោះ ។

[ ៤២៤ ] យានាយតនៈ របស់សត្វណា កើតឡើង ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈរបស់សត្វណា កើតឡើងហើយ ក្នុងទីណា យានាយតនៈ របស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វទាំងអស់ដែលមិនមានយានៈ កាលច្យុត កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ កើតឡើងហើយ ក្នុងទីនោះ តែយានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយយានៈ កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ កើតឡើងហើយផង យានាយតនៈ កើតឡើងផង ក្នុង

ទីនោះ ។

[ ៤២៥ ] រូបាយតនៈរបស់សត្វណា កើតឡើង ក្នុងទីណា មនាយតនៈរបស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស កាលចូលទៅកាន់អសញ្ញសត្វ រូបាយតនៈ របស់សត្វទាំងនោះ កើតឡើង ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសត្វក្រៅនេះ កាលចូលទៅកាន់បញ្ចវោការភព រូបាយតនៈ របស់សត្វទាំងនោះ កើតឡើងផង មនាយតនៈ កើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលច្យុតចាកបញ្ចវោការភព និងពួកអរូបព្រហ្ម មនាយតនៈរបស់សត្វទាំងនោះ កើតឡើងហើយ ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលចូលទៅកាន់បញ្ចវោការ-ភព មនាយតនៈ របស់សត្វទាំងនោះ កើតឡើងហើយផង រូបាយតនៈ កើតឡើងផង ក្នុងទីនោះ ។

[ ៤២៦ ] រូបាយតនៈ របស់សត្វណា កើតឡើង ក្នុងទីណា ធម្មា-យតនៈរបស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស រូបាយតនៈ របស់សត្វទាំងនោះ កើតឡើង ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយរូប កាលចាប់បដិសន្ធិ រូបាយតនៈ របស់

សត្វទាំងនោះ កើតឡើងផង ធម្មាយតនៈ កើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានរូប កាលច្យុត កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ កើតឡើងហើយ ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយរូប កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ កើតឡើងហើយផង រូបាយតនៈ កើតឡើងផង ក្នុងទីនោះ ។

[ ៤២៧ ] មនាយតនៈរបស់សត្វណា កើតឡើង ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស មនាយតនៈ របស់សត្វទាំងនោះ កើតឡើង ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយចិត្ត កាលចាប់បដិសន្ធិ មនាយតនៈ របស់សត្វទាំងនោះ កើតឡើងផង ធម្មាយតនៈ កើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា មនាយតនៈរបស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចិត្ត កាលច្យុត កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ កើតឡើងហើយ ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយចិត្ត កាលចាប់បដិសន្ធិ ធម្មាយតនៈ

របស់សត្វទាំងនោះ កើតឡើងហើយផង មនាយតនៈ កើតឡើងផង ក្នុងទីនោះ ។

[ ៤២៨ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើង សោតាយតនៈ របស់សត្វនោះ មិនកើតឡើងហើយឬ ។ កើតឡើងហើយ ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា មិនកើតឡើងហើយ ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើងឬ ។ មិនមានទេ ។

[ ៤២៩ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើង ឃានាយតនៈ ។បេ។ រូបាយតនៈ មនាយតនៈ ធម្មាយតនៈ របស់សត្វនោះ មិនកើតឡើងហើយឬ ។ កើតឡើងហើយ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា មិនកើតឡើងហើយ ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើងឬ ។ មិនមានទេ ។

[ ៤៣០ ] ឃានាយតនៈ ។បេ។ រូបាយតនៈ មនាយតនៈរបស់សត្វណា មិនកើតឡើង ធម្មាយតនៈ របស់សត្វនោះ មិនកើតឡើងហើយឬ ។ កើតឡើងហើយ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា មិនកើតឡើងហើយ មនាយតនៈ របស់សត្វនោះ មិនកើតឡើងឬ ។ មិនមានទេ ។

[ ៤៣១ ] ចក្ខាយតនៈ មិនកើតឡើង ក្នុងទីណា ។បេ។

[ ៤៣២ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើង ក្នុងទីណា សោតាយតនៈ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលច្យុតចាកបញ្ចវោការភព កាលចូលទៅកាន់កាមាវចរ-

ភព ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ តែសោតា-យតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងសុទ្ធាវាស ពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង សោតាយតនៈ មិនកើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស សោតាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលបរិ-និព្វានក្នុងសុទ្ធាវាស ពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម សោតាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង ចក្ខាយតនៈ មិនកើតឡើងផង ក្នុងទីនោះ ។

[ ៤៣៣ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើង ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរ-ភព ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ តែឃានា-យតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសត្វ កាលច្យុតចាករូបាវចរភព ពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម ចក្ខា-យតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង ឃានាយតនៈ មិនកើតឡើង

ហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ឃានាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ ពួកសត្វ កាលចូលទៅកាន់រូបាវចរភព ឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលច្យុតចាករូបាវចរភព ពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម ឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយផង ចក្ខាយតនៈ មិនកើតឡើងផង ក្នុងទីនោះ ។

[ ៤៣៤ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើង ក្នុងទីណា រូបាយតនៈ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលច្យុតចាកបញ្ចវោការភព កាលចូលទៅកាន់កាមាវចរភព និងពួកអសញ្ញសត្វ ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងសុទ្ធាវាស និងពួកអរូបព្រហ្ម ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង រូបាយតនៈ មិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស រូបាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វកាលបរិនិព្វានក្នុងសុទ្ធាវាស និងពួកអរូបព្រហ្ម រូបាយតនៈ

របស់សត្វទាំងនោះ មិនកើតឡើងហើយផង ចក្ខាយតនៈ មិនកើតឡើងផង ក្នុងទីនោះ ។

[ ៤៣៥ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើង ក្នុងទីណា មនាយតនៈ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលច្យុតចាកបញ្ចវោការភព កាលចូលទៅកាន់កាមាវចរភព និងពួកអរូបព្រហ្ម ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន ក្នុងសុទ្ធាវាស និងពួកអសញ្ញសត្វ ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង មនាយតនៈ មិនកើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា ចក្ខាយតនៈរបស់សត្វណា មិនកើតឡើង ក្នុងទីនោះឬ ។ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស មនាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែចក្ខាយតនៈរបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងសុទ្ធាវាស និងពួកអសញ្ញសត្វ មនាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយផង ចក្ខាយតនៈ មិនកើតឡើងផង ក្នុងទីនោះ ។

[ ៤៣៦ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើង ក្នុងទីណា ធម្មាយតនៈរបស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ ពួកសត្វទាំងអស់ដែលមិនមានចក្ខុ កាលច្យុត កាលចាប់បដិសន្ធិ ចក្ខាយតនៈ របស់សត្វទាំង

នោះ មិនកើតឡើង ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងសុទ្ធាវាស ចក្ខាយតនៈរបស់សត្វទាំងនោះ មិនកើតឡើងផង ធម្មាយតនៈ មិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះទេឬ ។ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស ធម្មាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងសុទ្ធាវាស ធម្មាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយផង ចក្ខាយតនៈ មិនកើតឡើងផង ក្នុងទីនោះ ។

[ ៤៣៧ ] ឃានាយតនៈ របស់សត្វណា មិនកើតឡើង ក្នុងទីណា រូបាយតនៈ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ ពួកសត្វដែលមិនមានឃានៈ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព និងពួកសត្វជារូបាវចរ ឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ តែរូបាយតនៈរបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ ឃានាយតនៈរបស់ពួកសុទ្ធាវាសសត្វ និងពួកអរូបព្រហ្មទាំងនោះ មិនកើតឡើងផង រូបាយតនៈ មិនកើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះទេឬ ។ អើ ។

[ ៤៣៨ ] ឃានាយតនៈ របស់សត្វណា មិនកើតឡើង ក្នុងទីណា មនាយតនៈ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ ពួកសត្វដែលមិនមានឃានៈ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព និងពួកសត្វជារូបាវចរ និងជាអរូបាវចរ ឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ ឃានាយតនៈ របស់ពួកសុទ្ធាវាសសត្វ និងពួកអសញ្ញសត្វទាំងនោះ មិនកើតឡើងផង មនាយតនៈ មិនកើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះទេឬ ។ អើ ។

[ ៤៣៩ ] ឃានាយតនៈ របស់សត្វណា មិនកើតឡើង ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ ពួកសត្វទាំងអស់ ដែលមិនមានឃានៈ កាលច្យុត កាលចាប់បដិសន្ធិ ឃានាយតនៈរបស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ ឃានាយតនៈរបស់សុទ្ធាវាសសត្វទាំងនោះ មិនកើតឡើងផង ធម្មាយតនៈ មិនកើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះទេឬ ។ អើ ។

[ ៤៤០ ] រូបាយតនៈ របស់សត្វណា មិនកើតឡើង ក្នុងទីណា មនា-

យតនៈ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ ពួកសត្វកាលច្យុតចាកបញ្ចវោការភព និងពួកអរូបព្រហ្ម រូបាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន ក្នុងសុទ្ធាវាស កាលច្យុតចាកអសញ្ញសត្វ រូបាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង មនាយតនៈ មិនកើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះទេឬ ។ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស កាលចូលទៅកាន់អសញ្ញសត្វ មនាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងសុទ្ធាវាស កាលច្យុតចាកអសញ្ញសត្វ មនាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយផង រូបាយតនៈ មិនកើតឡើងផង ក្នុងទីនោះ ។

[ ៤៤១ ] រូបាយតនៈ របស់សត្វណា មិនកើតឡើង ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ ពួកសត្វទាំងអស់ ដែលមិនមានរូប កាលច្យុត កាលចាប់បដិសន្ធិ រូបាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងសុទ្ធាវាស រូបាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង ធម្មាយតនៈ មិនកើតឡើង

ហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះទេឬ ។ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស ធម្មាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែរូបាយតនៈរបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងសុទ្ធាវាស ធម្មាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយផង រូបាយតនៈ មិនកើតឡើងផង ក្នុងទីនោះ ។

[ ៤៤២ ] មនាយតនៈ របស់សត្វណា មិនកើតឡើង ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ ពួកសត្វដែលមិនមានចិត្តទាំងអស់ កាលច្យុត កាលចាប់បដិសន្ធិ មនាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងសុទ្ធាវាស មនាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង ធម្មាយតនៈ មិនកើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា មនាយតនៈ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះទេឬ ។ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស ធម្មាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងសុទ្ធាវាស ធម្មាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយផង មនា-

យតនៈ មិនកើតឡើងផង ក្នុងទីនោះ ។

[ ៤៤៣ ] ចក្ខាយតនៈ របស់សត្វណា កើតឡើង សោតាយតនៈ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ បណ្ដាពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន ពួកសត្វនោះ កាលចាប់បដិសន្ធិ ចក្ខាយតនៈ របស់សត្វទាំងនោះ កើតឡើង តែសោតាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ ចក្ខាយតនៈ របស់សត្វទាំងនោះ កើតឡើងផង សោតាយតនៈ នឹងកើតឡើងផង ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា នឹងកើតឡើង ចក្ខាយតនៈរបស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចក្ខុ កាលច្យុត កាលចាប់បដិសន្ធិ សោតាយតនៈ របស់សត្វទាំងនោះ នឹងកើតឡើង តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ សោតាយតនៈ របស់សត្វទាំងនោះ នឹងកើតឡើងផង ចក្ខាយតនៈ កើតឡើងផង ។

[ ៤៤៤ ] ចក្ខាយតនៈ របស់សត្វណា កើតឡើង ឃានាយតនៈរបស់សត្វនោះ នឹងកើតឡើងដែរឬ ។ បណ្ដាពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព សត្វទាំងឡាយណា ចូលទៅកាន់រូបាវចរភព និងអរូបាវចរភពហើយ នឹងបរិនិព្វាន ពួកសត្វនោះ កាលចាប់បដិសន្ធិ ចក្ខាយតនៈ របស់សត្វទាំងនោះ កើតឡើង តែឃានាយតនៈ របស់សត្វទាំងនោះ

នឹងមិនកើតឡើងទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ ចក្ខាយតនៈ របស់សត្វទាំងនោះ កើតឡើងផង ឃានាយតនៈ នឹងកើតឡើងផង ។ មួយយ៉ាងទៀត ឃានាយតនៈ របស់សត្វណា នឹងកើតឡើង ចក្ខាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចក្ខុ កាលច្យុត កាលចាប់បដិសន្ធិ ឃានាយតនៈ របស់សត្វទាំងនោះ នឹងកើតឡើង តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ ឃានាយតនៈ របស់សត្វទាំងនោះ នឹងកើតឡើងផង ចក្ខាយតនៈ កើតឡើងផង ។

[ ៤៤៥ ] ចក្ខាយតនៈ របស់សត្វណា កើតឡើង រូបាយតនៈ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ បណ្ដាពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព សត្វទាំងឡាយណា ចូលទៅកាន់អរូបភពហើយនឹងបរិនិព្វាន ពួកសត្វនោះ កាលចាប់បដិសន្ធិ ចក្ខាយតនៈ របស់សត្វទាំងនោះ កើតឡើង តែចក្ខាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ ចក្ខាយតនៈ របស់សត្វទាំងនោះ កើតឡើងផង រូបាយតនៈ នឹងកើតឡើងផង ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងកើតឡើង ចក្ខាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចក្ខុ កាលច្យុត កាលចាប់បដិសន្ធិ រូបាយតនៈរបស់សត្វទាំងនោះ នឹងកើតឡើង តែចក្ខាយតនៈរបស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលចាប់

បដិសន្ធិ រូបាយតនៈ របស់សត្វទាំងនោះ នឹងកើតឡើងផង ចក្ខាយតនៈកើតឡើងផង ។

[ ៤៤៦ ] ចក្ខាយតនៈ របស់សត្វណា កើតឡើង មនាយតនៈ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព ចក្ខាយតនៈរបស់សត្វទាំងនោះ កើតឡើង តែមនាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ ចក្ខាយតនៈ របស់សត្វទាំងនោះ កើតឡើងផង មនាយតនៈ នឹងកើតឡើងផង ។ មួយយ៉ាងទៀត មនាយតនៈរបស់សត្វណា នឹងកើតឡើង ចក្ខាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចក្ខុ កាលច្យុត កាលចាប់បដិសន្ធិ មនាយតនៈរបស់សត្វទាំងនោះ នឹងកើតឡើង តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ មនាយតនៈរបស់សត្វទាំងនោះ នឹងកើតឡើងផង ចក្ខាយតនៈ កើតឡើងផង ។

[ ៤៤៧ ] ចក្ខាយតនៈ របស់សត្វណា កើតឡើង ធម្មាយតនៈ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ បណ្តាពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព ចក្ខាយតនៈ របស់សត្វទាំងនោះ កើតឡើង តែធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ ចក្ខាយតនៈ របស់សត្វទាំងនោះ កើតឡើងផង ធម្មាយតនៈ នឹងកើតឡើងផង ។ មួយយ៉ាងទៀត ធម្មាយតនៈរបស់

សត្វណា នឹងកើតឡើង ចក្ខាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចក្ខុ កាលច្យុត កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ នឹងកើតឡើង តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ នឹងកើតឡើងផង ចក្ខាយតនៈ កើតឡើងផង ។

[ ៤៤៨ ] ឃានាយតនៈ របស់សត្វណា កើតឡើង រូបាយតនៈរបស់សត្វនោះ នឹងកើតឡើងដែរឬ ។ បណ្តាពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព សត្វទាំងឡាយណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលចាប់បដិសន្ធិ ឃានាយតនៈ របស់សត្វទាំងនោះ កើតឡើង តែរូបាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយឃានៈ កាលចាប់បដិសន្ធិ ឃានាយតនៈរបស់សត្វទាំងនោះ កើតឡើងផង រូបាយតនៈ នឹងកើតឡើងផង ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងកើតឡើង ឃានាយតនៈរបស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានឃានៈ កាលច្យុត កាលចាប់បដិសន្ធិ រូបាយតនៈរបស់សត្វទាំងនោះ នឹងកើតឡើង តែឃានាយតនៈរបស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វដែលប្រកបដោយឃានៈ កាលចាប់បដិសន្ធិ រូបាយតនៈ របស់សត្វទាំងនោះ នឹងកើតឡើងផង ឃានាយតនៈ កើតឡើងផង ។

[ ៤៤៩ ] ឃានាយតនៈ របស់សត្វណា កើតឡើង មនាយតនៈ របស់

សត្វនោះ នឹងកើតឡើងដែរឬ ។ បណ្ដាពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព ឃានាយតនៈ របស់សត្វទាំងនោះ កើតឡើង តែមនាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយឃានៈ កាលចាប់បដិសន្ធិ ឃានាយតនៈ របស់សត្វទាំងនោះ កើតឡើងផង មនាយតនៈ នឹងកើតឡើងផង ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា នឹងកើតឡើង ឃានាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានឃានៈ កាលច្យុត កាលចាប់បដិសន្ធិ មនាយតនៈ របស់សត្វទាំងនោះ នឹងកើតឡើង តែឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វដែលប្រកបដោយឃានៈ កាលចាប់បដិសន្ធិ មនាយតនៈ របស់សត្វទាំងនោះ នឹងកើតឡើងផង ឃានាយតនៈ កើតឡើងផង ។

[ ៤៥០ ] ឃានាយតនៈ របស់សត្វណា កើតឡើង ធម្មាយតនៈរបស់សត្វនោះ នឹងកើតឡើងដែរឬ ។ បណ្ដាពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព ឃានាយតនៈ របស់សត្វទាំងនោះ កើតឡើង តែធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយឃានៈ កាលចាប់បដិសន្ធិ ឃានាយតនៈរបស់សត្វទាំងនោះ កើតឡើងផង ធម្មាយតនៈនឹងកើតឡើងផង ។ មួយយ៉ាងទៀត ធម្មាយតនៈរបស់សត្វណា នឹងកើតឡើង ឃានាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានឃានៈ កាលច្យុត កាលចាប់បដិសន្ធិ ធម្មា-

យតនៈ របស់សត្វទាំងនោះ នឹងកើតឡើង តែឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងទេ បណ្តាពួកសត្វដែលប្រកបដោយឃានៈ កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ នឹងកើតឡើងផង ឃានាយតនៈ កើតឡើងផង ។

[ ៤៥១ ] រូបាយតនៈ របស់សត្វណា កើតឡើង មនាយតនៈ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ បណ្តាពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព រូបាយតនៈ របស់សត្វទាំងនោះ កើតឡើង តែមនាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយរូប កាលចាប់បដិសន្ធិ រូបាយតនៈ របស់សត្វទាំងនោះ កើតឡើងផង មនាយតនៈ នឹងកើតឡើងផង ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា នឹងកើតឡើង រូបាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានរូប កាលច្យុត កាលចាប់បដិសន្ធិ មនាយតនៈ របស់សត្វទាំងនោះ នឹងកើតឡើង តែរូបាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វដែលប្រកបដោយរូប កាលចាប់បដិសន្ធិ មនាយតនៈរបស់សត្វទាំងនោះ នឹងកើតឡើងផង រូបាយតនៈ កើតឡើងផង ។

[ ៤៥២ ] រូបាយតនៈ របស់សត្វណា កើតឡើង ធម្មាយតនៈ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ បណ្តាពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព រូបាយតនៈ របស់សត្វទាំងនោះ កើតឡើង តែធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ ពួកសត្វក្រៅនេះ

ដែលប្រកបដោយរូប កាលចាប់បដិសន្ធិ រូបាយតនៈ របស់សត្វទាំងនោះ កើតឡើងផង ធម្មាយតនៈ នឹងកើតឡើងផង ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងកើតឡើង រូបាយតនៈរបស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វទាំងអស់ដែលមិនមានរូប កាលច្យុត កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ នឹងកើតឡើង តែរូបាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វដែលប្រកបដោយរូប កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ នឹងកើតឡើងផង រូបាយតនៈ កើតឡើងផង ។

[ ៤៥៣ ] មនាយតនៈ របស់សត្វណា កើតឡើង ធម្មាយតនៈ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ បណ្ដាពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ មនាយតនៈរបស់សត្វទាំងនោះ កើតឡើង តែធម្មាយតនៈរបស់សត្វទាំងនោះ នឹងមិនកើតឡើងទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយចិត្ត កាលចាប់បដិសន្ធិ មនាយតនៈរបស់សត្វទាំងនោះ កើតឡើងផង ធម្មាយតនៈ នឹងកើតឡើងផង ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងកើតឡើង មនាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វទាំងអស់ដែលមិនមានចិត្ត កាលច្យុត កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ នឹងកើតឡើង តែមនាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វដែលប្រកបដោយចិត្ត កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ នឹងកើតឡើងផង មនាយតនៈ កើតឡើងផង ។

[ ៤៥៤ ] ចក្ខាយតនៈ កើតឡើង ក្នុងទីណា ។បេ។

[ ៤៥៥ ] ចក្ខាយតនៈ របស់សត្វណា កើតឡើង ក្នុងទីណា សោតាយតនៈរបស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ បណ្ដាពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព ចក្ខាយតនៈ របស់សត្វទាំងនោះ កើតឡើង ក្នុងទីនោះ តែសោតាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ ចក្ខាយតនៈ របស់សត្វទាំងនោះ កើតឡើងផង សោតាយតនៈនឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលច្យុតចាកបញ្ចវោការភព កាលចូលទៅកាន់កាមាវចរភព សោតាយតនៈ របស់សត្វទាំងនោះ នឹងកើតឡើង ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ សោតាយតនៈរបស់សត្វទាំងនោះ នឹងកើតឡើងផង ចក្ខាយតនៈ កើតឡើងផង ក្នុងទីនោះ ។

[ ៤៥៦ ] ចក្ខាយតនៈ របស់សត្វណា កើតឡើង ក្នុងទីណា ឃានាយតនៈរបស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ បណ្ដាពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព កាលចូលទៅកាន់រូបាវចរភព ចក្ខាយតនៈ របស់សត្វទាំងនោះ កើតឡើង ក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយចក្ខុ កាលចូលទៅកាន់កាមាវចរភព ចក្ខាយតនៈ របស់

សត្វទាំងនោះ កើតឡើងផង ឃានាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ឃានាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព ឃានាយតនៈ របស់សត្វទាំងនោះ នឹងកើតឡើង ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលចូលទៅកាន់កាមាវចរភព ឃានាយតនៈ របស់សត្វទាំងនោះ នឹងកើតឡើងផង ចក្ខាយតនៈ កើតឡើងផង ក្នុងទីនោះ ។

[ ៤៥៧ ] ចក្ខាយតនៈ របស់សត្វណា កើតឡើង ក្នុងទីណា រូបាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ បណ្តាពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព ចក្ខាយតនៈ របស់សត្វទាំងនោះ កើតឡើង ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ ចក្ខាយតនៈ របស់សត្វទាំងនោះ កើតឡើងផង រូបាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងកើតឡើងក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលច្យុតចាកបញ្ចវោការភព និងពួកអសញ្ញសត្វ កាលចូលទៅកាន់កាមាវចរភព របស់សត្វទាំងនោះ នឹងកើតឡើង ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែល

ប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ រូបាយតនៈ របស់សត្វទាំងនោះ នឹងកើតឡើងផង ចក្ខាយតនៈ កើតឡើងផង ក្នុងទីនោះ ។

[ ៤៥៨ ] ចក្ខាយតនៈរបស់សត្វណា កើតឡើង ក្នុងទីណា មនាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព ចក្ខាយតនៈ របស់សត្វទាំងនោះ កើតឡើង ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ ចក្ខាយតនៈ របស់សត្វទាំងនោះ កើតឡើងផង មនាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលច្យុតចាកបញ្ចវោការភព កាលចូលទៅកាន់កាមាវចរភព និងពួកអរូបព្រហ្ម មនាយតនៈ របស់សត្វទាំងនោះ នឹងកើតឡើង ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ មនាយតនៈ របស់សត្វទាំងនោះ នឹងកើតឡើងផង ចក្ខាយតនៈ កើតឡើងផង ក្នុងទីនោះ ។

[ ៤៥៩ ] ចក្ខាយតនៈ របស់សត្វណា កើតឡើង ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព ចក្ខាយតនៈ របស់សត្វទាំងនោះ កើតឡើង ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង

ក្នុងទីនោះទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ ចក្ខាយតនៈ របស់សត្វទាំងនោះ កើតឡើងផង ធម្មាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វទាំងអស់ដែលមិនមានចក្ខុ កាលច្យុត កាលចាប់បដិសន្ធិ ធម្មាយតនៈរបស់សត្វទាំងនោះ នឹងកើតឡើង ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ នឹងកើតឡើងផង ចក្ខាយតនៈ កើតឡើងផង ក្នុងទីនោះ ។

[ ៤៦០ ] ឃានាយតនៈ របស់សត្វណា កើតឡើង ក្នុងទីណា រូបាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព ឃានាយតនៈ របស់សត្វទាំងនោះ កើតឡើង ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយឃានៈ កាលចាប់បដិសន្ធិ ឃានាយតនៈ របស់សត្វទាំងនោះ កើតឡើងផង រូបាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វដែលមិនមានឃានៈ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព និងពួករូបាវចរសត្វ រូបាយតនៈ របស់សត្វទាំងនោះ នឹងកើត

ឡើង ក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយឃានៈ កាលចាប់បដិសន្ធិ រូបាយតនៈ របស់សត្វទាំងនោះ នឹងកើតឡើងផង ឃានាយតនៈ កើតឡើងផង ក្នុងទីនោះ ។

[ ៤៦១ ] ឃានាយតនៈរបស់សត្វណា កើតឡើង ក្នុងទីណា មនាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព ឃានាយតនៈ របស់សត្វទាំងនោះ កើតឡើង ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយឃានៈ កាលចាប់បដិសន្ធិ ឃានាយតនៈ របស់សត្វទាំងនោះ កើតឡើងផង មនាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វដែលមិនមានឃានៈ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព និងពួករូបាវចរសត្វ និងពួកអរូបាវចរសត្វ មនាយតនៈ របស់សត្វទាំងនោះ នឹងកើតឡើង ក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយឃានៈ កាលចាប់បដិសន្ធិ មនាយតនៈ របស់សត្វទាំងនោះ នឹងកើតឡើងផង ឃានាយតនៈ កើតឡើងផង ក្នុងទីនោះ ។

[ ៤៦២ ] ឃានាយតនៈរបស់សត្វណា កើតឡើង ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វដែលកើតក្នុង

បច្ឆិមភព កាលចូលទៅកាន់កាមាវចរភព ឃានាយតនៈ របស់សត្វទាំងនោះ កើតឡើង ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយឃានៈ កាលចាប់បដិសន្ធិ ឃានាយតនៈ របស់សត្វទាំងនោះ កើតឡើងផង ធម្មាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វទាំងអស់ដែលមិនមានឃានៈ កាលច្យុត កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយឃានៈ កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ នឹងកើតឡើងផង ឃានាយតនៈ កើតឡើងផង ក្នុងទីនោះ ។

[ ៤៦៣ ] រូបាយតនៈរបស់សត្វណា កើតឡើង ក្នុងទីណា មនាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព កាលចូលទៅកាន់អសញ្ញសត្វ រូបាយតនៈ របស់សត្វទាំងនោះ កើតឡើង ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វក្រៅនេះ កាលចូលទៅកាន់បញ្ចវោការភព រូបាយតនៈ របស់សត្វទាំងនោះ កើតឡើងផង មនាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា រូបាយតនៈ របស់សត្វនោះ កើត

ឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលច្យុតចាកបញ្ចវោការភព និងពួក អរូបព្រហ្ម មនាយតនៈ របស់សត្វទាំងនោះ នឹងកើតឡើង ក្នុងទីនោះ តែរូបាយតនៈរបស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលចូលទៅកាន់បញ្ចវោការភព មនាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង រូបាយតនៈ កើតឡើងផង ក្នុងទីនោះ ។

[ ៤៦៤ ] រូបាយតនៈ របស់សត្វណា កើតឡើង ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព រូបាយតនៈ របស់សត្វទាំងនោះ កើតឡើង ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយរូប កាលចាប់បដិសន្ធិ រូបាយតនៈ របស់សត្វទាំងនោះ កើតឡើងផង ធម្មាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា រូបាយតនៈរបស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានរូប កាលច្យុត កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ នឹងកើតឡើង ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយរូប កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ នឹងកើតឡើងផង រូបាយតនៈ កើតឡើងផង ក្នុងទីនោះ ។

[ ៤៦៥ ] មនាយតនៈ របស់សត្វណា កើតឡើង ក្នុងទីណា ធម្មាយតនៈ

របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វដែលកើតក្នុង បច្ឆិមភព កាលចាប់បដិសន្ធិ មនាយតនៈ របស់សត្វទាំងនោះ កើតឡើងក្នុង ទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយចិត្ត កាលចាប់បដិសន្ធិ មនាយតនៈរបស់ សត្វទាំងនោះ កើតឡើងផង ធម្មាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈរបស់សត្វណា នឹងកើតឡើង ក្នុងទីណា មនា- យតនៈ របស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចិត្ត កាលច្យុត កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំង នោះ នឹងកើតឡើង ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនកើត ឡើង ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយចិត្ត កាលចាប់បដិសន្ធិ ធម្មា- យតនៈ របស់សត្វទាំងនោះ នឹងកើតឡើងផង មនាយតនៈ កើតឡើងផង ក្នុងទីនោះ ។

[ ៤៦៦ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើង សោតាយតនៈ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចក្ខុ កាលច្យុត កាលចាប់បដិសន្ធិ ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង តែសោតាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ បណ្តា ពួកសត្វ កាលបរិនិព្វាន ក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន សត្វ ទាំងនោះ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង

សោតាយតនៈ នឹងមិនកើតឡើងផង ។ មួយយ៉ាងទៀត សោតាយតនៈរបស់សត្វណា នឹងមិនកើតឡើង ចក្ខាយតនៈរបស់សត្វនោះ មិនកើតឡើងទេឬ ។ បណ្ដាពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលចាប់បដិសន្ធិ សោតាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង តែចក្ខាយតនៈរបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ បណ្ដាពួកសត្វ កាលបរិនិព្វាន ក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលច្យុត សោតាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ចក្ខាយតនៈមិនកើតឡើងផង ។

[ ៤៦៧ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើង ឃានាយតនៈរបស់សត្វនោះ នឹងមិនកើតឡើងដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចក្ខុ កាលច្យុត កាលចាប់បដិសន្ធិ ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង តែឃានាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ បណ្ដាពួកសត្វ កាលបរិនិព្វាន ក្នុងបញ្ចវោការភព និងពួកសត្វ ដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ពួកសត្វណា ចូលទៅកាន់រូបាវចរភព និងកាន់អរូបាវចរភពហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលច្យុត ចក្ខាយតនៈរបស់សត្វទាំងនោះ មិនកើតឡើងផង ឃានាយតនៈ នឹងមិនកើតឡើងផង ។ មួយយ៉ាងទៀត ឃានាយតនៈ របស់សត្វណា នឹងមិនកើតឡើង ចក្ខាយតនៈ

របស់សត្វនោះ មិនកើតឡើងទេឬ ។ បណ្ដាពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព ពួកសត្វណា ចូលទៅកាន់រូបាវចរភព និងកាន់អរូបាវចរភពហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលចាប់បដិសន្ធិ ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ បណ្ដាពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ពួកសត្វណា ចូលទៅកាន់រូបាវចរភព និងកាន់អរូបាវចរភពហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលច្យុត ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ចក្ខាយតនៈ មិនកើតឡើងផង ។

[ ៤៦៨ ] ចក្ខាយតនៈរបស់សត្វណា មិនកើតឡើង រូបាយតនៈរបស់សត្វនោះ នឹងមិនកើតឡើងទេឬ ។ ពួកសត្វទាំងអស់ដែលមិនមានចក្ខុ កាលច្យុត កាលចាប់បដិសន្ធិ ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង តែរូបាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ បណ្ដាពួកសត្វ កាលបរិនិព្វាន ក្នុងបញ្ចវោការភព និងពួកសត្វ ដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង រូបាយតនៈ នឹងមិនកើតឡើងផង ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងមិនកើតឡើង ចក្ខាយតនៈរបស់សត្វនោះ មិនកើតឡើងដែរឬ ។ បណ្ដាពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព ពួកសត្វណា ចូលទៅ

កាន់អរូបភពហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលចាប់បដិសន្ធិ រូបា-
យតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង តែចក្ខាយតនៈ របស់សត្វ
ទាំងនោះ មិនមែនជាមិនកើតឡើងទេ បណ្ដាពួកសត្វ កាលបរិនិព្វាន ក្នុង
បញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ពួកសត្វ
ណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលច្យុត
រូបាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ចក្ខាយតនៈ មិនកើត
ឡើងផង ។

[ ៤៦៩ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើង មនាយតនៈរបស់
សត្វនោះ នឹងមិនកើតឡើងដែរឬ ។ ពួកសត្វទាំងអស់ កាលច្យុត កាលចាប់
បដិសន្ធិ ចក្ខាយតនៈរបស់សត្វទាំងនោះ មិនកើតឡើង តែមនាយតនៈរបស់
សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ ពួកសត្វកាលបរិនិព្វាន ក្នុង
បញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ចក្ខាយតនៈ
របស់សត្វទាំងនោះ មិនកើតឡើងផង មនាយតនៈ នឹងមិនកើតឡើងផង ។
មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា នឹងកើតឡើង ចក្ខាយតនៈ របស់
សត្វនោះ មិនកើតឡើងទេឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូល
ទៅកាន់បញ្ចវោការភព មនាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង
តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ពួកសត្វកាល
បរិនិព្វានក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព
មនាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ចក្ខាយតនៈ មិនកើត

ឡើងផង ។

[ ៤៧០ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើង ធម្មាយតនៈ របស់សត្វនោះ នឹងមិនកើតឡើងទេឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចក្ខុ កាលច្យុត កាលចាប់បដិសន្ធិ ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ ពួកសត្វកាលបរិនិព្វាន ក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង ធម្មាយតនៈ នឹងមិនកើតឡើងផង ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនកើតឡើង ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើងទេឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព ធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ពួកសត្វកាលបរិនិព្វាន ក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ចក្ខាយតនៈ មិនកើតឡើងផង ។

[ ៤៧១ ] ឃានាយតនៈ របស់សត្វណា មិនកើតឡើង រូបាយតនៈរបស់សត្វនោះ នឹងមិនកើតឡើងទេឬ ។ ពួកសត្វទាំងអស់ដែលមិនមានឃានៈ កាលច្យុត កាលចាប់បដិសន្ធិ ឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង តែរូបាយតនៈរបស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ បណ្តាពួកសត្វកាលបរិនិព្វាន ក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុង

រូបាវចរភព និងក្នុងអរូបាវចរភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលច្យុត ឃានាយតនៈរបស់សត្វទាំងនោះ មិនកើតឡើងផង រូបាយតនៈ នឹងមិនកើតឡើងផង ។ មួយយ៉ាងទៀត រូបាយតនៈរបស់សត្វណា នឹងមិនកើតឡើង ឃានាយតនៈ របស់សត្វនោះ នឹងមិនកើតឡើងទេឬ ។ បណ្ដាពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលចាប់បដិសន្ធិ រូបាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង តែឃានាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ បណ្ដាពួកសត្វ កាលបរិនិព្វាន ក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងក្នុងអរូបាវចរភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលច្យុត រូបាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង ឃានាយតនៈ នឹងមិនកើតឡើងផង ។

[ ៤៧២ ] ឃានាយតនៈរបស់សត្វណា មិនកើតឡើង មនាយតនៈ ។បេ។ ធម្មាយតនៈរបស់សត្វនោះ នឹងមិនកើតឡើងទេឬ ។ ពួកសត្វទាំងអស់ ដែលមិនមានឃានៈ កាលច្យុត កាលចាប់បដិសន្ធិ ឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ ពួកសត្វកាលបរិនិព្វាន ក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងក្នុងអរូបាវចរភព ឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង ធម្មាយតនៈ នឹងមិនកើតឡើងផង ។ មួយ

យ៉ាងទៀត ធម្មាយតនៈរបស់សត្វណា នឹងមិនកើតឡើង ឃានាយតនៈរបស់សត្វនោះ មិនកើតឡើងទេឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព ធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង តែឃានាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ពួកសត្វកាលបរិនិព្វានក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងក្នុងអរូបាវចរភព ធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ឃានាយតនៈ មិនកើតឡើងផង ។

[ ៤៧៣ ] រូបាយតនៈរបស់សត្វណា មិនកើតឡើង មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ នឹងមិនកើតឡើងទេឬ ។ ពួកសត្វទាំងអស់ដែលមិនមានរូប កាលច្យុត កាលចាប់បដិសន្ធិ រូបាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ ពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព និងពួកសត្វ ដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព រូបាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង ធម្មាយតនៈ នឹងមិនកើតឡើងផង ។ មួយយ៉ាងទៀត ធម្មាយតនៈរបស់សត្វណា នឹងមិនកើតឡើង រូបាយតនៈ របស់សត្វនោះ មិនកើតឡើងទេឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព ធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ពួកសត្វកាលបរិនិព្វាន ក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ធម្មាយតនៈ របស់សត្វទាំងនោះ

នឹងមិនកើតឡើងផង រូបាយតនៈ មិនកើតឡើងផង ។

[ ៤៧៤ ] មនាយតនៈរបស់សត្វណា មិនកើតឡើង ធម្មាយតនៈរបស់សត្វនោះ នឹងមិនកើតឡើងទេឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចិត្ត កាលច្យុត កាលចាប់បដិសន្ធិ មនាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ ពួកសត្វកាលបរិនិព្វាន មនាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង ធម្មាយតនៈ នឹងមិនកើតឡើងផង ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនកើតឡើង មនាយតនៈ របស់សត្វនោះ មិនកើតឡើងទេឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង តែមនាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ពួកសត្វកាលបរិនិព្វាន ធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង មនាយតនៈ មិនកើតឡើងផង ។

[ ៤៧៥ ] ចក្ខាយតនៈ មិនកើតឡើង ក្នុងទីណា ។បេ។

[ ៤៧៦ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើង ក្នុងទីណា សោតាយតនៈ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលច្យុតចាកបញ្ចវោការភព កាលចូលទៅកាន់កាមាវចរភព ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ តែសោតាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វកាល បរិនិព្វានក្នុងបញ្ចវោការភព និងពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម

ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង សោតាយតនៈ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះទេឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព សោតាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព និងពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម សោតាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ចក្ខាយតនៈ មិនកើតឡើងផង ។

[ ៤៧៧ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើង ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វកាលបរិនិព្វាន ក្នុងកាមាវចរភព កាលច្យុតចាករូបាវចរភព ពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម ចក្ខាយតនៈរបស់សត្វទាំងនោះ មិនកើតឡើងផង ឃានាយតនៈ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ឃានាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះទេឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមា-

វចរភព កាលចូលទៅកាន់រូបាវចរភព ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងកាមាវចរភព កាលច្យុតចាករូបាវចរភព ពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ចក្ខាយតនៈ មិនកើតឡើងផង ក្នុងទីនោះ ។

[ ៤៧៨ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើង ក្នុងទីណា រូបាយតនៈ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលច្យុតចាកបញ្ចវោការភព កាលចូលទៅកាន់កាមាវចរភព និងពួកអសញ្ញសត្វ ចក្ខាយតនៈរបស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព និងពួកអរូបព្រហ្ម ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង រូបាយតនៈ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះទេឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព រូបាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព និងពួកអរូបព្រហ្ម រូបាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ចក្ខាយតនៈ មិនកើតឡើងផង ក្នុងទីនោះ ។

[ ៤៧៩ ] ចក្ខាយតន: របស់សត្វណា មិនកើតឡើង ក្នុងទីណា មនាយតន: របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលច្យុតចាកបញ្ចវោការភព កាលចូលទៅកាន់កាមាវចរភព និងពួកអរូបព្រហ្ម ចក្ខាយតន: របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ តែមនាយតន: របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព ពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព និងពួកអសញ្ញសត្វ ចក្ខាយតន: របស់សត្វទាំងនោះ មិនកើតឡើងផង មនាយតន: នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតន: របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ចក្ខាយតន: របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះទេឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព មនាយតន: របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែចក្ខាយតន: របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព ពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព និងពួកអសញ្ញសត្វ មនាយតន: របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ចក្ខាយតន: មិនកើតឡើងផង ក្នុងទីនោះ ។

[ ៤៨០ ] ចក្ខាយតន: របស់សត្វណា មិនកើតឡើង ក្នុងទីណា ធម្មាយតន: របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចក្ខុ កាលច្យុត កាលចាប់បដិសន្ធិ ចក្ខាយតន: របស់

សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន ក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង ធម្មាយតនៈ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះទេឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព ធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន ក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ចក្ខាយតនៈ មិនកើតឡើងផង ក្នុងទីនោះ ។

[ ៤៨១ ] ឃានាយតនៈរបស់សត្វណា មិនកើតឡើង ក្នុងទីណា រូបាយតនៈ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ ពួកសត្វដែលមិនមានឃានៈ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព និងពួកសត្វជារូបាវចរ ឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងកាមាវចរភព ពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងពួកអរូបព្រហ្ម ឃានាយតនៈរបស់សត្វទាំងនោះ

មិនកើតឡើងផង រូបាយតនៈ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាង ទៀត រូបាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះទេឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិម-ភព កាលចូលទៅកាន់កាមាវចរភព រូបាយតនៈ របស់សត្វទាំងនោះ នឹង មិនកើតឡើង ក្នុងទីនោះ តែឃានាយតនៈរបស់សត្វទាំងនោះ មិនមែនជាមិន កើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងកាមាវចរភព ពួកសត្វ ដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងពួកអរូបព្រហ្ម រូបាយតនៈរបស់ សត្វទាំងនោះ នឹងមិនកើតឡើងផង ឃានាយតនៈ មិនកើតឡើងផង ក្នុងទីនោះ ។

[ ៤៨២ ] ឃានាយតនៈ របស់សត្វណា មិនកើតឡើង ក្នុងទីណា មនា-យតនៈ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ ពួកសត្វដែល មិនមានឃានៈ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព ពួកសត្វជារូបាវចរ និងជាអរូបាវចរ ឃានាយតនៈ របស់សត្វទាំងនោះ មិន កើតឡើង ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹង មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងកាមាវចរភព ពួក សត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងក្នុងអរូបាវចរភព និងពួក អសញ្ញសត្វ ឃានាយតនៈរបស់សត្វទាំងនោះ មិនកើតឡើងផង មនាយតនៈ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វ ណា នឹងមិនកើតឡើង ក្នុងទីណា ឃានាយតនៈរបស់សត្វនោះ មិនកើតឡើង ក្នុងទីនោះទេឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមា-

វចរភព មនាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែយានាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងកាមាវចរភព ពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងក្នុងអរូបាវចរភព និងពួកអសញ្ញសត្វ មនាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង យានាយតនៈ មិនកើតឡើងផង ក្នុងទីនោះ ។

[ ៤៨៣ ] យានាយតនៈ របស់សត្វណា មិនកើតឡើង ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ពួកសត្វទាំងអស់ដែលមិនមានយានៈ កាលច្យុត កាលចាប់បដិសន្ធិ យានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងកាមាវចរភព ពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងក្នុងអរូបាវចរភព យានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង ធម្មាយតនៈ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា យានាយតនៈ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះទេឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព ធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែយានាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងកាមាវចរភព ពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងក្នុងអរូបាវចរភព ធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិន

កើតឡើងផង ឃានាយតនៈ មិនកើតឡើងផង ក្នុងទីនោះ ។

[ ៤៨៤ ] រូបាយតនៈ របស់សត្វណា មិនកើតឡើង ក្នុងទីណា មនាយតនៈ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ ពួកសត្វ កាលច្យុតចាកបញ្ចវោការភព និងពួកអរូបព្រហ្ម រូបាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព ពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព និងពួកសត្វ កាលច្យុតចាកអសញ្ញសត្វ រូបាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង មនាយតនៈ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា រូបាយតនៈ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះទេឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព និងពួកសត្វ កាលចូលទៅកាន់អសញ្ញសត្វ មនាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន ក្នុងបញ្ចវោការភព ពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព និងពួកសត្វ កាលច្យុតចាកអសញ្ញសត្វ មនាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង រូបាយតនៈ មិនកើតឡើងផង ក្នុងទីនោះ ។

[ ៤៨៥ ] រូបាយតនៈ របស់សត្វណា មិនកើតឡើង ក្នុងទីណា ធម្មាយតនៈរបស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ ពួកសត្វទាំងអស់

កាលច្យុត និងពួកអរូបព្រហ្ម កាលចាប់បដិសន្ធិ រូបាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព និងពួកសត្វ ដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព រូបាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង ធម្មាយតនៈ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា រូបាយតនៈ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះទេឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព ធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន ក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង រូបាយតនៈ មិនកើតឡើងផង ក្នុងទីនោះ ។

[ ៤៨៦ ] មនាយតនៈ របស់សត្វណា មិនកើតឡើង ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ ពួកសត្វទាំងអស់ដែលមិនមានចិត្ត កាលច្យុត កាលចាប់បដិសន្ធិ មនាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន មនាយតនៈរបស់សត្វទាំងនោះ មិនកើតឡើងផង ធម្មាយតនៈ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា

មនាយតនៈ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះទេឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន ធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង មនាយតនៈ មិនកើតឡើងផង ក្នុងទីនោះ ។

[ ៤៨៧ ] ចក្ខាយតនៈ របស់សត្វណា កើតឡើងហើយ សោតាយតនៈ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ បណ្តាពួកសត្វដែលកើតក្នុងបច្ឆិមភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន ចក្ខាយតនៈ របស់សត្វនោះ កើតឡើងហើយ តែសោតាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ ចក្ខាយតនៈ របស់សត្វទាំងនោះ ក្រៅនេះ កើតឡើងហើយផង សោតាយតនៈ នឹងកើតឡើងផង ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា នឹងកើតឡើង ចក្ខាយតនៈ របស់សត្វនោះ កើតឡើងហើយដែរឬ ។ អើ ។

[ ៤៨៨ ] ចក្ខាយតនៈ របស់សត្វណា កើតឡើងហើយ ឃានាយតនៈ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ បណ្តាពួកសត្វដែលកើតក្នុងបច្ឆិមភព ពួកសត្វណា ចូលទៅកាន់រូបាវចរភព និងអរូបាវចរភពហើយ នឹងបរិនិព្វាន ចក្ខាយតនៈ របស់សត្វទាំងនោះ កើតឡើងហើយ តែឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ ចក្ខាយតនៈ របស់សត្វទាំងនោះ ក្រៅនេះ កើតឡើងហើយផង ឃានាយតនៈ នឹងកើតឡើងផង ។ មួយយ៉ាងទៀត

ឃានាយតនៈ របស់សត្វណា នឹងកើតឡើង ចក្ខាយតនៈ របស់សត្វនោះ កើតឡើងហើយដែរឬ ។ អើ ។

[ ៤៨៩ ] ចក្ខាយតនៈ របស់សត្វណា កើតឡើងហើយ រូបាយតនៈ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ បណ្តាពួកសត្វដែលកើតក្នុងបច្ឆិមភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន ចក្ខាយតនៈ របស់សត្វទាំងនោះ កើតឡើងហើយ តែរូបាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ ចក្ខាយតនៈ របស់សត្វទាំងនោះ ក្រៅនេះ កើតឡើងហើយផង រូបាយតនៈ នឹងកើតឡើងផង ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងកើតឡើង ចក្ខាយតនៈ របស់សត្វនោះ កើតឡើងហើយដែរឬ ។ អើ ។

[ ៤៩០ ] ចក្ខាយតនៈ របស់សត្វណា កើតឡើងហើយ មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ ចក្ខាយតនៈរបស់ពួកសត្វនោះ ដែលកើតក្នុងបច្ឆិមភព កើតឡើងហើយ តែធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ ចក្ខាយតនៈ របស់សត្វទាំងនោះ ក្រៅនេះ កើតឡើងហើយផង ធម្មាយតនៈ នឹងកើតឡើងផង ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងកើតឡើង ចក្ខាយតនៈ របស់សត្វនោះ កើតឡើងហើយដែរឬ ។ អើ ។

[ ៤៩១ ] ឃានាយតនៈ របស់សត្វណា កើតឡើងហើយ រូបាយតនៈ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ បណ្តាពួកសត្វដែលកើតក្នុងបច្ឆិមភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន ឃានាយតនៈរបស់

សត្វទាំងនោះ កើតឡើងហើយ តែរូបាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ ឃានាយតនៈ របស់សត្វទាំងនោះ ក្រៅនេះ កើតឡើងហើយផង រូបាយតនៈ នឹងកើតឡើងផង ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងកើតឡើង ឃានាយតនៈ របស់សត្វនោះ កើតឡើងហើយដែរឬ ។ អើ ។

[ ៤៩២ ] ឃានាយតនៈ របស់សត្វណា កើតឡើងហើយ មនាយតនៈ ។បេ។ ធម្មាយតនៈរបស់សត្វនោះ នឹងកើតឡើងដែរឬ ។ ឃានាយតនៈរបស់ពួកសត្វនោះ ដែលកើតក្នុងបច្ឆិមភព កើតឡើងហើយ តែធម្មាយតនៈរបស់សត្វទាំងនោះ នឹងមិនកើតឡើងទេ ឃានាយតនៈ របស់សត្វទាំងនោះ ក្រៅនេះ កើតឡើងហើយផង ធម្មាយតនៈ នឹងកើតឡើងផង ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងកើតឡើង ឃានាយតនៈ របស់សត្វនោះ កើតឡើងហើយដែរឬ ។ អើ ។

[ ៤៩៣ ] រូបាយតនៈ របស់សត្វណា កើតឡើងហើយ មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ រូបាយតនៈរបស់ពួកសត្វនោះ ដែលកើតក្នុងបច្ឆិមភព កើតឡើងហើយ តែធម្មាយតនៈរបស់សត្វទាំងនោះ នឹងមិនកើតឡើងទេ រូបាយតនៈ របស់សត្វទាំងនោះ ក្រៅនេះ កើតឡើងហើយផង ធម្មាយតនៈ នឹងកើតឡើងផង ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងកើតឡើង រូបាយតនៈ របស់សត្វនោះ កើតឡើងហើយដែរឬ ។ អើ ។

[ ៤៩៤ ] មនាយតនៈ របស់សត្វណា កើតឡើងហើយ ធម្មាយតនៈ

របស់សត្វនោះ នឹងកើតឡើងដែរឬ ។ មនាយតនៈ របស់ពួកសត្វនោះ ដែលកើតក្នុងបច្ឆិមភព កើតឡើងហើយ តែធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ មនាយតនៈ របស់សត្វទាំងនោះ ក្រៅនេះ កើតឡើងហើយផង ធម្មាយតនៈ នឹងកើតឡើងផង ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងកើតឡើង មនាយតនៈ របស់សត្វនោះ កើតឡើងហើយដែរឬ ។ អើ ។

[ ៤៩៥ ] ចក្ខាយតនៈ កើតឡើងហើយ ក្នុងទីណា ។បេ។

[ ៤៩៦ ] ចក្ខាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា សោតាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ ចក្ខាយតនៈ របស់ពួកសត្វនោះ ដែលកើតក្នុងបច្ឆិមភព ក្នុងបញ្ចវោការភព កើតឡើងហើយ ក្នុងទីនោះ តែសោតាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងក្នុងទីនោះទេ ចក្ខាយតនៈ របស់ពួកសត្វជាបញ្ចវោការនោះ ក្រៅនេះ កើតឡើងហើយផង សោតាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ អើ ។

[ ៤៩៧ ] ចក្ខាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ ចក្ខាយតនៈ របស់ពួកសត្វ ដែលកើតក្នុងបច្ឆិមភព ក្នុងកាមាវចរភព និងរបស់ពួកសត្វជារូបាវចរនោះ កើតឡើងហើយ ក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំង

នោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ចក្ខាយតនៈ របស់ពួកសត្វជាកាមាវចរនោះ ក្រៅនេះ កើតឡើងហើយផង ឃានាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ឃានាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា ។បេ។ អើ ។

[ ៤៩៨ ] ចក្ខាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ ចក្ខាយតនៈរបស់សត្វទាំងនោះ ដែលកើតក្នុងបច្ឆិមភព ក្នុងបញ្ចវោការភព កើតឡើងហើយ ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ចក្ខាយតនៈ របស់បញ្ចវោការសត្វទាំងនោះ ក្រៅនេះ កើតឡើងហើយផង រូបាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត រូបាយតនៈរបស់សត្វណា នឹងកើតឡើង ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ រូបាយតនៈ របស់ពួកអសញ្ញសត្វនោះ នឹងកើតឡើង ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ រូបាយតនៈ របស់ពួកសត្វជាបញ្ចវោការនោះ នឹងកើតឡើងផង ចក្ខាយតនៈ កើតឡើងហើយផង ក្នុងទីនោះ ។

[ ៤៩៩ ] ចក្ខាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា មនាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ ចក្ខាយតនៈ របស់សត្វទាំងនោះ ដែលកើតក្នុងបច្ឆិមភព ក្នុងបញ្ចវោការភព កើតឡើងហើយ ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុង

*ទីនោះទេ ចក្ខ្វាយតនៈ របស់ពួកសត្វជាបញ្ចវោការនោះ ក្រៅនេះ កើតឡើង ហើយផង មនាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ចក្ខ្វាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ មនាយតនៈ របស់ពួកអរូបព្រហ្មនោះ នឹងកើតឡើង ក្នុងទីនោះ តែចក្ខ្វាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ មនាយតនៈ របស់ពួកសត្វជាបញ្ចវោការនោះ នឹងកើតឡើងផង ចក្ខ្វាយតនៈ កើតឡើងហើយផង ក្នុងទីនោះ ។*

*[ ៥០០ ] ចក្ខ្វាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ ចក្ខ្វាយតនៈរបស់សត្វទាំងនោះ ដែលកើតក្នុងបច្ឆិមភព ក្នុងបញ្ចវោការភព កើតឡើងហើយ ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ចក្ខ្វាយតនៈ របស់បញ្ចវោការសត្វទាំងនោះ ក្រៅនេះ កើតឡើងហើយផង ធម្មាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈរបស់សត្វណា នឹងកើតឡើង ក្នុងទីណា ចក្ខ្វាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ ធម្មាយតនៈ របស់ពួកអសញ្ញសត្វ និងអរូបព្រហ្មទាំងនោះ នឹងកើតឡើង ក្នុងទីនោះ តែចក្ខ្វាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ធម្មាយតនៈ របស់បញ្ចវោការសត្វនោះ នឹងកើតឡើងផង ចក្ខ្វាយតនៈ កើតឡើងហើយផង ក្នុងទីនោះ ។*

*[ ៥០១ ] ឃានាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា*

រូបាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ ឃានាយតនៈ របស់ពួកសត្វទាំងនោះ ដែលកើតក្នុងបច្ឆិមភព ក្នុងកាមាវចរភព កើតឡើងហើយ ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ឃានាយតនៈរបស់ពួកកាមាវចរសត្វនោះ ក្រៅនេះ កើតឡើងហើយផង រូបាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ រូបាយតនៈ របស់ពួកសត្វជារូបាវចរនោះ នឹងកើតឡើង ក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ រូបាយតនៈ របស់ពួកសត្វជាកាមាវចរ នឹងកើតឡើងផង ឃានាយតនៈ កើតឡើងហើយផង ក្នុងទីនោះ ។

[ ៥០២ ] ឃានាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ ឃានាយតនៈរបស់សត្វទាំងនោះ ដែលកើតក្នុងបច្ឆិមភព ក្នុងកាមាវចរភព កើតឡើងហើយ ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ឃានាយតនៈរបស់ពួកសត្វជាកាមាវចរនោះ ក្រៅនេះ កើតឡើងហើយផង ធម្មាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ ធម្មាយតនៈ របស់ពួកសត្វជារូបាវចរនោះ នឹងកើតឡើង ក្នុងទីនោះ តែឃានាយតនៈ

របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ធម្មាយតនៈ របស់សត្វជាកាមាវចរទាំងនោះ នឹងកើតឡើងផង ឃានាយតនៈ កើតឡើងហើយផង ក្នុងទីនោះ ។

[ ៥០៣ ] រូបាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា មនាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ រូបាយតនៈ របស់ពួកសត្វ ដែលកើតក្នុងបច្ឆិមភព ក្នុងបញ្ចវោការភព និងរបស់ពួកអសញ្ញសត្វនោះ កើតឡើងហើយ ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ រូបាយតនៈ របស់សត្វជាបញ្ចវោការទាំងនោះ ក្រៅនេះ កើតឡើងហើយផង មនាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា រូបាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ មនាយតនៈ របស់អរូបព្រហ្មទាំងនោះ នឹងកើតឡើង ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ មនាយតនៈ របស់សត្វជាបញ្ចវោការទាំងនោះ កាលច្យុត នឹងកើតឡើងផង រូបាយតនៈ កើតឡើងហើយផង ក្នុងទីនោះ ។

[ ៥០៤ ] រូបាយតនៈ របស់សត្វណា កើតឡើងហើយ ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ រូបាយតនៈ របស់សត្វទាំងនោះ ដែលកើតក្នុងបច្ឆិមភព ក្នុងបញ្ចវោការភព កើតឡើងហើយ ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ

រូបាយតនៈ របស់ពួកសត្វជាបញ្ចវោការ និងរបស់អសញ្ញសត្វទាំងនោះ ក្រៅនេះ កើតឡើងហើយផង ធម្មាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា រូបាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ ធម្មាយតនៈ របស់ពួកអរូបព្រហ្មនោះ នឹងកើតឡើង ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ធម្មាយតនៈ របស់ពួកសត្វជាបញ្ចវោការ និងរបស់អសញ្ញសត្វទាំងនោះ នឹងកើតឡើងផង រូបាយតនៈ កើតឡើងហើយផង ក្នុងទីនោះ ។

[ ៥០៥ ] មនាយតនៈរបស់សត្វណា កើតឡើងហើយ ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ មនាយតនៈរបស់សត្វទាំងនោះ ដែលកើតក្នុងបច្ឆិមភព កើតឡើងហើយក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ មនាយតនៈរបស់ពួកសត្វជាចតុវោការ និងជាបញ្ចវោការនោះ ក្រៅនេះ កើតឡើងហើយផង ធម្មាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា មនាយតនៈ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ ធម្មាយតនៈ របស់អសញ្ញសត្វទាំងនោះ នឹងកើតឡើង ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ធម្មាយតនៈ របស់ពួកសត្វជាចតុវោការ និងជាបញ្ចវោការនោះ នឹងកើតឡើងផង មនាយតនៈ កើតឡើងហើយផង ក្នុងទីនោះ ។

[ ៥០៦ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើងហើយ សោតាយតនៈ របស់សត្វនោះ នឹងមិនកើតឡើងទេឬ ។ មិនមានទេ ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា នឹងមិនកើតឡើង ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើងហើយទេឬ ។ កើតឡើងហើយ ។

[ ៥០៧ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើងហើយ ឃានាយតនៈ ។បេ។ រូបាយតនៈ មនាយតនៈ ធម្មាយតនៈ របស់សត្វនោះ នឹងមិនកើតឡើងទេឬ ។ មិនមានទេ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនកើតឡើង ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើងហើយទេឬ ។ មិនកើតឡើងហើយ ។

[ ៥០៨ ] ឃានាយតនៈ ។បេ។ រូបាយតនៈ មនាយតនៈរបស់សត្វណា មិនកើតឡើងហើយ ធម្មាយតនៈ របស់សត្វនោះ នឹងមិនកើតឡើងទេឬ ។ មិនមានទេ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនកើតឡើង មនាយតនៈ របស់សត្វនោះ មិនកើតឡើងហើយទេឬ ។ កើតឡើងហើយ ។

[ ៥០៩ ] ចក្ខាយតនៈ មិនកើតឡើងហើយ ក្នុងទីណា ។បេ។

[ ៥១០ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា សោតាយតនៈ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ អើ ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ សោតាយតនៈ របស់សត្វទាំងនោះ ដែលកើតក្នុងបច្ឆិមភព ក្នុងបញ្ចវោការភព នឹង

មិនកើតឡើង ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ សោតាយតនៈ របស់ពួកសុទ្ធាវាសសត្វ របស់អសញ្ញសត្វ និងរបស់ពួកអរូបព្រហ្មនោះ នឹងមិនកើតឡើងផង ចក្ខាយតនៈ មិនកើតឡើងហើយផង ក្នុងទីនោះ ។

[ ៥១១ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា ឃានាយតនៈរបស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ អើ ។ មួយយ៉ាងទៀត ឃានាយតនៈរបស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ចក្ខាយតនៈរបស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ ឃានាយតនៈ របស់ពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងកាមាវចរភព និងរបស់ពួកសត្វ ជារូបាវចរនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែចក្ខាយតនៈរបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ ឃានាយតនៈរបស់ពួកសុទ្ធាវាសសត្វ របស់ពួកអសញ្ញសត្វ និងរបស់ពួកអរូបព្រហ្មនោះ នឹងមិនកើតឡើងផង ចក្ខាយតនៈ មិនកើតឡើងហើយផង ក្នុងទីនោះ ។

[ ៥១២ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ ចក្ខាយតនៈ របស់អសញ្ញសត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ចក្ខាយតនៈរបស់ពួកសុទ្ធាវាសសត្វ និងរបស់ពួកអរូបព្រហ្មនោះ មិនកើតឡើងហើយផង រូបាយតនៈ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត រូបាយតនៈរបស់

សត្វណា នឹងមិនកើតឡើង ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ រូបាយតនៈ របស់សត្វទាំងនោះ ដែលកើតក្នុងបច្ឆិមភព ក្នុងបញ្ចវោការភព នឹងមិនកើតឡើង ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ រូបាយតនៈ របស់ពួកសុទ្ធាវាសសត្វ និងរបស់ពួកអរូបព្រហ្មនោះ នឹងមិនកើតឡើងផង ចក្ខាយតនៈ មិនកើតឡើងហើយផង ក្នុងទីនោះ ។

[ ៥១៣ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា មនាយតនៈ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ ចក្ខាយតនៈ របស់អរូបព្រហ្មទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែមនាយតនៈរបស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ចក្ខាយតនៈ របស់ពួកសុទ្ធាវាសសត្វ របស់ពួកសត្វ ដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព និងរបស់អសញ្ញសត្វទាំងនោះ មិនកើតឡើងហើយផង មនាយតនៈ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ មនាយតនៈ របស់សត្វទាំងនោះ ដែលកើតក្នុងបច្ឆិមភព ក្នុងបញ្ចវោការភព នឹងមិនកើតឡើង ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ មនាយតនៈ របស់ពួកសុទ្ធាវាសសត្វ របស់ពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព និងរបស់អសញ្ញសត្វទាំងនោះ នឹងមិនកើតឡើងផង ចក្ខាយតនៈ មិនកើតឡើងហើយ

ផង ក្នុងទីនោះ ។

[ ៥១៤ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ ចក្ខាយតនៈ របស់ពួកអសញ្ញសត្វ និងរបស់ពួកអរូបព្រហ្មនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ចក្ខាយតនៈ របស់ពួកសុទ្ធាវាសសត្វ និងរបស់សត្វទាំងនោះ ដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព មិនកើតឡើងហើយផង ធម្មាយតនៈ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ ធម្មាយតនៈ របស់សត្វទាំងនោះ ដែលកើតក្នុងបច្ឆិមភព ក្នុងបញ្ចវោការភព នឹងមិនកើតឡើង ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ ធម្មាយតនៈ របស់ពួកសុទ្ធាវាសសត្វ និងរបស់សត្វទាំងនោះ ដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព នឹងមិនកើតឡើងផង ចក្ខាយតនៈ មិនកើតឡើងហើយផង ក្នុងទីនោះ ។

[ ៥១៥ ] ឃានាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះដែរឬ ។ ឃានាយតនៈ របស់ពួកសត្វ ជារូបាវចរនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ឃានាយតនៈ របស់សត្វទាំងនោះ ដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងរបស់ពួក

អរូបព្រហ្ម មិនកើតឡើងហើយផង រូបាយតនៈ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ រូបាយតនៈ របស់សត្វទាំងនោះ ដែលកើតក្នុងបច្ឆិមភព ក្នុងកាមាវចរភព នឹងមិនកើតឡើង ក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ រូបាយតនៈ របស់ពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងរបស់ពួកអរូបព្រហ្មនោះ នឹងមិនកើតឡើងផង ឃានាយតនៈ មិនកើតឡើងហើយផង ក្នុងទីនោះ ។

[ ៥១៦ ] ឃានាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា មនាយតនៈ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ ឃានាយតនៈ របស់ពួកសត្វ ជារូបាវចរ និងជាអរូបាវចរនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ឃានាយតនៈ របស់ពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងក្នុងអរូបាវចរភព និងរបស់ពួកអសញ្ញសត្វនោះ មិនកើតឡើងហើយផង មនាយតនៈ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ មនាយតនៈ របស់សត្វទាំងនោះ ដែលកើតក្នុងបច្ឆិមភព ក្នុងកាមាវចរភព នឹងមិនកើតឡើង ក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ

មនាយតនៈ របស់ពួកសត្វ ដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងក្នុង អរូបាវចរភព និងរបស់ពួកអសញ្ញសត្វនោះ នឹងមិនកើតឡើងផង ឃានាយតនៈ មិនកើតឡើងហើយផង ក្នុងទីនោះ ។

[ ៥១៧ ] ឃានាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា ធម្មាយតនៈរបស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ ឃានាយតនៈ របស់ពួកសត្វជារូបាវចរ និងជាអរូបាវចរ មិនកើតឡើងហើយ ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ឃានាយតនៈ របស់សត្វទាំងនោះ ដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និង ក្នុងអរូបាវចរភព មិនកើតឡើងហើយផង ធម្មាយតនៈ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ឃានាយតនៈរបស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ ធម្មាយតនៈ របស់សត្វទាំងនោះ ដែលកើតក្នុងបច្ឆិមភព ក្នុងកាមាវចរភព នឹង មិនកើតឡើង ក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំងនោះ មិនមែនជា មិនកើតឡើងហើយ ក្នុងទីនោះទេ ធម្មាយតនៈ របស់សត្វទាំងនោះ ដែលកើត ក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងក្នុងអរូបាវចរភព នឹងមិនកើតឡើងផង ឃានាយតនៈ មិនកើតឡើងហើយផង ក្នុងទីនោះ ។

[ ៥១៨ ] រូបាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា មនាយតនៈ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ រូបាយតនៈ របស់ពួកអរូបព្រហ្មនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែមនាយតនៈរបស់

សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ រូបាយតនៈរបស់ពួកសុទ្ធាវាសសត្វ និងរបស់សត្វទាំងនោះ ដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព មិនកើតឡើងហើយផង មនាយតនៈ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា មិនកើតឡើង ក្នុងទីណា រូបាយតនៈ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ មនាយតនៈ របស់ពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងបញ្ចវោការភព និងរបស់ពួកអសញ្ញសត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ មនាយតនៈ របស់ពួកសុទ្ធាវាស-សត្វ និងរបស់សត្វទាំងនោះ ដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព នឹងមិនកើតឡើងផង រូបាយតនៈ មិនកើតឡើងហើយផង ក្នុងទីនោះ ។

[ ៥១៩ ] រូបាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ រូបាយតនៈ របស់ពួកអរូបព្រហ្មនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែធម្មាយតនៈរបស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ រូបាយតនៈរបស់ពួកសុទ្ធាវាសសត្វ និងរបស់សត្វទាំងនោះ ដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព មិនកើតឡើងហើយផង ធម្មាយតនៈ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈរបស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា រូបាយតនៈ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ ធម្មាយតនៈ របស់សត្វទាំងនោះ ដែលកើតក្នុងបច្ឆិមភព ក្នុងបញ្ចវោការភព នឹងមិនកើតឡើង

ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ ធម្មាយតនៈ របស់ពួកសុទ្ធាវាសសត្វ និងរបស់សត្វទាំងនោះ ដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព នឹងមិនកើតឡើងផង រូបាយតនៈ មិនកើតឡើងហើយផង ក្នុងទីនោះ ។

[ ៥២០ ] មនាយតនៈ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ មនាយតនៈ របស់អសញ្ញសត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ មនាយតនៈ របស់ពួកសុទ្ធាវាសសត្វនោះ មិនកើតឡើងហើយផង ធម្មាយតនៈ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា មនាយតនៈ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះទេឬ ។ ធម្មាយតនៈ របស់សត្វទាំងនោះ ដែលកើតក្នុងបច្ឆិមភព នឹងមិនកើតឡើង ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ ធម្មាយតនៈ របស់ពួកសុទ្ធាវាសសត្វនោះ នឹងមិនកើតឡើងផង មនាយតនៈ មិនកើតឡើងហើយផង ក្នុងទីនោះ ។

ឧប្បាទវារៈ ចប់

[ ៥២១ ] ចក្ខាយតនៈរបស់សត្វណា រលត់ទៅ សោតាយតនៈរបស់សត្វនោះ រលត់ទៅដែរឬ ។ ពួកសត្វដែលប្រកបដោយចក្ខុ មិនមានសោតៈ កាលច្យុត ចក្ខាយតនៈរបស់សត្វទាំងនោះ រលត់ទៅ តែសោតាយតនៈរបស់

សត្វទាំងនោះ មិនរលត់ទៅទេ ពួកសត្វដែលប្រកបដោយចក្ខុ ប្រកបដោយសោតៈ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ រលត់ទៅផង សោតាយតនៈ រលត់ទៅផង ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា រលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ រលត់ទៅដែរឬ ។ ពួកសត្វ ដែលប្រកបដោយសោតៈ មិនមានចក្ខុ កាលច្យុត សោតាយតនៈ របស់សត្វទាំងនោះ រលត់ទៅ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅទេ ពួកសត្វដែលប្រកបដោយសោតៈ ប្រកបដោយចក្ខុ កាលច្យុត សោតាយតនៈ របស់សត្វទាំងនោះ រលត់ទៅផង ចក្ខាយតនៈ រលត់ទៅផង ។

[ ៥២២ ] ចក្ខាយតនៈ របស់សត្វណា រលត់ទៅ ឃានាយតនៈរបស់សត្វនោះ រលត់ទៅដែរឬ ។ ពួកសត្វដែលប្រកបដោយចក្ខុ មិនមានឃានៈ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ រលត់ទៅ តែឃានាយតនៈរបស់សត្វទាំងនោះ មិនរលត់ទៅទេ ពួកសត្វ ដែលប្រកបដោយចក្ខុ ប្រកបដោយឃានៈ កាលច្យុត ចក្ខាយតនៈរបស់សត្វទាំងនោះ រលត់ទៅផង ឃានាយតនៈ រលត់ទៅផង ។ មួយយ៉ាងទៀត ឃានាយតនៈ របស់សត្វណា រលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ រលត់ទៅដែរឬ ។ ពួកសត្វដែលប្រកបដោយឃានៈ មិនមានចក្ខុ កាលច្យុត ឃានាយតនៈ របស់សត្វទាំងនោះ រលត់ទៅ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅទេ ពួកសត្វដែលប្រកបដោយឃានៈ ប្រកបដោយចក្ខុទាំងនោះ កាលច្យុត ឃានាយតនៈ របស់សត្វទាំងនោះ រលត់ទៅផង ចក្ខាយតនៈ រលត់ទៅផង ។

[ ៥២៣ ] ចក្ខាយតនៈ របស់សត្វណា រលត់ទៅ រូបាយតនៈ របស់សត្វនោះ រលត់ទៅដែរឬ ។ អើ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា រលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ រលត់ទៅដែរឬ ។ ពួកសត្វដែលប្រកបដោយរូប មិនមានចក្ខុ កាលច្យុត រូបាយតនៈ របស់សត្វទាំងនោះ រលត់ទៅ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលច្យុត រូបាយតនៈ របស់សត្វទាំងនោះ រលត់ទៅផង ចក្ខាយតនៈ រលត់ទៅផង ។

[ ៥២៤ ] ចក្ខាយតនៈ របស់សត្វណា រលត់ទៅ មនាយតនៈ របស់សត្វនោះ រលត់ទៅដែរឬ ។ អើ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា រលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ រលត់ទៅដែរឬ ។ ពួកសត្វដែលប្រកបដោយចិត្ត មិនមានចក្ខុ កាលច្យុត មនាយតនៈ របស់សត្វទាំងនោះ រលត់ទៅ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលច្យុត មនាយតនៈ របស់សត្វទាំងនោះ រលត់ទៅផង ចក្ខាយតនៈ រលត់ទៅផង ។

[ ៥២៥ ] ចក្ខាយតនៈ របស់សត្វណា រលត់ទៅ ធម្មាយតនៈ របស់សត្វនោះ រលត់ទៅដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា រលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ រលត់ទៅដែរឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលច្យុត ធម្មាយតនៈ របស់សត្វទាំងនោះ រលត់ទៅ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅទេ ពួកសត្វដែលប្រកបដោយ

ចក្ខុ កាលច្យុត ធម្មាយតនៈ របស់សត្វទាំងនោះ រលត់ទៅផង ចក្ខាយតនៈ រលត់ទៅផង ។

[ ៥២៦ ] ឃានាយតនៈ របស់សត្វណា រលត់ទៅ រូបាយតនៈ របស់សត្វនោះ រលត់ទៅដែរឬ ។ អើ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា រលត់ទៅ ឃានាយតនៈ របស់សត្វនោះ រលត់ទៅដែរឬ ។ ពួកសត្វដែលប្រកបដោយរូប មិនមានឃានៈ កាលច្យុត រូបាយតនៈ របស់សត្វទាំងនោះ រលត់ទៅ តែឃានាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅទេ ពួកសត្វដែលប្រកបដោយឃានៈ កាលច្យុត រូបាយតនៈ របស់សត្វទាំងនោះ រលត់ទៅផង ឃានាយតនៈ រលត់ទៅផង ។

[ ៥២៧ ] ឃានាយតនៈរបស់សត្វណា រលត់ទៅ មនាយតនៈរបស់សត្វនោះ រលត់ទៅដែរឬ ។ អើ ។ មួយយ៉ាងទៀត មនាយតនៈរបស់សត្វណា រលត់ទៅ ឃានាយតនៈ របស់សត្វនោះ រលត់ទៅដែរឬ ។ ពួកសត្វដែលប្រកបដោយចិត្ត មិនមានឃានៈ កាលច្យុត មនាយតនៈ របស់សត្វទាំងនោះ រលត់ទៅ តែឃានាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅទេ ពួកសត្វ ដែលប្រកបដោយឃានៈ កាលច្យុត មនាយតនៈ របស់សត្វទាំងនោះ រលត់ទៅផង ឃានាយតនៈ រលត់ទៅផង ។

[ ៥២៨ ] ឃានាយតនៈ របស់សត្វណា រលត់ទៅ ធម្មាយតនៈរបស់សត្វនោះ រលត់ទៅដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា រលត់ទៅ ឃានាយតនៈ របស់សត្វនោះ រលត់ទៅដែរឬ ។ ពួកសត្វ

ដែលមិនមានឃានៈ កាលច្យុត ធម្មាយតនៈ របស់សត្វទាំងនោះ រលត់ទៅ តែឃានាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅទេ ពួកសត្វ ដែលប្រកប ដោយឃានៈ កាលច្យុត ធម្មាយតនៈ របស់សត្វទាំងនោះ រលត់ទៅផង ឃានាយតនៈ រលត់ទៅផង ។

[ ៥២៩ ] រូបាយតនៈ របស់សត្វណា រលត់ទៅ មនាយតនៈ របស់សត្វនោះ រលត់ទៅដែរឬ ។ ពួកសត្វដែលប្រកបដោយរូប មិនមានចិត្ត កាលច្យុត រូបាយតនៈ របស់សត្វទាំងនោះ រលត់ទៅ តែមនាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅទេ ពួកសត្វដែលប្រកបដោយរូប ប្រកបដោយចិត្ត កាលច្យុត រូបាយតនៈ របស់សត្វទាំងនោះ រលត់ទៅផង មនាយតនៈ រលត់ទៅផង ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា រលត់ទៅ រូបាយតនៈ របស់សត្វនោះ រលត់ទៅដែរឬ ។ ពួកសត្វដែលមិនមានរូប កាលច្យុត មនាយតនៈ របស់សត្វទាំងនោះ រលត់ទៅ តែរូបាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅទេ ពួកសត្វដែលប្រកបដោយរូប ប្រកបដោយចិត្ត កាលច្យុត មនាយតនៈ របស់សត្វទាំងនោះ រលត់ទៅផង រូបាយតនៈ រលត់ទៅផង ។

[ ៥៣០ ] រូបាយតនៈ របស់សត្វណា រលត់ទៅ ធម្មាយតនៈ របស់សត្វនោះ រលត់ទៅដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា រលត់ទៅ រូបាយតនៈ របស់សត្វនោះ រលត់ទៅដែរឬ ។ ពួកសត្វដែលមិនមានរូប កាលច្យុត ធម្មាយតនៈ របស់សត្វទាំងនោះ រលត់ទៅ តែរូបាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅទេ ពួកសត្វដែលប្រកបដោយរូប

កាលច្យុត ធម្មាយតនៈ របស់សត្វទាំងនោះ រលត់ទៅផង រូបាយតនៈរលត់ទៅផង ។

[ ៥៣១ ] មនាយតនៈ របស់សត្វណា រលត់ទៅ ធម្មាយតនៈ របស់សត្វនោះ រលត់ទៅដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា រលត់ទៅ មនាយតនៈ របស់សត្វនោះ រលត់ទៅដែរឬ ។ ពួកសត្វដែលមិនមានចិត្ត កាលច្យុត ធម្មាយតនៈ របស់សត្វទាំងនោះ រលត់ទៅ តែមនាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅទេ ពួកសត្វដែលប្រកបដោយចិត្ត កាលច្យុត ធម្មាយតនៈ របស់សត្វទាំងនោះ រលត់ទៅផង មនាយតនៈ រលត់ទៅផង ។

[ ៥៣២ ] ចក្ខាយតនៈ រលត់ទៅ ក្នុងទីណា ។បេ។ ( ប្រយោគដែលប្រកបដោយពាក្យថា ក្នុងទីណា គឺក្នុងឧប្បាទក្ខ័ ក្នុងនិរោធក្ខ័ ក្នុងឧប្បាទនិងនិរោធក្ខ័ ប្រហែលៗ គ្នា ក្នុងទីទាំងពួង ) ។

[ ៥៣៣ ] ចក្ខាយតនៈ របស់សត្វណា រលត់ទៅ ក្នុងទីណា សោតាយតនៈ របស់សត្វនោះ រលត់ទៅ ក្នុងទីនោះ ដែរឬ ។បេ។ ឃានាយតនៈ រូបាយតនៈ មនាយតនៈ ធម្មាយតនៈ រលត់ទៅ ដែរឬ ។ ( សូម្បីប្រយោគដែលប្រកបដោយពាក្យថា របស់សត្វណា ក្នុងទីណា ជាពាក្យប្រហែលៗ គ្នា បណ្ឌិតគប្បីសម្តែងឲ្យពិស្តារផងចុះ ) ។

[ ៥៣៤ ] ចក្ខាយតនៈ របស់សត្វណា មិនរលត់ទៅ សោតាយតនៈ របស់សត្វនោះ មិនរលត់ទៅដែរឬ ។ ពួកសត្វដែលមិនមានចក្ខុ ប្រកបដោយ

សោតៈ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ តែសោតាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វទាំងអស់ ដែលមិនមានចក្ខុ មិនមានសោតៈ កាលចាប់បដិសន្ធិ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅផង សោតាយតនៈ មិនរលត់ទៅផង ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា មិនរលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ មិនរលត់ទៅដែរឬ ។ ពួកសត្វដែលមិនមានសោតៈ ប្រកបដោយចក្ខុ កាលច្យុត សោតាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វទាំងអស់ ដែលមិនមានសោតៈ មិនមានចក្ខុ កាលចាប់បដិសន្ធិ កាលច្យុត សោតាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅផង ចក្ខាយតនៈ មិនរលត់ទៅផង ។

[ ៥៣៥ ] ចក្ខាយតនៈ របស់សត្វណា មិនរលត់ទៅ ឃានាយតនៈ របស់សត្វនោះ មិនរលត់ទៅដែរឬ ។ ពួកសត្វដែលមិនមានចក្ខុ ប្រកបដោយឃានៈ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ តែឃានាយតនៈរបស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វទាំងអស់ដែលមិនមានចក្ខុ មិនមានឃានៈ កាលចាប់បដិសន្ធិ កាលច្យុត ចក្ខាយតនៈរបស់សត្វទាំងនោះ មិនរលត់ទៅផង ឃានាយតនៈ មិនរលត់ទៅផង ។ មួយយ៉ាងទៀត ឃានាយតនៈ របស់សត្វណា មិនរលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ មិនរលត់ទៅដែរឬ ។ ពួកសត្វដែលមិនមានឃានៈ ប្រកបដោយចក្ខុ

កាលច្យុត ឃានាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វទាំងអស់ ដែលមិនមានឃានៈ មិនមានចក្ខុ កាលចាប់បដិសន្ធិ កាលច្យុត ឃានាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅផង ចក្ខាយតនៈ មិនរលត់ទៅផង ។

[ ៥៣៦ ] ចក្ខាយតនៈ របស់សត្វណា មិនរលត់ទៅ រូបាយតនៈរបស់សត្វនោះ មិនរលត់ទៅដែរឬ ។ ពួកសត្វដែលមិនមានចក្ខុ ប្រកបដោយរូប កាលច្យុត ចក្ខាយតនៈរបស់សត្វទាំងនោះ មិនរលត់ទៅ តែរូបាយតនៈរបស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វទាំងអស់ ដែលមិនមានរូប កាលចាប់បដិសន្ធិ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅផង រូបាយតនៈ មិនរលត់ទៅផង ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា មិនរលត់ទៅ ចក្ខាយតនៈរបស់សត្វនោះ មិនរលត់ទៅដែរឬ ។ អើ ។

[ ៥៣៧ ] ចក្ខាយតនៈ របស់សត្វណា មិនរលត់ទៅ មនាយតនៈរបស់សត្វនោះ មិនរលត់ទៅដែរឬ ។ ពួកសត្វដែលមិនមានចក្ខុ ប្រកបដោយចិត្ត កាលច្យុត ចក្ខាយតនៈរបស់សត្វទាំងនោះ មិនរលត់ទៅ តែមនាយតនៈរបស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វទាំងអស់ ដែលមិនមានចិត្ត កាលចាប់បដិសន្ធិ កាលច្យុត ចក្ខាយតនៈរបស់សត្វទាំងនោះ មិនរលត់ទៅផង មនាយតនៈ មិនរលត់ទៅផង ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា មិនរលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ មិនរលត់ទៅដែរឬ ។ អើ ។

[ ៥៣៨ ] ចក្ខាយតនៈ របស់សត្វណា មិនរលត់ទៅ ធម្មាយតនៈរបស់

សត្វនោះ មិនរលត់ទៅដែរឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វទាំងអស់ កាលចាប់បដិសន្ធិ ចក្ខាយតនៈរបស់សត្វទាំងនោះ មិនរលត់ទៅផង ធម្មាយតនៈ មិនរលត់ទៅផង ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា មិនរលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ មិនរលត់ទៅដែរឬ ។ អើ ។

[ ៥៣៩ ] ឃានាយតនៈ របស់សត្វណា មិនរលត់ទៅ រូបាយតនៈ របស់សត្វនោះ មិនរលត់ទៅដែរឬ ។ ពួកសត្វដែលមិនមានឃានៈ ប្រកបដោយរូប កាលច្យុត ឃានាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វទាំងអស់ ដែលមិនមានរូប កាលចាប់បដិសន្ធិ កាលច្យុត ឃានាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅផង រូបាយតនៈ មិនរលត់ទៅផង ។ មួយយ៉ាងទៀត រូបាយតនៈរបស់សត្វណា មិនរលត់ទៅ ឃានាយតនៈ របស់សត្វនោះ មិនរលត់ទៅដែរឬ ។ អើ ។

[ ៥៤០ ] ឃានាយតនៈរបស់សត្វណា មិនរលត់ទៅ មនាយតនៈរបស់សត្វនោះ មិនរលត់ទៅដែរឬ ។ ពួកសត្វដែលមិនមានឃានៈ ប្រកបដោយចិត្ត កាលច្យុត ឃានាយតនៈរបស់សត្វទាំងនោះ មិនរលត់ទៅ តែមនាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វទាំងអស់ ដែលមិនមានចិត្ត កាលចាប់បដិសន្ធិ កាលច្យុត ឃានាយតនៈ របស់សត្វទាំងនោះ

មិនរលត់ទៅផង មនាយតនៈ មិនរលត់ទៅផង ។ មួយយ៉ាងទៀត មនា-យតនៈ របស់សត្វណា មិនរលត់ទៅ ឃានាយតនៈ របស់សត្វនោះ មិនរលត់ទៅដែរឬ ។ អើ ។

[ ៥៤១ ] ឃានាយតនៈ របស់សត្វណា មិនរលត់ទៅ ធម្មាយតនៈ របស់សត្វនោះ មិនរលត់ទៅដែរឬ ។ ពួកសត្វដែលមិនមានឃានៈ កាលច្យុត ឃានាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វទាំងអស់ កាលចាប់បដិសន្ធិ ឃានាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅផង ធម្មាយតនៈ មិនរលត់ទៅផង ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា មិនរលត់ទៅ ឃានាយតនៈ របស់សត្វនោះ មិនរលត់ទៅដែរឬ ។ អើ ។

[ ៥៤២ ] រូបាយតនៈរបស់សត្វណា មិនរលត់ទៅ មនាយតនៈរបស់សត្វនោះ មិនរលត់ទៅដែរឬ ។ ពួកសត្វដែលមិនមានរូប កាលច្យុត រូបា-យតនៈរបស់សត្វទាំងនោះ មិនរលត់ទៅ តែមនាយតនៈរបស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វទាំងអស់ កាលចាប់បដិសន្ធិ រូបាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅផង មនាយតនៈ មិនរលត់ទៅផង ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា មិនរលត់ទៅ រូបាយតនៈ របស់សត្វនោះ មិនរលត់ទៅដែរឬ ។ ពួកសត្វដែលមិនមានចិត្ត កាលច្យុត មនាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ តែរូបាយតនៈរបស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វទាំងអស់ កាលចាប់បដិសន្ធិ មនាយតនៈ របស់

សត្វទាំងនោះ មិនរលត់ទៅផង រូបាយតនៈ មិនរលត់ទៅផង ។

[ ៥៤៣ ] រូបាយតនៈ របស់សត្វណា មិនរលត់ទៅ ធម្មាយតនៈរបស់សត្វនោះ មិនរលត់ទៅដែរឬ ។ ពួកសត្វដែលមិនមានរូប កាលច្យុត រូបាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វទាំងអស់ កាលចាប់បដិសន្ធិ រូបាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅផង ធម្មាយតនៈ មិនរលត់ទៅផង ។ មួយយ៉ាងទៀត ធម្មាយតនៈរបស់សត្វណា មិនរលត់ទៅ រូបាយតនៈរបស់សត្វនោះ មិនរលត់ទៅដែរឬ ។ អើ ។

[ ៥៤៤ ] មនាយតនៈរបស់សត្វណា មិនរលត់ទៅ ធម្មាយតនៈរបស់សត្វនោះ មិនរលត់ទៅដែរឬ ។ ពួកសត្វដែលមិនមានចិត្ត កាលច្យុត មនាយតនៈរបស់សត្វទាំងនោះ មិនរលត់ទៅ តែធម្មាយតនៈរបស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វទាំងអស់ កាលចាប់បដិសន្ធិ មនាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅផង ធម្មាយតនៈ មិនរលត់ទៅផង ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា មិនរលត់ទៅ មនាយតនៈ របស់សត្វនោះ មិនរលត់ទៅដែរឬ ។ អើ ។

[ ៥៤៥ ] ចក្ខាយតនៈ មិនរលត់ទៅ ក្នុងទីណា ។បេ។

[ ៥៤៦ ] ចក្ខាយតនៈ របស់សត្វណា មិនរលត់ទៅ ក្នុងទីណា ។បេ។ ប្រយោគ ដែលប្រកបដោយពាក្យថា របស់សត្វណាក្តី របស់សត្វណា ក្នុងទីណាក្តី ជាពាក្យប្រហែលៗ គ្នា ។

[ ៥៤៧ ] ចក្ខាយតនៈរបស់សត្វណា រលត់ហើយ សោតាយតនៈរបស់សត្វនោះ រលត់ហើយឬ ។ អើ ។ បុច្ឆា ជាអតីត ក្នុងឧប្បាទវារៈក្តី ក្នុងនិរោធវារៈក្តី ក្នុងឧប្បាទនិរោធវារៈក្តី ជាអនុលោមក្តី បដិលោមក្តី ប្រហែលៗ គ្នា ។

[ ៥៤៨ ] ចក្ខាយតនៈ របស់សត្វណា នឹងរលត់ទៅ សោតាយតនៈរបស់សត្វនោះ នឹងរលត់ទៅដែរឬ ។ អើ ។ មួយយ៉ាងទៀត សោតាយតនៈរបស់សត្វណា នឹងរលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ អើ ។

[ ៥៤៩ ] ចក្ខាយតនៈរបស់សត្វណា នឹងរលត់ទៅ ឃានាយតនៈរបស់សត្វនោះ នឹងរលត់ទៅដែរឬ ។ បណ្តាពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់រូបាវចរភព ពួកសត្វណា ចូលទៅកាន់រូបាវចរភពហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលច្យុត ចក្ខាយតនៈរបស់សត្វទាំងនោះ នឹងរលត់ទៅ តែឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ចក្ខាយតនៈរបស់សត្វទាំងនោះ ក្រៅនេះ នឹងរលត់ទៅផង ឃានាយតនៈ នឹងរលត់ទៅផង ។ មួយយ៉ាងទៀត ឃានាយតនៈរបស់សត្វណា នឹងរលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ អើ ។

[ ៥៥០ ] ចក្ខាយតនៈរបស់សត្វណា នឹងរលត់ទៅ រូបាយតនៈរបស់សត្វនោះ នឹងរលត់ទៅដែរឬ ។ អើ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងរលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ អើ ។

[ ៥៥១ ] ចក្ខាយតនៈរបស់សត្វណា នឹងរលត់ទៅ មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈរបស់សត្វណា នឹងរលត់ទៅ ចក្ខាយតនៈរបស់សត្វនោះ នឹងរលត់ទៅដែរឬ ។ បណ្តាពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់អរូបភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលច្យុត ធម្មាយតនៈរបស់សត្វទាំងនោះ នឹងរលត់ទៅ តែចក្ខាយតនៈរបស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ធម្មាយតនៈ របស់សត្វទាំងនោះក្រៅនេះ នឹងរលត់ទៅផង ចក្ខាយតនៈ នឹងរលត់ទៅផង ។

[ ៥៥២ ] ឃានាយតនៈរបស់សត្វណា នឹងរលត់ទៅ រូបាយតនៈរបស់សត្វនោះ នឹងរលត់ទៅដែរឬ ។ អើ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងរលត់ទៅ ឃានាយតនៈ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ បណ្តាពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់រូបាវចរភព ពួកសត្វណា ចូលទៅកាន់រូបាវចរភពហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលច្យុត រូបាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ តែឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ រូបាយតនៈ របស់សត្វទាំងនោះ ក្រៅនេះ នឹងរលត់ទៅផង ឃានាយតនៈ នឹងរលត់ទៅផង ។

[ ៥៥៣ ] ឃានាយតនៈរបស់សត្វណា នឹងរលត់ទៅ មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងរលត់ទៅ ឃានាយតនៈ របស់សត្វនោះ នឹង

រលត់ទៅដែរឬ ។ បណ្ដាពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់រូបាវចរភព និងកាន់អរូបាវចរភព ពួកសត្វណា ចូលទៅកាន់រូបាវចរភព និងកាន់អរូបាវចរភពហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលច្យុត ធម្មាយតនៈរបស់សត្វទាំងនោះ នឹងរលត់ទៅ តែឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ធម្មាយតនៈ របស់សត្វទាំងនោះ ក្រៅនេះ នឹងរលត់ទៅផង ឃានាយតនៈ នឹងរលត់ទៅផង ។

[ ៥៥៤ ] រូបាយតនៈ របស់សត្វណា នឹងរលត់ទៅ មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងរលត់ទៅ រូបាយតនៈ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ បណ្ដាពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់អរូបភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលច្យុត ធម្មាយតនៈរបស់សត្វទាំងនោះ នឹងរលត់ទៅ តែរូបាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ធម្មាយតនៈ របស់សត្វទាំងនោះ ក្រៅនេះ នឹងរលត់ទៅផង រូបាយតនៈ នឹងរលត់ទៅផង ។

[ ៥៥៥ ] មនាយតនៈរបស់សត្វណា នឹងរលត់ទៅ ធម្មាយតនៈរបស់សត្វនោះ នឹងរលត់ទៅដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងរលត់ទៅ មនាយតនៈ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ អើ ។

[ ៥៥៦ ] ចក្ខាយតនៈ នឹងរលត់ទៅ ក្នុងទីណា ។បេ។

[ ៥៥៧ ] ចក្ខាយតនៈរបស់សត្វណា នឹងរលត់ទៅ ក្នុងទីណា សោតា-

យតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាង ទៀត សោតាយតនៈ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ អើ ។

[ ៥៥៨ ] ចក្ខាយតនៈ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ ជារូបាវចរ ។បេ។ ជាកាមាវចរ ។ ពួកអសញ្ញសត្វ ។បេ។ ពួកសត្វជា បញ្ចវោការ ។ ពួកអរូបព្រហ្ម ។បេ។ ពួកសត្វជាបញ្ចវោការ ។ ពួក អសញ្ញសត្វ ពួកអរូបព្រហ្ម ។បេ។ ពួកសត្វជាបញ្ចវោការ ។

[ ៥៥៩ ] ឃានាយតនៈ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយ យ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា ឃានា-យតនៈរបស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វជារូបាវចរ ។បេ។ ពួកសត្វជាកាមាវចរ ។ ពួកសត្វជារូបាវចរ និងជាអរូបាវចរ ។បេ។ ជាកាមាវចរ ។

[ ៥៦០ ] រូបាយតនៈរបស់សត្វណា នឹងរលត់ទៅ ក្នុងទីណា មនា-យតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកអសញ្ញសត្វ ។បេ។ ពួកសត្វជាបញ្ចវោការ ។ ពួកអរូបព្រហ្ម ។បេ។ ពួកសត្វជាបញ្ច-វោការ ។ ពួកអរូបព្រហ្ម ។បេ។ ពួកសត្វជាបញ្ចវោការ និងពួកអសញ្ញសត្វ ។

[ ៥៦១ ] មនាយតនៈរបស់សត្វណា នឹងរលត់ទៅ ក្នុងទីណា ធម្មា-

យតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈរបស់សត្វណា នឹងរលត់ទៅ ក្នុងទីណា មនាយតនៈរបស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកអសញ្ញសត្វ ។បេ។ ពួកសត្វជាចតុវោការ និងជាបញ្ចវោការ ធម្មាយតនៈរបស់សត្វទាំងនោះ នឹងរលត់ទៅផង មនាយតនៈ នឹងរលត់ទៅផង ក្នុងទីនោះ ។ បុច្ឆា ជាអនាគត ក្នុងពាក្យថា របស់សត្វណា ក្នុងទីណា ក្នុងឧប្បាទវារៈ ដែលបណ្ឌិតឲ្យពិស្តារហើយ យ៉ាងណា ក្នុងនិរោធ ក៏បណ្ឌិតគប្បីឲ្យពិស្តារ យ៉ាងនោះដែរ ។

[ ៥៦២ ] ចក្ខាយតនៈរបស់សត្វណា នឹងមិនរលត់ទៅ សោតាយតនៈរបស់សត្វនោះ នឹងមិនរលត់ទៅដែរឬ ។ អើ ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅដែរឬ ។ អើ ។

[ ៥៦៣ ] ចក្ខាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ឃានាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅដែរឬ ។ អើ ។ មួយយ៉ាងទៀត ឃានាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅដែរឬ ។ បណ្តាពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់រូបាវចរភព ពួកសត្វណា ចូលទៅកាន់រូបាវចរភពហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលច្យុត ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ តែចក្ខាយតនៈរបស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ បណ្តាពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុង

បច្ឆិមភព ក្នុងអរូបភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិ-និព្វាន សត្វទាំងនោះ កាលច្យុត ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ចក្ខាយតនៈ នឹងមិនរលត់ទៅផង ។

[ ៥៦៤ ] ចក្ខាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ រូបាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅដែរឬ ។ អើ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅដែរឬ ។ អើ ។

[ ៥៦៥ ] ចក្ខាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ មនាយតនៈ ។បេ។ ធម្មាយតនៈរបស់សត្វនោះ នឹងមិនរលត់ទៅដែរឬ ។ បណ្ដាពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់អរូបភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលច្យុត ចក្ខាយតនៈរបស់សត្វទាំងនោះ នឹងមិនរលត់ទៅ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ ពួកសត្វ កាលបរិនិព្វាន ចក្ខាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ធម្មាយតនៈ នឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅដែរឬ ។ អើ ។

[ ៥៦៦ ] ឃានាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ រូបាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅដែរឬ ។ បណ្ដាពួកសត្វដែលកើតក្នុងបច្ឆិម-ភព កាលចូលទៅកាន់រូបាវចរភព ពួកសត្វណា ចូលទៅកាន់រូបាវចរភព

ហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលច្យុត ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ បណ្ដាពួកសត្វ កាលបរិនិព្វាន ក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលច្យុត ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង រូបាយតនៈ នឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ឃានាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅដែរឬ ។ អើ ។

[ ៥៦៧ ] ឃានាយតនៈរបស់សត្វណា នឹងមិនរលត់ទៅ មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅដែរឬ ។ បណ្ដាពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់រូបាវចរភព និងកាន់អរូបាវចរភព ពួកសត្វណា ចូលទៅកាន់រូបាវចរភព និងកាន់អរូបាវចរភពហើយ នឹងបរិ-និព្វាន សត្វទាំងនោះ កាលច្យុត ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ ពួកសត្វ កាលបរិនិព្វាន ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ធម្មាយតនៈ នឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត ធម្មាយតនៈរបស់សត្វណា នឹងមិនរលត់ទៅ ឃានាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅដែរឬ ។ អើ ។

[ ៥៦៨ ] រូបាយតនៈរបស់សត្វណា នឹងមិនរលត់ទៅ មនាយតនៈ ។បេ។

ធម្មាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅដែរឬ ។ បណ្ដាពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់អរូបភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលច្យុត រូបាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ ពួកសត្វ កាលបរិនិព្វាន រូបាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ធម្មាយតនៈ នឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ រូបាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅដែរឬ ។ អើ ។

[ ៥៦៩ ] មនាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ធម្មាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ មនាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅដែរឬ ។ អើ ។

[ ៥៧០ ] ចក្ខាយតនៈ នឹងមិនរលត់ទៅ ក្នុងទីណា ។បេ។

[ ៥៧១ ] ចក្ខាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា សោតាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះដែរឬ ។ អើ ។

[ ៥៧២ ] ចក្ខាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះដែរឬ ។ អើ ។

មួយយ៉ាងទៀត ឃានាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះដែរឬ ។ ឃានាយតនៈ របស់ពួកសត្វ ជារូបាវចរនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ឃានាយតនៈ របស់ពួកសត្វ កាលបរិនិព្វាន ក្នុងបញ្ចវោការភព របស់ពួកអសញ្ញសត្វ និងរបស់ពួកអរូបព្រហ្មនោះ នឹងមិនរលត់ទៅផង ចក្ខាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។

[ ៥៧៣ ] ចក្ខាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះដែរឬ ។ ចក្ខាយតនៈ របស់ពួកអសញ្ញសត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ចក្ខាយតនៈ របស់ពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព និងរបស់ពួកអរូបព្រហ្មនោះ នឹងមិនរលត់ទៅផង រូបាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះដែរឬ ។ អើ ។

[ ៥៧៤ ] ចក្ខាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា មនាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះដែរឬ ។ ចក្ខាយតនៈរបស់ពួកអរូបព្រហ្មនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ចក្ខាយតនៈ

របស់ពួកសត្វ កាលបរិនិព្វាន និងរបស់ពួកអសញ្ញសត្វនោះ នឹងមិនរលត់ទៅផង មនាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះដែរឬ ។ អើ ។

[ ៥៧៥ ] ចក្ខាយតនៈរបស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ធម្មាយតនៈរបស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះដែរឬ ។ ចក្ខាយតនៈរបស់ពួកអសញ្ញសត្វ និងរបស់ពួកអរូបព្រហ្មនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន ចក្ខាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ធម្មាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះដែរឬ ។ អើ ។

[ ៥៧៦ ] ឃានាយតនៈរបស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា រូបាយតនៈរបស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះដែរឬ ។ ឃានាយតនៈ របស់ពួកសត្វ ជារូបាវចរនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ឃានាយតនៈ របស់ពួកសត្វ កាលបរិនិព្វាន ក្នុងបញ្ចវោការភព និងរបស់ពួកអរូបព្រហ្មនោះ នឹងមិនរលត់ទៅផង រូបាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា

ឃានាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះដែរឬ ។ អើ ។

[ ៥៧៧ ] ឃានាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា មនាយតនៈរបស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះដែរឬ ។ ឃានាយតនៈ របស់ពួកសត្វ ជារូបាវចរ និងជាអរូបាវចរនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ឃានាយតនៈ របស់ពួកសត្វ កាលបរិនិព្វាន និងរបស់ពួកអសញ្ញសត្វនោះ នឹងមិនរលត់ទៅផង មនាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះដែរឬ ។ អើ ។

[ ៥៧៨ ] ឃានាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ធម្មាយតនៈរបស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះដែរឬ ។ ឃានាយតនៈ របស់ពួកសត្វ ជារូបាវចរ និងជាអរូបាវចរនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ធម្មាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះដែរឬ ។ អើ ។

[ ៥៧៩ ] រូបាយតនៈរបស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា មនា-

យតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ រូបាយតនៈរបស់ពួកអរូបព្រហ្មនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន រូបាយតនៈរបស់សត្វទាំងនោះ នឹងមិនរលត់ទៅផង មនាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ មនាយតនៈ របស់ពួកអសញ្ញសត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន មនាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង រូបាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។

[ ៥៨០ ] រូបាយតនៈរបស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ រូបាយតនៈរបស់ពួកអរូបព្រហ្មនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន រូបាយតនៈរបស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ធម្មាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ អើ ។

[ ៥៨១ ] មនាយតនៈរបស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ធម្មា-

យតនៈរបស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ មនាយតនៈរបស់ពួកអសញ្ញសត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន មនាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ធម្មាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា មនាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ អើ ។

[ ៥៨២ ] ចក្ខាយតនៈ របស់សត្វណា រលត់ទៅ សោតាយតនៈ របស់សត្វនោះ រលត់ហើយដែរឬ ។ អើ ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា រលត់ហើយ ចក្ខាយតនៈ របស់សត្វនោះ រលត់ទៅដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចក្ខុ កាលចាប់បដិសន្ធិ កាលច្យុត សោតាយតនៈ របស់សត្វទាំងនោះ រលត់ហើយ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលច្យុត សោតាយតនៈរបស់សត្វទាំងនោះ រលត់ហើយផង ចក្ខាយតនៈ រលត់ទៅផង ។

[ ៥៨៣ ] ចក្ខាយតនៈ របស់សត្វណា រលត់ទៅ ឃានាយតនៈ ។បេ។ រូបាយតនៈ មនាយតនៈ ធម្មាយតនៈ របស់សត្វនោះ រលត់ហើយដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈរបស់សត្វណា រលត់ហើយ ចក្ខាយតនៈ របស់សត្វនោះ រលត់ទៅដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចក្ខុ កាលចាប់បដិសន្ធិ កាលច្យុត ធម្មាយតនៈ របស់សត្វទាំងនោះ រលត់ហើយ តែ

ចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលច្យុត ធម្មាយតនៈ របស់សត្វទាំងនោះ រលត់ហើយផង ចក្ខាយតនៈ រលត់ទៅផង ។

[ ៥៨៤ ] ឃានាយតនៈ របស់សត្វណា រលត់ទៅ រូបាយតនៈ ។បេ។ មនាយតនៈ ធម្មាយតនៈ របស់សត្វនោះ រលត់ហើយដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា រលត់ហើយ ឃានាយតនៈ របស់សត្វនោះ រលត់ទៅដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានឃានៈ កាលចាប់បដិសន្ធិ កាលច្យុត ធម្មាយតនៈ របស់សត្វទាំងនោះ រលត់ហើយ តែឃានាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅទេ ពួកសត្វដែលប្រកបដោយឃានៈ កាលច្យុត ធម្មាយតនៈ របស់សត្វទាំងនោះ រលត់ហើយផង ឃានាយតនៈ រលត់ទៅផង ។

[ ៥៨៥ ] រូបាយតនៈ របស់សត្វណា រលត់ទៅ មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ រលត់ហើយដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា រលត់ហើយ រូបាយតនៈ របស់សត្វនោះ រលត់ទៅដែរឬ ។ ពួកសត្វទាំងអស់ដែលមិនមានរូប កាលចាប់បដិសន្ធិ កាលច្យុត ធម្មាយតនៈ របស់សត្វទាំងនោះ រលត់ហើយ តែរូបាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅទេ ពួកសត្វដែលប្រកបដោយរូប កាលច្យុត ធម្មាយតនៈ របស់សត្វទាំងនោះ រលត់ហើយផង រូបាយតនៈ រលត់ទៅផង ។

[ ៥៨៦ ] មនាយតនៈ របស់សត្វណា រលត់ទៅ ធម្មាយតនៈ របស់

សត្វនោះ រលត់ហើយដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា រលត់ហើយ មនាយតនៈ របស់សត្វនោះ រលត់ទៅដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចិត្ត កាលចាប់បដិសន្ធិ កាលច្យុត ធម្មាយតនៈ របស់សត្វទាំងនោះ រលត់ហើយ តែមនាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅទេ ពួកសត្វដែលប្រកបដោយចិត្ត កាលច្យុត ធម្មាយតនៈ របស់សត្វទាំងនោះ រលត់ហើយផង មនាយតនៈ រលត់ទៅផង ។

[ ៥៨៧ ] ចក្ខាយតនៈ រលត់ទៅ ក្នុងទីណា ។បេ។

[ ៥៨៨ ] ចក្ខាយតនៈ របស់សត្វណា រលត់ទៅ ក្នុងទីណា សោតាយតនៈ របស់សត្វនោះ រលត់ហើយ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វាន ក្នុងសុទ្ធាវាស ចក្ខាយតនៈ របស់សត្វទាំងនោះ រលត់ទៅ ក្នុងទីនោះ តែសោតាយតនៈរបស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយចក្ខុ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ រលត់ទៅផង សោតាយតនៈ រលត់ហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា រលត់ហើយ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ រលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលចូលទៅកាន់បញ្ចវោការភព កាលច្យុតចាកកាមាវចរភព សោតាយតនៈ របស់សត្វទាំងនោះ រលត់ហើយ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលច្យុត សោតាយតនៈ របស់សត្វទាំងនោះ រលត់ហើយផង ចក្ខាយតនៈ រលត់ទៅ

ផង ក្នុងទីនោះ ។

[ ៥៨៩ ] ចក្ខាយតនៈ របស់សត្វណា រលត់ទៅ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ រលត់ហើយ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលច្យុតចាកកាមាវចរភព ចក្ខាយតនៈ របស់សត្វទាំងនោះ រលត់ទៅ ក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលច្យុតចាកកាមាវចរភព ចក្ខាយតនៈ របស់សត្វទាំងនោះ រលត់ទៅផង ឃានាយតនៈ រលត់ហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ឃានាយតនៈ របស់សត្វណា រលត់ហើយ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ រលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ ដែលមិនមានចក្ខុ កាលចូលទៅកាន់កាមាវចរភព កាលច្យុតចាកកាមាវចរភព ឃានាយតនៈរបស់សត្វទាំងនោះ រលត់ហើយ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលច្យុតចាកកាមាវចរភព ឃានាយតនៈ របស់សត្វទាំងនោះ រលត់ហើយផង ចក្ខាយតនៈ រលត់ទៅផង ក្នុងទីនោះ ។

[ ៥៩០ ] ចក្ខាយតនៈ របស់សត្វណា រលត់ទៅ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ រលត់ហើយ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងសុទ្ធាវាស ចក្ខាយតនៈ របស់សត្វទាំងនោះ រលត់ទៅ ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយចក្ខុ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ រលត់ទៅ

ផង រូបាយតនៈ រលត់ហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា រលត់ហើយ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ រលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលចូលទៅកាន់បញ្ចវោការភព កាលច្យុតចាកកាមាវចរភព និងពួកអសញ្ញសត្វ រូបាយតនៈ របស់សត្វទាំងនោះ រលត់ហើយ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលច្យុត រូបាយតនៈ របស់សត្វទាំងនោះ រលត់ហើយផង ចក្ខាយតនៈ រលត់ទៅផង ក្នុងទីនោះ ។

[ ៥៩១ ] ចក្ខាយតនៈ របស់សត្វណា រលត់ទៅ ក្នុងទីណា មនាយតនៈ របស់សត្វនោះ រលត់ហើយ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងសុទ្ធាវាស ចក្ខាយតនៈ របស់សត្វទាំងនោះ រលត់ទៅ ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយចក្ខុ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ រលត់ទៅផង មនាយតនៈ រលត់ហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា រលត់ហើយ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ រលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលចូលទៅកាន់បញ្ចវោការភព និងពួកអរូបព្រហ្ម កាលច្យុតចាកកាមាវចរភព មនាយតនៈ របស់សត្វទាំងនោះ រលត់ហើយ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយ

ចក្ខុ កាលច្យុត មនាយតនៈ របស់សត្វទាំងនោះ រលត់ហើយផង ចក្ខាយតនៈ រលត់ទៅផង ក្នុងទីនោះ ។

[ ៥៩២ ] ចក្ខាយតនៈ របស់សត្វណា រលត់ទៅ ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ រលត់ហើយ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងសុទ្ធាវាស ចក្ខាយតនៈរបស់សត្វទាំងនោះ រលត់ទៅ ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយចក្ខុ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ រលត់ទៅផង ធម្មាយតនៈ រលត់ហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈរបស់សត្វណា រលត់ហើយ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ រលត់ទៅក្នុងទីនោះដែរឬ ។ ពួកសត្វទាំងអស់ដែលមិនមានចក្ខុ កាលចាប់បដិសន្ធិ កាលច្យុត ធម្មាយតនៈរបស់សត្វទាំងនោះ រលត់ហើយ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលច្យុត ធម្មាយតនៈរបស់សត្វទាំងនោះ រលត់ហើយផង ចក្ខាយតនៈ រលត់ទៅផង ក្នុងទីនោះ ។

[ ៥៩៣ ] ឃានាយតនៈរបស់សត្វណា រលត់ទៅ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ រលត់ហើយ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត រូបាយតនៈរបស់សត្វណា រលត់ហើយ ក្នុងទីណា ឃានាយតនៈរបស់សត្វនោះ រលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វដែលមិនមានឃានៈ កាលចូលទៅកាន់កាមាវចរភព និងពួកសត្វជារូបាវចរ កាលច្យុតចាកកាមាវចរភព រូបាយតនៈ

របស់សត្វទាំងនោះ រលត់ហើយ ក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយឃានៈ កាលច្យុត រូបាយតនៈ របស់សត្វទាំងនោះ រលត់ហើយផង ឃានាយតនៈ រលត់ទៅផង ក្នុងទីនោះ ។

[ ៥៩៤ ] ឃានាយតនៈ របស់សត្វណា រលត់ទៅ ក្នុងទីណា មនាយតនៈ របស់សត្វនោះ រលត់ហើយ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា រលត់ហើយ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ រលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វដែលមិនមានឃានៈ កាលចូលទៅកាន់កាមាវចរភព ពួកសត្វជារូបាវចរ និងជាអរូបាវចរ កាលច្យុតចាកកាមាវចរភព មនាយតនៈ របស់សត្វទាំងនោះ រលត់ហើយ ក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយឃានៈ កាលច្យុត មនាយតនៈ របស់សត្វទាំងនោះ រលត់ហើយផង ឃានាយតនៈ រលត់ទៅផង ក្នុងទីនោះ ។

[ ៥៩៥ ] ឃានាយតនៈ របស់សត្វណា រលត់ទៅ ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ រលត់ហើយ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា រលត់ហើយ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ រលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានឃានៈ កាលចាប់បដិសន្ធិ កាលច្យុត ធម្មាយតនៈ របស់សត្វទាំងនោះ រលត់ហើយ ក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទី

នោះទេ ពួកសត្វដែលប្រកបដោយឈានៈ កាលច្យុត ធម្មាយតនៈ របស់សត្វទាំងនោះ រលត់ហើយផង ឈានាយតនៈ រលត់ទៅផង ក្នុងទីនោះ ។

[ ៥៩៦ ] រូបាយតនៈ របស់សត្វណា រលត់ទៅ ក្នុងទីណា មនាយតនៈ របស់សត្វនោះ រលត់ហើយ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងសុទ្ធាវាស និងពួកសត្វ កាលច្យុតចាកអសញ្ញសត្វ រូបាយតនៈ របស់សត្វទាំងនោះ រលត់ទៅ ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះទេ ពួកសត្វក្រៅនេះ កាលច្យុតចាកបញ្ចវោការភព រូបាយតនៈ របស់សត្វទាំងនោះ រលត់ទៅផង មនាយតនៈ រលត់ហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈរបស់សត្វណា រលត់ហើយ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ រលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកអរូបព្រហ្ម កាលចូលទៅកាន់បញ្ចវោការភព មនាយតនៈ របស់សត្វទាំងនោះ រលត់ហើយ ក្នុងទីនោះ តែរូបាយតនៈរបស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលច្យុតចាកបញ្ចវោការភព មនាយតនៈ របស់សត្វទាំងនោះ រលត់ហើយផង រូបាយតនៈ រលត់ទៅផង ក្នុងទីនោះ ។

[ ៥៩៧ ] រូបាយតនៈរបស់សត្វណា រលត់ទៅ ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ រលត់ហើយ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងសុទ្ធាវាស រូបាយតនៈរបស់សត្វទាំងនោះ រលត់ទៅ ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយរូប កាលច្យុត រូបាយតនៈ របស់សត្វទាំងនោះ រលត់ទៅផង

ធម្មាយតនៈ រលត់ហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈរបស់សត្វណា រលត់ហើយ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ រលត់ទៅក្នុងទីនោះដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានរូប កាលចាប់បដិសន្ធិ កាលច្យុត ធម្មាយតនៈ របស់សត្វទាំងនោះ រលត់ហើយ ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយរូប កាលច្យុត ធម្មាយតនៈ របស់សត្វទាំងនោះ រលត់ហើយផង រូបាយតនៈ រលត់ទៅផង ក្នុងទីនោះ ។

[ ៥៩៨ ] មនាយតនៈរបស់សត្វណា រលត់ទៅ ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ រលត់ហើយ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងសុទ្ធាវាស មនាយតនៈរបស់សត្វទាំងនោះ រលត់ទៅ ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយចិត្តក្រៅនេះ កាលច្យុត មនាយតនៈ របស់សត្វទាំងនោះ រលត់ទៅផង ធម្មាយតនៈ រលត់ហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា រលត់ហើយ ក្នុងទីណា មនាយតនៈ របស់សត្វនោះ រលត់ទៅក្នុងទីនោះដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចិត្ត កាលចាប់បដិសន្ធិ កាលច្យុត ធម្មាយតនៈ របស់សត្វទាំងនោះ រលត់ហើយ ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយចិត្ត កាលច្យុត ធម្មាយតនៈ របស់សត្វទាំងនោះ រលត់ហើយផង មនាយតនៈ រលត់ទៅផង ក្នុងទីនោះ ។

[ ៥៩៩ ] ចក្ខាយតនៈ របស់សត្វណា មិនរលត់ទៅ សោតាយតនៈ របស់សត្វនោះ មិនរលត់ហើយដែរឬ ។ រលត់ហើយ ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា មិនរលត់ហើយ ចក្ខាយតនៈ របស់សត្វនោះ មិនរលត់ទៅដែរឬ ។ មិនមានទេ ។

[ ៦០០ ] ចក្ខាយតនៈ របស់សត្វណា មិនរលត់ទៅ ឃានាយតនៈ ។បេ។ រូបាយតនៈ មនាយតនៈ ធម្មាយតនៈ របស់សត្វនោះ មិនរលត់ហើយដែរឬ ។ រលត់ហើយ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា មិនរលត់ហើយ ចក្ខាយតនៈ របស់សត្វនោះ មិនរលត់ទៅដែរឬ ។ មិនមានទេ ។

[ ៦០១ ] ឃានាយតនៈ ។បេ។ រូបាយតនៈ មនាយតនៈ របស់សត្វណា មិនរលត់ទៅ ធម្មាយតនៈ របស់សត្វនោះ មិនរលត់ហើយដែរឬ ។ រលត់ហើយ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា មិនរលត់ហើយ មនាយតនៈ របស់សត្វនោះ មិនរលត់ទៅដែរឬ ។ មិនមានទេ ។

[ ៦០២ ] ចក្ខាយតនៈ មិនរលត់ទៅ ក្នុងទីណា ។បេ។

[ ៦០៣ ] ចក្ខាយតនៈ របស់សត្វណា មិនរលត់ទៅ ក្នុងទីណា សោតាយតនៈ របស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះដែរឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលចូលទៅកាន់បញ្ចវោការភព កាលច្យុតចាកកាមាវចរភព ចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះ តែសោតាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយ ក្នុងទីនោះទេ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស និងពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម

ចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅផង សោតាយតនៈ មិនរលត់ហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា មិនរលត់ហើយ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ មិនរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងសុទ្ធាវាស សោតាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស និងពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម សោតាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយផង ចក្ខាយតនៈ មិនរលត់ទៅផង ក្នុងទីនោះ ។

[ ៦០៤ ] ចក្ខាយតនៈរបស់សត្វណា មិនរលត់ទៅ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះទេឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលចូលទៅកាន់កាមាវចរភព កាលច្យុតចាកកាមាវចរភព ចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយ ក្នុងទីនោះទេ ពួកសត្វ កាលចូលទៅកាន់រូបាវចរភព និងពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម ចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅផង ឃានាយតនៈ មិនរលត់ហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ឃានាយតនៈ របស់សត្វណា មិនរលត់ហើយក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ មិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វ កាលច្យុតចាករូបាវចរភព ឃានាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅ ក្នុង

ទីនោះទេ ពួកសត្វ កាលចូលទៅកាន់រូបាវចរភព និងពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម ឃានាយតនៈរបស់សត្វទាំងនោះ មិនរលត់ហើយផង ចក្ខាយតនៈ មិនរលត់ទៅផង ក្នុងទីនោះ ។

[ ៦០៥ ] ចក្ខាយតនៈ របស់សត្វណា មិនរលត់ទៅ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះទេឬ ។ ពួកសត្វ ដែលមិនមានចក្ខុ កាលចូលទៅកាន់បញ្ចវោការភព និងពួកអសញ្ញសត្វ កាលច្យុតចាកកាមាវចរភព ចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយ ក្នុងទីនោះទេ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស និងពួកអរូបព្រហ្ម ចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅផង រូបាយតនៈ មិនរលត់ហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា មិនរលត់ហើយ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ មិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងសុទ្ធាវាស រូបាយតនៈរបស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស និងពួកអរូបព្រហ្ម រូបាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយផង ចក្ខាយតនៈ មិនរលត់ទៅផង ក្នុងទីនោះ ។

[ ៦០៦ ] ចក្ខាយតនៈរបស់សត្វណា មិនរលត់ទៅ ក្នុងទីណា មនាយតនៈ របស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះទេឬ ។ ពួកសត្វដែល

មិនមានចក្ខុ កាលចូលទៅកាន់បញ្ចវោការភព និងពួកអរូបព្រហ្ម កាលច្យុត ចាកកាមាវចរភព ចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយ ក្នុងទីនោះទេ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស និងពួកអសញ្ញសត្វ ចក្ខាយតនៈរបស់សត្វទាំងនោះ មិនរលត់ទៅផង មនាយតនៈ មិនរលត់ហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា មិនរលត់ហើយ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ មិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វ កាលបរិនិព្វាន មនាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅ ក្នុងទីនោះទេ មនាយតនៈ របស់ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស និងរបស់អសញ្ញសត្វទាំងនោះ មិនរលត់ហើយផង ចក្ខាយតនៈ មិនរលត់ទៅផង ក្នុងទីនោះ ។

[ ៦០៧ ] ចក្ខាយតនៈ របស់សត្វណា មិនរលត់ទៅ ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះទេឬ ។ ពួកសត្វទាំងអស់ដែលមិនមានចក្ខុ កាលចាប់បដិសន្ធិ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយ ក្នុងទីនោះទេ ចក្ខាយតនៈ របស់សត្វទាំងនោះ កាលចូលទៅកាន់សុទ្ធាវាស មិនរលត់ទៅផង ធម្មាយតនៈ មិនរលត់ហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា មិនរលត់ហើយ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ មិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួក

សត្វ កាលបរិនិព្វានក្នុងសុទ្ធាវាស ធម្មាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស ធម្មាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយផង ចក្ខាយតនៈ មិនរលត់ទៅផង ក្នុងទីនោះ ។

[ ៦០៨ ] ឃានាយតនៈ របស់សត្វណា មិនរលត់ទៅ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះទេឬ ។ ពួកសត្វ ដែលមិនមានឃានៈ កាលចូលទៅកាន់កាមាវចរភព និងពួកសត្វ ជារូបាវចរ កាលច្យុតចាកកាមាវចរភព ឃានាយតនៈរបស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះ តែរូបាយតនៈរបស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយ ក្នុងទីនោះទេ ឃានាយតនៈរបស់ពួកសុទ្ធាវាសសត្វ និងរបស់ពួកអរូបព្រហ្មនោះ មិនរលត់ទៅផង រូបាយតនៈ មិនរលត់ហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា មិនរលត់ហើយ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ មិនរលត់ទៅ ក្នុងទីនោះដែរឬ ។ អើ ។

[ ៦០៩ ] ឃានាយតនៈ របស់សត្វណា មិនរលត់ទៅ ក្នុងទីណា មនាយតនៈ របស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះដែរឬ ។ ពួកសត្វ ដែលមិនមានឃានៈ កាលចូលទៅកាន់កាមាវចរភព និងពួកសត្វជារូបាវចរ និងជាអរូបាវចរ កាលច្យុតចាកកាមាវចរភព ឃានាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនមែន

ជាមិនរលត់ហើយ ក្នុងទីនោះទេ ឃានាយតនៈ របស់ពួកសុទ្ធាវាសសត្វ និង របស់ពួកអសញ្ញសត្វនោះ មិនរលត់ទៅផង មនាយតនៈ មិនរលត់ហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា មិនរលត់ហើយ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ មិនរលត់ទៅ ក្នុងទីនោះទេឬ ។ អើ ។

[ ៦១០ ] ឃានាយតនៈ របស់សត្វណា មិនរលត់ទៅ ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះទេឬ ។ ពួកសត្វទាំងអស់ ដែលមិនមានឃានៈ កាលចាប់បដិសន្ធិ កាលច្យុត ឃានាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយ ក្នុងទីនោះទេ ឃានាយតនៈ របស់ពួកសុទ្ធាវាសសត្វនោះ មិនរលត់ទៅផង ធម្មាយតនៈ មិនរលត់ហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា មិនរលត់ហើយ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ មិនរលត់ទៅ ក្នុងទីនោះដែរឬ ។ អើ ។

[ ៦១១ ] រូបាយតនៈ របស់សត្វណា មិនរលត់ទៅ ក្នុងទីណា មនាយតនៈ របស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះទេឬ ។ ពួកអរូបព្រហ្ម កាលចូលទៅកាន់បញ្ចវោការភព រូបាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះ តែមនាយតនៈរបស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយ ក្នុងទីនោះទេ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស ពួកសត្វ កាលចូលទៅកាន់អសញ្ញសត្វនោះ រូបាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅផង មនា-

យតនៈ មិនរលត់ហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈរបស់សត្វណា មិនរលត់ហើយ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ មិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងសុទ្ធាវាស កាលច្យុតចាកអសញ្ញសត្វ មនាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស និងពួកសត្វ កាលចូលទៅកាន់អសញ្ញសត្វ មនាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយផង រូបាយតនៈ មិនរលត់ទៅផង ក្នុងទីនោះ ។

[ ៦១២ ] រូបាយតនៈ របស់សត្វណា មិនរលត់ទៅ ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះទេឬ ។ ពួកសត្វទាំងអស់ដែលមិនមានរូប កាលចាប់បដិសន្ធិ កាលច្យុត រូបាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយ ក្នុងទីនោះទេ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស រូបាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅផង ធម្មាយតនៈ មិនរលត់ហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា មិនរលត់ហើយ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ មិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងសុទ្ធាវាស ធម្មាយតនៈ របស់សត្វទាំងនោះមិនរលត់ហើយ ក្នុងទីនោះ តែរូបាយតនៈរបស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស ធម្មាយតនៈរបស់

សត្វទាំងនោះ មិនរលត់ហើយផង រូបាយតនៈ មិនរលត់ទៅផង ក្នុងទីនោះ ។

[ ៦១៣ ] មនាយតនៈ របស់សត្វណា មិនរលត់ទៅ ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះទេឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចិត្ត កាលចាប់បដិសន្ធិ កាលច្យុត មនាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយ ក្នុងទីនោះទេ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស មនាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅផង ធម្មាយតនៈ មិនរលត់ហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈរបស់សត្វណា មិនរលត់ហើយ ក្នុងទីណា មនាយតនៈ របស់សត្វនោះ មិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងសុទ្ធាវាស ធម្មាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស ធម្មាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយផង មនាយតនៈ មិនរលត់ទៅផង ក្នុងទីនោះ ។

[ ៦១៤ ] ចក្ខាយតនៈ របស់សត្វណា រលត់ទៅ សោតាយតនៈ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ បណ្ដាពួកសត្វ កាលបរិនិព្វាន ក្នុងបញ្ចវោការភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ រលត់ទៅ តែសោតាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ពួកសត្វក្រៅនេះ ដែល

ប្រកបដោយចក្ខុ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ រលត់ទៅផង សោតាយតនៈ នឹងរលត់ទៅផង ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា នឹងរលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ រលត់ទៅដែរឬ ។ ពួកសត្វទាំងអស់ដែលមិនមានចក្ខុ កាលចាប់បដិសន្ធិ កាលច្យុត សោតាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលច្យុត សោតាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅផង ចក្ខាយតនៈ រលត់ទៅផង ។

[ ៦១៥ ] ចក្ខាយតនៈ របស់សត្វណា រលត់ទៅ ឃានាយតនៈរបស់សត្វនោះ នឹងរលត់ទៅដែរឬ ។ បណ្តាពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព ពួកសត្វណា ចូលទៅកាន់រូបាវចរភព និងកាន់អរូបាវចរភពហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលច្យុត ចក្ខាយតនៈរបស់សត្វទាំងនោះរលត់ទៅ តែឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយចក្ខុ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ រលត់ទៅផង ឃានាយតនៈ នឹងរលត់ទៅផង ។ មួយយ៉ាងទៀត ឃានាយតនៈ របស់សត្វណា ។បេ។

[ ៦១៦ ] ចក្ខាយតនៈ របស់សត្វណា រលត់ទៅ រូបាយតនៈ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ បណ្តាពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ រលត់ទៅ តែរូបាយតនៈ

របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយចក្ខុ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ រលត់ទៅផង រូបាយតនៈ នឹងរលត់ទៅផង ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា ។បេ។

[ ៦១៧ ] ចក្ខាយតនៈ របស់សត្វណា រលត់ទៅ មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព ចក្ខាយតនៈ របស់សត្វទាំងនោះ រលត់ទៅ តែធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយចក្ខុ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ រលត់ទៅផង ធម្មាយតនៈ នឹងរលត់ទៅផង ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងរលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។បេ។

[ ៦១៨ ] ឃានាយតនៈ របស់សត្វណា រលត់ទៅ រូបាយតនៈ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ បណ្តាពួកសត្វ កាលបរិនិព្វានក្នុងកាមាវចរភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលច្យុត ឃានាយតនៈ របស់សត្វទាំងនោះ រលត់ទៅ តែរូបាយតនៈរបស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយឃានៈ កាលច្យុត ឃានាយតនៈ របស់សត្វទាំងនោះ រលត់ទៅផង រូបាយតនៈ នឹងរលត់ទៅផង ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងរលត់ទៅ ឃានាយតនៈ របស់សត្វនោះ រលត់ទៅដែរឬ ។ ពួកសត្វដែលមិនមានឃានៈ កាលចាប់បដិសន្ធិ កាលច្យុត រូបាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ

តែយានាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅទេ ពួកសត្វដែលប្រកប ដោយយានៈ កាលច្យុត រូបាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅផង យានាយតនៈ រលត់ទៅផង ។

[ ៦១៩ ] យានាយតនៈ របស់សត្វណា រលត់ទៅ មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ ពួកសត្វ កាលបរិនិព្វាន ក្នុងកាមាវចរភព យានាយតនៈ របស់សត្វទាំងនោះ រលត់ទៅ តែធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ពួកសត្វក្រៅនេះ កាលច្យុត យានាយតនៈ របស់សត្វទាំងនោះ រលត់ទៅផង ធម្មាយតនៈ នឹងរលត់ទៅ ផង ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា ។បេ។

[ ៦២០ ] រូបាយតនៈ របស់សត្វណា រលត់ទៅ មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ ពួកសត្វ កាលបរិនិព្វាន ក្នុងបញ្ចវោការភព រូបាយតនៈ របស់សត្វទាំងនោះ រលត់ទៅ តែធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយ រូប កាលច្យុត រូបាយតនៈ របស់សត្វទាំងនោះ រលត់ទៅផង ធម្មាយតនៈ នឹងរលត់ទៅផង ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងរលត់ ទៅ រូបាយតនៈ របស់សត្វនោះ រលត់ទៅដែរឬ ។ ពួកសត្វទាំងអស់ ដែល មិនមានរូប កាលចាប់បដិសន្ធិ កាលច្យុត ធម្មាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ តែរូបាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅទេ ពួកសត្វ ដែលប្រកបដោយរូប កាលច្យុត ធម្មាយតនៈ របស់សត្វទាំងនោះ នឹងរលត់

ទៅផង រូបាយតនៈ រលត់ទៅផង ។

[ ៦២១ ] មនាយតនៈ របស់សត្វណា រលត់ទៅ ធម្មាយតនៈ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ ពួកសត្វ កាលបរិនិព្វាន មនាយតនៈ របស់សត្វទាំងនោះ រលត់ទៅ តែធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយចក្ខុ កាលច្យុត មនាយតនៈ របស់សត្វទាំងនោះ រលត់ទៅផង ធម្មាយតនៈ នឹងរលត់ទៅផង ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងរលត់ទៅ មនាយតនៈ របស់សត្វនោះរលត់ទៅដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចិត្ត កាលចាប់បដិសន្ធិ កាលច្យុត ធម្មាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ តែមនាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅទេ ពួកសត្វ ដែលប្រកបដោយចិត្ត កាលច្យុត ធម្មាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅផង មនាយតនៈ រលត់ទៅផង ។

[ ៦២២ ] ចក្ខាយតនៈ របស់សត្វណា រលត់ទៅ ។បេ។

[ ៦២៣ ] ចក្ខាយតនៈ របស់សត្វណា រលត់ទៅ ក្នុងទីណា សោតាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព ចក្ខាយតនៈ របស់សត្វទាំងនោះ រលត់ទៅ ក្នុងទីនោះ តែសោតាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយចក្ខុ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ រលត់ទៅផង សោតាយតនៈ នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា ចក្ខា-

យតនៈ របស់សត្វនោះ រលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលចូលទៅកាន់បញ្ចវោការភព កាលច្យុតចាកកាមាវចរភព សោតាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលច្យុត សោតាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅផង ចក្ខាយតនៈ រលត់ទៅផង ក្នុងទីនោះ ។

[ ៦២៤ ] ចក្ខាយតនៈរបស់សត្វណា រលត់ទៅ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងកាមាវចរភព កាលច្យុតចាករូបាវចរភព ចក្ខាយតនៈ របស់សត្វទាំងនោះ រលត់ទៅ ក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយចក្ខុ កាលច្យុតចាកកាមាវចរភព ចក្ខាយតនៈ របស់សត្វទាំងនោះ រលត់ទៅផង ឃានាយតនៈ នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ឃានាយតនៈរបស់សត្វណា រលត់ទៅ ក្នុងទីណា ។បេ។ អាយតនៈទាំង ៣ យ៉ាង ក្នុងអតីតដោយបច្ចុប្បន្ន ដែលលោកសម្តែងឲ្យពិស្តារហើយ យ៉ាងណា ក៏អាយតនៈនេះ បណ្ឌិតគប្បីសម្តែងឲ្យពិស្តារយ៉ាងនោះដែរ ។

[ ៦២៥ ] ចក្ខាយតនៈរបស់សត្វណា រលត់ទៅ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព ចក្ខាយតនៈរបស់សត្វទាំងនោះ រលត់ទៅ ក្នុងទីនោះ តែ

រូបាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយចក្ខុ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះរលត់ទៅផង រូបាយតនៈ នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា ( រលត់ទៅ ) ក្នុងទីណា ។បេ។

[ ៦២៦ ] ចក្ខាយតនៈ របស់សត្វណា រលត់ទៅ ក្នុងទីណា មនាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព ចក្ខាយតនៈ របស់សត្វទាំងនោះ រលត់ទៅ ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយចក្ខុ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះរលត់ទៅផង មនាយតនៈ នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា ( រលត់ទៅ ) ក្នុងទីណា ។បេ។

[ ៦២៧ ] ចក្ខាយតនៈ របស់សត្វណា រលត់ទៅ ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព ចក្ខាយតនៈ របស់សត្វទាំងនោះ រលត់ទៅ ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយចក្ខុ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះរលត់ទៅផង ធម្មាយតនៈ នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ រលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចក្ខុ កាលចាប់

បដិសន្ធិ កាលច្យុត ធម្មាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលច្យុត ធម្មាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅផង ចក្ខាយតនៈ រលត់ទៅផង ក្នុងទីនោះ ។

[ ៦២៨ ] ឃានាយតនៈរបស់សត្វណា រលត់ទៅ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងកាមាវចរភព ឃានាយតនៈ របស់សត្វទាំងនោះ រលត់ទៅ ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយឃានៈ កាលច្យុត ឃានាយតនៈ របស់សត្វទាំងនោះ រលត់ទៅផង រូបាយតនៈ នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា ( រលត់ទៅ ) ក្នុងទីណា ។បេ។

[ ៦២៩ ] ឃានាយតនៈ របស់សត្វណា រលត់ទៅ ក្នុងទីណា មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងកាមាវចរភព ឃានាយតនៈ របស់សត្វទាំងនោះ រលត់ទៅ ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយឃានៈ កាលច្យុត ឃានាយតនៈ របស់សត្វទាំងនោះ រលត់ទៅផង ធម្មាយតនៈ នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា ( រលត់ទៅ ) ក្នុងទីណា ។បេ។

[ ៦៣០ ] រូបាយតនៈ របស់សត្វណា រលត់ទៅ ក្នុងទីណា មនាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព កាលច្យុតចាកអសញ្ញសត្វ រូបាយតនៈ របស់សត្វទាំងនោះ រលត់ទៅ ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វក្រៅនេះ កាលច្យុតចាកបញ្ចវោការភព រូបាយតនៈ របស់សត្វទាំងនោះ រលត់ទៅផង មនាយតនៈ នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា ( រលត់ទៅ ) ក្នុងទីណា ។បេ។

[ ៦៣១ ] រូបាយតនៈ របស់សត្វណា រលត់ទៅ ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព រូបាយតនៈ របស់សត្វទាំងនោះ រលត់ទៅ ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយរូប កាលច្យុត រូបាយតនៈ របស់សត្វទាំងនោះ រលត់ទៅផង ធម្មាយតនៈ នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ រលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានរូប កាលចាប់បដិសន្ធិ កាលច្យុត ធម្មាយតនៈរបស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែរូបាយតនៈរបស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយរូប កាលច្យុត ធម្មាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅផង រូបាយតនៈ រលត់ទៅផង ក្នុងទីនោះ ។

[ ៦៣២ ] មនាយតនៈរបស់សត្វណា រលត់ទៅ ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វាន មនាយតនៈ របស់សត្វទាំងនោះ រលត់ទៅ ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយចិត្ត កាលច្យុត មនាយតនៈ របស់សត្វទាំងនោះ រលត់ទៅផង ធម្មាយតនៈ នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា មនាយតនៈ របស់សត្វនោះ រលត់ទៅក្នុងទីនោះដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចិត្ត កាលចាប់បដិសន្ធិ កាលច្យុត ធម្មាយតនៈរបស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយចិត្ត កាលច្យុត ធម្មាយតនៈរបស់សត្វទាំងនោះ នឹងរលត់ទៅផង មនាយតនៈ រលត់ទៅផង ក្នុងទីនោះ ។

[ ៦៣៣ ] ចក្ខាយតនៈ របស់សត្វណា មិនរលត់ទៅ សោតាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅទេឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចក្ខុ កាលចាប់បដិសន្ធិ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ តែសោតាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ ពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅផង សោតាយតនៈ នឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ចក្ខាយតនៈ របស់សត្វ

នោះ មិនរលត់ទៅទេឬ ។ បណ្តាពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលច្យុត សោតាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វដែលកើតក្នុងបច្ឆិម-ភព ក្នុងអរូបភព សោតាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ចក្ខាយតនៈ មិនរលត់ទៅផង ។

[ ៦៣៤ ] ចក្ខាយតនៈ របស់សត្វណា មិនរលត់ទៅ ឃានាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅទេឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចក្ខុ កាលចាប់បដិសន្ធិ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ តែឃានាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ ពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់រូបាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ចក្ខាយតនៈរបស់សត្វទាំងនោះ មិនរលត់ទៅផង ឃានាយតនៈ នឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត ឃានាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ មិនរលត់ទៅទេឬ ។ បណ្តាពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព ពួកសត្វណា ចូលទៅកាន់រូបាវចរភព និងកាន់អរូបាវចរភពហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលច្យុត ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់រូបាវចរភព និងពួកសត្វ ដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព

ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ចក្ខាយតនៈ មិនរលត់ទៅផង ។

[ ៦៣៥ ] ចក្ខាយតនៈ របស់សត្វណា មិនរលត់ទៅ រូបាយតនៈរបស់សត្វនោះ នឹងមិនរលត់ទៅទេឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចក្ខុ កាលចាប់បដិសន្ធិ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ ពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅផង រូបាយតនៈ នឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត រូបាយតនៈរបស់សត្វណា នឹងមិនរលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ មិនរលត់ទៅទេឬ ។ បណ្តាពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលច្យុត រូបាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព រូបាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ចក្ខាយតនៈ មិនរលត់ទៅផង ។

[ ៦៣៦ ] ចក្ខាយតនៈ របស់សត្វណា មិនរលត់ទៅ មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅទេឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលចាប់បដិសន្ធិ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ ពួកសត្វ កាលបរិនិព្វាន ក្នុងអរូបភព ចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់

ទៅផង ធម្មាយតនៈ នឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅទេឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព ធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វ កាលបរិនិព្វានក្នុងអរូបភព ធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ចក្ខាយតនៈ មិនរលត់ទៅផង ។

[ ៦៣៧ ] ឃានាយតនៈរបស់សត្វណា មិនរលត់ទៅ រូបាយតនៈរបស់សត្វនោះ នឹងមិនរលត់ទៅទេឬ ។ ពួកសត្វទាំងអស់ ដែលមិនមានឃានៈ កាលចាប់បដិសន្ធិ កាលច្យុត ឃានាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ ពួកសត្វ កាលបរិនិព្វានក្នុងរូបាវចរភព និងពួកសត្វ ដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ឃានាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅផង រូបាយតនៈ នឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា មិនរលត់ទៅ ឃានាយតនៈ របស់សត្វនោះ មិនរលត់ទៅទេឬ ។ បណ្តាពួកសត្វ កាលបរិនិព្វានក្នុងកាមាវចរភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលច្យុត រូបាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ តែឃានាយតនៈរបស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វ កាលបរិនិព្វានក្នុងរូបាវចរភព និងពួកសត្វ ដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព រូបាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ឃានា-

យតនៈ មិនរលត់ទៅផង ។

[ ៦៣៨ ] ឃានាយតនៈរបស់សត្វណា មិនរលត់ទៅ មនាយតនៈ ។បេ។ ធម្មាយតនៈរបស់សត្វនោះ នឹងមិនរលត់ទៅទេឬ ។ ពួកសត្វទាំងអស់ ដែលមិនមានឃានៈ កាលចាប់បដិសន្ធិ កាលច្យុត ឃានាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ តែធម្មាយតនៈរបស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ ពួកសត្វ កាលបរិនិព្វានក្នុងរូបាវចរភព និងក្នុងអរូបាវចរភព ឃានាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅផង ធម្មាយតនៈ នឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត ធម្មាយតនៈរបស់សត្វណា នឹងមិនរលត់ទៅ ឃានាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅទេឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងកាមាវចរភព ធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ តែឃានាយតនៈរបស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វ កាលបរិនិព្វានក្នុងរូបាវចរភព ធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ឃានាយតនៈ មិនរលត់ទៅផង ។

[ ៦៣៩ ] រូបាយតនៈរបស់សត្វណា មិនរលត់ទៅ មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅទេឬ ។ ពួកសត្វទាំងអស់ដែលមិនមានរូប កាលចាប់បដិសន្ធិ កាលច្យុត រូបាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ ពួកសត្វ កាលបរិនិព្វាន ក្នុងអរូបភព រូបាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅផង ធម្មាយតនៈ នឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត ធម្មា-

យតនៈ របស់សត្វណា នឹងមិនរលត់ទៅ រូបាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅទេឬ ។ ពួកសត្វ កាលបរិនិព្វាន ក្នុងបញ្ចវោការភព ធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វ កាលបរិនិព្វាន ក្នុងអរូបភព ធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង រូបាយតនៈ មិនរលត់ទៅផង ។

[ ៦៤០ ] មនាយតនៈរបស់សត្វណា មិនរលត់ទៅ ធម្មាយតនៈរបស់សត្វនោះ នឹងមិនរលត់ទៅទេឬ ។ នឹងរលត់ទៅ ។ មួយយ៉ាងទៀត ធម្មាយតនៈរបស់សត្វណា នឹងមិនរលត់ទៅ មនាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅទេឬ ។ រលត់ទៅ ។

[ ៦៤១ ] ចក្ខាយតនៈ មិនរលត់ទៅ ក្នុងទីណា ។បេ។

[ ៦៤២ ] ចក្ខាយតនៈ របស់សត្វណា មិនរលត់ទៅ ក្នុងទីណា សោតាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលចូលទៅកាន់បញ្ចវោការភព កាលច្យុតចាកកាមាវចរភព ចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះ តែសោតាយតនៈរបស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ចក្ខាយតនៈ របស់ពួកអសញ្ញសត្វ និងរបស់ពួកអរូបព្រហ្មនោះ មិនរលត់ទៅផង សោតាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ មិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វ កាលបរិនិព្វានក្នុង

បញ្ចវោការភព សោតាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅ ក្នុងទីនោះទេ សោតាយតនៈ របស់ពួកអសញ្ញសត្វ និងរបស់ពួកអរូបព្រហ្មនោះ នឹងមិនរលត់ទៅផង ចក្ខាយតនៈ មិនរលត់ទៅផង ក្នុងទីនោះ ។

[ ៦៤៣ ] ចក្ខាយតនៈ របស់សត្វណា មិនរលត់ទៅ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលចូលទៅកាន់កាមាវចរភព កាលច្យុតចាកកាមាវចរភព ចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វកាលចូលទៅកាន់រូបាវចរភព ពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម ចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅផង ឃានាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ឃានាយតនៈរបស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ មិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វកាលបរិនិព្វានក្នុងកាមាវចរភព កាលច្យុតចាកកាមាវចរភព ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលចូលទៅកាន់រូបាវចរភព ពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ចក្ខាយតនៈ មិនរលត់ទៅផង ក្នុងទីនោះ ។

[ ៦៤៤ ] ចក្ខាយតនៈ របស់សត្វណា មិនរលត់ទៅ ក្នុងទីណា រូបា-

យតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វ ដែលមិនមានចក្ខុ កាលចូលទៅកាន់បញ្ចវោការភព កាលច្យុតចាកកាមាវចរភព និងពួកអសញ្ញសត្វ ចក្ខាយតនៈរបស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ចក្ខាយតនៈ របស់ពួកអរូបព្រហ្មនោះ មិនរលត់ទៅផង រូបាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ មិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វ កាលបរិនិព្វាន ក្នុងបញ្ចវោការភព រូបាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅ ក្នុងទីនោះទេ រូបាយតនៈ របស់ពួកអរូបព្រហ្មនោះ នឹងមិនរលត់ទៅផង ចក្ខាយតនៈ មិនរលត់ទៅផង ក្នុងទីនោះ ។

[ ៦៤៥ ] ចក្ខាយតនៈ របស់សត្វណា មិនរលត់ទៅ ក្នុងទីណា មនាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលចូលទៅកាន់បញ្ចវោការភព កាលច្យុតចាកកាមាវចរភព និងពួកអរូបព្រហ្ម ចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងអរូបភព និងពួកអសញ្ញសត្វ ចក្ខាយតនៈរបស់សត្វទាំងនោះ មិនរលត់ទៅផង មនាយតនៈ នឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ចក្ខាយតនៈ

របស់សត្វនោះ មិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព មនាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងអរូបភព និងពួកអសញ្ញសត្វ មនាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ចក្ខាយតនៈ មិនរលត់ទៅផង ក្នុងទីនោះ ។

[ ៦៤៦ ] ចក្ខាយតនៈ របស់សត្វណា មិនរលត់ទៅ ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចក្ខុ កាលចាប់បដិសន្ធិ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន ក្នុងអរូបភព ចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅផង ធម្មាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ មិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព ធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន ក្នុងអរូបភព ធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ចក្ខាយតនៈ មិនរលត់ទៅផង ក្នុងទីនោះ ។

[ ៦៤៧ ] ឃានាយតនៈ របស់សត្វណា មិនរលត់ទៅ ក្នុងទីណា រូបា-

យតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វដែល មិនមានឃានៈ កាលចូលទៅកាន់កាមាវចរភព និងពួកសត្វ ជារូបាវចរ កាល ច្យុតចាកកាមាវចរភព ឃានាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុង ទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទី នោះទេ ពួកសត្វ កាលបរិនិព្វានក្នុងរូបាវចរភព និងពួកអរូបព្រហ្ម ឃានា-យតនៈ របស់សត្វទាំងនោះ មិនរលត់ទៅផង រូបាយតនៈ នឹងមិនរលត់ទៅ ផង ក្នុងទីនោះ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងមិនរលត់ ទៅ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ មិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងកាមាវចរភព រូបាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំងនោះ មិនមែន ជាមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងរូបាវចរភព និង ពួកអរូបព្រហ្ម រូបាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ឃានា-យតនៈ មិនរលត់ទៅផង ក្នុងទីនោះ ។

[ ៦៤៨ ] ឃានាយតនៈរបស់សត្វណា មិនរលត់ទៅ ក្នុងទីណា មនា-យតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វដែល មិនមានឃានៈ កាលចូលទៅកាន់កាមាវចរភព និងពួកសត្វជារូបាវចរ និង ជាអរូបាវចរ កាលច្យុតចាកកាមាវចរភព ឃានាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹង មិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន ក្នុងរូបាវចរភព និងក្នុង

អរូបាវចរភព និងពួកអសញ្ញសត្វ ឃានាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅផង មនាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈរបស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ឃានាយតនៈរបស់សត្វនោះ មិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងកាមាវចរភព មនាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងរូបាវចរភព និងក្នុងអរូបាវចរភព និងពួកអសញ្ញសត្វ មនាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ឃានាយតនៈ មិនរលត់ទៅផង ក្នុងទីនោះ ។

[ ៦៤៩ ] ឃានាយតនៈរបស់សត្វណា មិនរលត់ទៅ ក្នុងទីណា ធម្មាយតនៈរបស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វទាំងអស់ដែលមិនមានឃានៈ កាលចាប់បដិសន្ធិ កាលច្យុត ឃានាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន ក្នុងរូបាវចរភព និងក្នុងអរូបាវចរភព ឃានាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅផង ធម្មាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ មិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វ កាលបរិនិព្វាន ក្នុងកាមាវចរភព ធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ តែឃានាយតនៈ

របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាល បរិនិព្វាន ក្នុងរូបាវចរភព និងក្នុងអរូបាវចរភព ធម្មាយតនៈ របស់សត្វទាំង នោះ នឹងមិនរលត់ទៅផង ឃានាយតនៈ មិនរលត់ទៅផង ក្នុងទីនោះ ។

[ ៦៥០ ] រូបាយតនៈ របស់សត្វណា មិនរលត់ទៅ ក្នុងទីណា មនាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វ កាល ចូលទៅកាន់បញ្ចវោការភព និងពួកអរូបព្រហ្ម រូបាយតនៈ របស់សត្វទាំង នោះ មិនរលត់ទៅ ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនមែនជា នឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន ក្នុងអរូបភព កាល ចូលទៅកាន់អសញ្ញសត្វ រូបាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅផង មនាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ មិន រលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព កាល ច្យុតចាកអសញ្ញសត្វ មនាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុង ទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅ ក្នុងទីនោះ ទេ ពួកសត្វ កាលបរិនិព្វានក្នុងអរូបភព កាលចូលទៅកាន់អសញ្ញសត្វ មនាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង រូបាយតនៈ មិន រលត់ទៅផង ក្នុងទីនោះ ។

[ ៦៥១ ] រូបាយតនៈ របស់សត្វណា មិនរលត់ទៅ ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វទាំងអស់

ដែលមិនមានរូប កាលចាប់បដិសន្ធិ កាលច្យុត រូបាយតនៈ របស់សត្វទាំង នោះ មិនរលត់ទៅ ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជា នឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងអរូបភព រូបាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅផង ធម្មាយតនៈ នឹងមិនរលត់ទៅផង ក្នុង ទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុង ទីណា រូបាយតនៈ របស់សត្វនោះ មិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព ធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិន រលត់ទៅ ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន ក្នុងអរូបភព ធម្មាយតនៈ របស់ សត្វទាំងនោះ នឹងមិនរលត់ទៅផង រូបាយតនៈ មិនរលត់ទៅផង ក្នុងទីនោះ ។

[ ៦៥២ ] មនាយតនៈ របស់សត្វណា មិនរលត់ទៅ ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ នឹងរលត់ទៅ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា មនាយតនៈ របស់សត្វនោះ មិនរលត់ទៅ ក្នុងទីនោះទេឬ ។ រលត់ទៅ ។

[ ៦៥៣ ] ចក្ខាយតនៈ របស់សត្វណា រលត់ទៅហើយ សោតាយតនៈ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ បណ្ដាពួកសត្វ កាលបរិនិព្វាន ក្នុង បញ្ចវោការភព និងពួកសត្វ ដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ពួកសត្វ ណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ រលត់ទៅហើយ តែសោតាយតនៈ របស់

សត្វទាំងនោះ នឹងមិនរលត់ទៅទេ ចក្ខាយតនៈ របស់សត្វទាំងនោះ ក្រៅនេះ រលត់ទៅហើយផង សោតាយតនៈ នឹងរលត់ទៅផង ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា នឹងរលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ រលត់ទៅហើយឬ ។ អើ ។

[ ៦៥៤ ] ចក្ខាយតនៈ របស់សត្វណា រលត់ទៅហើយ ឃានាយតនៈ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ បណ្ដាពួកសត្វ កាលបរិនិព្វាន ក្នុងកាមាវចរភព និងពួកសត្វ ដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងក្នុងអរូបាវចរភព ពួកសត្វណា ចូលទៅកាន់រូបាវចរភព និងកាន់អរូបាវចរភពហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ រលត់ទៅហើយ តែឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ចក្ខាយតនៈរបស់សត្វទាំងនោះ ក្រៅនេះ រលត់ទៅហើយផង ឃានា-យតនៈ នឹងរលត់ទៅផង ។ មួយយ៉ាងទៀត ឃានាយតនៈ របស់សត្វណា ។បេ។ អើ ។

[ ៦៥៥ ] ចក្ខាយតនៈ របស់សត្វណា រលត់ទៅហើយ រូបាយតនៈ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ បណ្ដាពួកសត្វ កាលបរិនិព្វាន ក្នុងបញ្ចវោការភព និងពួកសត្វ ដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ រលត់ទៅហើយ តែរូបាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ចក្ខាយតនៈ របស់សត្វទាំងនោះ ក្រៅនេះ រលត់

ទៅហើយផង រូបាយតនៈ នឹងរលត់ទៅផង ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា ។បេ។ អើ ។

[ ៦៥៦ ] ចក្ខាយតនៈ របស់សត្វណា រលត់ទៅហើយ មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ ពួកសត្វ កាលបរិនិព្វាន ចក្ខាយតនៈ របស់សត្វទាំងនោះ រលត់ទៅហើយ តែធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ចក្ខាយតនៈ របស់សត្វទាំងនោះ ក្រៅនេះ រលត់ទៅហើយផង ធម្មាយតនៈ នឹងរលត់ទៅផង ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា ។បេ។ អើ ។

[ ៦៥៧ ] ឃានាយតនៈ របស់សត្វណា រលត់ទៅហើយ រូបាយតនៈ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ បណ្ដាពួកសត្វ កាលបរិនិព្វាន ក្នុងបញ្ចវោការភព និងពួកសត្វ ដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលច្យុត ឃានាយតនៈ របស់សត្វទាំងនោះ រលត់ទៅហើយ តែរូបាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ឃានាយតនៈ របស់សត្វទាំងនោះ ក្រៅនេះ រលត់ទៅហើយផង រូបាយតនៈ នឹងរលត់ទៅផង ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា ។បេ។ អើ ។

[ ៦៥៨ ] ឃានាយតនៈ របស់សត្វណា រលត់ទៅហើយ មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ ពួកសត្វ កាលបរិនិព្វាន ឃានាយតនៈ របស់សត្វទាំងនោះ រលត់ទៅហើយ តែធម្មាយតនៈ

របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ឃានាយតនៈ របស់សត្វទាំងនោះ ក្រៅនេះ រលត់ទៅហើយផង ធម្មាយតនៈ នឹងរលត់ទៅផង ។ មួយយ៉ាង ទៀត ធម្មាយតនៈ របស់សត្វណា ។បេ។ អើ ។

[ ៦៥៩ ] រូបាយតនៈ របស់សត្វណា រលត់ទៅហើយ មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅដែរឬ ។ ពួកសត្វកាល បរិនិព្វាន រូបាយតនៈ របស់សត្វទាំងនោះ រលត់ទៅហើយ តែធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ រូបាយតនៈ របស់សត្វទាំងនោះ ក្រៅនេះ រលត់ទៅហើយផង ធម្មាយតនៈ នឹងរលត់ទៅផង ។ មួយយ៉ាង ទៀត ធម្មាយតនៈ របស់សត្វណា ។បេ។ អើ ។

[ ៦៦០ ] មនាយតនៈ របស់សត្វណា រលត់ទៅហើយ ធម្មាយតនៈ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ ពួកសត្វ កាលបរិនិព្វាន មនាយតនៈ របស់សត្វទាំងនោះ រលត់ទៅហើយ តែធម្មាយតនៈ របស់សត្វទាំងនោះ នឹង មិនរលត់ទៅទេ មនាយតនៈ របស់សត្វទាំងនោះ ក្រៅនេះ រលត់ទៅហើយ ផង ធម្មាយតនៈ នឹងរលត់ទៅផង ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់ សត្វណា ។បេ។ អើ ។

[ ៦៦១ ] ចក្ខាយតនៈ រលត់ហើយ ក្នុងទីណា ។បេ។

[ ៦៦២ ] ចក្ខាយតនៈរបស់សត្វណា រលត់ហើយ ក្នុងទីណា សោតា- យតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាល បរិនិព្វាន ក្នុងបញ្ចវោការភព ចក្ខាយតនៈ របស់សត្វទាំងនោះ រលត់ទៅហើយ

ក្នុងទីនោះ តែសោតាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ ចក្ខាយតនៈ របស់ពួកសត្វ ជាបញ្ចវោការនោះ ក្រៅនេះ រលត់ហើយផង សោតាយតនៈ នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ រលត់ហើយ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស សោតាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែចក្ខាយតនៈរបស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះទេ សោតាយតនៈ របស់ពួកសត្វជាបញ្ចវោការនោះ ក្រៅនេះ នឹងរលត់ទៅផង ចក្ខាយតនៈ រលត់ហើយផង ក្នុងទីនោះ ។

[ ៦៦៣ ] ចក្ខាយតនៈ របស់សត្វណា រលត់ហើយ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វាន ក្នុងកាមាវចរភព និងពួកសត្វជារូបាវចរ ចក្ខាយតនៈ របស់សត្វទាំងនោះ រលត់ទៅហើយ ក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ ចក្ខាយតនៈ របស់ពួកសត្វជាកាមាវចរនោះ ក្រៅនេះ រលត់ហើយផង ឃានាយតនៈ នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ឃានាយតនៈ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ រលត់ហើយ ក្នុងទីនោះដែរឬ ។ អើ ។

[ ៦៦៤ ] ចក្ខាយតនៈ របស់សត្វណា រលត់ហើយ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាល

បរិនិព្វាន ក្នុងបញ្ចវោការភព ចក្ខាយតនៈ របស់សត្វទាំងនោះ រលត់ហើយ ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ ចក្ខាយតនៈ របស់ពួកសត្វ ជាបញ្ចវោការនោះ ក្រៅនេះ រលត់ហើយផង រូបាយតនៈ នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត រូបាយតនៈរបស់សត្វណា នឹងរលត់ទៅ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ រលត់ហើយ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស និងពួកអសញ្ញសត្វ រូបាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែចក្ខាយតនៈរបស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះទេ រូបាយតនៈ របស់ពួកសត្វ ជាបញ្ចវោការនោះ ក្រៅនេះ នឹងរលត់ទៅផង ចក្ខាយតនៈ រលត់ហើយផង ក្នុងទីនោះ ។

[ ៦៦៥ ] ចក្ខាយតនៈ របស់សត្វណា រលត់ហើយ ក្នុងទីណា មនាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វាន ក្នុងបញ្ចវោការភព ចក្ខាយតនៈ របស់សត្វទាំងនោះ រលត់ហើយ ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ ចក្ខាយតនៈ របស់ពួកសត្វ ជាបញ្ចវោការនោះ ក្រៅនេះ រលត់ហើយផង មនាយតនៈ នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ រលត់ហើយ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស និងពួកអរូបព្រហ្ម មនាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែ

ចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះទេ មនាយតនៈ របស់ពួកសត្វ ជាបញ្ចវោការនោះ ក្រៅនេះ នឹងរលត់ទៅផង ចក្ខាយតនៈ រលត់ហើយផង ក្នុងទីនោះ ។

[ ៦៦៦ ] ចក្ខាយតនៈ របស់សត្វណា រលត់ហើយ ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វាន ក្នុងបញ្ចវោការភព ចក្ខាយតនៈ របស់សត្វទាំងនោះ រលត់ហើយ ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ ចក្ខាយតនៈ របស់ពួកសត្វ ជាបញ្ចវោការនោះ ក្រៅនេះ រលត់ហើយផង ធម្មាយតនៈ នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈរបស់សត្វណា នឹងរលត់ទៅ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ រលត់ហើយ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស ពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម ធម្មាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែចក្ខាយតនៈរបស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះទេ ធម្មាយតនៈ របស់ពួកសត្វ ជាបញ្ចវោការនោះ ក្រៅនេះ នឹងរលត់ទៅផង ចក្ខាយតនៈ រលត់ហើយផង ក្នុងទីនោះ ។

[ ៦៦៧ ] ឃានាយតនៈ របស់សត្វណា រលត់ហើយ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វាន ក្នុងកាមាវចរភព ឃានាយតនៈ របស់សត្វទាំងនោះ រលត់ហើយ ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ

យានាយតនៈ របស់ពួកសត្វ ជាកាមាវចរនោះ ក្រៅនេះ រលត់ហើយផង រូបាយតនៈ នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត រូបាយតនៈរបស់សត្វណា នឹងរលត់ទៅ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ រលត់ហើយ ក្នុងទីនោះដែរឬ ។ រូបាយតនៈ របស់ពួកសត្វ ជារូបាវចរនោះ នឹងរលត់ទៅ ក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះទេ រូបាយតនៈ របស់ពួកសត្វ ជាកាមាវចរនោះ នឹងរលត់ទៅផង ឃានាយតនៈ រលត់ហើយផង ក្នុងទីនោះ ។

[ ៦៦៨ ] ឃានាយតនៈ របស់សត្វណា រលត់ហើយ ក្នុងទីណា មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងកាមាវចរភព ឃានាយតនៈ របស់សត្វទាំងនោះ រលត់ហើយ ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ ឃានាយតនៈ របស់ពួកសត្វជាកាមាវចរនោះ ក្រៅនេះ រលត់ហើយផង ធម្មាយតនៈ នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ រលត់ហើយ ក្នុងទីនោះដែរឬ ។ ធម្មាយតនៈ របស់ពួកសត្វជារូបាវចរ និងជាអរូបាវចរនោះ នឹងរលត់ទៅ ក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះទេ ធម្មាយតនៈ របស់ពួកសត្វ ជាកាមាវចរនោះ នឹងរលត់ទៅផង ឃានាយតនៈ រលត់ហើយផង ក្នុងទីនោះ ។

[ ៦៦៩ ] រូបាយតនៈ របស់សត្វណា រលត់ហើយ ក្នុងទីណា មនា-

យតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព និងពួកអសញ្ញសត្វ រូបាយតនៈ របស់សត្វទាំងនោះ រលត់ហើយ ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ រូបាយតនៈ របស់ពួកសត្វ ជាបញ្ចវោការនោះ ក្រៅនេះ រលត់ហើយផង មនាយតនៈ នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ រលត់ហើយ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស និងពួកអរូបព្រហ្ម មនាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះទេ មនាយតនៈ របស់ពួកសត្វ ជាបញ្ចវោការនោះ ក្រៅនេះ នឹងរលត់ទៅផង រូបាយតនៈ រលត់ហើយផង ក្នុងទីនោះ ។

[ ៦៧០ ] រូបាយតនៈ របស់សត្វណា រលត់ហើយ ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វាន ក្នុងបញ្ចវោការភព រូបាយតនៈ របស់សត្វទាំងនោះ រលត់ហើយ ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ រូបាយតនៈ របស់ពួកសត្វជាបញ្ចវោការ និងពួកអសញ្ញសត្វនោះ ក្រៅនេះ រលត់ហើយផង ធម្មាយតនៈ នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ រលត់ហើយ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស

និងពួកអរូបព្រហ្ម ធម្មាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះទេ ធម្មាយតនៈ របស់ពួកសត្វ ជាបញ្ចវោការ និងពួកអសញ្ញសត្វនោះ ក្រៅនេះ នឹងរលត់ទៅផង រូបាយតនៈ រលត់ហើយផង ក្នុងទីនោះ ។

[ ៦៧១ ] មនាយតនៈ របស់សត្វណា រលត់ហើយ ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលបរិនិព្វាន មនាយតនៈ របស់សត្វទាំងនោះ រលត់ហើយ ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ មនាយតនៈរបស់ពួកសត្វ ជាចតុវោការ និងជាបញ្ចវោការនោះ ក្រៅនេះ រលត់ហើយផង ធម្មាយតនៈ នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា មនាយតនៈ របស់សត្វនោះ រលត់ហើយ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស និងពួកអសញ្ញសត្វ ធម្មាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះទេ ធម្មាយតនៈ របស់ពួកសត្វជាចតុវោការ និងជាបញ្ចវោការនោះ ក្រៅនេះ នឹងរលត់ទៅផង មនាយតនៈ រលត់ហើយផង ក្នុងទីនោះ ។

[ ៦៧២ ] ចក្ខាយតនៈរបស់សត្វណា មិនរលត់ហើយ សោតាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅទេឬ ។ មិនមានទេ ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ មិន

រលត់ហើយឬ ។ រលត់ហើយ ។

[ ៦៧៣ ] ចក្ខាយតនៈ របស់សត្វណា មិនរលត់ហើយ ឃានាយតនៈ ។បេ។ រូបាយតនៈ មនាយតនៈ ធម្មាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅទេឬ ។ មិនមានទេ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ មិនរលត់ទៅហើយឬ ។ រលត់ហើយ ។

[ ៦៧៤ ] ឃានាយតនៈ ។បេ។ រូបាយតនៈ មនាយតនៈ របស់សត្វណា មិនរលត់ហើយ ធម្មាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅទេឬ ។ មិនមានទេ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ មនាយតនៈ របស់សត្វនោះ មិនរលត់ហើយឬ ។ រលត់ហើយ ។

[ ៦៧៥ ] ចក្ខាយតនៈ មិនរលត់ហើយ ក្នុងទីណា ។បេ។

[ ៦៧៦ ] ចក្ខាយតនៈរបស់សត្វណា មិនរលត់ហើយ ក្នុងទីណា សោតាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស ចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះ តែសោតាយតនៈ របស់សត្វនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងសុទ្ធាវាស ពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម ចក្ខាយតនៈរបស់សត្វទាំងនោះ មិនរលត់ហើយផង សោតាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះទេឬ ។ ពួកសត្វ កាលបរិនិព្វាន ក្នុងបញ្ចវោការភព សោតាយតនៈ

របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន ក្នុងសុទ្ធាវាស ពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម សោតាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ចក្ខាយតនៈ មិនរលត់ហើយផង ក្នុងទីនោះ ។

[ ៦៧៧ ] ចក្ខាយតនៈរបស់សត្វណា មិនរលត់ហើយ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ អើ ។ មួយយ៉ាងទៀត ឃានាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះទេឬ ។ ពួកសត្វ កាលបរិនិព្វាន ក្នុងកាមាវចរភព និងពួកសត្វជារូបាវចរ ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយ ក្នុងទីនោះទេ ឃានាយតនៈ របស់ពួកសុទ្ធាវាសសត្វ របស់ពួកអសញ្ញសត្វ របស់ពួកអរូបព្រហ្មនោះ នឹងមិនរលត់ទៅផង ចក្ខាយតនៈ មិនរលត់ហើយផង ក្នុងទីនោះ ។

[ ៦៧៨ ] ចក្ខាយតនៈ របស់សត្វណា មិនរលត់ហើយ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វកាលចូលទៅកាន់សុទ្ធាវាស និងពួកអសញ្ញសត្វ ចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន ក្នុងសុទ្ធាវាស និងពួកអរូបព្រហ្ម ចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយផង រូបាយតនៈ

នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត រូបាយតនៈរបស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ចក្ខាយតនៈរបស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះទេឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព រូបាយតនៈរបស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ តែចក្ខាយតនៈរបស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងសុទ្ធាវាស និងពួកអរូបព្រហ្ម រូបាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ចក្ខាយតនៈ មិនរលត់ហើយផង ក្នុងទីនោះ ។

[ ៦៧៩ ] ចក្ខាយតនៈ របស់សត្វណា មិនរលត់ហើយ ក្នុងទីណា មនាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស និងពួកអរូបព្រហ្ម ចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងសុទ្ធាវាស កាលបរិនិព្វានក្នុងអរូបភព និងពួកអសញ្ញសត្វ ចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយផង មនាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះទេឬ ។ ពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព មនាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងសុទ្ធាវាស កាលបរិ-

និព្វាន ក្នុងអរូបភព និងពួកអសញ្ញសត្វ មនាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ចក្ខាយតនៈ មិនរលត់ហើយផង ក្នុងទីនោះ ។

[ ៦៨០ ] ចក្ខាយតនៈ របស់សត្វណា មិនរលត់ហើយ ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស ពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម ចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វ ទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន ក្នុងសុទ្ធាវាស កាលបរិនិព្វាន ក្នុងអរូបភព ចក្ខាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយផង ធម្មាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះទេឬ ។ ពួកសត្វ កាលបរិនិព្វាន ក្នុងបញ្ចវោការភព ធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន ក្នុងសុទ្ធាវាស កាលបរិនិព្វានក្នុងអរូបភព ធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ចក្ខាយតនៈ មិនរលត់ហើយផង ក្នុងទីនោះ ។

[ ៦៨១ ] ឃានាយតនៈ របស់សត្វណា មិនរលត់ហើយ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ឃានាយតនៈ របស់ពួកសត្វជារូបាវចរនោះ មិនរលត់ហើយ ក្នុងទីនោះ តែរូបាយតនៈរបស់

សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន ក្នុងរូបាវចរភព និងពួកអរូបព្រហ្ម ឃានាយតនៈរបស់សត្វទាំងនោះ មិនរលត់ហើយផង រូបាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ឃានាយតនៈរបស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះទេឬ ។ ពួកសត្វ កាលបរិនិព្វាន ក្នុងកាមាវចរភព រូបាយតនៈរបស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងរូបាវចរភព និងពួកអរូបព្រហ្ម រូបាយតនៈរបស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ឃានាយតនៈ មិនរលត់ហើយផង ក្នុងទីនោះ ។

[ ៦៨២ ] ឃានាយតនៈ របស់សត្វណា មិនរលត់ហើយ ក្នុងទីណា មនាយតនៈរបស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ឃានាយតនៈ របស់ពួកសត្វ ជារូបាវចរ និងជាអរូបាវចរនោះ មិនរលត់ហើយ ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន ក្នុងរូបាវចរភព និងក្នុងអរូបាវចរភព និងពួកអសញ្ញសត្វ ឃានាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយផង មនាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះទេឬ ។ ពួកសត្វ កាលបរិនិព្វាន ក្នុងកាមាវចរភព

មនាយតនៈរបស់ សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងរូបាវចរភព និងក្នុងអរូបាវចរភព និងពួកអសញ្ញសត្វ មនាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ឃានាយតនៈ មិនរលត់ហើយផង ក្នុងទីនោះ ។

[ ៦៨៣ ] ឃានាយតនៈ របស់សត្វណា មិនរលត់ហើយ ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វជារូបាវចរ និងជាអរូបាវចរ ឃានាយតនៈរបស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះ តែធម្មាយតនៈរបស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន ក្នុងរូបាវចរភព និងក្នុងអរូបាវចរភព ឃានាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយផង ធម្មាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះទេឬ ។ ពួកសត្វ កាលបរិនិព្វាន ក្នុងកាមាវចរភព ធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងរូបាវចរភព និងក្នុងអរូបាវចរភព ធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ឃានាយតនៈ មិនរលត់ហើយផង ក្នុងទីនោះ ។

[ ៦៨៤ ] រូបាយតនៈរបស់សត្វណា មិនរលត់ហើយ ក្នុងទីណា មនា-

យតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាល ចូលទៅកាន់សុទ្ធាវាស និងពួកអរូបព្រហ្ម រូបាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះ តែមនាយតនៈរបស់សត្វទាំងនោះ មិនមែនជានឹង មិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន ក្នុងសុទ្ធាវាស កាល បរិនិព្វាន ក្នុងអរូបភព រូបាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយផង មនាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ មិន រលត់ហើយ ក្នុងទីនោះទេឬ ។ ពួកសត្វ កាលបរិនិព្វាន ក្នុងបញ្ចវោការភព និងពួកអសញ្ញសត្វ មនាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទី នោះ តែរូបាយតនៈរបស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយ ក្នុងទីនោះ ទេ ពួកសត្វ កាលបរិនិព្វានក្នុងសុទ្ធាវាស កាលបរិនិព្វានក្នុងអរូបភព មនា-យតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង រូបាយតនៈ មិនរលត់ ហើយផង ក្នុងទីនោះ ។

[ ៦៨៥ ] រូបាយតនៈរបស់សត្វណា មិនរលត់ហើយ ក្នុងទីណា ធម្មា-យតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វ កាល ចូលទៅកាន់សុទ្ធាវាស និងពួកអរូបព្រហ្ម រូបាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះ តែធម្មាយតនៈរបស់សត្វទាំងនោះ មិនមែនជានឹង មិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន ក្នុងសុទ្ធាវាស កាល បរិនិព្វានក្នុងអរូបភព រូបាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយផង

ធម្មាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះទេឬ ។ ពួកសត្វ កាលបរិនិព្វាន ក្នុងបញ្ចវោការភព ធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន ក្នុងសុទ្ធាវាស កាលបរិនិព្វាន ក្នុងអរូបភព ធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង រូបាយតនៈ មិនរលត់ហើយផង ក្នុងទីនោះ ។

[ ៦៨៦ ] មនាយតនៈ របស់សត្វណា មិនរលត់ហើយ ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស និងពួកអសញ្ញសត្វ មនាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន ក្នុងសុទ្ធាវាស មនាយតនៈ របស់សត្វទាំងនោះ មិនរលត់ហើយផង ធម្មាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា មនាយតនៈ របស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះទេឬ ។ ពួកសត្វ កាលបរិនិព្វាន ធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន ក្នុងសុទ្ធាវាស ធម្មាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង មនាយតនៈ មិនរលត់ហើយផង

ក្នុងទីនោះ ។

និរោធវារៈ ចប់

[ ៦៨៧ ] ចក្ខាយតនៈ របស់សត្វណា កើតឡើង សោតាយតនៈ របស់សត្វនោះ រលត់ទៅដែរឬ ។ មិនមែនទេ ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា រលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ មិនមែនទេ ។

[ ៦៨៨ ] ចក្ខាយតនៈ របស់សត្វណា កើតឡើង ឃានាយតនៈ រូបាយតនៈ មនាយតនៈ ធម្មាយតនៈ របស់សត្វនោះ រលត់ទៅដែរឬ ។ មិនមែនទេ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា រលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ មិនមែនទេ ។បេ។

[ ៦៨៩ ] មនាយតនៈ របស់សត្វណា កើតឡើង ធម្មាយតនៈ របស់សត្វនោះ រលត់ទៅដែរឬ ។ មិនមែនទេ ។ មួយយ៉ាងទៀត ធម្មាយតនៈរបស់សត្វណា រលត់ទៅ មនាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ មិនមែនទេ ។

[ ៦៩០ ] ចក្ខាយតនៈ កើតឡើង ក្នុងទីណា ។បេ។ ប្រយោគដែលប្រកបដោយពាក្យថា ក្នុងទីណា បណ្ឌិតគប្បីធ្វើដោយពាក្យបដិសេធថា មិនមែន ឬមិនមានទេ ។ ប្រយោគដែលប្រកបដោយពាក្យថា ក្នុងទីណា បណ្ឌិតគប្បីធ្វើឲ្យដូចគ្នា និងពួកប្រយោគដែលថា ប្រកបក្នុងទីណា ក្រៅនេះ ប្រយោគដែលប្រកបដោយពាក្យថា ក្នុងទីណា ដូចគ្នា ក្នុងវារៈទាំងបី ។

[ ៦៩១ ] ចក្ខាយតនៈ របស់សត្វណា កើតឡើង ក្នុងទីណា សោតាយតនៈរបស់សត្វនោះ រលត់ទៅ ក្នុងទីនោះដែរឬ ។ មិនមែនទេ ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា រលត់ទៅ ក្នុងទីណា ចក្ខាយតនៈរបស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ មិនមែនទេ ។បេ។

[ ៦៩២ ] មនាយតនៈរបស់សត្វណា កើតឡើង ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ រលត់ទៅ ក្នុងទីនោះដែរឬ ។ មិនមែនទេ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា រលត់ទៅ ក្នុងទីណា មនាយតនៈ របស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ មិនមែនទេ ។

[ ៦៩៣ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើង សោតាយតនៈ របស់សត្វនោះ មិនរលត់ទៅទេឬ ។ ពួកសត្វ ដែលប្រកបដោយសោតៈ កាលច្យុត ចក្ខាយតនៈរបស់សត្វទាំងនោះ មិនកើតឡើង តែសោតាយតនៈរបស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វ ដែលមិនមានចក្ខុ មិនមានសោតៈ កាលចាប់បដិសន្ធិ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង សោតាយតនៈ មិនរលត់ទៅផង ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា មិនរលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើងទេឬ ។ ពួកសត្វ ដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ សោតាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ តែចក្ខាយតនៈរបស់ពួកសត្វនោះ មិនមែនជាមិនកើតឡើងទេ ពួកសត្វ ដែលមិនមានសោតៈ មិនមានចក្ខុ កាលច្យុត កាលចាប់បដិសន្ធិ សោតាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅផង

ចក្ខាយតនៈ មិនកើតឡើងផង ។

[ ៦៩៤ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើង ឃានាយតនៈ របស់សត្វនោះ មិនរលត់ទៅទេឬ ។ ពួកសត្វ ដែលប្រកបដោយឃានៈ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងទេ តែឃានាយតនៈរបស់ពួកសត្វនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វ ដែលមិនមានចក្ខុ មិនមានឃានៈ កាលចាប់បដិសន្ធិ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង ឃានាយតនៈ មិនរលត់ទៅផង ។ មួយយ៉ាងទៀត ឃានាយតនៈ របស់សត្វណា មិនរលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើងទេឬ ។ ពួកសត្វ ដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ ឃានាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ តែចក្ខាយតនៈ របស់សត្វនោះ មិនមែនជាមិនកើតឡើងទេ ពួកសត្វ ដែលមិនមានឃានៈ មិនមានចក្ខុ កាលច្យុត កាលចាប់បដិសន្ធិ ឃានាយតនៈរបស់សត្វទាំងនោះ មិនរលត់ទៅផង ចក្ខាយតនៈ មិនកើតឡើងផង ។

[ ៦៩៥ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើង រូបាយតនៈ របស់សត្វនោះ មិនរលត់ទៅទេឬ ។ ពួកសត្វ ដែលប្រកបដោយរូប កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង តែរូបាយតនៈ របស់ពួកសត្វនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វ ដែលមិនមានចក្ខុ មិនមានរូប កាលចាប់បដិសន្ធិ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង រូបាយតនៈ មិនរលត់ទៅផង ។ មួយយ៉ាងទៀត រូបាយតនៈ របស់

សត្វណា មិនរលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើងទេឬ ។ ពួកសត្វ ដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ រូបាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ពួកសត្វ ដែលមិនមានរូប មិនមានចក្ខុ កាលច្យុត កាលចាប់បដិសន្ធិ រូបាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅផង ចក្ខាយតនៈ មិនកើតឡើងផង ។

[ ៦៩៦ ] ចក្ខាយតនៈរបស់សត្វណា មិនកើតឡើង មនាយតនៈរបស់សត្វនោះ មិនរលត់ទៅទេឬ ។ ពួកសត្វ ដែលប្រកបដោយចិត្ត កាលច្យុត ចក្ខាយតនៈរបស់សត្វទាំងនោះ មិនកើតឡើង តែមនាយតនៈរបស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វ ដែលមិនមានចក្ខុ មិនមានចិត្ត កាលចាប់បដិសន្ធិ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង មនាយតនៈ មិនរលត់ទៅផង ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា មិនរលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើងទេឬ ។ ពួកសត្វ ប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ មនាយតនៈរបស់សត្វទាំងនោះ មិនរលត់ទៅ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ពួកសត្វ ដែលមិនមានចិត្ត មិនមានចក្ខុ កាលច្យុត កាលចាប់បដិសន្ធិ មនាយតនៈរបស់សត្វទាំងនោះ មិនរលត់ទៅផង ចក្ខាយតនៈ មិនកើតឡើងផង ។

[ ៦៩៧ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើង ធម្មាយតនៈ របស់សត្វនោះ មិនរលត់ទៅទេឬ ។ ពួកសត្វទាំងអស់ កាលច្យុត ចក្ខាយតនៈ

របស់សត្វទាំងនោះ មិនកើតឡើង តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វដែលមិនមានចក្ខុ កាលចាប់បដិសន្ធិ ចក្ខាយតនៈរបស់សត្វទាំងនោះ មិនកើតឡើងផង ធម្មាយតនៈ មិនរលត់ទៅផង ។ មួយយ៉ាងទៀត ធម្មាយតនៈរបស់សត្វណា មិនរលត់ទៅ ចក្ខាយតនៈរបស់សត្វនោះ មិនកើតឡើងទេឬ ។ ពួកសត្វ ដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ ធម្មាយតនៈរបស់សត្វទាំងនោះ មិនរលត់ទៅ តែចក្ខាយតនៈរបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ពួកសត្វ ដែលមិនមានចក្ខុ កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅផង ចក្ខាយតនៈ មិនកើតឡើងផង ។

[ ៦៩៨ ] ឃានាយតនៈរបស់សត្វណា មិនកើតឡើង រូបាយតនៈរបស់សត្វនោះ មិនរលត់ទៅទេឬ ។ ពួកសត្វ ដែលប្រកបដោយរូប កាលច្យុត ឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វ ដែលមិនមានឃានៈ មិនមានរូប កាលចាប់បដិសន្ធិ កាលច្យុត ឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង រូបាយតនៈ មិនរលត់ទៅផង ។ មួយយ៉ាងទៀត រូបាយតនៈរបស់សត្វណា មិនរលត់ទៅ ឃានាយតនៈ របស់សត្វនោះ មិនកើតឡើងទេឬ ។ ពួកសត្វ ដែលប្រកបដោយឃានៈ កាលចាប់បដិសន្ធិ រូបាយតនៈរបស់សត្វទាំងនោះ មិនរលត់ទៅ តែឃានាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ពួកសត្វ ដែលមិនមានរូប មិនមានឃានៈ កាលច្យុត

កាលចាប់បដិសន្ធិ រូបាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅផង ឃានា-យតនៈ មិនកើតឡើងផង ។

[ ៦៩៩ ] ឃានាយតនៈ របស់សត្វណា មិនកើតឡើង មនាយតនៈ របស់សត្វនោះ មិនរលត់ទៅទេឬ ។ ពួកសត្វ ដែលប្រកបដោយចិត្ត កាលច្យុត ឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង តែមនាយតនៈរបស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វ ដែលមិនមានឃានៈ មិនមានចិត្ត កាលចាប់បដិសន្ធិ កាលច្យុត ឃានាយតនៈរបស់សត្វទាំងនោះ មិនកើតឡើងផង មនាយតនៈ មិនរលត់ទៅផង ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា មិនរលត់ទៅ ឃានាយតនៈ របស់សត្វនោះ មិនកើតឡើងទេឬ ។ ពួកសត្វ ដែលប្រកបដោយឃានៈ កាលចាប់បដិសន្ធិ មនាយតនៈរបស់សត្វទាំងនោះ មិនរលត់ទៅ តែឃានាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ពួកសត្វ ដែលមិនមានចិត្ត មិនមានឃានៈ កាលច្យុត កាលចាប់បដិសន្ធិ មនាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅផង ឃានាយតនៈ មិនកើតឡើងផង ។

[ ៧០០ ] ឃានាយតនៈ របស់សត្វណា មិនកើតឡើង ធម្មាយតនៈ របស់សត្វនោះ មិនរលត់ទៅទេឬ ។ ពួកសត្វទាំងអស់ កាលច្យុត ឃានា-យតនៈ របស់សត្វទាំងនោះ មិនកើតឡើង តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វ ដែលមិនមានឃានៈ កាលចាប់បដិសន្ធិ ឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង ធម្មាយតនៈ មិនរលត់

ទៅផង ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា មិនរលត់ទៅ យានាយតនៈ របស់សត្វនោះ មិនកើតឡើងទេឬ ។ ពួកសត្វ ដែលប្រកប ដោយយានៈ កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ មិនរលត់ ទៅ តែយានាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ពួក សត្វ ដែលមិនមានយានៈ កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំង នោះ មិនរលត់ទៅផង យានាយតនៈ មិនកើតឡើងផង ។

[ ៧០១ ] រូបាយតនៈ របស់សត្វណា មិនកើតឡើង មនាយតនៈ របស់សត្វនោះ មិនរលត់ទៅទេឬ ។ ពួកសត្វ ដែលប្រកបដោយចិត្ត កាល ច្យុត រូបាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង តែមនាយតនៈ របស់ សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វ ដែលមិនមានរូប មិនមាន ចិត្ត កាលច្យុត កាលចាប់បដិសន្ធិ រូបាយតនៈ របស់សត្វទាំងនោះ មិនកើត ឡើងផង មនាយតនៈ មិនរលត់ទៅផង ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា រលត់ទៅ រូបាយតនៈ របស់សត្វនោះ មិនកើតឡើងទេឬ ។ ពួកសត្វ ដែលប្រកបដោយរូប កាលចាប់បដិសន្ធិ មនាយតនៈ របស់សត្វ ទាំងនោះ មិនរលត់ទៅ តែរូបាយតនៈរបស់សត្វទាំងនោះ មិនមែនជាមិនកើត ឡើងទេ ពួកសត្វដែលមិនមានចិត្ត មិនមានរូប កាលច្យុត កាលចាប់បដិសន្ធិ មនាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅផង រូបាយតនៈ មិនកើតឡើង ផង ។

[ ៧០២ ] រូបាយតនៈ របស់សត្វណា មិនកើតឡើង ធម្មាយតនៈ

របស់សត្វនោះ មិនរលត់ទៅទេឬ ។ ពួកសត្វទាំងអស់ កាលច្យុត រូបាយតនៈរបស់សត្វទាំងនោះ មិនកើតឡើង តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វ ដែលមិនមានរូប កាលចាប់បដិសន្ធិ រូបាយតនៈរបស់សត្វទាំងនោះ មិនកើតឡើងផង ធម្មាយតនៈ មិនរលត់ទៅផង ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា មិនរលត់ទៅ រូបាយតនៈរបស់សត្វនោះ មិនកើតឡើងទេឬ ។ ពួកសត្វ ដែលប្រកបដោយរូប កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ តែរូបាយតនៈរបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ពួកសត្វ ដែលមិនមានរូប កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅផង រូបាយតនៈ មិនកើតឡើងផង ។

[ ៧០៣ ] មនាយតនៈរបស់សត្វណា មិនកើតឡើង ធម្មាយតនៈរបស់សត្វនោះ មិនរលត់ទៅទេឬ ។ ពួកសត្វទាំងអស់ កាលច្យុត មនាយតនៈរបស់សត្វទាំងនោះ មិនកើតឡើង តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វ ដែលមិនមានចិត្ត កាលចាប់បដិសន្ធិ មនាយតនៈរបស់សត្វទាំងនោះ មិនកើតឡើងផង ធម្មាយតនៈ មិនរលត់ទៅផង ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា មិនរលត់ទៅ មនាយតនៈ របស់សត្វនោះ មិនកើតឡើងទេឬ ។ ពួកសត្វ ដែលប្រកបដោយចិត្ត កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅ តែមនាយតនៈរបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ពួកសត្វ ដែលមិនមានចិត្ត

កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ មិនរលត់ទៅផង មនាយតនៈ មិនកើតឡើងផង ។

[ ៧០៤ ] ចក្ខាយតនៈ មិនកើតឡើង ក្នុងទីណា ។បេ។

[ ៧០៥ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើង ក្នុងទីណា ។បេ។ ( ចក្ខាយតនៈ ) របស់សត្វណាក្តី ( ចក្ខាយតនៈ ) របស់សត្វណា ក្នុងទីណាក្តី ដូចៗ គ្នា ។

[ ៧០៦ ] ចក្ខាយតនៈរបស់សត្វណា កើតឡើងហើយ សោតាយតនៈ របស់សត្វនោះ រលត់ហើយដែរឬ ។ អើ ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា រលត់ហើយ ចក្ខាយតនៈ របស់សត្វនោះ កើតឡើងហើយដែរឬ ។ អើ ។ ( បុច្ឆាជាអតីតក្នុងការកើតឡើងក្តី ក្នុងការរលត់ទៅក្តី ក្នុងការកើតឡើង និងការរលត់ទៅក្តី ជាអនុលោមក្តី ជាបដិលោមក្តី ដូចៗ គ្នា ) ។

[ ៧០៧ ] ចក្ខាយតនៈ របស់សត្វណា នឹងកើតឡើង សោតាយតនៈ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ អើ ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា នឹងរលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ បណ្តាពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន ពួកសត្វនោះ កើតឡើង សោតាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ តែចក្ខាយតនៈរបស់សត្វទាំងនោះ នឹងមិនកើតឡើងទេ សោតាយតនៈ របស់សត្វទាំងនោះ ក្រៅនេះ នឹងរលត់ទៅផង ចក្ខាយតនៈ នឹងកើតឡើងផង ។

[ ៧០៨ ] ចក្ខ្វាយតនៈ របស់សត្វណា នឹងកើតឡើង ឃានាយតនៈ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ ពួកសត្វណា ចូលទៅកាន់រូបាវចរភព ហើយ នឹងបរិនិព្វាន ពួកសត្វនោះ កាលច្យុត ចក្ខ្វាយតនៈ របស់សត្វទាំងនោះ នឹងកើតឡើង តែឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ចក្ខ្វាយតនៈ របស់សត្វទាំងនោះ ក្រៅនេះ នឹងកើតឡើងផង ឃានាយតនៈ នឹងរលត់ទៅផង ។ មួយយ៉ាងទៀត ឃានាយតនៈ របស់សត្វណា នឹងរលត់ទៅ ចក្ខ្វាយតនៈ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ បណ្តាពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន ឃានាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ តែចក្ខ្វាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ ឃានាយតនៈ របស់សត្វទាំងនោះ ក្រៅនេះ នឹងរលត់ទៅផង ចក្ខ្វាយតនៈ នឹងកើតឡើងផង ។

[ ៧០៩ ] ចក្ខ្វាយតនៈរបស់សត្វណា នឹងកើតឡើង រូបាយតនៈរបស់សត្វនោះ នឹងរលត់ទៅដែរឬ ។ អើ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងរលត់ទៅ ចក្ខ្វាយតនៈ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ បណ្តាពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន ពួកសត្វនោះ កាលចាប់បដិសន្ធិ រូបាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ តែចក្ខ្វាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ រូបាយតនៈ របស់សត្វទាំងនោះ ក្រៅនេះ

នឹងរលត់ទៅផង ចក្ខាយតនៈ នឹងកើតឡើងផង ។

[ ៧១០ ] ចក្ខាយតនៈរបស់សត្វណា នឹងកើតឡើង មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងរលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ បណ្តាពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលកើតឡើង ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន ធម្មាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ តែចក្ខាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ ធម្មាយតនៈ របស់សត្វទាំងនោះ ក្រៅនេះ នឹងរលត់ទៅផង ចក្ខាយតនៈ នឹងកើតឡើងផង ។

[ ៧១១ ] ឃានាយតនៈរបស់សត្វណា នឹងកើតឡើង រូបាយតនៈរបស់សត្វនោះ នឹងរលត់ទៅដែរឬ ។ អើ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងរលត់ទៅ ឃានាយតនៈ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ បណ្តាពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព ពួកសត្វណា ចូលទៅកាន់រូបាវចរភព និងអរូបាវចរភពហើយ នឹងបរិនិព្វាន ពួកសត្វនោះ កាលកើតឡើង រូបាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ តែឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ រូបាយតនៈ របស់សត្វទាំងនោះ ក្រៅនេះ នឹងរលត់ទៅផង ឃានាយតនៈ នឹងកើតឡើងផង ។

[ ៧១២ ] ឃានាយតនៈរបស់សត្វណា នឹងកើតឡើង មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ អើ ។ មួយយ៉ាងទៀត

ធម្មាយតនៈ របស់សត្វណា នឹងរលត់ទៅ ឃានាយតនៈ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ បណ្តាពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលកើតឡើង ពួកសត្វណា ចូលទៅកាន់រូបាវចរភព និងអរូបាវចរភពហើយ នឹងបរិនិព្វាន ធម្មាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ តែឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ ធម្មាយតនៈ របស់សត្វទាំងនោះ ក្រៅនេះ នឹងរលត់ទៅផង ឃានាយតនៈ នឹងកើតឡើងផង ។

[ ៧១៣ ] រូបាយតនៈរបស់សត្វណា នឹងកើតឡើង មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងរលត់ទៅ រូបាយតនៈ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ បណ្តាពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលកើតឡើង ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន ធម្មាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ តែរូបាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ ធម្មាយតនៈ របស់សត្វទាំងនោះ ក្រៅនេះ នឹងរលត់ទៅផង រូបាយតនៈ នឹងកើតឡើងផង ។

[ ៧១៤ ] មនាយតនៈ របស់សត្វណា នឹងកើតឡើង ធម្មាយតនៈរបស់សត្វនោះ នឹងរលត់ទៅដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងរលត់ទៅ មនាយតនៈ របស់សត្វនោះ នឹងកើតឡើងដែរឬ ។ ពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលកើតឡើង ធម្មាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ តែមនាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ

ធម្មាយតនៈ របស់សត្វទាំងនោះ ក្រៅនេះ នឹងរលត់ទៅផង មនាយតនៈ នឹងកើតឡើងផង ។

[ ៧១៥ ] ចក្ខាយតនៈ នឹងកើតឡើង ក្នុងទីណា ។បេ។

[ ៧១៦ ] ចក្ខាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា សោតាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព សោតាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ សោតាយតនៈ របស់ពួកសត្វ ជាបញ្ចវោការទាំងនោះ ក្រៅនេះ នឹងរលត់ទៅផង ចក្ខាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។

[ ៧១៧ ] ចក្ខាយតនៈរបស់សត្វណា នឹងកើតឡើង ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ ចក្ខាយតនៈរបស់ពួកសត្វ ជារូបាវចរទាំងនោះ នឹងកើតឡើង ក្នុងទីនោះ តែឃានាយតនៈរបស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ ចក្ខាយតនៈ របស់ពួកសត្វ ជាកាមាវចរទាំងនោះ នឹងកើតឡើងផង ឃានាយតនៈ នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ឃានាយតនៈ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វ

ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព ឃានាយតនៈរបស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ឃានាយតនៈ របស់ពួកសត្វ ជាកាមាវចរនោះ ក្រៅនេះ នឹងរលត់ទៅផង ចក្ខាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។

[ ៧១៨ ] ចក្ខាយតនៈរបស់សត្វណា នឹងកើតឡើង ក្នុងទីណា រូបាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព រូបាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ រូបាយតនៈ របស់ពួកសត្វ ជាបញ្ចវោការនោះ ក្រៅនេះ នឹងរលត់ទៅផង ចក្ខាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។

[ ៧១៩ ] ចក្ខាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា មនាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា ចក្ខាយតនៈរបស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព និងពួកអរូបព្រហ្ម មនាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ មនាយតនៈ របស់ពួកសត្វ ជាបញ្ចវោការនោះ

ក្រៅនេះ នឹងរលត់ទៅផង ចក្ខាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។

[ ៧២០ ] ចក្ខាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា ចក្ខាយតនៈរបស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ ធម្មាយតនៈ របស់ពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព ពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម ធម្មាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ធម្មាយតនៈ របស់ពួកសត្វ ជាបញ្ចវោការនោះ ក្រៅនេះ នឹងរលត់ទៅផង ចក្ខាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។

[ ៧២១ ] ឃានាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា រូបាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព និងពួកសត្វ ជារូបាវចរ រូបាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ រូបាយតនៈ របស់ពួកសត្វ ជាកាមាវចរនោះ ក្រៅនេះ នឹងរលត់ទៅផង ឃានាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។

[ ៧២២ ] ឃានាយតនៈរបស់សត្វណា នឹងកើតឡើង ក្នុងទីណា មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព ពួកសត្វ ជារូបាវចរ និងជាអរូបាវចរ ធម្មាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ធម្មាយតនៈរបស់ពួកសត្វ ជាកាមាវចរនោះ ក្រៅនេះ នឹងរលត់ទៅផង ឃានាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។

[ ៧២៣ ] រូបាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា មនាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ រូបាយតនៈ របស់អសញ្ញសត្វទាំងនោះ នឹងកើតឡើង ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ រូបាយតនៈ របស់ពួកសត្វ ជាបញ្ចវោការនោះ នឹងកើតឡើងផង មនាយតនៈ នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព និងពួកអរូបព្រហ្ម មនាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ មនាយតនៈរបស់ពួកសត្វជាបញ្ចវោការ

នោះ ក្រៅនេះ នឹងរលត់ទៅផង រូបាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។

[ ៧២៤ ] រូបាយតនៈរបស់សត្វណា នឹងកើតឡើង ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា រូបាយតនៈរបស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វ ដែលកើតក្នុងបច្ឆិមភពកាលចូលទៅកាន់បញ្ចវោការភព និងពួកអរូបព្រហ្ម ធម្មាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ធម្មាយតនៈ របស់ពួកសត្វជាបញ្ចវោការ និងពួកអសញ្ញសត្វនោះ ក្រៅនេះ នឹងរលត់ទៅផង រូបាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។

[ ៧២៥ ] មនាយតនៈ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈរបស់សត្វណា នឹងរលត់ទៅ ក្នុងទីណា មនាយតនៈរបស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វ ដែលកើតក្នុងបច្ឆិមភពកាលចាប់បដិសន្ធិ និងពួកអសញ្ញសត្វ ធម្មាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ធម្មាយតនៈ របស់ពួកសត្វជាចតុវោការ និងជាបញ្ចវោការនោះ ក្រៅនេះ នឹងរលត់ទៅផង មនាយតនៈ នឹងកើតឡើងផង ក្នុងទីនោះ ។

[ ៧២៦ ] ចក្ខាយតនៈរបស់សត្វណា នឹងមិនកើតឡើង សោតាយតនៈ

របស់សត្វនោះ នឹងមិនរលត់ទៅដែរឬ ។ បណ្ដាពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន ពួកសត្វនោះ កាលកើតឡើង ចក្ខាយតនៈរបស់សត្វទាំងនោះ នឹងមិនកើតឡើង តែសោតាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ បណ្ដាពួកសត្វ កាលបរិនិព្វាន ក្នុងបញ្ចវោការភព និងពួកសត្វ ដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន ពួកសត្វនោះ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង សោតាយតនៈ នឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ នឹងមិនកើតឡើងដែរឬ ។ អើ ។

[ ៧២៧ ] ចក្ខាយតនៈរបស់សត្វណា នឹងមិនកើតឡើង ឃានាយតនៈរបស់សត្វនោះ នឹងមិនរលត់ទៅដែរឬ ។ បណ្ដាពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន ពួកសត្វនោះ កាលចាប់បដិសន្ធិ ចក្ខាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង តែឃានាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ បណ្ដាពួកសត្វ កាលបរិនិព្វាន ក្នុងកាមាវចរភព និងពួកសត្វ ដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងក្នុងអរូបាវចរភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន ពួកសត្វនោះ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ឃានាយតនៈ នឹងមិន

រលត់ទៅផង ។ មួយយ៉ាងទៀត ឃានាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ចក្ខាយតនៈរបស់សត្វនោះ នឹងមិនកើតឡើងដែរឬ ។ ពួកសត្វណា ចូលទៅកាន់កាមាវចរភពហើយ នឹងបរិនិព្វាន ពួកសត្វនោះ កាលច្យុត ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ បណ្តាពួកសត្វ កាលបរិនិព្វាន ក្នុងកាមាវចរភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរភព និងក្នុងអរូបាវចរភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន ពួកសត្វនោះ កាលច្យុត ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ចក្ខាយតនៈ នឹងមិនកើតឡើងផង ។

[ ៧២៨ ] ចក្ខាយតនៈ របស់សត្វណា នឹងមិនកើតឡើង រូបាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅដែរឬ ។ បណ្តាពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន ពួកសត្វនោះ កាលចាប់បដិសន្ធិ ចក្ខាយតនៈរបស់សត្វទាំងនោះ នឹងមិនកើតឡើង តែរូបាយតនៈរបស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ បណ្តាពួកសត្វ កាលបរិនិព្វាន ក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន ពួកសត្វនោះ កាលច្យុត ចក្ខាយតនៈរបស់សត្វទាំងនោះ នឹងមិនកើតឡើងផង រូបាយតនៈ នឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ នឹង

មិនកើតឡើងដែរឬ ។ អើ ។

[ ៧២៩ ] ចក្ខាយតនៈរបស់សត្វណា នឹងមិនកើតឡើង មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅដែរឬ ។ បណ្តាពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន ចក្ខាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ ពួកសត្វកាលបរិនិព្វាន ចក្ខាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ធម្មាយតនៈ នឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា ។បេ។ អើ ។

[ ៧៣០ ] ឃានាយតនៈ របស់សត្វណា នឹងមិនកើតឡើង រូបាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅទេឬ ។ បណ្តាពួកសត្វ ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព ពួកសត្វណា ចូលទៅកាន់រូបាវចរភព និងកាន់អរូបាវចរភពហើយ នឹងបរិនិព្វាន ពួកសត្វនោះ កាលចាប់បដិសន្ធិ ឃានាយតនៈរបស់សត្វទាំងនោះ នឹងមិនកើតឡើង តែរូបាយតនៈរបស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ បណ្តាពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន ពួកសត្វនោះ កាលច្យុត ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង រូបាយតនៈ នឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា ។បេ។ អើ ។

[ ៧៣១ ] ឃានាយតនៈ របស់សត្វណា នឹងមិនកើតឡើង មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅទេឬ ។ បណ្តាពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ ពួកសត្វណា ចូលទៅកាន់រូបាវចរភព និងកាន់អរូបាវចរភពហើយ នឹងបរិនិព្វាន ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង តែធម្មាយតនៈរបស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ ពួកសត្វ កាលបរិនិព្វាន ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ធម្មាយតនៈ នឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា ។បេ។ អើ ។

[ ៧៣២ ] រូបាយតនៈ របស់សត្វណា នឹងមិនកើតឡើង មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅទេឬ ។ បណ្តាពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន រូបាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង តែធម្មាយតនៈរបស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ ពួកសត្វកាលបរិនិព្វាន រូបាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ធម្មាយតនៈ នឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា ។បេ។ អើ ។

[ ៧៣៣ ] មនាយតនៈ របស់សត្វណា នឹងមិនកើតឡើង ធម្មាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅទេឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ មនាយតនៈរបស់សត្វទាំងនោះ នឹងមិនកើតឡើង តែធម្មាយតនៈ

របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ ពួកសត្វ កាលបរិនិព្វាន មនាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ធម្មាយតនៈ នឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ មនាយតនៈ របស់សត្វនោះ នឹងមិនកើតឡើងទេឬ ។ អើ ។

[ ៧៣៤ ] ចក្ខាយតនៈ នឹងមិនកើតឡើង ក្នុងទីណា ។បេ។

[ ៧៣៥ ] ចក្ខាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា សោតាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព ចក្ខាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែសោតាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព ពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម ចក្ខាយតនៈ របស់សត្វទាំងនោះនឹងមិនកើតឡើងផង សោតាយតនៈនឹងមិនរលត់ទៅ ក្នុងទីនោះ ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា ក្នុងទីណា ។បេ។ អើ ។

[ ៧៣៦ ] ចក្ខាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព ចក្ខាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងកាមាវចរភព និងក្នុងរូបាវចរភព ពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម ចក្ខា-

យតនៈរបស់សត្វទាំងនោះ នឹងមិនកើតឡើងផង឴ ឃានាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ឃានាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ចក្ខាយតនៈរបស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ ឃានាយតនៈ របស់ពួកសត្វ ជារូបាវចរនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលបរិនិព្វាន ក្នុងកាមាវចរភព និងក្នុងរូបាវចរភព ពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ចក្ខាយតនៈ នឹងមិនកើតឡើងផង ក្នុងទីនោះ ។

[ ៧៣៧ ] ចក្ខាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា រូបាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព និងពួកអសញ្ញសត្វ ចក្ខាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វកាលបរិនិព្វាន ក្នុងបញ្ចវោការភព និងពួកអរូបព្រហ្ម ចក្ខាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង រូបាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា ក្នុងទីណា ។បេ។ អើ ។

[ ៧៣៨ ] ចក្ខាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា មនាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វ

ដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព និងពួកអរូបព្រហ្ម ចក្ខាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន និងពួកអសញ្ញសត្វ ចក្ខាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង មនាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា ក្នុងទីណា ។បេ។ អើ ។

[ ៧៣៩ ] ចក្ខាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព ពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម ចក្ខាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន ចក្ខាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ធម្មាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា ក្នុងទីណា ។បេ។ អើ ។

[ ៧៤០ ] ឃានាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា រូបាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព និងពួកសត្វ ជារូបាវចរ ឃានាយតនៈរបស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វកាល

បរិនិព្វាន ក្នុងបញ្ចវោការភព និងពួកអរូបព្រហ្ម ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង រូបាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា ក្នុងទីណា ។បេ។ អើ ។

[ ៧៤១ ] ឃានាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា មនាយតនៈរបស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព និងពួកសត្វ ជារូបាវចរ និងជាអរូបាវចរនោះ ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន និងពួកអសញ្ញសត្វ ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង មនាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា ក្នុងទីណា ។បេ។ អើ ។

[ ៧៤២ ] ឃានាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់កាមាវចរភព និងពួកសត្វ ជារូបាវចរ និងជាអរូបាវចរ ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ធម្មាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា ក្នុងទីណា ។បេ។ អើ ។

[ ៧៤៣ ] រូបាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា មនាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព និងពួកអរូបព្រហ្ម រូបាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន រូបាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង មនាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះដែរឬ ។ មនាយតនៈ របស់ពួកអសញ្ញសត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន មនាយតនៈរបស់សត្វទាំងនោះ នឹងមិនរលត់ទៅផង រូបាយតនៈ នឹងមិនកើតឡើងផង ក្នុងទីនោះ ។

[ ៧៤៤ ] រូបាយតនៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់បញ្ចវោការភព និងពួកអរូបព្រហ្ម រូបាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន រូបាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ធម្មាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វ

ណា ក្នុងទីណា ។បេ។ អើ ។

[ ៧៤៥ ] មនាយតនៈរបស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចាប់បដិសន្ធិ និងពួកអសញ្ញសត្វ មនាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែធម្មាយតនៈរបស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន មនាយតនៈ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ធម្មាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា មនាយតនៈ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះទេឬ ។ អើ ។

[ ៧៤៦ ] ចក្ខាយតនៈរបស់សត្វណា កើតឡើង សោតាយតនៈរបស់សត្វនោះ រលត់ហើយដែរឬ ។ អើ ។ មួយយ៉ាងទៀត សោតាយតនៈរបស់សត្វណា រលត់ហើយ ចក្ខាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វទាំងអស់ដែលមិនមានចក្ខុ កាលច្យុត កាលចាប់បដិសន្ធិ សោតាយតនៈ របស់សត្វទាំងនោះ រលត់ហើយ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ សោតាយតនៈ របស់សត្វទាំងនោះ រលត់ហើយផង ចក្ខាយតនៈ កើតឡើងផង ។ បុច្ឆាជាអតីត ដោយបច្ចុប្បន្ន ដែលលោកចែកហើយ ក្នុងឧប្បាទវារៈយ៉ាងណា ឯបុច្ឆា ជាអតីត ដោយបច្ចុប្បន្ន ដែលលោកចែកហើយ ក្នុងឧប្បាទ និងនិរោធ

ក៏យ៉ាងនោះដែរ បណ្ឌិតត្រូវបែងចែកជាអនុលោមផង ជាបដិលោមផងចុះ ។

[ ៧៤៧ ] ចក្ខាយតនៈរបស់សត្វណា កើតឡើង សោតាយតនៈរបស់សត្វនោះ នឹងរលត់ទៅដែរឬ ។ អើ ។ មួយយ៉ាងទៀត សោតាយតនៈរបស់សត្វណា នឹងរលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចក្ខុ កាលច្យុត កាលចាប់បដិសន្ធិ សោតាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ សោតាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅផង ចក្ខាយតនៈ កើតឡើងផង ។

[ ៧៤៨ ] ចក្ខាយតនៈ របស់សត្វណា កើតឡើង ឃានាយតនៈរបស់សត្វនោះ នឹងរលត់ទៅដែរឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់រូបាវចរភព ចក្ខាយតនៈ របស់សត្វទាំងនោះ កើតឡើង តែឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ពួកសត្វក្រៅនេះ ដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ ចក្ខាយតនៈ របស់សត្វទាំងនោះ កើតឡើងផង ឃានាយតនៈ នឹងរលត់ទៅផង ។ មួយយ៉ាងទៀត ឃានាយតនៈ របស់សត្វណា នឹងរលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចក្ខុ កាលច្យុត កាលចាប់បដិសន្ធិ ឃានាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ ឃានាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅផង ចក្ខាយតនៈ កើតឡើងផង ។

[ ៧៤៩ ] ចក្ខាយតនៈ របស់សត្វណា កើតឡើង រូបាយតនៈ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ អើ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងរលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចក្ខុ កាលច្យុត កាលចាប់បដិសន្ធិ រូបាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ តែចក្ខាយតនៈរបស់សត្វទាំងនោះ មិនកើតឡើង ពួកសត្វដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ រូបាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅផង ចក្ខាយតនៈ កើតឡើងផង ។

[ ៧៥០ ] ចក្ខាយតនៈ របស់សត្វណា កើតឡើង មនាយតនៈ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ អើ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា នឹងរលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចក្ខុ កាលច្យុត កាលចាប់បដិសន្ធិ មនាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ មនាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅផង ចក្ខាយតនៈ កើតឡើងផង ។

[ ៧៥១ ] ចក្ខាយតនៈ របស់សត្វណា កើតឡើង ធម្មាយតនៈ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងរលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចក្ខុ កាលច្យុត កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិន

កើតឡើងទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅផង ចក្ខាយតនៈ កើតឡើងផង ។

[ ៧៥២ ] ឃានាយតនៈ របស់សត្វណា កើតឡើង រូបាយតនៈ ។បេ។ មនាយតនៈ ធម្មាយតនៈ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងរលត់ទៅ ឃានាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានឃានៈ កាលច្យុត កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ តែឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វដែលប្រកបដោយឃានៈ កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅផង ឃានាយតនៈ កើតឡើងផង ។

[ ៧៥៣ ] រូបាយតនៈ របស់សត្វណា កើតឡើង មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងរលត់ទៅ រូបាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វទាំងអស់ដែលមិនមានរូប កាលច្យុត កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ តែរូបាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វ ដែលប្រកបដោយរូប កាលចាប់បដិសន្ធិ ធម្មាយតនៈរបស់សត្វទាំងនោះ នឹងរលត់ទៅផង រូបាយតនៈ កើតឡើងផង ។

[ ៧៥៤ ] មនាយតនៈ របស់សត្វណា កើតឡើង ធម្មាយតនៈ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់

សត្វណា នឹងរលត់ទៅ មនាយតនៈ របស់សត្វនោះ កើតឡើងដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចិត្ត កាលច្យុត កាលចាប់បដិសន្ធិ ធម្មាយតនៈរបស់សត្វទាំងនោះ នឹងរលត់ទៅ តែមនាយតនៈរបស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វដែលប្រកបដោយចិត្ត កាលចាប់បដិសន្ធិ ធម្មាយតនៈរបស់សត្វទាំងនោះ នឹងរលត់ទៅផង មនាយតនៈ កើតឡើងផង ។

[ ៧៥៥ ] ចក្ខាយតនៈ កើតឡើង ក្នុងទីណា ។បេ។

[ ៧៥៦ ] ចក្ខាយតនៈ របស់សត្វណា កើតឡើង ក្នុងទីណា សោតាយតនៈរបស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលច្យុតចាកបញ្ចវោការភព កាលចូលទៅកាន់កាមាវចរភព សោតាយតនៈរបស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ សោតាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅផង ចក្ខាយតនៈកើតឡើងផង ក្នុងទីនោះ ។

[ ៧៥៧ ] ចក្ខាយតនៈ របស់សត្វណា កើតឡើង ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វកាលចូលទៅកាន់រូបាវចរភព ចក្ខាយតនៈ របស់សត្វទាំងនោះ កើតឡើង ក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ

ដែលប្រកបដោយចក្ខុ កាលចូលទៅកាន់កាមាវចរភព ចក្ខាយតនៈ របស់សត្វទាំងនោះ កើតឡើងផង ឃានាយតនៈ នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ឃានាយតនៈ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព ឃានាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលចូលទៅកាន់កាមាវចរភព ឃានាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅផង ចក្ខាយតនៈ កើតឡើងផង ក្នុងទីនោះ ។

[ ៧៥៨ ] ចក្ខាយតនៈរបស់សត្វណា កើតឡើង ក្នុងទីណា រូបាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលច្យុតចាកបញ្ចវោការភព កាលចូលទៅកាន់កាមាវចរភព និងពួកអសញ្ញសត្វ រូបាយតនៈរបស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែចក្ខាយតនៈរបស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ រូបាយតនៈរបស់សត្វទាំងនោះ នឹងរលត់ទៅផង ចក្ខាយតនៈ កើតឡើងផង ក្នុងទីនោះ ។

[ ៧៥៩ ] ចក្ខាយតនៈ របស់សត្វណា កើតឡើង ក្នុងទីណា មនាយតនៈ

របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលច្យុតចាកបញ្ចវោការភព កាលចូលទៅកាន់កាមាវចរភព និងពួកអរូបព្រហ្ម មនាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ ដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ មនាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅផង ចក្ខាយតនៈ កើតឡើងផង ក្នុងទីនោះ ។

[ ៧៦០ ] ចក្ខាយតនៈរបស់សត្វណា កើតឡើង ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចក្ខុ កាលច្យុត កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយចក្ខុ កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅផង ចក្ខាយតនៈ កើតឡើងផង ក្នុងទីនោះ ។

[ ៧៦១ ] ឃានាយតនៈ របស់សត្វណា កើតឡើង ក្នុងទីណា រូបាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា ឃានាយតនៈ

របស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វដែលមិនមានឃានៈ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព និងពួកសត្វជារូបាវចរ រូបាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែឃានាយតនៈរបស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយឃានៈ កាលចាប់បដិសន្ធិ រូបាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅផង ឃានាយតនៈ កើតឡើងផង ក្នុងទីនោះ ។

[ ៧៦២ ] ឃានាយតនៈ របស់សត្វណា កើតឡើង ក្នុងទីណា មនាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វដែលមិនមានឃានៈ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព និងពួកសត្វជារូបាវចរ និងជាអរូបាវចរ មនាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយឃានៈ កាលចាប់បដិសន្ធិ មនាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅផង ឃានាយតនៈ កើតឡើងផង ក្នុងទីនោះ ។

[ ៧៦៣ ] ឃានាយតនៈ របស់សត្វណា កើតឡើង ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វ ដែលមិនមានឃានៈ

កាលច្យុត កាលចាប់បដិសន្ធិ ធម្មាយតនៈរបស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយឃានៈ កាលចាប់បដិសន្ធិ ធម្មាយតនៈរបស់សត្វទាំងនោះ នឹងរលត់ទៅផង ឃានាយតនៈ កើតឡើងផង ក្នុងទីនោះ ។

[ ៧៦៤ ] រូបាយតនៈរបស់សត្វណា កើតឡើង ក្នុងទីណា មនាយតនៈរបស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ ពួកសត្វ កាលចូលទៅកាន់អសញ្ញសត្វ រូបាយតនៈ របស់សត្វទាំងនោះ កើតឡើង ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលចូលទៅកាន់បញ្ចវោការភព រូបាយតនៈ របស់សត្វទាំងនោះ កើតឡើងផង មនាយតនៈ នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈរបស់សត្វណា នឹងរលត់ទៅ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ កើតឡើងក្នុងទីនោះដែរឬ ។ ពួកសត្វ កាលច្យុតចាកបញ្ចវោការភព និងពួកអរូបព្រហ្មមនាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែរូបាយតនៈរបស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលចូលទៅកាន់បញ្ចវោការភព មនាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅផង រូបាយតនៈ កើតឡើងផង ក្នុងទីនោះ ។

[ ៧៦៥ ] រូបាយតនៈ របស់សត្វណា កើតឡើង ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈរបស់សត្វណា នឹងរលត់ទៅ ក្នុងទីណា រូបាយតនៈរបស់

សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានរូប កាលច្យុត កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយរូប កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅផង រូបាយតនៈ កើតឡើងផង ក្នុងទីនោះ ។

[ ៧៦៦ ] មនាយតនៈរបស់សត្វណា កើតឡើង ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះដែរឬ ។ អើ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា មនាយតនៈ របស់សត្វនោះ កើតឡើង ក្នុងទីនោះដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចិត្ត កាលច្យុត កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយចិត្ត កាលចាប់បដិសន្ធិ ធម្មាយតនៈ របស់សត្វទាំងនោះ នឹងរលត់ទៅផង មនាយតនៈ កើតឡើងផង ក្នុងទីនោះ ។

[ ៧៦៧ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើង សោតាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចក្ខុ កាលច្យុត កាលចាប់បដិសន្ធិ ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង តែសោតាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ បណ្តាពួកសត្វ កាលបរិនិព្វាន ក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន

សត្វទាំងនោះ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង សោតាយតនៈ នឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត សោតាយតនៈរបស់សត្វណា នឹងមិនរលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើងដែរឬ ។ អើ ។

[ ៧៦៨ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើង ឃានាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចក្ខុ កាលច្យុត កាលចាប់បដិសន្ធិ ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង តែឃានាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ បណ្ដាពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិម-ភព ក្នុងអរូបភព ពួកសត្វណា ចូលទៅកាន់រូបាវចរភព និងកាន់អរូបាវចរភព ហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង ឃានាយតនៈ នឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត ឃានាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើងដែរឬ ។ ពួកសត្វដែលកើតក្នុងបច្ឆិមភព កាលចូលទៅកាន់រូបាវចរភព ឃានាយតនៈរបស់សត្វទាំងនោះ នឹងមិនរលត់ទៅ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ បណ្ដាពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ពួកសត្វណា ចូលទៅកាន់រូបាវចរភព និងកាន់អរូបាវចរភពហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលច្យុត ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ

ផង ចក្ខាយតនៈ មិនកើតឡើងផង ។

[ ៧៦៩ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើង រូបាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចក្ខុ កាលច្យុត កាលចាប់បដិសន្ធិ ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ បណ្តាពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព និងពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិ-និព្វាន សត្វទាំងនោះ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង រូបាយតនៈ នឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា ។បេ។ អើ ។

[ ៧៧០ ] ចក្ខាយតនៈរបស់សត្វណា មិនកើតឡើង មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅដែរឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលច្យុត កាលចាប់បដិសន្ធិ ចក្ខាយតនៈរបស់សត្វទាំងនោះ មិនកើតឡើង តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ ពួកសត្វ កាលបរិនិព្វាន ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង ធម្មាយតនៈ នឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា ។បេ។ អើ ។

[ ៧៧១ ] ឃានាយតនៈរបស់សត្វណា មិនកើតឡើង រូបាយតនៈរបស់សត្វនោះ នឹងមិនរលត់ទៅដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានឃានៈ

កាលច្យុត កាលចាប់បដិសន្ធិ ឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង តែរូបាយតនៈរបស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ បណ្ដាពួកសត្វ កាលបរិនិព្វាន ក្នុងបញ្ចវោការភព និងពួកសត្វ ដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលច្យុត ឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង រូបាយតនៈ នឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា ។បេ។ អើ ។

[ ៧៧២ ] ឃានាយតនៈរបស់សត្វណា មិនកើតឡើង មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅដែរឬ ។ ពួកសត្វទាំងអស់ ដែលមិនមានឃានៈ កាលច្យុត កាលចាប់បដិសន្ធិ ឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ ពួកសត្វ កាលបរិនិព្វាន ឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង ធម្មាយតនៈ នឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា ។បេ។ អើ ។

[ ៧៧៣ ] រូបាយតនៈរបស់សត្វណា មិនកើតឡើង មនាយតនៈ ។បេ។ ធម្មាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅទេឬ ។ ពួកសត្វទាំងអស់ ដែលមិនមានរូប កាលច្យុត កាលចាប់បដិសន្ធិ រូបាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង តែធម្មាយតនៈរបស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ ពួកសត្វ កាលបរិនិព្វាន រូបាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង

*ផង ធម្មាយតនៈ នឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត ធម្មាយតនៈរបស់សត្វណា ។បេ។ អើ ។*

*[ ៧៧៤ ] មនាយតនៈរបស់សត្វណា មិនកើតឡើង ធម្មាយតនៈរបស់សត្វនោះ នឹងមិនរលត់ទៅទេឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចិត្ត កាលច្យុត កាលចាប់បដិសន្ធិ មនាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង តែធម្មាយតនៈរបស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ ពួកសត្វកាលបរិនិព្វាន មនាយតនៈរបស់សត្វទាំងនោះ មិនកើតឡើងផង ធម្មាយតនៈនឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ មនាយតនៈ របស់សត្វនោះ មិនកើតឡើងទេឬ ។ អើ ។*

*[ ៧៧៥ ] ចក្ខាយតនៈ មិនកើតឡើង ក្នុងទីណា ។បេ។*

*[ ៧៧៦ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើង ក្នុងទីណា សោតាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលច្យុតចាកបញ្ចវោការភព កាលចូលទៅកាន់កាមាវចរភព ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ តែសោតាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព ពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង សោតាយតនៈនឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សោតាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ មិនកើត*

ឡើង ក្នុងទីនោះទេឬ ។ អើ ។

[ ៧៧៧ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើង ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ តែឃានាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងកាមាវចរភព កាលច្យុតចាករូបាវចរភព ពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង ឃានាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ឃានាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះទេឬ ។ ឃានាយតនៈ របស់សត្វទាំងនោះ កាលចូលទៅកាន់រូបាវចរភព នឹងមិនរលត់ទៅ ក្នុងទីនោះ តែចក្ខាយតនៈ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងកាមាវចរភព កាលច្យុតចាករូបាវចរភព ពួកអសញ្ញសត្វ និងពួកអរូបព្រហ្ម ឃានាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ចក្ខាយតនៈ មិនកើតឡើងផង ក្នុងទីនោះ ។

[ ៧៧៨ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើង ក្នុងទីណា រូបាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលច្យុតចាកបញ្ចវោការភព កាលចូលទៅកាន់កាមាវចរភព

និងពួកអសញ្ញសត្វ ចក្ខាយតនៈរបស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន ក្នុងបញ្ចវោការភព និងពួកអរូបព្រហ្ម ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង រូបាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះទេឬ ។ អើ ។

[ ៧៧៩ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើង ក្នុងទីណា មនាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វដែលមិនមានចក្ខុ កាលច្យុតចាកបញ្ចវោការភព កាលចូលទៅកាន់កាមាវចរភព និងពួកអរូបព្រហ្ម ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន និងពួកអសញ្ញសត្វ ចក្ខាយតនៈរបស់សត្វទាំងនោះ មិនកើតឡើងផង មនាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះទេឬ ។ អើ ។

[ ៧៨០ ] ចក្ខាយតនៈ របស់សត្វណា មិនកើតឡើង ក្នុងទីណា ធម្មាយតនៈរបស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វទាំងអស់ ដែលមិនមានចក្ខុ កាលច្យុត កាលចាប់បដិសន្ធិ ចក្ខាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែន

ជាទីងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន ចក្ខាយតនៈរបស់សត្វទាំងនោះ មិនកើតឡើងផង ធម្មាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ចក្ខាយតនៈ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះទេឬ ។ អើ ។

[ ៧៨១ ] ឃានាយតនៈ របស់សត្វណា មិនកើតឡើង ក្នុងទីណា រូបាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វដែលមិនមានឃានៈ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព និងពួកសត្វជារូបាវចរ ឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ តែរូបាយតនៈ របស់សត្វទាំងនោះ មិនមែនជាទីងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព និងពួកអរូបព្រហ្ម ឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង រូបាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត រូបាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះទេឬ ។ អើ ។

[ ៧៨២ ] ឃានាយតនៈ របស់សត្វណា មិនកើតឡើង ក្នុងទីណា មនាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វដែលមិនមានឃានៈ កាលច្យុតចាកកាមាវចរភព កាលចូលទៅកាន់កាមាវចរភព និងពួកសត្វជារូបាវចរ និងជាអរូបាវចរ ឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិន

*មែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន និងពួក អសញ្ញសត្វ ឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង មនាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ឃានាយតនៈ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះទេឬ ។ អើ ។*

*[ ៧៨៣ ] ឃានាយតនៈ របស់សត្វណា មិនកើតឡើង ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វ ទាំងអស់ កាលច្យុត កាលចាប់បដិសន្ធិ ឃានាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹង មិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន ឃានាយតនៈ របស់ សត្វទាំងនោះ មិនកើតឡើងផង ធម្មាយតនៈ នឹងមិនរលត់ទៅផង ក្នុងទី នោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុង ទីណា ឃានាយតនៈ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះទេឬ ។ អើ ។*

*[ ៧៨៤ ] រូបាយតនៈ របស់សត្វណា មិនកើតឡើង ក្នុងទីណា មនាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វ កាល ច្យុតចាកបញ្ចវោការភព និងពួកអរូបព្រហ្ម រូបាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ តែមនាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹង មិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន កាលច្យុតចាកអសញ្ញសត្វ រូបាយតនៈ របស់សត្វទាំងនោះ មិនកើតឡើងផង មនាយតនៈ នឹងមិន*

រលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មនាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា រូបាយតនៈរបស់សត្វនោះ មិនកើតឡើង ក្នុងទីនោះទេឬ ។ ពួកសត្វ កាលចូលទៅកាន់អសញ្ញសត្វ មនាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ តែរូបាយតនៈរបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន កាលច្យុតចាកអសញ្ញសត្វ មនាយតនៈរបស់សត្វទាំងនោះ នឹងមិនរលត់ទៅផង រូបាយតនៈមិនកើតឡើងផង ក្នុងទីនោះ ។

[ ៧៨៥ ] រូបាយតនៈ របស់សត្វណា មិនកើតឡើង ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វទាំងអស់ដែលមិនមានរូប កាលច្យុត កាលចាប់បដិសន្ធិ រូបាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន រូបាយតនៈរបស់សត្វទាំងនោះ មិនកើតឡើងផង ធម្មាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា រូបាយតនៈ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះទេឬ ។ អើ ។

[ ៧៨៦ ] មនាយតនៈ របស់សត្វណា មិនកើតឡើង ក្នុងទីណា ធម្មាយតនៈ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេឬ ។ ពួកសត្វទាំងអស់ដែលមិនមានចិត្ត កាលច្យុត កាលចាប់បដិសន្ធិ មនាយតនៈ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ តែធម្មាយតនៈ របស់សត្វទាំងនោះ មិនមែន

ជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលបរិនិព្វាន មនាយតនៈរបស់សត្វទាំងនោះ មិនកើតឡើងផង ធម្មាយតនៈ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ធម្មាយតនៈ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា មនាយតនៈ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះទេឬ ។ អើ ។

[ ៧៨៧ ] ចក្ខាយតនៈ របស់សត្វណា កើតឡើងហើយ សោតាយតនៈ របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ បណ្តាពួកសត្វ កាលបរិនិព្វានក្នុងបញ្ចវោការភព និងពួកសត្វ ដែលកើតក្នុងបច្ឆិមភព ក្នុងអរូបភព ពួកសត្វណា ចូលទៅកាន់អរូបភពហើយ នឹងបរិនិព្វាន សត្វទាំងនោះ កាលច្យុត ចក្ខាយតនៈ របស់សត្វទាំងនោះ កើតឡើងហើយ តែសោតាយតនៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ចក្ខាយតនៈ របស់សត្វទាំងនោះ ក្រៅនេះ មិនកើតឡើងហើយផង សោតាយតនៈ នឹងរលត់ទៅផង ។ មួយយ៉ាងទៀត សោតាយតនៈរបស់សត្វណា នឹងរលត់ទៅ ចក្ខាយតនៈរបស់សត្វនោះ កើតឡើងហើយដែរឬ ។ អើ ។ បុច្ឆា ជាអនាគត ដោយអតីត ក្នុងនិរោធវារៈ បទដែលប្រកបដោយពាក្យថា នៃសត្វណាក្តី បទដែលប្រកបដោយពាក្យថា ក្នុងទីណាក្តី បទដែលប្រកបដោយពាក្យថា នៃសត្វណា ក្នុងទីណាក្តី បទជាអនុលោមក្តី បទជាបច្ចនិយៈក្តី លោកចែកហើយ យ៉ាងណា បុច្ឆា ជាអនាគត ដោយអតីត សូម្បីក្នុងឧប្បាទនិរោធ លោកគប្បីចែកយ៉ាងនេះដែរ ។

ឧប្បាទនិរោធវារៈ ចប់

បវត្តិវារៈ ចប់

# បរិញ្ញាវារៈ

[ ៧៨៨ ] សត្វណា កំណត់ដឹង នូវចក្ខាយតនៈ សត្វនោះ ឈ្មោះថា កំណត់ដឹង នូវសោតាយតនៈដែរឬ ។ អើ ។ មួយយ៉ាងទៀត សត្វណា កំណត់ដឹងនូវសោតាយតនៈ សត្វនោះ ឈ្មោះថា កំណត់ដឹងនូវចក្ខាយតនៈដែរឬ ។ អើ ។ សត្វណា មិនកំណត់ដឹង នូវចក្ខាយតនៈ សត្វនោះ ឈ្មោះថា មិនកំណត់ដឹង នូវសោតាយតនៈដែរឬ ។ អើ ។ មួយយ៉ាងទៀត សត្វណា មិនកំណត់ដឹង នូវសោតាយតនៈ សត្វនោះ ឈ្មោះថា មិនកំណត់ដឹង នូវចក្ខាយតនៈដែរឬ ។ អើ ។

[ ៧៨៩ ] សត្វណា កំណត់ដឹងហើយ នូវចក្ខាយតនៈ សត្វនោះ ឈ្មោះថា កំណត់ដឹងហើយ នូវសោតាយតនៈដែរឬ ។ អើ ។ មួយយ៉ាងទៀត សត្វណា កំណត់ដឹងហើយ នូវសោតាយតនៈ សត្វនោះ ឈ្មោះថា កំណត់ដឹងហើយ នូវចក្ខាយតនៈដែរឬ ។ អើ ។ សត្វណា មិនកំណត់ដឹងហើយ នូវចក្ខាយតនៈ សត្វនោះ ឈ្មោះថា មិនកំណត់ដឹងហើយ នូវសោតាយតនៈដែរឬ ។ អើ ។ មួយយ៉ាងទៀត សត្វណា មិនកំណត់ដឹងហើយ នូវសោតាយតនៈ សត្វនោះ ឈ្មោះថា មិនកំណត់ដឹងហើយ នូវចក្ខាយតនៈដែរឬ ។ អើ ។

[ ៧៩០ ] សត្វណា នឹងកំណត់ដឹង នូវចក្ខាយតនៈ សត្វនោះ ឈ្មោះថា នឹងកំណត់ដឹង នូវសោតាយតនៈដែរឬ ។ អើ ។ មួយយ៉ាងទៀត សត្វណា នឹងកំណត់ដឹង នូវសោតាយតនៈ សត្វនោះ ឈ្មោះថា នឹងកំណត់ដឹង នូវចក្ខាយតនៈដែរឬ ។ អើ ។ សត្វណា នឹងមិនកំណត់ដឹង នូវចក្ខាយតនៈ

សត្វនោះ ឈ្មោះថា នឹងមិនកំណត់ដឹង នូវសោតាយតនៈដែរឬ ។ អើ ។ មួយយ៉ាងទៀត សត្វណា នឹងមិនកំណត់ដឹង នូវសោតាយតនៈ សត្វនោះ ឈ្មោះថា នឹងមិនកំណត់ដឹង នូវចក្ខាយតនៈដែរឬ ។ អើ ។

[ ៧៩១ ] សត្វណា កំណត់ដឹង នូវចក្ខាយតនៈ សត្វនោះ ឈ្មោះថា កំណត់ដឹងហើយ នូវសោតាយតនៈដែរឬ ។ មិនមែនទេ ។ មួយយ៉ាងទៀត សត្វណា កំណត់ដឹងហើយ នូវសោតាយតនៈ សត្វនោះ ឈ្មោះថា កំណត់ដឹង នូវចក្ខាយតនៈដែរឬ ។ មិនមែនទេ ។ សត្វណា មិនកំណត់ដឹង នូវចក្ខាយតនៈ សត្វនោះ ឈ្មោះថា មិនកំណត់ដឹងហើយ នូវសោតាយតនៈដែរឬ ។ ព្រះអរហន្ត មិនកំណត់ដឹង នូវចក្ខាយតនៈ តែមិនមែនជាមិនកំណត់ដឹងហើយ នូវសោតាយតនៈទេ ពួកបុគ្គលដ៏សេស វៀរលែងតែបុគ្គល ដែលប្រកប ដោយមគ្គដ៏ប្រសើរ និងព្រះអរហន្តចេញ មិនកំណត់ដឹង នូវចក្ខាយតនៈផង មិនកំណត់ដឹងហើយ នូវសោតាយតនៈផង ។ មួយយ៉ាងទៀត សត្វណា មិនកំណត់ដឹងហើយ នូវសោតាយតនៈ សត្វនោះ ឈ្មោះថា មិនកំណត់ដឹង នូវចក្ខាយតនៈដែរឬ ។ បុគ្គលប្រកបដោយមគ្គដ៏ប្រសើរ មិនកំណត់ដឹងហើយ នូវសោតាយតនៈ តែមិនមែនជាមិនកំណត់ដឹង នូវចក្ខាយតនៈទេ ពួកបុគ្គលដ៏សេស វៀរលែងតែបុគ្គលដែលប្រកបដោយមគ្គដ៏ប្រសើរ និងព្រះអរហន្តចេញ មិនកំណត់ដឹងហើយ នូវសោតាយតនៈផង មិនកំណត់ដឹង នូវចក្ខាយតនៈផង ។

[ ៧៩២ ] សត្វណា កំណត់ដឹង នូវចក្ខាយតនៈ សត្វនោះ នឹងកំណត់

ដឹងនូវសោតាយតនៈដែរឬ ។ មិនមែនទេ ។ មួយយ៉ាងទៀត សត្វណា នឹងកំណត់ដឹង នូវសោតាយតនៈ សត្វនោះ ឈ្មោះថា កំណត់ដឹង នូវចក្ខាយតនៈដែរឬ ។ មិនមែនទេ ។ សត្វណា មិនកំណត់ដឹង នូវចក្ខាយតនៈ សត្វនោះ នឹងមិនកំណត់ដឹង នូវសោតាយតនៈដែរឬ ។ ពួកសត្វណា នឹងបានចំពោះ នូវមគ្គ ពួកសត្វនោះ ឈ្មោះថា មិនកំណត់ដឹង នូវចក្ខាយតនៈ តែមិនមែនជានឹងមិនកំណត់ដឹង នូវសោតាយតនៈទេ ព្រះអរហន្តក្តី ពួកបុថុជ្ជនណាក្តី នឹងមិនបាននូវមគ្គ ពួកបុគ្គលនោះ មិនកំណត់ដឹង នូវចក្ខាយតនៈផង នឹងមិនកំណត់ដឹង នូវសោតាយតនៈផង ។ មួយយ៉ាងទៀត សត្វណា នឹងមិនកំណត់ដឹង នូវសោតាយតនៈ សត្វនោះ ឈ្មោះថា មិនកំណត់ដឹង នូវចក្ខាយតនៈដែរឬ ។ បុគ្គលប្រកបដោយមគ្គដ៏ប្រសើរ នឹងមិនកំណត់ដឹង នូវសោតាយតនៈ តែមិនមែនជាមិនកំណត់ដឹង នូវចក្ខាយតនៈទេ ព្រះអរហន្តក្តី ពួកបុថុជ្ជនណាក្តី នឹងមិនបាននូវមគ្គ ពួកបុគ្គលនោះ ឈ្មោះថា នឹងមិនកំណត់ដឹង នូវសោតាយតនៈផង មិនកំណត់ដឹង នូវចក្ខាយតនៈផង ។

[ ៧៩៣ ] សត្វណា កំណត់ដឹងហើយ នូវចក្ខាយតនៈ សត្វនោះ នឹងកំណត់ដឹង នូវសោតាយតនៈដែរឬ ។ មិនមែនទេ ។ មួយយ៉ាងទៀត សត្វណា នឹងកំណត់ដឹង នូវសោតាយតនៈ សត្វនោះ ឈ្មោះថា កំណត់ដឹងហើយ នូវចក្ខាយតនៈដែរឬ ។ មិនមែនទេ ។ សត្វណា មិនកំណត់ដឹងហើយ នូវចក្ខាយតនៈ សត្វនោះ នឹងមិនកំណត់ដឹង នូវសោតាយតនៈទេឬ ។ ពួកបុគ្គលណា នឹងបាននូវមគ្គ ពួកបុគ្គលនោះ មិនកំណត់ដឹងហើយ នូវចក្ខាយតនៈ

តែមិនមែនជានឹងមិនកំណត់ដឹង នូវសោតាយតនៈទេ បុគ្គលប្រកបដោយមគ្គដ៏ប្រសើរក្តី ពួកបុថុជ្ជនណាក្តី នឹងមិនបាននូវមគ្គ ពួកបុគ្គលនោះ មិនកំណត់ដឹងហើយ នូវចក្ខាយតនៈផង នឹងមិនកំណត់ដឹង នូវសោតាយតនៈផង ។ មួយយ៉ាងទៀត សត្វណា នឹងមិនកំណត់ដឹង នូវសោតាយតនៈ សត្វនោះ មិនកំណត់ដឹងហើយ នូវចក្ខាយតនៈដែរឬ ។ ព្រះអរហន្ត នឹងមិនកំណត់ដឹង នូវសោតាយតនៈ តែមិនមែនជាមិនកំណត់ដឹងហើយ នូវចក្ខាយតនៈទេ បុគ្គលប្រកបដោយមគ្គដ៏ប្រសើរក្តី ពួកបុថុជ្ជនណាក្តី នឹងមិនបាននូវមគ្គ ពួកបុគ្គលនោះ ឈ្មោះថា នឹងមិនកំណត់ដឹង នូវសោតាយតនៈផង មិនកំណត់ដឹងហើយ នូវចក្ខាយតនៈផង ។

បរិញ្ញាវារៈ ចប់

អាយតនយមកៈ ចប់

# អដ្ឋកថា

# អាយតនយមកៈ

## បណ្ណត្តិឧទ្ទេសវារៈ

[ ២៧៩-៧៩៣ ] ឥឡូវនេះ ជាកិច្ចពណ៌នាអាយតនយមកៈ ដែលលោករួបរួមដោយអំណាចអាយតនៈ ក្នុងធម៌ មានកុសលជាដើម ដែលសម្ដែងក្នុងមូលយមកៈនោះហើយ សម្ដែងក្នុងលំដាប់នៃខន្ធយមកៈ បណ្ឌិតគប្បីជ្រាបការកំណត់បាលី តាមន័យដែលពោលហើយ ក្នុងខន្ធយមកៈនោះឯង ។ ក្នុងខន្ធយមកៈនោះ មហាវារៈ ៣ យ៉ាង គឺ **បណ្ណត្តិវារ ១ បវត្តិវារ ១ បរិញ្ញាវារ ១** រមែងមានយ៉ាងណា សូម្បីក្នុងអាយតនយមកៈនេះ ក៏រមែងមានយ៉ាងនោះ ។ អត្ថនៃពាក្យរបស់មហាវារៈទាំងនោះ បណ្ឌិតគប្បីជ្រាបតាមន័យដែលលោកបានពោលហើយ ក្នុងខន្ធយមកៈនោះឯង ។

ក្នុងអាយតនយមកៈនេះ **បណ្ណត្តិវារ** លោកកំណត់ ២ យ៉ាងដោយអំណាចឧទ្ទេស និងនិទ្ទេស ។ វារៈទាំងឡាយក្រៅអំពីនេះ លោកកំណត់ហើយ ដោយអំណាចនិទ្ទេសនោះឯង ព្រោះហេតុនោះ ក្នុងវារៈទាំងនោះ បណ្ឌិតគប្បីធ្វើបទថា **ទ្វាទសាយតនានិ** ឲ្យជាខាងដើម ដរាបណា គប្បីជ្រាបឧទ្ទេសវារៈ នៃបណ្ណត្តិវារៈថា **ឆាយតនា ឆ មនោ** ដរាបនោះ ។ បណ្ដាបទទាំងនោះ បទថា **ទ្វាទសាយតនានិ** នេះ ជាឧទ្ទេសនៃអាយតនៈទាំងឡាយ ដែលគួរសួរដោយអំណាចយមកៈ ។ បទថា **ចក្ខាយតនានំ ។បេ។**

**ធម្មាយតនំ** ជាការកំណត់ឈ្មោះរបស់អាយតនៈទាំងនោះ ដោយប្រភេទនោះឯង ។ ក្នុងទីនេះ លោកពោលអជ្ឈត្តរូបាយតនៈ គឺអាយតនៈដែលជារូបខាងក្នុងទាំងឡាយហើយតាមលំដាប់មុន ដើម្បីឆ្លើយស្រួលដល់ការសួរ ដោយអំណាចយមកៈ ខាងក្រោយ ទើបពោលពាហិររូបាយតនៈ គឺអាយតនៈដែលជារូបខាងក្រៅទាំងឡាយក្នុងទីបំផុត ទើបពោលមនាយតនៈ និងធម្មាយតនៈទាំងឡាយ ។

នយវារៈទាំងឡាយ ៤ គឺ **បទសោធនវារ ១ បទសោធនមូលចក្កវារ ១ សុទ្ធាយតនវារ ១ សុទ្ធាយតនមូលចក្កវារ ១** រមែងមានដោយអំណាចនៃអាយតនៈទាំងឡាយក្នុងទីនេះ ដោយអំណាចនៃខន្ធនោះឯងក្នុងកាលជាក្រោយ ។ ក្នុងអាយតនយមកៈនេះ វារៈនីមួយៗ រមែងមាន ២ យ៉ាងនោះឯង ដោយអំណាចអនុលោម និងបដិលោម ។ អត្ថរបស់វារៈទាំងនោះ បណ្ឌិតគប្បីជ្រាបតាមន័យដែលពោលហើយក្នុងខន្ធយមកៈនោះឯង ។

បណ្ឌិតគប្បីជ្រាបឧទ្ទេសវារៈ នៃបណ្ណត្តិវារៈដែលប្រកបដោយយមកៈ ៥៧៦ ការសួរ ១១៥២ យ៉ាង និងអត្ថ ២៣០៤ យ៉ាង ក្នុងអាយតនយមកៈនេះ យ៉ាងនេះ គឺក្នុងអនុលោមវារៈនៃបទសោធនវារៈ ក្នុងខន្ធយមកៈ យមកៈ ៥ យ៉ាង មានពាក្យថា **រូបំ រូបក្ខន្ធោ រូបក្ខន្ធោ រូបំ** ដូច្នេះជាដើម រមែងមានយ៉ាងណា ក្នុងអាយតនយមកៈនេះ យមកៈ ១២ យ៉ាង មានពាក្យថា

**ចក្ខុ ចក្ខាយតនំ ចក្ខាយតនំ ចក្ខុ** *ជាដើម រមែងមានយ៉ាងនោះ ។ ក្នុងបដិលោមវារៈ ក៏មានយមកៈ ១២ យ៉ាង មានពាក្យថា* **ន ចក្ខុ ន ចក្ខាយតនំ ន ចក្ខាយតនំ ន ចក្ខុ** *ជាដើម ។ តែក្នុងអនុលោមវារៈ នៃបទសោធនមូលចក្កវារៈ មានយមកៈ ១៣២ យ៉ាង ព្រោះធ្វើមូលនៃអាយតនៈនីមួយៗ ឲ្យជា ១១ យ៉ាង សូម្បីក្នុងបដិលោមវារៈ ក៏មាន ១៣២ យ៉ាង នោះឯង ។ ក្នុងអនុលោមវារៈ នៃសុទ្ធាយតនវារៈ មានយមកៈ ១២ យ៉ាង ក្នុងបដិលោមវារៈ ក៏មាន ១២ យ៉ាង ក្នុងអនុលោមនៃសុទ្ធាយតនមូលចក្កវារៈ មានយមកៈ ១៣២ យ៉ាង ព្រោះធ្វើមូលនៃអាយតនៈនីមួយៗ ឲ្យជា ១១ យ៉ាង ក្នុងបដិលោមវារៈ ក៏មាន ១៣២ យ៉ាងដូចគ្នា ៕*

## បណ្ណត្តិឧទ្ទេសវារៈ ចប់

# បណ្ណត្តិនិទ្ទេសវារៈ

ក្នុងនិទ្ទេសវារៈ នៃអាយតនយមកៈនោះ បណ្ឌិតគប្បីជ្រាបអត្ថតាមន័យដែលពោលហើយ ក្នុងបណ្ណត្តិវារនិទ្ទេស នៃខន្ធយមកៈខាងដើមនោះឯង ។ ក្នុងវារៈដទៃ រមែងមានការប្លែកគ្នា ។

ក្នុងអាយតនយមកៈនោះ គប្បីជ្រាបការប្លែកគ្នាដូចតទៅ

បទថា **ទិព្វចក្ខុ** បានដល់ ទុតិយវិជ្ជាញាណ ។ បទថា **បញ្ញាចក្ខុ** បានដល់ តតិយវិជ្ជាញាណ ។ បទថា **ទិព្វសោតំ** បានដល់ ទុតិយ-អភិញ្ញាញាណ ។ តណ្ហានោះឯង ឈ្មោះថា **តណ្ហាសោតំ** ។ ពាក្យថា **នាមកាយ រូបកាយ ហត្ថិកាយ អស្សកាយ** ជាដើម ឈ្មោះថា **អវសេសោ កាយោ** គឺកាយដ៏សេស ។ បទថា **អវសេសំ រូបំ** បានដល់ ភូតរូប ឧបាទាយរូបនោះឯង និងបិយរូប សាតរូបដ៏សេសអំពីរូបាយតនៈ ។ បទថា **សីលគន្ធោ** ជាឈ្មោះរបស់ធម៌ទាំងឡាយ មានសីលជាដើមនោះឯង ព្រោះអត្ថថា ផ្សាយទៅ ។ បទថា **អត្ថរសោ** ជាដើម ក៏ជាឈ្មោះនៃធម៌ទាំងឡាយ មានអត្ថជាដើម ព្រោះអត្ថថា ពីរោះល្អ ។ បទថា **អវសេសោ ធម្មោ** បានដល់ ប្រភេទមិនមែនមួយនៃធម៌ មានបរិយត្តិធម៌ជាដើម នេះជាការប្លែកគ្នាក្នុងអាយតនយមកៈនេះ ។

## បណ្ណត្តិនិទ្ទេសវារៈ ចប់

# បវត្តិវារៈ

ក្នុងអាយតនយមកៈនេះ ក្នុងអន្តរវារៈ ៣ យ៉ាង មានឧប្បាទវារៈជាដើម នៃបវត្តិវារៈ មានប្រភេទនៃកាល ៦ ក្នុងប្រភេទនៃកាលនីមួយៗ នោះឯង បណ្តាប្រភេទនៃកាលទាំងនោះ វារៈទាំង ៣ មានបុគ្គលវារៈជាដើម រមែង មានក្នុងកាលនីមួយៗ ។ វារៈទាំងអស់នោះ រមែងមាន ២ យ៉ាង ដោយ អំណាចអនុលោមន័យ និងបដិលោមន័យ ក្នុងវារៈទាំងនោះ ក្នុងបច្ចុប្បន្ន-កាល ក្នុងអនុលោមន័យរបស់បុគ្គលវារៈ យមកៈ ១០ យ៉ាង រមែងមាន ដោយការកាន់យកហើយមិនកាន់យកទៀត គឺមូលនៃរូបក្ខន្ធ ក្នុងខន្ធយមកៈ ៤ មូលនៃវេទនាខន្ធ ៣ មូលនៃសញ្ញាខន្ធ ២ មូលនៃសង្ខារក្ខន្ធ ១ យ៉ាង ណា មូលនៃចក្ខាយតនៈ ១១ ក៏រមែងមានយ៉ាងនោះ យ៉ាងនេះ គឺចក្ខា-យតនៈ រមែងកើតឡើងដល់សត្វណា សោតាយតនៈ រមែងកើតឡើងដល់ សត្វនោះ ឬថា សោតាយតនៈ រមែងកើតឡើងដល់សត្វណា ចក្ខាយតនៈ រមែងកើតឡើងដល់សត្វនោះ ចក្ខាយតនៈ រមែងកើតឡើងដល់សត្វណា ឃានាយតនៈ ជិវ្ហាយតនៈ កាយាយតនៈ រូបាយតនៈ សទ្ទាយតនៈ គន្ធា-យតនៈ រសាយតនៈ ផោដ្ឋព្វាយតនៈ មនាយតនៈ ធម្មាយតនៈ រមែងកើត ឡើងដល់សត្វនោះ ឬថា ធម្មាយតនៈ រមែងកើតឡើងដល់សត្វណា ចក្ខា-យតនៈ រមែងកើតឡើងដល់សត្វនោះ ។ ដោយន័យថា **យស្ស សោតា-យតនំ ឧប្បជ្ជតិ តស្ស ឃានាយតនំ ឧប្បជ្ជតិ** ជាដើម ទើបមានយមកៈ ៦៦ ដោយការកាន់យកហើយមិនកាន់យកទៀត គឺមូលនៃសោតាយតនៈ ១០ មូលនៃឃានាយតនៈ ៩ មូលនៃជិវ្ហាយតនៈ ៨ មូលនៃកាយាយតនៈ ៧

មូលនៃរូបាយតនៈ ៦ មូលនៃសទ្ទាយតនៈ ៥ មូលនៃគន្ធាយតនៈ ៤ មូលនៃរសាយតនៈ ៣ មូលនៃផោដ្ឋព្វាយតនៈ ២ មូលនៃមនាយតនៈ ១ ដូច្នេះ ។ ក្នុងអាយតនៈ ១១ យ៉ាង ដែលជាមូលនៃចក្ខាយតនៈនោះ ចក្ខាយតនៈរមែងកើតឡើងដល់សត្វណា អាយតនៈ ៥ យ៉ាងនេះ គឺសោតាយតនៈ ឃានាយតនៈ រូបាយតនៈ មនាយតនៈ ធម្មាយតនៈ រមែងកើតឡើងដល់សត្វនោះ ដែលលោកវិសជ្ជនាហើយ ។

ក្នុងអាយតនៈទាំងនោះ លោកវិសជ្ជនាអាយតនៈដំបូង ដែលគួរវិសជ្ជនាមុន អាយតនៈទី ២ មានការវិសជ្ជនាដូចគ្នានឹងអាយតនៈដំបូងក៏ពិតតែអាយតនៈទី ២ លោកក៏វិសជ្ជនាហើយ ដើម្បីហាមនូវសេចក្តីសង្ស័យថា ព្រោះឃានាយតនៈ មិនប្រព្រឹត្តទៅហើយ ដោយចំណែកមួយ ក្នុងទីបវត្តិ-កាលរបស់ចក្ខុ និងសោតាយតនៈថា អាយតនៈមួយ គប្បីវិសជ្ជនាដូចម្តេចហ្ន៎ ។ យមកៈ ៣ យ៉ាង និងរូបាយតនៈ មនាយតនៈ និងធម្មាយតនៈឈ្មោះថា លោកវិសជ្ជនាហើយ ព្រោះវិសជ្ជនាមិនដូចគ្នា ។ ក្នុងអាយតនៈដ៏សេស យមកៈ ២ យ៉ាង មួយអន្លើដោយជិវ្ហាយតនៈ និងកាយាយតនៈមានការវិសជ្ជនាដូចគ្នានឹងអាយតនៈ ២ យ៉ាងខាងដើម ។

ការវិសជ្ជនាយមកៈនោះឯង មួយអន្លើដោយអាយតនៈនោះ រមែងមិនមាន ព្រោះមិនកើតឡើងក្នុងបដិសន្ធិក្ខណៈនៃសទ្ទាយតនៈ ។ អាយតនៈទាំងឡាយ លោកសង្ខេបហើយ ដើម្បីការស្រាលនៃបែបផែនថា យមកៈ ៣ យ៉ាង មួយអន្លើដោយគន្ធាយតនៈ រសាយតនៈ និងផោដ្ឋព្វាយតនៈ រមែង

*ជាការវិសជ្ជនាដូចគ្នានឹងអាយតនៈ ២ ខាងដើមនោះឯង ។ ក្នុងមូលនៃសោតា-យតនៈ អាយតនៈសូម្បីមួយ មិនឡើងកាន់ព្រះបាលីហើយថា អាយតនៈណា ដែលបណ្ឌិតរមែងបាន អាយតនៈនោះ រមែងមានការវិសជ្ជនាដូចគ្នានឹងអាយតនៈទាំងឡាយខាងដើម ។*

*ក្នុងមូលនៃឃានាយតនៈទាំងឡាយ យមកៈមួយឡើងកាន់បាលីហើយមួយអន្លើដោយរូបាយតនៈ យមកៈ ២ ឡើងកាន់បាលីហើយ មួយអន្លើដោយមនាយតនៈ និងធម្មាយតនៈ ដូច្នោះ ទើបយមកៈ ៣ ឡើងកាន់បាលីហើយយមកៈទាំងឡាយដ៏សេស មិនឡើងកាន់បាលី ព្រោះការវិសជ្ជនាដូចគ្នានឹងឃានាយតនយមកៈ ។ មូលនៃជិវ្ហាយតនៈ និងកាយាយតនៈ ក៏យ៉ាងនោះ ។*

*ក្នុងមូលនៃរូបាយតនៈទាំងឡាយ យមកៈ ២ យ៉ាងនោះឯង លោកវិសជ្ជនាហើយ មួយអន្លើដោយមនាយតនៈ និងធម្មាយតនៈ ។ យមកៈ ៣ មួយអន្លើដោយគន្ធៈ រសៈ និងផោដ្ឋព្វៈ មានការវិសជ្ជនាដូចគ្នានឹងរូបាយតនៈ និងមនាយតនៈនោះឯង ។ បទថា* **សរូបកានំ អចិត្តកានំ** *ជាដើម លោកពោលហើយខាងដើមយ៉ាងណា សូម្បីក្នុងអាយតនយមកៈនេះក៏យ៉ាងនោះ ។ គប្បីជ្រាបការប្រែរួមថា* **សរូបកានំ អគន្ធកានំ អរសកានំ អផោដ្ឋព្វកានំ** *ដូច្នេះ ។*

*ការកើតនៃអាយតនៈទាំងឡាយ មានគន្ធៈជាដើមនោះឯង លោកបំណាងយកហើយក្នុងអាយតនយមកៈនេះ ព្រោះហេតុនោះ បណ្ឌិតគប្បីជ្រាបអត្ថក្នុងអាយតនយមកៈនេះ ដោយអំណាចនៃអាយតនៈថា* **សរូបកានំ សគន្ធា-**

**យតនានំ** ។ មូលនៃសទ្ទាយតនៈទាំងឡាយ មិនឡើងហើយកាន់ព្រះបាលី នោះឯង ព្រោះមិនមានអត្ថ ។ អាយតនៈដែលជាមូលនៃគន្ធៈ រសៈ និង ផោដ្ឋព្វៈ ៤-៣-២ មិនឡើងកាន់បាលី ព្រោះវិសជ្ជនាដូចគ្នានឹងអាយតនៈ ទាំងឡាយដែលមានខាងដើម ។ យមកៈទាំង ៦៦ នេះ បណ្ឌិតគប្បីជ្រាប ថា ឈ្មោះថា ជាការដែលលោកវិសជ្ជនាហើយ ដោយការវិសជ្ជនាយមកៈ ២-៣ នោះឯង ។ ក្នុងអនុលោមន័យរបស់បុគ្គលវារៈ ក្នុងបច្ចុប្បន្នកាល យ៉ាងនេះថា ធម៌ដែលមានមនាយតនៈជាមូល ដែលលោកវិសជ្ជនាហើយ នោះឯង ដូច្នេះ ។ យមកៈ ១៩៨ រមែងមានក្នុងអនុលោមន័យ ក្នុងវារៈទាំង ៣ ក្នុងបច្ចុប្បន្នកាលថា ក្នុងបុគ្គលវារៈ មាន ៦៦ យ៉ាងណា សូម្បីក្នុង ឱកាសវារៈ ក្នុងបុគ្គលោកាសវារៈក៏យ៉ាងនោះ ដូច្នេះ ។ យមកៈ ៣៩៦ ទាំងអស់ រមែងមានក្នុងបច្ចុប្បន្នកាលថា ក្នុងអនុលោមន័យយ៉ាងណា សូម្បី ក្នុងបដិលោមន័យក៏យ៉ាងនោះ ដូច្នេះ ។ ការសួរ ៧៩២ យ៉ាង និងអត្ថ ១៥៨៤ យ៉ាង គប្បីជ្រាបថា មានក្នុងយមកៈទាំងឡាយនោះ ។ យមកៈ ២៣៧៦ ទាំងអស់ថា ក្នុងការចែកកាល ៥ យ៉ាងដ៏សេស ដូច្នេះ ក៏រមែង មានយ៉ាងនោះ ។ នេះជាការកំណត់ព្រះបាលីក្នុងឧប្បាទវារៈនេះថា ពាក្យសួរ ដែលទ្វេគុណអំពីយមកៈនោះ អត្ថដែលទ្វេគុណអំពីពាក្យសួរនោះ ។ ក្នុង និរោធវារៈ និងឧប្បាទនិរោធវារៈ ក៏មានន័យដូច្នេះឯង ។ យមកៈ ៧១២៨ រមែងមានក្នុងបវត្តិវារៈទាំងអស់ ។ គប្បីជ្រាបការសួរទ្វេគុណអំពីយមកៈនោះ គប្បីជ្រាបអត្ថទ្វេគុណអំពីពាក្យសួរនោះ ។ ព្រះបាលី លោកពោលពាក្យ

*ជាដើមថា មនាយតនៈ និងធម្មាយតនៈ មានការផ្សេងគ្នាជាមួយអាយតនៈ ១ តែសេចក្តីសង្ខេប មានក្នុងវារៈខាងលើ ដូច្នេះហើយ ទើបទ្រង់សង្ខេប ក្នុងអាយតនៈនោះៗ ។ ព្រោះហេតុនោះ ពាក្យណាលោកសង្ខេបហើយក្នុង ទីនោះៗ ពាក្យទាំងអស់នោះ បុគ្គលមិនវង្វេងគប្បីកំណត់ ។*

*ក្នុងការវិនិច្ឆ័យអត្ថ គប្បីជ្រាបនយមុខក្នុងអាយតនយមកៈនេះដូចតទៅ បទថា* **សចក្ខុកានំ អសោតកានំ** *លោកពោលសំដៅយកឱបបាតិកៈ ដែល មានត្រចៀកថ្លង់អំពីកំណើត ក្នុងអបាយ ។ បុគ្គលមានចក្ខុនោះ ជាបុគ្គល មិនមានសោតៈកើតឡើង ។ ដូចដែលព្រះធម្មសង្គាហកាចារ្យពោលហើយថា អាយតនៈ ១០ ដទៃទៀតរបស់បុគ្គលណា រមែងប្រាកដក្នុងឧបបត្តិក្ខណៈនៃ កាមធាតុ ។ អាយតនៈ ១០ គឺចក្ខាយតនៈ រូបាយតនៈ ឃានាយតនៈ គន្ធា-យតនៈ ជិវ្ហាយតនៈ រសាយតនៈ កាយាយតនៈ ផោដ្ឋព្វាយតនៈ មនាយតនៈ និងធម្មាយតនៈ រមែងប្រាកដក្នុងឧបបត្តិក្ខណៈរបស់ពួកប្រេត ដែលជាឱប-បាតិកៈ របស់ពួកអសុរដែលជាឱបបាតិកៈ របស់ពួកសត្វតិរច្ឆាន ដែលជា ឱបបាតិកៈ របស់ពួកសត្វនរកដែលជាឱបបាតិកៈ របស់ពួកបុគ្គលដែល ត្រចៀកថ្លង់អំពីកំណើត ។ បទថា* **សចក្ខុកានំ សសោតកានំ** *លោកពោល សំដៅយកអាយតនៈដែលបរិបូណ៌ ក្នុងសុគតិ និងទុគ្គតិ និងរូបព្រហ្មដែល ជាឱបបាតិកៈ ។ បុគ្គលដែលមានចក្ខុទាំងនោះ រមែងជាអ្នកមានសោតៈកើត ឡើង ។ ដូចព្រះធម្មសង្គាហកាចារ្យពោលហើយថា អាយតនៈ ១១ យ៉ាង របស់បុគ្គលណា រមែងប្រាកដក្នុងឧបបត្តិក្ខណៈនៃកាមធាតុ ។ អាយតនៈ*

១១ យ៉ាង រមែងប្រាកដដល់ពួកទេវតាជាន់កាមាវចរ ពួកមនុស្សបឋមកប្ប ពួកប្រេតដែលជាឱបបាតិកៈ ពួកអសុរដែលជាឱបបាតិកៈ ពួកសត្វតិរច្ឆាន ដែលជាឱបបាតិកៈ ពួកសត្វនរកដែលជាឱបបាតិកៈ ដែលមានអាយតនៈ បរិបូណ៌ ។

អាយតនៈ ៥ ពួកណា រមែងប្រាកដក្នុងឧបបត្តិក្ខណៈ នៃរូបធាតុ ។ អាយតនៈ គឺចក្ខាយតនៈ រូបាយតនៈ សោតាយតនៈ មនាយតនៈ ធម្មាយតនៈ រមែងប្រាកដក្នុងឧបបត្តិក្ខណៈ នៃរូបធាតុ ។

បទថា **អឃានកានំ** លោកពោលសំដៅយកព្រហ្ម មានព្រហ្មបារិសជ្ជា ជាដើម ។ ព្រហ្មទាំងនោះជាអ្នកមានចក្ខុ ជាបុគ្គលមិនមានឃានៈកើតឡើង ។ ឱបបាតិកៈដែលមិនមានឃានៈ រមែងមិនមានក្នុងកាមធាតុ ។ បើគប្បីមាន ដល់បុគ្គលណាសោត ក៏គប្បីពោលបានថា អាយតនៈ ៨ រមែងប្រាកដ ។ បុគ្គលដេកក្នុងផ្ទៃណា គប្បីជាបុគ្គលមិនមានឃានៈ បុគ្គលដេកក្នុងផ្ទៃនោះ លោកមិនបំណងយកហើយ ក្នុងអាយតនយមកៈនេះ ព្រោះពាក្យថា **សចក្ខុកានំ ។**

បទថា **សចក្ខុកានំ សឃានកានំ** លោកពោលសំដៅយកឱបបាតិកសត្វ ដែលបួងអំពីកំណើតខ្លះ ដែលមានអាយតនៈបរិបូណ៌ខ្លះ ។ បទថា **សឃានកានំ អចក្ខុកានំ** លោកពោលសំដៅយកឱបបាតិកសត្វ ដែលខ្វាក់អំពីកំណើតខ្លះ ដែលបួងអំពីកំណើតខ្លះ ។

បទថា **សចក្ខុកានំ សឃានកានំ** លោកពោលសំដៅយកឱបបាតិក-

សត្វ ដែលមានអាយតនៈបរិបូណ៌នោះឯង ។

បុគ្គលដទៃខ្លះ ដែលដេកក្នុងផ្ទៃខ្លះ ដែលបណ្ឌិតរមែងបាននោះឯងក្នុងពួកឱបបាតិកសត្វដែលខ្វាក់អំពីកំណើត និងថ្លង់អំពីកំណើត ក្នុងបទនេះថា **សរូបកានំ អចក្ខុកានំ** ។ បុគ្គលមិនមានរូប និងបុគ្គល ៣ ពួក មានបុគ្គលខ្វាក់អំពីកំណើតជាដើម ដែលពោលហើយខាងដើម ដែលបណ្ឌិតរមែងបានក្នុងពាក្យនេះថា **សចិត្តកានំ អចក្ខុកានំ** ។

ពួកអសញ្ញសត្វ និងបុគ្គល ៤ ពួកដែលពោលហើយក្នុងបទខាងដើម ដែលបណ្ឌិតរមែងបានក្នុងបទដំបូងនេះថា **អចក្ខុកានំ** ។ ពួកគព្ភសេយ្យកសត្វ ពួកអសញ្ញសត្វ និងពួករូបព្រហ្មដ៏សេស ដែលបណ្ឌិតរមែងបានក្នុងពាក្យនេះថា **សរូបកានំ អឃានកានំ** ។ ពួកគព្ភសេយ្យកសត្វ និងពួករូបព្រហ្ម និងអរូបព្រហ្ម ដែលបណ្ឌិតរមែងបានក្នុងពាក្យនេះថា **សចិត្តកានំ អឃានកានំ** ។ គប្បីជ្រាបបុគ្គលវិភាគ ក្នុងបុគ្គលវារៈទាំងអស់ដោយន័យនេះថា ពួកឯកវោ-ការសត្វ និងចតុវោការសត្វ ដែលបណ្ឌិតរមែងបានក្នុងបទទាំងឡាយថា **អចិត្តកានំ អរូបកានំ** ។

*ក្នុងឱកាសវារៈ បទថា* **យត្ថ ចក្ខាយតនំ** *បានដល់ រមែងសួរនូវលោកនៃរូបព្រហ្ម ព្រោះហេតុនោះឯង ទើបលោកពោលថា* **អាមន្តា** ។ *អាយតនៈទាំងនោះដោយនិយមក្នុងផ្ទៃនោះ រមែងកើតក្នុងបដិសន្ធិ ។ នេះជានយមុខក្នុងអាយតនយមកៈនេះ ។ គប្បីជ្រាបសេចក្តីក្នុងបវត្តិវារៈទាំងអស់ដោយនយមុខនេះ ។ បរិញ្ញាវារៈគប្បីជ្រាបថា ជាន័យដែលលោកពោលហើយក្នុងខន្ធយមកៈនោះឯង ។*

## អដ្ឋកថាអាយតនយមកៈ ចប់

# អភិធម្មបិដក-៨៨

# យមកៈ ទុតិយភាគ

## ធាតុយមកៈ

## បណ្ណត្តិវារៈ

[ ១ ] ធាតុ ១៨ គឺចក្ខុធាតុ ១ សោតធាតុ ១ ឃានធាតុ ១ ជិវ្ហាធាតុ ១ កាយធាតុ ១ រូបធាតុ ១ សទ្ទធាតុ ១ គន្ធធាតុ ១ រសធាតុ ១ ផោដ្ឋព្វធាតុ ១ ចក្ខុវិញ្ញាណធាតុ ១ សោតវិញ្ញាណធាតុ ១ ឃានវិញ្ញាណធាតុ ១ ជិវ្ហាវិញ្ញាណធាតុ ១ កាយវិញ្ញាណធាតុ ១ មនោធាតុ ១ មនោវិញ្ញាណធាតុ ១ ធម្មធាតុ ១ ។

## ឧទ្ទេសវារៈ

[ ២ ] ចក្ខុ ហៅថា ចក្ខុធាតុ ចក្ខុធាតុ ហៅថា ចក្ខុ ។ សោតៈ ហៅថា សោតធាតុ សោតធាតុ ហៅថា សោតៈ ។បេ។ ចក្ខុវិញ្ញាណ ហៅថា ចក្ខុវិញ្ញាណធាតុ ចក្ខុវិញ្ញាណធាតុ ហៅថា ចក្ខុវិញ្ញាណ ។បេ។ មនៈ ហៅថា មនោធាតុ មនោធាតុ ហៅថា មនៈ ។ មនោវិញ្ញាណ ហៅថា មនោវិញ្ញាណធាតុ មនោវិញ្ញាណធាតុ ហៅថា មនោវិញ្ញាណ ។ ធម៌ ហៅថា ធម្មធាតុ ធម្មធាតុ ហៅថា ធម៌ ។

[ ៣ ] មិនមែនចក្ខុ មិនហៅថា ចក្ខុធាតុ មិនមែនចក្ខុធាតុ មិនហៅថា

ចក្ខុ ។ មិនមែនសោតៈ មិនហៅថា សោតធាតុ មិនមែនសោតធាតុ មិនហៅថា សោតៈ ។បេ។ មិនមែនចក្ខុវិញ្ញាណ មិនហៅថា ចក្ខុវិញ្ញាណធាតុ មិនមែនចក្ខុវិញ្ញាណធាតុ មិនហៅថា ចក្ខុវិញ្ញាណ ។បេ។ មិនមែនមនៈ មិនហៅថា មនោធាតុ មិនមែនមនោធាតុ មិនហៅថា មនៈ ។ មិនមែនមនោ-វិញ្ញាណ មិនហៅថា មនោវិញ្ញាណធាតុ មិនមែនមនោវិញ្ញាណធាតុ មិនហៅថា មនោវិញ្ញាណ ។ មិនមែនធម៌ មិនហៅថា ធម្មធាតុ មិនមែនធម្មធាតុ មិនហៅថា ធម៌ ។

[ ៤ ] ចក្ខុ ហៅថា ចក្ខុធាតុ ធាតុទាំងឡាយ ហៅថា សោតធាតុ ។បេ។ ចក្ខុ ហៅថា ចក្ខុធាតុ ធាតុទាំងឡាយ ហៅថា ធម្មធាតុ ។ ចក្កដែលលោកចងក្នុងអាយតនយមកៈ យ៉ាងណា ចក្កដែលលោកចងក្នុងធាតុយមកៈនេះ យ៉ាងនោះដែរ ។

[ ៥ ] មិនមែនចក្ខុ មិនហៅថា ចក្ខុធាតុ មិនមែនធាតុទាំងឡាយ មិនហៅថា សោតធាតុ ។ មិនមែនចក្ខុ មិនហៅថា ចក្ខុធាតុ មិនមែនធាតុទាំងឡាយ មិនហៅថា ឃានធាតុ ។បេ។ មិនមែនចក្ខុ មិនហៅថា ចក្ខុធាតុ មិនមែនធាតុទាំងឡាយ មិនហៅថា ធម្មធាតុ ។បេ។ មិនមែនធម៌ មិនហៅថា ធម្មធាតុ មិនមែនធាតុទាំងឡាយ មិនហៅថា ចក្ខុធាតុ ។បេ។ មិនមែនធម៌ មិនហៅថា ធម្មធាតុ មិនមែនធាតុទាំងឡាយ មិនហៅថា មនោវិញ្ញាណ-ធាតុ ។ ចក្ក បណ្ណត្តិគប្បីចង ។

[ ៦ ] ចក្ខុ ហៅថា ធាតុ ធាតុ ហៅថា ចក្ខុ ។ សោតៈ ហៅថា ធាតុ

*ធាតុទាំងឡាយ ហៅថា សោតៈ ។ ប្រមុះ អណ្តាត កាយ រូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ។ ចក្ខុវិញ្ញាណ ហៅថា ធាតុ ធាតុទាំងឡាយ ហៅថា ចក្ខុ-វិញ្ញាណ ។ សោតវិញ្ញាណ ហៅថា ធាតុ ធាតុទាំងឡាយ ហៅថា សោត-វិញ្ញាណ ។ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ ។ មនៈ ហៅថា ធាតុ ធាតុទាំងឡាយ ហៅថា មនៈ ។ មនោវិញ្ញាណ ហៅថា ធាតុ ធាតុទាំងឡាយ ហៅថា មនោវិញ្ញាណ ។ ធម៌ ហៅថា ធាតុ ធាតុទាំងឡាយ ហៅថា ធម៌ ។*

*[ ៧ ] មិនមែនចក្ខុ មិនហៅថា ធាតុ មិនមែនធាតុទាំងឡាយ មិនហៅថា ចក្ខុ ។ មិនមែនសោតៈ មិនហៅថា ធាតុ មិនមែនធាតុទាំងឡាយ មិនហៅថា សោតៈ ។ មិនមែនប្រមុះ មិនមែនអណ្តាត មិនមែនកាយ មិនមែនរូប មិនមែនសំឡេង មិនមែនក្លិន មិនមែនរស មិនមែនផោដ្ឋព្វៈ ។ មិនមែនចក្ខុវិញ្ញាណ មិនហៅថា ធាតុ មិនមែនធាតុទាំងឡាយ មិនហៅថា ចក្ខុ-វិញ្ញាណ ។ មិនមែនសោតវិញ្ញាណ មិនមែនឃានវិញ្ញាណ មិនមែនជិវ្ហា-វិញ្ញាណ ។ មិនមែនកាយវិញ្ញាណ មិនហៅថា ធាតុ មិនមែនធាតុទាំងឡាយ មិនហៅថា កាយវិញ្ញាណ ។ មិនមែនមនៈ មិនហៅថា ធាតុ មិនមែនធាតុទាំងឡាយ មិនហៅថា មនៈ ។ មិនមែនមនោវិញ្ញាណ មិនហៅថា ធាតុ មិនមែនធាតុទាំងឡាយ មិនហៅថា មនោវិញ្ញាណ ។ មិនមែនធម៌ មិនហៅថា ធាតុ មិនមែនធាតុទាំងឡាយ មិនហៅថា ធម៌ ។*

*[ ៨ ] ចក្ខុ ហៅថា ធាតុ ធាតុទាំងឡាយ ហៅថា សោតៈ ។បេ។ ចក្ខុ*

ហៅថា ធាតុ ធាតុទាំងឡាយ ហៅថា ធម៌ ។បេ។ ធម៌ ហៅថា ធាតុ ធាតុទាំងឡាយ ហៅថា ចក្ខុ ។បេ។ ធម៌ ហៅថា ធាតុ ធាតុទាំងឡាយ ហៅថា មនោវិញ្ញាណ ។ ចក្ក បណ្ណត្តិកប្បីចង ។

[ ៩ ] មិនមែនចក្ខុ មិនហៅថា ធាតុ មិនមែនធាតុទាំងឡាយ មិនហៅថា សោតៈ ។ មិនមែនចក្ខុ មិនហៅថា ធាតុ មិនមែនធាតុទាំងឡាយ មិនហៅថា ឃានៈ ។បេ។ មិនមែនចក្ខុ មិនហៅថា ធាតុ មិនមែនធាតុទាំងឡាយ មិនហៅថា ធម៌ ។បេ។ មិនមែនធម៌ មិនហៅថា ធាតុ មិនមែនធាតុទាំងឡាយ មិនហៅថា ចក្ខុ ។បេ។ មិនមែនធម៌ មិនហៅថា ធាតុ មិនមែនធាតុទាំងឡាយ មិនហៅថា មនោវិញ្ញាណ ។ ចក្ក បណ្ណត្តិកប្បីចង ។

ឧទ្ទេសវារៈ ចប់

## និទ្ទេសវារៈ

[ ១០ ] សួរ. ចក្ខុ ហៅថា ចក្ខុធាតុឬ ។ ឆ្លើយ. ទិព្វចក្ខុ បញ្ញាចក្ខុ ហៅថា ចក្ខុ មិនហៅថា ចក្ខុធាតុទេ ឯចក្ខុធាតុ ហៅថា ចក្ខុផង ហៅថា ចក្ខុធាតុផង ។ ចក្ខុធាតុ ហៅថា ចក្ខុឬ ។ អើ ។ សោតៈ ហៅថា សោតធាតុឬ ។ ទិព្វសោតៈ តណ្ហាសោតៈ ហៅថា សោតៈ មិនហៅថា សោតធាតុទេ ឯសោតធាតុ ហៅថា សោតៈផង ហៅថា សោតធាតុផង ។ សោតធាតុ ហៅថា សោតៈឬ ។ អើ ។ ឃានៈ ហៅថា ឃានធាតុឬ ។ អើ ។ ឃានធាតុ ហៅថា ឃានៈឬ ។ អើ ។ ជិវ្ហា ដូចគ្នានឹងឃានធាតុ ។ កាយ ហៅថា កាយធាតុឬ ។ កាយដ៏សេស វៀរលែងកាយធាតុចេញ

ហៅថា កាយ មិនហៅថា កាយធាតុទេ ឯកាយធាតុ ហៅថា កាយផង ហៅថា កាយធាតុផង ។ កាយធាតុ ហៅថា កាយឬ ។ អើ ។ រូប ហៅថា រូបធាតុឬ ។ រូបដ៏សេស វៀរលែងរូបធាតុចេញ ហៅថា រូប មិនហៅថា រូបធាតុទេ ឯរូបធាតុ ហៅថា រូបផង ហៅថា រូបធាតុផង ។ រូបធាតុ ហៅថា រូបឬ ។ អើ ។ សទ្ទៈ ដូចគ្នានឹងឃានៈ ។ គន្ធៈ ហៅថា គន្ធធាតុឬ ។ សីលគន្ធៈ សមាធិគន្ធៈ បញ្ញាគន្ធៈ ហៅថា គន្ធៈ មិនហៅថា គន្ធធាតុទេ ឯគន្ធធាតុ ហៅថា គន្ធៈផង ហៅថា គន្ធធាតុផង ។ គន្ធធាតុ ហៅថា គន្ធៈឬ ។ អើ ។ រស ហៅថា រសធាតុឬ ។ អត្ថរស ធម្មរស វិមុត្តិរស ហៅថា រស មិនហៅថា រសធាតុទេ ឯរសធាតុ ហៅថា រសផង ហៅថា រសធាតុផង ។ រសធាតុ ហៅថា រសឬ ។ អើ ។ ផោដ្ឋព្វៈ ដូចគ្នានឹងឃានៈ ។ ចក្ខុវិញ្ញាណ ហៅថា ចក្ខុវិញ្ញាណធាតុឬ ។ អើ ។ ចក្ខុវិញ្ញាណធាតុ ហៅថា ចក្ខុវិញ្ញាណឬ ។ អើ ។ សោតវិញ្ញាណ ។បេ។ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ ។ មនៈ ហៅថា មនោធាតុឬ ។ មនៈដ៏សេស វៀរលែងមនោធាតុចេញ ហៅថា មនៈ មិនហៅថា មនោធាតុទេ ឯមនោធាតុ ហៅថា មនៈផង ហៅថា មនោធាតុផង ។ មនោធាតុ ហៅថា មនៈឬ ។ អើ ។ មនោវិញ្ញាណ ហៅថា មនោវិញ្ញាណធាតុឬ ។ អើ ។ មនោវិញ្ញាណធាតុ ហៅថា មនោវិញ្ញាណឬ ។ អើ ។ ធម៌ ហៅថា ធម្មធាតុឬ ។ ធម៌ដ៏សេស វៀរលែងធម្មធាតុចេញ ហៅថា ធម៌ មិនហៅថា ធម្មធាតុទេ ឯធម្មធាតុ ហៅថា ធម៌ផង ហៅថា ធម្មធាតុផង ។ ធម្មធាតុ ហៅថា ធម៌ឬ ។ អើ ។

[ ១១ ] មិនមែនចក្ខុ មិនហៅថា ចក្ខុធាតុឬ ។ អើ ។ មិនមែនចក្ខុធាតុ មិនហៅថា ចក្ខុឬ ។ ទិព្វចក្ខុ បញ្ញាចក្ខុ មិនហៅថា ចក្ខុធាតុទេ ហៅថា ចក្ខុ ធម្មជាតដ៏សេស វៀរលែងចក្ខុ និងចក្ខុធាតុចេញ មិនហៅថា ចក្ខុផង មិនហៅថា ចក្ខុធាតុផង ។ មិនមែនសោតៈ មិនហៅថា សោតធាតុឬ ។ អើ ។ មិនមែនសោតធាតុ មិនហៅថា សោតៈឬ ។ ទិព្វសោតៈ តណ្ហាសោតៈ មិនហៅថា សោតធាតុទេ ហៅថា សោតៈ ធម្មជាតដ៏សេស វៀរលែងសោតៈ និងសោតធាតុចេញ មិនហៅថា សោតៈផង មិនហៅថា សោតធាតុផង ។ មិនមែនឃានៈ មិនហៅថា ឃានធាតុឬ ។ អើ ។ មិនមែនឃានធាតុ មិនហៅថា ឃានៈឬ ។ អើ ។ ពាក្យណា ដែលលោកបង្រួញហើយ ( ពាក្យនោះ ) មានអាមន្តាពីរលើក ។ មិនមែនជិវ្ហា ។បេ។ មិនមែនកាយ មិនហៅថា កាយធាតុឬ ។ អើ ។ មិនមែនកាយធាតុ មិនហៅថា កាយឬ ។ កាយដ៏សេស វៀរលែងកាយធាតុចេញ មិនហៅថា កាយធាតុទេ ហៅថា កាយ ឯសភាវៈដ៏សេស វៀរលែងកាយ និងកាយធាតុចេញ មិនហៅថា កាយផង មិនហៅថា កាយធាតុផង ។ មិនមែនរូប មិនហៅថា រូបធាតុឬ ។ អើ ។ មិនមែនរូបធាតុ មិនហៅថា រូបឬ ។ រូបដ៏សេស វៀរលែងរូបធាតុចេញ មិនហៅថា រូបធាតុទេ ហៅថា រូប ឯធម្មជាតដ៏សេស វៀរលែងរូប និងរូបធាតុចេញ មិនហៅថា រូបផង មិនហៅថា រូបធាតុផង ។ មិនមែនសទ្ទៈ ។បេ។ មិនមែនគន្ធៈ មិនហៅថា គន្ធធាតុឬ ។ អើ ។ មិនមែនគន្ធធាតុ មិនហៅថា គន្ធៈឬ ។ សីលគន្ធៈ សមាធិ-

គន្ធៈ បញ្ញាគន្ធៈ មិនហៅថា គន្ធធាតុទេ ហៅថា គន្ធៈ ឯសភាវៈដ៏សេស វៀរលែងគន្ធៈ និងគន្ធធាតុចេញ មិនហៅថា គន្ធៈផង មិនហៅថា គន្ធធាតុផង ។ មិនមែនរសៈ មិនហៅថា រសធាតុឬ ។ អើ ។ មិនមែនរសធាតុ មិនហៅថា រសៈឬ ។ អត្ថរស ធម្មរស វិមុត្តិរស មិនហៅថា រសធាតុទេ ហៅថា រសៈ ឯសភាវៈដ៏សេស វៀរលែងរសៈ និងរសធាតុចេញ មិនហៅថា រសៈផង មិនហៅថា រសធាតុផង ។ មិនមែនផោដ្ឋព្វៈ ។បេ។ មិនមែនចក្ខុ-វិញ្ញាណ មិនហៅថា ចក្ខុវិញ្ញាណធាតុឬ ។ អើ ។ មិនមែនចក្ខុវិញ្ញាណធាតុ មិនហៅថា ចក្ខុវិញ្ញាណឬ ។ អើ ។ មិនមែនសោតវិញ្ញាណ មិនមែនឃានវិញ្ញាណ មិនមែនជិវ្ហាវិញ្ញាណ មិនមែនកាយវិញ្ញាណ ។ មិនមែនមនៈ មិនហៅថា មនោធាតុឬ ។ អើ ។ មិនមែនមនោធាតុ មិនហៅថា មនៈឬ ។ មនៈដ៏សេស វៀរលែងមនោធាតុចេញ មិនហៅថា មនោធាតុទេ ហៅថា មនៈ ឯសភាវៈដ៏សេស វៀរលែងមនៈ និងមនោធាតុចេញ មិនហៅថា មនៈផង មិនហៅថា មនោធាតុផង ។ មិនមែនមនោវិញ្ញាណ មិនហៅថា មនោវិញ្ញាណធាតុឬ ។ អើ ។ មិនមែនមនោវិញ្ញាណធាតុ មិនហៅថា មនោវិញ្ញាណឬ ។ អើ ។ មិនមែនធម៌ មិនហៅថា ធម្មធាតុឬ ។ អើ ។ មិនមែនធម្មធាតុ មិនហៅថា ធម៌ឬ ។ ធម៌ដ៏សេស វៀរលែងធម្មធាតុចេញ មិនហៅថា ធម្មធាតុទេ ហៅថា ធម៌ ឯសភាវៈដ៏សេស វៀរលែងធម៌ និងធម្មធាតុចេញ មិនហៅថា ធម៌ផង មិនហៅថា ធម្មធាតុផង ។

[ ១២ ] ចក្ខុ ហៅថា ចក្ខុធាតុឬ ។ ទិព្វចក្ខុ បញ្ញាចក្ខុ ហៅថា ចក្ខុ

មិនហៅថា ចក្ខុធាតុទេ ឯចក្ខុធាតុ ហៅថា ចក្ខុផង ហៅថា ចក្ខុធាតុផង ។ ធាតុទាំងឡាយ ហៅថា សោតធាតុឬ ។ សោតធាតុ ហៅថា ធាតុផង ហៅថា សោតធាតុផង ពួកធាតុដ៏សេស ហៅថា ធាតុ មិនហៅថា សោតធាតុទេ ។ ចក្ខុ ហៅថា ចក្ខុធាតុឬ ។ ទិព្វចក្ខុ បញ្ញាចក្ខុ ហៅថា ចក្ខុ មិនហៅថា ចក្ខុធាតុទេ ឯចក្ខុធាតុ ហៅថា ចក្ខុផង ហៅថា ចក្ខុធាតុផង ។ ធាតុទាំងឡាយ ហៅថា ឃានធាតុ ។បេ។ ធាតុទាំងឡាយ ហៅថា ធម្មធាតុឬ ។ ធម្មធាតុ ហៅថា ធាតុផង ហៅថា ធម្មធាតុផង ពួកធាតុដ៏សេស ហៅថា ធាតុ មិនហៅថា ធម្មធាតុទេ ។ បណ្ណត្តិក្នុងអាយតនយមកៈ យ៉ាងណា បណ្ណត្តិក្នុងធាតុយមកៈ ក៏យ៉ាងនោះ ។ ចក្ក បណ្ឌិតគប្បីចង ។

[ ១៣ ] មិនមែនចក្ខុ មិនហៅថា ចក្ខុធាតុឬ ។ អើ ។ មិនមែនធាតុទាំងឡាយ មិនហៅថា សោតធាតុឬ ។ អើ ។ មិនមែនចក្ខុ មិនហៅថា ចក្ខុធាតុឬ ។ អើ ។ មិនមែនធាតុទាំងឡាយ មិនហៅថា ឃានធាតុ ។បេ។ មិនមែនធាតុទាំងឡាយ មិនហៅថា ធម្មធាតុឬ ។ អើ ។ ចក្ក បណ្ឌិតគប្បីចង ។ អាមន្តា ទាំងអស់មានពីរក៏មាន មានសេសក៏មាន ។

[ ១៤ ] ចក្ខុ ហៅថា ធាតុឬ ។ អើ ។ ធាតុទាំងឡាយ ហៅថា ចក្ខុធាតុឬ ។ ចក្ខុធាតុ ហៅថា ធាតុផង ហៅថា ចក្ខុធាតុផង ពួកធាតុដ៏សេស ហៅថា ធាតុ មិនហៅថា ចក្ខុធាតុទេ ។ សោតៈ ហៅថា ធាតុឬ ។ អើ ។បេ។ ឃានៈ ជិវ្ហា កាយ រូប សទ្ទៈ គន្ធៈ រសៈ ផោដ្ឋព្វៈ ។ ចក្ខុវិញ្ញាណ ហៅថា ធាតុឬ ។ អើ ។ ធាតុទាំងឡាយ ហៅថា ចក្ខុវិញ្ញាណធាតុឬ ។

ចក្ខុវិញ្ញាណធាតុ ហៅថា ធាតុផង ហៅថា ចក្ខុវិញ្ញាណធាតុផង ពួកធាតុដ៏សេស ហៅថា ធាតុ មិនហៅថា ចក្ខុវិញ្ញាណធាតុទេ ។ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ ។ មនៈ ហៅថា ធាតុឬ ។ អើ ។ ធាតុទាំងឡាយ ហៅថា មនោធាតុឬ ។ មនោធាតុ ហៅថា ធាតុផង ហៅថា មនោធាតុផង ពួកធាតុដ៏សេស ហៅថា ធាតុ មិនហៅថា មនោធាតុទេ ។ មនោវិញ្ញាណ ហៅថា ធាតុឬ ។ អើ ។ ធាតុទាំងឡាយ ហៅថា មនោ-វិញ្ញាណធាតុឬ ។ មនោវិញ្ញាណធាតុ ហៅថា ធាតុផង ហៅថា មនោ-វិញ្ញាណធាតុផង ពួកធាតុដ៏សេស ហៅថា ធាតុ មិនហៅថា មនោ-វិញ្ញាណធាតុទេ ។ ធម៌ ហៅថា ធាតុឬ ។ អើ ។ ធាតុទាំងឡាយ ហៅថា ធម្មធាតុឬ ។ ធម្មធាតុ ហៅថា ធាតុផង ហៅថា ធម្មធាតុផង ពួកធាតុដ៏សេស ហៅថា ធាតុ មិនហៅថា ធម្មធាតុទេ ។

[ ១៥ ] មិនមែនចក្ខុ មិនហៅថា ធាតុឬ ។ ពួកធាតុដ៏សេស វៀរលែងចក្ខុចេញ មិនហៅថា ចក្ខុធាតុ ឯធម្មជាតដ៏សេស វៀរលែងចក្ខុ និងធាតុចេញ មិនហៅថា ចក្ខុផង មិនហៅថា ធាតុផង ។ មិនមែនធាតុទាំងឡាយ មិនហៅថា ចក្ខុធាតុឬ ។ អើ ។ មិនមែនសោតៈ មិនហៅថា ធាតុឬ ។ ( ពួកធាតុដ៏សេស ) វៀរលែងសោតៈចេញ ។បេ។ វៀរលែងឃានៈ វៀរលែងជិវ្ហាចេញ ។បេ។ មិនមែនកាយ មិនហៅថា ធាតុឬ ។ អើ ។ មិនមែនធាតុទាំងឡាយ មិនហៅថា កាយធាតុឬ ។ អើ ។ មិនមែនរូប មិនហៅថា ធាតុឬ ។ ( ពួកធាតុដ៏សេស ) វៀរលែងរូបចេញ ។បេ។ វៀរលែងសទ្ទៈ គន្ធៈ

រស: ផោដ្ឋព្វ: ចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ កាយវិញ្ញាណ មនៈ មនោវិញ្ញាណចេញ ។បេ។ មិនមែនធម៌ មិនហៅថា ធាតុឬ ។ អើ ។ មិនមែនធាតុទាំងឡាយ មិនហៅថា ធម្មធាតុឬ ។ អើ ។

[ ១៦ ] ចក្ខុ ហៅថា ធាតុឬ ។ អើ ។ ធាតុទាំងឡាយ ហៅថា សោតធាតុឬ ។ សោតធាតុ ហៅថា ធាតុផង ហៅថា សោតធាតុផង ពួកធាតុដ៏សេស ហៅថា ធាតុ មិនហៅថា សោតធាតុទេ ។ ចក្ខុ ហៅថា ធាតុឬ ។ អើ ។ ធាតុទាំងឡាយ ហៅថា ឃានធាតុ ។បេ។ ធាតុទាំងឡាយ ហៅថា ធម្មធាតុឬ ។ ធម្មធាតុ ហៅថា ធាតុផង ហៅថា ធម្មធាតុផង ពួកធាតុដ៏សេស ហៅថា ធាតុ មិនហៅថា ធម្មធាតុទេ ។ ចក្ក បណ្ឌិតគប្បីចង ។

[ ១៧ ] មិនមែនចក្ខុ មិនហៅថា ធាតុឬ ។ ពួកធាតុដ៏សេស វៀរលែងចក្ខុចេញ មិនហៅថា ចក្ខុធាតុ ឯធម្មជាតដ៏សេស វៀរលែងចក្ខុ និងធាតុចេញ មិនហៅថា ចក្ខុផង មិនហៅថា ធាតុផង ។ មិនមែនធាតុ មិនហៅថា សោតធាតុឬ ។ អើ ។ មិនមែនចក្ខុ មិនហៅថា ធាតុឬ ។ ពួកធាតុដ៏សេស វៀរលែងចក្ខុចេញ មិនហៅថា ចក្ខុ ហៅថា ធាតុ ឯធម្មជាតដ៏សេស វៀរលែងចក្ខុ និងធាតុចេញ មិនហៅថា ចក្ខុផង មិនហៅថា ធាតុផង ។ មិនមែនធាតុទាំងឡាយ មិនហៅថា ឃានធាតុ ។បេ។ មិនមែនពួកធាតុ មិនហៅថា ធម្មធាតុឬ ។ អើ ។បេ។ មិនមែនធម៌ មិនហៅថា ធាតុឬ ។ អើ ។ មិនមែនធាតុទាំងឡាយ មិនហៅថា សោតធាតុ ។បេ។ មិនមែនធាតុទាំងឡាយ មិនហៅថា មនោវិញ្ញាណធាតុឬ ។ អើ ។ ចក្ក បណ្ឌិត

គប្បីចង ។ បណ្ណត្តិ នៃអាយតនយមកៈ យ៉ាងណា បណ្ណត្តិនៃធាតុយមកៈ បណ្ឌិតគប្បីឲ្យពិស្តារយ៉ាងនោះដែរ ។

បណ្ណត្តិវារៈ ចប់

# បវត្តិវារៈ

[ ១៨ ] ចក្ខុធាតុ របស់សត្វណា រមែងកើតឡើង សោតធាតុរបស់សត្វនោះ រមែងកើតឡើងឬ ។ ពួកសត្វដែលមានចក្ខុ មិនមានសោតៈ កាលកើតឡើង ចក្ខុធាតុរបស់សត្វទាំងនោះ រមែងកើតឡើង ឯសោតធាតុរបស់សត្វទាំងនោះ រមែងមិនកើតឡើងទេ ពួកសត្វមានចក្ខុ មានសោតៈ កាលកើតឡើង ចក្ខុធាតុរបស់សត្វទាំងនោះរមែងកើតឡើងផង សោតធាតុរមែងកើតឡើងផង ។ មួយទៀត សោតធាតុរបស់សត្វណា រមែងកើតឡើង ចក្ខុធាតុរបស់សត្វនោះ រមែងកើតឡើងឬ ។ ពួកសត្វមានសោតៈ មិនមានចក្ខុ កាលកើតឡើង សោតធាតុរបស់សត្វទាំងនោះ រមែងកើតឡើង ឯចក្ខុធាតុរបស់សត្វទាំងនោះ រមែងមិនកើតឡើងទេ ពួកសត្វ មានសោតៈ មានចក្ខុ កាលកើតឡើង សោតធាតុរបស់សត្វទាំងនោះ រមែងកើតឡើងផង ចក្ខុធាតុរមែងកើតឡើងផង ។

[ ១៩ ] ចក្ខុធាតុរបស់សត្វណា រមែងកើតឡើង ឃានធាតុរបស់សត្វនោះ រមែងកើតឡើងឬ ។ ពួកសត្វមានចក្ខុ មិនមានឃានៈ កាលកើតឡើង ចក្ខុធាតុរបស់សត្វទាំងនោះ រមែងកើតឡើង ឯឃានធាតុរបស់សត្វទាំងនោះ រមែងមិនកើតឡើងទេ ពួកសត្វមានចក្ខុ មានឃានៈ កាលកើតឡើង ចក្ខុធាតុ

របស់សត្វទាំងនោះ រមែងកើតឡើងផង ឃានធាតុ រមែងកើតឡើងផង ។ មួយទៀត ឃានធាតុរបស់សត្វណារមែងកើតឡើង ចក្ខុធាតុរបស់សត្វនោះ រមែងកើតឡើងឬ ។ ពួកសត្វ មានឃានៈ មិនមានចក្ខុ កាលកើតឡើង ឃានធាតុរបស់សត្វទាំងនោះ រមែងកើតឡើង ឯចក្ខុធាតុរបស់សត្វទាំងនោះ រមែងមិនកើតឡើងទេ ពួកសត្វមានឃានៈ មានចក្ខុ កាលកើតឡើង ឃានធាតុរបស់សត្វទាំងនោះ រមែងកើតឡើងផង ចក្ខុធាតុ រមែងកើតឡើងផង ។

[ ២០ ] ចក្ខុធាតុរបស់សត្វណា រមែងកើតឡើង រូបធាតុរបស់សត្វនោះ រមែងកើតឡើងឬ ។ អើ ។ មួយទៀត រូបធាតុរបស់សត្វណា រមែងកើតឡើង ចក្ខុធាតុរបស់សត្វនោះ រមែងកើតឡើងឬ ។ ពួកសត្វមានរូប មិនមានចក្ខុ កាលកើតឡើង រូបធាតុរបស់សត្វទាំងនោះ រមែងកើតឡើង ឯចក្ខុធាតុរបស់សត្វទាំងនោះ រមែងមិនកើតឡើងទេ ពួកសត្វមានរូប មានចក្ខុ កាលកើតឡើង រូបធាតុរបស់សត្វទាំងនោះ រមែងកើតឡើងផង ចក្ខុធាតុ រមែងកើតឡើងផង ។

[ ២១ ] ចក្ខុធាតុរបស់សត្វណា រមែងកើតឡើង មនោវិញ្ញាណធាតុរបស់សត្វនោះ រមែងកើតឡើងឬ ។ អើ ។ មួយទៀត មនោវិញ្ញាណធាតុរបស់សត្វណា រមែងកើតឡើង ចក្ខុធាតុរបស់សត្វនោះ រមែងកើតឡើងឬ ។ ពួកសត្វមានចិត្ត មិនមានចក្ខុ កាលកើតឡើង មនោវិញ្ញាណធាតុរបស់សត្វទាំងនោះ រមែងកើតឡើង ឯចក្ខុធាតុរបស់សត្វទាំងនោះ រមែងមិនកើតឡើងទេ ពួកសត្វមានចិត្ត មានចក្ខុ កាលកើតឡើង មនោវិញ្ញាណធាតុរបស់សត្វ

ទាំងនោះ រមែងកើតឡើងផង ចក្ខុធាតុ រមែងកើតឡើងផង ។

[ ២២ ] ចក្ខុធាតុរបស់សត្វណា រមែងកើតឡើង ធម្មធាតុរបស់សត្វនោះ រមែងកើតឡើងឬ ។ អើ ។ មួយទៀត ធម្មធាតុរបស់សត្វណា រមែងកើតឡើង ចក្ខុធាតុរបស់សត្វនោះ រមែងកើតឡើងឬ ។ ពួកសត្វមិនមានចក្ខុ កាលកើតឡើង ធម្មធាតុរបស់សត្វទាំងនោះ រមែងកើតឡើង ឯចក្ខុធាតុរបស់សត្វទាំងនោះ រមែងមិនកើតឡើងទេ ពួកសត្វមានចក្ខុ កាលកើតឡើង ធម្មធាតុរបស់សត្វទាំងនោះ រមែងកើតឡើងផង ចក្ខុធាតុ រមែងកើតឡើងផង ។ អាយតនយមកៈ លោកចែកហើយយ៉ាងណា ឯធាតុយមកៈ បណ្ឌិតគប្បីចែកធ្វើឲ្យដូចៗ គ្នាយ៉ាងនោះដែរ ។

## បរិញ្ញាវារៈ

[ ២៣ ] បុគ្គលណា កំណត់ដឹងនូវចក្ខុធាតុ បុគ្គលនោះ កំណត់ដឹងនូវសោតធាតុឬ ។ អើ ។បេ។

ធាតុយមកៈ បរិបូណ៌ដោយបេយ្យាល ចប់

ធាតុយមកៈ ចប់

# អដ្ឋកថា

## ធាតុយមកៈ

[ ១-២៣ ] ឥឡូវនេះ ជាកិច្ចពណ៌នាធាតុយមកៈ ដែលលោករួបរួមសម្តែងហើយ ក្នុងលំដាប់អាយតនយមកៈ ដោយអំណាចធាតុក្នុងធម៌ មានកុសលជាដើម ដែលលោកសម្តែងហើយ ក្នុងមូលយមកៈទាំងនោះឯង ។ គប្បីជ្រាបការកំណត់ព្រះបាលី តាមន័យដែលលោកពោលហើយ ក្នុងអាយតនយមកៈនោះឯង ។ ក្នុងធាតុយមកៈនេះ មហាវារៈ ៣ មានបណ្ណត្តិវារៈជាដើម និងអន្តរវារៈដ៏សេស និងប្រភេទទាំងឡាយ មានប្រភេទនៃកាលជាដើម រមែងដូចគ្នា ដែលមកហើយក្នុងអាយតនយមកៈនោះឯង ។ ម្យ៉ាងទៀត ក្នុងធាតុយមកៈនេះ លោកពោលរូបធាតុខាងក្នុង និងខាងក្រៅហើយ ទើបពោលវិញ្ញាណធាតុតាមលំដាប់ ដើម្បីងាយស្រួលដល់ការសួរយមកៈ ។ យមកៈដែលច្រើនជាងអាយតនយមកៈ ការសួរដែលទទេគុណដោយយមកៈ និងអត្ថដែលទទេគុណដោយការសួរ រមែងមានក្នុងធាតុ-យមកៈនេះ ព្រោះធាតុយមកៈទាំងឡាយ មានច្រើន ។ ការវិនិច្ឆ័យអដ្ឋកថានៃយមកៈទាំងឡាយ ដែលបានក្នុងយមកៈទាំងឡាយ មានចក្ខុធាតុមូលកៈជាដើមនោះ គប្បីជ្រាបតាមន័យដែលពោលហើយ ក្នុងអាយតនយមកៈនោះឯង ។ គតិនៃអត្ថក្នុងធាតុយមកៈនេះ ដូចគ្នានឹងអាយតនយមកៈនោះឯង ។ ម្យ៉ាងទៀត សូម្បីព្រះបាលីលោកក៏សង្ខេបហើយ ព្រោះហេតុនោះឯង ។ បរិញ្ញាវារៈ គប្បីជ្រាបថា ជាវារៈតាមប្រក្រតីនោះឯង ដូច្នេះ ។៚

# អភិធម្មបិដក

## សច្ចយមកៈ

### បណ្ណត្តិវារៈ

សច្ចៈ ៤ គឺទុក្ខសច្ច ១ សមុទយសច្ច ១ និរោធសច្ច ១ មគ្គសច្ច ១ ។

### ឧទ្ទេសវារៈ

[ ២៤ ] ទុក្ខ ហៅថា ទុក្ខសច្ច ទុក្ខសច្ច ហៅថា ទុក្ខ ។ សមុទយៈ ហៅថា សមុទយសច្ច សមុទយសច្ច ហៅថា សមុទយៈ ។ និរោធ ហៅថា និរោធសច្ច និរោធសច្ច ហៅថា និរោធ ។ មគ្គ ហៅថា មគ្គសច្ច មគ្គសច្ច ហៅថា មគ្គ ។

[ ២៥ ] មិនមែនទុក្ខ មិនហៅថា ទុក្ខសច្ច មិនមែនទុក្ខសច្ច មិនហៅថា ទុក្ខ ។ មិនមែនសមុទយៈ មិនហៅថា សមុទយសច្ច មិនមែនសមុទយសច្ច មិនហៅថា សមុទយៈ ។ មិនមែននិរោធ មិនហៅថា និរោធសច្ច មិនមែននិរោធសច្ច មិនហៅថា និរោធ ។ មិនមែនមគ្គ មិនហៅថា មគ្គសច្ច មិនមែនមគ្គសច្ច មិនហៅថា មគ្គ ។

[ ២៦ ] ទុក្ខ ហៅថា ទុក្ខសច្ច សច្ចៈទាំងឡាយ ហៅថា សមុទយសច្ច ។ ទុក្ខ ហៅថា ទុក្ខសច្ច សច្ចៈទាំងឡាយ ហៅថា និរោធសច្ច ។ ទុក្ខ ហៅថា ទុក្ខសច្ច សច្ចៈទាំងឡាយ ហៅថា មគ្គសច្ច ។ សមុទយៈ

ហៅថា សមុទយសច្ច សច្ចៈទាំងឡាយ ហៅថា ទុក្ខសច្ច ។ សមុទយៈ ហៅថា សមុទយសច្ច សច្ចៈទាំងឡាយ ហៅថា និរោធសច្ច ។ សមុទយៈ ហៅថា សមុទយសច្ច សច្ចៈទាំងឡាយ ហៅថា មគ្គសច្ច ។ និរោធ ហៅថា និរោធសច្ច សច្ចៈទាំងឡាយ ហៅថា ទុក្ខសច្ច ។ និរោធ ហៅថា និរោធសច្ច សច្ចៈទាំងឡាយ ហៅថា សមុទយសច្ច ។ និរោធ ហៅថា និរោធសច្ច សច្ចៈទាំងឡាយ ហៅថា មគ្គសច្ច ។ មគ្គ ហៅថា មគ្គសច្ច សច្ចៈទាំងឡាយ ហៅថា ទុក្ខសច្ច ។ មគ្គ ហៅថា មគ្គសច្ច សច្ចៈទាំងឡាយ ហៅថា សមុទយសច្ច ។ មគ្គ ហៅថា មគ្គសច្ច សច្ចៈទាំងឡាយ ហៅថា និរោធសច្ច ។

[ ២៧ ] មិនមែនទុក្ខ មិនហៅថា ទុក្ខសច្ច មិនមែនសច្ចៈទាំងឡាយ មិនហៅថា សមុទយសច្ច ។ មិនមែនទុក្ខ មិនហៅថា ទុក្ខសច្ច មិនមែនសច្ចៈទាំងឡាយ មិនហៅថា និរោធសច្ច ។ មិនមែនទុក្ខ មិនហៅថា ទុក្ខសច្ច មិនមែនសច្ចៈទាំងឡាយ មិនហៅថា មគ្គសច្ច ។ មិនមែនសមុទយៈ មិនហៅថា សមុទយសច្ច មិនមែនសច្ចៈទាំងឡាយ មិនហៅថា ទុក្ខសច្ច ។ មិនមែនសមុទយៈ មិនហៅថា សមុទយសច្ច មិនមែនសច្ចៈទាំងឡាយ មិនហៅថា និរោធសច្ច ។ មិនមែនសមុទយៈ មិនហៅថា សមុទយសច្ច មិនមែនសច្ចៈទាំងឡាយ មិនហៅថា មគ្គសច្ច ។ មិនមែននិរោធ មិនហៅថា និរោធសច្ច មិនមែនសច្ចៈទាំងឡាយ មិនហៅថា ទុក្ខសច្ច ។ មិនមែននិរោធ មិនហៅថា និរោធសច្ច មិនមែនសច្ចៈទាំងឡាយ មិនហៅថា សមុទយសច្ច ។

មិនមែននិរោធ មិនហៅថា និរោធសច្ច មិនមែនសច្ចៈទាំងឡាយ មិនហៅថា មគ្គសច្ច ។ មិនមែនមគ្គ មិនហៅថា មគ្គសច្ច មិនមែនសច្ចៈទាំងឡាយ មិនហៅថា ទុក្ខសច្ច ។ មិនមែនមគ្គ មិនហៅថា មគ្គសច្ច មិនមែនសច្ចៈទាំងឡាយ មិនហៅថា សមុទយសច្ច ។ មិនមែនមគ្គ មិនហៅថា មគ្គសច្ច មិនមែនសច្ចៈទាំងឡាយ មិនហៅថា និរោធសច្ច ។

[ ២៨ ] ទុក្ខ ហៅថា សច្ចៈ សច្ចៈទាំងឡាយហៅថា ទុក្ខ ។ សមុទយៈ ហៅថា សច្ចៈ សច្ចៈទាំងឡាយ ហៅថា សមុទយៈ ។ និរោធ ហៅថា សច្ចៈ សច្ចៈទាំងឡាយ ហៅថា និរោធ ។ មគ្គ ហៅថា សច្ចៈ សច្ចៈទាំងឡាយ ហៅថា មគ្គ ។

[ ២៩ ] មិនមែនទុក្ខ មិនហៅថា សច្ចៈ មិនមែនសច្ចៈទាំងឡាយ មិនហៅថា ទុក្ខ ។ មិនមែនសមុទយៈ មិនហៅថា សច្ចៈ មិនមែនសច្ចៈទាំងឡាយ មិនហៅថា សមុទយៈ ។ មិនមែននិរោធ មិនហៅថា សច្ចៈ មិនមែនសច្ចៈទាំងឡាយ មិនហៅថា និរោធ ។ មិនមែនមគ្គ មិនហៅថា សច្ចៈ មិនមែនសច្ចៈទាំងឡាយ មិនហៅថា មគ្គ ។

[ ៣០ ] ទុក្ខ ហៅថា សច្ចៈ សច្ចៈទាំងឡាយ ហៅថា សមុទយៈ ។ ទុក្ខ ហៅថា សច្ចៈ សច្ចៈទាំងឡាយ ហៅថា និរោធ ។ ទុក្ខ ហៅថា សច្ចៈ សច្ចៈទាំងឡាយ ហៅថា មគ្គ ។ សមុទយៈ ហៅថា សច្ចៈ សច្ចៈទាំងឡាយ ហៅថា ទុក្ខ ។បេ។ សច្ចៈទាំងឡាយ ហៅថា មគ្គ ។ និរោធ ហៅថា សច្ចៈ សច្ចៈទាំងឡាយ ហៅថា ទុក្ខ ។បេ។ សច្ចៈទាំងឡាយ ហៅថា មគ្គ ។

មគ្គ ហៅថា សច្ចៈ សច្ចៈទាំងឡាយ ហៅថា ទុក្ខ ។ មគ្គ ហៅថា សច្ចៈ សច្ចៈទាំងឡាយ ហៅថា សមុទយៈ ។ មគ្គ ហៅថា សច្ចៈ សច្ចៈទាំងឡាយ ហៅថា និរោធ ។

[ ៣១ ] មិនមែនទុក្ខ មិនហៅថា សច្ចៈ មិនមែនសច្ចៈទាំងឡាយ មិនហៅថា សមុទយៈ ។ មិនមែនទុក្ខ មិនហៅថា សច្ចៈ មិនមែនសច្ចៈទាំងឡាយ មិនហៅថា និរោធ ។ មិនមែនទុក្ខ មិនហៅថា សច្ចៈ មិនមែនសច្ចៈទាំងឡាយ មិនហៅថា មគ្គ ។ មិនមែនសមុទយៈ មិនហៅថា សច្ចៈ មិនមែនសច្ចៈទាំងឡាយ មិនហៅថា ទុក្ខ ។បេ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថា មគ្គ ។ មិនមែននិរោធ មិនហៅថា សច្ចៈ មិនមែនសច្ចៈទាំងឡាយ មិនហៅថា ទុក្ខ ។បេ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថា មគ្គ ។ មិនមែនមគ្គ មិនហៅថា សច្ចៈ មិនមែនសច្ចៈទាំងឡាយ មិនហៅថា ទុក្ខ ។ មិនមែនមគ្គ មិនហៅថា សច្ចៈ មិនមែនសច្ចៈទាំងឡាយ មិនហៅថា សមុទយៈ ។ មិនមែនមគ្គ មិនហៅថា សច្ចៈ មិនមែនសច្ចៈទាំងឡាយ មិនហៅថា និរោធ ។

ឧទ្ទេសវារៈ ចប់

## និទ្ទេសវារៈ

[ ៣២ ] ទុក្ខ ហៅថា ទុក្ខសច្ចឬ ។ អើ ។ ទុក្ខសច្ច ហៅថា ទុក្ខឬ ។ ទុក្ខសច្ចដ៏សេស វៀរលែងទុក្ខប្រព្រឹត្តទៅក្នុងកាយ ទុក្ខប្រព្រឹត្តទៅក្នុងចិត្ត ហៅថា ទុក្ខសច្ច មិនហៅថា ទុក្ខ ឯទុក្ខប្រព្រឹត្តទៅក្នុងកាយ ទុក្ខប្រព្រឹត្តទៅ

ក្នុងចិត្ត ហៅថា ទុក្ខផង ហៅថា ទុក្ខសច្ចផង ។ សមុទយៈ ហៅថា សមុទយសច្ចឬ ។ សមុទយៈដ៏សេស វៀរលែងសមុទយសច្ច ហៅថា សមុទយៈ មិនហៅថា សមុទយសច្ច ឯសមុទយសច្ច ហៅថា សមុទយៈផង ហៅថា សមុទយសច្ចផង ។ សមុទយសច្ច ហៅថា សមុទយៈឬ ។ អើ ។ និរោធ ហៅថា និរោធសច្ចឬ ។ និរោធដ៏សេស វៀរលែងនិរោធសច្ច ហៅថា និរោធ មិនហៅថា និរោធសច្ច ឯនិរោធសច្ច ហៅថា និរោធផង ហៅថា និរោធសច្ចផង ។ និរោធសច្ច ហៅថា និរោធឬ ។ អើ ។ មគ្គ ហៅថា មគ្គសច្ចឬ ។ មគ្គដ៏សេស វៀរលែងមគ្គសច្ច ហៅថា មគ្គ មិនហៅថា មគ្គសច្ច ឯមគ្គសច្ច ហៅថា មគ្គផង ហៅថា មគ្គសច្ចផង ។ មគ្គសច្ច ហៅថា មគ្គឬ ។ អើ ។

[ ៣៣ ] មិនមែនទុក្ខ មិនហៅថា ទុក្ខសច្ចឬ ។ ទុក្ខសច្ចដ៏សេស វៀរលែងទុក្ខប្រព្រឹត្តទៅក្នុងកាយ ទុក្ខប្រព្រឹត្តទៅក្នុងចិត្ត មិនហៅថា ទុក្ខ ហៅថា ទុក្ខសច្ច ឯធម្មជាតដ៏សេស វៀរលែងទុក្ខ និងទុក្ខសច្ចចេញ មិនហៅថា ទុក្ខផង មិនហៅថា ទុក្ខសច្ចផង ។ មិនមែនទុក្ខសច្ច មិនហៅថា ទុក្ខឬ ។ អើ ។ មិនមែនសមុទយៈ មិនហៅថា សមុទយសច្ចឬ ។ អើ ។ មិនមែនសមុទយសច្ច មិនហៅថា សមុទយៈឬ ។ សមុទយៈដ៏សេស វៀរលែងសមុទយសច្ច មិនហៅថា សមុទយសច្ច ហៅថា សមុទយៈ ឯសភាវៈដ៏សេស វៀរលែងសមុទយៈ និងសមុទយសច្ចចេញ មិនហៅថា សមុទយៈផង មិនហៅថា សមុទយសច្ចផង ។ មិនមែននិរោធ មិនហៅថា និរោធសច្ច

ឬ ។ អើ ។ មិនមែននិរោធសច្ច មិនហៅថា និរោធឬ ។ និរោធដ៏សេស វៀរលែងនិរោធសច្ច មិនហៅថា និរោធសច្ច ហៅថា និរោធ ឯសភាវៈដ៏សេស វៀរលែងនិរោធ និងនិរោធសច្ចចេញ មិនហៅថា និរោធផង មិនហៅថា និរោធសច្ចផង ។ មិនមែនមគ្គ មិនហៅថា មគ្គសច្ចឬ ។ អើ ។ មិនមែនមគ្គសច្ច មិនហៅថា មគ្គឬ ។ មគ្គដ៏សេស វៀរលែងមគ្គសច្ច មិនហៅថា មគ្គសច្ច ហៅថា មគ្គ ឯសភាវៈដ៏សេស វៀរលែងមគ្គ និងមគ្គសច្ចចេញ មិនហៅថា មគ្គផង មិនហៅថា មគ្គសច្ចផង ។

[ ៣៤ ] ទុក្ខ ហៅថា ទុក្ខសច្ចឬ ។ អើ ។ សច្ចៈទាំងឡាយ ហៅថា សមុទយសច្ចឬ ។ សមុទយសច្ច ហៅថា សច្ចៈផង ហៅថា សមុទយសច្ចផង សច្ចៈទាំងឡាយដ៏សេស ហៅថា សច្ចៈ មិនហៅថា សមុទយសច្ចទេ ។ ទុក្ខ ហៅថា ទុក្ខសច្ចឬ ។ អើ ។ សច្ចៈទាំងឡាយ ហៅថា និរោធសច្ច ។បេ។ សច្ចៈទាំងឡាយ ហៅថា មគ្គសច្ចឬ ។ មគ្គសច្ច ហៅថា សច្ចៈផង ហៅថា មគ្គសច្ចផង សច្ចៈទាំងឡាយដ៏សេស ហៅថា សច្ចៈ មិនហៅថា មគ្គសច្ចទេ ។ សមុទយៈ ហៅថា សមុទយសច្ចឬ ។ សមុទយៈដ៏សេស វៀរលែងសមុទយសច្ច ហៅថា សមុទយៈ មិនហៅថា សមុទយសច្ច ឯសមុទយ-សច្ច ហៅថា សមុទយៈផង ហៅថា សមុទយសច្ចផង ។ សច្ចៈទាំងឡាយ ហៅថា ទុក្ខសច្ច ។បេ។ សច្ចៈទាំងឡាយ ហៅថា និរោធសច្ច ។បេ។ សច្ចៈទាំងឡាយ ហៅថា មគ្គសច្ចឬ ។ មគ្គសច្ច ហៅថា សច្ចៈផង ហៅថា មគ្គសច្ចផង សច្ចៈទាំងឡាយដ៏សេស ហៅថា សច្ចៈ មិនហៅថា មគ្គសច្ច

ទេ ។ និរោធ ហៅថា និរោធសច្ចឬ ។ និរោធដ៏សេស វៀរលែងនិរោធសច្ច ហៅថា និរោធ មិនហៅថា និរោធសច្ចទេ ឯនិរោធសច្ច ហៅថា និរោធផង ហៅថា និរោធសច្ចផង ។ សច្ចៈទាំងឡាយ ហៅថា ទុក្ខសច្ច ។បេ។ សច្ចៈទាំងឡាយ ហៅថា សមុទយសច្ច ។បេ។ សច្ចៈទាំងឡាយ ហៅថា មគ្គសច្ចឬ ។ មគ្គសច្ច ហៅថា សច្ចៈផង ហៅថា មគ្គសច្ចផង សច្ចៈទាំងឡាយដ៏សេស ហៅថា សច្ចៈ មិនហៅថា មគ្គសច្ចទេ ។ មគ្គ ហៅថា មគ្គសច្ចឬ ។ មគ្គដ៏សេស វៀរលែងមគ្គសច្ច ហៅថា មគ្គ មិនហៅថា មគ្គសច្ចទេ ឯមគ្គសច្ច ហៅថា មគ្គផង ហៅថា មគ្គសច្ចផង ។ សច្ចៈទាំងឡាយ ហៅថា ទុក្ខសច្ច ។បេ។ សច្ចៈទាំងឡាយ ហៅថា សមុទយសច្ច ។បេ។ សច្ចៈទាំងឡាយ ហៅថា និរោធសច្ចឬ ។ និរោធសច្ច ហៅថា សច្ចៈផង ហៅថា និរោធសច្ចផង សច្ចៈទាំងឡាយដ៏សេស ហៅថា សច្ចៈ មិនហៅថា និរោធសច្ចទេ ។

[ ៣៥ ] មិនមែនទុក្ខ មិនហៅថា ទុក្ខសច្ចឬ ។ ទុក្ខសច្ចដ៏សេស វៀរលែងទុក្ខប្រព្រឹត្តទៅក្នុងកាយ ទុក្ខប្រព្រឹត្តទៅក្នុងចិត្តចេញ មិនហៅថា ទុក្ខ ហៅថា ទុក្ខសច្ច ធម្មជាតដ៏សេស វៀរលែងទុក្ខ និងទុក្ខសច្ចចេញ មិនហៅថា ទុក្ខផង មិនហៅថា ទុក្ខសច្ចផង ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថា សមុទយសច្ចឬ ។ អើ ។ មិនមែនទុក្ខ មិនហៅថា ទុក្ខសច្ចឬ ។ ទុក្ខសច្ចដ៏សេស វៀរលែងទុក្ខប្រព្រឹត្តទៅក្នុងកាយ ទុក្ខប្រព្រឹត្តទៅក្នុងចិត្តចេញ មិនហៅថា ទុក្ខ ហៅថា ទុក្ខសច្ច ធម្មជាតដ៏សេស វៀរលែងទុក្ខ និងទុក្ខសច្ច

ចេញ មិនហៅថា ទុក្ខផង មិនហៅថា ទុក្ខសច្ចផង ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថា និរោធសច្ចឬ ។បេ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថា មគ្គសច្ចឬ ។ អើ ។ មិនមែនសមុទយៈ មិនហៅថា សមុទយសច្ចឬ ។ អើ ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថា ទុក្ខសច្ចឬ ។ អើ ។ មិនមែនសមុទយៈ មិនហៅថា សមុទយសច្ចឬ ។ អើ ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថា និរោធសច្ច ។បេ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថា មគ្គសច្ចឬ ។ អើ ។ មិនមែននិរោធ មិនហៅថា និរោធសច្ចឬ ។ អើ ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថា ទុក្ខសច្ចឬ ។បេ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថា សមុទយសច្ចឬ ។បេ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថា មគ្គ-សច្ចឬ ។ អើ ។ មិនមែនមគ្គ មិនហៅថា មគ្គសច្ចឬ ។ អើ ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថា ទុក្ខសច្ចឬ ។ អើ ។ មិនមែនមគ្គ មិនហៅថា មគ្គសច្ចឬ ។ អើ ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថា សមុទយសច្ចឬ ។បេ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថា និរោធសច្ចឬ ។ អើ ។

[ ៣៦ ] ទុក្ខ ហៅថា សច្ចៈឬ ។ អើ ។ សច្ចៈទាំងឡាយ ហៅថា ទុក្ខ-សច្ចឬ ។ ទុក្ខសច្ច ហៅថា សច្ចៈផង ហៅថា ទុក្ខសច្ចផង សច្ចៈទាំងឡាយដ៏សេស ហៅថា សច្ចៈ មិនហៅថា ទុក្ខសច្ចទេ ។ សមុទយៈ ហៅថា សច្ចៈឬ ។ អើ ។បេ។ និរោធ ហៅថា សច្ចៈឬ ។ អើ ។បេ។ មគ្គ ហៅថា សច្ចៈឬ ។ អើ ។ សច្ចៈទាំងឡាយ ហៅថា មគ្គសច្ចឬ ។ មគ្គសច្ច ហៅថា សច្ចៈផង ហៅថា មគ្គសច្ចផង សច្ចៈទាំងឡាយដ៏សេស ហៅថា សច្ចៈ មិនហៅ

ថា មគ្គសច្ចទេ ។

[ ៣៧ ] មិនមែនទុក្ខ មិនហៅថា សច្ចៈឬ ។ សច្ចៈទាំងឡាយដ៏សេស វៀរលែងទុក្ខ មិនហៅថា ទុក្ខ ហៅថា សច្ចៈ ធម្មជាតដ៏សេស វៀរលែងទុក្ខ និងសច្ចៈចេញ មិនហៅថា ទុក្ខផង មិនហៅថា សច្ចៈផង ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថា ទុក្ខសច្ចឬ ។ អើ ។ មិនមែនសមុទយៈ មិនហៅថា សច្ចៈឬ ។ ( សច្ចៈដ៏សេស ) វៀរលែងសមុទយៈ ។បេ។ មិនមែននិរោធ មិនហៅថា សច្ចៈឬ ។ ( សច្ចៈដ៏សេស ) វៀរលែងនិរោធ ។បេ។ មិនមែនមគ្គ មិនហៅថា សច្ចៈឬ ។ សច្ចៈទាំងឡាយដ៏សេស វៀរលែងមគ្គ មិនហៅថា មគ្គ ហៅថា សច្ចៈ ធម្មជាតដ៏សេស វៀរលែងមគ្គ និងសច្ចៈចេញ មិនហៅថា មគ្គផង មិនហៅថា សច្ចៈផង ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថា មគ្គសច្ចឬ ។ អើ ។

[ ៣៨ ] ទុក្ខ ហៅថា សច្ចៈឬ ។ អើ ។ សច្ចៈទាំងឡាយ ហៅថា សមុទយសច្ចឬ ។ សមុទយសច្ច ហៅថា សច្ចៈផង ហៅថា សមុទយសច្ចផង សច្ចៈទាំងឡាយដ៏សេស ហៅថា សច្ចៈ មិនហៅថា សមុទយសច្ចទេ ។ ទុក្ខ ហៅថា សច្ចៈឬ ។ អើ ។ សច្ចៈទាំងឡាយ ហៅថា និរោធសច្ច ។បេ។ សច្ចៈទាំងឡាយ ហៅថា មគ្គសច្ចឬ ។ មគ្គសច្ច ហៅថា សច្ចៈផង ហៅថា មគ្គសច្ចផង សច្ចៈទាំងឡាយដ៏សេស ហៅថា សច្ចៈ មិនហៅថា មគ្គសច្ចទេ ។ សមុទយៈ ហៅថា សច្ចៈឬ ។ អើ ។បេ។ និរោធ ហៅថា សច្ចៈឬ ។ អើ ។បេ។ មគ្គ ហៅថា សច្ចៈឬ ។ អើ ។ សច្ចៈទាំងឡាយ

ហៅថា ទុក្ខសច្ច ។បេ។ សច្ចៈទាំងឡាយ ហៅថា សមុទយសច្ច ។បេ។ សច្ចៈទាំងឡាយ ហៅថា និរោធសច្ចឬ ។ និរោធសច្ច ហៅថា សច្ចៈផង ហៅថា និរោធសច្ចផង សច្ចៈទាំងឡាយដ៏សេស ហៅថា សច្ចៈ មិនហៅថា និរោធសច្ចទេ ។

[ ៣៩ ] មិនមែនទុក្ខ មិនហៅថា សច្ចៈឬ ។ សច្ចៈទាំងឡាយដ៏សេស វៀរលែងទុក្ខ មិនហៅថា ទុក្ខ ហៅថា សច្ចៈ ធម្មជាតដ៏សេស វៀរលែងទុក្ខ និងសច្ចៈចេញ មិនហៅថា ទុក្ខផង មិនហៅថា សច្ចៈផង ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថា សមុទយសច្ចឬ ។ អើ ។ មិនមែនទុក្ខ មិនហៅថា សច្ចៈឬ ។ សច្ចៈទាំងឡាយដ៏សេស វៀរលែងទុក្ខ មិនហៅថា ទុក្ខ ហៅថា សច្ចៈ ធម្មជាតដ៏សេស វៀរលែងទុក្ខ និងសច្ចៈចេញ មិនហៅថា ទុក្ខផង មិនហៅថា សច្ចៈផង ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថា និរោធសច្ចឬ ។បេ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថា មគ្គសច្ចឬ ។ អើ ។ មិនមែនសមុទយៈ មិនហៅថា សច្ចៈឬ ។ សច្ចៈទាំងឡាយដ៏សេស វៀរលែងសមុទយៈ មិនហៅថា សមុទយៈ ហៅថា សច្ចៈ ធម្មជាតដ៏សេស វៀរលែងសមុទយៈ និងសច្ចៈចេញ មិនហៅថា សមុទយៈផង មិនហៅថា សច្ចៈផង ។បេ។ មិនមែននិរោធ មិនហៅថា សច្ចៈឬ ។ ( សច្ចៈទាំងឡាយដ៏សេស ) វៀរលែងនិរោធ ។បេ។ មិនមែនមគ្គ មិនហៅថា សច្ចៈឬ ។ សច្ចៈទាំងឡាយដ៏សេស វៀរលែងមគ្គ មិនហៅថា មគ្គ ហៅថា សច្ចៈ

*ធម្មជាតដ៏សេស វៀរលែងមគ្គ និងសច្ចៈចេញ មិនហៅថា មគ្គផង មិនហៅថា សច្ចៈផង ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថា ទុក្ខសច្ចឬ ។ អើ ។ មិនមែនមគ្គ មិនហៅថា សច្ចៈឬ ។ សច្ចៈទាំងឡាយដ៏សេស វៀរលែងមគ្គ មិនហៅថា មគ្គ ហៅថា សច្ចៈ ធម្មជាតដ៏សេស វៀរលែងមគ្គ និងសច្ចៈចេញ មិនហៅថា មគ្គផង មិនហៅថា សច្ចៈផង ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថា សមុទយសច្ចឬ ។បេ។ មិនមែនសច្ចៈទាំងឡាយ មិនហៅថា និរោធសច្ចឬ ។ អើ ។*

*បណ្ណត្តិវារៈ ចប់*

## បវត្តិវារៈ

*[ ៤០ ] ទុក្ខសច្ចរបស់សត្វណា កើតឡើង សមុទយសច្ចរបស់សត្វនោះ រមែងកើតឡើងឬ ។ ពួកសត្វទាំងអស់ កាលចាប់បដិសន្ធិ ទុក្ខសច្ចរបស់សត្វទាំងនោះ រមែងកើតឡើងក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកតណ្ហា ក្នុងកាលជាបច្ចុប្បន្ន ឯសមុទយសច្ចរបស់សត្វទាំងនោះ មិនកើតឡើងទេ ទុក្ខសច្ចរបស់សត្វទាំងនោះ រមែងកើតឡើងផង សមុទយសច្ច រមែងកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃតណ្ហា ។ មួយទៀត សមុទយសច្ចរបស់សត្វណា កើតឡើង ទុក្ខសច្ចរបស់សត្វនោះ រមែងកើតឡើងឬ ។ អើ ។*

*[ ៤១ ] ទុក្ខសច្ចរបស់សត្វណា កើតឡើង មគ្គសច្ចរបស់សត្វនោះ រមែងកើតឡើងឬ ។ ពួកសត្វទាំងអស់ កាលចាប់បដិសន្ធិ ទុក្ខសច្ចរបស់សត្វទាំងនោះ រមែងកើតឡើងក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកមគ្គ ក្នុង*

បច្ចុប្បន្ន ឯមគ្គសច្ចរបស់សត្វទាំងនោះ មិនកើតឡើងទេ ទុក្ខសច្ចរបស់សត្វទាំងនោះ រមែងកើតឡើងផង មគ្គសច្ចរមែងកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃមគ្គក្នុងបញ្ចវោការភព ។ មួយទៀត មគ្គសច្ចរបស់សត្វណា កើតឡើង ទុក្ខសច្ចរបស់សត្វនោះ រមែងកើតឡើងឬ ។ មគ្គសច្ចរបស់សត្វទាំងនោះ រមែងកើតឡើង ក្នុងឧប្បាទក្ខណៈនៃមគ្គ ក្នុងអរូបភព ទុក្ខសច្ចរបស់សត្វទាំងនោះ មិនកើតឡើងទេ មគ្គសច្ចរបស់សត្វទាំងនោះ រមែងកើតឡើងផង ទុក្ខសច្ច រមែងកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃមគ្គ ក្នុងបញ្ចវោការភព ។

[ ៤២ ] សមុទយសច្ចរបស់សត្វណា កើតឡើង មគ្គសច្ចរបស់សត្វនោះ រមែងកើតឡើងឬ ។ មិនកើតឡើងទេ ។ មួយទៀត មគ្គសច្ចរបស់សត្វណា កើតឡើង សមុទយសច្ចរបស់សត្វនោះ រមែងកើតឡើងឬ ។ មិនកើតឡើងទេ ។

[ ៤៣ ] ទុក្ខសច្ច កើតឡើងក្នុងទីណា សមុទយសច្ច រមែងកើតឡើងក្នុងទីនោះឬ ។ ទុក្ខសច្ចរមែងកើតឡើងក្នុងអសញ្ញសត្វនោះ ឯសមុទយសច្ច មិនកើតឡើង ក្នុងទីនោះទេ ទុក្ខសច្ច រមែងកើតឡើងផង សមុទយសច្ច រមែងកើតឡើងផង ក្នុងចតុវោការសត្វ និងបញ្ចវោការសត្វនោះ ។ មួយទៀត សមុទយសច្ច កើតឡើង ក្នុងទីណា ទុក្ខសច្ច រមែងកើតឡើង ក្នុងទីនោះឬ ។ អើ ។

[ ៤៤ ] ទុក្ខសច្ច កើតឡើងក្នុងទីណា មគ្គសច្ច រមែងកើតឡើងក្នុងទីនោះឬ ។ ទុក្ខសច្ច រមែងកើតឡើងក្នុងអបាយសត្វ និងអសញ្ញសត្វនោះ

ឯមគ្គសច្ច មិនកើតឡើង ក្នុងទីនោះទេ ។ ទុក្ខសច្ច រមែងកើតឡើងផង មគ្គសច្ច រមែងកើតឡើងផង ក្នុងចតុវោការសត្វ និងបញ្ចវោការសត្វដ៏សេសនោះ ។ មួយទៀត មគ្គសច្ច កើតឡើងក្នុងទីណា ទុក្ខសច្ច រមែងកើតឡើង ក្នុងទីនោះឬ ។ អើ ។

[ ៤៥ ] សមុទយសច្ច កើតឡើងក្នុងទីណា មគ្គសច្ច រមែងកើតឡើងក្នុងទីនោះឬ ។ សមុទយសច្ច រមែងកើតឡើងក្នុងអបាយសត្វនោះ ឯមគ្គសច្ច មិនកើតឡើងក្នុងទីនោះទេ សមុទយសច្ច រមែងកើតឡើងផង មគ្គសច្ច រមែងកើតឡើងផង ក្នុងចតុវោការសត្វ និងបញ្ចវោការសត្វដ៏សេសនោះ ។ មួយទៀត មគ្គសច្ច កើតឡើងក្នុងទីណា សមុទយសច្ច រមែងកើតឡើងក្នុងទីនោះឬ ។ អើ ។

[ ៤៦ ] ទុក្ខសច្ច របស់សត្វណា កើតឡើងក្នុងទីណា សមុទយសច្ច របស់សត្វនោះ រមែងកើតឡើង ក្នុងទីនោះឬ ។ ពាក្យថា របស់សត្វណាក្តី ពាក្យថា របស់សត្វណា ក្នុងទីណាក្តី បណ្ឌិតគប្បីឲ្យពិស្តារដូចគ្នាចុះ ។

[ ៤៧ ] ទុក្ខសច្ច របស់សត្វណា មិនកើតឡើង សមុទយសច្ច របស់សត្វនោះ មិនកើតឡើងដែរឬ ។ អើ ។ មួយទៀត សមុទយសច្ចរបស់សត្វណា មិនកើតឡើង ទុក្ខសច្ចរបស់សត្វនោះ មិនកើតឡើងឬ ។ ពួកសត្វទាំងអស់ កាលចាប់បដិសន្ធិ សមុទយសច្ចរបស់សត្វទាំងនោះ រមែងមិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលប្រាសចាកតណ្ហា ក្នុងបច្ចុប្បន្ន ឯទុក្ខសច្ចរបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ពួកសត្វទាំងអស់ កាល

ច្យុត សមុទយសច្ចរបស់សត្វទាំងអស់នោះ មិនកើតឡើងផង ទុក្ខសច្ច មិនកើតឡើងផង ក្នុងភង្គក្ខណៈនៃចិត្តក្នុងបច្ចុប្បន្នផង ក្នុងឧប្បាទក្ខណៈនៃមគ្គនិងផល ក្នុងអរូបភពផង ។

[ ៤៨ ] ទុក្ខសច្ច របស់សត្វណា មិនកើតឡើង មគ្គសច្ច របស់សត្វនោះ មិនកើតឡើងឬ ។ ទុក្ខសច្ចរបស់សត្វទាំងនោះ មិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃមគ្គក្នុងអរូបភព ឯមគ្គសច្ចរបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ពួកសត្វទាំងអស់ កាលច្យុត ទុក្ខសច្ចរបស់សត្វទាំងនោះ មិនកើតឡើងផង មគ្គសច្ចមិនកើតឡើងផង ក្នុងភង្គក្ខណៈនៃចិត្តក្នុងបច្ចុប្បន្នផង ក្នុងឧប្បាទក្ខណៈនៃផល ក្នុងអរូបភពផង ។ មួយទៀត មគ្គសច្ចរបស់សត្វណា មិនកើតឡើង ទុក្ខសច្ចរបស់សត្វនោះ មិនកើតឡើងឬ ។ ពួកសត្វទាំងអស់ កាលចាប់បដិសន្ធិ មគ្គសច្ចរបស់សត្វទាំងនោះ មិនកើតឡើង ក្នុងឧប្បាទក្ខណៈ នៃចិត្តដែលប្រាសចាកមគ្គ ក្នុងបច្ចុប្បន្ន ឯទុក្ខសច្ចរបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ពួកសត្វទាំងអស់ កាលច្យុត មគ្គសច្ចរបស់សត្វទាំងនោះ មិនកើតឡើងផង ទុក្ខសច្ច មិនកើតឡើងផង ក្នុងភង្គក្ខណៈនៃចិត្តក្នុងបច្ចុប្បន្នផង ក្នុងឧប្បាទក្ខណៈនៃផលក្នុងអរូបភពផង ។

[ ៤៩ ] សមុទយសច្ចរបស់សត្វណា មិនកើតឡើង មគ្គសច្ចរបស់សត្វនោះ មិនកើតឡើងឬ ។ សមុទយសច្ចរបស់សត្វទាំងនោះ មិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃមគ្គ ឯមគ្គសច្ចរបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ សមុទយសច្ចរបស់ពួកអសញ្ញសត្វទាំងនោះ ដែលចូលកាន់និរោធ

មិនកើតឡើងផង មគ្គសច្ច មិនកើតឡើងផង ក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកតណ្ហា និងប្រាសចាកមគ្គរបស់ពួកសត្វទាំងអស់ ។ មួយទៀត មគ្គសច្ចរបស់សត្វណា មិនកើតឡើង សមុទយសច្ចរបស់សត្វនោះ មិនកើតឡើងដែរឬ ។ មគ្គសច្ចរបស់សត្វទាំងនោះ មិនកើតឡើងក្នុងឧប្បាទក្ខណៈនៃតណ្ហា ឯសមុទយសច្ចរបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ មគ្គសច្ចរបស់អសញ្ញសត្វទាំងនោះ ដែលចូលកាន់និរោធ មិនកើតឡើងផង សមុទយសច្ចមិនកើតឡើងផង ក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលប្រាសចាកមគ្គ និងប្រាសចាកតណ្ហារបស់ពួកសត្វទាំងអស់ ។

[ ៥០ ] ទុក្ខសច្ច មិនកើតឡើងក្នុងទីណា សមុទយសច្ច មិនកើតឡើងក្នុងទីនោះឬ ។ មិនមានទេ ។ មួយទៀត សមុទយសច្ច មិនកើតឡើងក្នុងទីណា ទុក្ខសច្ច មិនកើតឡើងក្នុងទីនោះឬ ។ កើតឡើង ។

[ ៥១ ] ទុក្ខសច្ច មិនកើតឡើងក្នុងទីណា មគ្គសច្ច មិនកើតឡើងក្នុងទីនោះឬ ។ មិនមានទេ ។ មួយទៀត មគ្គសច្ច មិនកើតឡើងក្នុងទីណា ទុក្ខសច្ច មិនកើតឡើងក្នុងទីនោះឬ ។ កើតឡើង ។

[ ៥២ ] សមុទយសច្ច មិនកើតឡើងក្នុងទីណា មគ្គសច្ច មិនកើតឡើងក្នុងទីនោះឬ ។ អើ ។ មួយទៀត មគ្គសច្ច មិនកើតឡើងក្នុងទីណា សមុទយសច្ច មិនកើតឡើងក្នុងទីនោះឬ ។ មគ្គសច្ច មិនកើតឡើងក្នុងអបាយនោះ ឯសមុទយសច្ច មិនមែនជាមិនកើតឡើងក្នុងទីនោះទេ ។ មគ្គសច្ច មិន

កើតឡើងផង សមុទយសច្ច មិនកើតឡើងផង ក្នុងអសញ្ញសត្វនោះ ។

[ ៥៣ ] ទុក្ខសច្ច របស់សត្វណា មិនកើតឡើងក្នុងទីណា សមុទយសច្ច របស់សត្វនោះ មិនកើតឡើងក្នុងទីនោះដែរឬ ។ អើ ។ មួយទៀត សមុទយសច្ច របស់សត្វណា មិនកើតឡើងក្នុងទីណា ទុក្ខសច្ច របស់សត្វនោះ មិនកើតឡើងក្នុងទីនោះឬ ។ ពួកសត្វទាំងអស់ កាលចាប់បដិសន្ធិ សមុទយសច្ច របស់សត្វទាំងនោះ មិនកើតឡើងក្នុងឧប្បាទក្ខណៈ នៃចិត្ត ដែលប្រាសចាកតណ្ហា ក្នុងបច្ចុប្បន្នក្នុងទីនោះ ឯទុក្ខសច្ចរបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងក្នុងទីនោះទេ ពួកសត្វទាំងអស់ កាលច្យុត សមុទយសច្ច របស់សត្វទាំងនោះ មិនកើតឡើងផង ទុក្ខសច្ច មិនកើតឡើងផង ក្នុងភង្គក្ខណៈនៃចិត្តក្នុងបច្ចុប្បន្ន ក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព ក្នុងទីនោះ ។

[ ៥៤ ] ទុក្ខសច្ច របស់សត្វណា មិនកើតឡើងក្នុងទីណា មគ្គសច្ច របស់សត្វនោះ មិនកើតឡើងក្នុងទីនោះឬ ។ ទុក្ខសច្ចរបស់សត្វទាំងនោះ មិន កើតឡើងក្នុងឧប្បាទក្ខណៈនៃមគ្គក្នុងអរូបភពនោះ ឯមគ្គសច្ចរបស់សត្វទាំង នោះ មិនមែនជាមិនកើតឡើងក្នុងទីនោះទេ ពួកសត្វទាំងអស់ កាលច្យុត ទុក្ខសច្ច របស់សត្វទាំងនោះ មិនកើតឡើងផង មគ្គសច្ចមិនកើតឡើងផង ក្នុងភង្គក្ខណៈនៃចិត្តក្នុងបច្ចុប្បន្ន និងក្នុងឧប្បាទក្ខណៈនៃផល ក្នុងអរូបភព ក្នុងទីនោះ ។ មួយទៀត មគ្គសច្ច របស់សត្វណា មិនកើតឡើងក្នុងទីណា ទុក្ខសច្ច របស់សត្វនោះ មិនកើតឡើងក្នុងទីនោះឬ ។ ពួកសត្វទាំងអស់ កាល

ចាប់បដិសន្ធិ មគ្គសច្ចរបស់សត្វទាំងនោះ មិនកើតឡើងក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកមគ្គ ក្នុងបច្ចុប្បន្នក្នុងទីនោះ ឯទុក្ខសច្ចរបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងក្នុងទីនោះទេ ពួកសត្វទាំងអស់ កាលច្យុត មគ្គសច្ចរបស់សត្វទាំងនោះ មិនកើតឡើងផង ទុក្ខសច្ច មិនកើតឡើងផង ក្នុងភង្គក្ខណៈនៃចិត្តក្នុងបច្ចុប្បន្ន និងក្នុងឧប្បាទក្ខណៈនៃផល ក្នុងអរូបភព ក្នុងទីនោះ ។

[ ៥៥ ] សមុទយសច្ចរបស់សត្វណា មិនកើតឡើងក្នុងទីណា មគ្គសច្ចរបស់សត្វនោះ មិនកើតឡើងក្នុងទីនោះឬ ។ សមុទយសច្ចរបស់សត្វទាំងនោះ មិនកើតឡើងក្នុងឧប្បាទក្ខណៈនៃមគ្គ ក្នុងទីនោះ ឯមគ្គសច្ចរបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងក្នុងទីនោះទេ ។ សមុទយសច្ចរបស់ពួកអសញ្ញសត្វទាំងនោះ ដែលចូលកាន់និរោធ មិនកើតឡើងផង មគ្គសច្ចមិនកើតឡើងផង ក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលប្រាសចាកតណ្ហា និងប្រាសចាកមគ្គរបស់ពួកសត្វទាំងអស់ ។ មួយទៀត មគ្គសច្ចរបស់សត្វណា មិនកើតឡើងក្នុងទីណា សមុទយសច្ចរបស់សត្វនោះ មិនកើតឡើងក្នុងទីនោះដែរឬ ។ មគ្គសច្ចរបស់សត្វទាំងនោះ មិនកើតឡើងក្នុងឧប្បាទក្ខណៈនៃតណ្ហា ក្នុងទីនោះ ឯសមុទយសច្ច របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ មគ្គសច្ច របស់ពួកអសញ្ញសត្វទាំងនោះ ដែលចូលកាន់និរោធ មិនកើតឡើងផង សមុទយសច្ច មិនកើតឡើងផង ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងឧប្បាទក្ខណៈនៃចិត្តដែលប្រាសចាកមគ្គ និង

ប្រាសចាកតណ្ហារបស់ពួកសត្វទាំងអស់ ក្នុងទីនោះ ។

[ ៥៦ ] ទុក្ខសច្ចរបស់សត្វណា កើតឡើងហើយ សមុទយសច្ចរបស់សត្វនោះ កើតឡើងហើយឬ ។ អើ ។ មួយទៀត សមុទយសច្ចរបស់សត្វណា កើតឡើងហើយ ទុក្ខសច្ចរបស់សត្វនោះ កើតឡើងហើយឬ ។ អើ ។

[ ៥៧ ] ទុក្ខសច្ច របស់សត្វណា កើតឡើងហើយ មគ្គសច្ច របស់សត្វនោះ កើតឡើងហើយឬ ។ ទុក្ខសច្ចរបស់សត្វទាំងនោះ ដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ កើតឡើងហើយ ឯមគ្គសច្ចរបស់សត្វទាំងនោះ មិនកើតឡើងហើយទេ ទុក្ខសច្ចរបស់សត្វទាំងនោះ ដែលជាអ្នកត្រាស់ដឹងនូវសច្ចៈ ៤ កើតឡើងហើយផង មគ្គសច្ច កើតឡើងហើយផង ។ មួយទៀត មគ្គសច្ចរបស់សត្វណា ( កើតឡើងហើយ ) ។បេ។ ឬ ។ អើ ។

[ ៥៨ ] សមុទយសច្ច របស់សត្វណា កើតឡើងហើយ មគ្គសច្ច របស់សត្វនោះ កើតឡើងហើយឬ ។ សមុទយសច្ច របស់សត្វទាំងនោះ ដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ កើតឡើងហើយ ឯមគ្គសច្ចរបស់សត្វទាំងនោះ មិនកើតឡើងហើយទេ សមុទយសច្ច របស់សត្វទាំងនោះ ដែលជាអ្នកត្រាស់ដឹងនូវសច្ចៈ ៤ កើតឡើងហើយផង មគ្គសច្ច កើតឡើងហើយផង ។ មួយទៀត មគ្គសច្ច របស់សត្វណា ( កើតឡើងហើយ ) ។បេ។ ឬ ។ អើ ។

[ ៥៩ ] ទុក្ខសច្ច កើតឡើងហើយ ក្នុងទីណា ។បេ។ ពាក្យថា ក្នុងទីណា ប្រហែលៗ គ្នា ក្នុងទីទាំងពួង ការធ្វើនូវរបៀបផ្សេងៗ ក៏ប្រហែលគ្នា

នឹងពាក្យថា ក្នុងទីណា ខាងក្រោមដែរ ។

[ ៦០ ] ទុក្ខសច្ច របស់សត្វណា កើតឡើងហើយ ក្នុងទីណា សមុទយសច្ច របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះឬ ។ ទុក្ខសច្ច កើតឡើយហើយក្នុងចិត្តទី ២ របស់ពួកសុទ្ធាវាសសត្វកំពុងប្រព្រឹត្តទៅ និងពួកអសញ្ញសត្វទាំងនោះ ក្នុងទីនោះ ឯសមុទយសច្ច របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ទុក្ខសច្ច របស់សត្វទាំងនោះ ក្រៅនេះ ដែលស្ថិតនៅក្នុងចតុវោការភព និងបញ្ចវោការភព កើតឡើងហើយផង សមុទយសច្ច កើតឡើងហើយផង ក្នុងទីនោះ ។ មួយទៀត សមុទយសច្ចរបស់សត្វណា ( កើតឡើងហើយ ) ក្នុងទីណា ។បេ។ ឬ ។ អើ ។

[ ៦១ ] ទុក្ខសច្ច របស់សត្វណា កើតឡើងហើយក្នុងទីណា មគ្គសច្ច របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះឬ ។ ទុក្ខសច្ច កើតឡើងក្នុងចិត្តទី ២ របស់ពួកសុទ្ធាវាសសត្វ កំពុងប្រព្រឹត្តទៅ និងពួកអសញ្ញសត្វទាំងនោះ ដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ ក្នុងទីនោះ ឯមគ្គសច្ចរបស់សត្វទាំងនោះ មិនកើតឡើងហើយក្នុងទីនោះទេ ទុក្ខសច្ច របស់សត្វទាំងនោះ ដែលជាអ្នកត្រាស់ដឹងនូវសច្ចៈ ៤ កើតឡើងហើយផង មគ្គសច្ច កើតឡើងហើយផង ក្នុងទីនោះ ។ មួយទៀត មគ្គសច្ច របស់សត្វណា ( កើតឡើងហើយ ) ក្នុងទីណា ។បេ។ ឬ ។ អើ ។

[ ៦២ ] សមុទយសច្ច របស់សត្វណា កើតឡើងហើយ ក្នុងទីណា មគ្គសច្ច របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះឬ ។ សមុទយសច្ច

កើតឡើងហើយ ក្នុងអកុសលចិត្តទី ២ របស់ពួកសុទ្ធាវាសសត្វ កំពុងប្រព្រឹត្តទៅ និងពួកសត្វទាំងនោះ ដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ ក្នុងទីនោះ ឯមគ្គសច្ចរបស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ សមុទយសច្ច របស់សត្វទាំងនោះ ដែលជាអ្នកត្រាស់ដឹងនូវសច្ចៈ ៤ កើតឡើងហើយផង មគ្គសច្ច កើតឡើងហើយផង ក្នុងទីនោះ ។ មួយទៀត មគ្គសច្ច របស់សត្វណា កើតឡើងហើយ ក្នុងទីណា ។បេ។ ឬ ។ អើ ។

[ ៦៣ ] ទុក្ខសច្ច របស់សត្វណា មិនកើតឡើងហើយ សមុទយសច្ច របស់សត្វនោះ មិនកើតឡើងហើយឬ ។ មិនមានទេ ។ មួយទៀត សមុ-ទយសច្ចរបស់សត្វណា ( មិនកើតឡើងហើយ ) ។បេ។ ឬ ។ មិនមានទេ ។

[ ៦៤ ] ទុក្ខសច្ចរបស់សត្វណា មិនកើតឡើងហើយ មគ្គសច្ចរបស់សត្វនោះ មិនកើតឡើងហើយឬ ។ មិនមានទេ ។ មួយទៀត មគ្គសច្ចរបស់សត្វណា មិនកើតឡើងហើយ ទុក្ខសច្ចរបស់សត្វនោះ មិនកើតឡើងឬ ។ កើតឡើងហើយ ។

[ ៦៥ ] សមុទយសច្ច របស់សត្វណា មិនកើតឡើងហើយ មគ្គសច្ច របស់សត្វនោះ មិនកើតឡើងហើយឬ ។ មិនមានទេ ។ មួយទៀត មគ្គសច្ច របស់សត្វណា មិនកើតឡើងហើយ សមុទយសច្ច របស់សត្វនោះ មិនកើតឡើងហើយឬ ។ កើតឡើងហើយ ។

[ ៦៦ ] ទុក្ខសច្ច មិនកើតឡើងហើយ ក្នុងទីណា ។បេ។

[ ៦៧ ] ទុក្ខសច្ច របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា

សមុទយសច្ច របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ អើ ។ មួយទៀត សមុទយសច្ច របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា ទុក្ខសច្ច របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ សមុទយសច្ច មិនកើតឡើងហើយ ក្នុងចិត្តទី ២ របស់ពួកសុទ្ធាវាសសត្វ កំពុងប្រព្រឹត្តទៅ និងពួកអសញ្ញសត្វនោះ ក្នុងទីនោះ ឯទុក្ខសច្ច របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស សមុទយសច្ច របស់សត្វទាំងនោះ មិនកើតឡើងហើយផង ទុក្ខសច្ច មិនកើតឡើងហើយផង ក្នុងទីនោះទេ ។

[ ៦៨ ] ទុក្ខសច្ចរបស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា មគ្គសច្ចរបស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត មគ្គសច្ចរបស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា ទុក្ខសច្ចរបស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ ចិត្តទី ២ របស់ពួកសុទ្ធាវាសសត្វ កំពុងប្រព្រឹត្តទៅ និងពួកអសញ្ញសត្វ ដែលមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ មគ្គសច្ចរបស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែទុក្ខសច្ចរបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស មគ្គសច្ច របស់សត្វទាំងនោះ មិនកើតឡើងហើយផង ទុក្ខសច្ច មិនកើតឡើងហើយផង ក្នុងទីនោះ ។

[ ៦៩ ] សមុទយសច្ចរបស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា មគ្គសច្ច របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ អើ ។ មួយ

ទៀត មគ្គសច្ច របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា សមុទយ-សច្ច របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ អកុសលចិត្តទី ២ របស់ពួកសុទ្ធាវាសសត្វ កំពុងប្រព្រឹត្តទៅ និងពួកសត្វដែលមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ មគ្គសច្ច របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែសមុទយសច្ច របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយក្នុងទីនោះទេ ចិត្តទី ២ របស់ពួកសុទ្ធាវាសសត្វ កំពុងប្រព្រឹត្តទៅ និងពួកអសញ្ញសត្វ មគ្គសច្ច របស់សត្វទាំងនោះ មិនកើតឡើងហើយផង សមុ-ទយសច្ច មិនកើតឡើងហើយផង ក្នុងទីនោះ ។

[ ៧០ ] ទុក្ខសច្ច របស់សត្វណា នឹងកើតឡើង សមុទយសច្ច របស់សត្វនោះ នឹងកើតឡើងឬ ។ ព្រះអរហន្តទាំងឡាយ ដែលប្រកបដោយមគ្គដ៏ប្រសើរ និងពួកសត្វនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ទុក្ខ-សច្ច របស់សត្វទាំងនោះ នឹងកើតឡើង ( ក្នុងលំដាប់នៃចិត្តនោះ ) តែសមុ-ទយសច្ច របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ ទុក្ខសច្ច របស់សត្វទាំងនោះ ក្រៅនេះ នឹងកើតឡើងផង សមុទយសច្ច នឹងកើតឡើងផង ។ មួយយ៉ាងទៀត សមុទយសច្ចរបស់សត្វណា នឹងកើតឡើងឬ ។បេ។ អើ ។

[ ៧១ ] ទុក្ខសច្ច របស់សត្វណា នឹងកើតឡើង មគ្គសច្ចរបស់សត្វនោះនឹងកើតឡើងឬ ។ ព្រះអរហន្តទាំងឡាយ ដែលប្រកបដោយមគ្គដ៏ប្រសើរ និងពួកសត្វណា ជាបុថុជ្ជន នឹងមិនបាននូវមគ្គ ទុក្ខសច្ចរបស់សត្វទាំងនោះ នឹងកើតឡើង តែមគ្គសច្ចរបស់សត្វទាំងនោះ នឹងមិនកើតឡើងទេ ពួកសត្វ នឹង

បានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ឬក៏សត្វដទៃណា នឹងបានទូវមគ្គ ទុក្ខសច្ចរបស់សត្វទាំងនោះ នឹងកើតឡើងផង មគ្គសច្ច នឹងកើតឡើងផង ។ មួយយ៉ាងទៀត មគ្គសច្ចរបស់សត្វណា ( នឹងកើតឡើង ) ឬ ។បេ។ អើ ។

[ ៧២ ] សមុទយសច្ច របស់សត្វណា នឹងកើតឡើង មគ្គសច្ច របស់សត្វនោះ នឹងកើតឡើងឬ ។ ពួកសត្វណា ជាបុថុជ្ជន នឹងមិនបានទូវមគ្គ សមុទយសច្ចរបស់សត្វទាំងនោះ នឹងកើតឡើង តែមគ្គសច្ច របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ ពួកសត្វណា នឹងបានទូវមគ្គ សមុទយសច្ចរបស់សត្វទាំងនោះ នឹងកើតឡើងផង មគ្គសច្ច នឹងកើតឡើងផង ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងកើតឡើង សមុទយសច្ច របស់សត្វនោះ នឹងកើតឡើងឬ ។ ពួកសត្វណា នឹងបានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា មគ្គសច្ចរបស់សត្វទាំងនោះ នឹងកើតឡើង ( ក្នុងលំដាប់នៃចិត្តនោះ ) តែសមុទយសច្ចរបស់សត្វទាំងនោះ នឹងមិនកើតឡើងទេ ឬក៏សត្វដទៃណា នឹងបានទូវមគ្គ មគ្គសច្ចរបស់សត្វទាំងនោះ នឹងកើតឡើងផង សមុទយសច្ច នឹងកើតឡើងផង ។

[ ៧៣ ] ទុក្ខសច្ច នឹងកើតឡើង ក្នុងទីណា ។បេ។

[ ៧៤ ] ទុក្ខសច្ច របស់សត្វណា នឹងកើតឡើងក្នុងទីណា សមុទយសច្ច របស់សត្វនោះ នឹងកើតឡើងក្នុងទីនោះឬ ។ ព្រះអរហន្តទាំងឡាយ ដែលប្រកបដោយមគ្គដ៏ប្រសើរ ពួកសត្វនឹងបានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា និងពួកអសញ្ញសត្វ ទុក្ខសច្ច របស់សត្វទាំងនោះ នឹងកើតឡើងក្នុងទីនោះ

( ក្នុងលំដាប់នៃចិត្តនោះ ) តែសមុទយសច្ច របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វក្រៅនេះ ដែលស្ថិតនៅក្នុងចតុវោការភព និងបញ្ចវោការភព ទុក្ខសច្ច របស់សត្វទាំងនោះ នឹងកើតឡើងផង សមុទយសច្ច នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សមុទយសច្ច របស់សត្វណា ( នឹងកើតឡើង ) ក្នុងទីណាឬ ។បេ។ អើ ។

[ ៧៥ ] ទុក្ខសច្ច របស់សត្វណា នឹងកើតឡើង ក្នុងទីណា មគ្គសច្ច របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ ព្រះអរហន្តទាំងឡាយ ដែលប្រកបដោយមគ្គដ៏ប្រសើរ និងពួកសត្វណា ជាបុថុជ្ជន នឹងមិនបាននូវមគ្គ ពួកសត្វដែលកើតក្នុងអបាយ និងពួកអសញ្ញសត្វ ទុក្ខសច្ច របស់សត្វទាំងនោះ នឹងកើតឡើង ក្នុងទីនោះ តែមគ្គសច្ច របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ឬក៏ពួកសត្វដទៃណា នឹងបាននូវមគ្គ ទុក្ខសច្ច របស់សត្វទាំងនោះ នឹងកើតឡើងផង មគ្គសច្ច នឹងកើតឡើងផង ក្នុងទីនោះ ( ក្នុងលំដាប់នៃចិត្តនោះ ) ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងកើតឡើងក្នុងទីណា ទុក្ខសច្ច របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ អើ ។

[ ៧៦ ] សមុទយសច្ច របស់សត្វណា នឹងកើតឡើងក្នុងទីណា មគ្គសច្ចរបស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ ពួកសត្វដែលកើតក្នុងអបាយ និងពួកសត្វណា ជាបុថុជ្ជន នឹងមិនបាននូវមគ្គ សមុទយសច្ចរបស់សត្វទាំងនោះ នឹងកើតឡើង ក្នុងទីនោះ តែមគ្គសច្ចរបស់សត្វទាំងនោះ នឹង

មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វណា នឹងបានទូវមគ្គ សមុទយសច្ចរបស់សត្វទាំងនោះ នឹងកើតឡើងផង មគ្គសច្ច នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មគ្គសច្ចរបស់សត្វណា នឹងកើតឡើងក្នុងទីណា សមុទយ-សច្ចរបស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ ពួកសត្វនឹងបានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា មគ្គសច្ចរបស់សត្វទាំងនោះ នឹងកើតឡើង ក្នុងទីនោះ ( ក្នុងលំដាប់នៃចិត្តនោះ ) តែសមុទយសច្ច របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ឬក៏ពួកសត្វដទៃណា នឹងបានទូវមគ្គ មគ្គសច្ច របស់សត្វទាំងនោះ នឹងកើតឡើងផង សមុទយសច្ច នឹងកើតឡើងផង ក្នុងទីនោះ ។

[ ៧៧ ] ទុក្ខសច្ចរបស់សត្វណា នឹងមិនកើតឡើង សមុទយសច្ចរបស់សត្វនោះ នឹងមិនកើតឡើងឬ ។ អើ ។ មួយយ៉ាងទៀត សមុទយសច្ចរបស់សត្វណា នឹងមិនកើតឡើង ទុក្ខសច្ចរបស់សត្វនោះ នឹងមិនកើតឡើងឬ ។ ព្រះអរហន្តទាំងឡាយ ដែលប្រកបដោយមគ្គដ៏ប្រសើរ និងពួកសត្វ នឹងបានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា សមុទយសច្ច របស់សត្វទាំងនោះ នឹងមិនកើតឡើង ( ក្នុងលំដាប់នៃចិត្តនោះ ) តែទុក្ខសច្ច របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ ពួកសត្វដែលប្រកបដោយចិត្តជាទីបំផុត សមុ-ទយសច្ច របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ទុក្ខសច្ច នឹងមិនកើតឡើងផង ។

[ ៧៨ ] ទុក្ខសច្ច របស់សត្វណា នឹងមិនកើតឡើង មគ្គសច្ច របស់

សត្វនោះ នឹងមិនកើតឡើងឬ ។ អើ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងមិនកើតឡើង ទុក្ខសច្ច របស់សត្វនោះ នឹងមិនកើតឡើងឬ ។ ព្រះអរហន្តទាំងឡាយ ដែលប្រកបដោយមគ្គដ៏ប្រសើរ និងពួកសត្វណា ជាបុថុជ្ជន នឹងមិនបាននូវមគ្គ មគ្គសច្ចរបស់សត្វទាំងនោះ នឹងមិនកើតឡើង តែទុក្ខសច្ច របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ពួកសត្វដែលប្រកបដោយចិត្តជាទីបំផុត មគ្គសច្ច របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ទុក្ខសច្ច នឹងមិនកើតឡើងផង ។

[ ៧៩ ] សមុទយសច្ច របស់សត្វណា នឹងមិនកើតឡើង មគ្គសច្ច របស់សត្វនោះ នឹងមិនកើតឡើងឬ ។ ពួកសត្វនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា សមុទយសច្ច របស់សត្វទាំងនោះ នឹងមិនកើតឡើង តែមគ្គសច្ច របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ព្រះអរហន្តទាំងឡាយ ដែលប្រកបដោយមគ្គដ៏ប្រសើរ សមុទយសច្ច របស់សត្វទាំងនោះ នឹងមិនកើតឡើងផង មគ្គសច្ច នឹងមិនកើតឡើងផង ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងមិនកើតឡើង សមុទយសច្ច របស់សត្វនោះ នឹងមិនកើតឡើងឬ ។ ពួកសត្វណា ជាបុថុជ្ជន នឹងមិនបាននូវមគ្គ មគ្គសច្ច របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ តែសមុទយសច្ចរបស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ ព្រះអរហន្តទាំងឡាយ ដែលប្រកបដោយមគ្គដ៏ប្រសើរ មគ្គសច្ច របស់សត្វទាំងនោះ នឹងមិនកើតឡើងផង សមុទយសច្ច នឹងមិនកើតឡើងផង ។

[ ៨០ ] ទុក្ខសច្ច នឹងមិនកើតឡើងក្នុងទីណា ។បេ។

[ ៨១ ] ទុក្ខសច្ច របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា សមុទយសច្ច របស់សត្វនោះ នឹងមិនកើតឡើងក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត សមុទយសច្ច របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ទុក្ខសច្ច របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ព្រះអរហន្តទាំងឡាយ ដែលប្រកបដោយមគ្គដ៏ប្រសើរ ពួកសត្វ នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា និងពួកអសញ្ញសត្វ សមុទយសច្ចរបស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ ( ក្នុងលំដាប់នៃចិត្តនោះ ) តែទុក្ខសច្ច របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ ដែលប្រកបដោយចិត្តជាទីផុត សមុទយសច្ច របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ទុក្ខសច្ច នឹងមិនកើតឡើងផង ក្នុងទីនោះ ។

[ ៨២ ] ទុក្ខសច្ចរបស់សត្វណា នឹងមិនកើតឡើងក្នុងទីណា មគ្គសច្ច របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត មគ្គសច្ចរបស់សត្វណា នឹងមិនកើតឡើងក្នុងទីណា ទុក្ខសច្ចរបស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ព្រះអរហន្តទាំងឡាយ ដែលប្រកបដោយមគ្គដ៏ប្រសើរ ពួកសត្វណា ជាបុថុជ្ជន នឹងមិនបាននូវមគ្គ ពួកសត្វដែលកើតក្នុងអបាយ និងពួកអសញ្ញសត្វ មគ្គសច្ច របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងក្នុងទីនោះទេ ពួកសត្វ ដែលប្រកបដោយចិត្តជាទីបំផុត មគ្គសច្ចរបស់

សត្វទាំងនោះ នឹងមិនកើតឡើងផង ទុក្ខសច្ចនឹងមិនកើតឡើងផង ក្នុងទីនោះ ។

[ ៨៣ ] សមុទយសច្ច របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា មគ្គសច្ច របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ពួកសត្វនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា សមុទយសច្ច របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ ( ក្នុងលំដាប់នៃចិត្តនោះ ) តែមគ្គសច្ច របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ព្រះអរហន្តទាំងឡាយ ដែលប្រកបដោយមគ្គដ៏ប្រសើរ និងពួកអសញ្ញសត្វ សមុទយសច្ច របស់សត្វទាំងនោះ នឹងមិនកើតឡើងផង មគ្គសច្ច នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា សមុទយសច្ច របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ពួកសត្វដែលកើតក្នុងអបាយ និងពួកសត្វណា ជាបុថុជ្ជន នឹងមិនបាននូវមគ្គ មគ្គសច្ច របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែសមុទយ-សច្ចរបស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ព្រះអរហន្តទាំងឡាយ ដែលប្រកបដោយមគ្គដ៏ប្រសើរ និងពួកអសញ្ញសត្វ មគ្គសច្ច របស់សត្វទាំងនោះ នឹងមិនកើតឡើងផង សមុទយសច្ច នឹងមិនកើតឡើងផង ក្នុងទីនោះ ។

[ ៨៤ ] ទុក្ខសច្ច របស់សត្វណា កើតឡើង សមុទយសច្ច របស់សត្វនោះ កើតឡើងហើយឬ ។ អើ ។ មួយយ៉ាងទៀត សមុទយសច្ច របស់សត្វណា កើតឡើងហើយ ទុក្ខសច្ច របស់សត្វនោះ កើតឡើងឬ ។ ពួកសត្វ

ទាំងអស់ កាលច្យុត ក្នុងភង្គក្ខណៈនៃចិត្តក្នុងបច្ចុប្បន្ន និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព សមុទយសច្ច របស់សត្វទាំងនោះ កើតឡើងហើយ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វទាំងអស់ កាលចាប់បដិសន្ធិ ក្នុងឧប្បាទក្ខណៈនៃចិត្តក្នុងបច្ចុប្បន្ន សមុទយសច្ចរបស់សត្វទាំងនោះ កើតឡើងហើយផង ទុក្ខសច្ច កើតឡើងផង ។

[ ៨៥ ] ទុក្ខសច្ច របស់សត្វណា កើតឡើង មគ្គសច្ច របស់សត្វនោះ កើតឡើងហើយឬ ។ ពួកសត្វដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ កាលចាប់បដិសន្ធិក្នុងឧប្បាទក្ខណៈនៃចិត្តក្នុងបច្ចុប្បន្ន ទុក្ខសច្ចរបស់សត្វទាំងនោះ កើតឡើង តែមគ្គសច្ចរបស់សត្វទាំងនោះ មិនកើតឡើងហើយ ពួកសត្វដែលជាអ្នកត្រាស់ដឹងនូវសច្ចៈ ៤ កាលចាប់បដិសន្ធិ ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន ទុក្ខសច្ច របស់សត្វទាំងនោះ កើតឡើងផង មគ្គសច្ច កើតឡើងហើយផង ។ មួយយ៉ាងទៀត មគ្គសច្ចរបស់សត្វណា កើតឡើងហើយ ទុក្ខសច្ច របស់សត្វនោះ កើតឡើងឬ ។ ពួកសត្វដែលជាអ្នកត្រាស់ដឹងនូវសច្ចៈ ៤ កាលច្យុត ក្នុងភង្គក្ខណៈនៃចិត្តក្នុងបច្ចុប្បន្ន និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផលក្នុងអរូបភព មគ្គសច្ច របស់សត្វទាំងនោះ កើតឡើងហើយ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វដែលជាអ្នកត្រាស់ដឹងនូវសច្ចៈ ៤ កាលចាប់បដិសន្ធិ ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន មគ្គសច្ចរបស់សត្វទាំងនោះ កើតឡើងហើយផង ទុក្ខសច្ច កើតឡើងផង ។

[ ៨៦ ] សមុទយសច្ចរបស់សត្វណា កើតឡើង មគ្គសច្ចរបស់សត្វ

នោះ កើតឡើងហើយឬ ។ ពួកសត្វដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ ក្នុងឧប្បាទក្ខណៈនៃតណ្ហា សមុទយសច្ចរបស់សត្វទាំងនោះ កើតឡើង តែមគ្គសច្ច របស់សត្វទាំងនោះ មិនកើតឡើងហើយទេ ពួកសត្វដែលជាអ្នកត្រាស់ដឹងនូវសច្ចៈ ៤ ក្នុងឧប្បាទក្ខណៈនៃតណ្ហា សមុទយសច្ចរបស់សត្វទាំងនោះ កើតឡើងផង មគ្គសច្ច កើតឡើងហើយផង ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា កើតឡើងហើយ សមុទយសច្ចរបស់សត្វនោះ កើតឡើងឬ ។ ពួកសត្វដែលជាអ្នកត្រាស់ដឹងនូវសច្ចៈ ៤ ក្នុងភង្គក្ខណៈនៃតណ្ហា និងពួកសត្វដែលចូលកាន់និរោធ ក្នុងចិត្តដែលប្រាសចាកតណ្ហា កំពុងប្រព្រឹត្តទៅ មគ្គសច្ច របស់សត្វទាំងនោះ កើតឡើងហើយ តែសមុ-ទយសច្ច របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វដែលជាអ្នកត្រាស់ដឹងនូវសច្ចៈ ៤ ក្នុងឧប្បាទក្ខណៈនៃតណ្ហា មគ្គសច្ច របស់សត្វទាំងនោះ កើតឡើងហើយផង សមុទយសច្ច កើតឡើងផង ។

[ ៨៧ ] ទុក្ខសច្ច កើតឡើងក្នុងទីណា ។បេ។ ក្នុងទីណា ប្រហែលគ្នាទាំងអស់ ។

[ ៨៨ ] ទុក្ខសច្ច របស់សត្វណា កើតឡើងក្នុងទីណា សមុទយសច្ច របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះឬ ។ ពួកសុទ្ធាវាសសត្វ ក្នុងឧប្បាទក្ខណៈនៃឧប្បត្តិចិត្ត និងពួកសត្វ កាលចូលទៅកាន់អសញ្ញសត្វ ទុក្ខ-សច្ច របស់សត្វទាំងនោះ កើតឡើងក្នុងទីនោះ តែសមុទយសច្ច របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសត្វក្រៅនេះ កាលចូលទៅ

កាន់ចតុវោការភព និងបញ្ចវោការភព ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន ទុក្ខសច្ច របស់សត្វទាំងនោះ កើតឡើងផង សមុទយសច្ច កើតឡើងហើយផង ។ មួយយ៉ាងទៀត សមុទយសច្ច របស់សត្វណា កើតឡើងហើយ ក្នុងទីណា ទុក្ខសច្ច របស់សត្វនោះ កើតឡើងក្នុងទីនោះឬ ។ ពួកសត្វ កាលច្យុតចាកចតុវោការភព និងបញ្ចវោការភព ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព សមុទយសច្ច របស់សត្វទាំងនោះ កើតឡើងហើយ ក្នុងទីនោះ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនកើតឡើងក្នុងទីនោះទេ ពួកសត្វ កាលចូលទៅកាន់ចតុវោការភព និងបញ្ច-វោការភព ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន សមុទយសច្ច របស់សត្វទាំងនោះ កើតឡើងហើយផង ទុក្ខសច្ច កើតឡើងផង ក្នុងទីនោះ ។

[ ៨៩ ] ទុក្ខសច្ច របស់សត្វណា កើតឡើងក្នុងទីណា មគ្គសច្ច របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះឬ ។ ពួកសុទ្ធាវាសសត្វ ពួកសត្វដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ កាលចាប់បដិសន្ធិ ក្នុងឧប្បាទក្ខណៈនៃឧប្បត្តិចិត្ត និងពួកសត្វ កាលចូលទៅកាន់អសញ្ញសត្វ ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន ទុក្ខសច្ច របស់សត្វទាំងនោះ កើតឡើង ក្នុងទីនោះ តែមគ្គសច្ច របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសត្វដែលជាអ្នកត្រាស់ដឹងនូវសច្ចៈ ៤ កាលចាប់បដិសន្ធិ ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន ទុក្ខសច្ច របស់សត្វទាំងនោះ កើតឡើងផង មគ្គសច្ចកើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា

កើតឡើងហើយ ក្នុងទីណា ទុក្ខសច្ចរបស់សត្វនោះ កើតឡើងក្នុងទីនោះឬ ។ ពួកសត្វដែលជាអ្នកត្រាស់ដឹងនូវសច្ចៈ ៤ កាលច្យុតក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព មគ្គសច្ច របស់សត្វទាំងនោះ កើតឡើងហើយ ក្នុងទីនោះ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលជាអ្នកត្រាស់ដឹងនូវសច្ចៈ ៤ កាលចាប់បដិសន្ធិក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន មគ្គសច្ច របស់សត្វទាំងនោះ កើតឡើងហើយផង ទុក្ខសច្ច កើតឡើងផង ក្នុងទីនោះ ។

[ ៩០ ] សមុទយសច្ច របស់សត្វណា កើតឡើង ក្នុងទីណា មគ្គសច្ច របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះឬ ។ ពួកសត្វដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ ក្នុងឧប្បាទក្ខណៈនៃតណ្ហា សមុទយសច្ច របស់សត្វទាំងនោះ កើតឡើង ក្នុងទីនោះ តែមគ្គសច្ច របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសត្វដែលជាអ្នកត្រាស់ដឹងនូវសច្ចៈ ៤ ក្នុងឧប្បាទក្ខណៈនៃតណ្ហា សមុទយសច្ច របស់សត្វទាំងនោះ កើតឡើងផង មគ្គសច្ច កើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មគ្គសច្ចរបស់សត្វណា កើតឡើងហើយ ក្នុងទីណា សមុទយសច្ចរបស់សត្វនោះ កើតឡើងក្នុងទីនោះឬ ។ ពួកសត្វដែលជាអ្នកត្រាស់ដឹងនូវសច្ចៈ ៤ ក្នុងភង្គក្ខណៈនៃតណ្ហា ក្នុងចិត្តដែលប្រាសចាកតណ្ហា កំពុងប្រព្រឹត្តទៅ មគ្គសច្ច របស់សត្វទាំងនោះ កើតឡើងហើយ ក្នុងទីនោះ តែមគ្គសច្ច របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វជាអ្នកត្រាស់ដឹងនូវសច្ចៈ ៤ ក្នុងឧប្បា-

ទុក្ខណៈនៃតណ្ហា មគ្គសច្ច របស់សត្វទាំងនោះ កើតឡើងហើយផង សមុទយសច្ច កើតឡើងផង ក្នុងទីនោះ ។

[ ៩១ ] ទុក្ខសច្ច របស់សត្វណា មិនកើតឡើង សមុទយសច្ចរបស់សត្វនោះ មិនកើតឡើងហើយឬ ។ កើតឡើងហើយ ។ មួយយ៉ាងទៀត សមុទយសច្ច របស់សត្វណា មិនកើតឡើងហើយ ទុក្ខសច្ចរបស់សត្វនោះ មិនកើតឡើងឬ ។ មិនមានទេ ។

[ ៩២ ] ទុក្ខសច្ច របស់សត្វណា មិនកើតឡើង មគ្គសច្ច របស់សត្វនោះ មិនកើតឡើងហើយឬ ។ ពួកសត្វដែលជាអ្នកត្រាស់ដឹងនូវសច្ចៈ ៤ កាលប្រែក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព ទុក្ខសច្ច របស់សត្វទាំងនោះ មិនកើតឡើង តែមគ្គសច្ច របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយទេ ពួកសត្វដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ កាលប្រែក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន ទុក្ខសច្ចរបស់សត្វទាំងនោះ មិនកើតឡើងផង មគ្គសច្ចមិនកើតឡើងហើយផង ។ មួយយ៉ាងទៀត មគ្គសច្ចរបស់សត្វណា មិនកើតឡើងហើយ ទុក្ខសច្ច របស់សត្វនោះ មិនកើតឡើងឬ ។ ពួកសត្វដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ កាលចាប់បដិសន្ធិក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន មគ្គសច្ច របស់សត្វទាំងនោះ មិនកើតឡើងហើយ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ពួកសត្វដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ កាលប្រែក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន មគ្គសច្ច របស់សត្វទាំងនោះ

មិនកើតឡើងហើយផង ទុក្ខសច្ច មិនកើតឡើងផង ។

[ ៩៣ ] សមុទយសច្ច របស់សត្វណា មិនកើតឡើង មគ្គសច្ច របស់សត្វនោះ មិនកើតឡើងហើយឬ ។ ពួកសត្វដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ ក្នុងភង្គក្ខណៈនៃតណ្ហា និងពួកសត្វដែលចូលកាន់និរោធ ក្នុងចិត្តដែលប្រាសចាកតណ្ហា កំពុងប្រព្រឹត្តទៅ សមុទយសច្ច របស់សត្វទាំងនោះ មិនកើតឡើង តែមគ្គសច្ច របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយទេ ពួកសត្វដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ ក្នុងភង្គក្ខណៈនៃតណ្ហា និងពួកអសញ្ញសត្វក្នុងចិត្តដែលប្រាសចាកតណ្ហា កំពុងប្រព្រឹត្តទៅ សមុទយសច្ច របស់សត្វទាំងនោះមិនកើតឡើងផង មគ្គសច្ច មិនកើតឡើងផង ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា មិនកើតឡើងហើយ សមុទយសច្ច របស់សត្វនោះ មិនកើតឡើងឬ ។ ពួកសត្វដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ ក្នុងឧប្បាទក្ខណៈនៃតណ្ហា មគ្គសច្ច របស់សត្វទាំងនោះ មិនកើតឡើងហើយ តែសមុទយសច្ច របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ពួកសត្វដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ ក្នុងភង្គក្ខណៈនៃតណ្ហា និងពួកអសញ្ញសត្វ ក្នុងចិត្តដែលប្រាសចាកតណ្ហា កំពុងប្រព្រឹត្តទៅ មគ្គសច្ច របស់សត្វទាំងនោះ មិនកើតឡើងហើយផង សមុទយសច្ច មិនកើតឡើងផង ។

[ ៩៤ ] ទុក្ខសច្ច មិនកើតឡើង ក្នុងទីណា ។បេ។

[ ៩៥ ] ទុក្ខសច្ច របស់សត្វណា មិនកើតឡើងក្នុងទីណា សមុទយ-

សច្ច របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ ពួកសត្វ កាលច្យុតចាកចតុវោការភព និងបញ្ចវោការភព ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព ទុក្ខសច្ច របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ តែសមុទយសច្ច របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសុទ្ធាវាសសត្វ និងពួកអសញ្ញសត្វ កាលច្យុតក្នុងភង្គក្ខណៈនៃឧប្បត្តិចិត្ត ទុក្ខសច្ច របស់សត្វទាំងនោះ មិនកើតឡើងផង សមុទយសច្ច មិនកើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សមុទយសច្ច របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា ទុក្ខសច្ច របស់សត្វនោះ មិនកើតឡើងក្នុងទីនោះឬ ។ ពួកសុទ្ធាវាស-សត្វ និងពួកសត្វ កាលចូលទៅកាន់អសញ្ញសត្វ ក្នុងឧប្បាទក្ខណៈនៃឧប្បត្តិចិត្ត សមុទយសច្ច របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ពួកសុទ្ធាវាសសត្វ និងពួកអសញ្ញសត្វ កាលច្យុតក្នុងភង្គក្ខណៈ នៃឧប្បត្តិ-ចិត្ត សមុទយសច្ច របស់សត្វទាំងនោះ មិនកើតឡើងហើយផង ទុក្ខសច្ច មិនកើតឡើងផង ក្នុងទីនោះ ។

[ ៩៦ ] ទុក្ខសច្ច របស់សត្វណា មិនកើតឡើងក្នុងទីណា មគ្គសច្ច របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ ពួកសត្វដែលជាអ្នកត្រាស់ដឹងនូវសច្ចៈ ៤ កាលច្យុតក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព ទុក្ខសច្ច របស់សត្វទាំងនោះ

មិនកើតឡើង ក្នុងទីនោះ តែមគ្គសច្ច របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសុទ្ធាវាសសត្វ ពួកសត្វដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ កាលច្យុតក្នុងភង្គក្ខណៈនៃឧប្បត្តិចិត្ត និងពួកអសញ្ញ-សត្វ កាលច្យុតក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន ទុក្ខសច្ច របស់សត្វទាំងនោះ មិនកើតឡើងផង មគ្គសច្ច មិនកើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា ទុក្ខសច្ច របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ ពួកសុទ្ធាវាសសត្វ ពួកសត្វដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ កាលចាប់បដិសន្ធិ ក្នុងឧប្បាទក្ខណៈនៃឧប្បត្តិចិត្ត និងពួកសត្វ កាលចូលទៅកាន់អសញ្ញសត្វ ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន មគ្គសច្ច របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ពួកសុទ្ធាវាសសត្វ ពួកសត្វដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ កាលច្យុតក្នុងភង្គក្ខណៈនៃឧប្បត្តិចិត្ត និងពួកអសញ្ញសត្វ កាលច្យុតក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន មគ្គសច្ច របស់សត្វទាំងនោះ មិនកើតឡើងហើយផង ទុក្ខសច្ច មិនកើតឡើងផង ក្នុងទីនោះ ។

[ ៩៧ ] សមុទយសច្ច របស់សត្វណា មិនកើតឡើងក្នុងទីណា មគ្គសច្ច របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ ពួកសត្វដែលជាអ្នកត្រាស់ដឹងនូវសច្ចៈ ៤ ក្នុងភង្គក្ខណៈនៃតណ្ហា និងក្នុងកាលដែលចិត្តប្រាសចាកតណ្ហា កំពុងប្រព្រឹត្តទៅ សមុទយសច្ច របស់សត្វទាំងនោះ មិនកើតឡើង

ក្នុងទីនោះ តែមគ្គសច្ច របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ ចិត្តទី ២ របស់ពួកសុទ្ធាវាសសត្វ កំពុងប្រព្រឹត្តទៅ ពួកសត្វដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ ក្នុងភង្គក្ខណៈនៃតណ្ហា និងក្នុងកាលដែលចិត្តប្រាសចាកតណ្ហា កំពុងប្រព្រឹត្តទៅ និងពួកអសញ្ញសត្វ សមុទយសច្ច របស់សត្វទាំងនោះ មិនកើតឡើងផង មគ្គសច្ច មិនកើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា សមុទយសច្ច របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ ពួកសត្វដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ ក្នុងឧប្បាទក្ខណៈនៃតណ្ហា មគ្គសច្ច របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែសមុទយសច្ច របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ចិត្តទី ២ របស់ពួកសុទ្ធាវាសសត្វ កំពុងប្រព្រឹត្តទៅ ពួកសត្វដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ ក្នុងភង្គក្ខណៈនៃតណ្ហា និងក្នុងកាលដែលចិត្តប្រាសចាកតណ្ហា កំពុងប្រព្រឹត្តទៅ និងពួកអសញ្ញសត្វ មគ្គសច្ច របស់សត្វទាំងនោះ មិនកើតឡើងហើយផង សមុទយសច្ច មិនកើតឡើងផង ក្នុងទីនោះ ។

[ ៩៨ ] ទុក្ខសច្ច របស់សត្វណា កើតឡើង សមុទយសច្ច របស់សត្វនោះ នឹងកើតឡើងឬ ។ ទុក្ខសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ

កើតឡើង តែសមុទយសច្ច របស់សត្វនោះ នឹងមិនកើតឡើងទេ ពួកសត្វក្រៅនេះ កាលចាប់បដិសន្ធិក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន ទុក្ខសច្ច របស់សត្វទាំងនោះ កើតឡើងផង សមុទយសច្ច នឹងកើតឡើងផង ។ មួយយ៉ាងទៀត សមុទយសច្ច របស់សត្វណា នឹងកើតឡើង ទុក្ខសច្ច របស់សត្វនោះ កើតឡើងឬ ។ ពួកសត្វទាំងអស់ កាលប្រែតក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព សមុទយ-សច្ច របស់សត្វទាំងនោះ នឹងកើតឡើង តែទុក្ខសច្ច របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វទាំងអស់ កាលចាប់បដិសន្ធិក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន សមុទយសច្ច របស់សត្វទាំងនោះ នឹងកើតឡើងផង ទុក្ខសច្ច កើតឡើងផង ។

[ ៩៩ ] ទុក្ខសច្ច របស់សត្វណា កើតឡើង មគ្គសច្ច របស់សត្វនោះ នឹងកើតឡើងឬ ។ ទុក្ខសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វនោះៗ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្ត កាលចាប់បដិសន្ធិក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន កើតឡើង តែមគ្គសច្ច របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ ពួកសត្វណា នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ឬក៏ពួកសត្វដទៃណា នឹងបាននូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ ពួកសត្វទាំងនោះ កាលចាប់បដិសន្ធិក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន ទុក្ខសច្ច របស់សត្វទាំងនោះ កើតឡើងផង មគ្គសច្ច នឹងកើតឡើងផង ។ មួយយ៉ាងទៀត មគ្គសច្ចរបស់

សត្វណា នឹងកើតឡើង ទុក្ខសច្ចរបស់ សត្វនោះ កើតឡើងឬ ។ ពួកសត្វណា នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ឬក៏ពួកសត្វដទៃណា នឹងបាននូវមគ្គ ក្នុងភង្គក្ខណៈនៃចិត្តនោះ ពួកសត្វទាំងនោះ កាលច្យុតក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផលក្នុងអរូបភព មគ្គសច្ច របស់សត្វទាំងនោះ នឹងកើតឡើង តែទុក្ខសច្ចរបស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វណា នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ឬក៏ពួកសត្វដទៃណា នឹងបាននូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ ពួកសត្វទាំងនោះ កាលចាប់បដិសន្ធិ ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន មគ្គសច្ច របស់សត្វទាំងនោះ នឹងកើតឡើងផង ទុក្ខសច្ច កើតឡើងផង ។

[ ១០០ ] សមុទយសច្ច របស់សត្វណាកើតឡើង មគ្គសច្ច របស់សត្វនោះ នឹងកើតឡើងឬ ។ ពួកសត្វណា ជាបុថុជ្ជន នឹងមិនបាននូវមគ្គ សមុទយសច្ច របស់សត្វនោះៗ កើតឡើង ក្នុងឧប្បាទក្ខណៈនៃតណ្ហា តែមគ្គសច្ច របស់សត្វនោះ នឹងមិនកើតឡើងទេ ពួកសត្វណា នឹងបាននូវមគ្គ សមុទយសច្ច របស់សត្វនោះៗ កើតឡើងផង មគ្គសច្ច នឹងកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃតណ្ហា ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងកើតឡើង សមុទយសច្ច របស់សត្វនោះ កើតឡើងឬ ។ ពួកសត្វណា នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ឬក៏ពួកសត្វដទៃណា នឹងបាននូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ មគ្គសច្ច របស់សត្វនោះៗ ក្នុងភង្គក្ខណៈនៃតណ្ហា និងរបស់ពួកសត្វដែលចូលកាន់និរោធ ក្នុងកាលដែលចិត្តប្រាស

បាកតណ្ហា កំពុងប្រព្រឹត្តទៅ និងរបស់ពួកអសញ្ញសត្វ នឹងកើតឡើង តែសមុទយសច្ច របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វណា នឹងបាននូវមគ្គ មគ្គសច្ច របស់សត្វនោះៗ នឹងកើតឡើងផង សមុទយសច្ច កើតឡើងផង ក្នុងឧប្បាទក្ខណៈនៃតណ្ហា ។

[ ១០១ ] ទុក្ខសច្ច កើតឡើងក្នុងទីណា ។បេ។ ពាក្យថា ក្នុងទីណា បណ្ឌិតគប្បីធ្វើឲ្យប្រហែលនឹងពាក្យថា របស់សត្វណា ក្នុងទីណាដែរ ។

[ ១០២ ] ទុក្ខសច្ច របស់សត្វណា កើតឡើងក្នុងទីណា សមុទយសច្ច របស់សត្វនោះ នឹងកើតឡើងក្នុងទីនោះឬ ។ ទុក្ខសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃចិត្ត កាលចូលទៅកាន់អសញ្ញសត្វ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ កើតឡើងក្នុងទីនោះ តែសមុទយសច្ច របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វក្រៅនេះ កាលចូលទៅកាន់ចតុវោការភព និងបញ្ចវោការភព ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន ទុក្ខសច្ច របស់សត្វទាំងនោះ កើតឡើងផង សមុទយសច្ច នឹងកើតឡើងផងក្នុងទីនោះ ។ មួយយ៉ាងទៀត សមុទយសច្ច របស់សត្វណា នឹងកើតឡើងក្នុងទីណា ទុក្ខសច្ច របស់សត្វនោះ កើតឡើងក្នុងទីនោះឬ ។ ពួកសត្វ កាលច្យុតចាកចតុវោការភព និងបញ្ចវោការភព ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព សមុទយសច្ចរបស់សត្វទាំងនោះ នឹងកើតឡើង ក្នុងទីនោះ តែ

ទុក្ខសច្ច របស់សត្វទាំងនោះ មិនកើតឡើងក្នុង ទីនោះទេ ពួកសត្វ កាលចូលទៅកាន់ចតុវោការភព និងបញ្ចវោការភព ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន សមុទយសច្ច របស់សត្វទាំងនោះ នឹងកើតឡើងផង ទុក្ខសច្ច កើតឡើងផង ក្នុងទីនោះ ។

[ ១០៣ ] ទុក្ខសច្ច របស់សត្វណា កើតឡើងក្នុងទីណា មគ្គសច្ច របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ ទុក្ខសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្ត កាលចាប់បដិសន្ធិ និងរបស់ពួកសត្វនោះ កាលចូលទៅកាន់អបាយ និងអសញ្ញសត្វ ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន កើតឡើងក្នុងទីនោះ តែមគ្គសច្ច របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វណា នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ឬក៏ពួកសត្វដទៃណា នឹងបាននូវមគ្គក្នុងឧប្បាទក្ខណៈនៃចិត្តនោះ ពួកសត្វទាំងនោះ កាលចាប់បដិសន្ធិ ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន ទុក្ខសច្ច របស់សត្វទាំងនោះ កើតឡើងផង មគ្គសច្ច នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងកើតឡើងក្នុងទីណា ទុក្ខសច្ច របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ ពួកសត្វណា នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ឬក៏ពួកសត្វដទៃណា នឹងបាននូវមគ្គក្នុងភង្គក្ខណៈនៃចិត្តនោះ ពួកសត្វទាំងនោះ កាលច្យុតក្នុងភង្គក្ខណៈនៃចិត្តក្នុងបច្ចុប្បន្ន និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព មគ្គសច្ច

របស់សត្វទាំងនោះ នឹងកើតឡើង ក្នុងទីនោះ តែទុក្ខសច្ចរបស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វណា នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ឬក៏ពួកសត្វដទៃណា នឹងបាននូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ ពួកសត្វទាំងនោះ កាលចាប់បដិសន្ធិ ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន មគ្គសច្ច របស់សត្វទាំងនោះ នឹងកើតឡើងផង ទុក្ខសច្ច កើតឡើងផង ក្នុងទីនោះ ។

[ ១០៤ ] សមុទយសច្ច របស់សត្វណា កើតឡើង ក្នុងទីណា មគ្គសច្ច របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ សមុទយសច្ច របស់សត្វដែលកើតក្នុងអបាយ និងរបស់សត្វនោះៗ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ កើតឡើងក្នុងឧប្បាទក្ខណៈនៃតណ្ហា ក្នុងទីនោះ តែមគ្គសច្ច របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វណា នឹងបាននូវមគ្គ សមុទយសច្ចរបស់សត្វនោះៗ កើតឡើងផង មគ្គសច្ច នឹងកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃតណ្ហា ក្នុងទីនោះ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងកើតឡើង ក្នុងទីណា សមុទយសច្ច របស់សត្វនោះ កើតឡើងក្នុងទីនោះឬ ។ ពួកសត្វណា នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ឬក៏ពួកសត្វដទៃណា នឹងបាននូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ មគ្គសច្ច របស់សត្វនោះៗ នឹងកើតឡើង ក្នុងភង្គក្ខណៈនៃតណ្ហា និងក្នុងកាលដែលចិត្តប្រាសចាកតណ្ហា កំពុងប្រព្រឹត្តទៅ ក្នុងទីនោះ តែសមុទយសច្ច របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វណា នឹងបាន

នូវមគ្គ មគ្គសច្ច របស់សត្វនោះៗ នឹងកើតឡើងផង សមុទយសច្ច កើតឡើងផង ក្នុងឧប្បាទក្ខណៈនៃតណ្ហា ក្នុងទីនោះ ។

[ ១០៥ ] ទុក្ខសច្ច របស់សត្វណា មិនកើតឡើង សមុទយសច្ច របស់សត្វនោះ នឹងមិនកើតឡើងឬ ។ ពួកសត្វទាំងអស់ កាលច្យុតក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព ទុក្ខសច្ច របស់សត្វទាំងនោះ មិនកើតឡើង តែសមុទយសច្ច របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ ទុក្ខសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងភង្គក្ខណៈនៃចិត្តនោះ និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព មិនកើតឡើងផង សមុទយសច្ច នឹងមិនកើតឡើងផង ។ មួយយ៉ាងទៀត សមុទយសច្ច របស់សត្វណា នឹងមិនកើតឡើង ទុក្ខសច្ចរបស់សត្វនោះ មិនកើតឡើងឬ ។ សមុទយសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាសត្វនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ នឹងមិនកើតឡើង តែទុក្ខសច្ចរបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ សមុទយសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាសត្វនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងភង្គក្ខណៈនៃចិត្តនោះ និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល

ក្នុងអរូបភព មិនកើតឡើងផង ទុក្ខសច្ច មិនកើតឡើងផង ។

[ ១០៦ ] ទុក្ខសច្ច របស់សត្វណា មិនកើតឡើង មគ្គសច្ច របស់សត្វនោះ នឹងមិនកើតឡើងឬ ។ ពួកសត្វណា នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ឬក៏ពួកសត្វដទៃណា នឹងបាននូវមគ្គ ក្នុងភង្គក្ខណៈនៃចិត្តនោះ ពួកសត្វនោះ កាលច្យុតក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព ទុក្ខសច្ច របស់សត្វទាំងនោះ មិនកើតឡើង តែមគ្គសច្ចរបស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ ទុក្ខសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់ពួកសត្វនោះៗ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ ក្នុងភង្គក្ខណៈនៃចិត្ត កាលច្យុតក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព នឹងមិនកើតឡើងផង មគ្គសច្ច មិនកើតឡើងផង ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងមិនកើតឡើង ទុក្ខសច្ច របស់សត្វនោះ មិនកើតឡើងឬ ។ មគ្គសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់ពួកសត្វនោះៗ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្ត កាលចាប់បដិសន្ធិក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន នឹងមិនកើតឡើង តែទុក្ខសច្ច របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ មគ្គសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់ពួកសត្វនោះៗ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ ក្នុងភង្គក្ខណៈនៃចិត្ត កាលច្យុតក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុង

ឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព នឹងមិនកើតឡើងផង ទុក្ខសច្ច មិនកើតឡើងផង ។

[ ១០៧ ] សមុទយសច្ច របស់សត្វណា មិនកើតឡើង មគ្គសច្ច របស់សត្វនោះ នឹងមិនកើតឡើងឬ ។ ពួកសត្វណា នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ឬក៏ពួកសត្វដទៃណា នឹងបាននូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ សមុទយសច្ច របស់ពួកសត្វនោះ ក្នុងភង្គក្ខណៈនៃតណ្ហា និងរបស់ពួកសត្វដែលចូលកាន់និរោធ និងរបស់ពួកអសញ្ញសត្វទាំងនោះ ក្នុងកាលដែលចិត្តប្រាសចាកតណ្ហា កំពុងប្រព្រឹត្តទៅ មិនកើតឡើង តែមគ្គសច្ច របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ សមុទយសច្ច របស់ព្រះអរហន្តទាំងឡាយ ដែលប្រកបដោយមគ្គដ៏ប្រសើរ និងរបស់ពួកសត្វនោះដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ ក្នុងភង្គក្ខណៈនៃតណ្ហា និងរបស់ពួកសត្វដែលចូលកាន់និរោធ និងរបស់ពួកអសញ្ញសត្វទាំងនោះ ក្នុងកាលដែលចិត្តប្រាសចាកតណ្ហា កំពុងប្រព្រឹត្តទៅ មិនកើតឡើងផង មគ្គសច្ច នឹងមិនកើតឡើងផង ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងមិនកើតឡើង សមុទយសច្ច របស់សត្វនោះ មិនកើតឡើងឬ ។ ពួកសត្វណា ជាបុថុជ្ជន នឹងមិនបាននូវមគ្គ មគ្គសច្ច របស់ពួកសត្វនោះៗ នឹងមិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃតណ្ហា តែសមុទយសច្ច របស់សត្វនោះ មិនមែនជាមិនកើតឡើងទេ មគ្គសច្ច របស់ព្រះអរហន្តទាំងឡាយ ដែលប្រកបដោយមគ្គដ៏ប្រសើរ និងរបស់ពួកសត្វនោះ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ ក្នុង

កន្ត្តក្ខណៈនៃតណ្ហា និងរបស់ពួកសត្វដែលចូលកាន់និរោធ និងរបស់អសញ្ញសត្វទាំងនោះ ក្នុងកាលដែលចិត្តប្រាសចាកតណ្ហា កំពុងប្រព្រឹត្តទៅ នឹងមិនកើតឡើងផង សមុទយសច្ច មិនកើតឡើងផង ។

[ ១០៨ ] ទុក្ខសច្ច មិនកើតឡើង ក្នុងទីណា ។បេ។

[ ១០៩ ] ទុក្ខសច្ច របស់សត្វណា មិនកើតឡើង ក្នុងទីណា សមុទយសច្ច របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ពួកសត្វ កាលច្យុតចាកចតុវោការភព និងបញ្ចវោការភព ក្នុងភង្គក្ខណៈនៃចិត្តក្នុងបច្ចុប្បន្ន និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព ទុក្ខសច្ច របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ តែសមុទយសច្ច របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ទុក្ខសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់អសញ្ញសត្វទាំងនោះ ដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងភង្គក្ខណៈនៃចិត្ត កាលច្យុតក្នុងភង្គក្ខណៈនៃចិត្តនោះ និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព មិនកើតឡើងផង សមុទយសច្ច នឹងមិនកើតឡើងផង ។ មួយយ៉ាងទៀត សមុទយសច្ច របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ទុក្ខសច្ច របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ សមុទយសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់ពួកសត្វនោះ ដែលជាសត្វនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃចិត្ត កាលចូលទៅកាន់អសញ្ញសត្វ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ នឹងមិន

កើតឡើង ក្នុងទីនោះ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ សមុទយសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់ពួកអសញ្ញសត្វនោះ ដែលជាសត្វនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងភង្គក្ខណៈនៃចិត្ត កាលច្យុតក្នុងភង្គក្ខណៈនៃចិត្តនោះ និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព នឹងមិនកើតឡើងផង ទុក្ខសច្ច មិនកើតឡើងផង ក្នុងទីនោះ ។

[ ១១០ ] ទុក្ខសច្ច របស់សត្វណា មិនកើតឡើងក្នុងទីណា មគ្គសច្ច របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ពួកសត្វណា នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ឬក៏ពួកសត្វដទៃណា នឹងបាននូវមគ្គក្នុងភង្គក្ខណៈនៃចិត្តនោះ ពួកសត្វនោះ កាលច្យុត ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព ទុក្ខសច្ច របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ តែមគ្គសច្ច របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ទុក្ខសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់ពួកសត្វនោះ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គក្នុងភង្គក្ខណៈនៃចិត្ត កាលច្យុត ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងរបស់ពួកអសញ្ញសត្វនោះ កាលច្យុត ក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព មិនកើតឡើងផង មគ្គសច្ច នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ទុក្ខសច្ច របស់សត្វនោះ មិនកើតឡើងក្នុងទីនោះឬ ។ មគ្គសច្ច របស់ព្រះអរហន្ត

ទាំងឡាយ ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្ត កាលចាប់បដិសន្ធិ ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងរបស់សត្វទាំងនោះ កាលចូលទៅកាន់អសញ្ញសត្វ នឹងមិនកើតឡើង ក្នុងទីនោះ ។ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ មគ្គសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់ពួកសត្វនោះ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ ក្នុងភង្គក្ខណៈនៃចិត្ត កាលច្យុត ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងរបស់ពួកអសញ្ញសត្វនោះ កាលច្យុត ក្នុងឧប្បាទក្ខណៈនៃមគ្គនិងផល ក្នុងអរូបភព នឹងមិនកើតឡើងផង ទុក្ខសច្ច មិនកើតឡើងផង ក្នុងទីនោះ ។

[ ១១១ ] សមុទយសច្ច របស់សត្វណា មិនកើតឡើង ក្នុងទីណា មគ្គសច្ច របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ពួកសត្វណា នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ឬក៏ពួកសត្វដទៃណា នឹងបាននូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ សមុទយសច្ច របស់សត្វនោះៗ មិនកើតឡើង ក្នុងភង្គក្ខណៈនៃតណ្ហា និងក្នុងកាលដែលចិត្តប្រាសចាកតណ្ហាកំពុងប្រព្រឹត្តទៅ ក្នុងទីនោះ តែមគ្គសច្ចរបស់ពួកសត្វនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ សមុទយសច្ច របស់ព្រះអរហន្តទាំងឡាយ ដែលប្រកបដោយមគ្គដ៏ប្រសើរ និងរបស់ពួកសត្វនោះ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ ក្នុងភង្គក្ខណៈនៃតណ្ហា និងរបស់ពួកអសញ្ញសត្វនោះ ក្នុងកាល

ដែលចិត្តប្រាសចាកតណ្ហា កំពុងប្រព្រឹត្តទៅ មិនកើតឡើងផង មគ្គសច្ច នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា សមុទយសច្ច របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ មគ្គសច្ច របស់ពួកសត្វដែលកើតក្នុងអបាយ និងរបស់ពួកសត្វនោះៗ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ ក្នុងឧប្បាទក្ខណៈនៃតណ្ហា នឹងមិនកើតឡើង ក្នុងទីនោះ តែសមុទយសច្ច របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ មគ្គសច្ច របស់ព្រះអរហន្តទាំងឡាយ ដែលប្រកបដោយមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ ក្នុងភង្គក្ខណៈនៃតណ្ហា និងរបស់អសញ្ញសត្វទាំងនោះ ក្នុងកាលដែលចិត្តប្រាសចាកតណ្ហា កំពុងប្រព្រឹត្តទៅ នឹងមិនកើតឡើងផង សមុទយសច្ច មិនកើតឡើងផង ក្នុងទីនោះ ។

[ ១១២ ] ទុក្ខសច្ច របស់សត្វណា កើតឡើងហើយ សមុទយសច្ច របស់សត្វនោះ នឹងកើតឡើងឬ ។ ទុក្ខសច្ច របស់ព្រះអរហន្តទាំងឡាយ ដែលប្រកបដោយមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាសត្វនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា កើតឡើងហើយ តែសមុទយសច្ច របស់ពួកសត្វនោះ នឹងមិនកើតឡើងទេ ទុក្ខសច្ច របស់ពួកសត្វនោះ ក្រៅនេះ កើតឡើងហើយផង សមុទយសច្ច នឹងកើតឡើងផង ។ មួយយ៉ាងទៀត សមុទយសច្ច របស់សត្វណា នឹងកើតឡើង ទុក្ខសច្ច របស់សត្វនោះ កើតឡើងហើយឬ ។ អើ ។

[ ១១៣ ] ទុក្ខសច្ច របស់សត្វណា កើតឡើងហើយ មគ្គសច្ច របស់សត្វនោះ នឹងកើតឡើងឬ ។ ទុក្ខសច្ច របស់ព្រះអរហន្តទាំងឡាយ ដែលប្រកបដោយមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ កើតឡើងហើយ តែមគ្គសច្ច របស់សត្វទាំងនោះ របស់ពួកសត្វនោះ នឹងមិនកើតឡើងទេ ពួកសត្វណា នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ឬក៏ពួកសត្វដទៃណា នឹងបាននូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ ទុក្ខសច្ច របស់ពួកសត្វនោះ កើតឡើងហើយផង មគ្គសច្ច នឹងកើតឡើងផង ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា កើតឡើងហើយ ។បេ។ អើ ។

[ ១១៤ ] សមុទយសច្ច របស់សត្វណា កើតឡើងហើយ មគ្គសច្ច របស់សត្វនោះ នឹងកើតឡើងឬ ។ សមុទយសច្ច របស់ព្រះអរហន្តទាំងឡាយ ដែលប្រកបដោយមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ កើតឡើងហើយ តែមគ្គសច្ច របស់ពួកសត្វនោះ នឹងមិនកើតឡើងទេ ពួកសត្វណា នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ឬក៏ពួកសត្វដទៃណា នឹងបាននូវមគ្គ សមុទយសច្ច របស់សត្វទាំងនោះ កើតឡើងហើយផង មគ្គសច្ច នឹងកើតឡើងផង ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា កើតឡើងហើយ ។បេ។ អើ ។

[ ១១៥ ] ទុក្ខសច្ច កើតឡើងហើយ ក្នុងទីណា ។បេ។

[ ១១៦ ] ទុក្ខសច្ច របស់សត្វណា កើតឡើងហើយ ក្នុងទីណា

សមុទយសច្ច របស់សត្វនោះ នឹងកើតឡើងក្នុងទីនោះឬ ។ ទុក្ខសច្ច របស់ព្រះអរហន្តទាំងឡាយ ដែលប្រកបដោយមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាសត្វនឹងបានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា និងរបស់អសញ្ញសត្វទាំងនោះ កើតឡើងហើយ ក្នុងទីនោះ តែសមុទយសច្ច របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ទុក្ខសច្ច របស់ពួកសត្វនោះក្រៅនេះ ដែលនៅក្នុងចតុវោការភព និងបញ្ចវោការភព កើតឡើងហើយផង សមុទយសច្ច នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សមុទយ-សច្ច របស់សត្វណា នឹងកើតឡើង ក្នុងទីណា ទុក្ខសច្ច របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះឬ ។ សមុទយសច្ច របស់សត្វទាំងនោះ ដែលចូលទៅកាន់សុទ្ធាវាស នឹងកើតឡើង ក្នុងទីនោះ តែទុក្ខសច្ចរបស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ សមុទយសច្ច របស់ពួកសត្វនោះក្រៅនេះ ដែលនៅក្នុងចតុវោការភព និងបញ្ចវោការភព នឹងកើតឡើងផង ទុក្ខសច្ច កើតឡើងហើយផង ក្នុងទីនោះ ។

[ ១១៧ ] ទុក្ខសច្ច របស់សត្វណា កើតឡើងហើយ ក្នុងទីណា មគ្គ-សច្ច របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ ទុក្ខសច្ច របស់ព្រះអរហន្តទាំងឡាយ ដែលប្រកបដោយមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាបុថុជ្ជន នឹងមិនបានទូវមគ្គ និងរបស់ពួកសត្វដែលកើតក្នុងអបាយផង និងរបស់អសញ្ញសត្វទាំងនោះ កើតឡើងហើយ ក្នុងទីនោះ តែមគ្គសច្ច របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វណា នឹងបាន

នូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ឬក៏ពួកសត្វដទៃណា នឹងបាននូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ ទុក្ខសច្ច របស់សត្វទាំងនោះ កើតឡើងហើយផង មគ្គសច្ច នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងកើតឡើង ក្នុងទីណា ទុក្ខសច្ច របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះឬ ។ មគ្គសច្ច របស់សត្វទាំងនោះ ដែលចូលទៅកាន់សុទ្ធាវាស នឹងកើតឡើង ក្នុងទីនោះ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសត្វណា នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ឬក៏ពួកសត្វដទៃណា នឹងបាននូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ មគ្គសច្ច របស់សត្វទាំងនោះ នឹងកើតឡើងផង ទុក្ខសច្ច កើតឡើងហើយផង ក្នុងទីនោះ ។

[ ១១៨ ] សមុទយសច្ច របស់សត្វណា កើតឡើងហើយ ក្នុងទីណា មគ្គសច្ចរបស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ សមុទយសច្ចរបស់ព្រះអរហន្តទាំងឡាយ ដែលប្រកបដោយមគ្គដ៏ប្រសើរ និងរបស់ពួកសត្វដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ និងរបស់ពួកសត្វនោះ ដែលកើតក្នុងអបាយ កើតឡើងហើយ តែមគ្គសច្ច របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វណា នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ឬក៏ពួកសត្វដទៃណា នឹងបាននូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ សមុទយ-សច្ច របស់សត្វទាំងនោះ កើតឡើងហើយផង មគ្គសច្ច នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងកើតឡើង ក្នុង

ទីណា សមុទយសច្ច របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះឬ ។ មគ្គសច្ច របស់ពួកសុទ្ធាវាសសត្វនោះ នឹងកើតឡើងក្នុងកាលចិត្តទី ២ កំពុងប្រព្រឹត្តទៅក្នុងទីនោះ តែសមុទយសច្ច របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសត្វណា នឹងបានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ឬក៏ពួកសត្វដទៃណា នឹងបានទូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ មគ្គសច្ច របស់សត្វទាំងនោះ នឹងកើតឡើងផង សមុទយសច្ច កើតឡើងហើយផង ក្នុងទីនោះ ។

[ ១១៩ ] ទុក្ខសច្ច របស់សត្វណា មិនកើតឡើងហើយ សមុទយសច្ច របស់សត្វនោះ នឹងមិនកើតឡើងឬ ។ មិនមានទេ ។ មួយយ៉ាងទៀត សមុទយសច្ច របស់សត្វណា នឹងមិនកើតឡើង ទុក្ខសច្ច របស់សត្វនោះ មិនកើតឡើងហើយឬ ។ កើតឡើងហើយ ។

[ ១២០ ] ទុក្ខសច្ច របស់សត្វណា មិនកើតឡើងហើយ មគ្គសច្ច របស់សត្វនោះ នឹងមិនកើតឡើងឬ ។ មិនមានទេ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងមិនកើតឡើង ទុក្ខសច្ច របស់សត្វនោះ មិនកើតឡើងហើយឬ ។ កើតឡើងហើយ ។

[ ១២១ ] សមុទយសច្ចរបស់សត្វណា មិនកើតឡើងហើយ មគ្គសច្ច របស់សត្វនោះ នឹងមិនកើតឡើងឬ ។ មិនមានទេ ។ មួយយ៉ាងទៀត មគ្គ-សច្ចរបស់សត្វណា នឹងមិនកើតឡើង សមុទយសច្ចរបស់សត្វនោះ មិនកើតឡើងហើយឬ ។ កើតឡើងហើយ ។

[ ១២២ ] ទុក្ខសច្ច មិនកើតឡើងហើយ ក្នុងទីណា ។បេ។

[ ១២៣ ] ទុក្ខសច្ច របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា សមុទយសច្ច របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ នឹងកើតឡើង ។ មួយយ៉ាងទៀត សមុទយសច្ច របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ទុក្ខសច្ច របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ កើតឡើងហើយ ។

[ ១២៤ ] ទុក្ខសច្ច របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា មគ្គសច្ច របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ នឹងកើតឡើង ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ទុក្ខសច្ចរបស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ កើតឡើងហើយ ។

[ ១២៥ ] សមុទយសច្ច របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា មគ្គសច្ច របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ សមុទយសច្ច របស់ពួកសុទ្ធាវាសសត្វនោះ មិនកើតឡើងហើយ ក្នុងកាលចិត្តទី ២ កំពុងប្រព្រឹត្តទៅក្នុងទីនោះ តែមគ្គសច្ច របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងក្នុងទីនោះទេ សមុទយសច្ច របស់អសញ្ញសត្វទាំងនោះ មិនកើតឡើងហើយផង មគ្គសច្ច នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា សមុទយសច្ច របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ មគ្គសច្ច របស់ព្រះអរហន្តទាំងឡាយ ដែលប្រកបដោយមគ្គដ៏ប្រសើរ និងរបស់ពួកសត្វដែល

ជាបុថុជ្ជន នឹងមិនបានទូវមគ្គ និងរបស់ពួកសត្វនោះ ដែលកើតក្នុងអបាយ នឹងមិនកើតឡើង ក្នុងទីនោះ តែសមុទយសច្ច របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ មគ្គសច្ច របស់អសញ្ញសត្វទាំងនោះ នឹងមិនកើតឡើងផង សមុទយសច្ច មិនកើតឡើងហើយផង ក្នុងទីនោះ ។

ឧប្បាទវារៈ ចប់

[ ១២៦ ] ទុក្ខសច្ច របស់សត្វណារលត់ទៅ សមុទយសច្ច របស់សត្វនោះ រលត់ទៅឬ ។ ទុក្ខសច្ច របស់សត្វទាំងអស់នោះ កាលច្យុត រលត់ទៅក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាកតណ្ហា ក្នុងបច្ចុប្បន្ន តែសមុទយសច្ច របស់សត្វទាំងនោះ មិនរលត់ទៅទេ ទុក្ខសច្ច របស់សត្វទាំងនោះ រលត់ទៅផង សមុទយសច្ច រលត់ទៅផង ក្នុងភង្គក្ខណៈនៃតណ្ហា ។ មួយយ៉ាងទៀត សមុទយសច្ចរបស់សត្វណា រលត់ទៅ ទុក្ខសច្ចរបស់សត្វនោះ រលត់ទៅឬ ។ អើ ។

[ ១២៧ ] ទុក្ខសច្ច របស់សត្វណា រលត់ទៅ មគ្គសច្ច របស់សត្វនោះ រលត់ទៅឬ ។ ទុក្ខសច្ច របស់សត្វទាំងអស់នោះ កាលច្យុត រលត់ទៅក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាកមគ្គក្នុងបច្ចុប្បន្ន តែមគ្គសច្ច របស់សត្វទាំងនោះ មិនរលត់ទៅទេ ទុក្ខសច្ច របស់សត្វទាំងនោះ រលត់ទៅផង មគ្គសច្ច រលត់ទៅផង ក្នុងភង្គក្ខណៈនៃមគ្គ ក្នុងបញ្ចវោការភព ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា រលត់ទៅ ទុក្ខសច្ច របស់សត្វនោះ រលត់ទៅឬ ។ មគ្គសច្ច របស់សត្វទាំងនោះ រលត់ទៅ ក្នុងភង្គក្ខណៈនៃមគ្គ ក្នុងអរូបភព

តែទុក្ខសច្ច របស់សត្វទាំងនោះ មិនរលត់ទៅទេ មគ្គសច្ច របស់សត្វទាំងនោះ រលត់ទៅផង ទុក្ខសច្ច រលត់ទៅផង ក្នុងភង្គក្ខណៈនៃមគ្គ ក្នុងបញ្ចវោការភព ។

[ ១២៨ ] សមុទយសច្ចរបស់សត្វណា រលត់ទៅ មគ្គសច្ចរបស់សត្វនោះ រលត់ទៅឬ ។ ទេ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា រលត់ទៅ សមុទយសច្ច របស់សត្វនោះ រលត់ទៅឬ ។ ទេ ។

[ ១២៩ ] ទុក្ខសច្ច រលត់ទៅ ក្នុងទីណា សមុទយសច្ច រលត់ទៅ ក្នុងទីនោះឬ ។ ទុក្ខសច្ច រលត់ទៅក្នុងអសញ្ញសត្វនោះ ។បេ។ ពាក្យថា ក្នុងទីណា ប្រហែលគ្នា ក្នុងកាលជាទីកើតផង ក្នុងកាលជាទីរលត់ទៅផង ក្នុងកាលជាទីកើត និងកាលជាទីរលត់ទៅផង ។ ការធ្វើឲ្យផ្សេងៗ គ្នា មិនមានឡើយ ។

[ ១៣០ ] ទុក្ខសច្ច របស់សត្វណា រលត់ទៅក្នុងទីណា ។បេ។ ពាក្យថា របស់សត្វណា ក្នុងទីណា បណ្ឌិតគប្បីឲ្យពិស្តារដូចគ្នា ។

[ ១៣១ ] ទុក្ខសច្ច របស់សត្វណា មិនរលត់ទៅ សមុទយសច្ច របស់សត្វនោះ មិនរលត់ទៅឬ ។ អើ ។ មួយយ៉ាងទៀត សមុទយសច្ច របស់សត្វណា មិនរលត់ទៅ ទុក្ខសច្ច របស់សត្វនោះ មិនរលត់ទៅឬ ។ សមុទយសច្ច របស់សត្វទាំងអស់នោះ កាលច្យុត មិនរលត់ទៅ ក្នុងភង្គក្ខណៈនៃចិត្ត ដែលប្រាសចាកតណ្ហា ក្នុងបច្ចុប្បន្ន តែទុក្ខសច្ច របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ សមុទយសច្ច របស់សត្វទាំងអស់នោះ កាល

ចាប់បដិសន្ធិ មិនរលត់ទៅផង ទុក្ខសច្ច មិនរលត់ទៅផង ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងភង្គក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព ។

[ ១៣២ ] ទុក្ខសច្ច របស់សត្វណា មិនរលត់ទៅ មគ្គសច្ច របស់សត្វនោះ មិនរលត់ទៅឬ ។ ទុក្ខសច្ច របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងភង្គក្ខណៈនៃមគ្គ ក្នុងអរូបភព តែមគ្គសច្ច របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ទុក្ខសច្ច របស់សត្វទាំងអស់នោះ កាលចាប់បដិសន្ធិ មិនរលត់ទៅផង មគ្គសច្ច មិនរលត់ទៅផង ក្នុងឧប្បាទក្ខណៈនៃចិត្តក្នុងបច្ចុប្បន្ន និងក្នុងភង្គក្ខណៈនៃផល ក្នុងអរូបភព ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា រលត់ទៅ ទុក្ខសច្ច របស់សត្វនោះ មិនរលត់ទៅឬ ។ មគ្គសច្ច របស់សត្វទាំងអស់នោះ កាលច្យុត មិនរលត់ទៅ ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាកមគ្គ ក្នុងបច្ចុប្បន្ន តែទុក្ខសច្ច របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ មគ្គសច្ច របស់សត្វទាំងអស់នោះ កាលចាប់បដិសន្ធិ មិនរលត់ទៅផង ទុក្ខសច្ច មិនរលត់ទៅផង ក្នុងឧប្បាទក្ខណៈនៃចិត្តក្នុងបច្ចុប្បន្ន និងក្នុងភង្គក្ខណៈនៃផល ក្នុងអរូបភព ។

[ ១៣៣ ] សមុទយសច្ច របស់សត្វណា មិនរលត់ទៅ មគ្គសច្ច របស់សត្វនោះ មិនរលត់ទៅឬ ។ សមុទយសច្ច របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងភង្គក្ខណៈនៃមគ្គ តែមគ្គសច្ច របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ សមុទយសច្ច របស់សត្វទាំងអស់ ដែលចូលកាន់និរោធ និងរបស់អសញ្ញសត្វទាំងនោះ មិនរលត់ទៅផង មគ្គសច្ច មិនរលត់ទៅផង ក្នុង

ឧប្បាទក្ខណៈនៃចិត្ត និងក្នុងភង្គក្ខណៈនៃចិត្ត ដែលប្រាសចាកតណ្ហា និងប្រាសចាកមគ្គ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា មិនរលត់ទៅ សមុទយសច្ច របស់សត្វនោះ មិនរលត់ទៅឬ ។ មគ្គសច្ច របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងភង្គក្ខណៈនៃតណ្ហា តែសមុទយសច្ច របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ មគ្គសច្ច របស់សត្វទាំងអស់ ដែលចូលកាន់និរោធ និងរបស់អសញ្ញសត្វទាំងនោះ មិនរលត់ទៅផង សមុទយសច្ច មិនរលត់ទៅផង ក្នុងឧប្បាទក្ខណៈនៃចិត្ត និងក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាកមគ្គ និងប្រាសចាកតណ្ហា ។

[ ១៣៤ ] ទុក្ខសច្ច មិនរលត់ទៅ ក្នុងទីណា ។បេ។

[ ១៣៥ ] ទុក្ខសច្ច របស់សត្វណា មិនរលត់ទៅក្នុងទីណា ។បេ។ ពាក្យថា របស់សត្វណាក្តី ពាក្យថា ក្នុងទីណាក្តី ពាក្យថា របស់សត្វណា ក្នុងទីណាក្តី ដូចៗ គ្នា ។ មួយយ៉ាងទៀត ពាក្យថា ពួកសត្វដែលចូលកាន់និរោធ ដូច្នេះទុំៈ បណ្ឌិតមិនគប្បីធ្វើ ក្នុងពាក្យថា របស់សត្វណា ក្នុងទីណាទេ ។

[ ១៣៦ ] ទុក្ខសច្ច របស់សត្វណា រលត់ហើយ សមុទយសច្ច របស់សត្វនោះ រលត់ហើយឬ ។ អើ ។ បុច្ឆា ជាអតីត និងពាក្យបណ្តាយក្តី ពាក្យប្រាសក្តី ដែលលោកចែកហើយ ក្នុងឧប្បាទវារៈ យ៉ាងណា បណ្ឌិតគប្បីចែក ក្នុងនិរោធវារៈយ៉ាងនោះដែរ ។ ការធ្វើឲ្យផ្សេងៗ គ្នាមិនមានទេ ។

[ ១៣៧ ] ទុក្ខសច្ច របស់សត្វណា នឹងរលត់ទៅ សមុទយសច្ច របស់

សត្វនោះ នឹងរលត់ទៅឬ ។ ទុក្ខសច្ច របស់ព្រះអរហន្តទាំងឡាយ ដែលប្រកបដោយមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាសត្វនឹងមិនបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ នឹងរលត់ទៅ តែសមុទយសច្ច របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ទុក្ខសច្ច របស់សត្វទាំងនោះ ក្រៅនេះ នឹងរលត់ទៅផង សមុទយសច្ច នឹងរលត់ទៅផង ។ មួយយ៉ាងទៀត សមុទយសច្ច របស់សត្វណា ។បេ។ អើ ។

[ ១៣៨ ] ទុក្ខសច្ច របស់សត្វណា នឹងរលត់ទៅ មគ្គសច្ច របស់សត្វនោះ នឹងរលត់ទៅឬ ។ ទុក្ខសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ នឹងរលត់ទៅ តែមគ្គសច្ច របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ សត្វទាំងឡាយ នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ ឬក៏ពួកសត្វដទៃណា នឹងបាននូវមគ្គ ទុក្ខសច្ច របស់សត្វទាំងនោះ នឹងរលត់ទៅផង មគ្គសច្ច នឹងរលត់ទៅផង ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា ។បេ។ អើ ។

[ ១៣៩ ] សមុទយសច្ចរបស់សត្វណា នឹងរលត់ទៅ មគ្គសច្ចរបស់សត្វនោះ នឹងរលត់ទៅឬ ។ ពួកសត្វណា ជាបុថុជ្ជន នឹងមិនបាននូវមគ្គ សមុទយសច្ច របស់សត្វទាំងនោះ នឹងរលត់ទៅ តែមគ្គសច្ច របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ពួកសត្វណា នឹងបាននូវមគ្គ សមុទយសច្ច របស់សត្វទាំងនោះ នឹងរលត់ទៅផង មគ្គសច្ច នឹងរលត់ទៅផង ។ មួយយ៉ាង

ទៀត មគ្គសច្ច របស់សត្វណា នឹងរលត់ទៅ សមុទយសច្ច របស់សត្វនោះ នឹងរលត់ទៅឬ ។ ពួកសត្វណា នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ មគ្គសច្ច របស់សត្វទាំងនោះ នឹងរលត់ទៅ តែសមុទយសច្ច របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ពួកសត្វណា នឹងបាននូវមគ្គ មគ្គសច្ច របស់សត្វទាំងនោះ នឹងរលត់ទៅផង សមុទយសច្ច នឹងរលត់ទៅផង ។

[ ១៤០ ] ទុក្ខសច្ច នឹងរលត់ទៅ ក្នុងទីណា ។បេ។

[ ១៤១ ] ទុក្ខសច្ចរបស់សត្វណា នឹងរលត់ទៅក្នុងទីណា សមុទយសច្ច របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះឬ ។ ទុក្ខសច្ច របស់ព្រះអរហន្ត ទាំងឡាយ ដែលប្រកបដោយមគ្គដ៏ប្រសើរ និងរបស់អសញ្ញសត្វទាំងនោះ ដែលជាសត្វនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា នឹងរលត់ទៅក្នុងទីនោះ តែសមុទយសច្ច របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ ទុក្ខសច្ច របស់សត្វទាំងនោះ ក្រៅនេះ ដែលនៅក្នុងចតុវោការភព និងបញ្ច-វោការភព នឹងរលត់ទៅផង សមុទយសច្ច នឹងរលត់ទៅផង ក្នុងទីនោះ ។ ពាក្យថា របស់សត្វណាក្តី ពាក្យថា ក្នុងទីណាក្តី ពាក្យថា របស់សត្វណា ក្នុងទីណាក្តី ដូចគ្នា ។

[ ១៤២ ] ទុក្ខសច្ច របស់សត្វណា នឹងមិនរលត់ទៅ សមុទយសច្ច របស់សត្វនោះ នឹងមិនរលត់ទៅឬ ។ អើ ។ មួយយ៉ាងទៀត សមុទយ-សច្ចរបស់សត្វណា នឹងមិនរលត់ទៅ ទុក្ខសច្ច របស់សត្វនោះ នឹងមិនរលត់

*ទៅឬ ។ អើ ។ មួយយ៉ាងទៀត សមុទយសច្ច របស់សត្វណា នឹងមិនរលត់ទៅ ទុក្ខសច្ច របស់សត្វនោះ នឹងមិនរលត់ទៅឬ ។ សមុទយសច្ច របស់ព្រះអរហន្តទាំងឡាយ ដែលប្រកបដោយមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាសត្វនឹងបានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា នឹងមិនរលត់ទៅ តែទុក្ខសច្ចរបស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ សមុទយសច្ច របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ទុក្ខសច្ច នឹងមិនរលត់ទៅផង ក្នុងភង្គក្ខណៈនៃចិត្ត ជាទីបំផុត ។*

*[ ១៤៣ ] ទុក្ខសច្ច របស់សត្វណា នឹងមិនរលត់ទៅ មគ្គសច្ច របស់សត្វនោះ នឹងមិនរលត់ទៅឬ ។ អើ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងមិនរលត់ទៅ ទុក្ខសច្ច របស់សត្វនោះ នឹងមិនរលត់ទៅឬ ។ មគ្គសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាបុថុជ្ជន នឹងមិនបានទូវមគ្គ នឹងមិនរលត់ទៅ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ មគ្គសច្ច របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ទុក្ខសច្ច នឹងមិនរលត់ទៅផង ក្នុងភង្គក្ខណៈនៃចិត្ត ជាទីបំផុត ។*

*[ ១៤៤ ] សមុទយសច្ច របស់សត្វណា នឹងមិនរលត់ទៅ មគ្គសច្ច របស់សត្វនោះ នឹងមិនរលត់ទៅឬ ។ ពួកសត្វ នឹងបានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ សមុទយសច្ចរបស់សត្វទាំងនោះ នឹងមិនរលត់ទៅ តែមគ្គសច្ចរបស់សត្វទាំងនោះ មិនមែនជានឹងមិន*

រលត់ទៅទេ សមុទយសច្ច របស់ព្រះអរហន្តទាំងឡាយនោះ នឹងមិនរលត់ទៅផង មគ្គសច្ច នឹងមិនរលត់ទៅផង ក្នុងកង្គក្ខណៈនៃមគ្គដ៏ប្រសើរ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងមិនរលត់ទៅ សមុទយសច្ច របស់សត្វនោះ នឹងមិនរលត់ទៅឬ ។ ពួកសត្វណា ជាបុថុជ្ជន នឹងមិនបាននូវមគ្គ មគ្គសច្ច របស់សត្វទាំងនោះ នឹងមិនរលត់ទៅ តែសមុទយសច្ច របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ មគ្គសច្ច របស់ព្រះអរហន្តទាំងឡាយនោះ នឹងមិនរលត់ទៅផង សមុទយសច្ច នឹងមិនរលត់ទៅផង ក្នុងកង្គក្ខណៈនៃមគ្គដ៏ប្រសើរ ។

[ ១៤៥ ] ទុក្ខសច្ច នឹងមិនរលត់ទៅ ក្នុងទីណា ។បេ។

[ ១៤៦ ] ទុក្ខសច្ច របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា សមុទយសច្ច របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត សមុទយសច្ច របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ទុក្ខសច្ច របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះឬ ។ សមុទយសច្ច របស់ព្រះអរហន្តទាំងឡាយ ដែលប្រកបដោយមគ្គដ៏ប្រសើរ និងរបស់អសញ្ញសត្វទាំងនោះ ដែលជាសត្វនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា នឹងមិនរលត់ទៅ ក្នុងទីនោះ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ សមុទយសច្ច របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ទុក្ខសច្ច នឹងមិនរលត់ទៅផង ក្នុងកង្គក្ខណៈនៃចិត្តជាទីបំផុត ក្នុងទីនោះ ។

[ ១៤៧ ] ទុក្ខសច្ច របស់សត្វណា នឹងមិនរលត់ទៅក្នុងទីណា មគ្គសច្ច

របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ទុក្ខសច្ច របស់សត្វនោះ នឹងមិនរលត់ទៅក្នុងទីនោះឬ ។ មគ្គសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់ពួកសត្វដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ និងរបស់ពួកសត្វដែលកើតក្នុងអបាយ និងរបស់អសញ្ញសត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ មគ្គសច្ច របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ទុក្ខសច្ច នឹងមិនរលត់ទៅផង ក្នុងភង្គក្ខណៈនៃចិត្ត ជាទីបំផុត ក្នុងទីនោះ ។

[ ១៤៨ ] សមុទយសច្ច របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា មគ្គសច្ច របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះឬ ។ ពួកសត្វ នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ សមុទយសច្ចរបស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ តែមគ្គសច្ច របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ សមុទយសច្ច របស់ព្រះអរហន្តទាំងឡាយ និងរបស់អសញ្ញសត្វទាំងនោះ នឹងមិនរលត់ទៅផង មគ្គសច្ច នឹងមិនរលត់ទៅផង ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរក្នុងទីនោះ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា សមុទយសច្ច របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះឬ ។ មគ្គសច្ច របស់ពួកសត្វដែលកើតក្នុងអបាយ និងរបស់សត្វទាំងនោះ ដែលជាបុថុជ្ជន

នឹងមិនបាននូវមគ្គ នឹងមិនរលត់ទៅ ក្នុងទីនោះ តែសមុទយសច្ច របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ មគ្គសច្ច របស់ព្រះអរហន្តទាំងឡាយ និងរបស់អសញ្ញសត្វទាំងនោះ នឹងមិនរលត់ទៅផង សមុ-ទយសច្ច នឹងមិនរលត់ទៅផង ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ ក្នុងទីនោះ ។

[ ១៤៩ ] ទុក្ខសច្ច របស់សត្វណា រលត់ទៅ សមុទយសច្ច របស់សត្វនោះ រលត់ហើយឬ ។ អើ ។ មួយយ៉ាងទៀត សមុទយសច្ច របស់សត្វណា រលត់ហើយ ទុក្ខសច្ច របស់សត្វនោះ រលត់ទៅឬ ។ ពួកសត្វទាំងអស់ កាលចាប់បដិសន្ធិ សមុទយសច្ច របស់សត្វទាំងនោះ រលត់ហើយក្នុងឧប្បាទក្ខណៈនៃចិត្តក្នុងបច្ចុប្បន្ន និងក្នុងភង្គក្ខណៈនៃមគ្គ និងផលក្នុងអរូបភព តែទុក្ខសច្ច របស់សត្វទាំងនោះ មិនរលត់ទៅទេ ពួកសត្វទាំងអស់ កាលច្យុត សមុទយសច្ច របស់សត្វទាំងនោះ រលត់ហើយផង ទុក្ខសច្ច រលត់ទៅផង ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន ។

[ ១៥០ ] ទុក្ខសច្ច របស់សត្វណា រលត់ទៅ មគ្គសច្ច របស់សត្វនោះ រលត់ហើយឬ ។ ពួកសត្វ ដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ កាលច្យុត ទុក្ខសច្ច របស់សត្វទាំងនោះ រលត់ទៅ ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន តែមគ្គសច្ច របស់សត្វទាំងនោះ មិនរលត់ហើយទេ ពួកសត្វដែលជាអ្នកត្រាស់ដឹងនូវសច្ចៈ ៤ កាលច្យុត ទុក្ខសច្ច របស់សត្វទាំងនោះ រលត់ទៅផង មគ្គសច្ច រលត់ហើយផង ក្នុងភង្គក្ខណៈនៃចិត្តក្នុងបច្ចុប្បន្ន ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា រលត់ហើយ ទុក្ខសច្ច របស់សត្វនោះ

រលត់ទៅឬ ។ ពួកសត្វដែលជាអ្នកត្រាស់ដឹងនូវសច្ចៈ ៤ កាលចាប់បដិសន្ធិ មគ្គសច្ច របស់សត្វទាំងនោះ រលត់ហើយ ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងភង្គក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព តែទុក្ខសច្ច របស់សត្វទាំងនោះ មិនរលត់ទៅទេ ពួកសត្វដែលជាអ្នកត្រាស់ដឹងនូវសច្ចៈ ៤ កាលច្យុត មគ្គសច្ច របស់សត្វទាំងនោះ រលត់ហើយផង ទុក្ខសច្ច រលត់ទៅផង ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន ។

[ ១៥១ ] សមុទយសច្ច របស់សត្វណា រលត់ទៅ មគ្គសច្ច របស់សត្វនោះ រលត់ហើយឬ ។ ពួកសត្វដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ សមុទយសច្ច របស់សត្វទាំងនោះ រលត់ទៅ ក្នុងភង្គក្ខណៈនៃតណ្ហា តែមគ្គសច្ច របស់សត្វទាំងនោះ មិនរលត់ហើយទេ ពួកសត្វដែលជាអ្នកត្រាស់ដឹងនូវសច្ចៈ ៤ សមុទយសច្ច របស់សត្វទាំងនោះ រលត់ទៅផង មគ្គសច្ច រលត់ហើយផង ក្នុងភង្គក្ខណៈនៃតណ្ហា ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា រលត់ហើយ សមុទយសច្ច របស់សត្វនោះ រលត់ទៅឬ ។ ពួកសត្វដែលជាអ្នកត្រាស់ដឹងនូវសច្ចៈ ៤ និងពួកសត្វដែលចូលកាន់និរោធ ក្នុងឧប្បាទក្ខណៈនៃតណ្ហា និងក្នុងកាលដែលចិត្តប្រាសចាកតណ្ហា កំពុងប្រព្រឹត្តទៅ មគ្គសច្ច របស់សត្វទាំងនោះ រលត់ហើយ តែសមុទយសច្ច របស់សត្វទាំងនោះ មិនរលត់ទៅទេ ពួកសត្វដែលជាអ្នកត្រាស់ដឹងនូវសច្ចៈ ៤ មគ្គសច្ច របស់សត្វទាំងនោះ រលត់ហើយផង សមុទយសច្ច រលត់ទៅផង ក្នុងភង្គក្ខណៈនៃតណ្ហា ។

[ ១៥២ ] ទុក្ខសច្ចរលត់ទៅ ក្នុងទីណា ។បេ។

[ ១៥៣ ] ទុក្ខសច្ចរបស់សត្វណា រលត់ទៅក្នុងទីណា សមុទយសច្ច របស់សត្វនោះ រលត់ហើយក្នុងទីនោះឬ ។ ទុក្ខសច្ចរបស់ពួកសុទ្ធាវាសសត្វ និងរបស់សត្វទាំងនោះ កាលច្យុតចាកអសញ្ញសត្វ ក្នុងភង្គក្ខណៈនៃឧប្បត្តិ-ចិត្ត រលត់ទៅ ក្នុងទីនោះ តែសមុទយសច្ចរបស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះទេ ពួកសត្វក្រៅនេះ កាលច្យុតចាកចតុវោការភព និងបញ្ចវោការភព ទុក្ខសច្ច របស់សត្វទាំងនោះ រលត់ទៅផង សមុទយសច្ចរលត់ហើយផង ក្នុងភង្គក្ខណៈនៃចិត្តក្នុងបច្ចុប្បន្ន ក្នុងទីនោះ ។ មួយយ៉ាងទៀត សមុទយសច្ចរបស់សត្វណា រលត់ហើយ ក្នុងទីណា ទុក្ខសច្ចរបស់សត្វនោះ រលត់ទៅ ក្នុងទីនោះឬ ។ ពួកសត្វ កាលចូលទៅកាន់ចតុវោ-ការភព និងបញ្ចវោការភព សមុទយសច្ច របស់សត្វទាំងនោះ រលត់ហើយក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងភង្គក្ខណៈនៃមគ្គ និងផល ក្នុងអរូបភពក្នុងទីនោះ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនរលត់ទៅក្នុងទីនោះទេ ពួកសត្វ កាលច្យុតចាកចតុវោការភព និងបញ្ចវោការភព សមុទយ-សច្ច របស់សត្វទាំងនោះ រលត់ហើយផង ទុក្ខសច្ច រលត់ទៅផង ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន ក្នុងទីនោះ ។

[ ១៥៤ ] ទុក្ខសច្ច របស់សត្វណា រលត់ទៅ ក្នុងទីណា មគ្គសច្ច របស់សត្វនោះ រលត់ហើយ ក្នុងទីនោះឬ ។ ទុក្ខសច្ច របស់ពួកសុទ្ធាវាស-សត្វ និងរបស់ពួកសត្វដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ កាលច្យុត

ក្នុងភង្គក្ខណៈនៃឧប្បត្តិចិត្ត និងរបស់ពួកសត្វទាំងនោះ កាលច្យុតចាកអសញ្ញ-សត្វ ក្នុងភង្គក្ខណៈនៃចិត្តក្នុងបច្ចុប្បន្ន រលត់ទៅ ក្នុងទីនោះ តែមគ្គសច្ច របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះទេ ពួកសត្វដែលជាអ្នកត្រាស់ដឹងនូវសច្ចៈ ៤ កាលច្យុត ទុក្ខសច្ច របស់សត្វទាំងនោះ រលត់ទៅផង មគ្គសច្ច រលត់ហើយផង ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន ក្នុងទីនោះ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា រលត់ហើយ ក្នុងទីណា ទុក្ខសច្ច របស់សត្វនោះ រលត់ទៅ ក្នុងទីនោះឬ ។ ពួកសត្វដែលជាអ្នកត្រាស់ដឹងនូវសច្ចៈ ៤ កាលចាប់បដិសន្ធិ មគ្គសច្ច របស់សត្វទាំងនោះ រលត់ហើយ ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងភង្គក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព ក្នុងទីនោះ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វដែលជាអ្នកត្រាស់ដឹងនូវសច្ចៈ ៤ កាលច្យុត មគ្គសច្ច របស់សត្វទាំងនោះ រលត់ហើយផង ទុក្ខសច្ច រលត់ទៅផង ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន ក្នុងទីនោះ ។

[ ១៥៥ ] សមុទយសច្ច របស់សត្វណា រលត់ទៅ ក្នុងទីណា មគ្គសច្ច របស់សត្វនោះ រលត់ហើយក្នុងទីនោះឬ ។ ពួកសត្វដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ ក្នុងភង្គក្ខណៈនៃតណ្ហា សមុទយសច្ច របស់សត្វទាំងនោះ រលត់ទៅ ក្នុងទីនោះ តែមគ្គសច្ច របស់សត្វទាំងនោះ មិនរលត់ហើយក្នុងទីនោះទេ ពួកសត្វដែលជាអ្នកត្រាស់ដឹងនូវសច្ចៈ ៤ ក្នុងភង្គក្ខណៈនៃតណ្ហា សមុទយសច្ច របស់សត្វទាំងនោះ រលត់ទៅផង មគ្គសច្ច រលត់ហើយផង

ក្នុងទីនោះ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា រលត់ហើយ ក្នុងទីណា សមុទយសច្ច របស់សត្វនោះ រលត់ទៅ ក្នុងទីនោះឬ ។ ពួកសត្វដែលជាអ្នកត្រាស់ដឹងនូវសច្ចៈ ៤ ក្នុងឧប្បាទក្ខណៈនៃតណ្ហា និងក្នុងកាលដែលចិត្តប្រាសចាកតណ្ហា កំពុងប្រព្រឹត្តទៅ មគ្គសច្ច របស់សត្វទាំងនោះ រលត់ហើយ ក្នុងទីនោះ តែសមុទយសច្ច របស់សត្វទាំងនោះ មិនរលត់ទៅក្នុងទីនោះទេ ពួកសត្វដែលជាអ្នកត្រាស់ដឹងនូវសច្ចៈ ៤ ក្នុងភង្គក្ខណៈនៃតណ្ហា មគ្គសច្ច របស់សត្វទាំងនោះ រលត់ហើយផង សមុទយសច្ច រលត់ទៅផង ក្នុងទីនោះ ។

[ ១៥៦ ] ទុក្ខសច្ច របស់សត្វណា មិនរលត់ទៅ សមុទយសច្ច របស់សត្វនោះ មិនរលត់ហើយឬ ។ រលត់ហើយ ។ មួយយ៉ាងទៀត សមុទយ-សច្ច របស់សត្វណា មិនរលត់ហើយ ទុក្ខសច្ច របស់សត្វនោះ មិនរលត់ទៅឬ ។ មិនមានទេ ។

[ ១៥៧ ] ទុក្ខសច្ច របស់សត្វណា មិនរលត់ទៅ មគ្គសច្ច របស់សត្វនោះ មិនរលត់ហើយឬ ។ ពួកសត្វដែលជាអ្នកត្រាស់ដឹងនូវសច្ចៈ ៤ កាលចាប់បដិសន្ធិ ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងភង្គក្ខណៈនៃមគ្គនិងផល ក្នុងអរូបភព ទុក្ខសច្ច របស់សត្វទាំងនោះ មិនរលត់ទៅ តែមគ្គសច្ច របស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយទេ ពួកសត្វដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ កាលចាប់បដិសន្ធិ ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន ទុក្ខសច្ច របស់សត្វទាំងនោះ មិនរលត់ទៅផង មគ្គសច្ច មិនរលត់

ហើយផង ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា មិនរលត់ហើយ ទុក្ខសច្ច របស់សត្វនោះ មិនរលត់ទៅឬ ។ ពួកសត្វដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ កាលច្យុតក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន មគ្គសច្ច របស់សត្វទាំងនោះ មិនរលត់ហើយ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ កាលចាប់បដិសន្ធិក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន មគ្គសច្ច របស់សត្វទាំងនោះ មិនរលត់ហើយផង ទុក្ខសច្ច មិនរលត់ទៅផង ។

[ ១៥៨ ] សមុទយសច្ច របស់សត្វណា មិនរលត់ទៅ មគ្គសច្ច របស់សត្វនោះ មិនរលត់ហើយឬ ។ ពួកសត្វដែលជាអ្នកត្រាស់ដឹងនូវសច្ចៈ ៤ ក្នុងឧប្បាទក្ខណៈនៃតណ្ហា និងពួកសត្វដែលចូលកាន់និរោធ ក្នុងកាលដែលចិត្តប្រាសចាកតណ្ហា កំពុងប្រព្រឹត្តទៅ សមុទយសច្ច របស់សត្វទាំងនោះ មិនរលត់ទៅ តែមគ្គសច្ច របស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយទេ ពួកសត្វដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ ក្នុងឧប្បាទក្ខណៈនៃតណ្ហា និងពួកអសញ្ញសត្វ ក្នុងកាលដែលចិត្តប្រាសចាកតណ្ហា កំពុងប្រព្រឹត្តទៅ សមុទយសច្ច របស់សត្វទាំងនោះ មិនរលត់ទៅផង មគ្គសច្ច មិនរលត់ហើយផង ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា មិនរលត់ហើយ សមុទយសច្ច របស់សត្វនោះ មិនរលត់ទៅឬ ។ ពួកសត្វដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ ក្នុងភង្គក្ខណៈនៃតណ្ហា មគ្គសច្ច របស់សត្វទាំងនោះ មិនរលត់ហើយ តែសមុទយសច្ច របស់សត្វទាំងនោះ មិនមែនជាមិន

រលត់ទៅទេ ពួកសត្វ ដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ ក្នុងឧប្បាទក្ខណៈនៃតណ្ហា និងពួកអសញ្ញសត្វ ក្នុងកាលដែលចិត្តប្រាសចាកតណ្ហាកំពុងប្រព្រឹត្តទៅ មគ្គសច្ច របស់សត្វទាំងនោះ មិនរលត់ហើយផង សមុទយសច្ច មិនរលត់ទៅផង ។

[ ១៥៩ ] ទុក្ខសច្ច មិនរលត់ទៅ ក្នុងទីណា ។បេ។

[ ១៦០ ] ទុក្ខសច្ច របស់សត្វណា មិនរលត់ទៅ ក្នុងទីណា សមុទយសច្ច របស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះឬ ។ ពួកសត្វ កាលចូលទៅកាន់ចតុវោការភព និងបញ្ចវោការភព ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងភង្គក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព ទុក្ខសច្ច របស់សត្វទាំងនោះ មិនរលត់ទៅក្នុងទីនោះ ។ តែសមុទយសច្ចរបស់សត្វទាំងនោះមិនមែនជាមិនរលត់ហើយ ក្នុងទីនោះទេ ពួកសុទ្ធាវាសសត្វ និងពួកសត្វកាលចូលទៅកាន់អសញ្ញសត្វ ក្នុងឧប្បាទក្ខណៈនៃឧប្បត្តិចិត្ត ទុក្ខសច្ចរបស់សត្វទាំងនោះ មិនរលត់ទៅផង សមុទយសច្ច មិនរលត់ហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សមុទយសច្ចរបស់សត្វណា មិនរលត់ហើយ ក្នុងទីណា ទុក្ខសច្ច របស់សត្វនោះ មិនរលត់ទៅ ក្នុងទីនោះឬ ។ ពួកសុទ្ធាវាសសត្វ និងពួកសត្វ កាលច្យុតចាកអសញ្ញសត្វ ក្នុងភង្គក្ខណៈនៃឧប្បត្តិចិត្ត សមុទយសច្ច របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅ ក្នុងទីនោះទេ ពួកសុទ្ធាវាសសត្វ និងពួកសត្វ កាលចូលទៅកាន់អសញ្ញសត្វ ក្នុងឧប្បាទក្ខណៈ

នៃឧប្បត្តិចិត្ត សមុទយសច្ច របស់សត្វទាំងនោះ មិនរលត់ហើយផង ទុក្ខសច្ច មិនរលត់ទៅផង ក្នុងទីនោះ ។

[ ១៦១ ] ទុក្ខសច្ចរបស់សត្វណា មិនរលត់ទៅ ក្នុងទីណា មគ្គសច្ច របស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះឬ ។ ពួកសត្វដែលជាអ្នកត្រាស់ដឹងនូវសច្ចៈ ៤ កាលចាប់បដិសន្ធិ ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងភង្គក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព ទុក្ខសច្ច របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះ តែមគ្គសច្ច របស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយ ក្នុងទីនោះទេ ទុក្ខសច្ច របស់ពួកសុទ្ធាវាសសត្វ ក្នុងឧប្បាទក្ខណៈនៃឧប្បត្តិចិត្ត និងរបស់ពួកសត្វដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ កាលចាប់បដិសន្ធិ ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងរបស់សត្វទាំងនោះ កាលចូលទៅកាន់អសញ្ញសត្វ មិនរលត់ទៅផង មគ្គសច្ច មិនរលត់ហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា មិនរលត់ហើយ ក្នុងទីណា ទុក្ខសច្ច របស់សត្វនោះ មិនរលត់ទៅក្នុងទីនោះឬ ។ មគ្គសច្ច របស់ពួកសុទ្ធាវាសសត្វ ក្នុងភង្គក្ខណៈនៃឧប្បត្តិចិត្ត និងរបស់ពួកសត្វដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ កាលច្យុត និងរបស់សត្វទាំងនោះ កាលច្យុតចាកអសញ្ញសត្វ ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន មិនរលត់ហើយ ក្នុងទីនោះ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅ ក្នុងទីនោះទេ មគ្គសច្ច របស់ពួកសុទ្ធាវាសសត្វ ក្នុងឧប្បាទក្ខណៈនៃឧប្បត្តិចិត្ត និងរបស់ពួកសត្វដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ កាល

ចាប់បដិសន្ធិ ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងរបស់សត្វទាំងនោះ កាលចូលទៅកាន់អសញ្ញសត្វ មិនរលត់ហើយផង ទុក្ខសច្ច មិនរលត់ទៅផង ក្នុងទីនោះ ។

[ ១៦២ ] សមុទយសច្ច របស់សត្វណា មិនរលត់ទៅ ក្នុងទីណា មគ្គសច្ច របស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះឬ ។ ពួកសត្វដែលជាអ្នកត្រាស់ដឹងនូវសច្ចៈ ៤ ក្នុងឧប្បាទក្ខណៈនៃតណ្ហា និងក្នុងកាលដែលចិត្តប្រាសចាកតណ្ហា កំពុងប្រព្រឹត្តទៅ សមុទយសច្ច របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះ តែមគ្គសច្ច របស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយ ក្នុងទីនោះទេ ចិត្តទី ២ របស់ពួកសុទ្ធាវាសសត្វ កំពុងប្រព្រឹត្តទៅ និងពួកសត្វដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ ក្នុងឧប្បាទក្ខណៈនៃតណ្ហា និងក្នុងកាលដែលចិត្តប្រាសចាកតណ្ហា កំពុងប្រព្រឹត្តទៅ និងពួកអសញ្ញសត្វ សមុទយសច្ច របស់សត្វទាំងនោះ មិនរលត់ទៅផង មគ្គសច្ច មិនរលត់ហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មគ្គសច្ចរបស់សត្វណា មិនរលត់ហើយ ក្នុងទីណា សមុទយសច្ច របស់សត្វនោះ មិនរលត់ទៅក្នុងទីនោះឬ ។ ពួកសត្វដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ ក្នុងភង្គក្ខណៈនៃតណ្ហា មគ្គសច្ច របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះ តែសមុទយសច្ច របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅ ក្នុងទីនោះទេ ចិត្តទី ២ របស់ពួកសុទ្ធាវាសសត្វ កំពុងប្រព្រឹត្តទៅ និងពួកសត្វដែលជាអ្នកមិនទាន់ត្រាស់ដឹងនូវសច្ចៈ ៤ ក្នុងឧប្បាទក្ខណៈនៃតណ្ហា និងក្នុងកាល

ដែលចិត្តប្រាសចាកតណ្ហា កំពុងប្រព្រឹត្តទៅ និងពួកអសញ្ញសត្វ មគ្គសច្ច របស់សត្វទាំងនោះ មិនរលត់ហើយផង សមុទយសច្ច មិនរលត់ទៅផង ក្នុងទីនោះ ។

[ ១៦៣ ] ទុក្ខសច្ចរបស់សត្វណា រលត់ទៅ សមុទយសច្ចរបស់សត្វនោះ នឹងរលត់ទៅឬ ។ ទុក្ខសច្ចរបស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាសត្វនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងភង្គក្ខណៈនៃចិត្តនោះ រលត់ទៅ តែសមុទយសច្ចរបស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ពួកសត្វក្រៅនេះ កាលច្យុតក្នុងភង្គក្ខណៈនៃចិត្តក្នុងបច្ចុប្បន្ន ទុក្ខសច្ចរបស់សត្វទាំងនោះ រលត់ទៅផង សមុទយសច្ច នឹងរលត់ទៅផង ។ មួយយ៉ាងទៀត សមុទយ-សច្ច របស់សត្វណា នឹងរលត់ទៅ ទុក្ខសច្ច របស់សត្វនោះ រលត់ទៅឬ ។ ពួកសត្វទាំងអស់ កាលចាប់បដិសន្ធិក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងភង្គក្ខណៈនៃមគ្គ និងផលក្នុងអរូបភព សមុទយសច្ច របស់សត្វទាំងនោះ នឹងរលត់ទៅ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនរលត់ទៅទេ ពួកសត្វទាំងអស់ កាលច្យុតក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន សមុទយសច្ច របស់សត្វទាំងនោះ នឹងរលត់ទៅផង ទុក្ខសច្ច រលត់ទៅផង ។

[ ១៦៤ ] ទុក្ខសច្ច របស់សត្វណា រលត់ទៅ មគ្គសច្ច របស់សត្វនោះ នឹងរលត់ទៅឬ ។ ទុក្ខសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះៗ ដែលជាបុថុជ្ជន នឹងបាននូវមគ្គ ក្នុង

ភង្គក្ខណៈនៃចិត្ត កាលច្យុត ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន រលត់ទៅ តែមគ្គសច្ច របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ពួកសត្វនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ឬក៏ពួកសត្វដទៃណា នឹងបាននូវមគ្គ ក្នុងភង្គក្ខណៈនៃចិត្តនោះ ពួកសត្វនោះ កាលច្យុត ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន ទុក្ខសច្ច របស់សត្វទាំងនោះ រលត់ទៅផង មគ្គសច្ច នឹងរលត់ទៅផង ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងរលត់ទៅ ទុក្ខសច្ច របស់សត្វនោះ រលត់ទៅឬ ។ ពួកសត្វនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ ឬក៏ពួកសត្វដទៃណា នឹងបាននូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ ពួកសត្វនោះ កាលចាប់បដិសន្ធិ ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងភង្គក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព មគ្គសច្ច របស់សត្វទាំងនោះ នឹងរលត់ទៅ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនរលត់ទៅទេ ពួកសត្វនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ឬក៏ពួកសត្វដទៃណា នឹងបាននូវមគ្គ ក្នុងភង្គក្ខណៈនៃចិត្តនោះ ពួកសត្វនោះ កាលច្យុត ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន មគ្គសច្ច របស់សត្វទាំងនោះ នឹងរលត់ទៅផង ទុក្ខសច្ច រលត់ទៅផង ។

[ ១៦៥ ] សមុទយសច្ចរបស់សត្វណា រលត់ទៅ មគ្គសច្ចរបស់សត្វនោះ នឹងរលត់ទៅឬ ។ ពួកសត្វណាជាបុថុជ្ជន នឹងមិនបាននូវមគ្គ សមុទយសច្ច របស់សត្វនោះៗ រលត់ទៅ ក្នុងភង្គក្ខណៈនៃតណ្ហា តែមគ្គសច្ច របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ពួកសត្វណា នឹងបាននូវមគ្គ សមុទយសច្ច

របស់សត្វនោះៗ រលត់ទៅផង មគ្គសច្ច នឹងរលត់ទៅផង ក្នុងភង្គក្ខណៈនៃតណ្ហា ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងរលត់ទៅ សមុទយសច្ច របស់សត្វនោះ រលត់ទៅឬ ។ ពួកសត្វនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ ឬក៏ពួកសត្វដទៃណានឹងបាននូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ មគ្គសច្ច របស់សត្វទាំងនោះ ក្នុងឧប្បាទក្ខណៈនៃតណ្ហា និងរបស់ពួកសត្វដែលចូលកាន់និរោធ ក្នុងកាលដែលចិត្តប្រាសចាកតណ្ហា កំពុងប្រព្រឹត្តទៅ និងរបស់ពួកអសញ្ញសត្វនោះ នឹងរលត់ទៅ តែសមុទយសច្ច របស់សត្វទាំងនោះ មិនរលត់ទៅទេ ពួកសត្វណា នឹងបាននូវមគ្គ មគ្គសច្ច របស់សត្វនោះៗ នឹងរលត់ផង សមុទយសច្ច រលត់ទៅផង ក្នុងភង្គក្ខណៈនៃតណ្ហា ។

[ ១៦៦ ] ទុក្ខសច្ច រលត់ទៅ ក្នុងទីណា ។បេ។

[ ១៦៧ ] ទុក្ខសច្ច របស់សត្វណា រលត់ទៅ ក្នុងទីណា សមុទយសច្ច របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះឬ ។ ទុក្ខសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាសត្វនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងភង្គក្ខណៈនៃចិត្ត កាលច្យុតចាកអសញ្ញសត្វ ក្នុងភង្គក្ខណៈនៃចិត្តនោះ រលត់ទៅ ក្នុងទីនោះ តែសមុទយសច្ច របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វក្រៅនេះ កាលច្យុតចាកចតុវោការភព និងបញ្ចវោការភព ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន ទុក្ខសច្ច របស់សត្វទាំងនោះ រលត់ទៅផង សមុទយសច្ច

នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សមុទយសច្ចរបស់សត្វណា នឹងរលត់ទៅ ក្នុងទីណា ទុក្ខសច្ច របស់សត្វនោះ រលត់ទៅ ក្នុងទីនោះឬ ។ ពួកសត្វ កាលចូលទៅកាន់ចតុវោការភព និងបញ្ចវោការភព ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងភង្គក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព សមុទយសច្ច របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ កាលច្យុតចាកចតុវោការភព និងបញ្ចវោការភព ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន សមុទយសច្ច របស់សត្វទាំងនោះ នឹងរលត់ទៅផង ទុក្ខសច្ច រលត់ទៅផង ក្នុងទីនោះ ។

[ ១៦៨ ] ទុក្ខសច្ច របស់សត្វណា រលត់ទៅក្នុងទីណា មគ្គសច្ច របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះឬ ។ ទុក្ខសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់ពួកសត្វទាំងនោះ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ ក្នុងភង្គក្ខណៈនៃចិត្ត កាលច្យុត និងរបស់ពួកសត្វទាំងនោះ កាលច្យុតចាកអបាយ និងចាកអសញ្ញសត្វ ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន រលត់ទៅ ក្នុងទីនោះ តែមគ្គសច្ច របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងភង្គក្ខណៈនៃមគ្គ ក្នុងបញ្ចវោការភព ឬក៏ពួកសត្វដទៃណា នឹងបាននូវមគ្គ ក្នុងភង្គក្ខណៈនៃចិត្តនោះ ពួកសត្វនោះ កាលច្យុត ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន ទុក្ខសច្ច របស់សត្វទាំងនោះ រលត់ទៅផង មគ្គសច្ច នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹង

រលត់ទៅ ក្នុងទីណា ទុក្ខសច្ច របស់សត្វនោះ រលត់ទៅ ក្នុងទីនោះឬ ។ ពួកសត្វណា នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ ឬក៏ពួកសត្វដទៃណា នឹងបាននូវមគ្គក្នុងឧប្បាទក្ខណៈនៃចិត្តនោះ ពួកសត្វនោះ កាលចាប់បដិសន្ធិក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងភង្គក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព មគ្គសច្ច របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងភង្គក្ខណៈនៃមគ្គ ក្នុងបញ្ចវោការភព ឬក៏ពួកសត្វដទៃណា នឹងបាននូវមគ្គ ក្នុងភង្គក្ខណៈនៃចិត្តនោះ ពួកសត្វនោះ កាលច្យុត ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន មគ្គសច្ច របស់សត្វទាំងនោះ នឹងរលត់ទៅផង ទុក្ខសច្ច រលត់ទៅផង ក្នុងទីនោះ ។

[ ១៦៩ ] សមុទយសច្ច របស់សត្វណា រលត់ទៅក្នុងទីណា មគ្គសច្ច របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះឬ ។ សមុទយសច្ច របស់ពួកសត្វដែលកើតក្នុងអបាយ និងរបស់សត្វនោះៗ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ ក្នុងភង្គក្ខណៈនៃតណ្ហា រលត់ទៅ ក្នុងទីនោះ តែមគ្គសច្ច របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វណា នឹងបាននូវមគ្គ សមុទយសច្ច របស់សត្វនោះៗ រលត់ទៅផង មគ្គសច្ច នឹងរលត់ទៅផង ក្នុងភង្គក្ខណៈនៃតណ្ហា ក្នុងទីនោះ ។ មួយយ៉ាងទៀត មគ្គសច្ចរបស់សត្វណា នឹងរលត់ទៅក្នុងទីណា សមុទយសច្ចរបស់សត្វនោះ រលត់ទៅក្នុងទីនោះឬ ។

ពួកសត្វ នឹងបានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ ឬក៏ពួកសត្វដទៃណា នឹងបានទូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ មគ្គសច្ច របស់សត្វនោះៗ នឹងរលត់ទៅ ក្នុងឧប្បាទក្ខណៈនៃតណ្ហា និងក្នុងកាលដែលចិត្តប្រាសចាកតណ្ហា កំពុងប្រព្រឹត្តទៅ ក្នុងទីនោះ តែសមុទយសច្ច របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វណា នឹងបានទូវមគ្គ មគ្គសច្ច របស់សត្វនោះៗ នឹងរលត់ទៅផង សមុទយសច្ច រលត់ទៅផង ក្នុងភង្គក្ខណៈនៃតណ្ហា ក្នុងទីនោះ ។

[ ១៧០ ] ទុក្ខសច្ចរបស់សត្វណា មិនរលត់ទៅ សមុទយសច្ចរបស់សត្វនោះ នឹងមិនរលត់ទៅឬ ។ ពួកសត្វទាំងអស់ កាលចាប់បដិសន្ធិ ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងភង្គក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព ទុក្ខសច្ច របស់សត្វទាំងនោះ មិនរលត់ទៅ តែសមុទយសច្ច របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ ទុក្ខសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាសត្វ នឹងបានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ និងក្នុងភង្គក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព មិនរលត់ទៅផង សមុទយសច្ច នឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត សមុទយសច្ច របស់សត្វណា នឹងមិនរលត់ទៅ ទុក្ខសច្ច របស់សត្វនោះ មិនរលត់ទៅឬ ។ សមុទយសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាសត្វ នឹងបានទូវមគ្គដ៏ប្រសើរ

ក្នុងលំដាប់នៃចិត្តណា ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងភង្គក្ខណៈនៃចិត្តនោះ នឹងមិនរលត់ទៅ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ សមុទយសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាសត្វ នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ និងក្នុងភង្គក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព នឹងមិនរលត់ទៅផង ទុក្ខសច្ច មិនរលត់ទៅផង ។

[ ១៧១ ] ទុក្ខសច្ច របស់សត្វណា មិនរលត់ទៅ មគ្គសច្ច របស់សត្វនោះ នឹងមិនរលត់ទៅឬ ។ ពួកសត្វ នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ ឬក៏ពួកសត្វណា នឹងបាននូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ ពួកសត្វនោះ កាលចាប់បដិសន្ធិក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងភង្គក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព ទុក្ខសច្ច របស់សត្វទាំងនោះ មិនរលត់ទៅ តែមគ្គសច្ច របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ ទុក្ខសច្ច របស់ព្រះអរហន្តទាំងឡាយ និងរបស់សត្វនោះៗ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្ត កាលចាប់បដិសន្ធិក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងភង្គក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព មិនរលត់ទៅផង មគ្គសច្ច នឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងមិនរលត់ទៅ ទុក្ខសច្ច របស់សត្វនោះ មិនរលត់ទៅឬ ។ មគ្គសច្ចរបស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈ

នៃមគ្គដ៏ប្រសើរ និងរបស់សត្វនោះៗ ដែលជាបុថុជ្ជន នឹងមិនបានទូវមគ្គ ក្នុងភង្គក្ខណៈនៃចិត្ត កាលច្យុត ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន នឹងមិនរលត់ទៅ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ មគ្គសច្ច របស់ព្រះអរហន្តទាំងឡាយ និងរបស់សត្វនោះៗ ដែលជាបុថុជ្ជន នឹងមិនបានទូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្ត កាលចាប់បដិសន្ធិ ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងភង្គក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព នឹងមិនរលត់ទៅផង ទុក្ខសច្ច មិនរលត់ទៅផង ។

[ ១៧២ ] សមុទយសច្ច របស់សត្វណា មិនរលត់ទៅ មគ្គសច្ច របស់សត្វនោះ នឹងមិនរលត់ទៅឬ ។ ពួកសត្វនឹងបានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ ឬក៏ពួកសត្វដទៃណា នឹងបានទូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ សមុទយសច្ច របស់សត្វទាំងនោះ ក្នុងឧប្បាទក្ខណៈនៃតណ្ហា និងរបស់ពួកសត្វដែលចូលកាន់និរោធ ក្នុងកាលដែលចិត្តប្រាសចាកតណ្ហា កំពុងប្រព្រឹត្តទៅ និងរបស់ពួកអសញ្ញសត្វទាំងនោះ មិនរលត់ទៅ តែមគ្គសច្ច របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ សមុទយសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាបុថុជ្ជន នឹងមិនបានទូវមគ្គ ក្នុងឧប្បាទក្ខណៈនៃតណ្ហា និងរបស់ពួកសត្វដែលចូលកាន់និរោធ ក្នុងកាលដែលចិត្តប្រាសចាកតណ្ហា កំពុងប្រព្រឹត្តទៅ និងរបស់អសញ្ញសត្វទាំងនោះ មិនរលត់ទៅផង មគ្គសច្ច នឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វ

ណា នឹងមិនរលត់ទៅ សមុទយសច្ច របស់សត្វនោះ នឹងមិនរលត់ទៅឬ ។ ពួកសត្វណា ជាបុថុជ្ជន នឹងមិនបាននូវមគ្គ មគ្គសច្ច របស់សត្វនោះៗ នឹងមិនរលត់ទៅ ក្នុងភង្គក្ខណៈនៃតណ្ហា តែសមុទយសច្ច របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ មគ្គសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ ក្នុងឧប្បាទក្ខណៈនៃតណ្ហា និងរបស់ពួកសត្វដែលចូលកាន់និរោធ ក្នុងកាលដែលចិត្តប្រាសចាកតណ្ហា កំពុងប្រព្រឹត្តទៅ និងរបស់អសញ្ញសត្វទាំងនោះ នឹងមិនរលត់ទៅផង សមុទយសច្ច មិនរលត់ទៅផង ។

[ ១៧៣ ] ទុក្ខសច្ច មិនរលត់ទៅ ក្នុងទីណា ។បេ។

[ ១៧៤ ] ទុក្ខសច្ច របស់សត្វណា មិនរលត់ទៅ ក្នុងទីណា សមុទយសច្ច របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះឬ ។ ពួកសត្វ កាលចូលទៅកាន់ចតុវោការភព និងបញ្ចវោការភព ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងភង្គក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព ទុក្ខសច្ច របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះ តែសមុទយសច្ច របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ទុក្ខសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាសត្វនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃចិត្ត កាលចូលទៅកាន់អសញ្ញសត្វ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ និងក្នុងភង្គក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព មិនរលត់ទៅផង សមុទយសច្ច នឹង

មិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សមុទយសច្ចរបស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ទុក្ខសច្ច របស់សត្វនោះ មិនរលត់ទៅ ក្នុងទីនោះដែរឬ ។ សមុទយសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាសត្វនឹងបានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងភង្គក្ខណៈនៃចិត្ត កាលច្យុតចាកអសញ្ញសត្វ ក្នុងភង្គក្ខណៈនៃចិត្តនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅ ក្នុងទីនោះទេ សមុទយសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាសត្វនឹងបានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃចិត្ត កាលចូលទៅកាន់អសញ្ញសត្វ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ និងក្នុងភង្គក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព នឹងរលត់ទៅផង ទុក្ខសច្ច មិនរលត់ទៅផង ក្នុងទីនោះ ។

[ ១៧៥ ] ទុក្ខសច្ច របស់សត្វណា មិនរលត់ទៅក្នុងទីណា មគ្គសច្ច របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះឬ ។ ពួកសត្វ នឹងបានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ ក្នុងបញ្ចវោការភព ឬក៏ពួកសត្វដទៃណា នឹងបានទូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ ពួកសត្វនោះ កាលចាប់បដិសន្ធិ ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងភង្គក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព ទុក្ខសច្ច របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះ តែមគ្គសច្ច របស់សត្វទាំងនោះ មិនមែនជានឹងមិន

រលត់ទៅ ក្នុងទីនោះទេ ទុក្ខសច្ច របស់ព្រះអរហន្តទាំងឡាយ និងរបស់សត្វទាំងនោះ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្ត កាលចាប់បដិសន្ធិ និងរបស់ពួកសត្វទាំងនោះ កាលចូលទៅកាន់អបាយ និងអសញ្ញសត្វ ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងភង្គក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព មិនរលត់ទៅផង មគ្គសច្ច នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ទុក្ខសច្ច របស់សត្វនោះ មិនរលត់ទៅ ក្នុងទីនោះឬ ។ មគ្គសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ ក្នុងភង្គក្ខណៈនៃចិត្ត កាលច្យុត និងរបស់ពួកសត្វ កាលច្យុតចាកអបាយ និងអសញ្ញសត្វ ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន នឹងមិនរលត់ទៅ ក្នុងទីនោះ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅ ក្នុងទីនោះទេ មគ្គសច្ច របស់ព្រះអរហន្តទាំងឡាយ និងរបស់សត្វទាំងនោះ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្ត កាលចាប់បដិសន្ធិ និងរបស់ពួកសត្វទាំងនោះ កាលចូលទៅកាន់អបាយ និងអសញ្ញសត្វ ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងភង្គក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព នឹងមិនរលត់ទៅផង ទុក្ខសច្ច មិនរលត់ទៅផង ក្នុងទីនោះ ។

[ ១៧៦ ] សមុទយសច្ច របស់សត្វណា មិនរលត់ទៅ ក្នុងទីណា មគ្គសច្ច របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះឬ ។ ពួកសត្វ នឹងបាន

នូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ ឬក៏ពួកសត្វដទៃណា នឹងបាននូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ សមុទយសច្ច របស់សត្វនោះៗ ក្នុងឧប្បាទក្ខណៈនៃតណ្ហា និងក្នុងកាលដែលចិត្តប្រាសចាកតណ្ហា កំពុងប្រព្រឹត្តទៅ មិនរលត់ទៅ ក្នុងទីនោះ តែមគ្គសច្ច របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ សមុទយសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់ពួកសត្វទាំងនោះដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ ក្នុងឧប្បាទក្ខណៈនៃតណ្ហា និងក្នុងកាលដែលចិត្តប្រាសចាកតណ្ហា កំពុងប្រព្រឹត្តទៅ និងរបស់ពួកអសញ្ញសត្វទាំងនោះ មិនរលត់ទៅផង មគ្គសច្ច នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា សមុទយសច្ច របស់សត្វនោះ មិនរលត់ទៅ ក្នុងទីនោះឬ ។ មគ្គសច្ច របស់ពួកសត្វដែលកើតក្នុងអបាយ និងរបស់សត្វនោះៗ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ ក្នុងភង្គក្ខណៈនៃតណ្ហា នឹងមិនរលត់ទៅ ក្នុងទីនោះ តែសមុទយសច្ច របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅ ក្នុងទីនោះទេ មគ្គសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ ក្នុងឧប្បាទក្ខណៈនៃតណ្ហា និងក្នុងកាលដែលចិត្តប្រាសចាកតណ្ហា កំពុងប្រព្រឹត្តទៅ និងរបស់ពួកអសញ្ញសត្វនោះ នឹងមិនរលត់ទៅផង សមុទយសច្ច មិនរលត់ទៅផង ក្នុងទីនោះ ។

[ ១៧៧ ] ទុក្ខសច្ច របស់សត្វណា រលត់ហើយ សមុទយសច្ច របស់

សត្វនោះ នឹងរលត់ទៅឬ ។ ទុក្ខសច្ច របស់ព្រះអរហន្តទាំងឡាយ ដែលប្រកបដោយមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាសត្វនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា រលត់ហើយ តែសមុទយសច្ច របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ទុក្ខសច្ច របស់ពួកសត្វទាំងនោះក្រៅនេះ រលត់ហើយផង សមុទយសច្ច នឹងរលត់ទៅផង ។ មួយយ៉ាងទៀត សមុទយសច្ច របស់សត្វណា ។បេ។ អើ ។

[ ១៧៨ ] ទុក្ខសច្ច របស់សត្វណា រលត់ហើយ មគ្គសច្ច របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ ទុក្ខសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់ពួកសត្វទាំងនោះ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ រលត់ហើយ តែមគ្គសច្ច របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ពួកសត្វ នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ ឬក៏ពួកសត្វដទៃណា នឹងបាននូវមគ្គ ទុក្ខសច្ចរបស់សត្វទាំងនោះ រលត់ហើយផង មគ្គសច្ច នឹងរលត់ទៅផង ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា ។បេ។ អើ ។

[ ១៧៩ ] សមុទយសច្ច របស់សត្វណា រលត់ហើយ មគ្គសច្ច របស់សត្វនោះ នឹងរលត់ទៅដែរឬ ។ សមុទយសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ រលត់ហើយ តែមគ្គសច្ច របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ពួកសត្វ នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បា-

ទក្ខណៈនៃមគ្គដ៏ប្រសើរ ឬក៏ពួកសត្វដទៃណា នឹងបានទូវមគ្គ សមុទយសច្ច របស់សត្វទាំងនោះ រលត់ហើយផង មគ្គសច្ច នឹងរលត់ទៅផង ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា ។បេ។ អើ ។

[ ១៨០ ] ទុក្ខសច្ច រលត់ហើយ ក្នុងទីណា ។បេ។

[ ១៨១ ] ទុក្ខសច្ច របស់សត្វណា រលត់ហើយ ក្នុងទីណា សមុទយសច្ច របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះឬ ។ ទុក្ខសច្ច របស់ព្រះអរហន្តទាំងឡាយ ដែលប្រកបដោយមគ្គដ៏ប្រសើរ និងរបស់ពួកអសញ្ញសត្វទាំងនោះ ដែលជាសត្វនឹងបានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា រលត់ហើយ ក្នុងទីនោះ តែសមុទយសច្ច របស់សត្វទាំងនោះ នឹងមិនរលត់ទៅក្នុងទីនោះទេ ពួកសត្វក្រៅនេះ ដែលនៅក្នុងចតុវោការភព និងបញ្ចវោការភព ទុក្ខសច្ច របស់សត្វទាំងនោះ រលត់ហើយផង សមុទយសច្ច នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សមុទយសច្ច របស់សត្វណា នឹងរលត់ទៅក្នុងទីណា ទុក្ខសច្ច របស់សត្វនោះ រលត់ហើយ ក្នុងទីនោះឬ ។ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស សមុទយសច្ច របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះទេ ពួកសត្វក្រៅនេះ ដែលនៅក្នុងចតុវោការភព និងបញ្ចវោការភព សមុទយសច្ច របស់សត្វទាំងនោះ នឹងរលត់ទៅផង ទុក្ខសច្ច រលត់ហើយផង ក្នុងទីនោះ ។

[ ១៨២ ] ទុក្ខសច្ច របស់សត្វណា រលត់ហើយក្នុងទីណា មគ្គសច្ច

របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះឬ ។ ទុក្ខសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់ពួកសត្វដែលជាបុថុជ្ជន នឹងមិនបានទូវមគ្គ និងរបស់ពួកសត្វដែលកើតក្នុងអបាយ និងរបស់ពួកអសញ្ញសត្វទាំងនោះ រលត់ហើយ ក្នុងទីនោះ តែមគ្គសច្ច របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ នឹងបានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ ឬក៏ពួកសត្វដទៃណា នឹងបានទូវមគ្គ ទុក្ខសច្ច របស់សត្វទាំងនោះ រលត់ហើយផង មគ្គសច្ច នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា ទុក្ខសច្ច របស់សត្វនោះ រលត់ហើយ ក្នុងទីនោះឬ ។ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស មគ្គសច្ច របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះទេ ពួកសត្វនឹងបានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ ឬក៏ពួកសត្វដទៃណា នឹងបានទូវមគ្គ មគ្គសច្ច របស់សត្វទាំងនោះ នឹងរលត់ទៅផង ទុក្ខសច្ច រលត់ហើយផង ក្នុងទីនោះ ។

[ ១៨៣ ] សមុទយសច្ច របស់សត្វណា រលត់ហើយ ក្នុងទីណា មគ្គសច្ច របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះឬ ។ សមុទយសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់ពួកសត្វ ដែលជាបុថុជ្ជន នឹងមិនបានទូវមគ្គ និងរបស់ពួកសត្វដែលកើតក្នុងអបាយទាំងនោះ រលត់ហើយ ក្នុងទីនោះ តែមគ្គសច្ច របស់សត្វទាំងនោះ នឹងមិនរលត់ទៅ

ក្នុងទីនោះទេ ពួកសត្វ នឹងបានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ ឬក៏ពួកសត្វដទៃណា នឹងបានទូវមគ្គ សមុទយសច្ច របស់សត្វទាំងនោះ រលត់ហើយផង មគ្គសច្ច នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា សមុទយសច្ច របស់សត្វនោះ រលត់ហើយ ក្នុងទីនោះឬ ។ មគ្គសច្ច របស់ពួកសុទ្ធាវាសសត្វទាំងនោះ ក្នុងចិត្តទី ២ កំពុងប្រព្រឹត្តទៅ នឹងរលត់ទៅ ក្នុងទីនោះ តែសមុទយសច្ច របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះទេ ពួកសត្វ នឹងបានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ ឬក៏ពួកសត្វដទៃណា នឹងបានទូវមគ្គ មគ្គសច្ច របស់សត្វទាំងនោះ នឹងរលត់ទៅផង សមុទយសច្ច រលត់ហើយផង ក្នុងទីនោះ ។

[ ១៨៤ ] ទុក្ខសច្ច របស់សត្វណា មិនរលត់ហើយ សមុទយសច្ច របស់សត្វនោះ នឹងមិនរលត់ទៅដែរឬ ។ មិនមានទេ ។ មួយយ៉ាងទៀត សមុទយសច្ច របស់សត្វណា នឹងមិនរលត់ទៅ ទុក្ខសច្ច របស់សត្វនោះ មិនរលត់ហើយឬ ។ រលត់ហើយ ។

[ ១៨៥ ] ទុក្ខសច្ច របស់សត្វណា មិនរលត់ហើយ មគ្គសច្ច របស់សត្វនោះ នឹងមិនរលត់ទៅឬ ។ មិនមានទេ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងមិនរលត់ទៅ ទុក្ខសច្ច របស់សត្វនោះ មិនរលត់ហើយឬ ។ មិនរលត់ហើយ ។

[ ១៨៦ ] សមុទយសច្ច របស់សត្វណា មិនរលត់ហើយ មគ្គសច្ច របស់សត្វនោះ នឹងមិនរលត់ទៅឬ ។ មិនមានទេ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងមិនរលត់ទៅ សមុទយសច្ច របស់សត្វនោះ មិនរលត់ហើយឬ ។ រលត់ហើយ ។

[ ១៨៧ ] ទុក្ខសច្ច មិនរលត់ហើយ ក្នុងទីណា ។បេ។

[ ១៨៨ ] ទុក្ខសច្ច របស់សត្វណា មិនរលត់ហើយ ក្នុងទីណា សមុ-ទយសច្ច របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះដែរឬ ។ នឹងរលត់ទៅ ។ មួយយ៉ាងទៀត សមុទយសច្ច របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ទុក្ខសច្ច របស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះឬ ។ រលត់ហើយ ។

[ ១៨៩ ] ទុក្ខសច្ច របស់សត្វណា មិនរលត់ហើយ ក្នុងទីណា មគ្គសច្ច របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះឬ ។ នឹងរលត់ទៅ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ទុក្ខសច្ច របស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះឬ ។ រលត់ហើយ ។

[ ១៩០ ] សមុទយសច្ច របស់សត្វណា មិនរលត់ហើយ ក្នុងទីណា មគ្គសច្ច របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះឬ ។ សមុទយសច្ច របស់សុទ្ធាវាសសត្វទាំងនោះ ក្នុងចិត្តទី ២ កំពុងប្រព្រឹត្តទៅ មិនរលត់ហើយ ក្នុងទីនោះ តែមគ្គសច្ច របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ សមុទយសច្ច របស់អសញ្ញសត្វទាំងនោះ មិនរលត់ហើយផង មគ្គសច្ច នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មគ្គសច្ច

របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា សមុទយសច្ច របស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះឬ ។ មគ្គសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងកន្ត្កូណៈនៃមគ្គដ៏ប្រសើរ និងរបស់ពួកសត្វដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ និងរបស់ពួកសត្វ ដែលកើតក្នុងអបាយទាំងនោះ នឹងមិនរលត់ទៅក្នុងទីនោះ តែសមុទយសច្ច របស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយ ក្នុងទីនោះទេ មគ្គសច្ច របស់អសញ្ញសត្វទាំងនោះ នឹងមិនរលត់ទៅផង សមុ-ទយសច្ច មិនរលត់ហើយផង ក្នុងទីនោះ ។

និរោធវារៈ ចប់

[ ១៩១ ] ទុក្ខសច្ច របស់សត្វណា កើតឡើង សមុទយសច្ច របស់សត្វនោះ រលត់ទៅឬ ។ មិនរលត់ទេ ។ មួយយ៉ាងទៀត សមុទយសច្ច របស់សត្វណា រលត់ទៅ ទុក្ខសច្ច របស់សត្វនោះ កើតឡើងឬ ។ មិនកើតឡើងទេ ។ ទុក្ខសច្ច របស់សត្វណា កើតឡើង មគ្គសច្ច របស់សត្វនោះ រលត់ទៅឬ ។ មិនរលត់ទេ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា រលត់ទៅ ទុក្ខសច្ច របស់សត្វនោះ កើតឡើងឬ ។ មិនកើតឡើងទេ ។ សមុទយសច្ច របស់សត្វណា កើតឡើង មគ្គសច្ច របស់សត្វនោះ មិនរលត់ទៅឬ ។ មិនរលត់ទេ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា រលត់ទៅ សមុទយសច្ច របស់សត្វនោះ កើតឡើងឬ ។ មិនកើតឡើងទេ ។ ទុក្ខសច្ច កើតឡើងក្នុងទីណា សមុទយសច្ចរលត់ទៅក្នុងទីនោះឬ ។ ទុក្ខសច្ច កើតឡើង ក្នុងអសញ្ញសត្វនោះ តែសមុទយសច្ច មិនរលត់ទៅ ក្នុងទីនោះ

ទេ ។ ពាក្យថា ក្នុងទីណា គឺក្នុងឧប្បាទវារៈក្តី និរោធវារៈក្តី ឧប្បាទនិរោធវារៈក្តី ប្រហែលៗ គ្នា ។ ការធ្វើឲ្យផ្សេងៗ គ្នា មិនមានឡើយ ។ ទុក្ខសច្ច របស់សត្វណា កើតឡើង ក្នុងទីណា សមុទយសច្ច របស់សត្វនោះ រលត់ទៅ ក្នុងទីនោះឬ ។ មិនរលត់ទេ ។ ពាក្យថា របស់សត្វណាក្តី ពាក្យថា របស់សត្វណា ក្នុងទីណាក្តី ប្រហែលៗ គ្នា ។

[ ១៩២ ] ទុក្ខសច្ច របស់សត្វណា មិនកើតឡើង សមុទយសច្ច របស់សត្វនោះ មិនរលត់ទៅឬ ។ ទុក្ខសច្ច របស់សត្វទាំងនោះ មិនកើតឡើង ក្នុងភង្គក្ខណៈនៃតណ្ហា តែសមុទយសច្ច របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វទាំងអស់ កាលច្យុត ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាកតណ្ហា ក្នុងបច្ចុប្បន្ន និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព ទុក្ខសច្ច របស់សត្វទាំងនោះ នឹងមិនកើតឡើងផង សមុទយសច្ច មិនរលត់ទៅផង ។ មួយយ៉ាងទៀត សមុទយសច្ច របស់សត្វណា មិនរលត់ទៅ ទុក្ខសច្ច របស់សត្វនោះ មិនកើតឡើងឬ ។ ពួកសត្វទាំងអស់ កាលចាប់បដិសន្ធិ ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន សមុទយសច្ច របស់សត្វទាំងនោះ មិនរលត់ទៅ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ពួកសត្វទាំងអស់ កាលច្យុត ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាកតណ្ហា ក្នុងបច្ចុប្បន្ន និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព សមុទយសច្ចរបស់សត្វទាំងនោះ មិនរលត់ទៅផង ទុក្ខសច្ច មិនកើតឡើងផង ។

[ ១៩៣ ] ទុក្ខសច្ច របស់សត្វណា មិនកើតឡើង មគ្គសច្ច របស់

សត្វនោះ មិនរលត់ទៅឬ ។ ទុក្ខសច្ច របស់សត្វទាំងនោះ មិនកើតឡើង ក្នុងភង្គក្ខណៈនៃមគ្គ តែមគ្គសច្ច របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ពួកសត្វទាំងអស់ កាលច្យុត ក្នុងភង្គក្ខណៈនៃចិត្តដែលប្រាសចាកមគ្គ ក្នុងបច្ចុប្បន្ន និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព ទុក្ខសច្ច របស់សត្វទាំងនោះ មិនកើតឡើងផង មគ្គសច្ច មិនរលត់ទៅផង ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា មិនរលត់ទៅ ទុក្ខសច្ច របស់សត្វនោះ មិនកើតឡើងឬ ។ ពួកសត្វទាំងអស់ កាលចាប់បដិសន្ធិ ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន មគ្គសច្ច របស់សត្វទាំងនោះ មិនរលត់ទៅ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនមែនមិនកើតឡើងទេ ពួកសត្វទាំងអស់ កាលច្យុត ក្នុងភង្គក្ខណៈនៃចិត្ត ដែលប្រាសចាកមគ្គ ក្នុងបច្ចុប្បន្ន និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព មគ្គសច្ច របស់សត្វទាំងនោះ មិនរលត់ទៅផង ទុក្ខសច្ច មិនកើតឡើងផង ។

[ ១៩៤ ] សមុទយសច្ច របស់សត្វណា មិនកើតឡើង មគ្គសច្ច របស់សត្វនោះ មិនរលត់ទៅឬ ។ សមុទយសច្ច របស់សត្វទាំងនោះ មិនកើតឡើង ក្នុងភង្គក្ខណៈនៃមគ្គ តែមគ្គសច្ច របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ សមុទយសច្ច របស់ពួកសត្វដែលចូលកាន់និរោធ និងរបស់ពួកអសញ្ញសត្វទាំងនោះ មិនកើតឡើងផង មគ្គសច្ច មិនរលត់ទៅផង ក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលប្រាសចាកតណ្ហា និងក្នុងភង្គក្ខណៈនៃចិត្ត ដែលប្រាសចាកមគ្គ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា មិនរលត់ទៅ

សមុទយសច្ច របស់សត្វនោះកើតឡើងឬ ។ មគ្គសច្ច របស់សត្វទាំងនោះ មិនរលត់ទៅក្នុងឧប្បាទក្ខណៈនៃតណ្ហា តែសមុទយសច្ច របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ មគ្គសច្ច របស់ពួកសត្វដែលចូលកាន់និរោធ និង របស់ពួកអសញ្ញសត្វទាំងនោះ មិនរលត់ទៅផង សមុទយសច្ច មិនកើត ឡើងផង ក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលប្រាសចាកតណ្ហា និងក្នុងភង្គក្ខណៈ នៃចិត្ត ដែលប្រាសចាកមគ្គ ។

[ ១៩៥ ] ទុក្ខសច្ច មិនកើតឡើង ក្នុងទីណា ។បេ។

[ ១៩៦ ] ទុក្ខសច្ច របស់សត្វណា មិនកើតឡើង ក្នុងទីណា ។បេ។ ពាក្យថា របស់សត្វណាក្តី ពាក្យថា របស់សត្វណា ក្នុងទីណាក្តី ប្រហែលៗ គ្នា ។ ឯពាក្យថា របស់ពួកសត្វដែលចូលកាន់និរោធ បណ្ឌិតមិនគប្បីធ្វើត្រង់ ពាក្យថា របស់សត្វណា ក្នុងទីណាទេ ។

[ ១៩៧ ] ទុក្ខសច្ច របស់សត្វណា មិនកើតឡើងហើយ សមុទយសច្ច របស់សត្វនោះ រលត់ហើយឬ ។ អើ ។ មួយយ៉ាងទៀត សមុទយសច្ច របស់សត្វណា ។បេ។ អើ ។ បុច្ឆា ជាអតីត ដែលលោកចែកហើយ ក្នុង ឧប្បាទវារៈ យ៉ាងណា អនុលោមក្តី បច្ចនិយៈក្តី លោកគប្បីចែកក្នុង ឧប្បាទនិរោធ ក៏យ៉ាងនោះដែរ ។

[ ១៩៨ ] ទុក្ខសច្ច របស់សត្វណា នឹងកើតឡើង សមុទយសច្ច របស់ សត្វនោះ នឹងរលត់ទៅឬ ។ ទុក្ខសច្ច របស់ព្រះអរហន្តទាំងឡាយ ដែល ប្រកបដោយមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាសត្វនឹងបានទូវ

មគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា នឹងកើតឡើង តែសមុទយសច្ច របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ទុក្ខសច្ច របស់សត្វទាំងនោះ ក្រៅនេះ នឹងកើតឡើងផង សមុទយសច្ច នឹងរលត់ទៅផង ។ មួយយ៉ាងទៀត សមុទយសច្ច របស់សត្វណា ។បេ។ អើ ។

[ ១៩៩ ] ទុក្ខសច្ច របស់សត្វណា នឹងកើតឡើង មគ្គសច្ច របស់សត្វនោះ នឹងរលត់ទៅឬ ។ ទុក្ខសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ នឹងកើតឡើង តែមគ្គសច្ច របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ពួកសត្វនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ ឬក៏ពួកសត្វដទៃណា នឹងបាននូវមគ្គ ទុក្ខសច្ច របស់សត្វទាំងនោះ នឹងកើតឡើងផង មគ្គសច្ច នឹងរលត់ទៅផង ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា ។បេ។ អើ ។

[ ២០០ ] សមុទយសច្ច របស់សត្វណា នឹងកើតឡើង មគ្គសច្ច របស់សត្វនោះ នឹងរលត់ទៅឬ ។ ពួកសត្វណា ជាបុថុជ្ជន នឹងមិនបាននូវមគ្គ សមុទយសច្ច របស់សត្វទាំងនោះ នឹងកើតឡើង តែមគ្គសច្ច របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ពួកសត្វណា នឹងបាននូវមគ្គ សមុទយសច្ច របស់សត្វទាំងនោះ នឹងកើតឡើងផង មគ្គសច្ច នឹងរលត់ទៅផង ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងរលត់ទៅ សមុទយសច្ច របស់សត្វនោះ នឹងកើតឡើងឬ ។ ពួកសត្វនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃ

ចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ មគ្គសច្ច របស់សត្វទាំងនោះ នឹងរលត់ទៅ តែសមុទយសច្ច របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ ពួកសត្វណា នឹងបាននូវមគ្គ មគ្គសច្ច របស់សត្វទាំងនោះ នឹងរលត់ទៅផង សមុទយសច្ច នឹងកើតឡើងផង ។

[ ២០១ ] ទុក្ខសច្ច នឹងកើតឡើង ក្នុងទីណា ។បេ។

[ ២០២ ] ទុក្ខសច្ច របស់សត្វណា នឹងកើតឡើង ក្នុងទីណា សមុទយ-សច្ចរបស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះឬ ។ ទុក្ខសច្ចរបស់ព្រះអរហន្ត ទាំងឡាយ ដែលប្រកបដោយមគ្គដ៏ប្រសើរ និងរបស់អសញ្ញសត្វទាំងនោះ ដែលជាសត្វនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា នឹងកើតឡើងក្នុង ទីនោះ តែសមុទយសច្ច របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វក្រៅនេះ ដែលនៅក្នុងចតុវោការភព និងបញ្ចវោការភព ទុក្ខសច្ច របស់សត្វទាំងនោះ នឹងកើតឡើងផង សមុទយសច្ច នឹងរលត់ទៅផង ក្នុង ទីនោះ ។ ពាក្យថា របស់សត្វណាក្តី ពាក្យថា របស់សត្វណា ក្នុងទីណាក្តី ប្រហែលៗ គ្នា ។

[ ២០៣ ] ទុក្ខសច្ច របស់សត្វណា នឹងកើតឡើង សមុទយសច្ច របស់ សត្វនោះ នឹងមិនរលត់ទៅឬ ។ អើ ។ មួយយ៉ាងទៀត សមុទយសច្ច របស់ សត្វណា នឹងរលត់ទៅ ទុក្ខសច្ច របស់សត្វនោះ នឹងមិនកើតឡើងឬ ។ សមុទយសច្ច របស់ព្រះអរហន្តទាំងឡាយ ដែលប្រកបដោយមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា

នឹងមិនរលត់ទៅ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ ពួកសត្វដែលប្រកបដោយចិត្តជាទីបំផុត សមុទយសច្ច របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ទុក្ខសច្ច នឹងមិនកើតឡើងផង ។

[ ២០៤ ] ទុក្ខសច្ច របស់សត្វណា នឹងមិនកើតឡើង មគ្គសច្ច របស់សត្វនោះ នឹងមិនរលត់ទៅឬ ។ អើ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងមិនរលត់ទៅ ទុក្ខសច្ច របស់សត្វនោះ នឹងមិនកើតឡើងឬ ។ មគ្គសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ នឹងមិនរលត់ទៅ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ ពួកសត្វដែលប្រកបដោយចិត្តជាទីបំផុត មគ្គសច្ច របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ទុក្ខសច្ច នឹងមិនកើតឡើងផង ។

[ ២០៥ ] សមុទយសច្ច របស់សត្វណា នឹងមិនកើតឡើង មគ្គសច្ច របស់សត្វនោះ នឹងមិនរលត់ទៅឬ ។ ពួកសត្វនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ សមុទយសច្ច របស់សត្វទាំងនោះ នឹងមិនកើតឡើង តែមគ្គសច្ច របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ សមុទយសច្ច របស់ព្រះអរហន្តទាំងឡាយ នឹងមិនកើតឡើងផង មគ្គសច្ច នឹងមិនរលត់ទៅផង ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងមិនរលត់ទៅ សមុទយសច្ច របស់សត្វនោះ នឹងមិនកើតឡើងឬ ។ ពួកសត្វណា ជាបុថុជ្ជន នឹងមិនបាននូវមគ្គ

មគ្គសច្ចៈ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ តែសមុទយសច្ចៈ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ មគ្គសច្ចៈ របស់ព្រះអរហន្តទាំងឡាយ នឹងមិនរលត់ទៅផង សមុទយសច្ចៈ នឹងមិនកើតឡើងផង ក្នុងកន្ទក្ខណៈនៃមគ្គដ៏ប្រសើរ ។

[ ២០៦ ] ទុក្ខសច្ចៈ នឹងមិនកើតឡើង ក្នុងទីណា ។បេ។

[ ២០៧ ] ទុក្ខសច្ចៈ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ។ ពាក្យថា របស់សត្វណាក្តី ពាក្យថា របស់សត្វណា ក្នុងទីណាក្តី ប្រហែលៗគ្នា ។បេ។ សមុទយសច្ចៈ មគ្គសច្ចៈ មានការធ្វើផ្សេងៗ គ្នា ។ មគ្គសច្ចៈ របស់ព្រះអរហន្តទាំងឡាយ និងរបស់អសញ្ញសត្វទាំងនោះ នឹងមិនរលត់ទៅផង សមុទយសច្ចៈ នឹងមិនកើតឡើងផង ក្នុងកន្ទក្ខណៈនៃមគ្គដ៏ប្រសើរ ។

[ ២០៨ ] ទុក្ខសច្ចៈ របស់សត្វណា កើតឡើង សមុទយសច្ចៈ របស់សត្វនោះ រលត់ហើយឬ ។ អើ ។ មួយយ៉ាងទៀត របស់សត្វណា ។បេ។ បុច្ឆា ជាអតីត ( លោកចែកហើយ ) ដោយបច្ចុប្បន្ន ពាក្យថា របស់សត្វណាក្តី ពាក្យថា ក្នុងទីណាក្តី ពាក្យថា របស់សត្វណា ក្នុងទីណាក្តី អនុលោមក្តី បច្ចនិយៈក្តី ទាំងអស់នេះ ក្នុងឧប្បាទវារៈ និងឧប្បាទនិរោធវារៈ ប្រហែលៗ គ្នា ។ បណ្ឌិតដែលមិនវង្វេង គប្បីចែកផងចុះ ។

[ ២០៩ ] ទុក្ខសច្ចៈ របស់សត្វណាកើតឡើង សមុទយសច្ចៈ របស់សត្វនោះ នឹងរលត់ទៅឬ ។ ទុក្ខសច្ចៈ របស់ព្រះអរហន្តទាំងឡាយ ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាសត្វនឹងបាននូវមគ្គ

*ដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃចិត្ត កើតឡើង ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ តែសមុទយសច្ច របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ពួកសត្វក្រៅនេះ កាលចាប់បដិសន្ធិ ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន ទុក្ខសច្ច របស់សត្វទាំងនោះ កើតឡើងផង សមុទយសច្ច នឹងរលត់ទៅផង ។ មួយយ៉ាងទៀត សមុទយសច្ច របស់សត្វណា នឹងរលត់ទៅ ទុក្ខសច្ច របស់សត្វនោះ នឹងកើតឡើងឬ ។ ពួកសត្វទាំងអស់ កាលប្រែតក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផលក្នុងអរូបភព សមុទយសច្ច របស់សត្វទាំងនោះ នឹងរលត់ទៅ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វទាំងអស់ កាលចាប់បដិសន្ធិ ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន សមុទយសច្ច របស់សត្វទាំងនោះ នឹងរលត់ទៅផង ទុក្ខសច្ច កើតឡើងផង ។*

*[ ២១០ ] ទុក្ខសច្ច របស់សត្វណា កើតឡើង មគ្គសច្ច របស់សត្វនោះ នឹងរលត់ទៅឬ ។ ទុក្ខសច្ច របស់ព្រះអរហន្តទាំងឡាយ និងពួកសត្វនោះៗ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គក្នុងឧប្បាទក្ខណៈនៃចិត្ត កាលចាប់បដិសន្ធិ ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន កើតឡើង តែមគ្គសច្ច របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ពួកសត្វ នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ ឬក៏ពួកសត្វដទៃណា នឹងបាននូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ ពួកសត្វទាំងនោះ កាលចាប់បដិសន្ធិ ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន ទុក្ខសច្ច របស់សត្វទាំងនោះ*

កើតឡើងផង មគ្គសច្ច នឹងរលត់ទៅផង ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងរលត់ទៅ ទុក្ខសច្ច របស់សត្វនោះ កើតឡើងឬ ។ ពួកសត្វនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ ឬក៏ពួកសត្វដទៃណា នឹងបាននូវមគ្គ ក្នុងភង្គក្ខណៈនៃចិត្តនោះ ពួកសត្វទាំងនោះ កាលច្យុត ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព មគ្គសច្ច របស់សត្វទាំងនោះ នឹងរលត់ទៅ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វ នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ ឬក៏ពួកសត្វដទៃណា នឹងបាននូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ ពួកសត្វទាំងនោះ កាលចាប់បដិសន្ធិ ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន មគ្គសច្ច របស់សត្វទាំងនោះ នឹងរលត់ទៅផង ទុក្ខសច្ច កើតឡើងផង ។

[ ២១១ ] សមុទយសច្ច របស់សត្វណា កើតឡើង មគ្គសច្ច របស់សត្វនោះ នឹងរលត់ទៅឬ ។ ពួកសត្វណា ជាបុថុជ្ជន នឹងមិនបាននូវមគ្គ សមុទយសច្ច របស់សត្វនោះៗ កើតឡើង ក្នុងឧប្បាទក្ខណៈនៃតណ្ហា តែមគ្គសច្ច របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ពួកសត្វណា នឹងបាននូវមគ្គ សមុទយសច្ច របស់សត្វនោះៗ កើតឡើងផង មគ្គសច្ច នឹងរលត់ទៅផង ក្នុងឧប្បាទក្ខណៈនៃតណ្ហា ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងរលត់ទៅ សមុទយសច្ច របស់សត្វនោះ កើតឡើងឬ ។ ពួកសត្វ នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ ឬ

ក៏ពួកសត្វដទៃណា នឹងបានទូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ មគ្គសច្ច របស់សត្វទាំងនោះ ដែលចូលទៅកាន់និរោធ និងរបស់ពួកអសញ្ញសត្វទាំងនោះ នឹងរលត់ទៅ ក្នុងភង្គក្ខណៈនៃតណ្ហា និងក្នុងកាលដែលចិត្តប្រាសចាកតណ្ហា កំពុងប្រព្រឹត្តទៅ តែសមុទយសច្ច របស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វណា នឹងបានទូវមគ្គ មគ្គសច្ច របស់សត្វទាំងនោះ នឹងរលត់ទៅផង សមុទយសច្ច កើតឡើងផង ក្នុងឧប្បាទក្ខណៈនៃតណ្ហា ។

[ ២១២ ] ទុក្ខសច្ច កើតឡើង ក្នុងទីណា ។បេ។

[ ២១៣ ] ទុក្ខសច្ច របស់សត្វណា កើតឡើង ក្នុងទីណា សមុទយ-សច្ច របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះឬ ។ ទុក្ខសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាសត្វនឹងបានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃចិត្ត កាលចូលទៅកាន់អសញ្ញសត្វ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ កើតឡើងក្នុងទីនោះ តែសមុទយសច្ច របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វក្រៅនេះ កាលចូលទៅកាន់ចតុវោការភព និងបញ្ចវោការ-ភព ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន ទុក្ខសច្ច របស់សត្វទាំងនោះ កើតឡើងផង សមុទយសច្ច នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សមុទយសច្ច របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា ទុក្ខសច្ច របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ ពួកសត្វ កាលច្យុតចាកចតុវោការភព និងចាកបញ្ចវោការភព ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងឧប្បាទក្ខណៈ

នៃមគ្គ និងផល ក្នុងអរូបភព សមុទយសច្ច របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ កាលចូលទៅកាន់បតុវោការភព និងបញ្ចវោការភព ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន សមុទយសច្ច របស់សត្វទាំងនោះ នឹងរលត់ទៅផង ទុក្ខសច្ច កើតឡើងផង ក្នុងទីនោះ ។

[ ២១៤ ] ទុក្ខសច្ចរបស់សត្វណា កើតឡើងក្នុងទីណា មគ្គសច្ចរបស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះឬ ។ ទុក្ខសច្ចរបស់ព្រះអរហន្តទាំងឡាយ និងរបស់ពួកសត្វនោះ ដែលជាបុថុជ្ជន នឹងមិនបានទូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្ត កាលចាប់បដិសន្ធិ និងរបស់ពួកសត្វនោះ កាលចូលទៅកាន់អបាយ និងអសញ្ញសត្វ ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន កើតឡើង ក្នុងទីនោះ តែមគ្គសច្ចរបស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វ នឹងបានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ ឬក៏ពួកសត្វដទៃណា នឹងបានទូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ ពួកសត្វទាំងនោះ កាលចាប់បដិសន្ធិ ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន ទុក្ខសច្ចរបស់សត្វទាំងនោះ កើតឡើងផង មគ្គសច្ច នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា ទុក្ខសច្ចរបស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ ពួកសត្វ នឹងបានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ ឬក៏ពួកសត្វដទៃណា នឹងបានទូវមគ្គ ក្នុងភង្គក្ខណៈនៃចិត្តនោះ ពួកសត្វទាំងនោះ កាលច្យុត ក្នុង

*កន្តក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព មគ្គសច្ច របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វ នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ ឬក៏ពួកសត្វដទៃណា នឹងបាននូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ ពួកសត្វទាំងនោះ កាលចាប់បដិសន្ធិ ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន មគ្គសច្ច របស់សត្វទាំងនោះ នឹងរលត់ទៅផង ទុក្ខសច្ច នឹងកើតឡើងផង ក្នុងទីនោះ ។*

*[ ២១៥ ] សមុទយសច្ច របស់សត្វណា កើតឡើង ក្នុងទីណា មគ្គសច្ច របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះឬ ។ សមុទយសច្ច របស់ពួកសត្វដែលកើតក្នុងអបាយ និងរបស់ពួកសត្វនោះៗ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ ក្នុងឧប្បាទក្ខណៈនៃតណ្ហា កើតឡើង ក្នុងទីនោះ តែមគ្គសច្ច របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វណា នឹងបាននូវមគ្គ សមុទយសច្ច របស់សត្វនោះៗ កើតឡើងផង មគ្គសច្ច នឹងរលត់ទៅផង ក្នុងឧប្បាទក្ខណៈនៃតណ្ហា ក្នុងទីនោះ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា សមុទយសច្ច របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ ពួកសត្វ នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ ឬក៏ពួកសត្វដទៃណា នឹងបាននូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ មគ្គសច្ច របស់ពួកសត្វនោះៗ នឹងរលត់ទៅ ក្នុងកន្តក្ខណៈនៃតណ្ហា និងក្នុងកាលដែលចិត្តប្រាសចាកតណ្ហា កំពុងប្រព្រឹត្តទៅ*

ក្នុងទីនោះ តែសមុទយសច្ច របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វណា នឹងបាននូវមគ្គ មគ្គសច្ច របស់ពួកសត្វនោះៗ នឹងរលត់ទៅផង សមុទយសច្ច កើតឡើងផង ក្នុងឧប្បាទក្ខណៈនៃតណ្ហា ។

[ ២១៦ ] ទុក្ខសច្ច របស់សត្វណា មិនកើតឡើង សមុទយសច្ច របស់សត្វនោះ នឹងមិនរលត់ទៅឬ ។ ពួកសត្វទាំងអស់ កាលច្យុត ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព ទុក្ខសច្ច របស់សត្វទាំងនោះ មិនកើតឡើង តែសមុទយសច្ច របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ ទុក្ខសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាសត្វនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងភង្គក្ខណៈនៃចិត្ត មិនកើតឡើងផង សមុទយសច្ច នឹងមិនរលត់ទៅផង ក្នុងភង្គក្ខណៈនៃចិត្តនោះ និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផលក្នុងអរូបភព ។ មួយយ៉ាងទៀត សមុទយសច្ចរបស់សត្វណា នឹងមិនរលត់ទៅ ទុក្ខសច្ចរបស់សត្វនោះ មិនកើតឡើងឬ ។ សមុទយសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាសត្វនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃចិត្ត នឹងមិនរលត់ទៅ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ សមុទយសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាសត្វនឹងបាននូវមគ្គដ៏ប្រសើរ ក្នុង

លំដាប់នៃចិត្តណា ក្នុងភង្គក្ខណៈនៃចិត្ត នឹងមិនរលត់ទៅផង ទុក្ខសច្ច មិនកើតឡើងផង ក្នុងភង្គក្ខណៈនៃចិត្តនោះ និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព ។

[ ២១៧ ] ទុក្ខសច្ច របស់សត្វណា មិនកើតឡើង មគ្គសច្ច របស់សត្វនោះ នឹងមិនរលត់ទៅឬ ។ ពួកសត្វ នឹងបានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងភង្គក្ខណៈនៃមគ្គ ឬក៏ពួកសត្វដទៃណា នឹងបានទូវមគ្គក្នុងភង្គក្ខណៈនៃចិត្តនោះ ពួកសត្វទាំងនោះ កាលច្យុត ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព ទុក្ខសច្ច របស់សត្វទាំងនោះ មិនកើតឡើង តែមគ្គសច្ច របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ ទុក្ខសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់ពួកសត្វនោះៗ ដែលជាបុថុជ្ជន នឹងមិនបានទូវមគ្គ ក្នុងភង្គក្ខណៈនៃចិត្ត កាលច្យុត មិនកើតឡើងផង មគ្គសច្ច នឹងមិនរលត់ទៅផង ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងមិនរលត់ទៅ ទុក្ខសច្ច របស់សត្វនោះ មិនកើតឡើងឬ ។ មគ្គសច្ច របស់ព្រះអរហន្តទាំងឡាយ និងរបស់ពួកសត្វនោះៗ ដែលជាបុថុជ្ជន នឹងមិនបានទូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្ត កាលចាប់បដិសន្ធិ ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន នឹងមិនរលត់ទៅ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ មគ្គសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់ពួកសត្វនោះៗ

ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ ក្នុងភង្គក្ខណៈនៃចិត្ត កាលច្យុត ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព នឹងមិនរលត់ទៅផង ទុក្ខសច្ច មិនកើតឡើងផង ។

[ ២១៨ ] សមុទយសច្ច របស់សត្វណា មិនកើតឡើង មគ្គសច្ច របស់សត្វនោះ នឹងមិនរលត់ទៅឬ ។ ពួកសត្វ នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ ឬក៏ពួកសត្វដទៃណា នឹងបាននូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ សមុទយសច្ច របស់សត្វទាំងនោះ និងរបស់ពួកសត្វដែលចូលទៅកាន់និរោធ និងរបស់ពួកអសញ្ញសត្វទាំងនោះ មិនកើតឡើង ក្នុងភង្គក្ខណៈនៃតណ្ហា និងក្នុងកាលដែលចិត្តប្រាសចាកតណ្ហាកំពុងប្រព្រឹត្តទៅ តែមគ្គសច្ច របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ សមុទយសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ និងរបស់ពួកសត្វដែលចូលទៅកាន់និរោធ និងរបស់ពួកអសញ្ញសត្វទាំងនោះ មិនកើតឡើងផង មគ្គសច្ច នឹងមិនរលត់ទៅផង ក្នុងភង្គក្ខណៈនៃតណ្ហា និងក្នុងកាលដែលចិត្តប្រាសចាកតណ្ហា កំពុងប្រព្រឹត្តទៅ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងមិនរលត់ទៅ សមុទយសច្ច របស់សត្វនោះ មិនកើតឡើងឬ ។ ពួកសត្វណា ជាបុថុជ្ជន នឹងមិនបាននូវមគ្គ មគ្គសច្ចរបស់សត្វនោះៗ នឹងមិនរលត់ទៅ ក្នុងឧប្បាទក្ខណៈនៃតណ្ហា តែសមុទយសច្ច របស់

សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ មគ្គសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាបុថុជ្ជននឹងមិនបាននូវមគ្គ និងរបស់ពួកសត្វដែលចូលកាន់និរោធ និងរបស់ពួកអសញ្ញសត្វទាំងនោះ នឹងមិនរលត់ទៅផង សមុទយសច្ច មិនកើតឡើងផង ក្នុងភង្គក្ខណៈនៃតណ្ហា និងក្នុងកាល ដែលចិត្តប្រាសចាកតណ្ហា កំពុងប្រព្រឹត្តទៅ ។

[ ២១៩ ] ទុក្ខសច្ច មិនកើតឡើង ក្នុងទីណា ។បេ។

[ ២២០ ] ទុក្ខសច្ច របស់សត្វណា មិនកើតឡើង ក្នុងទីណា សមុទយសច្ច របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះឬ ។ ពួកសត្វ កាលច្យុតចាកចតុវោការភព និងបញ្ចវោការភព ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព ទុក្ខសច្ច របស់សត្វទាំងនោះ មិនកើតឡើង តែសមុទយសច្ច របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ទុក្ខសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាសត្វនឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងភង្គក្ខណៈនៃចិត្ត កាលច្យុតចាកអសញ្ញសត្វ ក្នុងភង្គក្ខណៈនៃចិត្តនោះ និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព មិនកើតឡើងផង សមុទយសច្ច នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត សមុទយសច្ច របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ទុក្ខសច្ច របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ សមុទយសច្ច របស់ព្រះ

អរហន្តទាំងឡាយ ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាសត្វនឹងបានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃចិត្ត កាលចូលទៅកាន់អសញ្ញសត្វ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ នឹងមិនរលត់ទៅ ក្នុងទីនោះ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ សមុទយសច្ចរបស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាសត្វនឹងបានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងភង្គក្ខណៈនៃចិត្ត កាលច្យុតចាកអសញ្ញសត្វ ក្នុងភង្គក្ខណៈនៃចិត្តនោះ និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព នឹងមិនរលត់ទៅផង ទុក្ខសច្ច មិនកើតឡើងផង ក្នុងទីនោះ ។

[ ២២១ ] ទុក្ខសច្ច របស់សត្វណា មិនកើតឡើង ក្នុងទីណា មគ្គសច្ច របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះឬ ។ ពួកសត្វ នឹងបានទូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងភង្គក្ខណៈនៃមគ្គ ឬក៏ពួកសត្វដទៃណា នឹងបានទូវមគ្គ ក្នុងភង្គក្ខណៈនៃចិត្តនោះ ពួកសត្វទាំងនោះ កាលច្យុតក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព ទុក្ខសច្ច របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះ តែមគ្គសច្ច របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ទុក្ខសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់ពួកសត្វនោះ ដែលជាបុថុជ្ជន នឹងមិនបានទូវមគ្គក្នុងភង្គក្ខណៈនៃចិត្ត កាលច្យុត និងរបស់ពួកសត្វនោះ កាលច្យុតចាកអបាយ និងចាកអសញ្ញសត្វ មិនកើតឡើងផង

មគ្គសច្ច នឹងមិនរលត់ទៅផង ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព ក្នុងទីនោះ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ទុក្ខសច្ច របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ មគ្គសច្ច របស់ព្រះអរហន្តទាំងឡាយ និងរបស់ពួកសត្វនោះ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្ត កាលចាប់បដិសន្ធិ និងរបស់ពួកសត្វនោះ កាលចូលទៅកាន់អបាយ និងកាន់អសញ្ញសត្វ នឹងមិនរលត់ទៅ ក្នុងឧប្បាទក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន ក្នុងទីនោះ តែទុក្ខសច្ច របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ មគ្គសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់ពួកសត្វនោះ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ កាលច្យុត និងរបស់ពួកសត្វនោះ កាលច្យុតចាកអបាយ និងចាកអសញ្ញសត្វ នឹងមិនរលត់ទៅផង ទុក្ខសច្ចមិនកើតឡើងផង ក្នុងភង្គក្ខណៈនៃចិត្ត ក្នុងបច្ចុប្បន្ន និងក្នុងឧប្បាទក្ខណៈនៃមគ្គ និងផល ក្នុងអរូបភព ក្នុងទីនោះ ។

[ ២២ ] សមុទយសច្ច របស់សត្វណា មិនកើតឡើង ក្នុងទីណា មគ្គសច្ច របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះឬ ។ ពួកសត្វ នឹងបាននូវមគ្គដ៏ប្រសើរ ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃមគ្គដ៏ប្រសើរ ឬក៏ពួកសត្វដទៃណា នឹងបាននូវមគ្គ ក្នុងឧប្បាទក្ខណៈនៃចិត្តនោះ សមុទយ-សច្ច របស់សត្វនោះៗ មិនកើតឡើង ក្នុងភង្គក្ខណៈនៃតណ្ហា និងក្នុងកាលដែលចិត្តប្រាសចាកតណ្ហា កំពុងប្រព្រឹត្តទៅក្នុងទីនោះ តែមគ្គសច្ចរបស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ សមុទយសច្ច របស់ព្រះ

អរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ និងរបស់អសញ្ញសត្វទាំងនោះ មិនកើតឡើងផង មគ្គសច្ច នឹងមិនរលត់ទៅផង ក្នុងភង្គក្ខណៈនៃតណ្ហា និងក្នុងកាលដែលចិត្តប្រាសចាកតណ្ហា កំពុងប្រព្រឹត្តទៅ ក្នុងទីនោះ ។ មួយយ៉ាងទៀត មគ្គសច្ច របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា សមុទយសច្ច របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ មគ្គសច្ច របស់ពួកសត្វដែលកើតក្នុងអបាយ និងរបស់សត្វទាំងនោះ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ នឹងមិនរលត់ទៅ ក្នុងឧប្បាទក្ខណៈនៃតណ្ហា ក្នុងទីនោះ តែសមុទយសច្ច របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ មគ្គសច្ច របស់ព្រះអរហន្តទាំងឡាយ ក្នុងភង្គក្ខណៈនៃមគ្គដ៏ប្រសើរ និងរបស់សត្វទាំងនោះ ដែលជាបុថុជ្ជន នឹងមិនបាននូវមគ្គ និងរបស់អសញ្ញសត្វទាំងនោះ នឹងមិនរលត់ទៅផង សមុទយសច្ច មិនកើតឡើងផង ក្នុងភង្គក្ខណៈនៃតណ្ហា និងក្នុងកាលដែលចិត្តប្រាសចាកតណ្ហា កំពុងប្រព្រឹត្តទៅ ក្នុងទីនោះ ។

[ ២២៣ ] ទុក្ខសច្ច របស់សត្វណា កើតឡើងហើយ សមុទយសច្ច របស់សត្វនោះ នឹងរលត់ទៅឬ ។ បុច្ឆា ជាអតីត និងអនាគត ជាអនុលោមក្តី ជាបច្ចនិយៈក្តី ដែលលោកចែកហើយ ក្នុងនិរោធវារៈ យ៉ាងណា បណ្ឌិតដែលមិនវង្វេង គប្បីចែកក្នុងឧប្បាទនិរោធវារៈ យ៉ាងនោះដែរ ។

ឧប្បាទនិរោធវារៈ ចប់

បវត្តិវារៈ ចប់

# បរិញ្ញាវារៈ

[ ២២៤ ] សត្វណា កំណត់ដឹងនូវទុក្ខសច្ច សត្វនោះ លះបង់នូវសមុទយសច្ចឬ ។ អើ ។ មួយយ៉ាងទៀត សត្វណា លះបង់នូវសមុទយសច្ច សត្វនោះ កំណត់ដឹងនូវទុក្ខសច្ចឬ ។ អើ ។ សត្វណា មិនកំណាន់ដឹងនូវទុក្ខសច្ច សត្វនោះ មិនលះបង់នូវសមុទយសច្ចឬ ។ អើ ។ មួយយ៉ាងទៀត សត្វណា មិនលះបង់នូវសមុទយសច្ច សត្វនោះ មិនកំណត់ដឹងនូវទុក្ខសច្ចឬ ។ អើ ។

[ ២២៥ ] សត្វណា កំណត់ដឹងហើយ នូវទុក្ខសច្ច សត្វនោះ លះបង់ហើយនូវសមុទយសច្ចឬ ។ អើ ។ មួយយ៉ាងទៀត សត្វណា លះបង់ហើយនូវសមុទយសច្ច សត្វនោះ កំណត់ដឹងហើយ នូវទុក្ខសច្ចឬ ។ អើ ។ សត្វណា មិនកំណាន់ដឹងហើយ នូវទុក្ខសច្ច សត្វនោះ មិនលះបង់ហើយ នូវសមុទយសច្ចឬ ។ អើ ។ មួយយ៉ាងទៀត សត្វណា មិនលះបង់ហើយ នូវសមុទយសច្ច សត្វនោះ មិនកំណត់ដឹងហើយ នូវទុក្ខសច្ចឬ ។ អើ ។

[ ២២៦ ] សត្វណា នឹងកំណត់ដឹង នូវទុក្ខសច្ច សត្វនោះ នឹងលះបង់នូវសមុទយសច្ចឬ ។ អើ ។ មួយយ៉ាងទៀត សត្វណា នឹងលះបង់នូវសមុទយសច្ច សត្វនោះ នឹងកំណត់ដឹង នូវទុក្ខសច្ចឬ ។ អើ ។ សត្វណា នឹងមិនកំណាន់ដឹង នូវទុក្ខសច្ច សត្វនោះ នឹងមិនលះបង់ នូវសមុទយសច្ចឬ ។ អើ ។ មួយយ៉ាងទៀត សត្វណា នឹងមិនលះបង់ នូវសមុទយសច្ច សត្វនោះ នឹងមិនកំណត់ដឹង នូវទុក្ខសច្ចឬ ។ អើ ។

[ ២២៧ ] សត្វណា កំណត់ដឹងនូវទុក្ខសច្ច សត្វនោះ លះបង់ហើយ

នូវសមុទយសច្ចឬ ។ មិនមែនទេ ។ មួយយ៉ាងទៀត សត្វណា លះបង់ហើយ នូវសមុទយសច្ច សត្វនោះ កំណត់ដឹងនូវទុក្ខសច្ចឬ ។ មិនមែនទេ ។ សត្វណា មិនកំណត់ដឹងនូវទុក្ខសច្ច សត្វនោះ មិនលះបង់ហើយ នូវសមុទយសច្ចឬ ។ ព្រះអរហន្ត មិនកំណត់ដឹងនូវទុក្ខសច្ច តែមិនមែនជាមិនលះបង់ហើយ នូវសមុទយសច្ចទេ ពួកបុគ្គលដ៏សេស លើកលែងតែបុគ្គលដែលប្រកបដោយមគ្គដ៏ប្រសើរ និងព្រះអរហន្តចេញ មិនកំណត់ដឹងនូវទុក្ខសច្ចផង មិនលះបង់ហើយ នូវសមុទយសច្ចផង ។ មួយយ៉ាងទៀត សត្វណា មិនលះបង់ហើយ នូវសមុទយសច្ច សត្វនោះ មិនកំណត់ដឹងនូវទុក្ខសច្ចឬ ។ បុគ្គលដែលប្រកបដោយមគ្គដ៏ប្រសើរ មិនលះបង់ហើយ នូវសមុទយសច្ច តែមិនមែនជាមិនកំណត់ដឹងនូវទុក្ខសច្ចទេ ពួកបុគ្គលដ៏សេស លើកលែងតែបុគ្គលដែលប្រកបដោយមគ្គដ៏ប្រសើរ និងព្រះអរហន្តចេញ មិនលះបង់ហើយ នូវសមុទយសច្ចផង មិនកំណត់ដឹង នូវទុក្ខសច្ចផង ។

[ ២២៨ ] សត្វណា កំណត់ដឹងនូវទុក្ខសច្ច សត្វនោះ នឹងលះបង់នូវសមុទយសច្ចឬ ។ មិនមែនទេ ។ មួយយ៉ាងទៀត សត្វណា នឹងលះបង់នូវសមុទយសច្ច សត្វនោះ កំណត់ដឹងនូវទុក្ខសច្ចឬ ។ មិនមែនទេ ។ សត្វណា មិនកំណត់ដឹងនូវទុក្ខសច្ច សត្វនោះ នឹងមិនលះបង់នូវសមុទយសច្ចឬ ។ ពួកសត្វណា នឹងបាននូវមគ្គ ពួកសត្វនោះ មិនកំណត់ដឹងនូវទុក្ខសច្ច តែមិនមែន

ជានឹងមិនលះបង់នូវសមុទយសច្ចទេ ព្រះអរហន្ត និងពួកបុថុជ្ជនណា នឹងមិនបាននូវមគ្គ ព្រះអរហន្ត និងពួកបុថុជ្ជននោះ មិនកំណត់ដឹងនូវទុក្ខសច្ចផង នឹងមិនលះបង់នូវសមុទយសច្ចផង ។ មួយយ៉ាងទៀត សត្វណា នឹងមិនលះបង់នូវសមុទយសច្ច សត្វនោះ មិនកំណត់ដឹងនូវទុក្ខសច្ចឬ ។ បុគ្គលប្រកបដោយមគ្គដ៏ប្រសើរ នឹងមិនលះបង់នូវសមុទយសច្ច តែមិនមែនជាមិនកំណត់ដឹងនូវសមុទយសច្ចទេ ព្រះអរហន្ត និងពួកបុថុជ្ជនណា នឹងមិនបាននូវមគ្គ ព្រះអរហន្ត និងពួកបុថុជ្ជននោះ នឹងមិនលះបង់នូវសមុទយសច្ចផង មិនកំណត់ដឹង នូវទុក្ខសច្ចផង ។

[ ២២៩ ] សត្វណា កំណត់ដឹងហើយ នូវទុក្ខសច្ច សត្វនោះ នឹងលះបង់នូវសមុទយសច្ចឬ ។ មិនមែនទេ ។ មួយយ៉ាងទៀត សត្វណា នឹងលះបង់នូវសមុទយសច្ច សត្វនោះ កំណត់ដឹងហើយ នូវទុក្ខសច្ចឬ ។ មិនមែនទេ ។ សត្វណា មិនកំណត់ដឹងហើយ នូវទុក្ខសច្ច សត្វនោះ នឹងមិនលះបង់នូវសមុទយសច្ចឬ ។ ពួកសត្វណា នឹងបាននូវមគ្គ ពួកសត្វនោះ មិនកំណត់ដឹងហើយ នូវទុក្ខសច្ច តែមិនមែនជានឹងមិនលះបង់នូវសមុទយ-សច្ចទេ បុគ្គលដែលប្រកបដោយមគ្គដ៏ប្រសើរ និងពួកបុថុជ្ជនណា នឹងមិនបាននូវមគ្គ បុគ្គលប្រកបដោយមគ្គដ៏ប្រសើរ និងពួកបុថុជ្ជននោះ មិនកំណត់

ដឹងហើយ នូវទុក្ខសច្ចផង នឹងមិនលះបង់នូវសមុទយសច្ចផង ។ មួយយ៉ាង ទៀត សត្វណា នឹងមិនលះបង់នូវសមុទយសច្ច សត្វនោះ ឈ្មោះថា មិនកំណត់ដឹងហើយនូវទុក្ខសច្ចឬ ។ ព្រះអរហន្ត នឹងមិនលះបង់នូវសមុទយសច្ច តែមិនមែនជាមិនកំណត់ដឹងហើយនូវទុក្ខសច្ចទេ ពួកបុគ្គលប្រកបដោយមគ្គដ៏ប្រសើរ និងពួកបុថុជ្ជនណា នឹងមិនបាននូវមគ្គ ពួកបុគ្គលប្រកបដោយមគ្គដ៏ប្រសើរ និងពួកបុថុជ្ជននោះ នឹងមិនលះបង់ នូវសមុទយសច្ចផង មិនកំណត់ដឹងហើយ នូវទុក្ខសច្ចផង ។

បរិញ្ញាវារៈ ចប់

សច្ចយមកៈ ចប់

# អដ្ឋកថា

# សច្ចយមកៈ

## បណ្ណត្តិវារៈ

[ ២៤-២២៩ ] កិច្ចពណ៌នាសច្ចយមកៈ ដែលលោកបានរួបរួមសម្តែងហើយ ក្នុងលំដាប់ធាតុយមកៈ ដោយអំណាចសច្ចៈ ក្នុងធម៌ មានកុសលជាដើម ដែលលោកសម្តែងហើយ ក្នុងមូលយមកៈទាំងនោះឯង រមែងមានក្នុងឥឡូវនេះ ។ គប្បីជ្រាបមហាវារៈ ៣ មានបណ្ណត្តិវារៈជាដើម និងប្រភេទនៃវារៈដ៏សេស មានអន្តរវារៈជាដើម តាមន័យដែលពោលហើយនោះឯងខាងដើម ក្នុងធាតុយមកៈនោះ ។ តែក្នុងបណ្ណត្តិវារៈ ក្នុងសច្ចយមកៈនេះ ដោយអំណាចសច្ចៈ ៤ គប្បីជ្រាបការរាប់យមកៈ ក្នុងវារៈទាំងឡាយ ៤ គឺបទសោធនវារៈ ១ បទសោធនមូលចក្កវារៈ ១ សុទ្ធសច្ចវារៈ ១ សុទ្ធ-សច្ចមូលចក្កវារៈ ១ ។ តែក្នុងបណ្ណត្តិវារនិទ្ទេស គប្បីជ្រាបតេភូមិកធម៌ដែលរួចផុតល្អហើយ ចាកទុក្ខវេទនា និងតណ្ហា ដោយពាក្យថា **អរិយសច្ចំ ទុក្ខសច្ចំ** ។ បទថា **អរិយសោ សមុទយោ** បានដល់ ប្រភេទនៃកាមាវចរ-កុសលជាដើម ដែលលោកបានសម្តែងហើយ ក្នុងសច្ចវិភង្គ រមែងជាបច្ច័យនៃទុក្ខសច្ច ។ បទថា **អរិយសោ និរោធោ** បានដល់ តទង្គនិរោធ វិក្ខម្ភន-និរោធ សមុច្ឆេទនិរោធ បដិបស្សទ្ធិនិរោធ និងខណភង្គនិរោធ ។ បទថា **អរិយសោ មគ្គោ** សេចក្តីថា មគ្គមានអង្គ ៥ រមែងមានក្នុងសម័យនោះ

ឯង ។ មគ្គ មានជាដើមយ៉ាងនេះ គឺអដ្ឋង្គិកមគ្គ មិច្ឆាមគ្គ ជង្ឃមគ្គ សកដមគ្គ ។

**បណ្ណត្តិវារៈ ចប់**

# បវត្តិវារៈ

ក្នុងបវត្តិវារៈ ក្នុងអនុលោមន័យរបស់បុគ្គលវារៈ ក្នុងបច្ចុប្បន្នកាលនេះ ទុក្ខសច្ចមូល ៣ សមុទយសច្ចមូល ២ និរោធសច្ចមូល ១ រួមជាយមកៈ ៦ ដោយអំណាចព្រះបាលី ព្រោះកាន់យកសច្ចៈដែលបាន និងមិនបានថា ទុក្ខសច្ច របស់សត្វណា កើតឡើង សមុទយសច្ច របស់សត្វនោះ រមែងកើតឡើងឬ មួយទៀត សមុទយសច្ចរបស់សត្វណា កើតឡើងទុក្ខសច្ចរបស់សត្វនោះ រមែងកើតឡើងឬ ដូច្នេះ ។ ក្នុងសច្ចៈទាំងឡាយនោះ ព្រោះការកើត និងការរលត់ រមែងមិនសមគួរដល់និរោធ ព្រោះហេតុនោះ យមកៈទាំង ៣ គឺយមកៈដែលជាមូលនៃទុក្ខសច្ច ២ មួយអន្ទើដោយសមុទយសច្ច និងមគ្គសច្ច យមកៈដែលជាមូលនៃសមុទយសច្ច ១ មួយអន្ទើដោយមគ្គសច្ច ទើបមកហើយ ។ ក្នុងបដិលោមន័យរបស់បុគ្គលវារៈនោះក្តី ក្នុងឱកាសវារៈជាដើមក្តី ក៏ន័យនេះឯង ។ គប្បីជ្រាបការរាប់យមកៈដោយអំណាចយមកៈ ៣ យ៉ាង ក្នុងវារៈទាំងអស់នេះ ដោយប្រការដូច្នេះ ។

ក្នុងអត្ថវិនិច្ឆ័យ គប្បីជ្រាបលក្ខណៈក្នុងសច្ចយមកៈនេះដូចតទៅ

ក្នុងបវត្តិភាវៈនៃសច្ចយមកៈនេះ បុគ្គលណាមួយ រមែងមិនបាននិរោធសច្ចមុននោះឯង តែក្នុងភាវៈដ៏សេសទាំង ៣ សមុទយសច្ច និងមគ្គសច្ច បុគ្គលរមែងបានក្នុងបវត្តិកាល ដោយចំណែកមួយនោះឯង ។ ទុក្ខសច្ច បុគ្គលរមែងបានក្នុងចុតិ និងបដិសន្ធិខ្ចះ ក្នុងបវត្តិកាលខ្ចះ ។ តែកាល ៣ មានបច្ចុប្បន្នកាលជាដើម បុគ្គលរមែងបានក្នុងចុតិ និងបដិសន្ធិខ្ចះ ក្នុងបវត្តិកាលខ្ចះ ។ បុគ្គលរមែងបានសច្ចៈណាមួយ ក្នុងសច្ចយមកៈនេះ គប្បីជ្រាបអត្ថវិនិច្ឆ័យដោយអំណាចនៃសច្ចៈនោះៗ ដោយប្រការដូច្នេះ ។

គប្បីជ្រាបនយមុខ ក្នុងសច្ចយមកៈនោះដូចតទៅ

បទថា **សព្វេសំ ឧបបជ្ជន្តានំ** សេចក្តីថា ដោយហោចសូម្បីជាន់សុទ្ធាវាស ។ ទេវតាជាន់សុទ្ធាវាសទាំងនោះ រមែងកើតដោយទុក្ខសច្ចនោះឯង ។ បទនេះថា **តណ្ហាវិប្បយុត្តចិត្តស្ស** លោកបានពោលហើយ ដើម្បីសម្តែងការកើតឡើងនៃចំណែកមួយក្នុងទុក្ខសច្ច និងសមុទយសច្ច ព្រោះហេតុនោះ ពាក្យនោះ គប្បីកាន់យកដោយអំណាចបញ្ចវោការភពនោះឯង តែក្នុងចតុវោការភព ពាក្យនេះថា សូម្បីសច្ចៈ ១ រមែងមិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃផលសមាបត្តិចិត្ត ដែលវិប្បយុត្តដោយតណ្ហា ដូច្នេះ បណ្ឌិតមិនគួរកាន់យកក្នុងសច្ចយមកៈនេះ ។ បទថា **តេសំ ទុក្ខសច្ចញ្ច** សេចក្តីថា ឈ្មោះថា ទុក្ខសច្ចដ៏សេស វៀរតណ្ហាចេញ រមែងមានក្នុងខណៈនោះ ពាក្យនោះ លោកពោលសំដៅយកទុក្ខសច្ចនោះ ។ ក្នុងឧប្បាទក្ខណៈនៃមគ្គ ក៏មានន័យនេះដូចគ្នា ។ តែក្នុងសច្ចយមកៈនោះ រូបនោះឯង ឈ្មោះថា ទុក្ខ-

សច្ចធម៌ទាំងឡាយ ដែលសម្បយុត្តដោយមគ្គដ៏សេស ជាធម៌ដែលផុតល្អ ហើយចាកសច្ចៈ ព្រោះហេតុនោះឯង ទើបលោកពោលហើយថា មគ្គសច្ច រមែងកើតឡើងដល់ជនទាំងនោះ ក្នុងឧប្បាទក្ខណៈនៃមគ្គ ក្នុងអរូប តែទុក្ខសច្ច រមែងមិនកើតឡើងដល់ជនទាំងនោះ ។ គប្បីជ្រាបឱកាសដោយអំណាចខណៈ ក្នុងសច្ចយមកៈនេះ យ៉ាងនេះថា ក្នុងខណៈនៃការកើតឡើងនោះ និងក្នុងខណៈនៃការកើតឡើងរបស់ចិត្ត ដែលវិប្បយុត្តដោយតណ្ហារបស់ជនទាំងនោះថា ក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលវិប្បយុត្តដោយតណ្ហា ដែលប្រព្រឹត្តទៅរបស់បុគ្គល ដែលកើតឡើងទាំងអស់ ក្នុងឧប្បាទក្ខណៈរបស់បុគ្គលដែលកើតឡើងទាំងអស់នោះ ។ ក្នុងសច្ចៈដែលមានសភាពយ៉ាងនោះ សូម្បីពួកដទៃ ក៏មានន័យនេះដូចគ្នា ។ បទថា **អនភិសមេតាវីនំ** បានដល់ សត្វដែលមិនសម្រេចអភិសម័យ ពោល គឺចតុសច្ចបដិវេធ គឺការត្រាស់ដឹងសច្ចៈ ៤ ។ បទថា **អភិសមេតាវីនំ** បានដល់ អភិសមិតសច្ច គឺសច្ចៈដែលខ្លួនត្រាស់ដឹង ។ គប្បីជ្រាបអត្ថវិនិច្ឆ័យក្នុងបទទាំងពួង ដោយនយមុខនេះ ។

**បវត្តិវារៈ ចប់**

## បរិញ្ញាវារៈ

*ក្នុងបរិញ្ញាវារៈ បុគ្គលរមែងបានបរិញ្ញា ៣ គឺ* **ញាតបរិញ្ញា ១ តីរណបរិញ្ញា ១ បហានបរិញ្ញា ១ ។** *ឈ្មោះថា* **បរិញ្ញា** *រមែងមិនមានក្នុងលោកុត្តរធម៌ទាំងឡាយ ព្រោះហេតុនោះ ទើបសច្ចៈ ២ លោកកាន់យកហើយ ក្នុងសច្ចយមកៈនេះ ។ បទថា* **ទុក្ខសច្ចំ បរិជានាតិ** *ក្នុងសច្ចយមកៈនោះ លោកពោលហើយ ដោយអំណាចញាតបរិញ្ញា និងតីរណបរិញ្ញានោះឯង ។ បទថា* **សមុទយសច្ចំ បជហាតិ** *លោកពោលហើយ ដោយអំណាចញាតបរិញ្ញា និងបហានបរិញ្ញា ។ គប្បីជ្រាបអត្ថក្នុងបទទាំងពួង ដោយអំណាចនៃបរិញ្ញាទាំងឡាយនេះ ដោយប្រការដូច្នេះឯង ។l៚*

### អដ្ឋកថាសច្ចយមកៈ ចប់

# អភិធម្មបិដក

# សង្ខារយមកៈ

## បណ្ណត្តិវារៈ

[ ២៣០ ] សង្ខារ ៣ យ៉ាង គឺកាយសង្ខារ ១ វចីសង្ខារ ១ ចិត្តសង្ខារ ១ ។ ពួកអស្សាសបស្សាសៈ ឈ្មោះថា កាយសង្ខារ ពួកវិតក្កវិចារ ឈ្មោះថា វចីសង្ខារ សញ្ញា និងវេទនា ឈ្មោះថា ចិត្តសង្ខារ ពួកធម៌ទាំងអស់ ដែលសម្បយុត្តដោយចិត្ត វៀរលែងតែពួកវិតក្ក និងវិចារចេញ ឈ្មោះថា ចិត្តសង្ខារដែរ ។

## ឧទ្ទេសវារៈ

[ ២៣១ ] កាយ ហៅថា កាយសង្ខារ កាយសង្ខារ ហៅថា កាយ ។ វចី ហៅថា វចីសង្ខារ វចីសង្ខារ ហៅថា វចី ។ ចិត្ត ហៅថា ចិត្តសង្ខារ ចិត្តសង្ខារ ហៅថា ចិត្ត ។

[ ២៣២ ] មិនមែនកាយ មិនហៅថា កាយសង្ខារ មិនមែនកាយសង្ខារ មិនហៅថា កាយ ។ មិនមែនវចី មិនហៅថា វចីសង្ខារ មិនមែនវចីសង្ខារ មិនហៅថា វចី ។ មិនមែនចិត្ត មិនហៅថា ចិត្តសង្ខារ មិនមែនចិត្តសង្ខារ មិនហៅថា ចិត្ត ។

[ ២៣៣ ] កាយ ហៅថា កាយសង្ខារ សង្ខារទាំងឡាយ ហៅថា វចីសង្ខារ ។ កាយ ហៅថា កាយសង្ខារ សង្ខារទាំងឡាយ ហៅថា ចិត្ត-

សង្ខារ ។ វចី ហៅថា វចីសង្ខារ សង្ខារទាំងឡាយ ហៅថា កាយសង្ខារ ។ វចី ហោថា វចីសង្ខារ សង្ខារទាំងឡាយ ហៅថា ចិត្តសង្ខារ ។ ចិត្ត ហៅថា ចិត្តសង្ខារ សង្ខារទាំងឡាយ ហៅថា កាយសង្ខារ ។ ចិត្ត ហៅថា ចិត្តសង្ខារ សង្ខារទាំងឡាយ ហៅថា វចីសង្ខារ ។

[ ២៣៤ ] មិនមែនកាយ មិនហៅថា កាយសង្ខារ មិនមែនសង្ខារទាំងឡាយ មិនហៅថា វចីសង្ខារ ។ មិនមែនកាយ មិនហៅថា កាយសង្ខារ មិនមែនសង្ខារទាំងឡាយ មិនហៅថា ចិត្តសង្ខារ ។ មិនមែនវចី មិនហៅថា វចីសង្ខារ មិនមែនសង្ខារទាំងឡាយ មិនហៅថា កាយសង្ខារ ។ មិនមែនវចី មិនហៅថា វចីសង្ខារ មិនមែនសង្ខារទាំងឡាយ មិនហៅថា ចិត្តសង្ខារ ។ មិនមែនចិត្ត មិនហៅថា ចិត្តសង្ខារ មិនមែនសង្ខារទាំងឡាយ មិនហៅថា កាយសង្ខារ ។ មិនមែនចិត្ត មិនហៅថា ចិត្តសង្ខារ មិនមែនសង្ខារទាំងឡាយ មិនហៅថា វចីសង្ខារ ។

[ ២៣៥ ] កាយសង្ខារ ហៅថា វចីសង្ខារ វចីសង្ខារ ហៅថា កាយសង្ខារ ។ កាយសង្ខារ ហៅថា ចិត្តសង្ខារ ចិត្តសង្ខារ ហៅថា កាយសង្ខារ ។ វចីសង្ខារ ហៅថា ចិត្តសង្ខារ ចិត្តសង្ខារ ហៅថា វចីសង្ខារ ។

[ ២៣៦ ] មិនមែនកាយសង្ខារ មិនហៅថា វចីសង្ខារ មិនមែនវចីសង្ខារ មិនហៅថា កាយសង្ខារ ។ មិនមែនកាយសង្ខារ មិនហៅថា ចិត្តសង្ខារ មិនមែនចិត្តសង្ខារ មិនហៅថា កាយសង្ខារ ។ មិនមែនវចីសង្ខារ មិនហៅថា ចិត្តសង្ខារ មិនមែនចិត្តសង្ខារ មិនហៅថា វចីសង្ខារ ។

ឧទ្ទេសវារៈ ចប់

# និទ្ទេសវារៈ

[ ២៣៧ ] កាយ ហៅថា កាយសង្ខារឬ ។ មិនមែនទេ ។ កាយសង្ខារ ហៅថា កាយឬ ។ មិនមែនទេ ។ វចី ហៅថា វចីសង្ខារឬ ។ មិនមែនទេ ។ វចីសង្ខារ ហៅថា វចីឬ ។ មិនមែនទេ ។ ចិត្ត ហៅថា ចិត្តសង្ខារឬ ។ មិនមែនទេ ។ ចិត្តសង្ខារ ហៅថា ចិត្តឬ ។ មិនមែនទេ ។

[ ២៣៨ ] មិនមែនកាយ មិនហៅថា កាយសង្ខារឬ ។ កាយសង្ខារ មិនហៅថា កាយទេ ហៅថា កាយសង្ខារ ឯពួកធម៌ដ៏សេស វៀរលែងតែកាយ និងកាយសង្ខារចេញ មិនហៅថា កាយផង មិនហៅថា កាយសង្ខារផង ។ មិនមែនកាយសង្ខារ មិនហៅថា កាយឬ ។ កាយ មិនហៅថា កាយសង្ខារទេ ហៅថា កាយ ឯពួកធម៌ដ៏សេស វៀរលែងតែកាយ និងកាយសង្ខារចេញ មិនហៅថា កាយផង មិនហៅថា កាយសង្ខារផង ។ មិនមែនកាយសង្ខារ មិនហៅថា កាយឬ ។ កាយ មិនហៅថា កាយសង្ខារទេ ហៅថា កាយ ឯពួកធម៌ដ៏សេស វៀរលែងតែកាយ និងកាយសង្ខារចេញ មិនហៅថា កាយផង មិនហៅថា កាយសង្ខារផង ។ មិនមែនវចី មិនហៅថា វចីសង្ខារឬ ។ វចីសង្ខារ មិនហៅថា វចីទេ ហៅថា វចីសង្ខារ ឯពួកធម៌ដ៏សេស វៀរលែងតែវចី និងវចីសង្ខារចេញ មិនហៅថា វចីផង មិនហៅថា វចីសង្ខារផង ។ មិនមែនវចីសង្ខារ មិនហៅថា វចីឬ ។ វចី មិនហៅថា វចីសង្ខារទេ ហៅថា វចី ឯពួកធម៌ដ៏សេស វៀរលែងតែវចី និងវចីសង្ខារចេញ មិនហៅថា វចីផង មិនហៅថា វចីសង្ខារផង ។ មិនមែនចិត្ត មិនហៅថា ចិត្តសង្ខារឬ ។ ចិត្តសង្ខារ មិនហៅថា ចិត្តទេ ហៅថា

ចិត្តសង្ខារ ឯពួកធម៌ដ៏សេស វៀរលែងតែចិត្ត និងចិត្តសង្ខារចេញ មិនហៅថា ចិត្តផង មិនហៅថា ចិត្តសង្ខារផង ។ មិនមែនចិត្តសង្ខារ មិនហៅថា ចិត្តឬ ។ ចិត្ត មិនហៅថា ចិត្តសង្ខារទេ ហៅថា ចិត្ត ឯពួកធម៌ដ៏សេស វៀរលែងតែចិត្ត និងចិត្តសង្ខារចេញ មិនហៅថា ចិត្តផង មិនហៅថា ចិត្ត-សង្ខារផង ។

[ ២៣៩ ] កាយ ហៅថា កាយសង្ខារឬ ។ មិនមែនទេ ។ សង្ខារទាំងឡាយ ហៅថា វចីសង្ខារឬ ។ វចីសង្ខារ ហៅថា សង្ខារផង ហៅថា វចីសង្ខារផង ឯពួកសង្ខារដ៏សេស ហៅថា សង្ខារទាំងឡាយ មិនហៅថា វចីសង្ខារទេ ។ កាយ ហៅថា កាយសង្ខារឬ ។ មិនមែនទេ ។ សង្ខារទាំងឡាយ ហៅថា ចិត្តសង្ខារឬ ។ ចិត្តសង្ខារ ហៅថា សង្ខារផង ហៅថា ចិត្តសង្ខារផង ឯពួកសង្ខារដ៏សេស ហៅថា សង្ខារទាំងឡាយ មិនហៅថា ចិត្តសង្ខារទេ ។ វចី ហៅថា វចីសង្ខារឬ ។ មិនមែនទេ ។ សង្ខារទាំងឡាយ ហៅថា កាយសង្ខារឬ ។ កាយសង្ខារ ហៅថា សង្ខារផង ហៅថា កាយ-សង្ខារផង ឯពួកសង្ខារដ៏សេស ហៅថា សង្ខារទាំងឡាយ មិនហៅថា កាយសង្ខារទេ ។ វចី ហៅថា វចីសង្ខារឬ ។ មិនមែនទេ ។ សង្ខារទាំងឡាយ ហៅថា ចិត្តសង្ខារឬ ។ ចិត្តសង្ខារ ហៅថា សង្ខារផង ហៅថា ចិត្តសង្ខារផង ឯពួកសង្ខារដ៏សេស ហៅថា សង្ខារទាំងឡាយ មិនហៅថា ចិត្តសង្ខារទេ ។ ចិត្ត ហៅថា ចិត្តសង្ខារឬ ។ មិនមែនទេ ។ សង្ខារទាំងឡាយ ហៅថា កាយសង្ខារឬ ។ កាយសង្ខារ ហៅថា សង្ខារផង ហៅថា

កាយសង្ខារផង ឯពួកសង្ខារដ៏សេស ហៅថា សង្ខារទាំងឡាយ មិនហៅថា កាយសង្ខារទេ ។ ចិត្ត ហៅថា ចិត្តសង្ខារឬ ។ មិនមែនទេ ។ សង្ខារទាំងឡាយ ហៅថា វចីសង្ខារឬ ។ វចីសង្ខារ ហៅថា សង្ខារផង ហៅថា វចីសង្ខារផង ឯពួកសង្ខារដ៏សេស ហៅថា សង្ខារទាំងឡាយ មិនមែនហៅថា វចីសង្ខារទេ ។

[ ២៤០ ] មិនមែនកាយ មិនហៅថា កាយសង្ខារឬ ។ កាយសង្ខារ មិនហៅថា កាយទេ ហៅថា កាយសង្ខារ ឯពួកធម៌ដ៏សេស វៀរលែងតែកាយ និងកាយសង្ខារចេញ មិនហៅថា កាយផង មិនហៅថា កាយសង្ខារផង ។ មិនមែនសង្ខារទាំងឡាយ មិនហៅថា វចីសង្ខារឬ ។ អើ ។ មិនមែនកាយ មិនហៅថា កាយសង្ខារឬ ។ កាយសង្ខារ មិនហៅថា កាយទេ ហៅថា កាយសង្ខារ ឯពួកធម៌ដ៏សេស វៀរលែងតែកាយ និងកាយសង្ខារចេញ មិនហៅថា កាយផង មិនហៅថា កាយសង្ខារផង ។ មិនមែនសង្ខារទាំងឡាយ មិនហៅថា ចិត្តសង្ខារឬ ។ អើ ។ មិនមែនវចី មិនហៅថា វចីសង្ខារឬ ។ វចីសង្ខារ មិនហៅថា វចីទេ ហៅថា វចីសង្ខារ ឯពួកធម៌ដ៏សេស លើកលែងតែវចី និងវចីសង្ខារចេញ មិនហៅថា វចីផង មិនហៅថា វចីសង្ខារផង ។ មិនមែនសង្ខារទាំងឡាយ មិនហៅថា កាយសង្ខារឬ ។ អើ ។ មិនមែនវចី មិនហៅថា វចីសង្ខារឬ ។ វចីសង្ខារ មិនហៅថា វចីទេ ហៅថា វចីសង្ខារ ឯពួកធម៌ដ៏សេស លើកលែងតែវចី និងវចីសង្ខារចេញ មិនហៅថា វចីផង មិនហៅថា វចីសង្ខារផង ។ មិនមែនសង្ខារទាំងឡាយ

មិនហៅថា ចិត្តសង្ខារឬ ។ អើ ។ មិនមែនចិត្ត មិនហៅថា ចិត្តសង្ខារឬ ។ ចិត្តសង្ខារ មិនហៅថា ចិត្តទេ ហៅថា ចិត្តសង្ខារ ឯពួកធម៌ដ៏សេស លើកលែងតែចិត្ត និងចិត្តសង្ខារចេញ មិនហៅថា ចិត្តផង មិនហៅថា ចិត្តសង្ខារផង ។ មិនមែនសង្ខារទាំងឡាយ មិនហៅថា កាយសង្ខារឬ ។ អើ ។ មិនមែនចិត្ត មិនហៅថា ចិត្តសង្ខារឬ ។ ចិត្តសង្ខារ មិនហៅថា ចិត្តទេ ហៅថា ចិត្តសង្ខារ ឯពួកធម៌ដ៏សេស លើកលែងតែចិត្ត និងចិត្តសង្ខារចេញ មិនហៅថា ចិត្តផង មិនហៅថា ចិត្តសង្ខារផង ។ មិនមែនសង្ខារទាំងឡាយ មិនហៅថា វចីសង្ខារឬ ។ អើ ។

[ ២៤១ ] កាយសង្ខារ ហៅថា វចីសង្ខារឬ ។ មិនមែនទេ ។ វចី-សង្ខារ ហៅថា កាយសង្ខារឬ ។ មិនមែនទេ ។ កាយសង្ខារ ហៅថា ចិត្ត-សង្ខារឬ ។ មិនមែនទេ ។ ចិត្តសង្ខារ ហៅថា កាយសង្ខារឬ ។ មិនមែនទេ ។ វចីសង្ខារ ហៅថា ចិត្តសង្ខារឬ ។ មិនមែនទេ ។ ចិត្តសង្ខារ ហៅថា វចី-សង្ខារឬ ។ មិនមែនទេ ។

[ ២៤២ ] មិនមែនកាយសង្ខារ មិនហៅថា វចីសង្ខារឬ ។ វចីសង្ខារ មិនហៅថា កាយសង្ខារទេ ហៅថា វចីសង្ខារ ឯពួកធម៌ដ៏សេស វៀរលែងតែកាយសង្ខារ និងវចីសង្ខារចេញ មិនហៅថា កាយសង្ខារផង មិនហៅថា វចីសង្ខារផង ។ មិនមែនវចីសង្ខារ មិនហៅថា កាយសង្ខារឬ ។ កាយ-សង្ខារ មិនហៅថា វចីសង្ខារទេ ហៅថា កាយសង្ខារ ឯពួកធម៌ដ៏សេស វៀរលែងតែវចីសង្ខារ និងកាយសង្ខារចេញ មិនហៅថា វចីសង្ខារផង មិន

ហៅថា កាយសង្ខារផង ។ មិនមែនកាយសង្ខារ មិនហៅថា ចិត្តសង្ខារឬ ។ ចិត្តសង្ខារ មិនហៅថា កាយសង្ខារទេ ហៅថា ចិត្តសង្ខារ ឯពួកធម៌ដ៏សេស វៀរលែងតែកាយសង្ខារ និងចិត្តសង្ខារចេញ មិនហៅថា កាយសង្ខារផង មិនហៅថា ចិត្តសង្ខារផង ។ មិនមែនចិត្តសង្ខារ មិនហៅថា កាយសង្ខារឬ ។ កាយសង្ខារ មិនហៅថា ចិត្តសង្ខារទេ ហៅថា កាយសង្ខារ ឯពួកធម៌ដ៏សេស វៀរលែងតែចិត្តសង្ខារ និងកាយសង្ខារចេញ មិនហៅថា ចិត្តសង្ខារផង មិនហៅថា កាយសង្ខារផង ។ មិនមែនវចីសង្ខារ មិនហៅថា ចិត្តសង្ខារឬ ។ ចិត្តសង្ខារ មិនហៅថា វចីសង្ខារទេ ហៅថា ចិត្តសង្ខារ ឯពួកធម៌ដ៏សេស វៀរលែងតែវចីសង្ខារ និងចិត្តសង្ខារចេញ មិនហៅថា វចីសង្ខារផង មិនហៅថា ចិត្តសង្ខារផង ។ មិនមែនចិត្តសង្ខារ មិនហៅថា វចីសង្ខារឬ ។ វចីសង្ខារ មិនហៅថា ចិត្តសង្ខារទេ ហៅថា វចីសង្ខារ ឯពួកធម៌ដ៏សេស វៀរលែងតែចិត្តសង្ខារ និងវចីសង្ខារចេញ មិនហៅថា ចិត្តសង្ខារផង មិនហៅថា វចីសង្ខារផង ។

បណ្ណត្តិវារៈ ចប់

# បវត្តិវារៈ

[ ២៤៣ ] កាយសង្ខាររបស់សត្វណា កើតឡើង វចីសង្ខាររបស់សត្វនោះ កើតឡើងឬ ។ កាយសង្ខាររបស់សត្វទាំងនោះ កើតឡើង ក្នុងឧប្បា-

ទុក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ ព្រោះវៀរចាកពួកវិតក្កៈ និងវិចារ តែវចីសង្ខាររបស់សត្វទាំងនោះ មិនកើតឡើងទេ ពួកកាមាវចរសត្វ ដែលចូលកាន់បឋមជ្ឈាន កាយសង្ខាររបស់សត្វទាំងនោះ កើតឡើងផង វចីសង្ខារកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ ។ មួយយ៉ាងទៀត វចីសង្ខាររបស់សត្វណា កើតឡើង កាយសង្ខាររបស់សត្វនោះ កើតឡើងឬ ។ វចីសង្ខាររបស់សត្វទាំងនោះ កើតឡើង ក្នុងឧប្បាទក្ខណៈនៃពួកវិតក្កៈ និងវិចារ ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ តែកាយ-សង្ខាររបស់សត្វទាំងនោះ មិនកើតឡើងទេ ពួកសត្វជាកាមាវចរ ដែលចូលកាន់បឋមជ្ឈាន វចីសង្ខាររបស់សត្វទាំងនោះ កើតឡើងផង កាយសង្ខារកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ ។

[ ២៨៤ ] កាយសង្ខាររបស់សត្វណា កើតឡើង ចិត្តសង្ខាររបស់សត្វនោះ កើតឡើងឬ ។ អើ ។ មួយយ៉ាងទៀត ចិត្តសង្ខាររបស់សត្វណា កើតឡើង កាយសង្ខាររបស់សត្វនោះ កើតឡើងឬ ។ ចិត្តសង្ខាររបស់សត្វទាំងនោះ កើតឡើង ក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ តែកាយសង្ខាររបស់សត្វទាំងនោះ មិនកើតឡើងទេ ចិត្តសង្ខាររបស់សត្វទាំងនោះ កើតឡើងផង កាយសង្ខារកើតឡើងផង ក្នុងឧប្បា-ទក្ខណៈ នៃពួកអស្សាសៈ និងបស្សាសៈ ។

[ ២៨៥ ] វចីសង្ខាររបស់សត្វណា កើតឡើង ចិត្តសង្ខាររបស់សត្វនោះ កើតឡើងឬ ។ អើ ។ មួយយ៉ាងទៀត ចិត្តសង្ខាររបស់សត្វណា កើត

ឡើង វចីសង្ខាររបស់សត្វនោះ កើតឡើងឬ ។ ចិត្តសង្ខាររបស់សត្វទាំងនោះ កើតឡើង ក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកវិតក្កៈ និងវិចារ តែវចីសង្ខាររបស់សត្វទាំងនោះ មិនកើតឡើងទេ ចិត្តសង្ខាររបស់សត្វទាំងនោះ កើតឡើងផង វចីសង្ខារកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃពួកវិតក្កៈ និងវិចារ ។

[ ២៤៦ ] កាយសង្ខារ កើតឡើងក្នុងទីណា វចីសង្ខារ កើតឡើងក្នុងទីនោះឬ ។ កាយសង្ខារ កើតឡើងក្នុងទុតិយជ្ឈាន និងក្នុងតតិយជ្ឈាននោះ តែវចីសង្ខារ មិនកើតឡើងក្នុងឈាននោះទេ កាយសង្ខារ កើតឡើងផង វចី-សង្ខារ កើតឡើងផង ក្នុងបឋមជ្ឈាន និងក្នុងកាមាវចរនោះ ។ មួយយ៉ាងទៀត វចីសង្ខារកើតឡើងក្នុងទីណា កាយសង្ខារកើតឡើងក្នុងទីនោះឬ ។ វចី-សង្ខារកើតឡើងក្នុងរូបាវចរ និងក្នុងអរូបាវចរនោះ តែកាយសង្ខារ មិនកើតឡើងក្នុងរូបាវចរ និងក្នុងអរូបាវចរនោះទេ វចីសង្ខារ កើតឡើងផង កាយ-សង្ខារ កើតឡើងផង ក្នុងបឋមជ្ឈាន និងក្នុងកាមាវចរនោះ ។

[ ២៤៧ ] កាយសង្ខារ កើតឡើងក្នុងទីណា ចិត្តសង្ខារកើតឡើងក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត ចិត្តសង្ខារ កើតឡើងក្នុងទីណា កាយ-សង្ខារ កើតឡើងក្នុងទីនោះឬ ។ ចិត្តសង្ខារ កើតឡើងក្នុងចតុត្ថជ្ឈាន ក្នុងរូបាវចរ និងក្នុងអរូបាវចរនោះ តែកាយសង្ខារ មិនកើតឡើងក្នុងទីនោះទេ ចិត្តសង្ខារ កើតឡើងផង កាយសង្ខារ កើតឡើងផង ក្នុងបឋមជ្ឈាន ក្នុងទុតិយជ្ឈាន ក្នុងតតិយជ្ឈាន និងក្នុងកាមាវចរនោះ ។

[ ២៤៨ ] វចីសង្ខារ កើតឡើងក្នុងទីណា ចិត្តសង្ខារ កើតឡើងក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត ចិត្តសង្ខារ កើតឡើងក្នុងទីណា វចីសង្ខារ កើតឡើងក្នុងទីនោះឬ ។ ចិត្តសង្ខារ កើតឡើង ក្នុងទុតិយជ្ឈាន ក្នុងតតិយជ្ឈាន និងក្នុងចតុត្ថជ្ឈាននោះ តែវចីសង្ខារ មិនកើតឡើងក្នុងទីនោះទេ ចិត្តសង្ខារ កើតឡើងផង វចីសង្ខារ កើតឡើងផង ក្នុងបឋមជ្ឈាន ក្នុងកាមាវចរ ក្នុងរូបាវចរ និងក្នុងអរូបាវចរនោះ ។

[ ២៤៩ ] កាយសង្ខាររបស់សត្វណា កើតឡើងក្នុងទីណា ។បេ។ ពាក្យថា របស់សត្វណាក្តី ថារបស់សត្វណា ក្នុងទីណាក្តី ដូចៗ គ្នា ។

[ ២៥០ ] កាយសង្ខាររបស់សត្វណា មិនកើតឡើង វចីសង្ខាររបស់សត្វនោះ មិនកើតឡើងឬ ។ កាយសង្ខាររបស់សត្វទាំងនោះ មិនកើតឡើង ក្នុងឧប្បាទក្ខណៈ នៃពួកវិតក្ក និងវិចារ ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ តែវចីសង្ខាររបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ កាយសង្ខាររបស់សត្វទាំងអស់ ក្នុងភង្គក្ខណៈនៃចិត្ត និងរបស់ពួកសត្វដែលចូលកាន់និរោធ ក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលមិនមានវិតក្ក មិនមានវិចារ ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ និងរបស់អសញ្ញសត្វទាំងនោះ មិនកើតឡើងផង វចីសង្ខារ មិនកើតឡើងផង ។ មួយយ៉ាងទៀត វចីសង្ខាររបស់សត្វណា មិនកើតឡើង កាយសង្ខាររបស់សត្វនោះ មិនកើតឡើងឬ ។ វចីសង្ខាររបស់សត្វទាំងនោះ មិនកើតឡើង ក្នុងឧប្បាទក្ខណៈ នៃពួកអស្សាសៈ និងបស្សាសៈ ព្រោះវៀរចាកពួកវិតក្ក និងវិចារ តែកាយសង្ខារ

របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ វចីសង្ខាររបស់សត្វទាំងអស់ ក្នុងភង្គក្ខណៈនៃចិត្ត និងរបស់ពួកសត្វដែលចូលកាន់និរោធ ក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលមិនមានវិតក្ក មិនមានវិចារ ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ និងរបស់អសញ្ញសត្វទាំងនោះ មិនកើតឡើងផង កាយសង្ខារមិនកើតឡើងផង ។

[ ២៥១ ] កាយសង្ខាររបស់សត្វណា មិនកើតឡើង ចិត្តសង្ខាររបស់សត្វនោះ មិនកើតឡើងឬ ។ កាយសង្ខាររបស់សត្វទាំងនោះ មិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ តែចិត្ត-សង្ខាររបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ កាយសង្ខាររបស់សត្វទាំងអស់ ដែលចូលកាន់និរោធ ក្នុងភង្គក្ខណៈនៃចិត្ត និងរបស់អសញ្ញសត្វទាំងនោះ មិនកើតឡើងផង ចិត្តសង្ខារ មិនកើតឡើងផង ។ មួយយ៉ាងទៀត ចិត្តសង្ខាររបស់សត្វណា មិនកើតឡើង កាយសង្ខាររបស់សត្វនោះ មិនកើតឡើងឬ ។ អើ ។

[ ២៥២ ] វចីសង្ខាររបស់សត្វណា មិនកើតឡើង ចិត្តសង្ខាររបស់សត្វនោះ មិនកើតឡើងឬ ។ វចីសង្ខាររបស់សត្វទាំងនោះ មិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកវិតក្ក និងវិចារ តែចិត្តសង្ខាររបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ វចីសង្ខាររបស់សត្វទាំងអស់ដែលចូលកាន់និរោធ ក្នុងភង្គក្ខណៈនៃចិត្ត និងរបស់អសញ្ញសត្វទាំងនោះ មិនកើតឡើងផង ចិត្តសង្ខារ មិនកើតឡើងផង ។ មួយយ៉ាងទៀត ចិត្តសង្ខាររបស់

សត្វណា មិនកើតឡើង វចីសង្ខាររបស់សត្វនោះ មិនកើតឡើងឬ ។ អើ ។

[ ២៥៣ ] កាយសង្ខារ មិនកើតឡើងក្នុងទីណា វចីសង្ខារ មិនកើតឡើងក្នុងទីនោះឬ ។ កាយសង្ខារ មិនកើតឡើងក្នុងរូបាវចរ និងក្នុងអរូបាវចរនោះ តែវចីសង្ខារ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ កាយសង្ខារ មិនកើតឡើងផង វចីសង្ខារ មិនកើតឡើងផង ក្នុងចតុត្ថជ្ឈាន និងក្នុងអសញ្ញសត្វនោះ ។ មួយយ៉ាងទៀត វចីសង្ខារ មិនកើតឡើង ក្នុងទីណា កាយសង្ខារ មិនកើតឡើង ក្នុងទីនោះឬ ។ វចីសង្ខារ មិនកើតឡើង ក្នុងទុតិយជ្ឈាន និងក្នុងតតិយជ្ឈាននោះ តែកាយសង្ខារ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ វចីសង្ខារ មិនកើតឡើងផង កាយសង្ខារ មិនកើតឡើងផង ក្នុងចតុត្ថជ្ឈាន និងក្នុងអសញ្ញសត្វនោះ ។

[ ២៥៤ ] កាយសង្ខារ មិនកើតឡើងក្នុងទីណា ចិត្តសង្ខារ មិនកើតឡើងក្នុងទីនោះឬ ។ កាយសង្ខារ មិនកើតឡើងក្នុងចតុត្ថជ្ឈាន ក្នុងរូបាវចរ និងក្នុងអរូបាវចរនោះ តែចិត្តសង្ខារ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ កាយសង្ខារ មិនកើតឡើងផង ចិត្តសង្ខារមិនកើតឡើងផង ក្នុងអសញ្ញសត្វនោះ ។ មួយយ៉ាងទៀត ចិត្តសង្ខារ មិនកើតឡើងក្នុងទីណា កាយសង្ខារមិនកើតឡើង ក្នុងទីនោះឬ ។ អើ ។

[ ២៥៥ ] វចីសង្ខារ មិនកើតឡើង ក្នុងទីណា ចិត្តសង្ខារ មិនកើតឡើង ក្នុងទីនោះឬ ។ វចីសង្ខារ មិនកើតឡើងក្នុងទុតិយជ្ឈាន ក្នុងតតិយជ្ឈាន និងក្នុងចតុត្ថជ្ឈាននោះ តែចិត្តសង្ខារ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ

វចីសង្ខារ មិនកើតឡើងផង ចិត្តសង្ខារ មិនកើតឡើងផង ក្នុងអសញ្ញសត្វនោះ ។ មួយយ៉ាងទៀត ចិត្តសង្ខារ មិនកើតឡើង ក្នុងទីណា វចីសង្ខារ មិនកើតឡើង ក្នុងទីនោះឬ ។ អើ ។

[ ២៥៦ ] កាយសង្ខារ របស់សត្វណា មិនកើតឡើង ក្នុងទីណា វចីសង្ខារ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ កាយសង្ខារ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃពួកវិតក្កៈ និងវិចារ ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ ក្នុងទីនោះ តែវចីសង្ខាររបស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ កាយសង្ខារ របស់អសញ្ញសត្វទាំងអស់នោះ មិនកើតឡើងផង វចីសង្ខារ មិនកើតឡើងផង ក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ដែលមិនមានវិតក្កៈ មិនមានវិចារ ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ ក្នុងទីនោះ ។ មួយយ៉ាងទៀត វចីសង្ខាររបស់សត្វណា ។បេ។ ពាក្យថា របស់សត្វណាក្តី ពាក្យថា របស់សត្វណា ក្នុងទីណាក្តី បណ្ឌិតគប្បីឲ្យពិស្តារដូចៗ គ្នាចុះ ។ ពាក្យថា របស់ពួកសត្វដែលចូលកាន់និរោធ បណ្ឌិតមិនបាន ( មិនគួរពោល ) ក្នុងបទថា របស់សត្វណា ក្នុងទីណាឡើយ ។

[ ២៥៧ ] កាយសង្ខារ របស់សត្វណា កើតឡើងហើយ វចីសង្ខារ របស់សត្វនោះ កើតឡើងហើយឬ ។ អើ ។ មួយយ៉ាងទៀត វចីសង្ខាររបស់សត្វណា ( កើតឡើងហើយ ) ។បេ។ អើ ។ កាយសង្ខារ របស់សត្វណា កើតឡើងហើយ ចិត្តសង្ខារ របស់សត្វនោះ កើតឡើងហើយឬ ។ អើ ។

មួយយ៉ាងទៀត ចិត្តសង្ខាររបស់សត្វណា ( កើតឡើងហើយ ) ។បេ។ អើ ។ វចីសង្ខារ របស់សត្វណា កើតឡើយហើយ ចិត្តសង្ខារ របស់សត្វនោះ កើតឡើងហើយឬ ។ អើ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា ( កើតឡើងហើយ ) ។បេ។ អើ ។

[ ២៥៨ ] កាយសង្ខារ កើតឡើងហើយ ក្នុងទីណា ។បេ។ ពាក្យថា ក្នុងទីណា ដូចគ្នាតែបែបមួយ ក្នុងទីទាំងពួង ។

[ ២៥៩ ] កាយសង្ខារ របស់សត្វណា កើតឡើងហើយ ក្នុងទីណា វចីសង្ខារ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះឬ ។ ពួកសត្វដែលចូលកាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន កាយសង្ខារ របស់សត្វទាំងនោះ កើតឡើងហើយ ក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសត្វជាកាមាវចរ ដែលចូលកាន់បឋមជ្ឈាន កាយ-សង្ខារ របស់សត្វទាំងនោះ កើតឡើងហើយផង វចីសង្ខារ កើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា កើតឡើងហើយ ក្នុងទីណា កាយសង្ខារ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះឬ ។ វចីសង្ខារ របស់ពួកសត្វជារូបាវចរ និងជាអរូបាវចរទាំងនោះ កើតឡើងហើយ ក្នុងទីនោះ តែកាយសង្ខារ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសត្វជាកាមាវចរ ដែលចូលកាន់បឋមជ្ឈាន វចីសង្ខារ របស់សត្វទាំងនោះ កើតឡើងហើយផង កាយសង្ខារ កើតឡើងហើយផង ក្នុងទីនោះ ។

[ ២៦០ ] កាយសង្ខារ របស់សត្វណា កើតឡើងហើយ ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា កើតឡើងហើយ ក្នុងទីណា កាយ-សង្ខារ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះដែរឬ ។ ពួកសត្វជារូបាវចរ ដែលចូលកាន់ចតុត្ថជ្ឈាន និងពួកសត្វជាអរូបាវចរ ចិត្តសង្ខាររបស់សត្វទាំងនោះ កើតឡើងហើយក្នុងទីនោះ តែកាយសង្ខាររបស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសត្វជាកាមាវចរ ដែលចូលកាន់បឋមជ្ឈាន កាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន ចិត្តសង្ខារ របស់សត្វទាំងនោះ កើតឡើងហើយផង កាយសង្ខារ កើតឡើងហើយផង ក្នុងទីនោះ ។

[ ២៦១ ] វចីសង្ខារ របស់សត្វណា កើតឡើងហើយ ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា កើតឡើងហើយ ក្នុងទីណា វចីសង្ខារ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះឬ ។ ចិត្តសង្ខារ របស់ពួកសត្វ ដែលចូលកាន់ទុតិយជ្ឈាន កាន់តតិយជ្ឈាន និងកាន់ចតុត្ថជ្ឈាន និងរបស់សុទ្ធាវាសសត្វទាំងនោះ ក្នុងចិត្តទី ២ កំពុងប្រព្រឹត្តទៅ កើតឡើងហើយ ក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ចិត្តសង្ខារ របស់ពួកសត្វជាកាមាវចរ ដែលចូលកាន់បឋមជ្ឈាន និងរបស់ពួកសត្វជារូបាវចរ និងជាអរូបាវចរទាំងនោះ ក្រៅនេះ កើតឡើងហើយផង វចីសង្ខារ កើតឡើងហើយផង ក្នុងទីនោះ ។

[ ២៦២ ] កាយសង្ខារ របស់សត្វណា មិនកើតឡើងហើយ វចីសង្ខារ របស់សត្វនោះ មិនកើតឡើងហើយឬ ។ មិនមានទេ ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា មិនកើតឡើងហើយ កាយសង្ខារ របស់សត្វនោះ មិនកើតឡើងហើយដែរឬ ។ មិនមានទេ ។ កាយសង្ខារ របស់សត្វណា មិនកើតឡើងហើយ ចិត្តសង្ខារ របស់សត្វនោះ មិនកើតឡើងហើយឬ ។ មិនមានទេ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា មិនកើតឡើងហើយ កាយសង្ខារ របស់សត្វនោះ មិនកើតឡើងហើយឬ ។ មិនមានទេ ។ វចី-សង្ខារ របស់សត្វណា មិនកើតឡើងហើយ ចិត្តសង្ខារ របស់សត្វនោះ មិនកើតឡើងហើយឬ ។ មិនមានទេ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា មិនកើតឡើងហើយ វចីសង្ខារ របស់សត្វនោះ មិនកើតឡើងហើយឬ ។ មិនមានទេ ។

[ ២៦៣ ] កាយសង្ខារ មិនកើតឡើងហើយ ក្នុងទីណា ។បេ។

[ ២៦៤ ] កាយសង្ខារ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា វចីសង្ខារ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ កាយ-សង្ខារ របស់ពួកសត្វជារូបាវចរ និងជាអរូបាវចរទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ កាយសង្ខារ របស់ពួកសត្វ ដែលចូលកាន់ចតុត្ថជ្ឈាន និងរបស់ពួកសុទ្ធាវាសសត្វ ក្នុងចិត្តទី ២ កំពុងប្រព្រឹត្តទៅ និងរបស់ពួកអសញ្ញសត្វទាំងនោះ មិនកើតឡើងហើយផង វចីសង្ខារ មិនកើត

ឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា កាយសង្ខារ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ វចីសង្ខារ របស់សត្វទាំងនោះ ដែលចូលកាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន មិនកើតឡើងហើយ ក្នុងទីនោះ តែកាយសង្ខារ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ វចីសង្ខារ របស់ពួកសត្វដែលចូលកាន់ចតុត្ថជ្ឈាន និងរបស់ពួកសុទ្ធាវាសសត្វ ក្នុងចិត្តទី ២ កំពុងប្រព្រឹត្តទៅ និងរបស់អសញ្ញសត្វទាំងនោះ មិនកើតឡើងហើយផង កាយសង្ខារ មិនកើតឡើងហើយផង ក្នុងទីនោះ ។

[ ២៦៥ ] កាយសង្ខាររបស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា ចិត្តសង្ខាររបស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ កាយសង្ខារ របស់ពួកសត្វជារូបាវចរ ដែលចូលកាន់ចតុត្ថជ្ឈាន និងរបស់ពួកសត្វជាអរូបាវចរទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែចិត្តសង្ខារ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសត្វកាលចូលទៅកាន់សុទ្ធាវាស និងពួកអសញ្ញសត្វ កាយសង្ខាររបស់សត្វទាំងនោះ មិនកើតឡើងហើយផង ចិត្តសង្ខារ មិនកើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា កាយសង្ខាររបស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ អើ ។

[ ២៦៦ ] វចីសង្ខារ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ វចីសង្ខារ

របស់ពួកសត្វដែលចូលកាន់ទុតិយជ្ឈាន កាន់តតិយជ្ឈាន និងកាន់ចតុត្ថជ្ឈាន និងរបស់ពួកសុទ្ធាវាសសត្វទាំងនោះ ក្នុងចិត្តទី ២ កំពុងប្រព្រឹត្តទៅ មិនកើតឡើងហើយ ក្នុងទីនោះ តែចិត្តសង្ខារ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសត្វកាលចូលទៅកាន់សុទ្ធាវាស និងពួកអសញ្ញសត្វ វចីសង្ខារ របស់សត្វទាំងនោះ មិនកើតឡើងហើយផង ចិត្តសង្ខារ មិនកើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា វចីសង្ខារ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ អើ ។

[ ២៦៧ ] កាយសង្ខារ របស់សត្វណា នឹងកើតឡើង វចីសង្ខារ របស់សត្វនោះ នឹងកើតឡើងឬ ។ អើ ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា នឹងកើតឡើង កាយសង្ខារ របស់សត្វនោះ នឹងកើតឡើងឬ ។ ចិត្តជាទីបំផុត របស់ពួកសត្វជាកាមាវចរ នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា ពួកសត្វដែលកើតក្នុងភពជាទីបំផុត ក្នុងរូបាវចរ និងក្នុងអរូបាវចរ និងពួកសត្វទាំងនោះ ដែលជាសត្វចូលទៅកាន់រូបាវចរ និងកាន់អរូបាវចរហើយ នឹងបរិនិព្វាន កាលច្យុត វចីសង្ខារ របស់សត្វទាំងនោះ នឹងកើតឡើង តែកាយសង្ខារ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ វចីសង្ខារ របស់ពួកសត្វក្រៅនេះ នឹងកើតឡើងផង កាយសង្ខារ នឹងកើតឡើងផង ។

[ ២៦៨ ] កាយសង្ខារ របស់សត្វណា នឹងកើតឡើង ចិត្តសង្ខារ របស់សត្វនោះ នឹងកើតឡើងឬ ។ អើ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វ

ណា នឹងកើតឡើង កាយសង្ខារ របស់សត្វនោះ នឹងកើតឡើងឬ ។ ចិត្ត ជាទីបំផុត របស់ពួកសត្វជាកាមាវចរ នឹងកើតឡើង ក្នុងលំដាប់នៃចិត្តណា ពួកសត្វដែលកើតក្នុងភពជាទីបំផុត ក្នុងរូបាវចរ និងក្នុងអរូបាវចរ និងពួកសត្វទាំងនោះ ដែលចូលទៅកាន់រូបាវចរ និងកាន់អរូបាវចរហើយ នឹងបរិនិព្វាន កាលច្យុត ចិត្តសង្ខារ របស់សត្វទាំងនោះ នឹងកើតឡើង តែកាយសង្ខារ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ ចិត្តសង្ខារ របស់ពួកសត្វក្រៅនេះ នឹងកើតឡើងផង កាយសង្ខារ នឹងកើតឡើងផង ។

[ ២៦៩ ] វចីសង្ខារ របស់សត្វណា នឹងកើតឡើង ចិត្តសង្ខារ របស់សត្វនោះ នឹងកើតឡើងឬ ។ អើ ។ មួយយ៉ាងទៀត ចិត្តសង្ខាររបស់សត្វណា នឹងកើតឡើង វចីសង្ខាររបស់សត្វនោះ នឹងកើតឡើងឬ ។ ចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា ចិត្តសង្ខារ របស់សត្វទាំងនោះ នឹងកើតឡើង តែវចីសង្ខាររបស់សត្វទាំងនោះ នឹងមិនកើតឡើងទេ ចិត្តសង្ខារ របស់ពួកសត្វក្រៅនេះ នឹងកើតឡើងផង វចីសង្ខារ កើតឡើងផង ។

[ ២៧០ ] កាយសង្ខារ នឹងកើតឡើង ក្នុងទីណា ។បេ។

[ ២៧១ ] កាយសង្ខារ របស់សត្វណា នឹងកើតឡើង ក្នុងទីណា វចីសង្ខារ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ ពួកសត្វដែលចូលកាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន កាយសង្ខាររបស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទី

នោះទេ ពួកសត្វជាកាមាវចរ ដែលចូលកាន់បឋមជ្ឈាន កាយសង្ខារ របស់សត្វទាំងនោះ នឹងកើតឡើងផង វចីសង្ខារ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា នឹងកើតឡើង ក្នុងទីណា កាយសង្ខាររបស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ ចិត្តជាទីបំផុត របស់ពួកសត្វជាកាមាវចរ នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា វចីសង្ខារ របស់ពួកសត្វជារូបាវចរ និងជាអរូបាវចរទាំងនោះ នឹងកើតឡើង ក្នុងទីនោះ តែកាយសង្ខារ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វជាកាមាវចរក្រៅនេះ ដែលចូលកាន់បឋមជ្ឈាន វចីសង្ខារ របស់សត្វទាំងនោះ នឹងកើតឡើងផង កាយសង្ខារ នឹងកើតឡើងផង ក្នុងទីនោះ ។

[ ២៧២ ] កាយសង្ខារ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងកើតឡើង ក្នុងទីណា កាយសង្ខារ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ ចិត្តជាទីបំផុត របស់ពួកសត្វជាកាមាវចរ នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា ពួកសត្វជារូបាវចរ និងជាអរូបាវចរ ដែលចូលកាន់ចតុត្ថជ្ឈាន ចិត្តសង្ខារ បស់សត្វទាំងនោះ នឹងកើតឡើង ក្នុងទីនោះ តែកាយសង្ខារ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វជាកាមាវចរក្រៅនេះ ដែលចូលកាន់បឋមជ្ឈាន កាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន ចិត្តសង្ខារ របស់សត្វទាំងនោះ នឹងកើតឡើងផង កាយសង្ខារ នឹងកើតឡើងផង ក្នុងទីនោះ ។

[ ២៧៣ ] វចីសង្ខារ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងកើតឡើង ក្នុងទីណា វចីសង្ខាររបស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ ចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា ពួកសត្វដែលចូលកាន់ទុតិយជ្ឈាន កាន់តតិយជ្ឈាន និងកាន់ចតុត្ថជ្ឈាន ចិត្តសង្ខាររបស់សត្វទាំងនោះ នឹងកើតឡើង ក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វជាកាមាវចរ ដែលចូលកាន់បឋមជ្ឈាន និងពួកសត្វជារូបាវចរ និងជាអរូបាវចរក្រៅនេះ ចិត្តសង្ខាររបស់សត្វទាំងនោះ នឹងកើតឡើងផង វចីសង្ខារ នឹងកើតឡើងផង ក្នុងទីនោះ ។

[ ២៧៤ ] កាយសង្ខារ របស់សត្វណា នឹងមិនកើតឡើង វចីសង្ខារ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ ចិត្តជាទីបំផុត របស់ពួកសត្វជាកាមាវចរ នឹងកើតឡើង ក្នុងលំដាប់នៃចិត្តណា ពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរ និងក្នុងអរូបាវចរ និងពួកសត្វនោះ ដែលចូលទៅកាន់រូបាវចរ និងកាន់អរូបាវចរហើយ នឹងបរិនិព្វាន កាលច្យុត កាយសង្ខាររបស់សត្វទាំងនោះ នឹងមិនកើតឡើង តែវចីសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ ចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ របស់ពួកសត្វដែលប្រកបដោយចិត្តជាទីបំផុត នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា កាយសង្ខារ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង វចីសង្ខារ នឹងមិនកើតឡើង

ផង ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា នឹងមិនកើតឡើង កាយ-សង្ខារ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ អើ ។

[ ២៧៥ ] កាយសង្ខារ របស់សត្វណា នឹងមិនកើតឡើង ចិត្តសង្ខារ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ ចិត្តជាទីបំផុត របស់ពួកសត្វជាកាមាវចរ នឹងកើតឡើង ក្នុងលំដាប់នៃចិត្តណា ពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរ និងក្នុងអរូបាវចរ និងពួកសត្វនោះ ដែលចូលទៅកាន់រូបាវចរ និងកាន់អរូបាវចរហើយ នឹងបរិនិព្វាន កាលច្យុត កាយសង្ខារ របស់សត្វទាំងនោះ នឹងមិនកើតឡើង តែចិត្តសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ កាយសង្ខារ របស់សត្វទាំងនោះ ដែលប្រកបដោយចិត្តជាទីបំផុត នឹងមិនកើតឡើងផង ចិត្តសង្ខារ នឹងមិនកើតឡើងផង ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងមិនកើតឡើង កាយសង្ខារ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ អើ ។

[ ២៧៦ ] វចីសង្ខារ របស់សត្វណា នឹងមិនកើតឡើង ចិត្តសង្ខារ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ ចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា វចីសង្ខារ របស់សត្វទាំងនោះ នឹងមិនកើតឡើង តែចិត្តសង្ខាររបស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ វចីសង្ខារ របស់សត្វទាំងនោះ ដែលប្រកបដោយចិត្តជាទីបំផុត នឹងមិនកើតឡើងផង ចិត្តសង្ខារ នឹងមិនកើតឡើងផង ។ មួយយ៉ាងទៀត ចិត្ត-សង្ខារ របស់សត្វណា នឹងមិនកើតឡើង វចីសង្ខារ របស់សត្វនោះ នឹងមិន

កើតឡើងឬ ។ អើ ។

[ ២៧៧ ] កាយសង្ខារ នឹងមិនកើតឡើង ក្នុងទីណា ។បេ។

[ ២៧៨ ] កាយសង្ខារ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា វចីសង្ខារ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ចិត្តជាទីបំផុត របស់ពួកសត្វជាកាមាវចរ នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា កាយសង្ខារ របស់ពួកសត្វជារូបាវចរ និងជាអរូបាវចរទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ របស់ពួកសត្វដែលប្រកបដោយចិត្តជាទីបំផុត នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា ពួកសត្វដែលចូលកាន់ចតុត្ថជ្ឈាន និងពួកអសញ្ញសត្វ កាយសង្ខារ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង វចីសង្ខារ នឹងមិនកើតឡើងផង ក្នុងទីនោះ ។

មួយយ៉ាងទៀត វចីសង្ខាររបស់សត្វណា នឹងមិនកើតឡើងក្នុងទីណា កាយសង្ខាររបស់សត្វនោះ នឹងមិនកើតឡើងក្នុងទីនោះឬ ។ ពួកសត្វដែលចូលកាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន វចីសង្ខារ របស់សត្វទាំងនោះ នឹងមិនកើតឡើងក្នុងទីនោះ តែកាយសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ របស់ពួកសត្វដែលប្រកបដោយចិត្តជាទីបំផុត នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា ពួកសត្វដែលចូលកាន់ចតុត្ថជ្ឈាន និងពួកអសញ្ញសត្វ វចីសង្ខាររបស់សត្វទាំងនោះ នឹងមិនកើតឡើងផង កាយសង្ខារ នឹងមិនកើតឡើងផង ក្នុង

ទីនោះ ។

[ ២៧៩ ] កាយសង្ខារ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ចិត្តជាទីបំផុត របស់ពួកសត្វជាកាមាវចរ នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា ពួកសត្វជារូបាវចរ និងជាអរូបាវចរ ដែលចូលកាន់ចតុត្ថជ្ឈាន កាយសង្ខារ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែចិត្តសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វដែលប្រកបដោយចិត្តជាទីបំផុត និងពួកអសញ្ញសត្វ កាយសង្ខារ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ចិត្តសង្ខារ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា កាយសង្ខារ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ អើ ។

[ ២៨០ ] វចីសង្ខារ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ ចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា ពួកសត្វដែលចូលកាន់ទុតិយជ្ឈាន កាន់តតិយជ្ឈាន និងកាន់ចតុត្ថជ្ឈាន វចី-សង្ខារ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែចិត្តសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ វចីសង្ខារ របស់ពួកសត្វដែលប្រកបដោយចិត្តជាទីបំផុត និងរបស់អសញ្ញសត្វទាំងនោះ នឹងមិនកើតឡើងផង ចិត្តសង្ខារ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាង

ទៀត ចិត្តសង្ខារ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា វចីសង្ខារ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ អើ ។

[ ២៨១ ] កាយសង្ខារ របស់សត្វណា កើតឡើង វចីសង្ខារ របស់សត្វនោះ កើតឡើងហើយឬ ។ អើ ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា កើតឡើងហើយ កាយសង្ខាររបស់សត្វនោះ កើតឡើងឬ ។ វចីសង្ខារ របស់ពួកសត្វទាំងអស់ ដែលចូលកាន់និរោធ និងរបស់អសញ្ញសត្វទាំងនោះ កើតឡើងហើយ ក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ តែកាយសង្ខារ របស់សត្វទាំងនោះ មិនកើតឡើងទេ វចីសង្ខារ របស់សត្វទាំងនោះ កើតឡើងហើយផង កាយសង្ខារកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ ។

[ ២៨២ ] កាយសង្ខារ របស់សត្វណា កើតឡើង ចិត្តសង្ខារ របស់សត្វនោះ កើតឡើងហើយឬ ។ អើ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា កើតឡើងហើយ កាយសង្ខាររបស់សត្វនោះ កើតឡើងឬ ។ ចិត្តសង្ខារ របស់ពួកសត្វទាំងអស់ ដែលចូលកាន់និរោធ និងរបស់អសញ្ញសត្វទាំងនោះ កើតឡើងហើយ ក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ តែកាយសង្ខារ របស់សត្វទាំងនោះ មិនកើតឡើងទេ ចិត្តសង្ខារ របស់សត្វទាំងនោះ កើតឡើងហើយផង កាយសង្ខារកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ ។

[ ២៨៣ ] វចីសង្ខារ របស់សត្វណា កើតឡើង ចិត្តសង្ខារ របស់សត្វ

នោះកើតឡើងហើយឬ ។ អើ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា កើតឡើងហើយ វចីសង្ខារ របស់សត្វនោះ កើតឡើងឬ ។ ចិត្តសង្ខារ របស់ពួកសត្វទាំងអស់ ដែលចូលកាន់និរោធ និងរបស់អសញ្ញសត្វទាំងនោះ កើតឡើងហើយ ក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកវិតក្ក និងវិចារ តែវចីសង្ខារ របស់សត្វទាំងនោះ មិនកើតឡើងទេ ចិត្តសង្ខារ របស់សត្វទាំងនោះ កើតឡើងហើយផង វចីសង្ខារកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃពួកវិតក្ក និងវិចារ ។

[ ២៨៤ ] កាយសង្ខារ កើតឡើង ក្នុងទីណា ។បេ។

[ ២៨៥ ] កាយសង្ខារ របស់សត្វណា កើតឡើង ក្នុងទីណា វចីសង្ខារ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះឬ ។ ពួកសត្វដែលចូលកាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន កាយសង្ខារ របស់សត្វទាំងនោះ កើតឡើង ក្នុងឧប្បាទក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ ក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសត្វជាកាមាវចរ ដែលចូលកាន់បឋមជ្ឈាន កាយសង្ខារ របស់សត្វទាំងនោះ កើតឡើងផង វចីសង្ខារ កើតឡើងហើយផង ក្នុងឧប្បាទក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ ក្នុងទីនោះ ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា កើតឡើងហើយ ក្នុងទីណា កាយសង្ខារ របស់សត្វនោះ កើតឡើងក្នុងទីនោះឬ ។ ពួកសត្វជាកាមាវចរ ដែលចូលកាន់បឋមជ្ឈាន ក្នុងភង្គក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ ពួកសត្វជារូបាវចរ និងជាអរូបាវចរទាំងនោះឯង

ក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ វចីសង្ខារ របស់សត្វទាំងនោះ កើតឡើងហើយ តែកាយសង្ខារ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វជាកាមាវចរ ដែលចូលកាន់បឋមជ្ឈាន វចីសង្ខារ របស់សត្វទាំងនោះ កើតឡើងហើយផង កាយសង្ខារ កើតឡើងផង ក្នុងឧប្បាទក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ ក្នុងទីនោះ ។

[ ២៨៦ ] កាយសង្ខារ របស់សត្វណា កើតឡើង ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា កើតឡើងហើយ ក្នុងទីណា កាយសង្ខារ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ ចិត្តសង្ខារ របស់សត្វទាំងអស់នោះ កើតឡើងហើយ ក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ ក្នុងទីនោះ តែកាយសង្ខាររបស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ចិត្តសង្ខារ របស់សត្វទាំងនោះ កើតឡើងហើយផង កាយសង្ខារ កើតឡើងផង ក្នុងឧប្បាទក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ ក្នុងទីនោះ ។

[ ២៨៧ ] វចីសង្ខារ របស់សត្វណា កើតឡើង ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា កើតឡើងហើយ ក្នុងទីណា វចីសង្ខារ របស់សត្វនោះ កើតឡើងក្នុងទីនោះឬ ។ ចិត្តសង្ខារ របស់សត្វទាំងអស់នោះ កើតឡើងហើយ ក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាក

ពួកវិតក្ក និងវិចារ ក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំងនោះ មិនកើតឡើងក្នុងទីនោះទេ ចិត្តសង្ខារ របស់សត្វទាំងនោះ កើតឡើងហើយផង វចីសង្ខារកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃពួកវិតក្ក និងវិចារ ក្នុងទីនោះ ។

[ ២៨៨ ] កាយសង្ខារ របស់សត្វណា មិនកើតឡើង វចីសង្ខារ របស់សត្វនោះ មិនកើតឡើងហើយឬ ។ កើតឡើងហើយ ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា មិនកើតឡើងហើយ កាយសង្ខារ របស់សត្វនោះ មិនកើតឡើងឬ ។ មិនមានទេ ។

[ ២៨៩ ] កាយសង្ខារ របស់សត្វណា មិនកើតឡើង ចិត្តសង្ខារ របស់សត្វនោះ មិនកើតឡើងហើយឬ ។ កើតឡើងហើយ ។ មួយយ៉ាងទៀត ចិត្តសង្ខាររបស់សត្វណា មិនកើតឡើងហើយ កាយសង្ខារ របស់សត្វនោះ មិនកើតឡើងឬ ។ មិនមានទេ ។

[ ២៩០ ] វចីសង្ខារ របស់សត្វណា មិនកើតឡើង ចិត្តសង្ខារ របស់សត្វនោះ មិនកើតឡើងហើយឬ ។ កើតឡើងហើយ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា មិនកើតឡើងហើយ វចីសង្ខារ របស់សត្វនោះ មិនកើតឡើងឬ ។ មិនមានទេ ។

[ ២៩១ ] កាយសង្ខារ មិនកើតឡើង ក្នុងទីណា ។បេ។

[ ២៩២ ] កាយសង្ខារ របស់សត្វណា មិនកើតឡើង ក្នុងទីណា វចីសង្ខារ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ កាយសង្ខារ របស់ពួកសត្វជាកាមាវចរនោះឯង ដែលចូលកាន់បឋមជ្ឈាន ក្នុងភង្គក្ខណៈ

នៃពួកអសញ្ញសត្វ និងបញ្ចសត្វ និងរបស់ពួកសត្វជារូបាវចរ និងជាអរូបា-វចរទាំងនោះ ក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអសញ្ញសត្វ និងបញ្ចសត្វ មិនកើតឡើង ក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ កាយសង្ខាររបស់ពួកសត្វទាំងនោះឯង ដែលចូលកាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន ក្នុងភង្គក្ខណៈនៃពួកអសញ្ញសត្វ និងបញ្ចសត្វ និងរបស់ពួកសត្វដែលចូលកាន់ចតុត្ថជ្ឈាន ក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអសញ្ញសត្វ និងបញ្ចសត្វ និងរបស់ពួកសុទ្ធាវាសសត្វ ក្នុងចិត្តទី ២ កំពុងប្រព្រឹត្តទៅ និងរបស់អសញ្ញសត្វទាំងនោះ មិនកើតឡើងផង វចីសង្ខារ មិនកើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា កាយសង្ខារ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ ពួកសត្វដែលចូលកាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន ក្នុងឧប្បាទក្ខណៈនៃពួកអសញ្ញសត្វ និងបញ្ចសត្វ វចីសង្ខារ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែកាយសង្ខារ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងក្នុងទីនោះទេ វចីសង្ខារ របស់សត្វទាំងនោះឯង ដែលចូលកាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន ក្នុងភង្គក្ខណៈនៃពួកអសញ្ញសត្វ និងបញ្ចសត្វ និងរបស់ពួកសត្វដែលចូលកាន់ចតុត្ថជ្ឈាន ក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអសញ្ញសត្វ និងបញ្ចសត្វ និងរបស់ពួកសុទ្ធាវាសសត្វ ក្នុងចិត្តទី ២ កំពុង

ប្រព្រឹត្តទៅ និងរបស់អសញ្ញសត្វទាំងនោះ មិនកើតឡើងហើយផង កាយ-សង្ខារ មិនកើតឡើងផង ក្នុងទីនោះ ។

[ ២៩៣ ] កាយសង្ខារ របស់សត្វណា មិនកើតឡើង ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ កាយសង្ខារ របស់សត្វទាំងអស់នោះ ក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ កើតឡើង ក្នុងទីនោះ តែចិត្ត-សង្ខារ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស និងពួកអសញ្ញសត្វ កាយសង្ខារ របស់សត្វទាំងនោះ មិនកើតឡើងផង ចិត្តសង្ខារ មិនកើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា កាយសង្ខារ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ អើ ។

[ ២៩៤ ] វចីសង្ខារ របស់សត្វណា មិនកើតឡើងក្នុងទីណា ចិត្ត-សង្ខារ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ វចីសង្ខារ របស់សត្វទាំងអស់នោះ មិនកើតឡើង ក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បា-ទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកវិតក្កវិចារ ក្នុងទីនោះ តែចិត្តសង្ខារ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ ពួកសត្វ កាលចូលទៅកាន់សុទ្ធាវាស និងពួកអសញ្ញសត្វ វចីសង្ខារ របស់សត្វទាំងនោះ មិនកើតឡើងផង ចិត្តសង្ខារ មិនកើតឡើងហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា

វចីសង្ខារ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ អើ ។

[ ២៩៥ ] កាយសង្ខារ របស់សត្វណា កើតឡើង វចីសង្ខារ របស់សត្វនោះ កើតឡើងឬ ។ អើ ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា នឹងកើតឡើង កាយសង្ខារ របស់សត្វនោះ កើតឡើងឬ ។ វចីសង្ខាររបស់ពួកសត្វទាំងអស់ ដែលចូលកាន់និរោធ និងរបស់អសញ្ញសត្វទាំងនោះ នឹងកើតឡើង ក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ តែកាយសង្ខារ របស់សត្វទាំងនោះ មិនកើតឡើងទេ វចីសង្ខារ របស់សត្វទាំងនោះ នឹងកើតឡើងផង កាយសង្ខារ កើតឡើងផង ក្នុងឧប្បាទក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ ។

[ ២៩៦ ] កាយសង្ខារ របស់សត្វណា កើតឡើង ចិត្តសង្ខារ របស់សត្វនោះ នឹងកើតឡើងឬ ។ អើ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងកើតឡើង កាយសង្ខាររបស់សត្វនោះ កើតឡើងឬ ។ ចិត្តសង្ខារ របស់ពួកសត្វទាំងអស់ ដែលចូលកាន់និរោធ និងរបស់អសញ្ញសត្វទាំងនោះ នឹងកើតឡើង ក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ តែកាយសង្ខារ របស់សត្វទាំងនោះ មិនកើតឡើងទេ ចិត្តសង្ខារ របស់សត្វទាំងនោះ នឹងកើតឡើងផង កាយសង្ខារ កើតឡើងផង ក្នុងឧប្បាទក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ ។

[ ២៩៧ ] វចីសង្ខារ របស់សត្វណា កើតឡើង ចិត្តសង្ខារ របស់សត្វនោះ នឹងកើតឡើងឬ ។ វចីសង្ខារ របស់សត្វទាំងនោះ កើតឡើងក្នុង

ឧប្បាទក្ខណៈ នៃចិត្តជាទីបំផុត ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ តែចិត្តសង្ខារ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ វចីសង្ខារ របស់សត្វទាំងនោះ ក្រៅនេះ កើតឡើងផង ចិត្តសង្ខារ នឹងកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃពួកវិតក្ក និងវិចារ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងកើតឡើង វចីសង្ខារ របស់សត្វនោះ កើតឡើងឬ ។ ចិត្តសង្ខារ របស់ពួកសត្វទាំងអស់ ដែលចូលកាន់និរោធ និងរបស់អសញ្ញសត្វទាំងនោះ នឹងកើតឡើងក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកវិតក្ក និងវិចារ តែវចីសង្ខារ របស់សត្វទាំងនោះ មិនកើតឡើងទេ ចិត្តសង្ខារ របស់សត្វទាំងនោះ នឹងកើតឡើងផង វចីសង្ខារ កើតឡើងផង ក្នុងឧប្បាទក្ខណៈនៃពួកវិតក្ក និងវិចារ ។

[ ២៩៨ ] កាយសង្ខារ កើតឡើង ក្នុងទីណា ។បេ។

[ ២៩៩ ] កាយសង្ខារ របស់សត្វណា កើតឡើង ក្នុងទីណា វចីសង្ខារ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ កាយសង្ខារ របស់សត្វទាំងនោះ ដែលចូលកាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន ក្នុងឧប្បាទក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ កើតឡើង ក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ពួកសត្វជាកាមាវចរ ដែលចូលកាន់បឋមជ្ឈាន ក្នុងឧប្បាទក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ កាយសង្ខារ របស់សត្វទាំងនោះ កើតឡើងផង វចីសង្ខារ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា នឹងកើតឡើង ក្នុងទីណា

*កាយសង្ខារ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ វចីសង្ខារ របស់ពួកសត្វជាកាមាវចរនោះឯង ដែលចូលកាន់បឋមជ្ឈាន ក្នុងភង្គក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ និងរបស់ពួកសត្វជារូបាវចរ និងជាអរូបាវចរទាំងនោះ ក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ នឹងកើតឡើង ក្នុងទីនោះ តែកាយសង្ខារ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ពួកសត្វជាកាមាវចរ ដែលចូលកាន់បឋមជ្ឈាន ក្នុងឧប្បាទក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ វចីសង្ខារ របស់សត្វទាំងនោះ នឹងកើតឡើងផង កាយសង្ខារ កើតឡើងផង ក្នុងទីនោះ ។*

*[ ៣០០ ] កាយសង្ខារ របស់សត្វណា កើតឡើង ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងកើតឡើង ក្នុងទីណា កាយសង្ខាររបស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ ចិត្តសង្ខារ របស់ពួកសត្វទាំងអស់នោះ នឹងកើតឡើងក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ ក្នុងទីនោះ តែកាយសង្ខារ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ចិត្តសង្ខារ របស់សត្វទាំងនោះ នឹងកើតឡើងផង កាយសង្ខារ កើតឡើងផង ក្នុងឧប្បាទក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ ក្នុងទីនោះ ។*

*[ ៣០១ ] វចីសង្ខារ របស់សត្វណា កើតឡើង ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ វចីសង្ខារ របស់សត្វទាំងនោះ*

*កើតឡើង ក្នុងឧប្បាទក្ខណៈនៃចិត្តជាទីបំផុត ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ក្នុងទីនោះ តែចិត្តសង្ខារ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ វចីសង្ខារ របស់សត្វទាំងនោះ ក្រៅនេះ កើតឡើងផង ចិត្តសង្ខារ នឹងកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃពួកវិតក្ក និងវិចារ ក្នុងទីនោះ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងកើតឡើង ក្នុងទីណា វចីសង្ខារ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ ចិត្តសង្ខារ របស់សត្វទាំងអស់នោះ នឹងកើតឡើងក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកវិតក្ក និងវិចារ ក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ចិត្តសង្ខារ របស់សត្វទាំងនោះ នឹងកើតឡើងផង វចីសង្ខារ កើតឡើងផង ក្នុងឧប្បាទក្ខណៈនៃពួកវិតក្ក និងវិចារ ក្នុងទីនោះ ។*

*[ ៣០២ ] កាយសង្ខារ របស់សត្វណា មិនកើតឡើង វចីសង្ខារ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ កាយសង្ខារ របស់សត្វទាំងអស់ក្នុងភង្គក្ខណៈនៃចិត្ត និងរបស់ពួកសត្វដែលចូលកាន់និរោធ ក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ និងរបស់អសញ្ញសត្វទាំងនោះ មិនកើតឡើង តែវចីសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ ចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ របស់ពួកសត្វដែលប្រកបដោយចិត្តជាទីបំផុត នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា កាយសង្ខារ របស់សត្វទាំងនោះ មិនកើតឡើងផង វចីសង្ខារ នឹងមិនកើតឡើងផង ។ មួយយ៉ាង*

ទៀត វចីសង្ខារ របស់សត្វណា នឹងមិនកើតឡើង កាយសង្ខារ របស់សត្វនោះ មិនកើតឡើងឬ ។ អើ ។

[ ៣០៣ ] កាយសង្ខាររបស់សត្វណា មិនកើតឡើង ចិត្តសង្ខាររបស់សត្វនោះ នឹងមិនកើតឡើងឬ ។ កាយសង្ខារ របស់សត្វទាំងអស់ ក្នុងភង្គក្ខណៈនៃចិត្ត និងរបស់ពួកសត្វដែលចូលកាន់និរោធ ក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ និងរបស់អសញ្ញសត្វទាំងនោះ មិនកើតឡើង តែចិត្តសង្ខារ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ កាយសង្ខារ របស់សត្វទាំងនោះ ដែលប្រកបដោយចិត្តជាទីបំផុត មិនកើតឡើងផង ចិត្តសង្ខារ នឹងមិនកើតឡើងផង ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងមិនកើតឡើង កាយសង្ខារ របស់សត្វនោះ មិនកើតឡើងឬ ។ អើ ។

[ ៣០៤ ] វចីសង្ខារ របស់សត្វណា មិនកើតឡើង ចិត្តសង្ខារ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ វចីសង្ខារ របស់សត្វទាំងអស់ក្នុងភង្គក្ខណៈនៃចិត្ត និងរបស់ពួកសត្វដែលចូលកាន់និរោធ ក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកវិតក្ក និងវិចារ និងរបស់អសញ្ញសត្វទាំងនោះ មិនកើតឡើង តែចិត្តសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងទេ វចីសង្ខារ របស់ពួកសត្វទាំងនោះ ដែលប្រកបដោយចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ មិនកើតឡើងផង ចិត្តសង្ខារ នឹងមិនកើតឡើងផង ។ មួយ

យ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងមិនកើតឡើង វចីសង្ខារ របស់សត្វនោះ មិនកើតឡើងឬ ។ ចិត្តសង្ខារ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃចិត្តជាទីបំផុត ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ តែវចីសង្ខារ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ចិត្តសង្ខារ របស់សត្វទាំងនោះ ដែលប្រកបដោយចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ នឹងមិនកើតឡើងផង វចីសង្ខារ មិនកើតឡើងផង ។

[ ៣០៥ ] កាយសង្ខារ មិនកើតឡើង ក្នុងទីណា ។បេ។

[ ៣០៦ ] កាយសង្ខារ របស់សត្វណា មិនកើតឡើង ក្នុងទីណា វចីសង្ខារ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ កាយសង្ខារ របស់ពួកសត្វ ជាកាមាវចរទាំងនោះឯង ដែលចូលកាន់បឋមជ្ឈាន ក្នុងភង្គក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ និងរបស់ពួកសត្វជារូបាវចរ និងជាអរូបាវចរទាំងនោះ ក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ មិនកើតឡើង ក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចាររបស់ពួកសត្វ ដែលប្រកបដោយចិត្តជាទីបំផុត នឹងកើតឡើង ក្នុងលំដាប់នៃចិត្តណា កាយសង្ខារ របស់សត្វទាំងនោះឯង ដែលចូលកាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន ក្នុងភង្គក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ និងរបស់ពួកសត្វដែលចូលកាន់ចតុត្ថជ្ឈាន និងរបស់អសញ្ញសត្វទាំងនោះ

ក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអសញ្ញសត្វ និងបសញ្ញសត្វ មិនកើត ឡើងផង វចីសង្ខារ មិនកើតឡើងផង ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា កាយសង្ខារ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ វចីសង្ខារ របស់សត្វទាំងនោះ ដែលចូលកាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន ក្នុងឧប្បាទក្ខណៈនៃពួកអសញ្ញសត្វ និងបសញ្ញសត្វ នឹងមិនកើតឡើង ក្នុងទីនោះ តែកាយសង្ខារ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ របស់ពួកសត្វដែលប្រកបដោយចិត្តជាទីបំផុត នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា វចីសង្ខារ របស់សត្វទាំងនោះ ដែលចូលកាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន ក្នុងភង្គក្ខណៈនៃពួកអសញ្ញសត្វ និងបសញ្ញសត្វ និងរបស់ពួកសត្វដែលចូលកាន់ចតុត្ថជ្ឈាន និងរបស់អសញ្ញសត្វទាំងនោះ ក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអសញ្ញសត្វ និងបសញ្ញសត្វ នឹងមិនកើតឡើងផង កាយសង្ខារ មិនកើតឡើងផង ។

[ ៣០៧ ] កាយសង្ខារ របស់សត្វណា មិនកើតឡើង ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ កាយសង្ខារ របស់សត្វទាំងអស់នោះ មិនកើតឡើងក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអសញ្ញសត្វ និងបសញ្ញសត្វ ក្នុងទីនោះ តែចិត្តសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ កាយសង្ខារ របស់ពួកសត្វ ដែលប្រកបដោយចិត្តជាទីបំផុត និងរបស់អសញ្ញសត្វទាំង

នោះ មិនកើតឡើងផង ចិត្តសង្ខារ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា កាយសង្ខារ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ អើ ។

[ ៣០៨ ] វចីសង្ខារ របស់សត្វណា មិនកើតឡើង ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ វចីសង្ខារ របស់សត្វទាំងអស់នោះ មិនកើតឡើងក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកវិតក្ក និងវិចារ ក្នុងទីនោះ តែចិត្តសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ វចីសង្ខារ របស់ពួកសត្វដែលប្រកបដោយចិត្តជាទីបំផុត ដែលមិនមានវិតក្ក និងមិនមានវិចារ និងរបស់អសញ្ញសត្វទាំងនោះ ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ មិនកើតឡើងផង ចិត្តសង្ខារ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ចិត្តសង្ខាររបស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា វចីសង្ខារ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ ចិត្តសង្ខារ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងឧប្បាទក្ខណៈនៃចិត្តជាទីបំផុត ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ចិត្តសង្ខារ របស់ពួកសត្វដែលប្រកបដោយចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ និងរបស់អសញ្ញសត្វទាំងនោះ ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ នឹងមិនកើតឡើងផង វចីសង្ខារ មិនកើត

ឡើងផង ក្នុងទីនោះ ។

[ ៣០៩ ] កាយសង្ខារ របស់សត្វណា កើតឡើងហើយ វចីសង្ខារ របស់សត្វនោះ នឹងកើតឡើងឬ ។ ចិត្តជាទីបំផុតដែលមិនមានវិតក្ក មិនមានវិចារ របស់ពួកសត្វដែលប្រកបដោយចិត្តជាទីបំផុត នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា កាយសង្ខារ របស់សត្វទាំងនោះ កើតឡើងហើយ តែវចីសង្ខារ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ កាយសង្ខារ របស់ពួកសត្វទាំងនោះ ក្រៅនេះ កើតឡើងហើយផង វចីសង្ខារ នឹងកើតឡើងផង ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា នឹងកើតឡើង កាយសង្ខារ របស់សត្វនោះ កើតឡើងហើយឬ ។ អើ ។

[ ៣១០ ] កាយសង្ខារ របស់សត្វណា កើតឡើងហើយ ចិត្តសង្ខារ របស់សត្វនោះ នឹងកើតឡើងឬ ។ កាយសង្ខារ របស់សត្វទាំងនោះ ដែលប្រកបដោយចិត្តជាទីបំផុត កើតឡើងហើយ តែចិត្តសង្ខាររបស់សត្វទាំងនោះ នឹងមិនកើតឡើងទេ កាយសង្ខាររបស់ពួកសត្វក្រៅនេះ កើតឡើងហើយផង ចិត្តសង្ខារ នឹងកើតឡើងផង ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា ( កើតឡើងហើយ ) ។បេ។ អើ ។

[ ៣១១ ] វចីសង្ខាររបស់សត្វណា កើតឡើងហើយ ចិត្តសង្ខាររបស់សត្វនោះនឹងកើតឡើងឬ ។ វចីសង្ខាររបស់សត្វទាំងនោះ ដែលប្រកបដោយចិត្តជាទីបំផុត កើតឡើងហើយ តែវចីសង្ខាររបស់សត្វទាំងនោះ នឹងមិនកើតឡើងទេ វចីសង្ខាររបស់ពួកសត្វក្រៅនេះ កើតឡើងហើយផង ចិត្តសង្ខារ

នឹងកើតឡើងផង ។ មួយយ៉ាងទៀត ចិត្តសង្ខាររបស់សត្វណា ( កើតឡើងហើយ ) ។បេ។ អើ ។

[ ៣១២ ] កាយសង្ខារ កើតឡើងហើយ ក្នុងទីណា ។បេ។

[ ៣១៣ ] កាយសង្ខារ របស់សត្វណា កើតឡើងហើយ ក្នុងទីណា វចីសង្ខារ របស់សត្វនោះ នឹងកើតឡើងក្នុងទីនោះឬ ។ កាយសង្ខារ របស់ពួកសត្វដែលប្រកបដោយចិត្តជាទីបំផុត ក្នុងកាមាវចរភព និងរបស់សត្វទាំងនោះ ដែលចូលកាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន កើតឡើងហើយ ក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ កាយសង្ខារ របស់ពួកសត្វដែលចូលកាន់បឋមជ្ឈាន និងរបស់ពួកសត្វជាកាមាវចរទាំងនោះ ក្រៅនេះ កើតឡើងហើយផង វចីសង្ខារ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា នឹងកើតឡើង ក្នុងទីណា កាយសង្ខារ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះឬ ។ វចីសង្ខារ របស់ពួកសត្វជារូបាវចរ និងជាអរូបាវចរទាំងនោះ នឹងកើតឡើង ក្នុងទីនោះ តែកាយសង្ខារ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ វចីសង្ខាររបស់ពួកសត្វ ដែលចូលកាន់បឋមជ្ឈាន និងរបស់សត្វជាកាមាវចរទាំងនោះ នឹងកើតឡើងផង កាយសង្ខារ កើតឡើងហើយផង ក្នុងទីនោះ ។

[ ៣១៤ ] កាយសង្ខារ របស់សត្វណា កើតឡើងហើយ ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ កាយសង្ខារ របស់

សត្វទាំងនោះ ដែលប្រកបដោយចិត្តជាទីបំផុត ក្នុងកាមាវចរ កើតឡើង ហើយ ក្នុងទីនោះ តែចិត្តសង្ខារ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ កាយសង្ខារ របស់ពួកសត្វជាកាមាវចរទាំងនោះ ក្រៅនេះ ដែលចូលកាន់បឋមជ្ឈាន កាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន កើតឡើងហើយផង ចិត្តសង្ខារ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងកើតឡើង ក្នុងទីណា កាយសង្ខារ របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះឬ ។ ចិត្តសង្ខារ របស់ពួកសត្វជារូបាវចរ និងជាអរូបាវចរទាំងនោះ ដែលចូលកាន់ចតុត្ថជ្ឈាន នឹងកើតឡើង ក្នុងទីនោះ តែកាយសង្ខារ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ចិត្តសង្ខារ របស់ពួកសត្វជាកាមាវចរទាំងនោះ ដែលចូលកាន់បឋមជ្ឈាន កាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន នឹងកើតឡើងផង កាយសង្ខារ កើតឡើងហើយផង ក្នុងទីនោះ ។

[ ៣១៥ ] វចីសង្ខារ របស់សត្វណា កើតឡើងហើយ ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ វចីសង្ខាររបស់សត្វទាំងនោះ ដែលប្រកបដោយចិត្តជាទីបំផុត ក្នុងសវិតក្កសវិចារភូមិ កើតឡើងហើយ ក្នុងទីនោះ តែចិត្តសង្ខារ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ វចីសង្ខារ របស់ពួកសត្វទាំងនោះ ក្រៅនេះ ក្នុងសវិតក្កសវិចារភូមិ កើតឡើងហើយផង ចិត្តសង្ខារ នឹងកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងកើតឡើង ក្នុងទីណា វចីសង្ខារ

របស់សត្វនោះ កើតឡើងហើយ ក្នុងទីនោះឬ ។ ចិត្តសង្ខារ របស់សត្វទាំងនោះ ក្នុងអវិតក្កអវិចារភូមិ នឹងកើតឡើង ក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះទេ ចិត្តសង្ខារ របស់សត្វទាំងនោះ ក្នុងសវិតក្កសវិចារភូមិ នឹងកើតឡើងផង វចីសង្ខារ កើតឡើងហើយផង ក្នុងទីនោះ ។

[ ៣១៦ ] កាយសង្ខារ របស់សត្វណា មិនកើតឡើងហើយ វចីសង្ខារ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ មិនមានទេ ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា នឹងមិនកើតឡើង កាយសង្ខារ របស់សត្វនោះ មិនកើតឡើងហើយឬ ។ កើតឡើងហើយ ។

[ ៣១៧ ] កាយសង្ខារ របស់សត្វណា មិនកើតឡើងហើយ ចិត្តសង្ខារ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ មិនមានទេ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងមិនកើតឡើង កាយសង្ខារ របស់សត្វនោះ មិនកើតឡើងហើយឬ ។ កើតឡើងហើយ ។

[ ៣១៨ ] វចីសង្ខារ របស់សត្វណា មិនកើតឡើងហើយ ចិត្តសង្ខារ របស់សត្វនោះ នឹងមិនកើតឡើងឬ ។ មិនមានទេ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងមិនកើតឡើង វចីសង្ខារ របស់សត្វនោះ មិនកើតឡើងហើយឬ ។ កើតឡើងហើយ ។

[ ៣១៩ ] កាយសង្ខារ មិនកើតឡើងហើយ ក្នុងទីណា ។បេ។

[ ៣២០ ] កាយសង្ខារ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា

វចីសង្ខារ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ កាយសង្ខារ របស់សត្វជារូបាវចរ និងជាអរូបាវចរទាំងនោះ មិនកើតឡើងហើយ ក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ ចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ របស់ពួកសត្វដែលប្រកបដោយចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ នឹងកើតឡើង ក្នុងលំដាប់នៃចិត្តណា ក្នុងកង្ខណៈនៃចិត្តជាទីបំផុត ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ក្នុងរូបាវចរ និងក្នុងអរូបាវចរ កាយសង្ខារ របស់ពួកសត្វនោះ ដែលចូលកាន់ចតុត្ថជ្ឈាន និងរបស់អសញ្ញសត្វទាំងនោះ មិនកើតឡើងហើយផង វចីសង្ខារ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា កាយ-សង្ខារ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ វចីសង្ខារ របស់ពួកសត្វដែលប្រកបដោយចិត្តជាទីបំផុត ក្នុងកាមាវចរ និងរបស់សត្វទាំងនោះ ដែលចូលកាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន នឹងមិនកើតឡើង ក្នុងទីនោះ តែកាយសង្ខារ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយក្នុងទីនោះទេ ចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ របស់ពួកសត្វដែលប្រកបដោយចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា ក្នុងកង្ខណៈនៃចិត្តជាទីបំផុត ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ក្នុងរូបាវចរ និងក្នុងអរូបាវចរ វចីសង្ខារ របស់ពួកសត្វដែលចូលកាន់ចតុត្ថជ្ឈាន និងរបស់អសញ្ញសត្វទាំងនោះ នឹងមិនកើត

*ឡើងផង កាយសង្ខារ មិនកើតឡើងហើយផង ក្នុងទីនោះ ។*

*[ ៣២១ ] កាយសង្ខារ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ កាយសង្ខារ របស់ពួកសត្វជារូបាវចរ និងជាអរូបាវចរទាំងនោះ ដែលចូលកាន់ចតុត្ថជ្ឈាន មិនកើតឡើងហើយ ក្នុងទីនោះ តែចិត្តសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើង ក្នុងទីនោះទេ កាយសង្ខារ របស់ពួកសត្វដែលប្រកបដោយចិត្តជាទីបំផុត ក្នុងរូបាវចរ និងក្នុងអរូបាវចរ និងរបស់អសញ្ញសត្វទាំងនោះ មិនកើតឡើងហើយផង ចិត្តសង្ខារ នឹងមិនកើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា កាយសង្ខារ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ ចិត្តសង្ខារ របស់សត្វទាំងនោះ ដែលប្រកបដោយចិត្តជាទីបំផុត ក្នុងកាមាវចរ នឹងមិនកើតឡើង ក្នុងទីនោះ តែកាយសង្ខារ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ ចិត្តសង្ខារ របស់ពួកសត្វ ដែលប្រកបដោយចិត្តជាទីបំផុត ក្នុងរូបាវចរ និងក្នុងអរូបាវចរ និងរបស់អសញ្ញសត្វទាំងនោះ នឹងមិនកើតឡើងផង កាយសង្ខារ មិនកើតឡើងហើយផង ក្នុងទីនោះ ។*

*[ ៣២២ ] វចីសង្ខារ របស់សត្វណា មិនកើតឡើងហើយ ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ វចីសង្ខារ របស់សត្វទាំងនោះ ក្នុងអវិតក្កអវិចារភូមិ មិនកើតឡើងហើយ ក្នុងទីនោះ តែ*

ចិត្តសង្ខារ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ វចី- សង្ខារ របស់ពួកសត្វ ដែលប្រកបដោយចិត្តជាទីបំផុត ក្នុងអវិតក្កអវិចារភូមិ និងរបស់អសញ្ញសត្វទាំងនោះ មិនកើតឡើងហើយផង ចិត្តសង្ខារ នឹងមិន កើតឡើងផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹង មិនកើតឡើង ក្នុងទីណា វចីសង្ខារ របស់សត្វនោះ មិនកើតឡើងហើយ ក្នុងទីនោះឬ ។ ចិត្តសង្ខារ របស់សត្វទាំងនោះ ដែលប្រកបដោយចិត្តជាទី បំផុត ក្នុងសវិតក្កសវិចារភូមិ នឹងមិនកើតឡើង ក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងហើយ ក្នុងទីនោះទេ ចិត្តសង្ខារ របស់ពួកសត្វដែលប្រកបដោយចិត្តជាទីបំផុត ក្នុងអវិតក្កអវិចារភូមិ និងរបស់ អសញ្ញសត្វទាំងនោះ នឹងមិនកើតឡើងផង វចីសង្ខារ មិនកើតឡើងហើយ ផង ក្នុងទីនោះ ។

## ឧប្បាទវារៈ ចប់

[ ៣២៣ ] កាយសង្ខារ របស់សត្វណា រលត់ទៅ វចីសង្ខារ របស់សត្វ នោះ រលត់ទៅឬ ។ កាយសង្ខារ របស់សត្វទាំងនោះ រលត់ទៅ ក្នុង កង្គក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ ព្រោះវៀរចាកពួកវិតក្ក និងវិចារ តែវចីសង្ខារ របស់សត្វទាំងនោះ មិនរលត់ទៅទេ កាយសង្ខារ របស់ពួក សត្វជាកាមាវចរទាំងនោះ ដែលចូលកាន់បឋមជ្ឈាន រលត់ទៅផង វចីសង្ខារ រលត់ទៅផង ក្នុងភង្គក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ ។ មួយយ៉ាង ទៀត វចីសង្ខារ របស់សត្វណា រលត់ទៅ កាយសង្ខារ របស់សត្វនោះ

រលត់ទៅឬ ។ វចីសង្ខារ របស់សត្វទាំងនោះ រលត់ទៅ ក្នុងកង្គក្ខណៈនៃពួក វិតក្ក និងវិចារ ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ តែកាយសង្ខារ របស់សត្វទាំងនោះ មិនរលត់ទៅទេ វចីសង្ខារ របស់សត្វជាកាមាវចរទាំង នោះ ដែលចូលកាន់បឋមជ្ឈានរលត់ទៅផង កាយសង្ខារ រលត់ទៅផង ក្នុងកង្គក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ ។

[ ៣២៤ ] កាយសង្ខារ របស់សត្វណា រលត់ទៅ ចិត្តសង្ខារ របស់ សត្វនោះ រលត់ទៅឬ ។ អើ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា រលត់ទៅ កាយសង្ខារ របស់សត្វនោះ រលត់ទៅឬ ។ ចិត្តសង្ខារ របស់ សត្វទាំងនោះ រលត់ទៅ ក្នុងកង្គក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ តែកាយសង្ខារ របស់សត្វទាំងនោះ មិនរលត់ទៅទេ ចិត្ត-សង្ខារ របស់សត្វទាំងនោះ រលត់ទៅផង កាយសង្ខារ រលត់ទៅផង ក្នុង កង្គក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ ។

[ ៣២៥ ] វចីសង្ខារ របស់សត្វណា រលត់ទៅ ចិត្តសង្ខារ របស់សត្វ នោះ រលត់ទៅឬ ។ អើ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា រលត់ ទៅ វចីសង្ខារ របស់សត្វនោះ រលត់ទៅឬ ។ ចិត្តសង្ខារ របស់សត្វទាំង នោះ រលត់ទៅ ក្នុងកង្គក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកវិតក្ក និងវិចារ តែ វចីសង្ខារ របស់សត្វទាំងនោះ មិនរលត់ទៅទេ ចិត្តសង្ខារ របស់សត្វទាំង នោះ រលត់ទៅផង វចីសង្ខារ រលត់ទៅផង ក្នុងកង្គក្ខណៈនៃពួកវិតក្ក និង វិចារ ។

[ ៣២៦ ] កាយសង្ខារ រលត់ទៅក្នុងទីណា វចីសង្ខារ រលត់ទៅក្នុងទីនោះឬ ។ កាយសង្ខារ រលត់ទៅក្នុងទុតិយជ្ឈាន និងក្នុងតតិយជ្ឈាន ក្នុងទីនោះ តែវចីសង្ខារ មិនរលត់ទៅ ក្នុងទីនោះទេ ។បេ។

[ ៣២៧ ] កាយសង្ខារ របស់សត្វណា រលត់ទៅក្នុងទីណា វចីសង្ខារ របស់សត្វនោះ រលត់ទៅក្នុងទីនោះឬ ។បេ។ ពាក្យថា របស់សត្វណាក្តី ថា របស់សត្វណា ក្នុងទីណាក្តី ដូចៗ គ្នា ។

[ ៣២៨ ] កាយសង្ខារ របស់សត្វណា មិនរលត់ទៅ វចីសង្ខារ របស់សត្វនោះ មិនរលត់ទៅឬ ។ កាយសង្ខារ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងភង្គក្ខណៈនៃពួកវិតក្ក និងវិចារ ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ តែវចីសង្ខារ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ កាយសង្ខារ របស់ពួកសត្វទាំងអស់ ដែលចូលកាន់និរោធ និងរបស់អសញ្ញសត្វទាំងនោះ មិនរលត់ទៅផង វចីសង្ខារ មិនរលត់ទៅផង ក្នុងឧប្បាទក្ខណៈនៃចិត្ត និងក្នុងភង្គក្ខណៈនៃចិត្តដែលមិនមានវិតក្ក មិនមានវិចារ ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា មិនរលត់ទៅ កាយសង្ខារ របស់សត្វនោះ មិនរលត់ទៅឬ ។ វចីសង្ខារ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងភង្គក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ ព្រោះវៀរចាកពួកវិតក្ក និងវិចារ តែកាយសង្ខារ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ វចីសង្ខារ របស់សត្វទាំងអស់ ដែលចូលកាន់និរោធ និងរបស់អសញ្ញសត្វទាំងនោះ មិនរលត់ទៅផង កាយសង្ខារ មិនរលត់ទៅផង ក្នុង

ឧប្បាទក្ខណៈនៃចិត្ត និងក្នុងភង្គក្ខណៈនៃចិត្ត ដែលមិនមានវិតក្ក មិនមានវិចារ ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ ។

[ ៣២៩ ] កាយសង្ខារ របស់សត្វណា មិនរលត់ទៅ ចិត្តសង្ខារ របស់សត្វនោះ មិនរលត់ទៅឬ ។ កាយសង្ខារ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងភង្គក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ តែចិត្តសង្ខារ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ កាយសង្ខារ របស់សត្វទាំងអស់ ដែលចូលកាន់និរោធ និងរបស់អសញ្ញសត្វទាំងនោះ មិនរលត់ទៅផង ចិត្តសង្ខារ មិនរលត់ទៅផង ក្នុងឧប្បាទក្ខណៈនៃចិត្ត ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា មិនរលត់ទៅ កាយសង្ខារ របស់សត្វនោះ មិនរលត់ទៅឬ ។ អើ ។

[ ៣៣០ ] វចីសង្ខារ របស់សត្វណា មិនរលត់ទៅ ចិត្តសង្ខារ របស់សត្វនោះ មិនរលត់ទៅឬ ។ វចីសង្ខារ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងភង្គក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកវិតក្ក និងវិចារ តែចិត្តសង្ខារ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ វចីសង្ខារ របស់សត្វទាំងអស់ ដែលចូលកាន់និរោធ និងរបស់អសញ្ញសត្វទាំងនោះ មិនរលត់ទៅផង ចិត្ត-សង្ខារ មិនរលត់ទៅផង ក្នុងឧប្បាទក្ខណៈនៃចិត្ត ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា មិនរលត់ទៅ វចីសង្ខារ របស់សត្វនោះ មិនរលត់ទៅឬ ។ អើ ។

[ ៣៣១ ] កាយសង្ខារ មិនរលត់ទៅ ក្នុងទីណា ។បេ។

[ ៣៣២ ] កាយសង្ខារ របស់សត្វណា មិនរលត់ទៅ ក្នុងទីណា វចី-
សង្ខារ របស់សត្វនោះ មិនរលត់ទៅ ក្នុងទីនោះឬ ។ កាយសង្ខារ របស់
សត្វទាំងនោះ មិនរលត់ទៅ ក្នុងភង្គក្ខណៈនៃពួកវិតក្ក និងវិចារ ព្រោះវៀរ
ចាកពួកអស្សាសៈ និងបស្សាសៈ ក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំង
នោះ មិនមែនជាមិនរលត់ទៅ ក្នុងទីនោះទេ កាយសង្ខារ របស់សត្វទាំង
អស់ និងរបស់អសញ្ញសត្វទាំងនោះ មិនរលត់ទៅផង វចីសង្ខារ មិនរលត់
ទៅផង ក្នុងឧប្បាទក្ខណៈនៃចិត្ត និងក្នុងភង្គក្ខណៈនៃចិត្ត ដែលមិនមានវិតក្ក
មិនមានវិចារ ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ ក្នុងទីនោះ ។
មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា មិនរលត់ទៅ ក្នុងទីណា ។បេ។
ពាក្យថា របស់សត្វណាក្តី ពាក្យថា របស់សត្វណា ក្នុងទីណាក្តី ដូចៗ គ្នា
បណ្ឌិតគប្បីឲ្យពិស្តារផងចុះ ។ ពាក្យថា របស់ពួកសត្វដែលចូលកាន់និរោធ
បណ្ឌិតមិនគប្បីធ្វើក្នុងពាក្យថា របស់សត្វណា ក្នុងទីណាទេ ។

[ ៣៣៣ ] កាយសង្ខារ របស់សត្វណា រលត់ហើយ វចីសង្ខារ របស់
សត្វនោះ រលត់ហើយឬ ។ អើ ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វ
ណា ។បេ។ បុច្ឆា ជាអតីត ពាក្យថា របស់សត្វណាក្តី ពាក្យថា របស់សត្វ
ណា ក្នុងទីណាក្តី អនុលោមក្តី បច្ចនិយៈក្តី ដែលលោកចែកហើយ ក្នុង
ឧប្បាទវារៈ យ៉ាងណា បណ្ឌិតគប្បីចែកក្នុងនិរោធវារៈ ក៏យ៉ាងនោះដែរ ។
ការធ្វើឲ្យផ្សេងៗ គ្នា មិនមានឡើយ ។

[ ៣៣៤ ] កាយសង្ខារ របស់សត្វណា នឹងរលត់ទៅ វចីសង្ខារ របស់

សត្វនោះ នឹងរលត់ទៅឬ ។ អើ ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា នឹងរលត់ទៅ កាយសង្ខារ របស់សត្វនោះ នឹងរលត់ទៅឬ ។ ចិត្តជាទីបំផុត របស់ពួកសត្វជាកាមាវចរ នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃចិត្តជាទីបំផុត វចីសង្ខារ របស់ពួកសត្វជាកាមាវចរ និងរបស់ពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរ និងក្នុងអរូបាវចរ និងរបស់សត្វនោះៗ ដែលចូលកាន់រូបាវចរ និងកាន់អរូបាវចរហើយ នឹងបរិនិព្វាន កាលច្យុត នឹងរលត់ទៅ តែកាយសង្ខារ របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ វចីសង្ខារ របស់សត្វទាំងនោះ ក្រៅនេះ នឹងរលត់ទៅផង កាយសង្ខារ នឹងរលត់ទៅផង ។

[ ៣៣៥ ] កាយសង្ខារ របស់សត្វណា នឹងរលត់ទៅ ចិត្តសង្ខារ របស់សត្វនោះ នឹងរលត់ទៅឬ ។ អើ ។ មួយយ៉ាងទៀត ចិត្តសង្ខាររបស់សត្វណា នឹងរលត់ទៅ កាយសង្ខារ របស់សត្វនោះ នឹងរលត់ទៅឬ ។ ចិត្តជាទីបំផុត របស់ពួកសត្វជាកាមាវចរ នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃចិត្តជាទីបំផុត ចិត្តសង្ខារ របស់ពួកសត្វជាកាមាវចរ និងរបស់ពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរ និងក្នុងអរូបាវចរ និងរបស់ពួកសត្វនោះៗ ដែលចូលកាន់រូបាវចរ និងកាន់អរូបាវចរហើយ នឹងបរិនិព្វាន កាលច្យុត នឹងរលត់ទៅ តែកាយសង្ខារ របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ចិត្តសង្ខារ របស់ពួកសត្វ ក្រៅនេះ នឹងរលត់ទៅផង កាយសង្ខារ នឹងរលត់ទៅផង ។

[ ៣៣៦ ] វចីសង្ខារ របស់សត្វណា នឹងរលត់ទៅ ចិត្តសង្ខារ របស់សត្វនោះ នឹងរលត់ទៅឬ ។ អើ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងរលត់ទៅ វចីសង្ខារ របស់សត្វនោះ នឹងរលត់ទៅឬ ។ ចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ នឹងកើតឡើង ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ ចិត្តសង្ខារ របស់សត្វទាំងនោះ នឹងរលត់ទៅ តែវចីសង្ខារ របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ ចិត្តសង្ខារ របស់ពួកសត្វ ក្រៅនេះ នឹងរលត់ទៅផង វចីសង្ខារ នឹងរលត់ទៅផង ។

[ ៣៣៧ ] កាយសង្ខារ នឹងរលត់ទៅ ក្នុងទីណា ។បេ។

[ ៣៣៨ ] កាយសង្ខារ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា វចីសង្ខារ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះឬ ។ កាយសង្ខារ របស់សត្វទាំងនោះ ដែលចូលកាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន នឹងរលត់ទៅក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ កាយសង្ខារ របស់ពួកសត្វដែលចូលកាន់បឋមជ្ឈាន និងរបស់ពួកសត្វជាកាមាវចរទាំងនោះ នឹងរលត់ទៅផង វចីសង្ខារ នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា កាយសង្ខារ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះឬ ។ ចិត្តជាទីបំផុត របស់ពួកសត្វជាកាមាវចរ នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃចិត្តជាទីបំផុត វចីសង្ខារ របស់ពួកសត្វជាកាមាវចរ និងរបស់ពួកសត្វ ជា

រូបាវចរ និងជាអរូបាវចរទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែកាយសង្ខារ របស់សត្វទាំងនោះ នឹងមិនរលត់ ក្នុងទីនោះទេ វចីសង្ខារ របស់សត្វជាកាមាវចរទាំងនោះ ក្រៅនេះ ដែលចូលកាន់បឋមជ្ឈាន នឹងរលត់ទៅផង កាយសង្ខារ នឹងរលត់ទៅផង ក្នុងទីនោះ ។

[ ៣៣៩ ] កាយសង្ខារ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ នឹងរលត់ទៅក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា កាយសង្ខារ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះឬ ។ ចិត្តជាទីបំផុតរបស់ពួកសត្វជាកាមាវចរ នឹងកើតឡើង ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃចិត្តជាទីបំផុត ចិត្តសង្ខារ របស់ពួកសត្វជាកាមាវចរ និងរបស់សត្វជារូបាវចរ និងជាអរូបាវចរទាំងនោះ ដែលចូលកាន់ចតុត្ថជ្ឈាន នឹងរលត់ទៅ ក្នុងទីនោះ តែកាយសង្ខារ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ ចិត្តសង្ខារ របស់សត្វ ជាកាមាវចរទាំងនោះ ក្រៅនេះ ដែលចូលកាន់បឋមជ្ឈាន កាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន នឹងរលត់ទៅផង កាយសង្ខារ នឹងរលត់ទៅផង ក្នុងទីនោះ ។

[ ៣៤០ ] វចីសង្ខារ របស់សត្វណា នឹងរលត់ទៅក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ នឹងរលត់ទៅក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងរលត់ទៅក្នុងទីណា វចីសង្ខារ របស់សត្វនោះ នឹងរលត់ទៅក្នុងទីនោះឬ ។ ចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ នឹងកើត

ឡើង ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ ចិត្តសង្ខារ របស់សត្វទាំងនោះ ដែលចូលកាន់ទុតិយជ្ឈាន កាន់តតិយជ្ឈាន និងកាន់ចតុត្ថជ្ឈាន នឹងរលត់ទៅ ក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ ចិត្តសង្ខារ របស់ពួកសត្វជាកាមាវចរ ដែលចូលកាន់បឋមជ្ឈាន និងរបស់សត្វជារូបាវចរ និងជាអរូបាវចរទាំងនោះ ក្រៅនេះ នឹងរលត់ទៅផង វចីសង្ខារ នឹងរលត់ទៅផង ក្នុងទីនោះ ។

[ ៣៤១ ] កាយសង្ខារ របស់សត្វណា នឹងមិនរលត់ទៅ វចីសង្ខារ របស់សត្វនោះ នឹងមិនរលត់ទៅឬ ។ ចិត្តជាទីបំផុតរបស់ពួកសត្វជាកាមាវចរ នឹងកើតឡើង ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃចិត្តជាទីបំផុត កាយសង្ខារ របស់ពួកសត្វជាកាមាវចរ និងរបស់ពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរ និងក្នុងអរូបាវចរ និងរបស់ពួកសត្វនោះៗ ដែលចូលកាន់រូបាវចរ និងកាន់អរូបាវចរហើយ នឹងបរិនិព្វាន កាលច្យុត នឹងមិនរលត់ទៅ តែវចីសង្ខារ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ របស់ពួកសត្វ ដែលប្រកបដោយចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ នឹងកើតឡើង ក្នុងលំដាប់នៃចិត្តណា ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ កាយសង្ខារ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង វចីសង្ខារ នឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា នឹងមិនរលត់ទៅ

កាយសង្ខារ របស់សត្វនោះ នឹងមិនរលត់ទៅឬ ។ អើ ។

[ ៣៤២ ] កាយសង្ខារ របស់សត្វណា នឹងមិនរលត់ទៅ ចិត្តសង្ខារ របស់សត្វនោះ នឹងមិនរលត់ទៅឬ ។ ចិត្តជាទីបំផុតរបស់ពួកសត្វជាកាមាវចរ នឹងកើតឡើង ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃចិត្តជាទីបំផុត កាយសង្ខារ របស់ពួកសត្វជាកាមាវចរ និងរបស់ពួកសត្វ ដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរ និងក្នុងអរូបាវចរ និងរបស់ពួកសត្វនោះៗ ដែលចូលកាន់រូបាវចរ និងកាន់អរូបាវចរហើយ នឹងបរិនិព្វាន កាលច្យុត នឹងមិនរលត់ទៅ តែចិត្តសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ កាយសង្ខារ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ចិត្តសង្ខារ នឹងមិនរលត់ទៅផង ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ។ មួយយ៉ាងទៀត ចិត្តសង្ខាររបស់សត្វណា នឹងមិនរលត់ទៅ កាយសង្ខាររបស់សត្វនោះ នឹងមិនរលត់ទៅឬ ។ អើ ។

[ ៣៤៣ ] វចីសង្ខារ របស់សត្វណា នឹងមិនរលត់ទៅ ចិត្តសង្ខារ របស់សត្វនោះ នឹងមិនរលត់ទៅឬ ។ ចិត្តជាទីបំផុតដែលមិនមានវិតក្ក មិនមានវិចារ នឹងកើតឡើង ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ វចីសង្ខារ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ តែចិត្តសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ វចីសង្ខារ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង ចិត្តសង្ខារ នឹងមិនរលត់ទៅផង ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ។ មួយយ៉ាងទៀត ចិត្តសង្ខារ

របស់សត្វណា នឹងមិនរលត់ទៅ វចីសង្ខារ របស់សត្វនោះ នឹងមិនរលត់ទៅ ឬ ។ អើ ។

[ ៣៤៤ ] កាយសង្ខារ នឹងមិនរលត់ទៅ ក្នុងទីណា ។បេ។

[ ៣៤៥ ] កាយសង្ខារ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា វចីសង្ខាររបស់សត្វនោះ នឹងមិនរលត់ទៅក្នុងទីនោះឬ ។ ចិត្តជាទីបំផុតរបស់ពួកសត្វជាកាមាវចរ នឹងកើតឡើង ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃចិត្តជាទីបំផុត កាយសង្ខារ របស់ពួកសត្វជាកាមាវចរ និងរបស់ពួកសត្វជារូបាវចរ និងជាអរូបាវចរទាំងនោះ នឹងមិនរលត់ទៅក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ចិត្តជាទីបំផុតដែលមិនមានវិតក្កៈ មិនមានវិចាររបស់ពួកសត្វ ដែលប្រកបដោយចិត្តជាទីបំផុត ដែលមិនមានវិតក្កៈ មិនមានវិចារ នឹងកើតឡើង ក្នុងលំដាប់នៃចិត្តណា ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារ កាយសង្ខារ របស់ពួកសត្វ ដែលចូលកាន់ចតុត្ថជ្ឈាន និងរបស់អសញ្ញសត្វទាំងនោះ នឹងមិនរលត់ទៅផង វចីសង្ខារ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា កាយ-សង្ខារ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះឬ ។ វចីសង្ខារ របស់សត្វទាំងនោះ ដែលចូលកាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន នឹងមិនរលត់ទៅក្នុងទីនោះ តែកាយសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ចិត្តជាទីបំផុត ដែលមិនមានវិតក្កៈ មិនមានវិចារ របស់ពួក

សត្វដែលប្រកបដោយចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ នឹងកើតឡើង ក្នុងលំដាប់នៃចិត្តណា ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ វចីសង្ខារ របស់ពួកសត្វដែលចូលកាន់ចតុត្ថជ្ឈាន និងរបស់អសញ្ញសត្វទាំងនោះ នឹងមិនរលត់ទៅផង កាយសង្ខារ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។

[ ៣៤៦ ] កាយសង្ខារ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះឬ ។ ចិត្តជាទីបំផុត របស់ពួកសត្វជាកាមាវចរ នឹងកើតឡើង ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃចិត្តជាទីបំផុត កាយសង្ខារ របស់ពួកសត្វជាកាមាវចរ និងរបស់ពួកសត្វជារូបាវចរ និងជាអរូបាវចរទាំងនោះ ដែលចូលកាន់ចតុត្ថជ្ឈាន នឹងមិនរលត់ទៅ ក្នុងទីនោះ តែចិត្តសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ កាយសង្ខារ របស់អសញ្ញសត្វទាំងនោះ នឹងមិនរលត់ទៅផង ចិត្តសង្ខារ នឹងមិនរលត់ទៅផង ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ក្នុងទីនោះ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា កាយសង្ខារ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះឬ ។ អើ ។

[ ៣៤៧ ] វចីសង្ខារ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះឬ ។ ចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ នឹងកើតឡើង ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ វចីសង្ខារ

របស់សត្វទាំងនោះ ដែលចូលកាន់ទុតិយជ្ឈាន កាន់តតិយជ្ឈាន និងកាន់ចតុត្ថជ្ឈាន នឹងមិនរលត់ទៅ ក្នុងទីនោះ តែចិត្តសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ វចីសង្ខារ របស់អសញ្ញសត្វទាំងនោះ នឹងមិនរលត់ទៅផង ចិត្តសង្ខារ នឹងមិនរលត់ទៅផង ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុតក្នុងទីនោះ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា វចីសង្ខារ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះឬ ។ អើ ។

[ ៣៤៨ ] កាយសង្ខាររបស់សត្វណា រលត់ទៅ វចីសង្ខាររបស់សត្វនោះ រលត់ហើយឬ ។ អើ ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា រលត់ហើយ កាយសង្ខារ របស់សត្វនោះ រលត់ទៅឬ ។ វចីសង្ខាររបស់សត្វទាំងអស់ ដែលចូលកាន់និរោធ និងរបស់អសញ្ញសត្វទាំងនោះ រលត់ហើយ ក្នុងឧប្បាទក្ខណៈនៃចិត្ត និងក្នុងភង្គក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ តែកាយសង្ខារ របស់សត្វទាំងនោះ មិនរលត់ទៅទេ វចីសង្ខារ របស់សត្វទាំងនោះ រលត់ហើយផង កាយសង្ខារ រលត់ទៅផង ក្នុងភង្គក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ ។

[ ៣៤៩ ] កាយសង្ខាររបស់សត្វណា រលត់ទៅ ចិត្តសង្ខាររបស់សត្វនោះ រលត់ហើយឬ ។ អើ ។ មួយយ៉ាងទៀត ចិត្តសង្ខាររបស់សត្វណា រលត់ហើយ កាយសង្ខាររបស់សត្វនោះ រលត់ទៅឬ ។ ចិត្តសង្ខាររបស់សត្វទាំងអស់ ដែលចូលកាន់និរោធ និងរបស់អសញ្ញសត្វទាំងនោះ រលត់ហើយ

ក្នុងឧប្បាទក្ខណៈនៃចិត្ត និងក្នុងភង្គក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ តែកាយសង្ខារ របស់សត្វទាំងនោះ មិនរលត់ទៅទេ ចិត្តសង្ខារ របស់សត្វទាំងនោះ រលត់ហើយផង កាយសង្ខារ រលត់ទៅផង ក្នុងភង្គក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ ។

[ ៣៥០ ] វចីសង្ខារ របស់សត្វណា រលត់ទៅ ចិត្តសង្ខារ របស់សត្វនោះ រលត់ហើយឬ ។ អើ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា រលត់ហើយ វចីសង្ខារ របស់សត្វនោះ រលត់ទៅឬ ។ ចិត្តសង្ខារ របស់សត្វទាំងអស់ ដែលចូលកាន់និរោធ និងរបស់អសញ្ញសត្វទាំងនោះ រលត់ហើយ ក្នុងឧប្បាទក្ខណៈនៃចិត្ត និងក្នុងភង្គក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកវិតក្ក និងវិចារ តែវចីសង្ខារ របស់សត្វទាំងនោះ មិនរលត់ទៅទេ ចិត្តសង្ខារ របស់សត្វទាំងនោះ រលត់ហើយផង វចីសង្ខារ រលត់ទៅផង ក្នុងភង្គក្ខណៈនៃពួកវិតក្ក និងវិចារ ។

[ ៣៥១ ] កាយសង្ខារ រលត់ទៅ ក្នុងទីណា ។បេ។

[ ៣៥២ ] កាយសង្ខារ របស់សត្វណា រលត់ទៅ ក្នុងទីណា វចីសង្ខារ របស់សត្វនោះ រលត់ហើយ ក្នុងទីនោះឬ ។ កាយសង្ខារ របស់សត្វទាំងនោះ ដែលចូលកាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន រលត់ទៅ ក្នុងភង្គក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ ក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះទេ កាយសង្ខារ របស់ពួកសត្វជាកាមាវចរទាំងនោះ ដែលចូលកាន់បឋមជ្ឈាន រលត់ទៅផង វចីសង្ខារ រលត់ហើយ

ផង ក្នុងភង្គក្ខណៈនៃពួកអសញ្ញសត្វ និងបសញ្ញសត្វ ក្នុងទីនោះ ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា រលត់ហើយ ក្នុងទីណា កាយសង្ខារ របស់សត្វនោះ រលត់ទៅ ក្នុងទីនោះឬ ។ វចីសង្ខារ របស់ពួកសត្វជាកាមាវចរទាំងនោះឯង ដែលចូលកាន់បឋមជ្ឈាន ក្នុងឧប្បាទក្ខណៈនៃពួកអសញ្ញសត្វ និងបសញ្ញសត្វ និងរបស់ពួកសត្វជារូបាវចរ និងជាអរូបាវចរទាំងនោះ ក្នុងភង្គក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអសញ្ញសត្វ និងបសញ្ញសត្វ រលត់ហើយក្នុងទីនោះ តែកាយសង្ខារ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះទេ វចីសង្ខារ របស់ពួកសត្វជាកាមាវចរទាំងនោះ ដែលចូលកាន់បឋមជ្ឈាន រលត់ហើយផង កាយសង្ខារ រលត់ទៅផង ក្នុងភង្គក្ខណៈនៃពួកអសញ្ញសត្វ និងបសញ្ញសត្វ ក្នុងទីនោះ ។

[ ៣៥៣ ] កាយសង្ខារ របស់សត្វណា រលត់ទៅ ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ រលត់ហើយក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា រលត់ហើយ ក្នុងទីណា កាយសង្ខារ របស់សត្វនោះ រលត់ទៅ ក្នុងទីនោះឬ ។ ចិត្តសង្ខារ របស់សត្វទាំងអស់នោះ រលត់ហើយ ក្នុងឧប្បាទក្ខណៈនៃចិត្ត និងក្នុងភង្គក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអសញ្ញសត្វ និងបសញ្ញសត្វ ក្នុងទីនោះ តែកាយសង្ខារ របស់សត្វទាំងនោះ មិនរលត់ទៅក្នុងទីនោះទេ ចិត្តសង្ខារ របស់សត្វទាំងនោះ រលត់ហើយផង កាយសង្ខារ រលត់ទៅផង ក្នុងភង្គក្ខណៈនៃពួកអសញ្ញសត្វ និងបសញ្ញសត្វ ក្នុងទីនោះ ។

[ ៣៥៤ ] វចីសង្ខារ របស់សត្វណា រលត់ទៅ ក្នុងទីណា ចិត្តសង្ខារ

របស់សត្វនោះ រលត់ហើយ ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត ចិត្ត-សង្ខារ របស់សត្វណា រលត់ហើយ ក្នុងទីណា វចីសង្ខារ របស់សត្វនោះ រលត់ទៅ ក្នុងទីនោះឬ ។ ចិត្តសង្ខារ របស់សត្វទាំងអស់នោះ រលត់ហើយ ក្នុងឧប្បាទក្ខណៈនៃចិត្ត និងក្នុងភង្គក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកវិតក្ក និង វិចារ ក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំងនោះ មិនរលត់ទៅក្នុងទីនោះទេ ចិត្តសង្ខារ របស់សត្វទាំងនោះ រលត់ហើយផង វចីសង្ខារ រលត់ទៅផង ក្នុងភង្គក្ខណៈនៃពួកវិតក្ក និងវិចារ ក្នុងទីនោះ ។

[ ៣៥៥ ] កាយសង្ខារ របស់សត្វណា មិនរលត់ទៅ វចីសង្ខារ របស់ សត្វនោះ មិនរលត់ហើយឬ ។ រលត់ហើយ ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា មិនរលត់ហើយ កាយសង្ខារ របស់សត្វនោះ មិនរលត់ ទៅឬ ។ មិនមានទេ ។

[ ៣៥៦ ] កាយសង្ខារ របស់សត្វណា មិនរលត់ទៅ ចិត្តសង្ខារ របស់ សត្វនោះ មិនរលត់ហើយឬ ។ រលត់ហើយ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា មិនរលត់ហើយ កាយសង្ខារ របស់សត្វនោះ មិនរលត់ទៅ ឬ ។ មិនមានទេ ។

[ ៣៥៧ ] វចីសង្ខារ របស់សត្វណា មិនរលត់ទៅ ចិត្តសង្ខារ របស់ សត្វនោះ មិនរលត់ហើយឬ ។ រលត់ហើយ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា មិនរលត់ហើយ វចីសង្ខារ របស់សត្វនោះ មិនរលត់ទៅ ឬ ។ មិនមានទេ ។

[ ៣៥៨ ] កាយសង្ខារ មិនរលត់ទៅ ក្នុងទីណា ។បេ។

[ ៣៥៩ ] កាយសង្ខារ របស់សត្វណា មិនរលត់ទៅ ក្នុងទីណា វចីសង្ខារ របស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះឬ ។ កាយសង្ខារ របស់ពួកសត្វជាកាមាវចរទាំងនោះឯង ដែលចូលកាន់បឋមជ្ឈាន ក្នុងឧប្បាទក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ និងរបស់ពួកសត្វជារូបាវចរ និងជាអរូបាវចរទាំងនោះ ក្នុងភង្គក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ មិនរលត់ទៅ ក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយ ក្នុងទីនោះទេ កាយសង្ខារ របស់សត្វទាំងនោះឯង ដែលចូលកាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន ក្នុងឧប្បាទក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ និងរបស់ពួកសត្វដែលចូលកាន់ចតុត្ថជ្ឈាន ក្នុងភង្គក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ និងរបស់ពួកសុទ្ធាវាសសត្វ ក្នុងចិត្តទី ២ កំពុងប្រព្រឹត្តទៅ និងរបស់អសញ្ញសត្វទាំងនោះ មិនរលត់ទៅផង វចីសង្ខារ មិនរលត់ហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វចីសង្ខាររបស់សត្វណា មិនរលត់ហើយ ក្នុងទីណា កាយសង្ខាររបស់សត្វនោះ មិនរលត់ទៅក្នុងទីនោះឬ ។ វចីសង្ខារ របស់សត្វទាំងនោះ ដែលចូលកាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន មិនរលត់ហើយ ក្នុងភង្គក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ ក្នុងទីនោះ តែកាយសង្ខារ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅ ក្នុងទីនោះទេ វចីសង្ខារ របស់សត្វទាំងនោះឯង ដែលចូលកាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន ក្នុង

ឧប្បាទក្ខណៈនៃពួកអសញ្ញសៈ និងបសញ្ញសៈ និងរបស់ពួកសត្វដែលចូលកាន់ចតុត្ថជ្ឈាន ក្នុងភង្គក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអសញ្ញសៈ និងបសញ្ញសៈ និងរបស់ពួកសុទ្ធាវាសសត្វក្នុងចិត្តទី ២ កំពុងប្រព្រឹត្តទៅ និងរបស់អសញ្ញសត្វទាំងនោះ មិនរលត់ហើយផង កាយសង្ខារ មិនរលត់ទៅផង ក្នុងទីនោះ ។

[ ៣៦០ ] កាយសង្ខារ របស់សត្វណា មិនរលត់ទៅ ក្នុងទីណា ចិត្តសង្ខាររបស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះឬ ។ កាយសង្ខារ របស់សត្វទាំងអស់នោះ មិនរលត់ទៅ ក្នុងឧប្បាទក្ខណៈនៃចិត្ត និងក្នុងភង្គក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអសញ្ញសៈ និងបសញ្ញសៈ ក្នុងទីនោះ តែចិត្តសង្ខាររបស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយ ក្នុងទីនោះទេ កាយសង្ខាររបស់ពួកសត្វដែលចូលកាន់សុទ្ធាវាស និងរបស់អសញ្ញសត្វទាំងនោះ មិនរលត់ទៅផង ចិត្តសង្ខារ មិនរលត់ហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា មិនរលត់ហើយ ក្នុងទីណា កាយសង្ខាររបស់សត្វនោះ មិនរលត់ទៅ ក្នុងទីនោះឬ ។ អើ ។

[ ៣៦១ ] វចីសង្ខារ របស់សត្វណា មិនរលត់ទៅក្នុងទីណា ចិត្តសង្ខាររបស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះឬ ។ វចីសង្ខារ របស់សត្វទាំងអស់នោះ មិនរលត់ទៅ ក្នុងឧប្បាទក្ខណៈនៃចិត្ត និងក្នុងភង្គក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកវិតក្ក និងវិចារក្នុងទីនោះ តែចិត្តសង្ខាររបស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយ ក្នុងទីនោះទេ វចីសង្ខារ របស់ពួកសត្វ កាលចូល

ទៅកាន់សុទ្ធាវាស និងរបស់អសញ្ញសត្វទាំងនោះ មិនរលត់ទៅផង ចិត្ត-សង្ខារ មិនរលត់ហើយផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ចិត្តសង្ខាររបស់សត្វណា មិនរលត់ហើយ ក្នុងទីណា វចីសង្ខារ របស់សត្វនោះ មិនរលត់ទៅ ក្នុងទីនោះឬ ។ អើ ។

[ ៣៦២ ] កាយសង្ខារ របស់សត្វណា រលត់ទៅ វចីសង្ខារ របស់សត្វនោះ នឹងរលត់ទៅឬ ។ អើ ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា នឹងរលត់ទៅ កាយសង្ខារ របស់សត្វនោះ រលត់ទៅឬ ។ វចីសង្ខារ របស់សត្វទាំងអស់ ដែលចូលកាន់និរោធ និងរបស់អសញ្ញសត្វទាំងនោះ នឹងរលត់ទៅក្នុងឧប្បាទក្ខណៈនៃចិត្ត និងក្នុងភង្គក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ តែកាយសង្ខាររបស់សត្វទាំងនោះ មិនរលត់ទៅទេ វចីសង្ខារ របស់សត្វទាំងនោះ នឹងរលត់ទៅផង កាយសង្ខាររលត់ទៅផង ក្នុងភង្គក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ ។

[ ៣៦៣ ] កាយសង្ខារ របស់សត្វណា រលត់ទៅ ចិត្តសង្ខារ របស់សត្វនោះ នឹងរលត់ទៅឬ ។ អើ ។ មួយយ៉ាងទៀត ចិត្តសង្ខាររបស់សត្វណា នឹងរលត់ទៅ កាយសង្ខារ របស់សត្វនោះ រលត់ទៅឬ ។ ចិត្តសង្ខារ របស់សត្វទាំងអស់ ដែលចូលកាន់និរោធ និងរបស់អសញ្ញសត្វទាំងនោះ នឹងរលត់ទៅ ក្នុងឧប្បាទក្ខណៈនៃចិត្ត និងក្នុងភង្គក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ តែកាយសង្ខារ របស់សត្វទាំងនោះ មិនរលត់ទៅទេ ចិត្តសង្ខារ របស់សត្វទាំងនោះ នឹងរលត់ទៅផង កាយសង្ខារ

រលត់ទៅផង ក្នុងកង្គក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ ។

[ ៣៦៤ ] វចីសង្ខារ របស់សត្វណា រលត់ទៅ ចិត្តសង្ខារ របស់សត្វនោះ នឹងរលត់ទៅឬ ។ វចីសង្ខារ របស់សត្វទាំងនោះ រលត់ទៅ ក្នុងកង្គក្ខណៈនៃចិត្តជាទីបំផុត ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ តែចិត្តសង្ខារ របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ វចីសង្ខារ របស់សត្វទាំងនោះ ក្រៅនេះ រលត់ទៅផង ចិត្តសង្ខារ នឹងរលត់ទៅផង ក្នុងកង្គក្ខណៈនៃពួកវិតក្ក និងវិចារ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងរលត់ទៅ វចីសង្ខាររបស់សត្វនោះ រលត់ទៅឬ ។ ចិត្តសង្ខារ របស់សត្វទាំងអស់ ដែលចូលកាន់និរោធ និងរបស់អសញ្ញសត្វទាំងនោះ នឹងរលត់ទៅក្នុងឧប្បាទក្ខណៈនៃចិត្ត និងក្នុងកង្គក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកវិតក្ក និងវិចារ តែវចីសង្ខារ របស់សត្វទាំងនោះ មិនរលត់ទៅទេ ចិត្តសង្ខារ របស់សត្វទាំងនោះ នឹងរលត់ទៅផង វចីសង្ខាររលត់ទៅផង ក្នុងកង្គក្ខណៈនៃពួកវិតក្ក និងវិចារ ។

[ ៣៦៥ ] កាយសង្ខារ រលត់ទៅ ក្នុងទីណា ។បេ។

[ ៣៦៦ ] កាយសង្ខារ របស់សត្វណា រលត់ទៅ ក្នុងទីណា វចីសង្ខារ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះឬ ។ កាយសង្ខារ របស់សត្វទាំងនោះ ដែលចូលកាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន រលត់ទៅក្នុងកង្គក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ ក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ កាយសង្ខារ របស់ពួកសត្វ ដែលចូល

កាន់បឋមជ្ឈាន និងរបស់ពួកសត្វជាកាមាវចរទាំងនោះ រលត់ទៅផង វចី-សង្ខារ នឹងរលត់ទៅផង ក្នុងភង្គក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ ក្នុងទីនោះ ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា កាយសង្ខារ របស់សត្វនោះ រលត់ទៅ ក្នុងទីនោះឬ ។ វចីសង្ខារ របស់ពួកសត្វជាកាមាវចរទាំងនោះឯង ដែលចូលកាន់បឋមជ្ឈាន ក្នុងឧប្បាទក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ និងរបស់ពួកសត្វជារូបាវចរ និងជាអរូ-បាវចរទាំងនោះ ក្នុងភង្គក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ នឹងរលត់ទៅ ក្នុងទីនោះ តែកាយសង្ខារ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះទេ វចីសង្ខារ របស់សត្វជាកាមាវចរទាំងនោះ ដែលចូលកាន់បឋមជ្ឈាន នឹងរលត់ទៅផង កាយសង្ខារ រលត់ទៅផង ក្នុងភង្គក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ ក្នុងទីនោះ ។

[ ៣៦៧ ] កាយសង្ខារ របស់សត្វណា រលត់ទៅ ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត ចិត្ត-សង្ខារ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា កាយសង្ខារ របស់សត្វនោះ រលត់ទៅ ក្នុងទីនោះឬ ។ ចិត្តសង្ខារ របស់សត្វទាំងអស់នោះ នឹងរលត់ទៅ ក្នុងឧប្បាទក្ខណៈនៃចិត្ត និងក្នុងភង្គក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ ក្នុងទីនោះ តែកាយសង្ខារ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះទេ ចិត្តសង្ខារ របស់សត្វទាំងនោះ នឹងរលត់ទៅផង កាយសង្ខារ រលត់ទៅផង ក្នុងភង្គក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ

ក្នុងទីនោះ ។

[ ៣៦៨ ] វចីសង្ខារ របស់សត្វណា រលត់ទៅ ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះឬ ។ វចីសង្ខារ របស់សត្វទាំងនោះ រលត់ទៅក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ក្នុងទីនោះ តែចិត្តសង្ខារ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ វចីសង្ខារ របស់សត្វទាំងនោះ ក្រៅនេះ រលត់ទៅផង ចិត្តសង្ខារ នឹងរលត់ទៅផង ក្នុងភង្គក្ខណៈនៃពួកវិតក្ក និងវិចារ ក្នុងទីនោះ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា វចីសង្ខារ របស់សត្វនោះ រលត់ទៅ ក្នុងទីនោះឬ ។ ចិត្តសង្ខារ របស់សត្វទាំងអស់នោះ នឹងរលត់ទៅ ក្នុងឧប្បាទក្ខណៈនៃចិត្ត និងក្នុងភង្គក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកវិតក្ក និងវិចារ ក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងទីនោះទេ ចិត្តសង្ខារ របស់សត្វទាំងនោះ នឹងរលត់ទៅផង វចីសង្ខារ រលត់ទៅផង ក្នុងភង្គក្ខណៈនៃពួកវិតក្ក និងវិចារ ក្នុងទីនោះ ។

[ ៣៦៩ ] កាយសង្ខារ របស់សត្វណា មិនរលត់ទៅ វចីសង្ខារ របស់សត្វនោះ នឹងមិនរលត់ទៅឬ ។ កាយសង្ខារ របស់សត្វទាំងអស់ ដែលចូលកាន់និរោធ និងរបស់អសញ្ញសត្វទាំងនោះ មិនរលត់ទៅ ក្នុងឧប្បាទក្ខណៈនៃចិត្ត និងក្នុងភង្គក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ តែវចីសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ ចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចាររបស់ពួកសត្វ ដែលប្រកបដោយចិត្ត

ជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ នឹងកើតឡើងក្នុងលំដាប់នៃចិត្ត ណា ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ដែលប្រកបដោយវិតក្ក ប្រកបដោយ វិចារ កាយសង្ខារ របស់សត្វទាំងនោះ មិនរលត់ទៅផង វចីសង្ខារ នឹងមិន រលត់ទៅផង ។ មួយយ៉ាងទៀត វចីសង្ខាររបស់សត្វណា នឹងមិនរលត់ទៅ កាយសង្ខាររបស់សត្វនោះ មិនរលត់ទៅឬ ។ អើ ។

[ ៣៧០ ] កាយសង្ខារ របស់សត្វណា មិនរលត់ទៅ ចិត្តសង្ខារ របស់សត្វនោះ នឹងមិនរលត់ទៅឬ ។ កាយសង្ខារ របស់សត្វទាំងអស់ ដែលចូលកាន់និរោធ និងរបស់អសញ្ញសត្វទាំងនោះ មិនរលត់ទៅក្នុងឧប្បា-ទក្ខណៈនៃចិត្ត និងក្នុងភង្គក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និង បស្សាសៈ តែចិត្តសង្ខាររបស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ កាយសង្ខាររបស់សត្វទាំងនោះ មិនរលត់ទៅផង ចិត្តសង្ខារ នឹងមិនរលត់ ទៅផង ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ។ មួយយ៉ាងទៀត ចិត្តសង្ខាររបស់ សត្វណា ។បេ។ អើ ។

[ ៣៧១ ] វចីសង្ខារ របស់សត្វណា មិនរលត់ទៅ ចិត្តសង្ខារ របស់ សត្វនោះ នឹងមិនរលត់ទៅឬ ។ វចីសង្ខារ របស់សត្វទាំងអស់ ដែលចូល កាន់និរោធ និងរបស់អសញ្ញសត្វទាំងនោះ មិនរលត់ទៅក្នុងឧប្បាទក្ខណៈនៃ ចិត្ត និងក្នុងភង្គក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកវិតក្ក និងវិចារ តែចិត្តសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ វចីសង្ខារ របស់សត្វទាំង នោះ មិនរលត់ទៅផង ចិត្តសង្ខារ នឹងមិនរលត់ទៅផង ក្នុងភង្គក្ខណៈនៃចិត្ត

ជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងមិនរលត់ទៅ វចីសង្ខារ របស់សត្វនោះ មិនរលត់ទៅឬ ។ ចិត្តសង្ខារ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ តែវចីសង្ខារ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ ចិត្តសង្ខារ របស់សត្វទាំងនោះ នឹងមិនរលត់ទៅផង វចីសង្ខារ មិនរលត់ទៅផង ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ ។

[ ៣៧២ ] កាយសង្ខារ មិនរលត់ទៅ ក្នុងទីណា ។បេ។

[ ៣៧៣ ] កាយសង្ខារ របស់សត្វណា មិនរលត់ទៅ ក្នុងទីណា វចី-សង្ខារ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះឬ ។ កាយសង្ខារ របស់ពួកសត្វជាកាមាវចរទាំងនោះឯង ដែលចូលកាន់បឋមជ្ឈាន និងរបស់ពួកសត្វជារូបាវចរ និងជាអរូបាវចរទាំងនោះ មិនរលត់ទៅក្នុង ឧប្បាទក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ និងក្នុងភង្គក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ ក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចាររបស់ពួកសត្វ ដែលប្រកបដោយចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ កាយសង្ខារ របស់សត្វទាំងនោះឯង ដែលចូលកាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន និងរបស់ពួក

សត្វដែលចូលកាន់ចតុត្ថជ្ឈាន និងរបស់អសញ្ញសត្វទាំងនោះ មិនរលត់ទៅផង វចីសង្ខារ នឹងមិនរលត់ទៅផង ក្នុងឧប្បាទក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ និងក្នុងភង្គក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ ក្នុងទីនោះ ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា កាយសង្ខារ របស់សត្វនោះ មិនរលត់ទៅ ក្នុងទីនោះឬ ។ វចីសង្ខារ របស់សត្វទាំងនោះ ដែលចូលកាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន នឹងមិនរលត់ទៅក្នុងភង្គក្ខណៈ នៃពួកអស្សាសៈ និងបស្សាសៈ ក្នុងទីនោះ តែកាយសង្ខារ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅក្នុងទីនោះទេ ចិត្តជាទីបំផុត ដែលមិនមានវិតក្កៈ មិនមានវិចារ របស់ពួកសត្វដែលប្រកបដោយចិត្តជាទីបំផុត ដែលមិនមានវិតក្កៈ មិនមានវិចារ នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ដែលប្រកបដោយវិតក្កៈ ប្រកបដោយវិចារ វចីសង្ខាររបស់សត្វទាំងនោះឯង ដែលចូលកាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន និងរបស់ពួកសត្វ ដែលចូលកាន់ចតុត្ថជ្ឈាន និងរបស់អសញ្ញសត្វទាំងនោះ នឹងមិនរលត់ទៅផង កាយសង្ខារ មិនរលត់ទៅផង ក្នុងឧប្បាទក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ និងក្នុងភង្គក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ ក្នុងទីនោះ ។

[ ៣៧៤ ] កាយសង្ខារ របស់សត្វណា មិនរលត់ទៅ ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះឬ ។ កាយសង្ខារ របស់សត្វទាំងអស់នោះ មិនរលត់ទៅ ក្នុងឧប្បាទក្ខណៈនៃចិត្ត និងក្នុងភង្គក្ខណៈ

នៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ ក្នុងទីនោះ តែចិត្តសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ កាយសង្ខារ របស់អសញ្ញសត្វទាំងនោះ មិនរលត់ទៅផង ចិត្តសង្ខារ នឹងមិនរលត់ទៅផង ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុតក្នុងទីនោះ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា កាយសង្ខារ របស់សត្វនោះ មិនរលត់ទៅ ក្នុងទីនោះឬ ។ អើ ។

[ ៣៧៥ ] វចីសង្ខារ របស់សត្វណា មិនរលត់ទៅ ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះឬ ។ វចីសង្ខារ របស់សត្វទាំងអស់នោះ មិនរលត់ទៅ ក្នុងឧប្បាទក្ខណៈនៃចិត្ត និងក្នុងភង្គក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកវិតក្ក និងវិចារ ក្នុងទីនោះ តែចិត្តសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ វចីសង្ខារ របស់អសញ្ញសត្វទាំងនោះ មិនរលត់ទៅផង ចិត្តសង្ខារ នឹងមិនរលត់ទៅផង ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ ក្នុងទីនោះ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា វចីសង្ខារ របស់សត្វនោះ មិនរលត់ទៅ ក្នុងទីនោះឬ ។ ចិត្តសង្ខារ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅ ក្នុងទីនោះទេ ចិត្តសង្ខាររបស់អសញ្ញសត្វទាំងនោះ នឹងមិនរលត់ទៅផង វចីសង្ខារ មិនរលត់ទៅផង ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត

ដែលមិនមានវិតក្ក មិនមានវិចារ ក្នុងទីនោះ ។

[ ៣៧៦ ] កាយសង្ខារ របស់សត្វណា រលត់ហើយ វចីសង្ខារ របស់សត្វនោះ នឹងរលត់ទៅឬ ។ ចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ របស់ពួកសត្វ ដែលប្រកបដោយចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ កាយសង្ខារ របស់សត្វទាំងនោះ រលត់ហើយ តែវចីសង្ខារ របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ កាយសង្ខារ របស់ពួកសត្វក្រៅនេះ រលត់ហើយផង វចីសង្ខារនឹងរលត់ទៅផង ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា ។បេ។ អើ ។

[ ៣៧៧ ] កាយសង្ខារ របស់សត្វណា រលត់ហើយ ចិត្តសង្ខារ របស់សត្វនោះ នឹងរលត់ទៅឬ ។ កាយសង្ខារ របស់សត្វទាំងនោះ រលត់ហើយ ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត តែចិត្តសង្ខារ របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ កាយសង្ខារ របស់ពួកសត្វក្រៅនេះ រលត់ហើយផង ចិត្តសង្ខារ នឹងរលត់ទៅផង ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា ។បេ។ អើ ។

[ ៣៧៨ ] កាយសង្ខារ រលត់ហើយ ក្នុងទីណា ។បេ។

[ ៣៧៩ ] កាយសង្ខារ របស់សត្វណា រលត់ហើយ ក្នុងទីណា វចីសង្ខារ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះឬ ។ កាយសង្ខារ របស់សត្វទាំងនោះ ដែលចូលកាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន រលត់ហើយ ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ក្នុងកាមាវចរ ក្នុងទីនោះ តែវចីសង្ខារ របស់

សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ កាយសង្ខារ របស់ពួកសត្វជាកាមាវចរទាំងនោះក្រៅនេះ ដែលចូលកាន់បឋមជ្ឈាន រលត់ហើយផង វចីសង្ខារ នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វចីសង្ខាររបស់សត្វណា នឹងរលត់ទៅ ក្នុងទីណា កាយសង្ខារ របស់សត្វនោះ រលត់ហើយ ក្នុងទីនោះឬ ។ វចីសង្ខារ របស់ពួកសត្វជារូបាវចរ និងជាអរូបាវចរទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែកាយសង្ខារ របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះទេ វចីសង្ខារ របស់សត្វជាកាមាវចរទាំងនោះ ដែលចូលកាន់បឋមជ្ឈាន នឹងរលត់ទៅផង កាយសង្ខារ រលត់ហើយផង ក្នុងទីនោះ ។

[ ៣៨០ ] កាយសង្ខារ របស់សត្វណា រលត់ហើយ ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះឬ ។ កាយសង្ខារ របស់សត្វទាំងនោះ រលត់ហើយ ក្នុងកង្ខណៈនៃចិត្តជាទីបំផុត ក្នុងកាមាវចរ ក្នុងទីនោះ តែចិត្តសង្ខាររបស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ កាយសង្ខារ របស់ពួកសត្វជាកាមាវចរនោះ ក្រៅនេះ ដែលចូលកាន់បឋមជ្ឈាន កាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន រលត់ហើយផង ចិត្តសង្ខារ នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា កាយសង្ខារ របស់សត្វនោះ រលត់ហើយ ក្នុងទីនោះឬ ។ ចិត្តសង្ខារ របស់ពួកសត្វជារូបាវចរ និងជាអរូបាវចរទាំងនោះ ដែលចូលកាន់ចតុត្ថជ្ឈាន នឹងរលត់ទៅ ក្នុងទីនោះ តែកាយសង្ខារ របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះទេ ចិត្តសង្ខារ របស់សត្វជាកាមាវចរ

ទាំងនោះ ដែលចូលកាន់បឋមជ្ឈាន កាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន នឹងរលត់ទៅផង កាយសង្ខារ រលត់ហើយផង ក្នុងទីនោះ ។

[ ៣៨១ ] វចីសង្ខារ របស់សត្វណា រលត់ហើយ ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះឬ ។ វចីសង្ខារ របស់សត្វទាំងនោះ រលត់ទៅ ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ក្នុងសវិតក្កសវិចារភូមិ ក្នុងទីនោះ តែចិត្តសង្ខារ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ វចីសង្ខារ របស់សត្វទាំងនោះ ក្រៅនេះ រលត់ហើយផង ចិត្តសង្ខារ នឹងរលត់ទៅផង ក្នុងសវិតក្កសវិចារភូមិ ក្នុងទីនោះ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា វចីសង្ខារ របស់សត្វនោះ រលត់ហើយ ក្នុងទីនោះឬ ។ ចិត្តសង្ខារ របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងអវិតក្កអវិចារភូមិ ក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំងនោះ មិនរលត់ហើយ ក្នុងទីនោះទេ ចិត្តសង្ខារ របស់សត្វទាំងនោះ នឹងរលត់ទៅផង វចីសង្ខារ រលត់ហើយផង ក្នុងសវិតក្កសវិចារភូមិ ក្នុងទីនោះ ។

[ ៣៨២ ] កាយសង្ខារ របស់សត្វណា មិនរលត់ហើយ វចីសង្ខារ របស់សត្វនោះ នឹងមិនរលត់ទៅឬ ។ មិនមានទេ ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា នឹងមិនរលត់ទៅ កាយសង្ខារ របស់សត្វនោះ មិនរលត់ហើយឬ ។ រលត់ហើយ ។

[ ៣៨៣ ] កាយសង្ខារ របស់សត្វណា មិនរលត់ហើយ ចិត្តសង្ខារ របស់សត្វនោះ នឹងមិនរលត់ទៅឬ ។ មិនមានទេ ។ មួយយ៉ាងទៀត ចិត្ត-

សង្ខារ របស់សត្វណា នឹងមិនរលត់ទៅ កាយសង្ខារ របស់សត្វនោះ មិនរលត់ហើយឬ ។ រលត់ហើយ ។

[ ៣៨៤ ] វចីសង្ខារ របស់សត្វណា មិនរលត់ហើយ ចិត្តសង្ខារ របស់សត្វនោះ នឹងមិនរលត់ទៅឬ ។ មិនមានទេ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងមិនរលត់ទៅ វចីសង្ខារ របស់សត្វនោះ មិនរលត់ទៅហើយឬ ។ រលត់ហើយ ។

[ ៣៨៥ ] កាយសង្ខារ មិនរលត់ហើយ ក្នុងទីណា ។បេ។

[ ៣៨៦ ] កាយសង្ខារ របស់សត្វណា មិនរលត់ហើយ ក្នុងទីណា វចីសង្ខារ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះឬ ។ កាយសង្ខារ របស់ពួកសត្វជារូបាវចរ និងជាអរូបាវចរទាំងនោះ មិនរលត់ហើយ ក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ របស់ពួកសត្វ ដែលប្រកបដោយចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ នឹងកើតឡើង ក្នុងលំដាប់នៃចិត្តណា ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ក្នុងរូបាវចរ និងអរូបាវចរ កាយសង្ខារ របស់ពួកសត្វ ដែលចូលកាន់ចតុត្ថជ្ឈាន និងរបស់អសញ្ញសត្វទាំងនោះ មិនរលត់ហើយផង វចីសង្ខារ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា កាយសង្ខារ របស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះឬ ។ វចីសង្ខារ របស់សត្វទាំងនោះ ដែលចូល

កាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន នឹងមិនរលត់ទៅ ក្នុងភង្គក្ខណៈនៃចិត្ត ជាទីបំផុត ក្នុងកាមាវចរ ក្នុងទីនោះ តែកាយសង្ខារ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយ ក្នុងទីនោះទេ ចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ របស់ពួកសត្វ ដែលប្រកបដោយចិត្តជាទីបំផុត ដែលមិនមាន វិតក្ក មិនមានវិចារ នឹងកើតឡើង ក្នុងលំដាប់នៃចិត្តណា ក្នុងភង្គក្ខណៈនៃ ចិត្តជាទីបំផុត ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ ក្នុងរូបាវចរ និង ក្នុងអរូបាវចរ វចីសង្ខារ របស់ពួកសត្វដែលចូលកាន់ចតុត្ថជ្ឈាន និងរបស់ អសញ្ញសត្វទាំងនោះ នឹងមិនរលត់ទៅផង កាយសង្ខារ មិនរលត់ហើយផង ក្នុងទីនោះ ។

[ ៣៨៧ ] កាយសង្ខារ របស់សត្វណា មិនរលត់ហើយ ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះឬ ។ កាយសង្ខារ របស់ពួកសត្វជារូបាវចរ និងជាអរូបាវចរទាំងនោះ ដែលចូលកាន់ចតុត្ថជ្ឈាន មិនរលត់ហើយ ក្នុងទីនោះ តែចិត្តសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹង មិនរលត់ទៅ ក្នុងទីនោះទេ កាយសង្ខារ របស់អសញ្ញសត្វទាំងនោះ មិន រលត់ហើយផង ចិត្តសង្ខារ មិនរលត់ទៅផង ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ក្នុងរូបាវចរ និងក្នុងអរូបាវចរក្នុងទីនោះ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់ សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា កាយសង្ខារ របស់សត្វនោះ មិន រលត់ហើយ ក្នុងទីនោះឬ ។ ចិត្តសង្ខារ របស់សត្វទាំងនោះ នឹងមិនរលត់ ទៅ ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ក្នុងកាមាវចរ ក្នុងទីនោះ តែកាយសង្ខារ

របស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយ ក្នុងទីនោះទេ ចិត្តសង្ខារ របស់អសញ្ញសត្វទាំងនោះ នឹងមិនរលត់ទៅផង កាយសង្ខារ មិនរលត់ហើយផង ក្នុងកង្គក្ខណៈនៃចិត្តជាទីបំផុត ក្នុងរូបាវចរ និងក្នុងអរូបាវចរ ក្នុងទីនោះ ។

[ ៣៨៨ ] វចីសង្ខារ របស់សត្វណា មិនរលត់ហើយ ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះឬ ។ វចីសង្ខារ របស់សត្វទាំងនោះ ក្នុងអវិតក្កអវិចារភូមិ មិនរលត់ហើយ ក្នុងទីនោះ តែចិត្តសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ វចីសង្ខារ របស់អសញ្ញសត្វទាំងនោះ មិនរលត់ហើយផង ចិត្តសង្ខារ នឹងមិនរលត់ទៅផង ក្នុងកង្គក្ខណៈនៃចិត្តជាទីបំផុត ក្នុងអវិតក្កអវិចារភូមិ ក្នុងទីនោះ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា វចីសង្ខារ របស់សត្វនោះ មិនរលត់ហើយ ក្នុងទីនោះឬ ។ ចិត្តសង្ខារ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងកង្គក្ខណៈនៃចិត្តជាទីបំផុត ក្នុងសវិតក្កសវិចារភូមិ ក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ហើយ ក្នុងទីនោះទេ ចិត្តសង្ខារ របស់អសញ្ញសត្វទាំងនោះ នឹងមិនរលត់ទៅផង វចីសង្ខារ មិនរលត់ហើយផង ក្នុងកង្គក្ខណៈនៃចិត្តជាទីបំផុត ក្នុងអវិតក្កអវិចារភូមិ ក្នុងទីនោះ ។

**និរោធវារៈ ចប់**

[ ៣៨៩ ] កាយសង្ខារ របស់សត្វណា កើតឡើង វចីសង្ខារ របស់សត្វនោះ រលត់ទៅឬ ។ មិនមែនទេ ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា រលត់ទៅ កាយសង្ខារ របស់សត្វនោះ កើតឡើងឬ ។ មិនមែនទេ ។ កាយសង្ខារ របស់សត្វណា កើតឡើង ចិត្តសង្ខារ របស់សត្វនោះ រលត់ទៅឬ ។ មិនមែនទេ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា រលត់ទៅ កាយសង្ខារ របស់សត្វនោះ កើតឡើងឬ ។ មិនមែនទេ ។ វចីសង្ខារ របស់សត្វណា កើតឡើង ចិត្តសង្ខារ របស់សត្វនោះ រលត់ទៅឬ ។ មិនមែនទេ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា រលត់ទៅ វចីសង្ខារ របស់សត្វនោះ កើតឡើងឬ ។ មិនមែនទេ ។ កាយសង្ខារ កើតឡើងក្នុងទីណា វចីសង្ខារ រលត់ទៅ ក្នុងទីនោះឬ ។ កាយសង្ខារ កើតឡើង ក្នុងទុតិយជ្ឈាន និងក្នុងតតិយជ្ឈាននោះ តែវចីសង្ខារ មិនរលត់ទៅ ក្នុងទីនោះទេ ។បេ។ ពាក្យថា របស់សត្វក្រៅនេះ ដូចគ្នានឹងពាក្យថា ក្នុងទីណា ។ កាយសង្ខារ របស់សត្វណា កើតឡើង ក្នុងទីណា ។បេ។ ពាក្យថា របស់សត្វណាក្តី ពាក្យថា របស់សត្វណា ក្នុងទីណាក្តី ដូចៗ គ្នា ។

[ ៣៩០ ] កាយសង្ខារ របស់សត្វណា មិនកើតឡើង វចីសង្ខារ របស់សត្វនោះមិនរលត់ទៅទេឬ ។ កាយសង្ខាររបស់សត្វទាំងនោះ មិនកើតឡើង ក្នុងភង្គក្ខណៈនៃពួកវិតក្ក និងវិចារ តែវចីសង្ខារ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ កាយសង្ខារ របស់ពួកសត្វ ដែលចូលកាន់និរោធ និងរបស់អសញ្ញសត្វទាំងនោះ មិនកើតឡើងផង វចីសង្ខារ មិនរលត់ទៅផង

ក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ និងក្នុងភង្គក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកវិតក្ក និងវិចារ ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា មិនរលត់ទៅ កាយសង្ខារ របស់សត្វនោះ មិនកើតឡើងឬ ។ វចីសង្ខារ របស់សត្វទាំងនោះ មិនរលត់ទៅ ក្នុងឧប្បាទក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ តែកាយសង្ខារ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ វចីសង្ខារ របស់ពួកសត្វ ដែលចូលកាន់និរោធ និងរបស់អសញ្ញសត្វទាំងនោះ រលត់ទៅផង កាយសង្ខារ មិនកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ និងក្នុងភង្គក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកវិតក្ក និងវិចារ ។

[ ៣៩១ ] កាយសង្ខារ របស់សត្វណា មិនកើតឡើង ចិត្តសង្ខារ របស់សត្វនោះ មិនរលត់ទៅឬ ។ កាយសង្ខារ របស់សត្វទាំងអស់នោះ មិនកើតឡើង ក្នុងភង្គក្ខណៈនៃចិត្ត តែចិត្តសង្ខារ របស់សត្វទាំងនោះ មិនមែនជាមិនរលត់ទៅទេ កាយសង្ខារ របស់ពួកសត្វ ដែលចូលកាន់និរោធ និងរបស់អសញ្ញសត្វទាំងនោះ មិនកើតឡើងផង ចិត្តសង្ខារ មិនរលត់ទៅផង ក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា មិនរលត់ទៅ កាយសង្ខារ របស់សត្វនោះ មិនកើតឡើងឬ ។ ចិត្តសង្ខារ របស់សត្វទាំងនោះ មិនរលត់ទៅក្នុងឧប្បាទក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ តែកាយសង្ខារ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើងទេ ចិត្តសង្ខារ របស់ពួកសត្វ ដែលចូល

កាន់និរោធ និងរបស់អសញ្ញសត្វទាំងនោះ មិនរលត់ទៅផង កាយសង្ខារ មិនកើតឡើងផង ក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និង បស្សាសៈ ។

[ ៣៩២ ] វចីសង្ខារ របស់សត្វណា មិនកើតឡើង ចិត្តសង្ខារ របស់ សត្វនោះ មិនរលត់ទៅឬ ។ វចីសង្ខារ របស់សត្វទាំងអស់នោះ មិនកើត ឡើង ក្នុងភង្គក្ខណៈនៃចិត្ត តែចិត្តសង្ខារ របស់សត្វទាំងនោះ មិនមែនជាមិន រលត់ទៅទេ វចីសង្ខារ របស់ពួកសត្វ ដែលចូលកាន់និរោធ និងរបស់ អសញ្ញសត្វទាំងនោះ មិនកើតឡើងផង ចិត្តសង្ខារ មិនរលត់ទៅផង ក្នុង ឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកវិតក្កៈ និងវិចារ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា មិនរលត់ទៅ វចីសង្ខារ របស់សត្វនោះ មិនកើត ឡើងឬ ។ ចិត្តសង្ខារ របស់សត្វទាំងនោះ មិនរលត់ទៅក្នុងឧប្បាទក្ខណៈនៃ ពួកវិតក្កៈ និងវិចារ តែវចីសង្ខារ របស់សត្វទាំងនោះ មិនមែនជាមិនកើត ឡើងទេ ចិត្តសង្ខាររបស់ពួកសត្វដែលចូលកាន់និរោធ និងរបស់អសញ្ញសត្វ ទាំងនោះ មិនរលត់ទៅផង វចីសង្ខារ មិនកើតឡើងផង ក្នុងឧប្បាទក្ខណៈ នៃចិត្ត ព្រោះវៀរចាកពួកវិតក្កៈ និងវិចារ ។

[ ៣៩៣ ] កាយសង្ខារ មិនកើតឡើង ក្នុងទីណា ។បេ។

[ ៣៩៤ ] កាយសង្ខារ របស់សត្វណា មិនកើតឡើង ក្នុងទីណា ។បេ។ ពាក្យថា របស់សត្វណាក្តី ពាក្យថា របស់សត្វណា ក្នុងទីណាក្តី ដូចៗ គ្នា ។ ពាក្យថា របស់ពួកសត្វដែលចូលកាន់និរោធ បណ្ឌិតមិនបាន ( មិនគួរពោល )

ក្នុងពាក្យថា របស់សត្វណា ក្នុងទីណាឡើយ ។

[ ៣៩៥ ] កាយសង្ខារ របស់សត្វណា កើតឡើងហើយ វចីសង្ខារ របស់សត្វនោះ រលត់ហើយឬ ។ អើ ។ បុច្ឆា ជាអតីត បណ្ឌិតគប្បីឲ្យពិស្តារដូចៗ គ្នា ក្នុងឧប្បាទវារៈផង ក្នុងនិរោធវារៈផង ក្នុងឧប្បាទនិរោធ-វារៈផង ។

[ ៣៩៦ ] កាយសង្ខារ របស់សត្វណា នឹងកើតឡើង វចីសង្ខារ របស់សត្វនោះ នឹងរលត់ទៅឬ ។ អើ ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា នឹងរលត់ទៅ កាយសង្ខារ របស់សត្វនោះ នឹងកើតឡើងឬ ។ ចិត្តជាទីបំផុតរបស់ពួកសត្វជាកាមាវចរ នឹងកើតឡើង ក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃចិត្តជាទីបំផុត វចីសង្ខារ របស់ពួកសត្វជាកាមាវចរ និងរបស់ពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរ និងក្នុងអរូបាវចរ និងរបស់ពួកសត្វនោះៗ ដែលចូលទៅកាន់រូបាវចរ និងកាន់អរូបាវចរហើយ នឹងបរិនិព្វានកាលច្យុត នឹងរលត់ទៅ តែកាយសង្ខារ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ វចីសង្ខារ របស់ពួកសត្វក្រៅនេះ នឹងរលត់ទៅផង កាយសង្ខារនឹងកើតឡើងផង ។

[ ៣៩៧ ] កាយសង្ខារ របស់សត្វណា នឹងកើតឡើង ចិត្តសង្ខារ របស់សត្វនោះ នឹងរលត់ទៅឬ ។ អើ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងរលត់ទៅ កាយសង្ខារ របស់សត្វនោះ នឹងកើតឡើងឬ ។ ចិត្តជាទីបំផុត របស់ពួកសត្វជាកាមាវចរ នឹងកើតឡើង ក្នុងលំដាប់នៃចិត្តណា ក្នុង

ឧប្បាទក្ខណៈនៃចិត្តជាទីបំផុត របស់ពួកសត្វជាកាមាវចរ ចិត្តសង្ខារ របស់ពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរ និងក្នុងអរូបាវចរ និងរបស់ពួកសត្វនោះៗ ដែលចូលទៅកាន់រូបាវចរ និងកាន់អរូបាវចរហើយ នឹងបរិនិព្វាន នឹងរលត់ទៅ តែកាយសង្ខារ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ ចិត្តសង្ខារ របស់ពួកសត្វក្រៅនេះ នឹងរលត់ទៅផង កាយសង្ខារ នឹងកើតឡើងផង ។

[ ៣៩៨ ] វចីសង្ខារ របស់សត្វណា នឹងកើតឡើង ចិត្តសង្ខារ របស់សត្វនោះ នឹងរលត់ទៅឬ ។ អើ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងរលត់ទៅ វចីសង្ខារ របស់សត្វនោះ នឹងកើតឡើងឬ ។ ចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃចិត្តជាទីបំផុត ចិត្តសង្ខារ របស់សត្វទាំងនោះ នឹងរលត់ទៅ តែវចីសង្ខារ របស់សត្វទាំងនោះ នឹងមិនកើតឡើងទេ ចិត្តសង្ខារ របស់ពួកសត្វ ក្រៅនេះ នឹងរលត់ទៅផង វចីសង្ខារ នឹងកើតឡើងផង ។

[ ៣៩៩ ] កាយសង្ខារ នឹងកើតឡើង ក្នុងទីណា ។បេ។

[ ៤០០ ] កាយសង្ខារ របស់សត្វណា នឹងកើតឡើង ក្នុងទីណា វចីសង្ខារ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះឬ ។ កាយសង្ខារ របស់សត្វទាំងនោះ ដែលចូលកាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន នឹងកើតឡើង ក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ កាយសង្ខារ របស់ពួកសត្វ ជាកាមាវចរទាំងនោះ ដែលចូលកាន់បឋមជ្ឈាន

នឹងកើតឡើងផង វចីសង្ខារ នឹងរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា កាយសង្ខារ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ ចិត្តជាទីបំផុត របស់ពួកសត្វជាកាមាវចរ នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃចិត្តជាទីបំផុត របស់ពួកសត្វជាកាមាវចរ វចីសង្ខារ របស់ពួកសត្វជារូបាវចរ និងជាអរូបាវចរ ទាំងនោះ នឹងរលត់ទៅ ក្នុងទីនោះ តែកាយសង្ខារ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ វចីសង្ខាររបស់ពួកសត្វដែលចូលកាន់បឋមជ្ឈាន និងពួកសត្វជាកាមាវចរទាំងនោះ ក្រៅនេះ នឹងរលត់ទៅផង កាយសង្ខារ នឹងកើតឡើងផង ក្នុងទីនោះ ។

[ ៤០១ ] កាយសង្ខារ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា កាយសង្ខាររបស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ ចិត្តជាទីបំផុត របស់ពួកសត្វជាកាមាវចរ នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃចិត្ត ជាទីបំផុតរបស់ពួកសត្វជាកាមាវចរ ចិត្តសង្ខារ របស់ពួកសត្វ ជារូបាវចរ និងជាអរូបាវចរ ទាំងនោះ ដែលចូលកាន់ចតុត្ថជ្ឈាន នឹងរលត់ទៅ ក្នុងទីនោះ តែកាយសង្ខារ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ចិត្តសង្ខារ របស់ពួកសត្វដែលចូលកាន់បឋមជ្ឈាន កាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន និងរបស់ពួកសត្វជាកាមាវចរទាំងនោះ ក្រៅនេះ នឹងរលត់ទៅផង កាយសង្ខារ នឹង

កើតឡើងផង ក្នុងទីនោះ ។

[ ៤០២ ] វចីសង្ខារ របស់សត្វណា នឹងកើតឡើង ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា វចីសង្ខារ របស់សត្វនោះ នឹងកើតឡើង ក្នុងទីនោះឬ ។ ចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃចិត្តជាទីបំផុត ចិត្តសង្ខារ របស់សត្វទាំងនោះ ដែលចូលកាន់ទុតិយជ្ឈាន កាន់តតិយជ្ឈាន និងកាន់ចតុត្ថជ្ឈាន នឹងរលត់ទៅ ក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះទេ ចិត្តសង្ខារ របស់ពួកសត្វជាកាមាវចរ ដែលចូលកាន់បឋមជ្ឈាន និងរបស់ពួកសត្វជារូបាវចរ និងជាអរូបាវចរទាំងនោះ ក្រៅនេះ នឹងរលត់ទៅផង វចីសង្ខារ នឹងកើតឡើងផង ក្នុងទីនោះ ។

[ ៤០៣ ] កាយសង្ខារ របស់សត្វណា នឹងមិនកើតឡើង វចីសង្ខារ របស់សត្វនោះ នឹងមិនរលត់ទៅឬ ។ ចិត្តជាទីបំផុត របស់ពួកសត្វជាកាមាវចរ នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃចិត្តជាទីបំផុត កាយសង្ខារ របស់ពួកសត្វជាកាមាវចរ របស់ពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរ និងក្នុងអរូបាវចរ និងរបស់ពួកសត្វនោះៗ ដែលចូលទៅកាន់រូបាវចរ និងកាន់អរូបាវចរហើយ នឹងបរិនិព្វាន កាលច្យុត នឹងមិនកើតឡើង តែវចីសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ ចិត្តជាទីបំផុត

ដែលមិនមានវិតក្ក មិនមានវិចារ របស់ពួកសត្វ ដែលប្រកបដោយចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ កាយសង្ខារ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង វចីសង្ខារ នឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា ។បេ។ អើ ។

[ ៤០៤ ] កាយសង្ខារ របស់សត្វណា នឹងមិនកើតឡើង ចិត្តសង្ខារ របស់សត្វនោះ នឹងមិនរលត់ទៅឬ ។ ចិត្តជាទីបំផុត របស់ពួកសត្វជាកាមាវចរ នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃចិត្តជាទីបំផុត របស់ពួកសត្វជាកាមាវចរ កាយសង្ខារ របស់ពួកសត្វដែលកើតក្នុងបច្ឆិមភព ក្នុងរូបាវចរ និងក្នុងអរូបាវចរ និងរបស់ពួកសត្វនោះៗ ដែលចូលទៅកាន់រូបាវចរ និងកាន់អរូបាវចរហើយ នឹងបរិនិព្វាន កាលច្យុត នឹងមិនកើតឡើង តែចិត្តសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ កាយសង្ខារ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ចិត្តសង្ខារ នឹងមិនរលត់ទៅផង ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា ។បេ។ អើ ។

[ ៤០៥ ] វចីសង្ខារ របស់សត្វណា នឹងមិនកើតឡើង ចិត្តសង្ខារ របស់សត្វនោះ នឹងមិនរលត់ទៅឬ ។ ចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃចិត្ត ជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ វចីសង្ខារ របស់សត្វទាំងនោះ នឹង

មិនកើតឡើង តែចិត្តសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ វចីសង្ខារ របស់សត្វទាំងនោះ នឹងមិនកើតឡើងផង ចិត្តសង្ខារ នឹងមិនរលត់ទៅផង ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា ។បេ។ អើ ។

[ ៤០៦ ] កាយសង្ខារ នឹងមិនកើតឡើង ក្នុងទីណា ។បេ។

[ ៤០៧ ] កាយសង្ខារ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា វចីសង្ខារ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះឬ ។ ចិត្តជាទីបំផុត របស់ពួកសត្វជាកាមាវចរ នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃចិត្តជាទីបំផុត របស់ពួកសត្វជាកាមាវចរ កាយសង្ខារ របស់ពួកសត្វជារូបាវចរ និងជាអរូបាវចរទាំងនោះ នឹងមិនកើតឡើង ក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ របស់ពួកសត្វដែលប្រកបដោយចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ កាយសង្ខារ របស់ពួកសត្វដែលចូលកាន់ចតុត្ថជ្ឈាន និងរបស់អសញ្ញសត្វទាំងនោះ នឹងមិនកើតឡើងផង វចីសង្ខារ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា កាយសង្ខារ របស់សត្វនោះ នឹងមិនកើតឡើង ក្នុងទីនោះឬ ។ វចីសង្ខារ របស់សត្វទាំងនោះ ដែលចូលកាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន នឹងមិន

រលត់ទៅ ក្នុងទីនោះ តែកាយសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនកើតឡើងក្នុងទីនោះទេ ចិត្តជាទីបំផុតដែលមិនមានវិតក្ក មិនមានវិចារ របស់ពួកសត្វដែលប្រកបដោយចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ វចីសង្ខារ របស់ពួកសត្វ ដែលចូលកាន់ចតុត្ថជ្ឈាន និងរបស់អសញ្ញសត្វទាំងនោះ នឹងមិនរលត់ទៅផង កាយសង្ខារ នឹងមិនកើតឡើងផង ក្នុងទីនោះ ។

[ ៤០៨ ] កាយសង្ខារ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះឬ ។ ចិត្តជាទីបំផុត របស់ពួកសត្វជាកាមាវចរ នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បាទក្ខណៈនៃចិត្តជាទីបំផុត របស់ពួកសត្វជាកាមាវចរ កាយសង្ខារ របស់ពួកសត្វជារូបាវចរ និងជាអរូបាវចរទាំងនោះ ដែលចូលកាន់ចតុត្ថជ្ឈាន នឹងមិនកើតឡើង ក្នុងទីនោះ តែចិត្តសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ កាយសង្ខារ របស់អសញ្ញសត្វទាំងនោះ នឹងមិនកើតឡើងផង ចិត្តសង្ខារ នឹងមិនរលត់ទៅផង ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ក្នុងទីនោះ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា ក្នុងទីណា ។បេ។ អើ ។

[ ៤០៩ ] វចីសង្ខារ របស់សត្វណា នឹងមិនកើតឡើង ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះឬ ។ ចិត្តជាទីបំផុតដែល

មិនមានវិតក្កៈ មិនមានវិចារ នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា ក្នុងឧប្បា-ទក្ខណៈនៃចិត្តជាទីបំផុត ដែលមិនមានវិតក្កៈ មិនមានវិចារ វចីសង្ខារ របស់សត្វទាំងនោះ ដែលចូលកាន់ទុតិយជ្ឈាន កាន់តតិយជ្ឈាន និងកាន់ចតុត្ថជ្ឈាន នឹងមិនកើតឡើង ក្នុងទីនោះ តែចិត្តសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ វចីសង្ខារ របស់អសញ្ញសត្វទាំងនោះ នឹងមិនកើតឡើងផង ចិត្តសង្ខារ នឹងមិនរលត់ទៅផង ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ក្នុងទីនោះ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា ក្នុងទីណា ។បេ។ អើ ។

[ ៤១០ ] កាយសង្ខាររបស់សត្វណា កើតឡើង វចីសង្ខាររបស់សត្វនោះ រលត់ហើយឬ ។ អើ ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា រលត់ហើយ កាយសង្ខារ របស់សត្វនោះ កើតឡើងឬ ។ វចីសង្ខារ របស់សត្វទាំងអស់ ដែលចូលកាន់និរោធ និងរបស់អសញ្ញសត្វទាំងនោះ រលត់ហើយ ក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ តែកាយសង្ខារ របស់សត្វទាំងនោះ មិនកើតឡើងទេ វចីសង្ខារ របស់សត្វទាំងនោះ រលត់ហើយផង កាយសង្ខារ កើតឡើងផង ក្នុងឧប្បាទក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ ។បេ។ អនុលោមក្តី បច្ចនិយៈក្តី ជាបច្ចុប្បន្នបុច្ឆា និងជាអតីតបុច្ឆា ដែលចែកហើយ ក្នុងឧប្បាទ-វារៈ យ៉ាងណា ក៏អនុលោមក្តី បច្ចនិយៈក្តី ជាបច្ចុប្បន្នបុច្ឆា និងជាអតីត-បុច្ឆា ក្នុងឧប្បាទនិរោធវារៈ បណ្ឌិតគប្បីចែក យ៉ាងនោះដែរ ។

[ ៤១១ ] កាយសង្ខាររបស់សត្វណា កើតឡើង វចីសង្ខាររបស់សត្វនោះ នឹងរលត់ទៅឬ ។ អើ ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា នឹងរលត់ទៅ កាយសង្ខារ របស់សត្វនោះ កើតឡើងឬ ។ ពួកសត្វទាំងអស់ ដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ វចីសង្ខារ របស់សត្វទាំងនោះ នឹងរលត់ទៅក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ តែកាយសង្ខារ របស់សត្វទាំងនោះ មិនកើតឡើងទេ វចីសង្ខារ របស់សត្វទាំងនោះ នឹងរលត់ទៅផង កាយសង្ខារ កើតឡើងផង ក្នុងឧប្បាទក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ ។

[ ៤១២ ] កាយសង្ខាររបស់សត្វណា កើតឡើង ចិត្តសង្ខាររបស់សត្វនោះ នឹងរលត់ទៅឬ ។ អើ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងរលត់ទៅ កាយសង្ខារ របស់សត្វនោះ កើតឡើងឬ ។ ពួកសត្វទាំងអស់ ដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ ចិត្តសង្ខារ របស់សត្វទាំងនោះ នឹងរលត់ទៅក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ តែកាយសង្ខារ របស់សត្វទាំងនោះ មិនកើតឡើងទេ ចិត្តសង្ខារ របស់សត្វទាំងនោះ នឹងរលត់ទៅផង កាយសង្ខារ កើតឡើងផង ក្នុងឧប្បាទក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ ។

[ ៤១៣ ] វចីសង្ខារ របស់សត្វណា កើតឡើង ចិត្តសង្ខាររបស់សត្វនោះ នឹងរលត់ទៅឬ ។ អើ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងរលត់ទៅ វចីសង្ខារ របស់សត្វនោះ កើតឡើងឬ ។ ពួកសត្វទាំងអស់

ដែលចូលកាន់និរោធ និងពួកអសញ្ញសត្វ ចិត្តសង្ខារ របស់សត្វទាំងនោះ នឹងរលត់ទៅ ក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកវិតក្ក និងវិចារ តែវចីសង្ខារ របស់សត្វទាំងនោះ មិនកើតឡើងទេ ចិត្តសង្ខារ របស់សត្វទាំងនោះ នឹងរលត់ទៅផង វចីសង្ខារ កើតឡើងផង ក្នុងឧប្បាទក្ខណៈនៃពួកវិតក្ក និងវិចារ ។

[ ៤១៤ ] កាយសង្ខារ កើតឡើង ក្នុងទីណា ។បេ។

[ ៤១៥ ] កាយសង្ខារ របស់សត្វណា កើតឡើង ក្នុងទីណា វចីសង្ខារ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះឬ ។ កាយសង្ខារ របស់សត្វទាំងនោះ ដែលចូលកាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន កើតឡើង ក្នុងឧប្បាទក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ ក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំងនោះ នឹងមិនរលត់ទៅ ក្នុងទីនោះទេ ពួកសត្វជាកាមាវចរ ដែលចូលកាន់បឋមជ្ឈាន កាយសង្ខារ របស់សត្វទាំងនោះ កើតឡើងផង វចីសង្ខារ នឹងរលត់ទៅផង ក្នុងឧប្បាទក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ ក្នុងទីនោះ ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា កាយសង្ខារ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ វចីសង្ខារ របស់សត្វទាំងនោះឯង ជាកាមាវចរ ដែលចូលកាន់បឋមជ្ឈាន ក្នុងភង្គក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ និងរបស់ពួកសត្វជារូបាវចរ និងជាអរូបាវចរទាំងនោះ នឹងរលត់ទៅក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ ក្នុងទីនោះ តែកាយសង្ខារ របស់សត្វទាំងនោះ មិនកើតឡើង

ក្នុងទីនោះទេ វចីសង្ខារ របស់ពួកសត្វជាកាមាវចរទាំងនោះ ដែលចូលកាន់បឋមជ្ឈាន នឹងរលត់ទៅផង កាយសង្ខារ កើតឡើងផង ក្នុងឧប្បាទក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ ក្នុងទីនោះ ។

[ ៤១៦ ] កាយសង្ខាររបស់សត្វណា កើតឡើង ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា កាយសង្ខារ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ ចិត្តសង្ខារ របស់សត្វទាំងអស់នោះ នឹងរលត់ទៅ ក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ ក្នុងទីនោះ តែកាយសង្ខារ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ចិត្តសង្ខារ របស់សត្វទាំងនោះ នឹងរលត់ទៅផង កាយសង្ខារ កើតឡើងផង ក្នុងឧប្បាទក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ ក្នុងទីនោះ ។

[ ៤១៧ ] វចីសង្ខារ របស់សត្វណា កើតឡើង ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ នឹងរលត់ទៅ ក្នុងទីនោះឬ ។ អើ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងរលត់ទៅ ក្នុងទីណា វចីសង្ខារ របស់សត្វនោះ កើតឡើង ក្នុងទីនោះឬ ។ ចិត្តសង្ខារ របស់សត្វទាំងអស់នោះ នឹងរលត់ទៅ ក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកវិតក្ក និងវិចារ ក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំងនោះ មិនកើតឡើង ក្នុងទីនោះទេ ចិត្តសង្ខារ របស់សត្វទាំងនោះ នឹងរលត់ទៅផង វចីសង្ខារ កើតឡើង

ផង ក្នុងឧប្បាទក្ខណៈនៃពួកវិតក្ក និងវិចារ ក្នុងទីនោះ ។

[ ៤១៨ ] កាយសង្ខារ របស់សត្វណា មិនកើតឡើង វចីសង្ខារ របស់សត្វនោះ នឹងមិនរលត់ទៅឬ ។ កាយសង្ខារ របស់សត្វទាំងអស់ ដែលចូលកាន់និរោធ និងរបស់អសញ្ញសត្វទាំងនោះ មិនកើតឡើង ក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ តែវចីសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ ចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ របស់ពួកសត្វដែលប្រកបដោយចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ កាយសង្ខារ របស់សត្វទាំងនោះ មិនកើតឡើងផង វចីសង្ខារ នឹងមិនរលត់ទៅផង ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា នឹងមិនរលត់ទៅ កាយសង្ខារ របស់សត្វនោះ មិនកើតឡើងទេឬ ។ អើ ។

[ ៤១៩ ] កាយសង្ខារ របស់សត្វណា មិនកើតឡើង ចិត្តសង្ខារ របស់សត្វនោះ នឹងមិនរលត់ទៅឬ ។ កាយសង្ខារ របស់សត្វទាំងអស់ ដែលចូលកាន់និរោធ និងរបស់អសញ្ញសត្វទាំងនោះ មិនកើតឡើងក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ តែចិត្តសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ កាយសង្ខារ របស់សត្វទាំងនោះ មិនកើតឡើងផង ចិត្តសង្ខារ នឹងមិនរលត់ទៅផង ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹង

មិនរលត់ទៅ កាយសង្ខាររបស់សត្វនោះ មិនកើតឡើងទេឬ ។ អើ ។

[ ៤២០ ] វចីសង្ខារ របស់សត្វណា មិនកើតឡើង ចិត្តសង្ខារ របស់សត្វនោះ នឹងមិនរលត់ទៅឬ ។ វចីសង្ខារ របស់សត្វទាំងអស់ ដែលចូលកាន់និរោធ និងរបស់អសញ្ញសត្វទាំងនោះ មិនកើតឡើងក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកវិតក្ក និងវិចារ តែចិត្តសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅទេ វចីសង្ខារ របស់សត្វទាំងនោះ មិនកើតឡើងផង ចិត្តសង្ខារ នឹងមិនរលត់ទៅផង ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងមិនរលត់ទៅ វចីសង្ខារ របស់សត្វនោះ មិនកើតឡើងទេឬ ។ អើ ។

[ ៤២១ ] កាយសង្ខារ មិនកើតឡើង ក្នុងទីណា ។បេ។

[ ៤២២ ] កាយសង្ខារ របស់សត្វណា មិនកើតឡើង ក្នុងទីណា វចី-សង្ខារ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះឬ ។ កាយសង្ខារ របស់ពួកសត្វជាកាមាវចរទាំងនោះឯង ដែលចូលកាន់បឋមជ្ឈាន ក្នុងភង្គក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ និងរបស់ពួកសត្វជារូបាវចរ និងជាអរូបាវចរទាំងនោះ មិនកើតឡើងក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ ក្នុងទីនោះ តែវចីសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ ចិត្តជាទីបំផុតដែលមិនមានវិតក្ក មិនមានវិចារ របស់ពួកសត្វដែលប្រកបដោយចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ដែល

ប្រកបដោយវិតក្ក និងប្រកបដោយវិចារ កាយសង្ខារ របស់សត្វទាំងនោះ ឯង ដែលចូលកាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន ក្នុងភង្គក្ខណៈនៃពួក អស្សាសៈ និងបស្សាសៈ និងរបស់ពួកសត្វដែលចូលកាន់ចតុត្ថជ្ឈាន និង របស់អសញ្ញសត្វទាំងនោះ ក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួក អស្សាសៈ និងបស្សាសៈ មិនកើតឡើងផង វចីសង្ខារ នឹងមិនរលត់ទៅផង ក្នុងទីនោះ ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា កាយសង្ខារ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះឬ ។ វចី-សង្ខារ របស់សត្វទាំងនោះ ដែលចូលកាន់ទុតិយជ្ឈាន និងកាន់តតិយជ្ឈាន នឹងមិនរលត់ទៅក្នុងឧប្បាទក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ ក្នុងទីនោះ តែកាយសង្ខារ របស់សត្វទាំងនោះ មិនមែនជាមិនកើតឡើង ក្នុងទីនោះទេ ចិត្តជាទីបំផុតដែលមិនមានវិតក្ក មិនមានវិចារ របស់ពួកសត្វដែលប្រកប ដោយចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ នឹងកើតឡើង ក្នុង លំដាប់នៃចិត្តណា ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ វចីសង្ខារ របស់សត្វទាំងនោះឯង ដែលចូលកាន់ទុតិ-យជ្ឈាន និងកាន់តតិយជ្ឈាន និងរបស់ពួកសត្វ ដែលចូលកាន់ចតុត្ថជ្ឈាន និងរបស់អសញ្ញសត្វទាំងនោះ នឹងមិនរលត់ទៅផង កាយសង្ខារ មិនកើត ឡើងផង ក្នុងភង្គក្ខណៈនៃពួកអស្សាសៈ និងបស្សាសៈ និងក្នុងឧប្បាទក្ខណៈ នៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ ក្នុងទីនោះ ។

[ ៤២៣ ] កាយសង្ខារ របស់សត្វណា មិនកើតឡើង ក្នុងទីណា ចិត្ត-

សង្ខារ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះឬ ។ កាយសង្ខារ របស់សត្វទាំងអស់នោះ មិនកើតឡើងក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកអស្សាសៈ និងបស្សាសៈ ក្នុងទីនោះ តែចិត្តសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ កាយសង្ខារ របស់អសញ្ញសត្វទាំងនោះ មិនកើតឡើងផង ចិត្តសង្ខារ នឹងមិនរលត់ទៅផង ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុតក្នុងទីនោះ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា កាយសង្ខារ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះទេឬ ។ អើ ។

[ ៤២៤ ] វចីសង្ខារ របស់សត្វណា មិនកើតឡើង ក្នុងទីណា ចិត្តសង្ខារ របស់សត្វនោះ នឹងមិនរលត់ទៅ ក្នុងទីនោះឬ ។ វចីសង្ខារ របស់សត្វទាំងអស់នោះ មិនកើតឡើងក្នុងភង្គក្ខណៈនៃចិត្ត និងក្នុងឧប្បាទក្ខណៈនៃចិត្ត ព្រោះវៀរចាកពួកវិតក្ក និងវិចារ ក្នុងទីនោះ តែចិត្តសង្ខារ របស់សត្វទាំងនោះ មិនមែនជានឹងមិនរលត់ទៅ ក្នុងទីនោះទេ វចីសង្ខារ របស់អសញ្ញសត្វទាំងនោះ មិនកើតឡើងផង ចិត្តសង្ខារនឹងមិនរលត់ទៅផង ក្នុងភង្គក្ខណៈនៃចិត្តជាទីបំផុត ក្នុងទីនោះ ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងមិនរលត់ទៅ ក្នុងទីណា វចីសង្ខារ របស់សត្វនោះ មិនកើតឡើង ក្នុងទីនោះទេឬ ។ អើ ។

[ ៤២៥ ] កាយសង្ខារ របស់សត្វណា កើតឡើងហើយ វចីសង្ខារ របស់សត្វនោះ នឹងរលត់ទៅឬ ។ ចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិនមានវិចារ របស់ពួកសត្វដែលប្រកបដោយចិត្តជាទីបំផុត ដែលមិនមានវិតក្ក មិន

មានវិចារ នឹងកើតឡើងក្នុងលំដាប់នៃចិត្តណា ក្នុងកង្ខណៈនៃចិត្តជាទីបំផុត ដែលប្រកបដោយវិតក្ក ប្រកបដោយវិចារ កាយសង្ខារ របស់សត្វទាំងនោះ មិនកើតឡើងហើយ តែវចីសង្ខារ របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ កាយសង្ខារ របស់ពួកសត្វក្រៅនេះ មិនកើតឡើងហើយផង វចីសង្ខារ នឹងរលត់ទៅផង ។ មួយយ៉ាងទៀត វចីសង្ខារ របស់សត្វណា នឹងរលត់ទៅ កាយសង្ខារ របស់សត្វនោះ កើតឡើងហើយឬ ។ អើ ។

[ ៤២៦ ] កាយសង្ខារ របស់សត្វណា កើតឡើងហើយ ចិត្តសង្ខារ របស់សត្វនោះ នឹងរលត់ទៅឬ ។ កាយសង្ខារ របស់សត្វទាំងនោះ កើតឡើងហើយក្នុងកង្ខណៈនៃចិត្តជាទីបំផុត តែចិត្តសង្ខារ របស់សត្វទាំងនោះ នឹងមិនរលត់ទៅទេ កាយសង្ខារ របស់ពួកសត្វក្រៅនេះ កើតឡើងហើយផង ចិត្តសង្ខារ នឹងរលត់ទៅផង ។ មួយយ៉ាងទៀត ចិត្តសង្ខារ របស់សត្វណា នឹងរលត់ទៅ កាយសង្ខារ របស់សត្វនោះ កើតឡើងហើយឬ ។ អើ ។បេ។

អនុលោមក្តី បច្ចនិយៈក្តី ជាអតីតបុច្ឆា និងជាអនាគតបុច្ឆា ដែលលោកចែកហើយ ក្នុងនិរោធវារៈ យ៉ាងណា អនុលោមក្តី បច្ចនិយៈក្តី ជាអតីតបុច្ឆា និងជាអនាគតបុច្ឆា បណ្ឌិតដែលមិនវង្វេង គប្បីចែកក្នុងឧប្បាទនិរោធវារៈ យ៉ាងនោះដែរ ។ ពាក្យក្នុងនិរោធវារៈ ដូចៗ គ្នា ។ ការធ្វើឲ្យផ្សេងៗ គ្នា មិនមានឡើយ ។

ឧប្បាទនិរោធវារៈ ចប់

បវត្តិវារៈ ចប់

## បរិញ្ញាវារៈ

[ ៤២៧ ] សត្វណា កំណត់ដឹងនូវកាយសង្ខារ សត្វនោះ ឈ្មោះថា កំណត់ដឹងនូវវចីសង្ខារឬ ។ អើ ។ មួយយ៉ាងទៀត សត្វណា កំណត់ដឹងនូវវចីសង្ខារ សត្វនោះ ឈ្មោះថា កំណត់ដឹងនូវកាយសង្ខារឬ ។ អើ ។ បរិញ្ញាវារៈ ក្នុងខន្ធយមកៈ ដែលលោកចែកហើយ យ៉ាងណា បរិញ្ញាវារៈ ក្នុងសង្ខារយមកៈ បណ្ឌិតគប្បីចែក យ៉ាងនោះដែរ ។

បរិញ្ញាវារៈ ចប់

សង្ខារយមកៈ ចប់

# អដ្ឋកថា

# សង្ខារយមកៈ

## បណ្ណត្តិវារៈ

[ ២៣០-៤២៧ ] ឥឡូវនេះ ជាកិច្ចពណ៌នាសង្ខារយមកៈ ដែលព្រះមានព្រះភាគ ទ្រង់សម្តែងបន្ទាប់អំពីសច្ចយមកៈ ទ្រង់រួបរួមធម៌ទាំងឡាយ មានកុសលជាដើម ដែលទ្រង់សម្តែងហើយ ក្នុងមូលយមកៈទាំងនោះឯងជាឯកទេស ១ ដោយអំណាចនៃធម៌ដែលសង្គ្រោះបាន ។ ក្នុងសង្ខារយមកៈនោះ គប្បីជ្រាបប្រភេទនៃវារៈដ៏សេស គឺមហាវារៈទាំងឡាយ មានបណ្ណត្តិវារៈជាដើម និងអន្តរវារៈជាដើម ដោយន័យដែលពោលហើយខាងដើមនោះឯង ។

ឯការប្លែកគ្នា ក្នុងសង្ខារយមកៈនេះ មានដូច្នេះ ក្នុងបណ្ណត្តិវារៈ បទសោធនវារៈថា **រូបំ រូបក្ខន្ធោ** រូប ហៅថា រូបក្ខន្ធឬ **ចក្ខុ ចក្ខាយតនំ** ចក្ខុ ហៅថា ចក្ខាយតនៈឬ **ចក្ខុ ចក្ខុធាតុ** ចក្ខុ ហៅថា ចក្ខុធាតុឬ **ទុក្ខំ ទុក្ខសច្ចំ** ទុក្ខ ហៅថា ទុក្ខសច្ចឬ ដូច្នេះ ព្រះមានព្រះភាគ ទ្រង់លើកធម៌ទាំងឡាយ មានខន្ធជាដើម ដែលព្រះអង្គទ្រង់ប្រារព្ធហើយ សម្តែងហើយខាងដើម យ៉ាងណា សូម្បីសង្ខារ ៣ ខាងដើម ទ្រង់មិនប្រារព្ធហើយ យ៉ាងនោះ តែទ្រង់ចែកថា **អស្សាស បស្សាសា កាយសង្ខារោ** ប្រែថា ខ្យល់អស្សាសៈ បស្សាសៈ ឈ្មោះថា កាយសង្ខារ ដូច្នេះជាដើម ។

ក្នុងសង្ខារទាំង ៣ នោះ សង្ខារនៃកាយ ឈ្មោះថា កាយសង្ខារ សង្ខារដែលជាផលនៃករជកាយ ដែលកើតហើយចាកហេតុនោះឯង ឈ្មោះថា កាយសង្ខារ ព្រោះព្រះបាលី ( ក្នុងសំយុត្តនិកាយ សឡាយតនវគ្គ ) ថា ខ្យល់ដង្ហើមចេញ-ចូល ប្រព្រឹត្តទៅក្នុងកាយ ធម៌ទាំងនុ៎ះ ជាប់ចំពោះដោយកាយ ដូច្នេះ ។

ន័យម្យ៉ាងទៀត សភាវៈណា ដែលបច្ច័យរមែងធ្វើព្រម គឺតាក់តែង ហេតុនោះ សភាវៈនោះ ឈ្មោះថា សង្ខារ សួរថា សង្ខារនោះ ដែលអ្វីតាក់តែង ឆ្លើយថា សង្ខារនោះ កាយតាក់តែង សង្ខារនេះ ដែលករជកាយតាក់តែង ហាក់បីដូចសម្លៀតស្បែកតាក់តែងនូវខ្យល់ កាលបើយ៉ាងនេះ កាយសង្ខារ គឺសង្ខារនៃកាយ ។ អធិប្បាយថា ខ្យល់អស្សាសៈ បស្សាសៈ ដែលកាយធ្វើហើយ ។

សភាវៈណា តាក់តែង ហេតុនោះ សភាវៈនោះ ឈ្មោះថា សង្ខារ ព្រោះព្រះបាលី ( ក្នុងមជ្ឈិមនិកាយ មូលបណ្ណាសក ) ថា ម្នាលអាវុសោវិសាខ បុគ្គល ត្រិះរិះ ពិចារណាមុនសិន ទើបបញ្ចេញវាចា ( ក្រោយ ) ព្រោះហេតុនោះ បានជាវិតក្ក និងវិចារ ហៅថា វចីសង្ខារ ដូច្នេះ ។

សួរថា អ្វីជាសង្ខារ ឆ្លើយថា វចីជាសង្ខារ ។ សង្ខារនៃវចី ឈ្មោះថា វចីសង្ខារ ។ ពាក្យថា វចីសង្ខារនេះ ជាឈ្មោះនៃពួក ២ របស់វិតក្ក និងវិចារ ដែលជាសមុដ្ឋាននៃការបន្ទឺវាចា ។

ក្នុងបទទី ៣ សភាវៈណា ដែលបច្ច័យតាក់តែង ព្រោះហេតុនោះ

សភាវៈនោះ ឈ្មោះថា សង្ខារ ព្រោះព្រះបាលី ( សំយុត្តនិកាយ សឡាយតនវគ្គ ) ថា សញ្ញា និងវេទនា ប្រព្រឹត្តទៅក្នុងចិត្ត ធម៌ទាំងនុ៎ះឯង ជាប់ចំពោះដោយចិត្ត ដូច្នេះឯង ។

សួរថា អ្វីតាក់តែង ឆ្លើយថា ចិត្តតាក់តែង ។

សង្ខារនៃចិត្ត ឈ្មោះថា ចិត្តសង្ខារ ព្រោះធ្វើធម្មវិភត្តិឲ្យចុះក្នុងអត្ថនៃតតិយាវិភត្តិ ។ ពាក្យថា ចិត្តសង្ខារនេះ ជាឈ្មោះនៃចេតសិកធម៌ទាំងឡាយដែលមានចិត្តជាសមុដ្ឋានទាំងអស់ ព្រះមានព្រះភាគ ត្រាស់វៀរវិតក្ក និងវិចារចេញ ព្រោះទ្រង់កាន់យកវិតក្ក និងវិចារ ជាផ្នែកមួយ ដោយភាពជាវចីសង្ខារ ។

ឥឡូវនេះ ទ្រង់ផ្តើមបទសោធនវារៈថា **កាយោ កាយសង្ខារោ** កាយ ហៅថា កាយសង្ខារឬ ជាដើម បទសោធនវារៈនោះ មានយមកៈ ៦ យ៉ាង គឺយមកៈ ៣ យ៉ាង ក្នុងអនុលោមន័យ ៣ យ៉ាង ក្នុងបដិលោមន័យ យមកៈ ១២ យ៉ាង គឺយមកៈ ៦ យ៉ាង ក្នុងអនុលោមន័យ ៦ យ៉ាង ក្នុងបដិលោមន័យ ព្រោះធ្វើមូលនៃសង្ខារនីមួយៗ ក្នុងបទសោធនមូលចក្កវារៈ ឲ្យជា ២ ចំណែក ។

ឯក្នុងសុទ្ធសង្ខារវារៈ ត្រាស់យមកៈទាំងឡាយ ដោយន័យជាដើមថា **រូបំ ចក្ខុ** រូប ហៅថា ខន្ធឬ **ខន្ធា រូបំ** ខន្ធទាំងឡាយ ហៅថា រូបឬ **ចក្ខុ អាយតនំ** ចក្ខុ ហៅថា អាយតនៈដែរឬ **អាយតនា ចក្ខុ** អាយតនៈទាំងឡាយ ហៅថា ចក្ខុដែរឬ ដូច្នេះ ក្នុងវារៈទាំងឡាយ មានសុទ្ធក្ខន្ធវារៈ

*ជាដើម យ៉ាងណា ក៏ត្រាស់យមកៈ ៦ យ៉ាង ក្នុងសុទ្ធិកវារៈទាំងពួង ក៏យ៉ាងនោះ គឺយមកៈ ៣ ក្នុងអនុលោម យមកៈ ៣ ក្នុងបដិលោម គឺមានកាយសង្ខារជាមូល ២ មានវចីសង្ខារជាមូល ១ ដោយន័យជាដើមថា* **កាយសង្ខារោ វចីសង្ខារោ** *កាយសង្ខារ ហៅថា វចីសង្ខារឬ* **វចីសង្ខារោ កាយសង្ខារោ** *វចីសង្ខារ ហៅថា កាយសង្ខារឬ មិនត្រាស់ថា កាយ ហៅថា សង្ខារឬ សង្ខារ ហៅថា កាយឬ សួរថា ព្រោះហេតុអ្វី ឆ្លើយថា ព្រោះភាពដែលយមកៈ ៦ នោះ មិនមានដោយអំណាចនៃបទនីមួយៗ ក្នុងសុទ្ធិកវារៈ ។ អត្ថ រមែងមានដោយអំណាចការជម្រះបទនីមួយៗ ក្នុងសុទ្ធិកវារៈថា* **រូបំ ខន្ធោ** *រូប ហៅថា ខន្ធឬ* **ខន្ធា រូបំ** *ខន្ធទាំងឡាយ ហៅថា រូបឬ* **ចក្ខុ អាយតនំ** *ចក្ខុ ហៅថា អាយតនៈដែរឬ* **អាយតនា ចក្ខុ** *អាយតនៈទាំងឡាយ ហៅថា ចក្ខុដែរឬ ព្រោះក្នុងខន្ធយមកៈជាដើម ទ្រង់បំណងយកខន្ធដែលប្រសើរ មានរូបជាដើម អាយតនៈដែលប្រសើរ មានចក្ខុជាដើម យ៉ាងណា ក្នុងសង្ខារយមកៈនេះ មិនមានអត្ថថា កាយ ហៅថា សង្ខារឬ សង្ខារ ហៅថា កាយឬ ក៏យ៉ាងនោះ ។ ឯអត្ថមួយថា* **កាយសង្ខារោ** *រមែងបានដោយបទ ២ គឺកាយ និងសង្ខារ ព្រះមានព្រះភាគមិនត្រាស់ថា កាយ ហៅថា សង្ខារឬ សង្ខារ ហៅថា កាយឬ ព្រោះមិនមានអត្ថថា អស្សាសៈ ឬបស្សាសៈ ដោយអំណាចការជម្រះបទនីមួយៗ ក្នុងសុទ្ធិកវារៈ តែគប្បីត្រាស់ថា* **កាយោ កាយសង្ខារោ** *កាយ ហៅថា កាយសង្ខារឬ ជាបទដើម សូម្បីពាក្យថា* **កាយោ កាយសង្ខារោ**

*នោះ រមែងមិនសមគួរដោយបទនៃកាយ វចី និងចិត្ត ព្រោះភាពនៃសង្ខារទាំងឡាយ ដែលលោកបំណងយកហើយ លោកមិនកាន់យកក្នុងទីនេះ ។ អត្ថនេះ ជាសុទ្ធសង្ខារវារៈ អធិប្បាយថា ក្នុងការជម្រះបទ សូម្បីវៀរចាកអត្ថ ការពោល រមែងមិនសមគួរ ។ ន័យនោះ លោកកាន់យកហើយ ក្នុងសុទ្ធសង្ខារវារៈ តែក្នុងបទសោធនវារៈនេះ យមកៈ ៦ យ៉ាង រមែងសមគួរ ព្រោះធ្វើមូលនៃសង្ខារនីមួយៗ គឺ* **កាយសង្ខារោ វចីសង្ខារោ** *កាយសង្ខារ ហៅថា វចីសង្ខារឬ* **វចីសង្ខារោ កាយសង្ខារោ** *វចីសង្ខារ ហៅថា កាយសង្ខារឬជាដើម ឲ្យជា ២ ព្រោះភាពនៃកាយសង្ខារ ដទៃអំពីវចីសង្ខារជាដើម វចីសង្ខារ ដទៃអំពីចិត្តសង្ខារជាដើម ហើយចិត្តសង្ខារ ក៏ដទៃអំពីកាយសង្ខារជាដើម ក្នុងយមកៈទាំង ៦ យ៉ាងនោះ រមែងបាន ៣ យ៉ាង ប៉ុណ្ណោះ ព្រោះរាប់ហើយមិនរាប់ទៀត ព្រោះហេតុនោះ ទើបត្រាស់យមកៈ ៦ យ៉ាង គឺ ៣ យ៉ាង ក្នុងអនុលោមន័យ ៣ យ៉ាង ក្នុងបដិលោមន័យ គប្បីសម្តែងយមកៈ ៣ យ៉ាងនោះឯង ។ អធិប្បាយថា ក្នុងសុទ្ធសង្ខារមូលចក្កវារៈ ទ្រង់មិនកាន់យកក្នុងទីនេះ គប្បីជ្រាបឧទ្ទេសវារៈនៃបណ្ណត្តិវារៈ ដោយប្រការដូច្នេះ ។*

*ក្នុងអនុលោមនៃនិទ្ទេសវារៈ ឈ្មោះនៃសង្ខារទាំងឡាយ មានកាយសង្ខារជាដើម មិនមែនកាយជាដើម ព្រោះហេតុណា ព្រោះហេតុនោះ ទើបលោកបដិសេធថា* **នោ** *ប្រែថា មិនមែន ។*

*ក្នុងបដិលោម ពាក្យសួរថា* **ន កាយោ ន កាយសង្ខារោ** *មិនមែន*

*កាយ មិនហៅថា កាយសង្ខារ ដូច្នេះ បានដល់ សួរថា ធម៌ណា មិនជាកាយ ធម៌នោះ មិនជាកាយសង្ខារឬ ពាក្យឆ្លើយថា កាយសង្ខារ មិនជាកាយ តែជាកាយសង្ខារ អធិប្បាយថា កាយសង្ខារ មិនមែនកាយ កាយនោះ មិនមែនកាយសង្ខារ ។*

*បទថា* **អវសេសំ** *អធិប្បាយថា ពួក ២ នៃសង្ខារដ៏សេសតែម្យ៉ាងក៏មិនមែន សូម្បីធម្មជាត មានសង្ខតាសង្ខតបញ្ញត្តិដ៏សេសទាំងអស់ ដែលផុតហើយចាកកាយសង្ខារ ក៏មិនឈ្មោះថា កាយ និងមិនឈ្មោះថា កាយ-សង្ខារ គប្បីជ្រាបអត្ថក្នុងពាក្យវិសជ្ជនាទាំងពួងដោយឧបាយនេះ ដោយប្រការដូច្នេះ ។*

**បណ្ណត្តិវារៈ ចប់**

# បវត្តិវារៈ

*ក្នុងបវត្តិវារៈ ក្នុងសង្ខារយមកៈនេះ ក្នុងអនុលោមន័យរបស់បុគ្គលវារៈក្នុងបច្ចុប្បន្នកាល យមកៈ ៣ យ៉ាងប៉ុណ្ណោះ គឺយមកៈដែលមានកាយសង្ខារជាមូល ២ និងដែលមានវចីសង្ខារជាមូល ១ រមែងបានក្នុងពាក្យសួរថា កាយសង្ខារ របស់សត្វណា កើតឡើង វចីសង្ខារ របស់សត្វនោះ កើតឡើងឬ ដូច្នេះ យមកៈ ៣ យ៉ាងនោះ លោកកាន់យកហើយនោះឯង ។ ក្នុងបដិលោមន័យក្តី ក្នុងវារៈទាំងឡាយ មានឱកាសវារៈជាដើមក្តី នៃបវត្តិវារៈនោះ ក៏ន័យនេះឯង ។ គប្បីជ្រាបការរាប់យមកៈ ដោយអំណាចយមកៈ ៣*

*ក្នុងវារៈទាំងពួង ក្នុងបវត្តិវារៈយ៉ាងនេះ ។*

*ក្នុងការវិនិច្ឆ័យអត្ថ ក្នុងបវត្តិវារៈនេះ គប្បីជ្រាបលក្ខណៈនេះដូចតទៅ*

*ក្នុងសង្ខារយមកៈនេះ ប្រភេទនៃកាល មានបច្ចុប្បន្នកាលជាដើម គប្បីកាន់យកដោយអំណាចបវត្តិកាល ដោយព្រះបាលីជាដើមថា ក្នុងឧប្បាទក្ខណៈនៃខ្យល់អស្សាសៈ បស្សាសៈ ក្នុងឧប្បាទក្ខណៈនៃវិតក្កៈ និងវិចារ ដូច្នេះ មិនគប្បីកាន់យកដោយអំណាចចុតិ និងបដិសន្ធិកាល គប្បីកាន់យកដោយអំណាចនៃបវត្តិកាល ដោយពាក្យជាដើមថា កាយសង្ខារ កំពុងកើតឡើងក្នុងទីនោះ គឺក្នុងទុតិយជ្ឈាន ក្នុងតតិយជ្ឈាន ។ សូម្បីក្នុងចតុត្ថជ្ឈាន ( ភូមិ ) គប្បីជ្រាបថា លោកកាន់យកហើយ ដោយអំណាចឱកាសវារៈ ។ គប្បីជ្រាបវិនិច្ឆ័យអត្ថ ដោយអំណាចនៃលក្ខណៈដែលបាននោះៗ ក្នុងបវត្តិវារៈនេះ ដោយប្រការដូច្នេះ ។*

*គប្បីជ្រាបនយមុខ ក្នុងបវត្តិវារៈនោះដូចតទៅ*

*បទថា* **វិនា វិតក្កវិចារេហិ** *លោកពោលហើយ ដោយអំណាចទុតិយជ្ឈាន និងតតិយជ្ឈាន ។ បទថា* **តេសំ** *បានដល់ ការព្រមព្រៀងនៃទុតិយជ្ឈាន និងតតិយជ្ឈានរបស់បុគ្គលទាំងនោះ ។ បទថា* **កាមាវចរានំ** *បានដល់ សត្វដែលកើតហើយ ក្នុងកាមាវចរភូមិ តែខ្យល់អស្សាសៈបស្សាសៈ មិនមានដល់ទេវតាក្នុងរូបាវចរភូមិ រូបនោះឯង មិនមានដល់ទេវតាក្នុងអរូបាវចរភូមិ ។*

*បទថា* **វិនា អស្សាសបស្សាសេហិ** *ដូច្នេះ លោកពោលសំដៅយក*

ការកើតឡើងនៃវិតក្ក វិចារ របស់សត្វដែលកើតហើយ ក្នុងរូបភព និង អរូបភព ។

បទថា **បឋមជ្ឈានេ កាមាវចរេ** ដូច្នេះ បានដល់ ក្នុងបឋមជ្ឈាន ដែលកើតឡើងហើយ ក្នុងកាមាវចរភូមិ ។ ឯបឋមជ្ឈានក្នុងកាមាវចរភូមិ នេះ លោកកាន់យកដោយអំណាចមគ្គដ៏ប្រសើរ មិនកាន់យកដោយអំណាច អប្បនាឡើយ ព្រោះថា ពួក ២ នៃសង្ខារនេះ រមែងកើតឡើងក្នុងចិត្តដែល ប្រព្រឹត្តទៅដោយវិតក្ក វិចារ សូម្បីមិនទាន់ដល់អប្បនា ។

បទនេះថា **ចិត្តស្ស ភង្គក្ខណេ** លោកពោលហើយ ព្រោះភាពនៃ កាយសង្ខារ មានចិត្តជាសមុដ្ឋានពិតប្រាកដ ព្រោះចិត្ត កាលកើតនោះឯង រមែងញ៉ាំងរូប ឬអរូបឲ្យកើតឡើង កាលរលត់ រមែងមិនញ៉ាំងរូប ឬអរូប ឲ្យកើតឡើង ។

បទថា **សុទ្ធាវាសានំ ទុតិយេ ចិត្តេ វត្តមានេ** បានដល់ ភវង្គចិត្ត ដែលជាចិត្តជួងទី ២ រាប់អំពីបដិសន្ធិចិត្ត ពាក្យនោះ លោកពោលហើយ ដើម្បីសម្ដែងថា ភវង្គចិត្តនោះ កាលបដិសន្ធិចិត្តប្រព្រឹត្តទៅ មិនធ្លាប់កើត ឡើងហើយនោះឯងដល់ព្រហ្ម ក្នុងសុទ្ធាវាសភូមិនោះក៏ពិត តែវិបាកចិត្ត ដែលមិនលាយឡំគ្នា រមែងប្រព្រឹត្តទៅអស់កាលដរាបណា ឈ្មោះថា មិន ធ្លាប់កើតឡើងអស់កាលដរាបនោះឯង ព្រហ្មទាំងនោះ កើតឡើងហើយ ដោយវិបាកចិត្តរបស់ឈានណា វិបាកចិត្តរបស់ឈាននោះ កាលកើតសូម្បី ១០០ ដងខ្លះ ១០០០ ដងខ្លះ ឈ្មោះថា បឋមចិត្តនោះឯង ( សំដៅដល់

*ភវង្គដែលកើតបន្ទាប់អំពីបដិសន្ធិចិត្ត )* ។

*ឯអាវជ្ជនចិត្តក្នុងភវនិកន្តិ ( ជវន ) មិនដូចគ្នាដោយវិបាកចិត្ត ( ព្រោះអាវជ្ជនចិត្ត ជាកិរិយាចិត្ត ) ឈ្មោះថា ទុតិយចិត្ត ។ គប្បីជ្រាបថា ពាក្យថា ទុតិយចិត្តនោះ លោកពោលសំដៅយកអាវជ្ជនចិត្តនោះ ។*

*បទថា* **បច្ឆិមចិត្តសមង្គីនំ** *បានដល់ ព្រះខីណាស្រព ដែលដល់ព្រមដោយចិត្ត ដែលមិនជាបច្ច័យដល់បដិសន្ធិ ដែលជាចិត្តដួងចុងក្រោយ នៃចិត្តទាំងពួង ។*

*បទថា* **អវិតក្កអវិចារានំ បច្ឆិមចិត្តំ** *នេះ លោកពោលហើយដោយអំណាចចុតិចិត្តដែលប្រកបដោយទុតិយជ្ឈាន របស់រូបាវចរបុគ្គល និងដោយអំណាចចុតិចិត្តដែលប្រកបដោយចតុត្ថជ្ឈានរបស់អរូបាវចរបុគ្គល ។ បទថា* **តេសំ** *បានដល់ បុគ្គលទាំងនោះ ដែលដល់ព្រមនៃបច្ឆិមចិត្តជាដើម ។ បទថា* **យស្ស កាយសង្ខារោ និរុជ្ឈតិ តស្ស ចិត្តសង្ខារោ និរុជ្ឈតិ** *នេះ លោកឲ្យពាក្យឆ្លើយទទួលថា* **អាមន្តា** *ព្រោះការរលត់ទៅក្នុងខណៈនីមួយៗ របស់កាយសង្ខារ ព្រមជាមួយចិត្តសង្ខារដោយពិតប្រាកដ មិនបានឆ្លើយទទួលព្រោះការរលត់នៃចិត្តសង្ខារ មួយអន្លើដោយកាយសង្ខារឡើយ ។*

*សួរថា ព្រោះហេតុអ្វី ឆ្លើយថា ចិត្តសង្ខារ សូម្បីវៀរចាកកាយសង្ខារ រមែងកើតឡើងផង រមែងរលត់ផង ឯកាយសង្ខារ មានចិត្តជាសមុដ្ឋាន ។*

*ខ្យល់អស្សាសៈ បស្សាសៈ និងរូប ដែលមានចិត្តជាសមុដ្ឋាន កើតឡើងហើយ ក្នុងឧប្បាទក្ខណៈនៃចិត្ត រមែងតាំងនៅស្មើនឹងចិត្ត ១៦ ដួង*

ដទៃទៀត កើតឡើង ។

ពាក្យថា រូបដែលមានចិត្តជាសមុដ្ឋាន រមែងរលត់ទៅព្រមជាមួយចិត្តដួងចុងក្រោយ ក្នុងចិត្ត ១៦ ដួងនោះ បានដល់ រូបដែលមានចិត្តជាសមុដ្ឋាន រមែងកើតឡើងព្រមជាមួយចិត្តដួងណា រមែងរលត់ទៅព្រមជាមួយចិត្តដួងទី ១៧ ចាប់ផ្តើមអំពីចិត្តនោះ រមែងមិនរលត់ទៅក្នុងឧប្បាទ ឬឋិតិក្ខណៈនៃចិត្តដួងណាមួយ និងរមែងមិនកើតឡើងក្នុងភង្គក្ខណៈ ។ លោកពោលថា **អាមន្តា** ព្រោះការរលត់ទៅក្នុងខណៈនីមួយៗ ព្រមគ្នានឹងចិត្តសង្ខារដោយពិតប្រាកដថា នេះជាធម្មតារបស់រូប ដែលមានចិត្តជាសមុដ្ឋាន ។

តែក្នុងអដ្ឋកថា សីហឡនៃវិភង្គប្បករណ៍ ពោលថា រូបដែលមានចិត្តជាសមុដ្ឋាន រមែងរលត់ទៅក្នុងឧប្បាទក្ខណៈនៃចិត្តដួងទី ១៧ ដូច្នេះ ពាក្យពោលនោះ រមែងខុសអំពីព្រះបាលីនេះ ។ លោកពោលហើយក្នុងព្រះបាលីថា បាលីនោះឯង មានកម្លាំងជាងអដ្ឋកថា គប្បីកាន់យកពាក្យនោះជាប្រមាណ ។

ក្នុងពាក្យសួរនេះថា **យស្ស កាយសង្ខារោ ឧប្បជ្ជតិ តស្ស វចីសង្ខារោ និរុជ្ឈតិ** ដូច្នេះ លោកធ្វើការបដិសេធថា **នោ** ព្រោះកាយសង្ខាររមែងកើតឡើងក្នុងឧប្បាទក្ខណៈនៃចិត្ត តែវិតក្ក វិចារ រមែងរលត់ទៅក្នុងខណៈនោះក៏មិនមែន ។ គប្បីជ្រាបវិនិច្ឆ័យក្នុងទីទាំងពួងដោយនយមុខនេះ ។

បរិញ្ញាវារៈ ប្រព្រឹត្តទៅ ដោយប្រក្រតីនោះឯង ។

**អដ្ឋកថាសង្ខារយមកៈ ចប់**

# ក្បាលទី ៧៣

# អភិធម្មបិដក បាលីប្រែ ~៨៧

## យមកៈ បឋមភាគ

## សន្ទឹកចង្អុលប្រាប់មាតិកា

មាតិកា លេខទំព័រ

### មូលយមកៈ


អភិធម្មបិដក ឧទ្ទេសវារៈ ...... ...... ...... ...... ...... ...... ២

អដ្ឋកថាឧទ្ទេសវារៈ ...... ...... ...... ...... ...... ...... ១១

អភិធម្មបិដក និទ្ទេសវារៈ ...... ...... ...... ...... ...... ...... ១៦

អដ្ឋកថានិទ្ទេសវារៈ ...... ...... ...... ...... ...... ...... ៣២


### ខន្ធយមកៈ


អភិធម្មបិដក ឧទ្ទេសវារៈ ...... ...... ...... ...... ...... ...... ៣៨

អដ្ឋកថាបណ្ណត្តិឧទ្ទេសវារៈ ...... ...... ...... ...... ...... ...... ៤៤

អភិធម្មបិដក និទ្ទេសវារៈ ...... ...... ...... ...... ...... ...... ៤៩

អដ្ឋកថាបណ្ណត្តិនិទ្ទេសវារៈ ...... ...... ...... ...... ...... ...... ៥១

បទសោធនវារៈ ...... ...... ...... ...... ...... ...... ៥១

អភិធម្មបិដក ...... ...... ...... ...... ...... ...... ៥៣

អដ្ឋកថាបទសោធនមូលចក្កវារៈ ... ...... ...... ...... ...... ៦០

អភិធម្មបិដក ...... ...... ...... ...... ...... ...... ៦១

អដ្ឋកថាសុទ្ធខន្ធវារៈ ...... ...... ...... ...... ...... ...... ៦៣

អភិធម្មបិដក ...... ...... ...... ...... ...... ...... ៦៥

អដ្ឋកថាសុទ្ធខន្ធមូលចក្កវារៈ ...... ...... ...... ...... ...... ...... ៧៣

អភិធម្មបិដក បវត្តិវារៈ ...... ...... ...... ...... ...... ...... ៧៤
អដ្ឋកថាបវត្តិវារៈ ...... ...... ...... ...... ...... ...... ១៣៤
អភិធម្មបិដក បរិញ្ញាវារៈ ...... ...... ...... ...... ...... ...... ១៥១
អដ្ឋកថាបរិញ្ញាវារៈ ...... ...... ...... ...... ...... ...... ១៥៥

### អាយតនយមកៈ

អភិធម្មបិដក បណ្ណត្តិវារៈ ...... ...... ...... ...... ...... ...... ១៥៩
អភិធម្មបិដក ឧទ្ទេសវារៈ ...... ...... ...... ...... ...... ...... ១៥៩
អភិធម្មបិដក និទ្ទេសវារៈ ...... ...... ...... ...... ...... ...... ១៦៤
អភិធម្មបិដក បវត្តិវារៈ ...... ...... ...... ...... ...... ...... ១៧៣
អភិធម្មបិដក បរិញ្ញាវារៈ ...... ...... ...... ...... ...... ...... ៤០២
អដ្ឋកថាអាយតនយមកៈ បណ្ណត្តិឧទ្ទេសវារៈ ..... ...... ...... ...... ៤០៦
បណ្ណត្តិនិទ្ទេសវារៈ ...... ...... ...... ...... ...... ...... ៤០៩
បវត្តិវារៈ ...... ...... ...... ...... ...... ...... ...... ...... ...... ៤១០

# បាលីប្រែ ~៨៨

# យមកៈ ទុតិយភាគ

### ធាតុយមកៈ

អភិធម្មបិដក បណ្ណត្តិវារៈ ...... ...... ...... ...... ...... ...... ៤១៨
អភិធម្មបិដក ឧទ្ទេសវារៈ ...... ...... ...... ...... ...... ...... ៤១៨
អភិធម្មបិដក និទ្ទេសវារៈ ...... ...... ...... ...... ...... ...... ៤២១
អភិធម្មបិដក បវត្តិវារៈ ...... ...... ...... ...... ...... ...... ៤២៨
អភិធម្មបិដក បរិញ្ញាវារៈ ...... ...... ...... ...... ...... ...... ៤៣០
អដ្ឋកថាធាតុយមកៈ ...... ...... ...... ...... ...... ...... ៤៣១

## សច្ចយមកៈ

អភិធម្មបិដក បណ្ណត្តិវារៈ ...... ...... ...... ...... ...... ...... ៤៣២
អភិធម្មបិដក ឧទ្ទេសវារៈ ...... ...... ...... ...... ...... ...... ៤៣២
អភិធម្មបិដក និទ្ទេសវារៈ ...... ...... ...... ...... ...... ...... ៤៣៥
អភិធម្មបិដក បវត្តិវារៈ ...... ...... ...... ...... ...... ...... ៤៤២
អភិធម្មបិដក បរិញ្ញាវារៈ ...... ...... ...... ...... ...... ...... ៥៤១
អដ្ឋកថាសច្ចយមកៈ បណ្ណត្តិវារៈ ...... ...... ...... ...... ...... ...... ៥៤៥
បវត្តិវារៈ ...... ...... ...... ...... ...... ...... ៥៤៦
បរិញ្ញាវារៈ ...... ...... ............ ...... ...... ...... ...... ...... ៥៤៩

## សង្ខារយមកៈ

អភិធម្មបិដក បណ្ណត្តិវារៈ ...... ...... ...... ...... ...... ...... ៥៥០
អភិធម្មបិដក ឧទ្ទេសវារៈ ...... ...... ...... ...... ...... ...... ៥៥០
អភិធម្មបិដក និទ្ទេសវារៈ ...... ...... ...... ...... ...... ...... ៥៥២
អភិធម្មបិដក បវត្តិវារៈ ...... ...... ...... ...... ...... ...... ៥៥៦
អភិធម្មបិដក បរិញ្ញាវារៈ ...... ...... ...... ...... ...... ...... ៦៤៥
អដ្ឋកថាសង្ខារយមកៈ បណ្ណត្តិវារៈ ...... ...... ...... ...... ...... ៦៤៦
បវត្តិវារៈ ...... ...... ...... ...... ...... ...... ...... ...... ...... ៦៥១